ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INST

ភទ្ធសរិយា

ៈស្សតាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែកក្កដា លេខ ៧

ព. ស. ២៤៩៤ — គ. ស. ១៩៥១

ផ្ទៃនដំណឹង

ជូនដំណឹងដល់អស់លោកអ្នកជាវ "ព្រះត្រៃបិដក"

ពុទ្ធសាសនបណ្ឌិត្យ សូមជូនដំណឹងដល់អស់លោក - អ្នក ជាវព្រះត្រៃបិដក ដែលសៀវភៅទៀត ៣៦ ទើបនឹងចេញពីពេជពុម្ព, ដូច្នេះ អស់លោក - អ្នកនៅក្នុងក្រុងដែលបានចុះឈ្មោះជាវ សូម អញ្ជើញចូលទៅមន្ទីរនោះ ដើម្បីទទួលយកសៀវភៅតាមឈ្មោះ ដោយយកបង្កាន់ដៃជាប់ទៅជាមួយផង ។

ចំណែកអស់លោក - អ្នកនៅខេត្តក្រៅដែលបានចុះឈ្មោះជាវ គង់នឹងបានទទួលសៀវភៅនោះ ក្នុងពេលឆាប់ៗ នេះ តាមរយៈ ផ្លូវសាលាខេត្ត ។

ឯអស់លោក - អ្នកដទៃទៀត ដែលមានបំណងចង់បានសៀវ-ភៅនោះ ក៏សូមអញ្ជើញទៅចុះឈ្មោះជាវយកនៅមន្ទីរពុទ្ធសាសន-បណ្ឌិត្យចុះ ។

សៀវភៅពីរក្បាល ៣៧ ទៅ កំពុងដំបោះពុម្ពតទៅទៀត ព្រម ទាំងរើបោះពុម្ពពីរក្បាល ១ - ២ ឡើងវិញផង ។



ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
ពុទ្ធសាស្ទានៃនគ្រឹស្តសាសនា (សន្ទនាសិទ្ធ លោកវេជ្ជបណ្ឌិតម៉ាក្ខូត៍) (តមក)	លោក ភ័យ - ប៊ុក	៤៧៣
ពន្ធអាស៊ីទ្វីប (តមក)	លោក ភ័យ - ប៊ុក	៤៧៩
អបាយមុខ	ព្រះគ្រូសិរីសោភ័ណ កែម - គួរ	៤៨៣
ផ្នែកអក្សរសាស្ត្រ		
ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៊ម	៥០៣
អឺឡេណា - សិមភ្ញ៉ាណា (តមក)	លោកផេង - ដ្រីវ	៥១៥
រឿងសាមកុក (តមក)	ឧកញ៉ា គួ - ពន	៥២៣
ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក)	ឧកញ៉ា ឈឹម - ក្រែសោម	៥៣៥
រឿងអារក្សថ្លែងរឿងម្តែ៣	លោក ស ង - សាភ័ត	៥៤២
កំណត់ទឹងប្រវត្តិការណ៍		
ដំណើរមកកាន់ប្រទេសកម្ពុជានៃមហាបណ្ឌិត គុណាឋាលបិយសេន ម៉ាល៉ាឡាសេកេរ៉	ពុទ្ធសាសនបណ្ឌិត្យ	៥៥១

មួយឆ្នាំមាន ១២ លេខ តំលៃ ១,៤៤,០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE — Pages

Bouddhisme et Christianisme (Conférence du Docteur A. Migot) (suite)	M. RAY-BUC	483
La Lumière de l'Asie (suite)	M. RAY-BUC	489
Apayamukha	PRAH-KROU-KEM-TO	497

PARTIE LITTERAIRE

Education morale (suite)	Prah Maha PEUNG-PAM .	507
Histoire d'Hélèna-Simiana (suit)	M. PHENG-CHRIEU	515
Histoire de SAMKOK (suite)	Oknha NOU-KAN	523
Histoire du Royaume du Cambodge (suite	Oknha CHHIM-KRASEM . . .	535
Les vingt-cinq récits du mauvais génie «Corte indien»	M. SANG-SAVAT	542

NOTES ET CHRONIQUES

Voyage au Cambodge du Dr. G. P. Malalasekera, Président du Centre Mondial des Bouddhistes de Ceylan	Institut Bouddhique.	550

Prix d'abonnement annuel comprenant 12 numéros: 145$00

ពុទ្ធសាសនា និង គ្រិស្តសាសនា

សន្និសិទលោកផ្លែបណ្ឌិតមីក្លូត

លោក ប៉ាយ-ប៊ុក គ្រូមការ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីទស្សនាវដ្តី "ហ្សង់អាស៊ី" ខែមិថុនា ឆ្នាំ ១៩៥០

(តមក)

ព្រះពុទ្ធសាសនានៅស៊ីឡង់ ឬកម្ពុជរដ្ឋមិនដូចព្រះពុទ្ធសាសនានៅប្រទេសជប៉ុន ឬទីបេត៍ទេ; ព្រះពុទ្ធសាសនានេះមានន័យខុសទៅតាមជាតិ តាមអាកាសធាតុ តាមស្ថានទីដែលពួកពុទ្ធសាសនិកជននោះបានស្ថិតនៅ តាមមជ្ឈដ្ឋានន៍ឆតាមកិច្ចត្រូវការខាងមិនបានខាងផ្លូវធ្វើជា ។ ហេតុដែលធ្វើឲ្យព្រះពុទ្ធសាសនាមានតម្លៃ គឺការចលនានៃព្រះពុទ្ធសាសនា, ការពិសោធន៍ខាងវិធីប្រតិបត្តិ ចំពោះពុទ្ធសាសនិកជនម្នាក់ៗ, ការព្យាយាមនៃពុទ្ធសាសនិកជន ទៅតាមមូលដ្ឋានន៍ឆគោលការណ៍ជាសាធារណ៍តែមួយដូចគ្នា អហេតុកធាតុសញ្ញាណចំពោះសាសនិកជនយ៉ាងណាក៏ដោយ សមតិនាមយ៉ាងណា ការសំខាន់បំផុតគឺការសម្រេចឲ្យដល់អហេតុកធាតុចំពោះខ្លួន ។ ឯង ។ ការដែលអប់រំព្រះពុទ្ធសាសនាទៅតាមគតិជាតិខាងអស់កន្លងពិភពលោក ជាហេតុធ្វើឲ្យព្រះពុទ្ធសាសនា

មានឥទ្ធិពលសម្បើមអស្ចារ្យ ។ ព្រហ្មញ្ញសាសនានឹងសាសនាអ៊ីស្លាម ច្រើនជាសាសនាពិសេស ; គ្រិស្តសាសនាបានរក្សាទុកនូវលោកវិជ្ជា បរមត្ថវិជ្ជា ឡាក់គោលខាងសាសនាស៊ុយដាអ៊ីក (judaïque) នឹងក្រិក (hellènique) ដែលពួកខាងបូពាប្រទេសមិនអាចយល់បានឡើយ ។ ព្រះពុទ្ធសាសនាមានសភាពស្រួលអាចយកទៅនិយមប្រើនៅប្រទេសក្រៅ ពីប្រទេសឥណ្ឌានឹងជប៉ុនបាន ; ព្រះពុទ្ធសាសនាអាចតម្រូវចិត្តទាំងជាតិទីបេត់ដែលនិយមប្រែមន្តអាគម នឹងជាតិអឺរុប ដែលនិយមប្រើទៅតាមវិចារណញ្ញាណលទ្ធិ ។ ដោយហេតុនេះហើយបានជាព្រះពុទ្ធសាសនា ជាសាសនាអាចប្រតិស្ឋានគាន់តែច្រើនឡើងនៅបច្ចុប្បន្នបាន ។ ហេតុខាងលើនេះ បង្ហាញឲ្យយើងឃើញជាក់ស្តែងនូវដីវ័នន៍ស្ថិរភាពនៃព្រះពុទ្ធសាសនា ក្នុងសម័យបច្ចុប្បន្ន ។ ចំណែកខាងពួកបេសកជនខាងគ្រិស្តសាសនា ពិតមែនតែប្រកបដោយព្យាយាមយ៉ាងម៉ឺងម៉ាត់ ព្រមទាំងមានថាមភាពយ៉ាងរឹងប៉ឹង ក៏មិនអាចនឹងញុំាងពួកប្រជាជនដែលកាន់ពុទ្ធសាសនា ឲ្យដើរជាក់ប្រព្រឹត្តប្រតិបត្តិតាមខ្លួនបានឡើយ ។

មានផ្នែកផ្សេងពីនេះទៀតដែលជាការគាន់ច្រឡំ ដូចយើងបានពោលខាងលើនេះ នាំឲ្យអ្នកទាំងពួងប្រមាថមើលងាយខ្លាំង គឺផ្នែកខាងសីលធម៌ ។ បើតាមអ្នកឯកទេសខាងបច្ចឹមប្រទេសខ្លះ យល់ថា

សីលធម៌ខាងព្រះពុទ្ធសាសនាមានសភាពខាងប្រាជ្ញាសុទ្ធ ប្រកបដោយ
អកម្ម, អចលនភាព ហើយទុត្តមគតិខាងព្រះពុទ្ធសាសនា គឺទុត្តមគតិ
ក្នុងការរួចចាកទុក្ខទាំងពួងប្រកបដោយអត្តទត្ថភាព (ចំពោះខ្លួនៗ ឯង) ។
គេអាចស្រាវជ្រាវរកបានតាមគម្ពីរកាសាបាលី, មានអត្ថបទជាច្រើន
បញ្ជាក់ឲ្យឃើញច្បាស់លាស់នូវយោបល់ខាងលើនេះ តែអត្ថបទទាំងនុ៎ះ
ជាសភាវៈពិសេស ហើយជាអនិច្ចតាភាពនៃព្រះពុទ្ធសាសនា ។ បើ
តាមពិនិត្យនូវខ្លឹមដ៏នៃអត្ថបទទាំងនោះ ឃើញថាជាអត្ថបទប្រកបដោយ
សីលធម៌ តែមានរូបភាពអាចយកទៅនិយមប្រើជាផ្លូវការនូវសាលារៀន
តែមិនសូវមានតុជាវេស ។ តាមសភាពផ្ទុយ, បើពិនិត្យឲ្យដឹងឆ្ងាយនៃ
វិជ្ជាខាងព្រះពុទ្ធសាសនា, បើគេចូលមកសេពគប់នឹងប្រជាពស្តុដែល
កាន់ព្រះពុទ្ធសាសនាម៉ឺងម៉ាត់ គេអាចឃើញដោយឆាប់ហ័សថា ទំយ
ព្រះពុទ្ធសាសនាខាងបច្ចឹមប្រទេស មានសភាពខុសគ្នាពីធម្មតាលោក
ហើយមិនត្រូវទៅតាមសច្ចធម៌ទេ ។

ឯកសារពីសម័យបុរាណ ដែលបានតំកល់ទុកចំពោះរឿងព្រះពុទ្ធ-
សាសនា មានសិលាចារឹកនៃព្រះបាទអសោក អធិរាជនៃប្រទេសឥណ្ឌា
សម័យបុរាណ ដែលសោយរាជសម្បត្តិពី ២៧៤ ទៅ ២៣៦ មុនគ្រិស្ត
សករាជ ។ ព្រះមហាក្សត្រិយ៍អង្គនេះទ្រង់ជាពុទ្ធសាសនូបត្ថម្ភក៍, ទ្រង់
បានចាត់ឲ្យយករឿងពុទ្ធសាសនាមកចារឹកទុក នៅផែនសិលានៅភូមិភាគ

ក្នុងព្រះពុទ្ធសាសនាក្នុងវេនសតវត្សក្រោយសង្គាយនា នៃធម្មិនីនិយាយ
ភាសាថ្មី ។ មានសិលាចារឹកមួយថ្លែងថា ច្បាប់នៃសាសនាមាន
សភាពវិសេស ; ច្បាប់នោះខ្ញុំនាំថា មិនត្រូវប្រព្រឹត្តបាបត្រូវបំពេញ
បុណ្យឲ្យច្រើន, ត្រូវធ្វើទាន, កាន់សុចរិត, ធ្វើជីវភាពឲ្យបរិសុទ្ធស្អាត ។
យើងខ្ញុំបានធ្វើទានជាអនេកប្បការ ដល់សត្វលោកទាំងអស់មានមនុស្ស
និងសត្វតិរច្ឆានជាច្រើនបែបច្រើនយ៉ាង ។ យើងខ្ញុំបានផ្សាយសេចក្តី
អនុគ្រោះដ៏ពន្ធឹក រហូតដល់ជួយឧបត្ថម្ភឲ្យសត្វទាំងអស់មានទឹកបរិភោគ
គ្រប់ៗគ្នា ; អ្នកណាបានធ្វើយ៉ាងនេះ ហៅថាបានបំពេញកុសល ។
គេច្រើនមើលឃើញតែត្រង់បុណ្យដែលខ្ញុំបានធ្វើ, គេមិនអាចឃើញ
នូវបាបដែលខ្ញុំប្រព្រឹត្តទេ ឬ គេមិនចង់ពោលពីបាបដែលគេធ្វើ, យើង
ខ្ញុំបានប្រព្រឹត្តនូវកម្មកាពដ៏លាមកខ្លះដែរ ។ ការដែលយើងខ្ញុំទទួល
ខ្ញុំខុសត្រង់ការប្រតិបត្តិជាការលំបាក, តែត្រូវត្រួតត្រាខ្ញុំដោយខ្ញុំ
ឯង ; ហើយពោលចំពោះខ្ញុំថា : មានអំពើខ្លះជាបាប ដូចជាមនស្ស-
ចិត្ត, សេចក្តីក្រោធ, ឥរិណកាពឬកាពកាច, មាន: (Orgueil) ត្រូវ
ពោលចំពោះខ្ញុំថា· ខ្ញុំមិនព្រមប្រព្រឹត្តលោភ (envie) នោះទេ ; ខ្ញុំមិន
ពោលពាក្យបំផ្លើស, បង្កាច់ (ផ្សុសាទ) ទេ ; ដោយការប្រព្រឹត្តបែប
នេះ ខ្ញុំអាចរក្សាសេចក្តីសុខក្នុងលោកនេះនឹងបរលោកបាន ។ តើជា

សីលធម៌មានសភាពជាអកម្មប្រកបដោយអចលនភាពឬ ? ត្រូវអ្នកយល់ថាអត្ថបទនោះមានពណ៌នាអំពីទានប្រកបដោយសកម្ម, ចិត្តល្អហើយនឹងចិត្តសន្តោស តាំងពីបឋមវត្ត មុនព្រះគ្រិស្តបដំសន្ធិ គឺមិនមែនលោកសង្ឃកំសត់ទេដែលមានពុទ្ធដីកានេះ គឺព្រះអធិរាជដ៏មានពលភាពអស្ចារ្យមានព្រះពាជនុង្ការនូវព្រះបន្ទូលសូរសីហនាទ ចំពោះអ្នកនៅក្រោមអំណាចព្រះអង្គ ។ នេះជាធម៌ដែលព្រះពុទ្ធសាសនា បានប្រាន្តប្រទេសឥណ្ឌាតាំងពីពីរសតវត្សមកហើយ ។

បើយើងបានអានគម្ពីរបាលី យើងនឹងឃើញនូវព្រះបរមពុទ្ធោវាទប្រកបដោយសីលធម៌ដូចគ្នានឹងសិក្ខាបទ ស៊ុយដាអ៊ីក (Décalogue judaïque) កុំសម្លាប់, កុំលួច. កុំពោលពាក្យកុហក, កុំប្រព្រឹត្តកន្ទួលកិរិយាអ្នកដទៃនឹងស្ត្រីដែលគេហួងហែងរក្សា (អព្រហ្មចរិយធម៌) ។ ល ។ តែក្រៅពីព្រះបរមពុទ្ធោវាទប្រកបដោយអវិជ្ជមាន (négatif) នេះ មានន័យពាសពេញក្នុងគម្ពីរនោះ ព្រះពុទ្ធោវាទដទៃទៀតប្រកបដោយសីលធម៌ដូចគ្នានឹងនៃព្រះគ្រិស្ត ។ តើវាចាវិសេសដែលព្រះសម្មាសម្ពុទ្ធទ្រង់ទេសនាមាននៅក្នុងគម្ពីរធម្មបទមិនស្មើនឹងនៃព្រះគ្រិស្តឬ ? ដូចជា "សេចក្តីស្អប់មិនអាចរម្ងាប់បានដោយសេចក្តីស្អប់, សេចក្តីស្អប់អាចរម្ងាប់បានដោយសេចក្តីស្រឡាញ់" ឬថា "ត្រូវប្រើចិត្តសន្តោសចំពោះអ្នកគ្មានសន្តោស, ប្រើចិត្តស្លូតចំពោះអ្នកកាច, ប្រើចិត្តទូលំទូលាយចំពោះ

មនុស្សលោក, ឲ្យបំបាត់សេចក្តីក្រោធខឹងដោយចិត្តមេត្តាល្អ, សេចក្តីអាក្រក់ដោយសេចក្តីល្អ, ពាក្យកុហកដោយពាក្យសច្ចៈ" ។ ពាក្យដូចពណ៌នាខាងក្រោមដែលច្រៀបលជកស្រង់ពីសៀវភៅ ហ្វីអូរេទី (fioretti) នៃលោកហ្វ្រង់ស្វាដាស៊ីស (François d'Assise) បើមានមនុស្សកាចធ្វើទុក្ខលំបាកដល់អ្នក ត្រូវកុំបណ្តោយឲ្យចិត្តខឹងមកគ្របសង្កត់បាន, កុំធ្វើចិត្តឲ្យឃ្លេងឃ្លោង, កុំឲ្យវាចាអសប្បុរសចេញពីបបូរមាត់ឲ្យសោះ, ចូរអ្នកតំកល់ចិត្តឲ្យល្អ, ចិត្តប្រកបដោយព្រហ្មវិហារផុតចាកសេចក្តីកំណាច ។ ចូរអ្នកផ្សាយចិត្តាប្រកបដោយមេត្តា, ច្បាស់ចាកសេចក្តីខឹង, ស្អប់" ។ នេះហើយជាសីលធម៌នៃព្រះពុទ្ធសាសនា ដែលគេបានចារឹកមកក្នុងគម្ពីរបាលី ជាសីលធម៌យ៉ាងជាន់អន់មិនសូវមានទុជ្ជារស ហើយច្រើនគេយកទៅនិយមអនុវត្តន៍តាមសាលារៀន ។

(មានត)

វគ្គទី ៦

La Lumière de l'Asie

លោក ស៊ីរ - អេតវ៉ាន អាណូលត៍ តែង

លោករ៉ាយ - ប៊ុក ក្រមការ ប្រែរៀបរៀង

(ភាគ)

គ្មានបុគ្គលណាអាចលះបង់នូវកាមច្ឆន្ទៈ ប្រកបដោយសេចក្តីព្រួយលំបាកប្លុកប្លែកដែលទៅពួនសម្ងំខាងក្នុងបញ្ចេញមកក្រៅ ជាសភាពគួរឱ្យតក់ស្លុតយ៉ាងនេះ បើបុគ្គលនោះមិនទាន់បានវិជ្ជាដែលពន្យល់ឲ្យដឹងនូវឧបស័គ្គផ្សេង ៗ ដែលកំពុងមិនឲ្យឃើញធម៌; តែបើអ្នកណាស្គាល់ច្បាស់នូវវិជ្ជាសភាពគ្រប់គ្រង អ្នកនោះអាចចៀសវាងនូវឧបស័គ្គនោះបាន, លែងពេញចិត្តខាងការស្នេហានូវដីវភាព តែខំព្យាយាមចាកចេញពីដីវភាពនេះបាន ។ បញ្ញាចក្ខុអ្នកនោះបានយល់ច្បាស់ឃើញជាក់ក្នុងចិត្តថា អវិជ្ជាជាបច្ច័យនាំឲ្យកើតសង្ខារ (ពាលទុច្ចរិត) ហើយនឹងវិញ្ញាណ (ថាមភាព, énergie) ដែលនាំឲ្យកើតនាមរូប (ទម្រង់បុគ្គលិកលក្ខណៈ, forme individuelle) បុគ្គលិកលក្ខណៈ (personnalité) សំបករូប (enveloppe corporelle) ដែលធ្វើឲ្យបុគ្គលបណ្តាយវេទនាឲ្យធ្វើតាមទំនើងចិត្ត ឥតអ្វីមកការពារបាន, កញ្ចក់ដែលធ្វើឲ្យឃើញក្នុងហាយវត្ថុនូវអារម្មណ៍ដែលមិនពិត, នេះហើយ ហេតុដែលឲ្យចំរើនមានវ័យវឌ្ឍនាការឡើងនូវវេទនា (ជីវភាព

នៃអារម្មណ៍) (la vie de sens)- ត្រូវទាំងសេចក្តីសប្បាយដែលខុសចាកគន្ធធម៌ទឹងទុក្ខលំបាក, តែវេទនានោះ បើទុកជាគោមនស្សប្តូរសោមនស្ស ជាហេតុឲ្យកើតតណ្ហា (désir) គឺការស្រែកឃ្លានដែលនាំឲ្យអ្នករស់នៅក្នុងកពអណ្តែតត្រសែតលើគង្គា ត្រេបផឹកនូវលេកដែលមានរស់ជាតិប្រៃ ហើយមានសភាពចេះប្រែកិច្ចកលផ្សេងៗ គឺសាមិសសុខ (plaisir), មហិច្ឆតា (ambitions), កោតទ្រព្យ (richesse). កិត្តិគុណ (Gloire), កិត្តិស័ព្ទ (renommée), វំលោក (domination), លទ្ធិកម្មដោយអាវុធ (Conquête), សេចក្តីស្នេហាទឹងកោដនាហារ ដែលមានតុជារស, ត្រឡឹងសំលៀកបំពាក់ល្អឆើត, ត្រេះបរមភជាំងសម្បើមអស្ចារ្យ, មាន: (orgueil) ពីកំណើត, កាមច្ឆន្ទៈ (concupicence), ការសង្គ្រាមដើម្បីជីវិត ហើយទឹងផលដែលបានពីការសង្គ្រាមនោះ ខ្លះផ្អែមខ្លះល្វីង ។ ត្រោះហេតុដូចនេះ សេចក្តីស្រែកនៃជីវភាព នាំឲ្យត្រេបផឹកនូវទឹកស្រវឹងដែលនាំសត្វឲ្យកាន់តែស្រែកឡើងថែមទៀត; តែបណ្តិតបានដឹកនាំលើងន្លូវឫសនៃតណ្ហាចេញចាកសន្តាន ហើយលែងបំប៉ននាហារ គឺអារម្មណ៍ដែលបញ្ចេញនូវស្រមោលផ្សេងៗ នាំឲ្យចិត្តភ័ន្តច្រឡំនោះ ។ បណ្តិតទម្លាប់ចិត្តរបស់លោកឲ្យនៅទឹង ឥតកម្រើក, លែងស្វែងរក, លែងតស៊ូ, លែងបំផ្លាញអ្នកដទៃ, លោកទទួលដោយហាសនចិត្តនូវបាបអកុសលដែលលោកបានត្រឡប់ពីអតីតជាតិមក, លោកអាចសម្លាប់នូវ

តណ្ហានេះឯង, ព្រោះហេតុដូចនេះ ការប្រមូលខ្យល់ដីវាតទាំងអស់, កម្ម (karma), ការប្រមូលអាត្មន្តដែលមានកម្មិកភាពនឹងចិត្តាអតីតៈ ជាសមាសភាព, អាត្មន្តដែលលោកបានយកកាលព្រមទាំងកិច្ចការមើលមិនឃើញមកគ្រងវេញជាមួយហើយតា្បញឲ្យដឹតស្ទុះយូរមកហើយ ត្រឡប់ទៅជាមានលទ្ធផលចំពោះលោកជាតុ ប្រែសភាពជាបរិសុទ្ធហើយផុតចាកអកុសលកម្មទាំងអស់ ។ ម្ល៉ោះហើយ, បណ្ឌិតមិនត្រូវការនឹងស្វែងរករូបបដិសន្ធិជាថ្មីទៀត នឹងភព ឬជាត្រូវបន្ទាបម្រង់ជាថ្មីក៏ដីវាតនោះ ហើយក៏ប្រព្រឹត្តខ្យល់ធម៌ដែលនាំឲ្យខ្ពុកនោះ កាន់តែស្តើងស្លួចចុះទៅតាមលំដាប់ លុះត្រាតែបានផុតរលត់ដល់អវសាន, ហើយលោកក៏បានធ្វើដំណើរទៅដល់ចុងផ្លូវ (មគ្គសច្ច). លោកក៏ផុតស្រឡះពីសេចក្តីកង្ខ្ចែងឡំដែលមានតាសពេញលើផែនដី ព្រមទាំងស្កន្ធ[1] (ខន្ធ) ទាំងអស់នឹងកាទិកិលេស, លោកបានកាច់បំបាក់នូវចំណងមានតើឧបាទាន, លោកលែងវិលទៅតាមលំនាំនៃកង់លោក, លោកក្បាក់ពីនិទ្រាហើយគ្រោកជីងខ្លួនសប្បាយរីករាយក្នុងចិត្ត ដូចមនុស្សដែលគេឲ្យទុសច្រែបធឹកចាត់លែងរើរៃយ ។ រូបមានសភាពឧត្តមជាងមហាក្សត្រិយ៍ សុខស្រួល

---

១ ស្កន្ធ ឬ ខន្ធ គឺ ពន្ធវត្ថុជាតុដែលប្រជុំលើកើតជាបុគ្គល (individu) មាន៥ប្រភេទ ទី១ គុណភាពខាងសម្ភារៈ (វិសាលភាព, សភាពរឹង ពណ៌); ទី ២ វេទនាមណ៌; ទី ៣ វិបារ (perception) ការសំគាល់ (jugements); ទី ៤ អាកប្បកិរិយានៃសីលធម៌ទំនងចិត្ត; ទី៥ ចិត្តា ឬ ញាណ ។ ឯខន្ធវត្ថុជាគុណាមួយជាធាតុស្ថិតថេរខ្លោកាលឡើយ គឺជាវត្ថុមិនទៀងទាំងអស់ ។

ជាង ព្រះព្រហ្ម ព្រះឥន្ទ្រនិងទេវតា, លោកក៏ចាន់ទៅដល់អវសានជាតិផុត
ពីសេចក្តី ទុក្ខនៃជីវភាព ហើយទៅដួចនឹងជីវភាពបែបថ្មីដែលមិនមែន
ជាជីវិតកង់លោក, កង់លើកដំបូង ពេលនោះគឺសេចក្តីស្ងប់ជាអស្ចារ្យ
សេចក្តីសុខជានិរាមិសសុខគឺនិព្វាណ (ព្រះនិព្វាន) ជាទីគោរព ជាទី
ឈប់សម្រាកគ្មានចាប់អកុសល គ្មានកង្វល់រវល់ ជាញាណប្រែប្រួល
តែមិនអាចប្រែភាពទៅជាអ្វីខ្សោយ ។

កង់មួយរំពេចនោះ បុព្វណ្ហសម័យក៏បញ្ចេញរស្មីភ្លឺត្រចះត្រចង់
បញ្ជាក់ឲ្យឃើញនូវជោគជ័យព្រះសម្មាសម្ពុទ្ធ, រស្មីជាបឋមនៃព្រះអរុណ
ចាំងចែងពីទិសបូព៌ា ចូលទៅជ្រែកចំលុះនៃផ្ទាំងខ្មៅងងឹតនៃនិសា (Nuit) ។
នៅលើមេឃ, ផ្កាយព្រឹកចាន់បញ្ចាំងអាកា មានពណ៌សដូចប្រាក់ រួច
ចាត់ពីទីនោះទៅ ហើយមានរស្មីពណ៌កុឡាបស្រស់ភ្លឺពាសពេញកា-
ល័យចោលមក ឆ្លុតពីលើអដ្ឋជាកាសមានពណ៌ប្រផេះ ។ នៅឆ្ងាយ,
មានគីរីដែលមានស្រមោលរុំពីខ្នងដុំវិញ ហើយមានពពកមានពណ៌ក្រហម
ផ្លេអណ្តែតពីលើដូចជាគេពាក់មកុដ មានគេទៅឃើញព្រះសុរិយាមុននឹង
ពិភពលោកភ្ញាក់ពីនិទ្រា ។ វាយោភ្លើលូមនៃសាយណ្ហសម័យផាយ
ផាត់តាមបុប្ផា ហើយធ្វើឲ្យស្រទាប់បុប្ផាទាំងនោះបើករីកពាសពេញ
ប្រថពិ ។ អាកាត្រាច់ដើរលឿនហើយប៉ះពាល់ដល់តំណាជាតិដែល
មានទឹកសន្សើមដឹតជាមដុំវិញ ហើយដល់ព្រះអរុណនេះឡើងទឹកសន្សើម

នោះទៅជាគ្រឿងអលង្ការដ៏ប្រសើរអស្ចារ្យគួរឲ្យពេចពិលរមិលមើល, ធ្វើឲ្យប្រថពីតាំងមូលក្តីចាំងចែងអស្ចារ្យ, រចនារមៃពពកដែលមានសភាពភ្លៅ ចោកផាត់ដោយខ្យល់ព្យុះសង្ឃរា ហើយបាត់ទៅឲ្យមានរំយោលជារជាយប្រកបដោយសុវណ្ណព៌ណ, តាំងស្តឹកកំពូលនៃតាលព្រឹក្សឲ្យមានព៌ណក្រហមដូចមាស ហើយស្តឹកនោះគោរទន់ដោយព្រះពាយផាយផាត់ដូចជាគេធ្វើតារវគាត, ធ្វើឲ្យពែរចោះឲ្យមានព៌ណក្រហមស្រស់ហើយធ្លាក់ទៅដល់ទឹកក្នុងស្តឹង ដូចជាគេគោះចង្កើះទិព្វនៃទេពធីតាទៅលើទឹកនោះ ប្រែទៅជាមានព៌ណក្រហមទទឹម ភ្នំពលជាលពាសពេញ ចុះទៅត្រង់គុម្ពោតវែនប្បទេសទៅចំក្បែកស្តូតនៃប្រឹស ដែលដេកស្ងៀមនៅទីនោះ ។ អាកានោះពោលថា: "ថ្ងៃរះហើយ" ប៉ះពាល់ដល់សំបុកដែលមានកូនបក្សាដេកលក់ចាំងក្រោមស្លាបហើយឱ្យបថា: ' នែអ្នកនាង, ចូរមើលពន្លឺព្រះអរុណ" ។ រួចបក្សាតាំងអស់ក៏បញ្ចេញសូរស័ព្ទអឺងកងរំពង ។ មានចំរៀងបក្សា កូអ៊ីអូល (Koil) ដូចគេផ្ងុំខ្ទុយ, ខំនុកនៃសត្វគូកថា "ត្រឹក, ត្រឹក", អាអូតមានស្លាបរំលេចព៌ណាជាច្រើនបែបដូចគំនូរ, សូរសៀងបក្សាចង្រៃរួចហើរលើអាកាសទៅស្វែងរកទឹកយ៉ាំមុននឹងមកចេញពីសំបុកវា, សំឡេងកាកាឡេងងឹត, សូរដូចកញ្ជែនៃសត្វសេក, សូរបក្សាត្រសេះខៀវស្រែងាត់ចោះរុក្ខា, សំឡេងសារិកាកែវ, សំពួលលកគ្រាំងមើកបខ្មេស្មោគូវ ។ ផលដែលបានមកកង

ឬព្វណ្ហសម័យដែលបញ្ចេញអានុភាពជាអស្ចារ្យ ជាមួយនឹងជោគជ័យនៃ
ព្រះសម្មាសម្ពុទ្ធ បណ្តាលឲ្យតាមកូមិដ៏តឆ្ងាយក្នុងលោកសន្និវាសនេះ
មានសន្តិសុខចូលទៅស្ថិតគ្រប់គេហដ្ឋានមនុស្សគ្រាំងអស់ ។ បើកាលណា
ក្រែឡេកទៅយល់សាយណ្ហសម័យបញ្ចេញរស្មីស្រទន់ពាសពេញផែនដី,
នាយពេដ្យឃាតលាក់កាំបិត, ពួកចោរចុះបង់ចោលខ្លួរកោតទ្រព្យ. ពួក
សារហ្វ Sharaff)(១) ក៏ពាក់ប្រាក់ឲ្យត្រឹមត្រូវ ; អ្នកណាដែលមានចិត្ត
កាចពាលត្រឡប់ជាស្លូតល្អទៅវិញ, អ្នកណាដែលល្អប្រែជាវិសេស
ថ្លៃថ្លា ។ មហាក្សត្រិយ៍ដែលធ្វើសង្គ្រាមបង្ហូរឈាមសន្ធឹកសន្ធាប់, ពួកអាពាធក្រោក
ឡើងសើចសប្បាយលើគ្រែដម្បឺ. អ្នកដែលឯកមរណភាពញញឹម ដូច
ជាធ្លាប់បានដឹងថាបច្ចុសសម័យនេះបញ្ចេញពីប្រកព ដែលឆ្ងាយលន់លឺម
លន់លោចពីដើងមេឃឯទិសបូពា ។ ហើយក្នុងពេលនោះ ព្រះទ័យ
ព្រះនាងយសោធរាដែលវង់ទុក្ខលំបាកគង់នៅលើគ្រឡាព្រះបន្ទូលព្រះអង្គ
ម្ចាស់សិទ្ធត្ថ ស្រាប់តែមានរស្មីជាសញ្ញាសពេញចេញកំសួលសុខស្រួល
សប្បាយក្នុងមួយរំពេច ហើយព្រះនាងស្មានក្នុងព្រះទ័យថា សេចក្តី
ស្នេហារបស់ព្រះនាងចំពោះព្រះអង្គ មិនមែនធ្វើឲ្យព្រះនាងកន្តគំនិត
ហើយសេចក្តីទុក្ខរបស់ព្រះនាងនឹងអស់ត្រឹមពេលនេះ ប្រែទៅជាសុខដ៏
ធំទូលាយទៅវិញ ។ ចំណែកខាងពិភពលោកទៅជាសប្បាយ; ដោយ

---

(១) សារហ្វ; ធនាគារ, អ្នកផ្លូវច្រើក ។

មើលហេតុនោះពុំឃើញ ហើយនៅពីលើវាលខ្សាច់រហោស្ថាន ដែលជាទីស្មសាន គេបានឮសំឡេងសូរចំរៀងពួកប្រែត[1] នឹងពួកបុត្រៈ (ប្រែហៀលជាបិសាច) គ្មានកាយ ដែលបានដឹងនូវដៅគជ័យនៃព្រះសម្មាសម្ពុទ្ធ; ហើយពួកទេវៈស្រែកឮកណ្តាលនភាល័យៈ "អស់ហើយ, អស់ហើយ" ។ ព្រះកិកុសន្ធគង់ឈរតាមវីថីជាមួយនឹងប្រជាពស្ត្រ ដោយធ្ងឹងធ្ងល់, ក្រឡេកមើលទៅអាកាសមានពណ៌ដូចមាស ដែលផ្សព្វផ្សាយពេញមហាមេឃហើយពោលថាៈ "ប្រហែលមានព្រឹត្តិការណ៍អ្វីប្លែកអស្ចារ្យ!" ។ ហើយនៅកន្លែង[2] នឹងអញ្ជាប្រទេស ពួកសត្វលោកសំដែងនូវមិត្តភាពទៅវិញទៅមក; រមាំងមានកាយពណ៌ពាលបរិភោគស្មៅដោយសុខនៅជិតខ្លាញីដែលកំពុងបំបៅកូន, សត្វខ្លារខិនអាស្រ័យទឹកជិតឈ្លូស, សត្វទន្សាយពណ៌ប្រផេះ រត់នៅក្រោមថ្មសិលាដែលបក្សាអកកំពុងយកចំពុះសៀតស្លាបវាលេងកំសាន្ត ។ ពស់ដេកហាលថ្ងៃ មានកាយពណ៌ឆ្តងរៀនហើយបញ្ចូលចង្កឹមពស់ទៅក្នុងមាត់វិញ ។ បក្សាខ្វែងបណ្តាយឲ្យសត្វចាបចៀបកប្បាស (Pinson) ធ្លាប់សំបុក, ត្រចៀកកាំសមុទ្រ (alcyons) ពណ៌នីលដេកយល់សប្តិចំឡែក, ចំណែកឯមច្ឆាជាតិហែលសប្បាយឥតមានភ័យនៅជិត; បក្សាមេរុប (Mérops) (ប្រហែលជាប្រចៀវ) នៅស្ងៀមពិតមែនតែមេអំបៅមានពណ៌ក្រហមផ្លេ ខៀវ ផ្ទៃមេឃ ប្រឡឹង ប្រផេះ

---

១ ប្រែតៈ ព្រលឹងអត្មាខន្ធសត្វ ដែលធ្វើមរណភាពទៅហើយ ។ ២ រង់ (Ran) ភាសាស្មើ

ហិចហើរដាហ្វូងនៅដុំវិញខ្ទេំក់, ដោយហេតុនេះហើយព្រះទ័យព្រះសម្មាសម្ពុទ្ធបានផ្សាយចំពោះមនុស្សលោក, បក្សាទាំងអស់, សត្វតិរច្ឆាន, តែចំណែកព្រះអង្គកំពុងពិចារណានៅក្រោមម្លប់ពោធិព្រឹក្សដម្កល់នៅក្នុងការដោតជ័យ ការដែលព្រះអង្គឈ្នះតិលេសមារ ដើម្បីមនុស្សទាំងអស់ ហើយព្រះប្រាជ្ញាកំពុងមានវស្សីភ្លឺស្វាងរុងរឿងដូចថ្ងៃ ។

ក្នុងអវសាន, ព្រះអង្គមានហសិតុប្បាទចិត្តប្រកបដោយទសពលញ្ញាណ, ទ្រង់តើនឡើងចេញចាកអដ្ឋបាលនិគ្រោធហើយបន្ទឹព្រះសូរសីហនាទជាប្រថមវ៉ាចា ដែលអ្នកទាំងអស់ក្នុងសាកលលោកធ្លាប់បានឮគ្រប់កាលថា :

« អញបានស្ថិតនៅក្នុងគេហដ្ឋានជាច្រើនដ៏វែកាព, ស្វែងរកបុគ្គលណាដែលសង់ពន្ធនាគារដែលប្រកបដោយផស្សារម្មណ៍ ជាហេតុឲ្យកើតទុក្ខ ហើយអញបានតស៊ូជានិន្តរកាល, លំបាកព្រួយពីមុនមក ។ តែឥឡូវនេះ, ឯងដែលជាអ្នកស្ថាបនិកនៃខន្ធនេះអញស្គាល់ច្បាស់ហើយ, តទៅអនាគត ឯងលែងស្ថាបនាខ្ទមកំពែងនេះដែលពេញទៅដោយទុក្ខ, ឯងលែងសង់មេដំបូលនៃទុច្ចាយកលទុច្ចរិត ហើយឯងលែងជាក់ផ្ទោងថ្មលើដីឥដ្ឋនេះហើយ, គេហដ្ឋានឯងវិនាសហើយ, ឯផ្ទានគឺអវិជ្ជាស្ថាបនិកនៃគេហដ្ឋាននោះបាក់បែកអស់ហើយ ។ តាំងពីថ្ងៃនេះតទៅ, អញនឹងត្រេចប្រាសសត្វ ឲ្យរួចពីកណ្តាប់ដៃឯង !" ។

(មានត)

អធ្យាយមុខ

ព្រះត្រៃសរីសោភ័ណ កឹម - ត្ថរ ក្រុមជំនុំព្រះត្រៃបិដក

ទេសនាជាកវិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា

កាលពីថ្ងៃ ៨ កើតខែកត្តិក ឆ្នាំកុរឯស័ក ព. ស. ២៤៩០

(២០-១១-៤៦)

ឧបត្ថរតនត្តយស្ស

សូមនមស្សការថ្វាយបង្គំ ចំពោះព្រះរតនត្រ័យ គឺ:

ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ ដោយសេចក្តីគោរព ។

លំដាប់អំពីបទនមស្សការនេះទៅ, អាត្មាភាពសូមសំដែងអំពីអធ្យាយមុខ ៦ យ៉ាង ដែលសម្តេចព្រះសព្វញ្ញាពុទ្ធទ្រង់ទេសនាប្រារព្ធចំពោះសិង្គាលមាណព ក្នុងគម្ពីរទីឃនិកាយ ត្រង់សិង្គាលោវាទសូត្រ ដូចសេចក្តីតទៅនេះ :

អធ្យាយមុខ ប្រែថា: "ហេតុជាប្រធាននៃសេចក្តីវិនាស" ។ អ្នកដែលបានប្រព្រឹត្តអធ្យាយមុខនេះ នឹងជួបសេចក្តីវិនាសឃើញៗ ទាន់ហន់ក្នុងលោកនេះ ។ អធ្យាយមុខនោះមាន ៦ យ៉ាង គឺ:

១ – ការផឹកទឹកស្រវឹងគឺសុរាឆ្អឹងមេរ័យ – សុរាឆ្អឹងមេរ័យនេះ ជាទឹកសម្រាប់បំពុល ឬ សម្រាប់បង្វិលចិត្តមនុស្សឲ្យខុសប្រក្រតី ។ មនុស្សអ្នកគ្រែបលេបទឹកស្រវឹងចូលទៅហើយ, ទឹកនេះអាចកំដៅហាយ:

គឺបេះដូងឲ្យញាប់ញ័រ ច្រើនតែបណ្តាលឲ្យកើតសេចក្តីក្តៅហាន ត្រហើន-
កោងកាចប្រមាថមើលងាយអ្នកដទៃ, អំពើខុសយល់ថាជាត្រូវ, អំពើ
ត្រូវយល់ថាជាខុសវិញ ។ មនុស្សខ្លះបើមិនទាន់ត្រូវសុភចូលទៅដល់
ទេ តែងមានឫកពាសុភាពរាបសា ដឹងខុសត្រូវគួរសម, តែវេលា
ណាត្រូវសុភហើយ អំណាចសុភនេះបង្វិលចិត្តឲ្យខុសប្រក្រតីមួយរំពេច
គឺបញ្ចេញអាការៈថោកទាបដោយផ្លូវកាយនឹងវាចា, ទៅជាមនុស្សច្រេះ
ច្រងាំឯទៀតទៅ ក្បាលញាក់ញញ័រ ចាំងសំដីសោតទៀតក៏និយាយ
ជ្រុលជ្រែលៗ មិនទៅមុខ ចេញលំនាំប្រហែលគ្នានឹងមនុស្សឆ្កួត ។ មនុស្ស
ប្រមឹកញៀនសុភនេះ រមែងទទួលរងទុក្ខទោសគ្រោះថ្នាក់ ៦ យ៉ាង អាច
យើញជាក់ច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្នជាតិនេះគឺ :

ក) អ្នកប្រមឹកសុភ តែងចាយវាយទ្រព្យសម្បត្តិតិញ្ជះតិញ្ជាយ,
យកទៅទិញដូរសុភខ្លះ សាច់ខ្លះ ឬរបស់អ្វីឯទៀតខ្លះ សម្រាប់ក្លែមជា-
មួយនឹងសុភ; អ្នកខ្លះថាស៊ីផឹកតែម្នាក់ឯងមិនសូវធ្ងាញ់មិនសូវសប្បាយទេ,
លុះតែមានគ្នាទើបហឺហាសប្បាយ, ម្ល៉ោះហើយក៏ហៅរកបបួលមនុស្ស
ណាដែលមានចរិយាថោកទាបដូចខ្លួនដែរមកស៊ីផឹកជាមួយ ។ អ្នកប្រមឹក
សុភបែបនេះ គ្មានពេលនឹកាសនឹងធ្វើការងើបឡើងរកទ្រព្យសម្បត្តិទេ, មាន
តែផ្លូវចាយវាយបំផ្លេចបំផ្លាញតែម្យ៉ាង, កាលបើប្រាក់កាសសម្រាប់ចាយ
ធម្មតាមិនគ្រប់គ្រាន់ទេ, ក៏តោងលក់ផ្តាច់ប្តូរបញ្ចាំក្រែមតិក មានផ្ទះ

សម្បែងដ៏ស្រែចំការច្បារដំណាំជាដើម ដកបទាល់តែអស់រលីង, កំតាំង សំកុកកើតទុក្ខមុខស្លូតអស់ទាំងគ្រួសារ ធ្លាក់ខ្លួនទៅជាមនុស្សអនាថាឥតតើពឹង ក្រអួមរហាម ក្លាយទៅជាចោរលួចចោរប្លន់ក៏មាន ។

ខ) អ្នកប្រមឹកសុរា ពេលណាស្រវឹងស៊ប់ហើយ ក៏តាំងបង្កហេតុរករឿងឈ្លោះជេរប្រទេចប្រពន្ធកូនឯង; បើរករឿងប្រពន្ធកូនរបស់ខ្លួនមិនបានទេ, ក៏បែរទៅរករឿងឈ្លោះនឹងរបស់ប្រើប្រាស់ មានពាងចានឆ្នាំងជាដើម ហាយសំពងខ្ទេចខ្ទីបែកបាក់អស់ក៏មាន, បើមិនដូច្នោះទេ, បង្កហេតុរករឿងអ្នកផងជិតខាង គេអត់មិនបានក៏កើតទៅជាដេរតបតវាយដំគាប់ចាក់គ្នាទៅវិញទៅមក ជាប់គុកច្រវាក់បន់ឲ្យថែមទៀតក៏មាន ។

គ) អ្នកប្រមឹកសុរា ឈ្មោះថាជាអ្នកបង្កភេគផ្សេង ឲ្យកើតចំរើនទៅក្នុងពងកាយរបស់ខ្លួន មានភេគងងឹតក្អែក ខូចក្រពះពោះវៀន ខូចស្លូតជាដើម ធាប់ចាស់ជរាអាយុខ្លី ដោយអំណាចសុរាក៏មាន ។

ឃ) អ្នកប្រមឹកសុរា មានកិត្តិសព្ទកេរ្តិ៍ឈ្មោះមិនល្អ ជាទីខ្ពើមរអើមរបស់ពួកសប្បុរស, ទាំងសំដីនិយាយកិច្ចការអ្វីសោតទៀត គេក៏មិនសូវជឿស្តាប់មិនយកជាប្រមាណ, បើទុកជាមានកូនតំណែរក្រមុំច្រើនចាំង គេក៏មិនត្រូវការ ថែមទាំងគេដៀលថា "ពូជប្រមឹកសុរាកុំបួលទៅដិត, នាំឲ្យសៅហ្មងដល់ពូជឆ្ងាត់កូលរបស់យើង" យ៉ាងនេះក៏មាន ។

ង) អ្នកប្រមឹកសុរា រៀលស្រវឹងស៊ប់ហើយ ឥតមានសេចក្តីអៀនខ្មាសទេ, អវយវៈដែលគេត្រូវលាក់បិទបាំង ខ្លួនឯងទៅជាសើយលាត់

បញ្ចេញអាការកិរិយាឲ្យគេឃើញជាក់ស្តែង, ដូនកាលដើរស្រែករឭកឭ
ប៉ាច់ប៉ោចតាមផ្លូវដូចឆ្កួត សំដែងអាការថោកទាបក៏មាន, ខ្លះស្រាំង
ក្តួតដួលដេកស្តឹងស្កូកហាក់ដូចស្លាប់ តាមចន្លោះផ្លូវ ឬសំយាបផ្លូវគេ
ក៏មាន, មិនតែប៉ុណ្ណោះ ចិត្តធំព្រហើនហ៊ានកាប់សម្លាប់ឥតកោតញញើត
យ៉ាងនេះក៏មាន ។

ច) អ្នកប្រមឹកសុភ ឈ្មោះថាជាអ្នកធ្វើចំណេះវិជ្ជាព្រមទាំងប្រាជ្ញា
ស្មារតីឲ្យអន់ថយខ្សោយចុះទៅជាដរាប, ដើន្បីងគិតការអ្វីឬធ្វើការអ្វី ត្រូវ
ធ្វើប្រមុយទៅទាំងកំពេលឥតដឹងខុសត្រូវ ។

អ្នកប្រមឹកសុភមិនមែនធ្វើឲ្យថោកតែមតែខ្លួន ១ ឬគ្រួសាររបស់ខ្លួន ១
ទេ, ឬានឈ្មោះថាធ្វើជាតិនឹងប្រទេសឲ្យថោកថែមទៀត ។ ហេតុនេះ,
អស់លោកអ្នកកាន់អំណាច គួរតែផ្តាញ់ផ្តាលបំបាត់សភាពប្រមឹកថែបនេះ
ក្នុងស្រុកនីមួយៗកុំឲ្យមាន ទើបនឹងមានសេចក្តីចំរើន ។

សេចក្តីដែលបានពណ៌នាមកនេះឈ្មោះថា អបាយមុខទី ១ ។

២ – ការដើរលេងក្នុងវេលាយប់ខុសកាល – ពេលដែល
គេត្រូវសម្រាកសម្រាន្តពួន ខ្លួនដើរលេងដជ្រុលមកតាមច្រកល្អក់ផ្លូវគួប
ធំហួសពេលវេលា ចោលប្រពន្ធកូនឲ្យសម្លឹងទៅឯផ្ទះ ឥតមាន
អ្នកណាគ្រប់គ្រងរក្សា ឈ្មោះថាបើកឱកាសឲ្យដល់សត្រូវគឺចោរប្រមាថ
មើលងាយដល់ឲ្យសម្លឹងក៏មាន, ដូនកាលខ្លួនឯងដើរលេងទៅក៏ត្រូវ

ទទួលគ្រោះថ្នាក់ មានឥស្សរជាំទិចជាដើមក៏មាន, ពុំនោះសោត មានអ្នកផងគេរង្កៀសសង្ស័យថា អ្នកនេះមែនដើរពេលយប់ ប្រហែលជាអ្នករកស៊ីដោយផ្លូវខុសច្បាប់ទេដឹង ?, ជួនកាលមានចោរលួចធ្វើឲ្យសម្បត្តិរបស់គេពិតហើយ ក៏រៀសគេចខ្លួនបាត់ទៅ, ទទួលគេឃើញខ្លួនដើរទៅ, ម្ចាស់ទ្រព្យគេក៏ចោទប្រកាន់ខ្លួនថាជាចោរ ហើយក៏នាំគ្នាចាប់ចងធ្វើទុក្ខទោស ជាក់ពិន័យជាប់គុកច្រើនឆ្នាំជាដើមក៏មាន ។ នេះឈ្មោះថា អបាយមុខទី ២ ។

៣ – ការដើរមើលល្បែងមហោស្រពផ្សេងៗ – បុរសក្តីស្ត្រីក្តី កាលបើដឹងឮថាល្បែងប្រឹងពុតកំប្លែង មាននៅកន្លែងណា ក៏ដើរចូលទៅកាន់ទីនោះ ហើយស្តាប់ឬមើលល្បែងនោះៗ ដោយសេចក្តីសប្បាយជាប់ចិត្តភ្លេចខ្លួនឥតនឹកនាដល់ប្រពន្ធកូន ឬប្តីសម្បត្តិដែលមាននៅក្នុងផ្ទះ, មិនតែប៉ុណ្ណោះ ខាតទាំងធ្វាក់កាសដែលត្រូវចាយក្នុងល្បែងនោះៗផង, ខាតទាំងពេលដែលត្រូវប្រកបការងាររកស៊ីផង ។ ធម្មតាអ្នកមើលល្បែងមិនអាចធ្វើចិត្តឲ្យស្ងប់ស្ងាត់បានទេ, ឈ្មោះថាជាអ្នកពន្លឹកបណ្តែតបណ្តោយចិត្តឲ្យរវើរវាយវង់វៀនទៅកន្លែងតាមគុណកាន់តែខ្លាំងឡើងៗ, ជួនកាលប្រុសលះលែងប្រពន្ធរបស់ខ្លួនវង្វេងទៅតាមស្រីអ្នកលេងល្បែងក៏មាន, ជួនកាលស្រីលះលែងប្តីរបស់ខ្លួន វង្វេងទៅតាមប្រុសអ្នកលេងល្បែងក៏មាន,

ចំណែកប្រុសលបលាក់យកទ្រព្យរបស់ទៅឲ្យស្រី, ចំណែកស្រីលបលាក់យកទ្រព្យរបស់ទៅឲ្យប្រុស ។ រឿងទាំងនេះក្នុងសម័យបច្ចុប្បន្នឥឡូវសឹងមានជាច្រើននៅស្រុកគ្រោនឹងមីក្រែង, បើបុរសឬស្ត្រីមានសភាពយ៉ាងនោះ ដែលជាអ្នកមានអំណាច កាលបើប្តាក់កាសសម្រាប់ចាយចាត់ចែងមិនគ្រប់គ្រាន់ទេ ក៏តាំងប្រើឧបាយកលសង្កត់សង្កិនដោយផ្លូវអយុត្តិធម៌ ឥតអាណិតអាសូរដល់អ្នកផង ដើម្បីយកទៅបង្ក្រប់បំប៉នតាមគុណតាំងនោះ ។ រឿងនេះគួរឲ្យសង្វេគ គួរឲ្យនឹកស្តាយពេកណាស់, បើប្រសិនជាយកចិត្តទុកដាក់ទំនុកបម្រុងស្រុកទេស ឲ្យបានប្រហែលគ្នានឹងយកចិត្តទុកដាក់ក្នុងមាតុគ្រាមវិញ, ស្រុកទេសមុខតែនឹងបានសេចក្តីចំរើនក្តៅថ្កើងតាន់សម័យមិនខាន ។ សេចក្តីដែលបានពណ៌នាមកនេះឈ្មោះថា អបាយមុខទី ៣ ។

๔ ការលេងល្បែងភ្នាល់ស៊ីសង - ល្បែងភ្នាល់ស៊ីសងនេះមានច្រើនយ៉ាង រាប់តាំងពីបៀនឹងឆួជាដើមទៅ ។ បុរសស្ត្រីអ្នកចូលចិត្តប្រព្រឹត្តលេងល្បែងស៊ីសងឯណាមួយ សុទ្ធតែមានបំណងចង់បានប្រយោជន៍ចំណេញមកធាប់ៗ, ប៉ុន្តែហេតុការណ៍ពិតនោះ មិនមែនត្រូវដូចគំនិតដែលប៉ងនោះទេ, បើទុកជាត្រូវបំណងខ្លះក៏មានតិចណាស់ក្នុងលោកនេះ; គួរអស់លោកអ្នកពិចារណាមើលដូច្នេះថា អ្នកមានកោតសម្បើមច្រើនរាប់មុឺនរាប់សែននៅជុំវិញខ្លួនសព្វថ្ងៃនេះ តើគេមានមកអំពី

លេងល្បែង ឬគេមានមកអំពីប្រកបកសិកម្មនឹងការណាជួកម្ម? ។ ធម្មតា
អ្នកប្រព្រឹត្តលេងល្បែងក្តាស់, មិនដែលអ្នកណាមួយមានកំណើតទៅជា
មនុស្សគ្រាន់បើទេ, ច្រើនតែទទួលវេរគ្រោះថ្នាក់សេចក្តីវិនាសច្រើន
ប្រការគឺ: អ្នកប្រព្រឹត្តលេងល្បែង កាលបើខ្វះឈ្នះក៏ប្រើអំណាចរំលោភ
អូសយកទ្រព្យសម្បត្តិអំពីអ្នកចាញ់។ ក៏កើតៈសេចក្តីក្តៅក្រហាយចង់ឲ្យវា
ព្យាបាទគ្នាទៅវិញទៅមកក៏មាន, អ្នកចាញ់តែងដេកកើតទុក្ខថ្ងូរដកដង្ហើម
ធំស្តាយទ្រព្យសម្បត្តិ ដែលវិនាសបាត់ទៅរហូតដល់លែងចង់រស់នៅជា
មនុស្ស ដោយប្រើវិធីចងកសម្លាប់ខ្លួនឯងជាដើមក៏មាន, អ្នកលេងល្បែង
ច្រើនមានទុប្បាយកុហកកូតកវញ្ចកបោកប្រាស់គេឲ្យតែបានដល់ដៃ ឬទោះបី
ទៅនិយាយពីឯពាក់ព្រស័យកិច្ចការអ្វី ។ ឱនឹងគេ ។ ក៏មិនជឿមិនយកជា
ប្រមាណ ម្ល៉ោះហើយក៏ធ្លាក់ខ្លួនទៅជាមនុស្សថោកឥតតម្លៃត្រូវគេរាប់រក ។
ម្យ៉ាងទៀត ល្បែងស៊ីសងអស់នេះច្រើនធ្វើទុក្ខដល់អ្នកនៅទំនេរ, ដូច
កាលប្តីទៅធ្វើការចាត់ ប្រពន្ធនៅផ្ទះទំនេរឥតការអ្វីធ្វើ ក៏តាំងវ៉ៃក្តែន
តទល់នឹងប្រុស។ ឬនឹងស្រី។ ដូចគ្នា តាំងពីព្រលឹមទល់ថ្ងៃត្រង់ តាំង
ពីបៃតីថ្ងៃត្រង់ទល់ល្ងាច, ដូនកាលក៏ចាញ់អស់រលីងពីខ្លួន ហើយក៏
តាំងលក់ឬបញ្ចាំគ្រឿងអលង្ការ សម្រាប់តាក់តែងកាយយកមកលេង
ទៀត, កាលណាបើប្តីដឹងក៏កើតទៅជាឈ្លោះទាស់ទែងលែងលះគ្នាក៏
មាន ។ នេះឈ្មោះថាអបាយមុខទី ៤ ។

៥ - ការសេពគប់នឹងបាបមិត្ត - មនុស្សណាដែលប្រព្រឹត្ត
ធ្វើនូវអំពើអាក្រក់ ជាហេតុនាំឲ្យកើតសេចក្តីវិនាសដល់ខ្លួនឬដល់អ្នក
ដទៃ, មនុស្សនោះគេហៅថាបាបមិត្ត ។ បើអស់លោកអ្នកចង់ស្គាល់
ថាមនុស្សបែបណាជាបាបមិត្តនោះ គោងពិនិត្យសង្កេតដោយផ្លូវ
កាយ - វាចានឹងចិត្ត ក៏នឹងអាចដឹងបាន ។ បណ្តាមនុស្សក្នុងលោក,
អ្នកណាមួយគោះជាមនុស្សជាន់ខ្ពស់ក្តី ជាន់កណ្តាលក្តី ជាន់ទាបក្តី
សុទ្ធសឹងតែមានការងារត្រូវធ្វើជាប្រក្រតី, បើមនុស្សសប្បុរសល្អ ការងារ
ចេញមកតាមផ្លូវកាយក៏ល្អ ចេញមកតាមផ្លូវវាចាក៏ល្អ ចេញមកតាម
ផ្លូវចិត្តក៏ល្អ; មិនតែប៉ុណ្ណោះ វិថមទាំងជាអ្នកមានករុណាអាណិតអាសូរ
ចំពោះអ្នកដទៃជានិច្ច, ធ្វើការអ្វីមិនអាងយសស័ក្តិ មិនអាងអំណាច មិន
លំអៀងព្រោះស្រឡាញ់ ព្រោះស្អប់ ព្រោះខ្លាចទេ; មនុស្សបែបនេះ
ហៅថាកល្យាណមិត្ត, គួរសេពគប់រាប់រកយកជាមិត្តសំឡាញ់ ។
មនុស្សណាជាអ្នកប្រព្រឹត្តលេងល្បែងស្គាល់ស៊ីសង, ជាអ្នកលេងស្រី, ជា
អ្នកលេងធ្មឹកសុក, ជាអ្នកបញ្ឆោតបោកប្រាស់អ្នកដទៃដោយឧបាយកល
ណាមួយ, ជាអ្នកប្រើអំណាចរំលោភសង្កត់សង្កិនអ្នកដទៃ ដោយអាង
យសស័ក្តិឬដោយអាងទ្រព្យសម្បត្តិ មនុស្សបែបនេះហៅថាបាបមិត្ត,
កុំចូលទៅសេពគប់រាប់រកយកជាមិត្តសំឡាញ់ឡើយ ។

សេចក្តីដែលពណ៌នានេះ ចាត់ជាអធ្យាយមុខទី ៥ ។

៦ - ការខ្ជិលច្រអូស - សេចក្តីខ្ជិលនេះ បើមាននៅលើរូបបុគ្គលណាហើយ អាចនឹងពន្ធិចបន្ទាបបុគ្គលនោះ ឲ្យធ្លាក់ទៅជាមនុស្សក្រីក្រលំបាកទៀត មិនមានចំណេះវិជ្ជានឹងកោតសម្បើម ។ ធម្មតាមនុស្សដែលលុះក្នុងអំណាចនៃសេចក្តីខ្ជិល បើនឹងធ្វើការអ្វីឬរៀនចំណេះអ្វីច្រើនច្រៃអាការខ្ជែមន់ដោយយកអ្វីម្យ៉ាង។ មកធ្វើជាលេសគ្រឿងអាងរបស់ខ្លួន គឺអ្នកខ្លះអាងថា ថ្ងៃនេះនៅព្រឹកណាស់, ល្ងាចណាស់, ត្រជាក់ណាស់, ក្តៅណាស់, ឃ្លានណាស់, ស្រេកណាស់ ធ្វើការឬរៀនអ្វីពុំទាន់កើតទេ ចាំសម្រាកខ្លួនឬចាំបរិភោគអ្វីបន្តិចសិន សឹមធ្វើការឬសឹមរៀន; ការខ្ជែមន់ខ្ជិលបែបនេះហើយ ដែលជាច្រកានធ្វើបុគ្គលនោះឲ្យដល់នូវភាពជាមនុស្សថោកទាបឥតគេត្រូវការរកត ។ ម្យ៉ាងទៀត អស់លោកអ្នកដែលជាមេបា្ន ក្នុងគ្រួសារឬក្រុមមួយ ។ ខ្លះមិនសូវប្រឹតប្រែនរំលឹកជាស់តឿនកូនចៅឬអ្នកដែលនៅក្រោមបង្គាប់បស់ខ្លួន ឲ្យខំប្រឹងធ្វើការឬឲ្យខំប្រឹងរៀនតាមមុខការរបស់ពាក់ទេ, ច្រើនតែបណ្តែតបណ្តោយឲ្យក្មេងនៅទំនេរខ្ជិលដើរលេងតាមអំពើចិត្ត, លុះយូរទៅក៏ក្លាយទៅជាមនុស្សល្ងង់ខ្លៅខ្ជាត់ខ្ជាយចំណេះវិជ្ជានឹងកោតសម្បើម, មិនតែប៉ុណ្ណោះ មនុស្សល្ងង់ឈ្មោះថាធ្វើជាតិត្រកូលនឹងស្រុកទេសឲ្យថោកទាបថែមទៀត ។ សូមអស់លោកអ្នកពិនិត្យសង្កេតមើលទោសរបស់មនុស្សខ្ជិល សព្វថ្ងៃនេះចុះ, នៅក្នុងក្រុងយើញាមាននៅដេរជាសង្កាំងស្រែកាំងច្រុស, ខ្លះដេកដើរឈរអង្គុយរដូវណាលក្រោមម្លប់ឈើ ឬតាម

សំយោបផ្ទះ កែរចិញ្ចើមថ្នល់, រកស៊ីគ្រាន់តែឲ្យរស់ត្រឹមមួយថ្ងៃៗ ប៉ុណ្ណោះ, បើនឹងធ្វើការគិតមានឧបាយគំនិតណាថាអញត្រូវធ្វើយ៉ាងនេះ យ៉ាងនោះដើបល្អដូច្នេះសោះឡើយ, មនុស្សបែបនេះហើយ ដែលសំដែងអាការឲ្យឃើញថាកាបដល់ជាតិនឹងស្រុកទេស ។ នេះឈ្មោះថា អបាយមុខ ទី ៦ ។

មនុស្សឆ្លៀវដូចបានពណ៌នាមកខាងនេះ ប្រសិនបើពាជការបង្កើតរបរការអ្វីមួយ ដើម្បីតម្រូវដល់មនុស្សខាងនេះឲ្យមានការធ្វើឡើង គង់ប្រហែលជានឹងមានសេចក្តីចំរើនដល់ពាជការវិញពុំខាន ។

អាត្មាភាពសំដែងអំពីអបាយមុខខាង ៦ យ៉ាង ចប់ត្រឹមតែប៉ុណ្ណេះ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្ពេបិ ញាតិនោ ។

សព្វសត្វដែលដល់ហើយនូវទុក្ខ សូមឲ្យបាត់ទុក្ខទៅ! ដែលដល់ហើយនូវភ័យ សូមឲ្យបាត់ភ័យទៅ! ដែលដល់ហើយនូវសោក សូមឲ្យជាអ្នកបាត់សោកទៅ! ។

ឥមិនា ធម្មទេសនាវសេន កោដ្ឋាសរដ្ឋវាសិនោ
វុឌ្ឍី ហិរញ្ញ បបេញ្ចត្តិ សន្តិការញ្ច ញាញថា ។

ដោយអំណាចនៃព្រះធម្មទេសនា (នេះ) សូមឲ្យប្រជាជនតាំងពីអ្នកនៅក្នុងកម្ពុជរដ្ឋ ដល់នូវការលូតលាស់ចំរើនទាំងសន្តិភាព កុំបីឃ្លាតឡើយ! ។

ព្រះមហាឧត្តមវិជ្ជា ផលញ្ញាណោ ប៊ុំង-ប៊ម
អាចារ្យសាលាបាលីវគ្គ វត្តបទុមវតី ក្រុងកំពង់ចាម រៀបរៀង
ឃុនបណ្ឌាគុរ៍ក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

ឧបាយបណ្តុះនិស្ស័យទី ២

និស្ស័យសុភាព

អស់លោក-អ្នកសុភាពចាំងឡាយ ! ពាក្យថា "បុរសសុភាព ស្ត្រីសុភាព" នេះ យើងគង់ធ្លាប់បានឮស្ទើរតែច្រើនតែច្រើនមកហើយ ។ តែទោះបីដូច្នោះ ក៏សូមកុំភ្លេចថា "បុរសដែលសុភាពឬស្ត្រីដែលសុភាព នោះមិនមែនព្រោះអ្វីទេ គឺព្រោះតែគេជាមនុស្សល្អ មាននិស្ស័យសុភាពនៅក្នុងខ្លួន" ។ បើលក្ខណៈសុភាព មិនមានជាប់នៅក្នុងខ្លួនទេ ក៏គេនឹងទៅជាមនុស្សសុភាពមិនបានឡើយ ។ ព្រោះមនុស្សនិស្ស័យសុភាព ត្រូវមានសេចក្តីសុភាពរៀបរយនៅក្នុងខ្លួនសន្ធាន ចាំងសំដែងកិរិយានឹងវាចាចេញមកទៀត ក៏ជាទីនិយមរាប់អាននៃមនុស្សខ្លួនទៅ ។ មិនត្រឹមតែសំដែងអាការកាយ-វាចាឲ្យឃើញថាមានកិរិយាខ្ជនលំនោន និយាយពីរោះផ្អែមល្ហែម នឹង មានទឹកមុខរីករាយស្រស់ស្រាយញញឹមញញែម

ប៉ុណ្ណោះទៀ សូម្បីផ្លូវចិត្តក៏នៅតែខ្ចាប់ខ្ជួនកង់លក្ខណៈនៃការសុភាព
នោះដែរ ។

មើលចុះ! មនុស្សសុភាពយើងធ្លាប់ឃើញមកហើយ ទំនងឃើញ
ប្រតិក្សប្បាស់លាស់តទៅទៀត ដោយអាការគោរពនូនលំពោនជានិច្ច
ប្រើកំរិយានឹងវាចាចំពោះអ្នកតូច ដូចគ្នានឹងប្រតិបត្តិចំពោះអ្នកធំ មិន
លើកតំកើងខ្លួន សូម្បីក្នុងករណីយកិច្ចណា។ ទាំងអស់ ។ ឯមនុស្សមិន
សុភាពវិញ សូម្បីធ្លើត្រូវប្រុនិយាយពីពេះ ក៏គង់មានរឿងអ្វីមួយ នាំឲ្យ
ខុសប្លែកពីមនុស្សដទៃ ។ យើងអាចដឹងបានដោយសារអ្នកនោះ នៅខ្វះ
សេចក្តីល្អដទៃទៀតជាច្រើន ។ ព្រោះមនុស្សមិនសុភាពនោះ សូម្បី
មានគុណគឺសេចក្តីល្អកង់ផ្លូវដទៃនៅក្នុងខ្លួនខ្វះ ក៏គង់ធ្លើឲ្យគេកើតសេចក្តី
និយមជ្រះថ្លានឹងគោរពរាប់អានមិនបាន ។

កាលបើយើងមានធម៌សុភាពនៅក្នុងខ្លួនហើយ ក៏អាចធ្លើឲ្យអ្នកដទៃ
កើតសេចក្តីត្រេកអរ ស្រឡាញ់ គោរពរាប់អាន ដោយសុទ្ធចិត្តពិតៗ
បាន ។ បើគ្មានសេចក្តីសុភាពវិញ ក៏មិនអាចធ្លើឲ្យគេមានសេចក្តីនិយម
រាប់អាន ក្នុងកិរិយានឹងវាចារបស់យើង សូម្បីតែបន្តិចបន្តួចបានទេ,
នេះព្រោះតែការមិនសុភាពនោះចូលមកជ្រែតជ្រែក បណ្តេញយើងឲ្យ
ឆ្ងាយចាកមនុស្សដទៃ ទាំងហាមមនុស្សដទៃមិនឲ្យចូលមកជាក់ទងនឹង
យើង ឈ្មោះថាយើងមានឫសគល់ដែលជាគ្រឿងបាន់ខ្លួនឲ្យធ្លាក់ទៅ

កាន់ទីភាបត្រៃប់វេលា ។ "បើយើងមានលក្ខណៈទន់ដែងនៅក្នុងខ្លួនហើយ យើងនឹងទៅជាមាសពុំបានឡើយ" នេះជារឿងដែលត្រូវនឹកវត្ថុកជានិច្ច ។

ការប្រព្រឹត្តិល្អប្រពៃ តាមក្របខ័ណ្ឌនៃមនុស្សធម៌ ជាលក្ខណៈនៃសេចក្តីសុភាព ។ មនុស្សសុភាព គឺមនុស្សប្រព្រឹត្តល្អតាមរបៀបនៃមនុស្សធម៌ មានអធ្យាស្រ័យទឹកចិត្តល្អត្រជាក់ត្រជុំ ស្គាល់ចិត្តថ្នើមរបស់មិត្តភក្តិកងក្នុងភូមិហូតដល់មិត្តភក្តិកងសាកលលោក សំដែងកិរិយានឹងវាចាសម្ងាគារវៈរៀបរយចាំងចំពោះមុខអ្នកធំ ចាំងចំពោះមុខអ្នកតូចមិនច្រេងច្រាំង មិនរើងរុស ។ បើជាអ្នកធំវិញ ក៏មិនជ្រែតជ្រៀតអ្នកតូច ។ សូម្បីជាអ្នកតូច ក៏មិនព្រហើនកោងកាចចំពោះអ្នកធំ ប្រើសំដីអន្ទះកូលដល់គ្នានឹងគ្នា មិនយកឈ្នះយកប្រៀបគ្នា ។ បើពោលដោយខ្លីទៅ ខ្លឹមសារនៃការសុភាពនោះ នៅត្រង់សេចក្តីល្អ ។ មនុស្សសុភាព ក៏គឺមនុស្សល្អនោះឯង ។ មនុស្សល្អនោះ មិនមែនល្អព្រោះវិការៈនៃពងកាយល្វាសល្វន់ មិនមែនល្អព្រោះរូបសម្បត្តិ មិនមែនល្អព្រោះជាតិត្រកូលឫទ្ធិឫសម្បត្តិឡើយ គឺល្អព្រោះតែអ្នកនោះមានសេចក្តីល្អនៅក្នុងខ្លួន ។ និយាយ ១ ជាន់ទៀតថា សេចក្តីល្អដែលនៅក្នុងខ្លែតដែនៃការសុភាពនេះ គឺកិរិយាសុភាព វាចាសុភាព ទឹងចិត្តសុភាព ។ អ្នកមានកិរិយាសុភាព មានវាចាសុភាព ទឹងមានចិត្តសុភាពនោះឯង ជាមនុស្សសុភាព ។

កិរិយាសុភាព – "កិរិយា" សំដៅយកអាការដែលសំដែងចេញ
ប្រាកដមកដល់អ្នកដទៃ ។ កិរិយានេះ សូម្បីគ្រឹមតែជាអាការខាងក្រៅ
ក៏ពិតមែន តែគង់ជាវត្ថុយ៉ាងសំខាន់ក្រៃលែង ព្រោះជាការសែតសម្រាប់
បើកផ្លូវឬបិទផ្លូវរបស់ជីវិត ទាំងជាគ្រឿងប្រដាប់នៃការធ្វើ និងការ
និយាយផង ។ ដ្បិតថា កាលបើយើងធ្វើសេចក្តីអាណិតអាសូរគុណា
ប្រណីនិយាយរាក់ទាក់ផ្អែមល្ហែម ឬធ្វើសេចក្តីអាក្រក់ផ្សេង ។ និយាយ
ពាក្យអាក្រក់គ្រោតគ្រាតគំរោះគំរើយហើយ កិរិយានោះតង់ចំពេញផល
ល្អឬផលអាក្រក់តាមតែអំពើដែលយើងធ្វើនោះ ឲ្យមានកំឡាំងឡើង
អាចបើកបង្ហាញនូវនិស្ស័យចិត្តដល់អ្នកដទៃបាន គឺបង្ហាញសេចក្តីគាប់
ចិត្ត សេចក្តីស្រឡាញ់ សេចក្តីចេះដឹង សេចក្តីត្រេកអរ ឬសេចក្តី
ក្រោធ ។ ល ។ ដែលចេញមកពីខាងក្នុងខ្លួនឲ្យប្រាកដដល់អ្នកដទៃ
ល្មមឲ្យគេដឹងបានថា ជាកិរិយាល្អ ឬកិរិយាអាក្រក់ ។

អស់លោកអ្នកប្រាជ្ញសុខុំតាំងឡាយ ! កិរិយាអាការខាងក្រៅដូច
ជាការយាត្រា ការទុនលំនោន ការនិយាយអតិប្រយ ការធ្វើក្តែក
ឬធ្វើមាត់ ជាគំនូសឲ្យយើងស្គាល់ដឹងដល់ចិត្តគ្នាបាន ដូចកង់បុរាណ
ភាសិតថា "សំឡេងប្រាប់ភាសា កិរិយាប្រាប់ត្រកូល" ។ សូម្បីក្នុង
លោកនីតិក៏មានពោលដែរថា

"ប្រមាណជម្រៅទឹកពិនិត្យ ឲ្យដកព្រលឹតវាស់វែងវា
ប្រមាណត្រកូលអ្នកកាចជា ឲ្យមើលកិរិយាអាការចេញ ។

ប្រមាណអ្នកឈ្មោះវៃប្រាជ្ញប្រាយ មើលការនិយាយគោលមកមិញ ប្រមាណប្រថពីដីរដើដេញ - មើលស្មៅទៀវចេញអាតែកំណ្ដ ។

កិរិយាល្អ, កិរិយារម្យទម ទំងកិរិយាទុនលំទោន សម្រាប់ប្រាប់ផ្លូវរបស់ដីតែឲ្យប្រាកដប្រជា ពាំងធ្វើឲ្យការសមាគមជិតស្និទ្ធចូលគ្នាបាន នេះជាលក្ខណៈនៃកិរិយាសុភាព ។

មនុស្សសុភាព សូម្បីធ្វើការអ្វីត្រឹមតែបន្តិចបន្តួច ក៏គួរជាទីរីករាយជាទីនិយម ជាទីពាប់អាន ជាទីមិលមើលនៃជនដទៃ ព្រោះអំពើនោះសុទ្ធតែជាគ្រឿងបើកផ្លូវឲ្យដីតធ្វើដំណើរទៅដោយសួស្ដីពាំនអស់ ។ ចំណែកមនុស្សមិនសុភាពវិញ សូម្បីធ្វើការអ្វីដែលជាអង្គនៃសេចក្ដីល្អ ក៏គង់ជាគ្រឿងទើសកែក ទើសត្រចៀក ទាស់ចិត្តនៃមនុស្សដទៃដែរ ព្រោះជាហេតុធ្វើគន្លងផ្លូវនៃការងាររបស់ខ្លួនឯង ឲ្យទុសស្រឡះទៅពាំងស្រុង ។

ក) កិរិយាល្អ— កិរិយាល្អប្លែកមិនល្អ ខានៅត្រង់កាលៈទេសៈ ។ លោកក្នុងសម័យមុន រមែងនិយមការល្ងាសល្ងន់ ទន់ភ្លន់ យាងយាសតែកាយ ថាជាកិរិយាល្អ ។ តែលោកក្នុងបច្ចុប្បន្ននេះ ត្រឡប់យល់ឃើញកិរិយាយ៉ាងនោះថាជាកិរិយាយឺត កិរិយាប្រអូស កិរិយាញុកញ៉ាក់ មិនគួរមើលទៅវិញ ។ ពិតមែន បើយើងពិចារណាហេតុក្នុងសម័យនេះហើយ ក៏គង់ឃើញបានថាសេចក្ដីល្អ មិនមែននៅត្រង់ការយាងយាស

នោះទេ ។ អ្នកណាមិនបានឈានដើងដោយអាការដ៏ហ័សរហួនហើយ អ្នកនោះ នឹងត្រូវគេតិះដៀលថាជាមនុស្សយឺត មនុស្សច្រអូស ។ អ្នកប្រាជ្ញខាងវិទ្យាសាស្ត្របានពោលថា "កិរិយាយាងយាសតែក្រាយនោះជាហេតុឲ្យយឺត ការយឺតជាហេតុឲ្យកាយមិនមានកំឡាំងល្មមដល់សេចក្តីបំណងរបស់ធម្មជាតិ ជាសម្បុដ្ឋានឲ្យកើតរោគភ័យឈឺ ចាប់ នឹងអាយុខ្លី" ។ សូម្បីអ្នកប្រាជ្ញខាងផ្លូវចិត្ត ក៏មានមតិត្រូវគ្នាថា "កាយយឺត ចិត្តក៏យឺត, ចិត្តយឺតជាចិត្តដែលខន់ខ្សោយ, ឯចិត្តដែលខន់ខ្សោយនោះគឺចិត្តដែលមិនអង់អាច ជាចិត្តធ្វើអ្វីមិនសម្រេច" ។

កិរិយាល្អដែលលោកនិយមក្នុងសម័យអារ្យៈ នៅត្រង់កិរិយាប្រញាប់ប្រញាល់រហ័សរហួន មានពាក្យស្វាហាប់ បានរូបពាក្យ បានខ្លឹមថា "ឆាប់ខែងវែង" ។ កិរិយាល្អមិនមែននៅត្រង់កិរិយាយាងយាសតែក្រាយស្ងាសស្ងន់ មិតពត់ប្តេជ្ញាសើន មិនសមនឹងដំណើរខ្ពង់នោះទេ ។ បើខ្លួនក៏មិនខ្លួនតែក្បាលក្នុកនោះដែរ គឺខ្លួនលំពោនដែលប្រកបត្រមដោយការរឹងប៉ឹងអង់អាចនឹងខែងវែងគួរមើល ។ ឯកិរិយាដែលល្អនោះសោតត្រូវឲ្យសមគួរដល់បុគ្គល ដល់ទីឋាន នឹងដល់កាលសម័យផង ។ គ្រប់តែពេលដែលយើងសំដែងកិរិយា យើងគួរកុំភ្លេចថា "ចូលស្រុកអ្នកមានក្អែកមួយ ត្រូវធ្វើឲ្យមានក្អែកមួយតាមគេ" ដូចជាយើងចូលទៅវត្តព្រះសង្ឃ ចូលទៅរកអ្នកមានទ្រព្យ អ្នកធំ ចូលគាល់ម្ចាស់ផែនដី ឬនាយ

ចៅហ្វាយ ចូលទៅកាន់សមាគមបរជាតិឬក្នុងទីប្រជុំនឹងទីធ្វើបុណ្យ ពិធី
តូចធំណាមួយ ត្រូវតែអនុលោមខ្លួនឲ្យសមគួរដល់បុគ្គល នឹងកាល:
ទេស:នោះៗ គួរថ្វាយបង្គំក៏ថ្វាយបង្គំ គួរគោរពក៏គោរព គួរលុត
ក្រាបក៏លុតក្រាប ឬគួរធ្វើសេចក្តីគោរពយ៉ាងដទៃទៀត តាមសម័យ
និយមដែលអ្នកប្រជុំសរសើរ ក៏ធ្វើដែរ ។ មនុស្សយើងមានរូបពណ៌
សណ្ឋានផ្សេងៗគ្នា នឹងរើសយកតាមចិត្តប្រាថ្នាពុំបាន ស្រេចហើយ
តែកម្មដែលខ្លួនកសាងមក តាក់តែងឲ្យជាអ្នកមានរូបល្អខ្លះ អាក្រក់ខ្លះ
ផ្សេងៗគ្នា ។ អ្នកមានរូបល្អ រមែងជាទីនិយមចូលចិត្តរបស់ជនដែល
បានឃើញ ប្រៀបដូចផ្កាឈើដែលមានពណ៌សណ្ឋានល្អ ។ ឯអ្នក
ដែលមានរូបអាក្រក់ តែងមិនជាទីពិតពិលរមិលមើល នៃជនដែលបាន
ឃើញ ដូចជាផ្កាឈើដែលមានពណ៌សណ្ឋានមិនល្អ ។ តែកិរិយាដែល
ល្អ ប្រសើរជាងរូបល្អ ព្រោះមនុស្សមានកិរិយាល្អនោះ សូម្បីរូបមិនល្អ
ក៏គង់ជាទីនាំឲ្យចាប់ចិត្ត ចាប់ភ្នែករបស់មនុស្សដទៃបាន តាំងជាគ្រឿង
ណែនាំឲ្យគេយកចិត្តទុកជាក់នឹងខ្លួនផង គ្រាន់បើជាងមនុស្សមានរូបល្អ
ដែលមានកិរិយាថោកទាប ។ បើមានកិរិយាល្អ ហើយមានរូបល្អផង
ក៏រឹតតែជាទីស្រឡាញ់របស់ប្រជាជនថែមទៀត ។

មនុស្សមានកិរិយាថោកទាប សូម្បីជាអ្នកមានទំរូបល្អ ក៏គេលន់តឹង
មនុស្សមានរូបអាក្រក់ដែលមានកិរិយាល្អពុំបាន ។ បើកិរិយាអាក្រក់

ហើយ រូបអាក្រែក៏ផង ក៏រឹតតែអភ័ព្វក្រៃលែងទៅទៀត មិនមាន
នរណាចូលចិត្តស្រឡាញ់រាប់អានឬស្នេហាគេសមាគមរួមជាមួយឡើយ ។
អញ្ជើញមើលចុះ ! ផ្កាឈើដែលមានព័ណ៌ទឹងទែងគួរយល់ តែគ្មាន
ក្លិនក្រអូប រមែងប៉ះទង្គិចផ្កាឈើដែលមានពណ៌សណ្តានអាក្រក់ តែមាន
ក្លិនក្រអូបពុំបានទេ ; បើគ្មានក្លិនក្រអូប ថែមទាំងមានពណ៌ទ្រង់ទ្រាយ
អាក្រក់ទៀតផង ក៏រឹតតែជាទីមិនគួរប្រាថ្នារបស់នរណាៗឡើយ ។

ផ្កាសេរមាន់ ផ្កាថា មានពណ៌ល្អ
តែគ្មានក្លិន នោះក៏ គ្មានដំណៀ
ដូចប្រុសស្រី រូបល្អ គួរពិស្ម័យ
តែកិរិយា វិស័យ សត្វតិរច្ឆាន ។
បើជាស្រី រូបល្អ គួរកិសវង់
តែឫកខ្វើស ទ្រនង់ ពុំសមហាន
ប្រុសចេះគិត មិនខ្វី ចង់រាប់អាន
ទាំងមិនបាន ងាកមើល ដោយស្នេហា ។
សូម្បីប្រុស ក៏ចុះ ក្បួនដូចគ្នា
ខើបឃើញថា ឫកពា ល្អថ្លៃថ្លា
នៅត្រង់ចិត្ត សុភាព ចេះពាក្យសា
មិននៅត្រង់ រូបឆ្កា ដែលល្អឡើយ ។

អ័ង្គ្លេ ឈា - សំស្ក្រឹ ណា

"រឿងព្រៃនប្រទេសរូម៉ានី"

លោក ផេង - ជ្រឿ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

(តមក)

លុះទ្រង់ទតព្រះនេត្រមើលសព្វគ្រប់ហើយ, ព្រះពជធីតាវើសយកដាវមួយដែលច្រែះចាប់បន្តិច ប៉ុន្តែផ្លែល្អ ពងវែងដូចស្នែងក្របី ។ រួចព្រះនាងច្រាប់យក្សថា: ស្អែកនេះនាងនឹងធ្វើដំណើរតទៅទៀត ។

ការជ្រើសរើសនៃព្រះពជធីតានេះ ធ្វើឲ្យនាងយក្ខិនីក្តៅក្រហាយពេក ព្រោះវាមិនអាចរកសេចក្តីពិតឃើញ ។ នាងយក្ខិនីច្រាប់កូនថា: ទោះបីអាការខាងក្រៅដូច្នេះក៏ដោយ ក៏ព្រះអង្គម្ចាស់នេះឯងច្រាកដជាស្រី ហើយជាស្ត្រីឆ្លាតផុត ។ ដោយអស់សង្ឃឹមនឹងមជ្ឈដ្ឋានដើម្បីដោះប្រស្នានេះ យក្សម្តាយនឹងកូននាំគ្នានៅឯក្រោលសេះ ហើយយកសេះសុរ្យាបកាថ្វាយព្រះពជធីតា។ ក៏លាយក្សធ្វើដំណើរចេញទៅ ។

សេះនិយាយថា: បពិត្រព្រះនាងម្ចាស់! តាំងពីដើមរហូតមកដល់ថ្ងៃនេះ ទ្រង់តែងតែធ្វើតាមដំបូន្មានខ្ញុំព្រះបង្គំទាំងអស់ ហើយទ្រង់ក៏ច្បានឈ្នះមារសត្រូវគ្រប់កន្លែង ។ ឥឡូវនេះ, សូមព្រះនាងធ្វើតាមដំបូន្មានខ្ញុំព្រះបង្គំម្តងទៀតចុះ ទ្រង់នឹងមិនមានសេចក្តីក្តៅក្រហាយព្រះ

ហ្អូទ័យស្តាយគ្រោយឡើយ ។ ឥឡូវនេះទូលព្រះបង្គំចាស់ណាស់ហើយ កំឡាំងមិនសូវមានប៉ុន្មាន ចុះប្រសិនបើទូលព្រះបង្គំទៅជាម៉ែចៗទៅ... សុំព្រះនាង៎យកសេះសុរ្យាបកា ដែលត្រូវជាហ្អូនទូលព្រះបង្គំជាជំនិះកុង ដំណើរនេះចុះ ។ ខ្ញុំធ្លាប់មានព្រះហ្អូទ័យដឿលើរូបទូលព្រះបង្គំយ៉ាងណា ក៏សូមទុកព្រះហ្អូទ័យលើរូបសុរ្យាបកាយ៉ាងនោះ ។ ខ្ញុំនឹងមិនស្តាយគ្រោយទេ ។ សុរ្យាបកាក្មេងក៏ក្មេង រហ័សក៏រហ័សជាងទូលព្រះបង្គំ ហើយគេឲ្យដំបូន្មានដល់ខ្ញុំល្អជាងទូលព្រះបង្គំកុងពេលដែលមានការត្រូវធ្វើ ។

ព្រះពជធីតាមានព្រះបន្ទូលតបថា ប្អាកដមែនហើយ បងមនោ-មយ! ខ្ញុំបានសម្រេចប្រយោជន៍គ្រប់ជង កាលណាខ្ញុំធ្វើតាមដំបូន្មានបងឯង ។ ខ្ញុំដឹងថា: បងមានចិត្តស្មោះត្រង់ចំពោះព្រះពជបិតាខ្ញុំណាស់, បើដូច្នេះ ខ្ញុំត្រូវតែស្តាប់ពាក្យរបស់បងទៀត ។ ប៉ុន្តែខ្ញុំបង់ដឹងឲ្យជាក់ច្បាស់ តើហ្អូនរបស់បងមានសេចក្តីទុកចិត្តលើរូបខ្ញុំដូចខ្លួនរបស់បងឬទេ? ត្រូវឲ្យគេសំដែងសេចក្តីស្នេហាឲ្យឃើញចំពោះខ្លួនខ្ញុំសិន ។

សុរ្យាបកាក្រាបបង្គំទូលថា: សូមទ្រង់ទុកព្រះពជហ្អូទ័យលើរូបទូលព្រះបង្គំចុះ, ទូលព្រះបង្គំត្រែកអរជាពន់ពេក ដោយបានព្រះអង្គម្ចាស់ហាវហានដូចជាទ្រង់គង់លើខ្លួន, ហើយទូលព្រះបង្គំនឹងខំយកចិត្តទុកដាក់ធ្វើការថ្វាយទ្រង់តាមចំណេះដែលអាចធ្វើបាន ដូចជាបងរបស់

ទូលព្រះបង្គំដែរ ។ ទូលព្រះបង្គំមានបំណងចង់រំដោះសេចក្តីព្រួយនឹងគ្រោះថ្នាក់ដែលទ្រង់ត្រូវជួបប្រទះ អំពីបងទូលព្រះបង្គំផង ព្រោះគាត់ចាស់ហើយ។ ទ្រង់មុខជាជ្រាបហើយថា យើងទៀងតែត្រូវផ្តាំញ៉ាំនូវសេចក្តីលំបាកនឹងមរណភ័យក្នុងផ្លូវជាមិនខាន ។

ក្នុណោះ ព្រះពជធីតាទ្រង់ព្រះកន្សែង ដោយការអាឡោះអាល័យចំពោះព្រះពជអស្សពាហន៍ចាស់ ហើយទ្រង់ក៏ខ្សឹងគង់លើខ្នងសុរាបកាអាជានេយ្យបរទៅ ។

ព្រះនាងគង់លើព្រះពជធីនាងសុរាបកាបរទៅមិនបានជាយូរប៉ុន្មាន, ទ្រង់ប្រទះឃើញកម្រងសក់មាសមួយជ្រុះនៅដី ។ នាងបញ្ឈប់សេះហើយសួរថា តើត្រូវរើសយកកម្រងសក់នេះទុក ឬដូចម្តេច? ។ សេះក្រាបបង្គំទូលថា: បើទ្រង់រើស ទ្រង់នឹងមានសេចក្តីស្តាយក្រោយ, បើទ្រង់មិនរើសយក ទ្រង់ក៏មានសេចក្តីស្តាយក្រោយដែរ; បើដូច្នោះត្រូវរើសយកទុកល្អជាជាង ។ នាងពៅរើសកម្រងសក់ទុកក្នុងព្រះពស្ត្រ ហើយធ្វើដំណើរតទៅទៀត ។

ព្រះនាងធ្វងកាត់គិរីបពិត ធ្វងជ្រោះ ធ្វងព្រៃញាតស្បាតស៊ុបទ្រុប, ចំការពោសពេញដោយបុប្ផជាតិផ្សេងៗ ដែលព្រះនាងមិនដែលប្រទះធ្វង, ជ្រោះមានទឹកថ្លាត្រជាក់; ក្នុងទីបំផុត ព្រះនាងក៏បានទៅដល់ព្រះពជវាំងនៃព្រះចៅពជាធិពជដ៏ទ្រង់ឫទ្ធានុភាពអស្ចារ្យ ។

ថ្ងៃនិងអំពីព្រះពាជបុត្រតាំងឡាយ នៃស្តេចប្រទេសពាជដទៃដែលនៅក្នុងវាំងនោះ នាំគ្នាមកទទួលនូវអាគន្តុកពាជបុត្រ ហើយមិនអាចដាក់មុខចេញពីព្រះក័ក្តនៃនាងឡើយ ព្រោះព្រះនាងមានស្នេហ៍នៅត្រង់ព្រះវាចានិងព្រះកត្តុ ។

ព្រឹកឡើង ព្រះនាងស្តេចទៅថ្វាយបង្គំគាល់សម្តេចព្រះចៅពាជាធិពាជ ហើយទូលថ្វាយដំណឹងដល់ព្រះអង្គ អំពីហេតុដែលនាំឲ្យព្រះនាងយាងមកកន្លែងនេះ ។ ព្រះចៅពាជាធិពាជទ្រង់មានព្រះហឫទ័យត្រេកអរជាពន់ពេក ដោយឃើញអ្នកហ៊ារហានមានមុខស្រស់ឋសង់មកដល់ ទ្រង់សព្វព្រះហឫទ័យនឹងចម្ងើយរបស់ព្រះនាងដែលប្រកបដោយសេចក្តីគោរព នឹងពេញដោយការស្ងួតបួតពាបសា, ទ្រង់ពេញព្រះហឫទ័យនឹងព្រះពាជធីតាពេក ក៏ទ្រង់តាំងឲ្យព្រះនាងនៅធ្វើការផ្ទាល់ព្រះអង្គ ។ ព្រះនាងមាណ-វីពាជធីតា មិនបានមានការច់ាក់ទងរវាងព្រះពាជបុត្រជាគូកនតាំងឡាយឯទៀត ដែលច្រើនតែជាអ្នកលោភលន់ ជាអ្នកកំដៀលហើយនឹងជាអ្នកមានច្បាជាមិនពេញលេញទេ ។ ហេតុដូច្នេះ ព្រះពាជបុត្រតាំងនេះមានចិត្តឈ្នានីសប៉ងចងអាឃាតចំពោះព្រះអង្គម្ចាស់ក្សត្រី ព្រោះព្រះចៅមានព្រះហឫទ័យស្រឡាញ់ច្បាសប្រណីព្រះនាងជាងគេ ។

មានថ្ងៃមួយ នាងឡើងទ្រង់ដាំសូរដោយព្រះអង្គឯងម្ចាង, ហើយវេលាដែលព្រះនាងកំពុងសោយព្រះក្រយាស្ងួយ ស្រាប់តែព្រះពាជបុត្រ

ពីព្រៃអង្គយាងមកឃើញ ។ ព្រះពជបុត្រទាំងពីរនេះក៏ចូលសោយជាមួយនឹងព្រះនាង ។ ព្រះក្រយាស្វាយនុ៎ះត្រូវព្រះនុស្ងោតក តាលំតែព្រះអង្គម្ចាស់ទាំងពីរសោយលិទ្ធព្រះហស្ត ហើយទ្រង់សរសើរព្រះនាងអំពីការចេះដណ្តាំស្ងូថា : ខ្ញុំមិនដែលសោយក្រយាស្វាយណាមានឧជារសជាងនេះសោះ ។

កូនស្តេចទាំងពីរនិយាយសរសើរប្រាប់មិត្តភក្តិទាំងពួងថា: ជាន សោយអាហារជាមួយនឹងព្រះអង្គម្ចាស់អាគន្តុក:, ថាអាហារនុ៎ះមានឧជារសលើសលុបជាងព្រះស្វាយនៃព្រះចៅពជាធិពជទៅទៀត, ថាអាហារនោះ ជាអាហារដែលនាងដណ្តាំស្ងូដោយខ្លួនឯង ។ កាលនោះ អស់ទាំងព្រះពជបុត្រនាំគ្នាទៅអង្វរសូមឲ្យព្រះនាងដណ្តាំស្ងូម្តងទៀត ។ ដូនជាទេសកាលអ្វីថ្ងៃនោះនាយពិសេសស្រីធឹងស្រាទាំងអស់គ្នា ហើយនៅក្នុងដើងក្រអកក្លើងគ្មាន ; ព្រះនាងក៏ព្រមទទួលធ្វើតាមពាក្យអង្វរនៃព្រះពជបុត្រទាំងឡាយ ។ សម្ងូដែលព្រះនាងទៅធ្វើមានឧជារសពន់ពេក ។ កាលនោះគេលើកព្រះក្រយាស្វាយទៅថ្វាយព្រះចៅពជាធិពជ, ព្រះអង្គទ្រង់សោយមិនចង់ឈប់ ។ ទ្រង់ក៏ហៅនាយពិសេសមក ហើយមានព្រះពជនុ៎ាវបង្គាប់ថា: ទៅថ្ងៃមុខទៀតត្រូវធ្វើតែបែបដូច្នេះ ។ ប៉ុន្តែនាយពិសេសពុំសូវយល់ចិត្តក្រាបបង្គំទូលថ្វាយ អំពីអ្នកដែលធ្វើព្រះក្រយាស្វាយនេះ ។ ព្រះចៅពជាធិពជស្រាប់តែទ្រង់នៅស្ងៀម ហើយទ្រង់ព្រះតម្រិះតែក្នុងព្រះពជហ្ឫទ័យ ។

លុះកាលកន្ធង់មកមិនយូរប៉ុន្មាន ព្រះរាជបុត្រនៃព្រះរាជាដទៃមក
ក្រាបបង្គំថ្វៃង់សេចក្តីថ្វាយព្រះចៅរាជាធិរាជថា: មានមួយថ្ងៃ ពួកខ្ញុំ
ព្រះបង្គំបានទទួលទានអាហារជាមួយនឹងអាគន្តុករាជបុត្រ។ បាននិយាយ
អួតថា: ខ្លួនស្គាល់ទីលំនៅនៃនាង "អ៊ីឡែណា - សិម្ប៉ាណា" ដែល
មានកម្រងសក់មាស មាត់ទិព្យ ចេះធ្វើឈើឲ្យលូតលាស់សន្ធឹក ឲ្យមាន
ផ្លាផ្លែ, ហើយថែមទាំងថាខ្លួនមានកម្រងសក់មាសមួយដុំផង ។

ព្រះចុតរាជាធិរាជលុះទ្រង់ព្រះសណ្តាប់ដូច្នោះ ទ្រង់ក៏ឲ្យគេហៅ
ព្រះអគ្គមហេសីហាវហានមកភ្លាម ហើយមានព្រះរាជឧង្ការបន្ទោសថា:
ឯងដឹងកន្ទែងនៃនាង "អ៊ីឡែណា - សិម្ប៉ាណា" ហើយឯងគ្មាននិយាយ
ប្រាប់យើងសោះ យើងថាមុកចិត្តលើឯង ហើយស្រឡាញ់ឯងជាងគេ ។

ព្រះចៅទ្រង់បង្គាប់ឲ្យព្រះនាងយកកម្រងសក់មាសមក ហើយមាន
ព្រះបន្ទូលបន្ថែមថា: បុរេបញ្ញានៃព្រះរាជាធិរាជ ថាត្រូវឯងទៅនាំនាង
អ៊ីឡែណា - សិម្ប៉ាណាឲ្យបានមក បើឯងមិនចង់ឲ្យក្បាលឯងរមៀល
មកដី ។

ព្រះនាងកំសត់រកនិយាយក្រាបទូលអ្វីមិនកើត ព្រោះព្រះចៅចេះ
តែមានព្រះឧង្ការស្អាក់អស់ ។ ទាល់ចំណោះ នាងពោយករឿងនេះទៅ
និយាយប្រាប់សេះ។ ក្រាបបង្គំទូលថា: បពិត្រព្រះនាងជាម្ចាស់!
សូមទ្រង់កុំភ័យបារម្ភ ។ យប់មិញបងទូលព្រះបង្គំបាននិយាយប្រាប់ថា:

នាងកម្រងសក់មាស ឥឡូវយក្សចាប់យកទៅហើយ ។ តែនាងមិនខាន់ត្រមយកយក្សធ្វើជាប្តីទៅឡើយ មុនដែលយក្សទៅរកហ្វូងមេសេះមកប្រគល់ឲ្យនាង ។ ហើយយក្សកំពុងតែក្តៅក្រហាយក្នុងចិត្ត ព្រោះមិនដឹងនឹងទៅរកហ្វូងមេសេះឯណាមក ដើម្បីនឹងបំពេញចិត្តនាង ។ ឥឡូវនេះនាងអ៊ីឡេណា សិម្ប៉ាណាទៅកន្លែងកោះកណ្តាលសមុទ្រ ។ សូមព្រះនាងយាងទៅទូលព្រះចៅវិញថា ត្រូវការសំពៅម្តែហើយផុតសុទ្ធតែទំនិញយ៉ាងល្អៗ ។

ព្រះពជធីតា ក៏ស្តេចទ្រង់យាងទៅក្រាបទូលព្រះចៅថា: បពិត្រព្រះអង្គដ៏ទ្រង់ព្រះបុណ្យចារើ! សេចក្តីបង្គាប់របស់ទ្រង់ទាំងប៉ុន្មាន ខ្ញុំលព្រះបង្គំនឹងបំពេញថ្វាយ ប៉ុន្តែសូមទ្រង់ប្រទានសំពៅម្តែ នឹងមាសច្រាក់យ៉ាងច្រើន ព្រមទាំងទំនិញទំនិញជាក់យកទៅផង ។

ព្រះចៅឆ្លើយថា: តាមតែឯងធ្វើដូចម្តេចក៏ដោយ ឲ្យតែនាំនាងអ៊ីឡេណា - សិម្ប៉ាណាបានមកឲ្យយើង ។

មិនយូរប៉ុន្មានសំពៅក៏ធ្វើបានស្រាម ហើយផុតសុទ្ធតែទំនិញយ៉ាងមានដំឡៃ ។ ព្រះពជធីតានឹងសុរាបការឡើងគង់លើសំពៅមួយដែលល្អជាងគេ ហើយនាំគ្នាចេញទៅ ។ គ្មានឲ្យល់គ្មានរលកអ្វីអាចបញ្ឈប់ដំណើរនៃព្រះនាងបានទេ ហើយខាងក្រោយដែលបានបើកសំពៅអស់ច្រើនសប្តាហ:ទើបបានដល់កោះយក្ស ។ ព្រះពជធីតាយកស្បែកដើង

មួយគូ ប៉ាកខ្សែសយមាសលំអដោយត្បូងពេជ្រ ទ្រង់គាន់ចេញយាង
ទៅតាមឆ្នេរសមុទ្រជាមួយនឹងសុរាបតា ។ មួយស្របក់ ព្រះនាង
ទតព្រះនេត្រឃើញប្រាសាទយក្សនៅអណ្តែតលើព្រះធរណីវិលបាន គឺ
ប្រាសាទនោះបែរមុខទៅរកតែព្រះអាទិត្យ ដូចជាមេដែកតម្រង់ទៅតែ
ទិសឧត្តរ ហើយព្រះនាងទ្រង់យាងចំពោះប្រាសាទនោះ ។ កំពុងតែ
ស្តេចទៅ ព្រះនាងបានដួមនឹងបរិចារិកាបីនាក់របស់យក្ស ដែលឲ្យនៅ
ចាំថែរក្សានាង អ៊ីឡេណា - សិម្ប៉ាណា ។ ស្រីទាំងបីលុះបានឃើញ
ស្បែកដើងល្អអស្ចារ្យ ក៏សំឡឹងមើលមិនដាក់ភ្នែក ។ ព្រះពជធីតាតាំង
ខ្លួនជាឈ្មួញសំពៅរង្វេងផ្លូវកន់សមុទ្រ ។

នាងស្រីបំរើ ៣ នាក់ទៅនិយាយប្រាប់ម្ចាស់ក្សត្រីអំពីវត្ថុដែលរាបាន
ឃើញ ។ ចំណែកនាងអ៊ីឡេណា - សិម្ប៉ាណា គ្រាន់តែក្រឡេកឃើញ
ឈ្មួញពីព្រះសីហបញ្ជរ ស្រាប់តែរំភើបក្នុងដើមទ្រូង មិនដឹងជាមាន
ហេតុអ្វី ហើយនាងហាក់ដូចជាសប្បាយចិត្ត ដោយគិតឃើញថា
ប្រហែលខ្លួននាងបានរួចចេញពីកណ្តាប់ដៃយក្សជាមិនខាន ព្រោះយក្ស
មិននៅ ដោយសារនាងបានបញ្ជូនវាឲ្យទៅរកពួកមេសេះមកឲ្យនាង ។

កណ្ឌទី ៩

ឧកញ៉ាវិបុលរាជសេនា ឆ្លូ-កន ប្រែរៀបរៀង

(តទៅ)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាជវរៀងបើបានអាន
ធំងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ចូតូបានឮក៏សើចហើយតបថា "លីចុ៉ាំនោះជាមនុស្សមិនចេះគិត កាលណាឡើយនឹងយកទាហានទៅបង្កប់នៅទីនោះ, យើងដឹងថា ឥឡូវនេះលីចុ៉ាំឲ្យលីហងនឹងស៊ីឡាន់ផ្តួទាហានទៅរក្សាស្រុកគុនដីរ៉ា ខ្លួនលីចុ៉ាំឯងទុលទ័ពទៅរក្សាស្រុកចាក់អៀង, ដូច្នេះយើងត្រូវបញ្ជូនចោយិនឲ្យលើកទាហានជាច្រើនទៅឡោមព័ទ្ធស្រុកគុនដីរ៉ាជាមុន" ថាហើយក៏លើកទាហានទន្ទ្រានទៅតាមច្រកភ្នំថៃសាន់ ។

តាន់កុងដឹងដូច្នោះក៏និយាយនឹងលីចុ៉ាំថា ចូតូស្រួតលើកទាហានតមកដោយកំឡាំងគ្រាចរឹង ខ្ញុំដឹងថាទាហានទាំងនោះ មុខជាហត់នឿយ

ខ្ញាំងណាស់ សុំឲ្យលោកបង្ខំលើកទាហានខាងយើងចេញទៅទទួលតទល់ជាធាប់ យើងគង់នឹងបានចំណាប់ឈ្នះចូឆូជាប្រាកដ, បើបង្អង់ឲ្យយូរទាហានបាត់ទៀយហត់ទៅវិញ យើងនឹងផ្ចាញ់បានដោយកម្រណាស់ ។ លីប៉ាតបថា មុនយើងនឹងតាំងខ្លួន យើងមានគ្រឹមតែខ្លួនមួយហើយនឹងសេះប៉ុណ្ណោះ លុះបានធ្វើការសង្គ្រាមតាមលំដាប់រៀងមក ពាល់តែបានសេនាទាហានដល់ប៉ុណ្ណេះហើយ មិនត្រូវគិតគោតញាញើតចូឆូនោះសោះឡើយ ទោះបីចូឆូនឹងមកតាំងបន្ទាយឲ្យមាំមួនយ៉ាងណា យើងក៏ត្រូវតែពុះពារទំលាយវាយយកឲ្យបាន ។

ខណៈនោះ ចូឆូបានលើកទ័ពមកដល់ស្រុកប៉ាក់អៀង ហើយឲ្យតាំងបន្ទាយពាយសេនាទាហានជាមាំមួនបានស្រេចគាំងអស់ ។ លុះព្រឹកឡើងពួកទាហានចេញទៅដំរៀបនៅមុខបន្ទាយ ចូឆូជានាយជិះសេះចេញទៅឈរនៅមុខទាហាន បានក្រឡេកឃើញលីប៉ានឹងទាហានឯក ៨ នាយ ឈរអមគាំងឆ្វេងស្តាំគឺឈ្មោះតៀវលៀវ ១, ចុងចា ១, ឡាន់ប៉ង ១, សោស៊ុន ១ សេងលៀម ១, ប៊ុយសុក ១, សុងហៀន ១, ហោសេង ១ នឹងទាហានឡៃវជាច្រើនហ៊ោកញ្ជ្រៀវគឹកកងចេញមក ។ ចូឆូយកវាត់សេះចង្អុលមុខលីប៉ាហើយថា ខ្លួនហ៊ានឹងយើងនឹងបានមានទោសទាស់ព្រោះអ្វីក៏ទេ ហេតុម្តេចខ្លួនក៏លើកទាហានមកវាយយកស្រុករបស់យើងដូច្នេះ ។

លីចោ"ឆ្លើយថា "ស្រុកទាំងអម្បាលនេះ ជារបស់ព្រះមហាក្សត្រិយ៍ ក៏ពុតដូចជារបស់មនុស្សប្រុសស្រីទាំងពួង. ដែលនៅលើផែនដី បើអ្នកឯណា មានបុណ្យវិន្ធីខ្លាំងពូកែជាងគេ ត្រូវតែគ្រប់គ្រងស្រុកនីមួយៗបានដូចគ្នា, ហេតុម្តេចអ្នកមកថា ស្រុកនេះជារបស់អ្នក អ្នកគ្មានសេចក្តីអៀនខ្មាសទេឬ?" ថាហើយក៏ប្រើចុងចាំឲ្យចេញទៅចាប់ចូត្ ។ ចូត្ឲ្យងាក់ជនចេញមកតយុទ្ធគ្នានឹងចុងចាំបាន ៣០ស្នែត ។ ហែហ្គុនបរសេះចេញទៅជួយងាក់ជន តៀវលៀវក៏ចេញមកតយុទ្ធនឹងហែហ្គុន ។ តាហាន ៤ នាយប្រយុទ្ធគ្នា ជាអង់អាចមិនបានចាញ់ឈ្នះ. លីចោ"ឃើញដូច្នោះខឹងណាស់ បរសេះកំហែងទៅតនឹងហែហ្គុន ងាក់ជន, ឯហែហ្គុនឆ្លងងាក់ជនតស៊ូនឹងលីចោ"មិនបានកំញាក់សេះថយរត់, លីចោ"ស្ទុះដេញប្រយុទ្ធពីក្រោយ តាហានចូត្បែកខ្ចាត់ខ្ចាយអស់ទៅ លីចោ"ញាក់សេះត្រឡប់មកវិញ ។ ចូត្ឃើបប្រាប់ឆន៍លីចោ"ក៏ថយទ័ពត្រឡប់ចូលបន្ទាយ ហើយប្រឹក្សានឹងសេនាតាហានទាំងពួងថា លីចោ"កំឡាំងខ្លាំងពូកែណាស់ ឆន៍រកអ្នកឯណាតស៊ូមិនបាន ។

អ៊ីគីមឆ្លើយថា ខ្ញុំបាទឡើងទៅលើកំរើញបន្ទាយលីចោ"ទិសខាងលិចមានតាហានស្តើងណាស់, ដែលលីចោ"ច្បាំងឈ្នះចូលទៅគ្រានេះមុខជាឆន៍មានចិត្តកំរើបមើលងាយ, តាហានលីចោ"គង់ឆន៍ប្រមាទមិនបានរក្សាបន្ទាយឲ្យមាំមួនទេ; រោយយប់នេះ សុំឲ្យលោកលើកតាហានចូល

ប្អូនយកបន្ទាយលីចោ" គង់នឹងបានដោយងាយ ។ ចូរឆ្លៀតយល់ព្រមផង
ទើបចាត់ចោហង ១ លីតៀន ១ លីយ"យ ១ អ៊ីគីម ១ តៀនអ៊ុយ ១
នឹងទាហានឡៃប្រហែល ៤ ម៉ឺនត្រៀមទុកជាស្រេច ។

ឯលីចោ"កាលត្រឡប់ទៅក្នុងបន្ទាយ បង្គាប់ឲ្យរៀបចំលៀងសេនា
ទាហាននឹងឲ្យបំណាច់រង្វាន់តាំងពួងតាមសមគួរ ។ គាន់កុងនិយាយនឹង
លីចោ"ថា ដែលចូរឆ្លៀតទៅនោះ មុខជានឹងមានសេចក្តីគិតត្រឡប់
មកធ្វើការសងសឹកវិញជាប្រាកដ, ខ្ញុំឃើញថាបន្ទាយទិសខាងលិចមាន
ទាហាននៅស្តើងស្តួចណាស់ សុំឲ្យប្រមូលទាហានទៅបំពេញឲ្យមាំមួន
ឡើងវិញ ។ លីចោ"តបថាចូរឆ្លៀតទៅពីព្រោះចាញ់ប្រៀបយើង
ប្រហែលមិនគិតមកប្អូនបន្ទាយយើងវិញទេ ។ គាន់កុងថាលោកកុំអាលទុក
ចិត្ត ដ្បិតចូរជាមនុស្សមានសតិប្រញាក់ឆ្លៀតក្នុងការសង្គ្រាមណាស់,
ខ្ញុំឃើញថាមុខជានឹងលើកទ័ពមកប្អូនបន្ទាយជាប្រាកដ ។ លីចោ"ឃើញ
ត្រូវផង ទើបចាត់ឲ្យកោស៊ុន ១ ង៉ុយសុក ១ ហោសេង ១ នាំយក
ទាហានជាច្រើនទៅរក្សាបន្ទាយទិសខាងលិចជាយ"ង៉ាមួន ។

លុះដល់ពេលកណ្តាលយប់ប្រហែលជាមពីរចូយ ចូរឆ្លៀតលើក
ទាហានដែលត្រៀមទុកនោះទៅព័ទ្ធផ្លូវព័ទិសខាងត្បូង ចូលទៅជិតដល់
បន្ទាយហើយក៏ឲ្យវាយព័ទ្ធជុំវិញ ហើយហោរត្រសុកទៅលុកកាច់យក
បន្ទាយនោះចុង ។ ទាហានលីចោ"ដែលនៅក្នុងបន្ទាយ ក៏បែកឆ្ងាយ

រត់ចេញទៅ; ឯង៉ុយសុក ១ ហោសេង ១ គោស៊ុន ១ ដែលលីប៉ោឲ្យ
នាំតាហានទៅរក្សាបន្ទាយនោះ បានលើកទៅដិតបន្ទាយកងពេលនោះ
លុះឃើញតាហានចូធួបួនយកបន្ទាយបាន កំនឹកភ័យខ្លាចលីប៉ោនឹងយក
គោសទុស ទើបទំបញ្ជុះពុះពារចម្បាំងយកបន្ទាយបានមកវិញ ។ ចូធួ
ឃើញដូច្នោះ ក៏លើកតាហានគ្នាខាងក្រៅ; សន្ធឹកតាហានតាំងសង
ខាងដែលប្រឡូកចម្បាំងគ្នាកងពេលយប់នោះ ហាក់បីដូចឲ្យលំព្រុះសង្ឃក
កក្រើកតាំងដែនពសុធាគឹកកងរំពងគាល់តែក្ដីស្ងាត ។

លីប៉ោបានដឹង ក៏តាំងលើកតាហានស្រែតតម្រង់ទៅបន្ទាយខាង
ត្បូងទៀត ។ បំរើសេះនាំសេចក្ដីនោះទៅប្រាប់ចូធួថា បានឃើញ
លីប៉ោលើកតាហានមកជិតនឹងដល់ហើយ ។ ចូធួបានឮដាក់ក៏តក់ស្លុត
ក្នុងចិត្ត គិតនឹងលើកតាហានត្រឡប់បែរមុខទៅក្រោយរត់បណ្ដាយទៅ។
គោស៊ុន ង៉ុយសុក ហោសេង ឃើញដូច្នោះក៏លើកតាហានបង្អុះតាម
ពីក្រោយដូចគេរួបប្រសព្វគ្នានឹងទ័ពលីប៉ោពីមុន តាំងតែគ្រលុកប្រកាប់
គ្នាទៅវិញទៅមក ។ ចូធួក្រែអ័គ័មនឹងងាក់ជិនចេញតនឹងទ័ពលីប៉ោ
ដោយអង់អាច, តែអ័គ័មនឹងងាក់ជិនកម្ងាំងតិច តស៊ូនឹងលីប៉ោពុំបាន
ក៏ញាក់សេះស្ទុះរត់ត្រឡប់ក្រោយទាំចូធួគេចបណ្ដាយទៅទិសឯដើង ។
លីប៉ោស្ទុះឡើងតាមចាក់កាប់សម្លាប់តាហានចូធួស្លាប់តរលើគ្នា; ឯចូធួ
អ័គ័ម នឹងងាក់ជិន ក៏លើកតាហានរត់ទៅដល់ដើងកុំ ១ ខ្លួលជួបនឹង

តៀវលៀវ ចោចា" លើកទ័ព ២ កង មកវាស់ស្អាត់ពីមុខ; ចូឆូកឹង្យចោហង នឹងលីយ"យាចេញតយុទ្ធគ្នា នឹងតៀវលៀវ ចោចា"យ៉ាងម៉ាមួន; ចោហង លីយ"យតស៊ូមិនឈ្នះក៏ញាក់សេះថ្យាសថយក្រោយ នាំចូឆូនឹងទាហាន រត់លៃបណ្តាយទៅទិសឯត្បូង ទទួលប្រទះនឹងឡាន់ប៉េង ចោសេង សេងលៀម សុងហៀនទាំង ៤ នាក់ លើកទាហានជា ២ កងវាស់ស្អាត់ជាប់; ចូឆូកឹបឆ្កឹកងទ័ពចូលប្រកាប់គ្នាជាច្រឡំបល់ ចូឆូយល់ថាកម្លាំងថយអន់ណាស់, ទ័ពលីចោ"ព័ទ្ធស្អាត់ដុំវិញចេញពុំបាន ចូឆូក៏ខំសុះបំពានរួចជាមួយនឹងទាហាន ៥ នាក់ លុះដល់ទៅដើងកុំមួយ ឮសូរសំឡេងផាវលើកុំ ចូឆូក្រឡេកមើលទៅឃើញទាហានចាញ់ឆូតម្រែងមកព្រួញហាក់ដូចគេចាចសាច, ចូឆូរឹតតែខ្លាចញញើត ក៏ញាក់សេះត្រឡប់មកវិញ ពួកទាហានលីចោ"តាមដេញឡោមព័ទ្ធដុំវិញចូឆូ។ ភ័យណាស់ក៏ស្រែកថា នរណាមានកំឡាំង ចូរជួយប្រឹងយកអាយុយើងផង ។ តៀនអ៊ុយឮហើយក៏ថា: "លោកកុំភ័យចាវម្ភសុំខ្ញុំជួយ" ហើយក៏លោតចុះពីលើសេះ យកទួនផ្លែ ២ ត្បាត់កង់ក្លៀកហើយកន្ត្រាក់យកលំពែងឮយកាន់ទុកប្រហែល ១៥ ផ្លែ ទើបបង្គាប់ទាហាន ៥ នាក់ដែលមកជាមួយផងនោះថា "បើឃើញពួកសត្រូវមកជិតប្រហែល ៥ ព្យាម ចូរជ្រាប់យើង" ហើយក៏នាំមុខសេះចូឆូចាញ់ឆូតទៅវិញ ។ ទាហានលីចោ"លើកតាមមកពីក្រោយប្រហែល ២០ នាក់ ពួកចូឆូក៏ស្រែកជ្រាប់

តៀនអ៊ុយថា សត្រូវតាមមកដិតប្រហែល ៥ ញាមហើយ ។ តៀនអ៊ុយ
បានឮកំពង់ផង្អដ៏ហើយយកព្រួញបាញ់ ទៅត្រូវខាហានសត្រូវធ្លាក់ពីលើ
សេះស្លាប់ ។ តៀនអ៊ុយក៏ចេះតែបាញ់ពាល់តែអស់ព្រួញពីដៃត្រូវសត្រូវ
គប់ព្រួញ, ខាហានដែលលើកតាមពីក្រោយទៅសល់ប្រហែល ៤ - ៥
នាក់ក៏រត់ត្រឡប់ថយក្រោយទៅវិញ ។ តៀនអ៊ុយក៏តឿនសេះនាំបូធូនឹង
រត់ចូលទៅកងបន្ទាយ លុះទៅដល់កណ្ដាលផ្លូវដួនពេលថ្ងៃល្ងាច បានឮ
សំឡេងខាហានស្រែកហៅតាមមកខ្លាំងជាច្រើន ។ បូធូក្រឡេកទៅ
ក្រោយឃើញលីចុ"បរសេះសុះមកមុខខាហាន ក៏មានសេចក្ដីកិតក័យខ្លាំង
ណាស់ ។ ឯខាហានដែលតាមមក ៥ នាក់នោះ ឮយហាត់អស់កំឡាំង
ពាំងមនុស្សពាំងសេះ ក៏នាំគ្នាសុះរត់ព្រាត់បែកគ្នាអស់ទៅ នៅតែតៀន
អ៊ុយនឹងបូធូ ២ នាក់ ខ្លួលក្រឡេកទៅឃើញហែហ្មុខនលើកខាហាន
ចេញមកពីម្ខាងដួបនឹងបូធូ ។ ហែហ្មុខនក៏ចូលច្បាំងកំងកុតនឹងលីចុ"
ពាល់តែព្រលប់ ; យប់នោះ មានបណ្ដាលព្យុះខ្យល់វាល់ធ្លាក់ភ្លៀងធំ
លីចុ"លើកខាហានត្រឡប់ទៅវិញ ។

ឯបូធូនាំហែហ្មុខននឹងតៀនអ៊ុយចូលបន្ទាយ ហើយយកប្រាក់មាស
ឲ្យជាបំណាច់ផ្ងាន់តៀនអ៊ុយជាច្រើន ។ លុះព្រឹកឡើង គាន់កុងនិយាយ
នឹងលីចុ"ថា ទៅហ្ងាយស្រុកចុ"ក់អៀងនោះរត់ចាត់ទៅហើយ, ក្នុងស្រុក
នោះមានសេដ្ឋីមាក់ឈ្មោះតៀនស៊ីជាមនុស្សស្លូតត្រង់ នឹងជាទីរាប់អាន

ដល់បណ្តាអ្នកស្រុកទាំងពួង, បើតៀនស៊ីនធីនិយាយការអ្វី អ្នកស្រុក
ក៏ដឿស្តាប់គ្រប់គ្នាទាំងអស់ សុំឲ្យលោកហៅយកខ្លួនតៀនស៊ីមកនិយាយ
ហើយឲ្យមានសំបុត្រទៅដល់ចូឆូថា លោកមានដំណឹងដោយយកបាន
ស្រុកប៉ាក់អៀង ឥឡូវនេះកោស៊ីនទៅរក្សាស្រុកនោះ ឯខ្លួនលោកនឹង
លើកទ័ពទៅវាយយកស្រុកលីយ៉ុងវិញ ឲ្យចូឆូលើកទាហានទៅចូនយក
ស្រុកប៉ាក់អៀងចុះ លោកត្រូវឲ្យតៀនស៊ីទៅឃុំរក្សាបណ្តាអ្នកស្រុកទុក
ជាកងទ័ពសន្ធប់ ឯខ្លួនយើងត្រូវលបលើកទាហានចូលទៅនៅក្នុងស្រុក
ប៉ាក់អៀង ហើយយកទុសទៅតរុកនៅមុខទ្វារទាំង ៤ ទិសឲ្យស្រែច
បើឃើញចូឆូលើកទ័ពមកដល់ យើងត្រូវដុតភ្លើងឲ្យឆេះឡើងកណ្តាល
ស្រុក ដុតទាំងគំនរទុសទាំង ៤ ទិសឲ្យឆេះស្មើគ្នា គេះបីចូឆូនឹងមាន
សេចក្តីគិតយ៉ាងណា ក៏ឃើញថាគង់នឹងមិនរួចពីដៃយើង ។ លីចោ៉ាបាន
ស្តាប់ក៏ចាប់ចិត្តគិតឃើញត្រូវក៏ហៅតៀនស៊ីចេញមក ហើយនិយាយ
ល្បួងលួងលោមយកចិត្តតាមគំនិតគាន់កុងពន្យល់នោះ ។ តៀនស៊ីក៏ព្រម
ធ្វើតាម, លីចោ៉ានឹងតៀនស៊ីក៏នាំគ្នាត្រឡប់ចូលទៅក្នុងស្រុក ហើយធ្វើ
សំបុត្រចាត់អ្នកបំរើស្និទ្ធយកទៅឲ្យចូឆូកងជម្លោយ ។

ចូឆូទទួលយកសំបុត្រទៅឃើញសេចក្តីថា ខ្ញុំបាទឈ្មោះតៀនស៊ី
ដំរាបមកលោកចូឆូបានជ្រាប ដែលលីចោ៉ាជាមនុស្សគាត់លើកទាហាន
ទៅវាយស្រុកប៉ាក់អៀងធ្វើអន្តរាយដល់បណ្តាពួកស្តូ ក្នុងស្រុកឲ្យបាន

សេចក្តីទុក្ខក្តៅក្រហាយនោះ ឥឡូវនេះលីចាំ"មានសេចក្តីកំរើបលើកទាហានទៅវាយស្រុកលីយ៉ុង" ហើយឲ្យកោស៊ុន ហោសេង៉នៅគ្រប់គ្រងរក្សាស្រុកនុ៎ះ សូមឲ្យលោកលើកទាហានចូលទៅបន្ទាយកស្រុកនេះជាបញ្ចាប់ចុះ ខ្ញុំបាទនឹងដោតទង់សរទុកជាសំគាល់ ហើយនឹងលើកពួកអ្នកស្រុកចូលគ្រលុកជាទីពឹងជាប់ពីមុខ ឃើញនឹងបានស្រុកចាំ"ត់អៀងដោយងាយ ។

ចូធូបានឃើញសេចក្តីសំបុត្រដូច្នោះ ក៏មានសេចក្តីស្មោះសរអរមិនមានសន្ទុះសង្ស័យ ទើបយកសំពត់មានដំរៀឲ្យជាបំណាច់ផ្ងារអ្នកកាន់សំបុត្រ ហើយឲ្យទៅប្រាប់តៀនស៊ីវិញថាយើងនឹងធ្វើតាម ។ អ្នកបំរើក៏លាគ្រឡប់វិលទៅវិញ ។ ចូធូនិយាយថា "យើងខ្ញុំទាហានគ្រានេះក៏ជាល់តំនិតសោះ លុះឃើញតៀនស៊ីឲ្យសំបុត្រមកយើងដូច្នេះ ឧបមាបីដូចក្អែកងងឹត ហើយមានគេនាំបង្ហាញផ្លូវឲ្យដើរទៅបាន" និយាយហើយក៏ឲ្យចាត់ចែងទាហានត្រៀមទុក ។

ឡៅហ៊ូនិយាយថា លីចាំ"នោះមិនជាអ្នកចេះគិតគូរក៏មែនហើយតែថាបានធ្វើជាមេទ័ពធំមានទីប្រឹក្សាច្រើន តាំងតាន់កុងក៏មានសតិប្បញ្ញាដែលលោកនឹងដឿីស្តាប់ពាក្យតៀនស៊ុ ហើយលើកទាហានទៅធ្វើការនោះបើគួរទៅក៏ទៅចុះ តែឲ្យមានជំរិះគិតប្រយ័ត្នការឲ្យមាំមួន បើនឹងលើកទាហានទៅត្រូវចែកជា ៣កង; ឯ២កងឲ្យបំរុងទុកត្រៀស្រុកជាទីពឹង

ស្ងួតបាត់, មួយកង៏ទៀតឲ្យលើកចូលទៅធ្វើការជាមួយនឹងខ្លួន ហើយឲ្យ រាំង៏ស្តាប់ដំណឹង៏ល្អអាត្រកល់សិន បើឃើញមិនពិតដល់លោកក៏ឲ្យគាហាន ១ កង៏នោះចេញមកវិញ ។ ចូឆូបានស្តាប់ហើយក៏យល់ព្រមឯង៏ ទើប ចាត់គាហានចែកជា ៣ កង៏ ហើយលើកចេញទៅដល់ស្រុកចាំក់អៀន ត្រម្បែកទៅឃើញទង់សដោតនៅមាត់ទ្វារខាង៏លិច ជាសំគាល់ដូចពាក្យ តៀនស៊ីថា ។

លុះដល់ពេលពាក់កណ្តាលអាធ្រាត្រ ហោសេង៏ក៏លើកគាហាន ចេញមកជាកង៏មុខ កោស៊ុនជាកង៏ក្រោយ បើកទ្វារទិសឯកើតចេញទៅ តបាំង៏នឹង៏កង៏ទ័ពចូឆូ ។ ឲ្យតៀនអ៊ុយចេញមកតទល់គ្នា ទឹង៏ហោសេង ជាពន្ធឹក ហោសេង៏បែកទ័ពត្រឡប់ថយក្រោយ កោស៊ុនក៏នាំគ្នាថយ បណ្តាយចូលបន្ទាយវិញ តៀនអ៊ុយបរបណ្តាញសេះតាមទៅទល់នឹង ដើង៏កំពែង ទទួលអ្នកបំរើតៀនស៊ីកាន់សំបុត្រចេញទៅខាង៏ទ្វារទិសឯលិច យកទៅឲ្យចូឆូ។ លាមើលឃើញសេចក្តីថា ពេលអាធ្រាត្រយប់នេះ ខ្ញុំបាទ តៀនស៊ីនឹង៏បើកទ្វារទិសឯលិចចេញបាំង៏ បើបានឮសំឡេង៏គង៏ឃ្មោះ ឲ្យ លើកគាហានបង្រិះចូលទៅជាប្រញាប់ ។ ចូឆូត្រែកអរណាស់ ក៏ចាត់ឲ្យ ហៃហួនាំគាហានបង្ការខាង៏ស្តាំ ឲ្យចោហង៏រៀបបញ្ជាំជួយខាង៏ឆ្វេង ។ ចូឆូនឹង៏ហៃហួអៀន លីតៀន ង៉ាក់ជិន · តៀនអ៊ុយលើកគាហានជាកង៏ កណ្តាល, ដល់ពេលអាធ្រាត្រខែង៏ងឹត ស្រាប់តែឮសំឡេង៏គង៏ឃ្មោះ

ខាងកន ឃើញគ្មានឯលិចបើកចំហ ។ ចូធ្លូគិតនឹងឲ្យលើកគាហានចូលទៅ, លើតៀនឃាត់ចូធ្លូថា លោកជាមេទ័ពធំមិនត្រូវបង្ខំលើកគាហានចូលទៅខ្លួនឯងតែម្តងទេ ត្រូវតែឲ្យខ្ញុំបាទទទួលអាសាចូលទៅបានហើយ បើឃើញការណ៍ល្អសិមលោកលើកចូលទៅចុះ ។ ចូធ្លូតបថា ដែលមិនឲ្យយើងចូលទៅជាមួយផងនោះ ឃើញថាគាហានតាំងអស់មិនស្រុះចិត្តគ្នាធ្វើការទេ ។ ចូធ្លូបរសេះបង្កើះចូលទៅមុខគាហាន រហូតដល់ពាក់កណ្តាលស្រុក មិនឃើញមានមនុស្សដើរទៅមកសោះ កំតក់ស្ងួតរន្ធត់មហិមា ឃើញថាជាការណ៍តលុចុយ ទើបស្រែកហៅគាហានតាំងឲ្យស្រួតត្រៅចេញទៅក្រៅវិញ, ស្រាប់តែឮសំឡេងផារនឹងគង ឃ្មោះស្រែកហ៊ោរំពងអឺងកងដុំវិញ ភ្លើងឆេះឡើងគ្រប់ទ្វារទាំង ៤ ទិស ពលឆេះផ្ទះសំបែងអ្នកស្រុកពេញទីបរិវេណក្នុងដូចថ្ងៃ ។

ចោចា"កំបរសេះស្ទុះទៅដេញតាមកងទ័ពចូធ្លូពីទិសឯកើត, តៀវលៀវបរសេះស្ទុះទៅដេញកាប់កងទ័ពចូធ្លូពីទិសឯលិចរួបប្រសព្វគ្នា ។ ចូធ្លូឃើញចា្បស់ក័យណាស់បរសេះរត់តម្រង់ទៅទិសឯជើង ប្រទះទ័ពឆ្មាំប៉ើង ចោសេង បរសេះដេញគាហានបំពានមកស្ទុះពីមុខ, ចូធ្លូបរសេះត្រឡប់រត់តម្រង់ទៅទិសឯត្បូង ប្រទះទ័ពកោស៊ុន ហោសេង ចេញមកស្ទុះពីមុខទៀត ។ តៀនអ៊ុយគាមចូធ្លូទៅ ឃើញដូច្នោះក៏បរសេះចំលុះទៅប្រយុទ្ធគ្នានឹងគាហានកោស៊ុន ហោសេង ចេញទៅខាងក្រៅ

ស្រុកបាន លុះត្រឡែកមើលមកគ្រោយមិនឃើញចូនូ កំព័យស្ទុះរិល
ត្រឡប់ចូលទៅដល់ខាត់ទ្វារ ជួបនឹងលីតៀនសួរថា អ្នកបានឃើញ
ចូនូដែរឬទេ? ។ លីតៀនឆ្លើយថា ខ្ញុំក៏តាមរកដែរ តែមិនដឹងចូនូ
នៅត្រង់កន្លែងណា ។

តៀនអ៊ុយថា "អ្នកត្រូវខំប្រឹងស្តាប់ប្រមូលគោហានរបស់យើង ដែល
រត់ចេញទៅបាននោះកុំឲ្យបែកខ្ញែកគ្នា ខ្ញុំនឹងរិលទៅរកចូនូ" ថាហើយក៏
ស្ទុះបង្អុរគោហានលីចោ"ចូលទៅស្វែងរកចូនូក្នុងស្រុក លុះមិនជួបប្រទះក៏
ពុះពារគោហានចេញទៅដល់ស្មាមភ្លោះកំពែងស្រុក ជួបនឹងង៉ាក់ដំនឿ
សួរតៀនអ៊ុយថា ជួបប្រទះនឹងចូនូឬទេ? ។ តៀនអ៊ុយឆ្លើយថា ខ្ញុំស្វែង
រក ២-៣ ត្រឡប់ហើយមិនជួបប្រទះសោះ ។ ង៉ាក់ដំនបបួលតៀនអ៊ុយ
ត្រឡប់រិលទៅដល់ទ្វារស្រុក គោហានលីចោ"ដែលនៅលើសែនយកក្តៀង
គប់អុជឈួនទម្លាក់ចុះមក, ង៉ាក់ដំនភ័យស្ទុះក៏ញាក់សេះថយចេញមកវិញ
ឯតៀនអ៊ុយបរសេះស្ទុះទំលាយក្តៀងចូលទៅបានស្វែងរកចូនូក្នុងស្រុក ។

ឯចូនូកាលក្លាត់បែកចាកគ្នាពីតៀនអ៊ុយនោះ កំបរសេះពុះទំលាយ
ក្តៀងរត់ទៅផ្លូវទិសឯដើង ជួបប្រទះនឹងលីចោ"កាន់ខ្លួនបរសេះមក ចូនូខ្លាច
ក៏លើកដៃធ្វេងឡើងចាំងមុខ ដៃស្តាំកាន់បង្ហៀរសេះបរពុះទំលាយក្តៀង
ទៅដល់មុខលីចោ" ។ ឃើញមិនច្បាស់ស្មានថា គោហានរបស់ខ្លួនក័យក
ខ្លួនគោះក្បាលចូនូហើយសួរថា? ឃើញចូនូនៅខាងណា? ។ (មាន)

ភាគទី ២

សម័យនគរធំ

ឧកញ៉ាទេពពិទូរ ឈឹម - ក្រសែម រៀបរៀង

(តមក)

មានសិលាចារឹកហៅថា: "ប្រកាសពេងព្យាចាល" សំដែងថា ព្រះបាទជយវរ្ម័នទី ៧ ទ្រង់បានសាងមន្ទីរព្យាបាលពេគ សម្រាប់ព្យាបាលពេគសាធារណជន ចំនួន ១០២ អន្លើ ។ មន្ទីរព្យាបាលទាំងនេះតាំងនៅរៀងពាយតាមបរិវេណក្រុង ទីដែលមាននៅតាមវិថីត្រកៀកខ្លះផង ។ គេបានស្រាវជ្រាវរកទីតាំងមន្ទីរព្យាបាលអំបាលនេះ តែមិនប្រទះឃើញស្នាមសោះ ទើបសន្និដ្ឋានថា ប្រហែលជាធ្វើដោយឥដ្ឋឬគ្រឿងឈើបានជារលាយបាត់បង់អស់ទៅ ។ មន្ទីរព្យាបាលទាំងនេះនៅក្រោមសេចក្តីប្រសិទ្ធីរបស់ព្រះពុទ្ធ ១ អង្គទ្រង់ព្រះនាមថា តៃសជ្យគុរុ "គ្រូថ្មី" (១) ។ នៅក្បែរមន្ទីរព្យាបាលវិមានមានវិហាររបស់ព្រះពុទ្ធតៃសជ្យគុរុ គ្រប់អន្លើ ។

ប្រកាសរបស់មន្ទីរព្យាបាលនោះ ខាងដើមនមស្សការដល់ព្រះរតនត្រ័យ ទីបំ សរសើរព្រះបារមីរបស់ព្រះមហាក្សត្រិយ៍ ស្រែចហើយ

---

១ ព្រះពុទ្ធភៃសជ្យគុរុនេះ មានន៎ៅតែក្នុងគម្ពីរបស់គណៈ មហាយាន គេនិយមចាត់ព្រះគ្រូតែងប្រសិទ្ធីថ្នាំឲ្យដល់អ្នកមានជម្ងឺ, ទៅប្រទេសបិនឆិងទីបេត៌និយមកប់អាន ព្រះពុទ្ធនេះច្រើន ។

ទើបនិយាយអំពីកិច្ចការក្នុងមន្ទីរពេទ្យចាស់ភេតថា "មនុស្សទាំង ៤ ពួកអាច
នឹងចូលទៅឲ្យគេរក្សាភេតរបស់ខ្លួនក្នុងទីនេះបានគ្រប់ៗ គ្នា ; ទីនេះមាន
គ្រូពេទ្យ ២ នាក់ ក្នុងពេទ្យម្នាក់ៗ មានមនុស្សនៅក្រោមបង្គាប់ជាច្រើន
គឺប្រុសម្នាក់ស្រីពីរនាក់ ដែលត្រូវបានទីលំនៅក្នុងទីនោះ, នាយឃ្លាំង
ពីរនាក់ មានមុខការត្រូវចែកថ្នាំ, ចុងភៅពីរនាក់, អ្នកបំរើពីរនាក់
សម្រាប់រៀបដង្ហាយព្រះ អ្នកពាចាស់ភេត ១៤ នាក់ត្រូវចែកថ្នាំឲ្យអ្នក
ជម្ងឺ, ស្រី ៦ នាក់ ជាអ្នកបុកថ្នាំនឹងដាំទឹកក្តៅ, ស្រីពីរនាក់ទៀតសម្រាប់
បុកស្រូវ, រួមស្រីទាំងអស់ ៨ នាក់ ដែលត្រូវបានទីលំនៅក្នុងមន្ទីរពេទ្យចាស់
គឺកង ១ បន្ទប់ពីរនាក់, មនុស្សដែលត្រូវបានទីលំនៅកងពេទ្យចាស់រួម
ទាំងអស់ ៣២ នាក់ ។ នៅមានអ្នកបំរើ ៦៦ នាក់ទៀត ដែលនៅដោយ
ចេញសោហ៊ុយខ្លួនឯង រួមអ្នកទាំងនេះផង ត្រូវ ៩៨ នាក់ ។

អង្ករសម្រាប់ធ្វើគ្រឿងបូជា កំណត់ក្នុង ១ ថ្ងៃ ១ ចាំង, សល់ពីបូជា
ទាំងប៉ុន្មាន ត្រូវឲ្យទៅអ្នកជម្ងឺ ។ របស់ទាំងពួងដែលត្រូវបើកពីឃ្លាំង
ហួងកំណត់ក្នុង ១ ឆ្នាំ ៣ ដង ។ តែងនេះមានភាយឈ្មោះតែជាច្រើន
គឺទឹកឃ្មុំ ស្ករ ភស្សរ លូ គ្រឿងទេស តែឡាត់ភ្លៅ ឡាវហាវ ភ៉ាន់ស៊ុយ
ផាក់ដី ក្រាញ ខ្ញី សំបោរលែង ឆ្អិបទឹកខ្ទះធ្វើពីផ្លែពុត្រ; របស់ទាំង
នេះសុទ្ធតែវាល់ប្រគល់ឲ្យដោយទៀងទាត់ ។

សិលាចារឹកនៅប្រាសាទតាព្រហ្ម ក៏មាននិយាយដល់ការសាងមន្ទីរ
ពាចាស់ភេតទាំង ១០២ ក្នុងឆ្នាំ ព. ស. ១៧២៩ ទាំងមានភាយពាក់ព័ន្ធ

ផ្សេងៗ ដែលត្រូវប្រើក្នុងមន្ទីរពេទ្យបាលដែរ តែមានចំនួនទ្វេឡើងជាច្រើន គឺគុណជា ៣×១០២ ។ ដូច្នេះ យើញថា ក្រសួងពេគាតិបាលចាយក្នុង ១ ឆ្នាំ អស់ស្មើ ១១.១៨២ តោន ត្រូវគូមិតាំង ៨៣៨ សឹងមានមនុស្ស ៨១.៦៤០ ជាអ្នកចេញ, មន្ទីរពេទ្យបាលទាំងអស់ប្រើអស់: ល្ង ២.១២៤ គីឡូក្រាម, ក្រវាញ ១០៥ គីឡូក្រាម, គ្រាប់តែឡាត់ ៣.៤០១ គ្រាប់, ថ្នាំគ្រួន ៤៨.០០០ គ្រាប់, ថ្នាំបិទឬសដូងបាទ ១.៨៦០ ប្រអប់, របស់ឯទៀតក្រៅពីប៉ុន្មានមុខនេះ ដូចគ្នាក្នុងប្រកាសពេងពេទ្យបាលមុន ។

ការដែលព្រះបាទជយវរ្ម័នទី ៧ ទ្រង់ទំសាងមន្ទីរពេទ្យបាលច្រើនដល់ម្ល៉ឺះ ក្នុងប្រកាសពេងពេទ្យបាលមានសំដែងអំពីទឹកព្រះពជហ្ឫទ័យថា ទ្រង់ប្រឈួនដោយពេគរបស់បណ្តាពស្ត្រ ឆ្ងន់ជាងព្រះពេគផ្ទាល់ព្រះអង្គទៅទៀត, ទ្រង់មានព្រះពជហ្ឫទ័យ ពេញទៅដោយមេត្តាករុណា ដែលជាព្រហ្មវិហារធម៌, ទ្រង់ធ្វើអ្វីៗ ក៏ដើម្បីសេចក្តីសុខ-ចំរើនដល់លោកទាំងមូល ទ្រង់តាំងប្រណិធានថា បណ្តាសត្វទាំងឡាយដែលលិចលង់ក្នុងសមុទ្រគឺវដ្តសង្សារ សូមឲ្យខ្ញុំអាចស្រោចស្រង់បាន ដោយអំណាចបុញ្ញកិរិយាវត្ថុនេះ សូមឲ្យក្សត្រៃយ៍ទាំងឡាយគ្រប់ព្រះអង្គ កន្លងកម្ពុជប្រទេសដែលប្រតិព័ទ្ធដោយសេចក្តីល្អ ហើយដែលជាអ្នកជួយថែទាំគាំរក្សារបស់ដែលខ្ញុំកសាង, បានដល់នូវទីដែលផុតចាកទុក្ខដែលឥតជម្ងឺដំកាត់ ព្រមទាំងព្រះពជវង្ស ព្រះអគ្គមហេសី សេនាមាត្យនិងមិត្តសំឡាញ់រួមជាតិទាំងអស់ ។ នេះហើយជាឧត្តមគតិរបស់ព្រះមហាក្សត្រៃយ៍អ្នកគ្រប់គ្រងផែនដី ។

ការព្រះសាសនា – សាសនាក្នុងប្រទេសកម្ពុជាកាលនេះ មានទាំងសាសនាព្រាហ្មណ៍ទាំងព្រះពុទ្ធសាសនា ។ ឯព្រះពុទ្ធសាសនា មានទាំងលទ្ធិមហាយានទាំងលទ្ធិហីនយាន, តែលទ្ធិមហាយានរុងរឿងជាងលទ្ធិដទៃទាំងអស់ ។ ព្រះបាទជយវរ្ម័នទី ៧ នឹងព្រះអគ្គមហេសី ទ្រង់និយមរាប់អានលទ្ធិមហាយានធ្ងន់ជាងលទ្ធិទាំងពួង ទាំងពីព្រះអង្គទ្រង់ជ្រួតជ្រាបគតិធម៌ក្នុងលទ្ធិមហាយានយ៉ាងជ្រៅជ្រះ ដូចមានពោលមកខាងដើមខ្លះហើយ, ទ្រង់បានឧបត្ថម្ភព្រះពុទ្ធសាសនាឲ្យចំរើនរុងរឿងជាយ៉ាងខ្លាំង, ទ្រង់បានសាងថាវរវត្តស្ថានក្នុងព្រះពុទ្ធសាសនា ដូចយ៉ាងព្រះពុទ្ធរូបនឹងព្រះអាគមជាយ៉ាងច្រើន ។ មិនតែប៉ុណ្ណេះ ក្នុងគតិមហាយានមានសេចក្តីនិយមថា បុគ្គលរាល់រូបត្រូវតែកសាងថ្វាយជាពោធិសត្វ - ពុទ្ធភូមិគ្រប់ៗគ្នា ដើម្បីនឹងបានស្រោចស្រង់សត្វលោកដាក់ទៅត្រើយ គឺព្រះនិព្វាន ។ ចំពោះក្នុងរឿងនេះ ព្រះបាទជយវរ្ម័នទី ៧ អ្នកមានព្រះរាជហឫទ័យធំទូលាយ ទ្រង់ក៏បានសាងព្រះបារមីជាពុទ្ធភូមិ ទាំងបានសាងព្រះពុទ្ធរូបឆ្លងព្រះអង្គ ប្រតិស្ឋាននៅក្នុងប្រាសាទកណ្តាលក្រុង នឹងនៅឥដ្ឋខ្លះទៀត, ព្រះពុទ្ធរូបអង្គនេះជាព្រះពុទ្ធរូបធម្មតា គ្រាន់តែសំគាល់ថា "ព្រះឆ្លងព្រះអង្គ" ដោយសេចក្តី គឺថាព្រះបាទជយវរ្ម័នទី ៧ ទ្រង់តាំងព្រះអង្គជាព្រះពុទ្ធតាំងពីក្នុងបច្ចុប្បន្ននេះទៅ ។ លុះកាលក្រោយមកគេបានតែលក្ខណៈព្រះពុទ្ធរូបឆ្លង

ព្រះអង្គនុ៎ះ ទៅជាព្រះពុទ្ធរូបខ្មែរគ្រឿង គឺខ្មែរគ្រឿងជាព្រះពុទ្ធពាក់កណ្តាលជាព្រះរាជាពាក់កណ្តាល, គេហៅព្រះពុទ្ធរូបបែបនេះថា "ព្រះពុទ្ធរាជ", តែតាមពាក្យសាមញ្ញហៅថា "ព្រះពុទ្ធរូបខ្មែរគ្រឿង" ។ ដូច្នេះ គប្បីឲ្យដឹងថា ទំនៀមសាងព្រះពុទ្ធរូបមែបនេះក្នុងប្រទេសកម្ពុជាមានមកពីគ្រឹមរជ្ជកាលព្រះបាទជយវរ្ម័នទី ៧ នេះ ។ ចំណែកព្រះអគ្គមហេសីរបស់ព្រះអង្គ បានសាងព្រមទាំងបូជាថា "ព្រះនាងប្រជ្ញាបារមិតា" ។ ព្រះបរមរូប "នាងប្រជ្ញាបារមិតា" នេះ មានព្រះពុទ្ធរូបនៅត្រង់ព្រះនលាដៈជាសំគាល់ ។

មកក្នុងចុងរជ្ជកាល ព. ស. ១៧៤៤ (គ. ស. ១២០១) នេះ ខ្មែរបានតែងរាជទូត ឲ្យនាំព្រះរាជសារទៅសុំចងសម្ពន្ធមេត្រីភាពនឹងប្រទេសចិន, ប្រទេសចិនក៏បានទទួលជាសម្ពន្ធមេត្រីផង ។ ប្រទេសកម្ពុជាបានចងសម្ពន្ធមេត្រីភាពជាមួយប្រទេសចិន ពាក់ជាគ្រាទី ៦ ក្នុងរជ្ជកាលនេះ ។

ព្រះបាទជយវរ្ម័នទី ៧ គង់នៅក្នុងរាជសម្បត្តិបានត្រឹម ២៩ ឆ្នាំ បើរាប់ឲ្យពេញ ប្រមាណ ២៣ ឆ្នាំ ក្រាយប៉ុណ្ណោះ, តែព្រះរាជករណីយដែលខ្មែរបានធ្វើឲ្យជាប្រយោជន៍ដល់ប្រទេសជាតិ មានច្រើនជាបំផុតជាងព្រះមហាក្សត្រិយ៍ទាំងឡាយ ក្នុងអតីតកាល ។ ពោលចំពោះតែការធំសំខាន់ៗ គឺ:

១ – ខ្មែរកម្រាបអរិរាជសត្រូវ ទាំងក្នុងប្រទេសទាំងខាងក្រៅឲ្យរាបទាបទៅ ឲ្យកើតសាន្តត្រាណឡើងវិញ ។

២ – ទ្រង់បានពង្រីកព្រះពាជអាណាខេត្តដែលរួមចុះក្នុងរដ្ឋកាលមុនៗ នោះ ឲ្យធំទូលាយដល់ខ្នាតដើមស្មើក្នុងរដ្ឋកាលព្រះបាទសុរ្យវរ្ម័នទី ២ ។

៣ – ទ្រង់បានពង្រីកសាងកំពែងក្រុងនគរធំនឹងគូរដុំវិញ ឲ្យល្អមាំនឹងធំទូលាយជាងមុន ។

៤ – ទ្រង់បានសាងប្រាសាទសិលាទុកជាគ្រឿងលំអក្នុងប្រទេសច្រើនជាងក្នុងរដ្ឋកាលមុនៗ, ទ្រង់បានសាងមន្ទីរព្យាបាលពេគយ៉ាងធំៗ មានដល់ ១០២ អន្លើ គួរជាតម្រាប់ដល់អ្នកគ្រប់គ្រងប្រទេសទាំងឡាយគប្បីយកយ៉ាងតាម។

៥ – ទ្រង់ព្រមទាំងព្រះអគ្គមហេសី បានទំនុកបម្រុងព្រះពុទ្ធសាសនាក្នុងប្រទេស ឲ្យចំរើនឡើងជាច្រើនជាងទៀត, ក្នុងរដ្ឋកាលនេះទ្រង់ទុកជាក់ព្រះពុទ្ធសាសនាជាសាសនាសម្រាប់រដ្ឋ ។ ចំពោះខាងសាសនាព្រាហ្មណ៍ ទ្រង់កំនិយមខ្លះដែរ ទៅតាមពាជប្រពៃណី ។

អំពីព្រះគុណសម្បត្តិផ្សេងទៀត ព្រះបាទជយវរ្ម័នទី ៧ នេះ ទ្រង់មានព្រះរូបធំខ្ពស់ពាងស្មាហាប់, កាលពីកុមារទ្រង់បានសិក្សាវិជ្ជាផ្សេងៗស្ទើរតែគ្រប់យ៉ាង ; វិជ្ជាដែលទ្រង់ជ្រួតជ្រាបជ្រៅជ្រះគឺគតិធម៌ក្នុងព្រះពុទ្ធសាសនា លទ្ធិធម៌ក្នុងសាសនាព្រាហ្មណ៍, វិទ្យាសាស្ត្រនឹងយុទ្ធសាស្ត្រ ។ ព្រះអង្គមានព្រះកាយធំខ្ពស់ពាងស្មាហាប់មានព្រះពាជហ្ហឫទ័យធ្ងន់ មានព្រះអធ្យាស្រ័យប្រកបដោយព្រហ្មវិហារធម៌ជានិច្ច ទ្រង់មាន

ព្រះវិហារ យ៉ាងក្នុង, ការអ្វីដែលគ្រែដំបងនឹងធ្វើហើយ ទោះបីលំបាក យ៉ាងណា ក៏គ្រែដំឡាយមធ្វើតាលតែសម្រេចៗ លុះឆ្នាំ ព.ស. ១៧៤៨ គ្រែដំសោយទិវង្គតដោយអំណាចជរាភាព, លុះទិវង្គតហើយ គេថ្វាយ ព្រះនាមព្រះបរមសព្វជូចម្តេចមិនច្បាស់ដ ។ ព្រះមហាក្សត្រិយ៍នេះ កប់ជា "កជាធិកដ" ១ អង្គក្នុងប្រវត្តិសាស្ត្រ ។ (ម.ន.ព)

អ្នកចៀនកុំចៀនៗទៅ ត្រូវតាំងចិត្តជជថា:

រៀនថ្ងៃហ្នឹង ចាំថ្ងៃហ្នឹង យល់ថ្ងៃហ្នឹង,
ចាំដោយប្រឹង ចំខន្ធេញ ចំហាត់ថា,
យល់ដោយប្រឹង គិតសង្កេត ពិចារណា,
ចាំនឹងយល់ លោកហៅថា ការរៀនចេះ ។
ចេះត្រូវផង់ ចំតម្រង់ សោតវិញ្ញាណ
ព្រមទាំងមាន ស្មារតីមាំ ត្រឹមចំណេះ
គួរប្រាប់អ្វី គប្បីចាំ រួចត្រិះរិះ
រៀនឲ្យចេះ ឲ្យចេះនាប់ ឲ្យឆ្លាតថៅ ។
យើងកុំឲ្យល យើងខ្ពើមឲ្យល យើងខ្មាសឲ្យល,
ឲ្យលមនុល នាំឲ្យក្ងេច នាំថោកតេរ្ជិ,
យើងខុសប្រាប់ កុងការរៀន កុំទំនេរ
ទើបបំបែរ កែអង្គខ្លួន ជាប្រាជ្ញបាន ។

យ. អ.

រឿងអារក្សថ្លែងរឿងមែកទ្រា

លោក សាង - សារ៉ាត លេខាធិការក្រសួងអប់រំវិញ្ញាតិ

ប្រែពីភាសាបាលីមកជាខ្មែរ

ព្រះបាទគន្ធព្វសេន (Gandharb.Sên) ព្រះចៅនៃទីក្រុងធារានគរ (Dhârâ nagar) មានអគ្គមហេសី៤អង្គនឹងបុត្រា ៦ អង្គ សុទ្ធសឹងតែមានប្រាជ្ញាហើយខ្លាំងមាំមួន ។ លុះស្តេចអង្គនេះទិវង្គតទៅ, ក្រោយបន្តិចមក បុត្រាច្បងព្រះនាមសង្ខ (Shank) ឡើងសោយរាជ្យ ។ កន្លងច្រើនថ្ងៃមក ព្រះអនុជរបស់ព្រះបាទសង្ខព្រះនាមពិក្រន (Bikran) បានសម្លាប់ព្រះរៀមទាំងឡាយរបស់ព្រះអង្គគ្មានសល់ ហើយទ្រង់គ្រប់គ្រងរាជ្យប្រកបដោយគតិបណ្ឌិតនឹងដោយគន្លងធម៌ ។ ស្តេចអង្គនេះបានរាតត្បាតអំណាចព្រះអង្គមួយថ្ងៃបន្តិច។ តាលៃតែថ្ងៃមួយនោះទៅជាព្រះចៅប្រទេសភ្លើងទាំងមូល ។ ហេតុដូច្នេះ ព្រះអង្គបានរៀបចំប្រទេសឲ្យមានឥទ្ធិពលយ៉ាងប្រសើរ ហើយថារឹតនាមព្រះអង្គក្នុងដើមសតវត្សមួយ ។

ក្នុងពេលបន្តិចតមក ព្រះអង្គទ្រង់ព្រះចិន្តាឃើញថា: ត្រូវតែព្រះអង្គយាងទៅតាមភូមិស្រុក ដើម្បីនឹងទ្រង់ព្រះសណ្តាប់កិច្ចការក្នុងប្រទេស ។ លុះទ្រង់ព្រះចិន្តាសម្រេចយ៉ាងដូច្នោះហើយ ទើបប្រគល់រដ្ឋាភិបាលទៅព្រះអនុជរបស់ព្រះអង្គ ព្រះនាមភថរី (Barthari) ហើយ

ទ្រង់ព្រះផ្នួសប្រតិត្តជាអ្នកធុតង្គ រួចទ្រង់យាងតែមួយព្រះអង្គឯងពីស្រុកមួយទៅស្រុកមួយ នឹង ពីព្រៃមួយទៅព្រៃមួយ ។

មានព្រាហ្មណ៍ម្នាក់ជាអ្នកសុមនៅទីក្រុងនោះ ។ ថ្ងៃមួយទេវតាបានយកផ្លែ "កាល់" មួយមកឲ្យព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍លុះបានផ្លែឈើនោះយកទៅផ្ទះហើយនិយាយប្រាប់ប្រពន្ធថា: "កាលទេវតាឲ្យផ្លែនេះមកបង លោកប្រាប់ថា: បើអ្នកណាបរិភោគផ្លែនេះ អ្នកនោះលែងស្លាប់" ។ ព្រាហ្មណីលុះឮដូច្នោះ យំសោកជាខ្លាំង ។ នាងនិយាយថា: "ឧ! របស់នេះជាទុក្ខមួយយ៉ាងធ្ងន់របស់យើង ព្រោះថាបើយើងលែងស្លាប់ តើដល់កាលណាទៅទើបយើងឈប់ស៊ីបានគេ, ហេតុដូច្នោះស្លាប់វិញល្អជាង! លុះស្លាប់ទៅ យើងនឹងធុតចាកទុក្ខព្រួយលំបាកនេះពុំខាន" ។ ព្រាហ្មណ៍និយាយឡើងវិញថា: "បងបានយកផ្លែនេះមកឲ្យអ្នក ប៉ុន្តែពាក្យសំដីរបស់អ្នក នាំឲ្យបងវង្វេងអស់, បើដូច្នោះចូរអ្នកប្រាប់បងមើល តើឲ្យបងធ្វើយ៉ាងណាវិញក្នុងពេលនេះ?" ។

ព្រាហ្មណីនិយាយប្រាប់ប្តីថា: យកផ្លែនេះទៅថ្វាយស្តេចទៅ បងនឹងបានរង្វាន់ដែលអាចធ្វើឲ្យយើងបានស្គាល់ នូវសេចក្តីសប្បាយគាំងលោកនេះនឹងលោកខាងមុខ ។

លុះបានឮយ៉ាងដូច្នោះហើយ ព្រាហ្មណ៍បានចូលទៅដិតព្រះមហាក្សត្រ ហើយបានគាំងថ្វាយពរសួរសាធុការដល់ព្រះអង្គផង ។

រួចព្រាហ្មណ៍ក៏បាននិយាយអំពីគុណសម្បត្តិនៃផ្លែឈើចំណែកនោះ ក្រាបទូលស្តេចថា: "សូមទ្រង់ព្រះមេត្តាប្រោស! សូមព្រះអង្គយកផ្លែឈើនេះចុះ ហើយសូមប្រទានតែទ្រព្យសម្បត្តិមកទូលបង្គំខ្ញុះបានហើយ ព្រោះទូលបង្គំពេញចិត្តណាស់ ត្រង់ការឃើញព្រះអង្គទ្រង់គង់ព្រះជន្មយឺនយូរ" ។ ព្រះមហាក្សត្រទ្រង់ប្រទានប្រាក់ មួយពាន់រៀលកហាបន: ហើយទ្រង់បើកឲ្យព្រាហ្មណ៍ចេញមកវិញ រួចទ្រង់យាងចូលទៅក្នុងបន្ទប់ក្រឡាព្រះបន្ទំរបស់ព្រះអង្គ ។ ស្តេចទ្រង់មានព្រះបន្ទូលហៅឯកអគ្គមហេសី ដែលទ្រង់សព្វព្រះរាជហឫទ័យជាងគេមកជិតព្រះអង្គ ហើយទ្រង់ប្រទានផ្លែឈើនោះដោយព្រះរាជទន្លាវថា: "បរិភោគផ្លែនេះទៅប្អូនសំឡាញ់! ដើម្បីឲ្យប្អូនបានរស់ជីវិតរហូតតទៅផង ដើម្បីឲ្យប្អូននៅក្នុងតំណែរយ៉ាងជាបទៅផង" ។ លុះបានឮព្រះរាជទន្លាវដូច្នោះ ឯកអគ្គមហេសីក៏បានទទួលយកផ្លែឈើនោះ ។ ចំណែកខាងព្រះរាជា ក៏ស្តេចយាងចូលទៅក្នុងព្រះទីនាំងចុងកែងទៅ ។ ព្រះនាងបានយកផ្លែនោះទៅឲ្យនាយកងក្រវែលម្នាក់ដែលព្រះនាងស្គាល់ ។ ឯនាយកងក្រវែលបានឲ្យផ្លែនោះទៅស្រីស្នំម្នាក់ដែលខ្លួនស្គាល់ ហើយបានពន្យល់ពីគុណសម្បត្តិនៃផ្លែនោះផង ។ នារីនោះគិតថា ' នេះជាវត្ថុមួយដែលសមនឹងបុណ្យស្តេចពិត" ទើបនាងយកផ្លែនោះទៅថ្វាយព្រះមហាក្សត្រ ។ ទ្រង់ក៏បានឲ្យនាងត្រឡប់មកលំនៅវិញ បានទាំងប្រទានទ្រព្យសម្បត្តិជា

ច្រែនឲ្យនាងនោះផង ។ កាលព្រះអគ្គទ្រង់ទតផ្លែនោះ ទ្រង់ព្រួយ
ព្រះហឫទ័យធុញទ្រាន់ទីឯលោកិយនេះពេក ទើបទ្រង់មានព្រះពាក្យ
ថា: "រាត្រីដែលអាចវិនាសសាបសូន្យនៃលោកនេះ ហើយដែលនាំឲ្យយើង
ភ្ញាក់ផៅសោយទុក្ខកង្វល់នេះ តើមានប្រយោជន៍អ្វី? ត្រូវតែយកផ្លូវ
សមណៈវស់នៅតាមគំនិតរបស់ព្រះវិញ នោះនឹងបានដល់សម្បត្តិនិព្វាន
ពុំខាន" ។ លុះទ្រង់ព្រះតម្រិះដូច្នោះ ទ្រង់ក៏យាងចូលក្នុងព្រះពាដបន្ទំ
ហើយទ្រង់សួរព្រះអគ្គមហេសីថា: តើនាងយកផ្លែ "កាល់" ដែល
ទ្រង់ប្រទាននោះទៅឯណាទៅ"? ។ ព្រះនាងទូលតបថា: "ទូល
ព្រះបង្គំបរិភោគហើយ" ។ ព្រះរាជាទ្រង់បង្ហាញផ្លែនោះ ។ លុះ
ឃើញដូច្នោះ ព្រះនាងក៏តក់ស្លុត ឥតនឹកឃើញពាក្យដែលគួរទូលតប
សូម្បីតែមួយម៉ាត់ឡើយ ។ ព្រះរាជាយាងចេញមកវិញ ទ្រង់ដុសលាង
ផ្លែនោះ ហើយទ្រង់សោយទៅ ។ បន្ទាប់មក ទ្រង់លះបង់រាជសម្បត្តិ
ទៅទ្រង់ព្រះផ្នួស ដោយឥតមានព្រះពាក្យប្រាប់អ្នកណា ឬ ស្តាប់អ្នក
ណាសោះ ទ្រង់យាងចូលទៅគង់នៅក្នុងព្រៃ ។

រាជសម្បត្តិស្តេចពិភពនឹកក៏នៅទំនេរ ។ ព្រះឥន្ទ្រជ្រាបដំណឹង
នោះ ទើបទ្រង់បង្គាប់ឲ្យអាវក្សចុះមកកាន់រាជពន្ធ ។ ឯអាវក្សក៏ចាន
មកនៅថែរក្សាទីក្រុងនោះតាំងយប់តាំងថ្ងៃ ។

ឯដំណឹងថាស្តេចពភរិ (Barthari) ចេញចាកចោលព្រះរាជសម្បត្តិ
នេះ ក៏លេចឮឡើងសុះសាយក្នុងព្រះរាជអាណាចក្រ ។

លុះកាលណាទ្រង់ដ្ឋាបដូច្នេះ ព្រះបាទពិភវន័ក៏ទ្រង់យាងយ៉ាងប្រញាប់មកកាន់ព្រះពាជអាណាចក្រព្រះអង្គវិញ ។ ទ្រង់យាងមកដល់ក្នុងវេលាយប់ ។ ក្នុងពេលដែលទ្រង់យាងមកដល់ទីក្រុង អារក្សស្រែកឃាត់ព្រះអង្គថា: "ឯងជាអ្នកណា ? ឯងទៅឯណា ? ចូរឯងឈប់សិនហើយចូរថ្កាប់ឈ្មោះយើង? ។ ព្រះបាទពិភវន័តបថា: "យើងជាស្តេចពិភវន័ យើងត្រឡប់ចូលក្នុងព្រះពាជធានីរបស់យើងវិញ ឯងជាអ្វីដែលមកឃាត់យើងនេះ? ។

អារក្សឆ្លើយថា: "យើងជាពាជទូតរបស់ព្រះ, មកនៅទីនេះ ដើម្បីមើលរក្សាព្រះពាជធានីនេះ, បើឯងពិតជាស្តេចពិភវន័មែន ចូរឯងប្រយុទ្ធជាមួយយើងសិន រួចចាំឯងចូលទៅក្នុងព្រះពាជធានីជាក្រោយ" ។

លុះទ្រង់ឮដូច្នេះ ស្តេចក៏ទ្រង់រឹតព្រះកដិ ហើយទ្រង់ប្រឆងប្រយុទ្ធនឹងអារក្ស ។ ឯអារក្សបែរមុខមករកព្រះអង្គ រួចការប្រយុទ្ធក៏ឆ្លើមឡើង ។ ក្រោយបង្អស់ ស្តេចវាយអារក្សដួលលើដែនដី ហើយទ្រង់អង្គុយលើដើមទ្រូងវា ។ អារក្សទូលព្រះអង្គថា: "ឧព្រះមហាក្សត្រស្តេចវាយខ្ញុំដួលដេកដីហើយ ! ខ្ញុំសូមទុកជីវិតថ្វាយព្រះអង្គ" ។ ស្តេចក៏ទ្រង់សំណើចថា: "ឯងប្រហែលជាឆ្គួតហើយ តើឯងទុកជីវិតឲ្យអ្នកណា ? បើអញចង់សម្លាប់ឯងនោះ អញអាចសម្លាប់ឯងឥឡូវនេះបាន, តើឯងទុកជីវិតឲ្យអញយ៉ាងណា ?" ។

ឯអាក្សនិយាយដូចតទៅនេះថា: "បពិត្រព្រះមហាក្សត្រ! ខ្ញុំ
ព្រះបង្គំជួយព្រះអង្គឲ្យផុតអំពីសេចក្តីស្លាប់, ប៉ុន្តែដំបូងបង្អស់ សូមទ្រង់
ស្តាប់ខ្ញុំព្រះបង្គំសិន, ក្រោយទៅទៀត ព្រះអង្គមុខជាទ្រង់បានកាន់
ចង្កឹតខ្ញុំបាំងអស់នេះ ដោយឥតព្រួយព្រះហប្ញទ័យឡើយ" ។

ព្រះមហាក្សត្រទ្រង់លែងអាក្សនោះទៅ ទ្រង់ស្តាប់ក៏យ៉ាងប្រុង
ប្រយ័ត្ន ។ ឯអាក្សនិយាយដូច្នេះថា: "នៅក្នុងទីក្រុងនេះ មានស្តេចមួយ
ព្រះអង្គមានព្រះទ័យល្អណាស់ព្រះនាមចន្ទ្រភាណ (Chandr-Bhan) ។
ថ្ងៃមួយនោះ ស្តេចអង្គនេះយាងចូលទៅកន្លែងព្រៃ បានឃើញអ្នកធុតង្គ
ម្នាក់ព្យួរខ្លួននៅលើដើមឈើ ក្បាលត្រឡប់ចុះមកដីហើយហិតយកផ្សែង
ជាជាតិ ។ មនុស្សនេះមិនដែលទទួលអ្វីពីអ្នកណា ហើយមិនដែល
និយាយទៅអ្នកណាសោះ ។

លុះស្តេចបានឃើញមនុស្សនោះ ព្រះអង្គទ្រង់យាងត្រឡប់ចូល
ទៅក្នុងប្រាសាទ ទ្រង់គង់កណ្តាលព្រះពជរកេង ហើយមានព្រះព-
ន្ធូរថា: "អ្នកណាមួយទៅយកអ្នកធុតង្គនោះមក - ទឹងបានរង្វាន់មួយ
ពាន់រៀល" ។ ស្រីសុំមួយពួកលុះឮដូច្នេះ បានចូលទៅដិតព្រះអង្គ
ហើយក្រាបទូលថា: "សូមព្រះអង្គទ្រង់បង្គាប់ចុះ ខ្ញុំម្ចាស់នឹងទៅរួមរក្ស
នឹងអ្នកធុតង្គនោះលុះត្រាតែបានកូនមួយ ហើយទូលបង្គំនឹងនាំមកថ្វាយ
ព្រះអង្គ ហើយឲ្យអ្នកធុតង្គនោះលើកកូនដាក់លើស្មាមកផង" ។

ព្រះមហាក្សត្រទ្រង់ជ្រមុនឆ័ពាក្យសំដីនោះណាស់ ហើយទ្រង់ប្រទានឲ្យម្ចាស់មួយសន្ធឹកទៅនារីនោះ ដែលជាសញ្ញាបង្ហាញឲ្យឃើញថា: "ព្រះអង្គស្រុះស្រួល" រួចទ្រង់បង្គាប់ឲ្យនាងនោះចេញទៅ ។

នាងចូលទៅកន្លែងដែល លុះទៅដល់ទីកន្លែងអ្នកជុតង្គនោះ តើនាងឃើញអ្វី? នាងឃើញអ្នកជុតង្គព្យួរក្បាលត្រឡប់ចុះមកក្រោម ។ អ្នកជុតង្គនោះឥតបរិភោគ ឥតអាស្រ័យទឹក ហើយខ្លួនកាន់តែស្គិតទៅ ។

នាងដាំបាយយកទៅដាក់ក្នុងមាត់អ្នកជុតង្គនោះ អ្នកជុតង្គក៏លេបបាយនោះ, ហើយនាងក៏ឲ្យបាយតទៅទៀត ។ ចំនួនពីរថ្ងៃតមក នាងតែងឲ្យបាយដល់អ្នកជុតង្គ ។ អ្នកជុតង្គលុះបរិភោគទៅ ក៏មានកំលាំងឡើង ។ អ្នកជុតង្គនោះ លុះបើកភ្នែកឃើញនាងក៏ចុះពីលើដើមឈើ រួចសួរអំពីហេតុដែលនាំឲ្យនាងមកកន្លែងនេះ ។ នាងឆ្លើយថា: "ខ្ញុំជាកូនទេវតា ខ្ញុំបួសក្នុងស្ថានព្រះឥន្ទ្រ ឥឡូវខ្ញុំមកកន្លែងនេះ" ។

អ្នកជុតង្គនិយាយថា "ផ្ទះនាងនៅឯណា? បង្អុលប្រាប់ខ្ញុំមើល" ។ នាងក៏នាំអ្នកជុតង្គនោះទៅផ្ទះនាង, រៀបចំម្ហូបចំណីដែលមានរសជាតិឆ្ងាញ់ៗយ៉ាង ។ ឯអ្នកជុតង្គក៏ឈប់ហឹតផ្សែងហើយតាំងបរិភោគនឹងផឹកទឹកភ្លាមថ្លៃ ។ ដល់ចុងបង្អស់ ទេវតាព្រះនាមកាម: (Kima) បានធ្វើឲ្យអ្នកជុតង្គនោះវង្វេងស្មារតី ភ្លេចបង្ក្រឹមការនោ គិតតែត្រេកត្រអាលនឹងតណ្ហា

ប្តូនាង៖នោះកំមានផ្ទៃពោះ ។ ដប់ខែក្រោយមក កូនប្រុសមួយកើតឡើង ។

ចំនួនច្រើនខែកន្លងមកទៀត នាង៖នោះ និយាយទៅអ្នកធុតង្គថា: "ទុសន្តបុគ្គល! (Saint) ឥឡូវត្រូវទៅតាំងសីលដើម្បីលុបបាបរបស់យើង" ។ លុះនិយាយអង្វរករួច នាង៖លើកកូនដាក់លើស្មាគាត់ ហើយដើរតម្រង់ទៅព្រះបរមរាជវាំង ដើម្បីចំពេញកិច្ចសន្យារបស់នាង៖ឲ្យជ្រះស្រឡះ ។ លុះនាង៖ទៅដល់ចំពោះកត្តិព្រះករុណា ដែលទ្រង់ស្គាល់នាង៖ពីចម្ងាយ ហើយដែលទ្រង់ទតឃើញក្មេងម្នាក់នៅលើស្មាអាចារ្យផង នោះ ព្រះអង្គក៏មានព្រះពាក្យរាជឫកាទៅអាមាត្យទាំងអស់គ្នាថា: "ចូរអ្នកទាំងអស់មើល! តើនាង៖ស្មុំដែលចេញទៅយកអាចារ្យបានមកវិលមកវិញឬទេ?" ។ អាមាត្យទាំងអស់ទូលថា: "សូមទ្រង់ព្រះមេត្តាប្រោស! ព្រះអង្គមានព្រះពាក្យរាជឫកាត្រូវមែន, គឺប្រាកដជានាង៖នេះហើយ សូមទ្រង់ព្រះពាក្យទានទោស ដើម្បីឲ្យយើងខ្ញុំព្រះអង្គទាំងអស់បញ្ជាក់ព្រះអង្គថា: អំពើដែលនាង៖នេះបានសន្យាទាំងប៉ុន្មាន គឺនាង៖បានធ្វើមកអស់ហើយ" ។

(មានត)

ដំណើរមកកាន់ប្រទេសកម្ពុជា

នៃមហាបណ្ឌិត គុណាបាលបិយសេន ម៉ាល៉ាឡាសេកេរៈ

ជាអធិបតីនៃពុទ្ធិកសមាគមពិភពលោកនៅលង្កាទ្វីប

របស់

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

លោកម៉ាឡាឡាសេកេរៈ ជាជាតិអ្នកលង្កា អាយុ ៥១ ឆ្នាំសម្បុរសណ្តែកបាយ មាឌធាត់ខាបត្រអាញ ក្បែកនឹងឫកពាសមជាអ្នកសុភាពរាងវែលោកជាប្រធាននៃពុទ្ធិកសមាគមពិភពលោកនៅលង្កាទ្វីប ។

កាលពីថ្ងៃទី ២៤ ខែមេសា ឆ្នាំ ១៩៥១ មហាបណ្ឌិតនេះ បានអញ្ជើញចេញពីប្រទេសលង្កាទ្វីបដោយអាកាសយាន សំដៅទៅកាន់ប្រទេសនានា ដែលមានកាន់សាសនាព្រះពុទ្ធដើម្បីទស្សនាទូរព្រះពុទ្ធសាសនាក្នុងប្រទេសនោះ ។ ។ មុនដំបូង លោកឆ្ពោះចូលទៅសិង្គបុរ (មលូកា) ក្រុងកូឡាឡាំពួរ (ជ្វា) នឹងពីណាំង រួចហើយលោកមកសំណាក់នៅក្រុងចាំងកកចំនួន ១២ ថ្ងៃ ។ លុះដល់ថ្ងៃទី ១៥ ខែឧសភា លោកចេញពីប្រទេសថៃមកកាន់ខែត្រសៀមរាប ដោយក្បួនរថយន្តដែលរាជការថៃជូនមក ។ នៅថ្ងៃទី ១៦ ខែដដែលនេះ លោកអញ្ជើញទៅទស្សនាប្រាសាទបុរាណតាំងពីយូរយារមកនៅសៀមរាប ដោយមាន

ចៅហ្វាយខែត្រសៀមរាបជូនដំណើរ ។ លុះដល់ថ្ងៃទី ១៩ ខែ១សកា
ពេលម៉ោង ៥ កន្លះរសៀល លោកអញ្ជើញមកដល់រាជធានីភ្នំពេញ
ដោយក្បួនជូនរថយន្ត ។

បដិសណ្ឋារកិច្ចចំពោះមហាបណ្ឌិត
នៃក្រុមពន្ធបរិសទ្យ ភ្នំពេញ

នៅត្រង់កូមិចាំងចំរេះដែលជាជាយរាជធានីខ្មែរ មានគណៈកម្មការ
បដិសណ្ឋារៈមួយក្រុម នៃសមាគមមិត្តសាលាបាលី នឹងពុទ្ធបរិស័ទចាំង
ប្រុសចាំងស្រីជាច្រើនបានទៅរង់ចាំទទួលលោក ។ ក្នុង
ចំណួននេះ គេសង្កេតឃើញឯកឧត្តម សម - ញ៉ាណ រដ្ឋមន្ត្រីក្រសួងធម្ម-
ការជាដើមជាអ្នកចាត់ចែងកិច្ចការទទួល ។ លុះមហាបណ្ឌិតមកដល់ភ្លាម
ពួកអ្នកចាំទទួលចាំងប្រុសចាំងស្រីនាំគ្នាទៅចោមរោម សំដែងសេចក្តីគួរ
សមដល់លោក ។ មហាបណ្ឌិតនេះក៏ចេះតែលើកដៃសំពះហើយសំពះ
ទៀត ដល់អ្នកដែលទៅធ្វើបដិសណ្ឋារកិច្ចចាំងប៉ុន្មាន តាមរបៀបពុទ្ធ-
សាសនា គឺគ្មានប្រើការចាប់ដៃតាមបែបអឺរុបទេ ។

ក្នុងពេលនោះ ឯកឧត្តម សម - ញ៉ាណ បានថ្លែងសាគមន៍
(ដំណើរមកដ៏ប្រពៃ) ហើយបានធ្វើតំណរសេចក្តីចាប់អារម្មណ៍របស់
លោក ក្នុងការដែលលោកអញ្ជើញទៅមើលប្រាសាទបុរាណរបស់ខ្មែរ ។
មហាបណ្ឌិតមានប្រសាស្តបមកវិញ ជាភាសាអង់គ្លេស ដោយមាន

លោកក្លេម៉ង់ ជាអ្នកបកប្រែ ។ លោកថា "ក្បួនច្បាប់វចនាយ៉ាងឆើតនៃប្រទេសខ្មែរបុរាណដែលលោកបានឃើញទាំងប៉ុន្មាននោះ មិនមែនគ្រាន់តែនាំឲ្យលោកចង់គយគន់ ដោយពិនិត្យពិច័យយ៉ាងជាប់ចិត្តប៉ុណ្ណោះទេ គឺនាំឲ្យលោកឃើញច្បាស់ដល់វិវឌ្ឍន៍នៃការចាក់ឫសយ៉ាងមុតមាំនៃពុទ្ធសាសនានៅប្រទេសនេះផង" ។ មហាបណ្ឌិតបានបញ្ជាក់អំពីវត្តបំណងនៃបេសកកម្មរបស់លោកថា "គ្មានត្រូវការអ្វីដទៃក្រៅអំពីពិនិត្យកិច្ចការសាសនា ហើយនឹងបបួលប្រទេសដែលកាន់ព្រះពុទ្ធសាសនាទាំងឡាយឲ្យសាមគ្គីរួបរួមគ្នា ចោះបង់ការប្រកាន់ពួកគណៈចោលទៅ ដើម្បីនឹងបង្កើតមជ្ឈមណ្ឌលកូមិភាគនៃសមាគមពុទ្ធសាសនាគ្រប់ពីកន្លែងឡើង" ។ លោកបានបន្ថែមថា "កន្លងពេលដែលប្រទេសកាន់ពុទ្ធសាសនាទាំងឡាយ មានដំរាមភាពឡើងជាថ្មីនេះ ការរួបរួមគ្នាដោយឥតប្រកាន់និកាយ នៃពុទ្ធបរិស័ទក្នុងពិភពលោកទាំងមូល ជាការណីយកិច្ចមួយយ៉ាងសំខាន់ ដែលត្រូវតែខំខ្នះខ្នែងធ្វើ ដើម្បីនឹងញ៉ាំងការប្រស័ព្ទរវាងគ្នានឹងគ្នា ដែលបានបាត់បង់ទៅជាច្រើនសតវត្សមកហើយនោះ ឲ្យមានរុបកាន់ឡើងវិញ គឺសាមគ្គីធម៌យ៉ាងមុតមាំនេះហើយដែលនឹងអាចរំលត់ភ្លើងសង្គ្រាម កំពុងតែឆេះជាលក់លសព្វថ្ងៃនេះបាន" ។

បន្ទាប់មក ឯកឧត្តម សម - ញ៉ាណ បានថ្លែងសេចក្តីរីករាយកងឹកងមនៃពុទ្ធសាសនិកជនខ្មែរទាំងមូល ចំពោះដំណើរមកដោយសួស្តីនៃលោកម៉ាល៉ាល៉ៈសេកេរៈនេះ ។

រួចហើយ លោកព័ន្ធ-ប៊ុក ជាប្រធាននៃសមាគមមិត្តសាលាបាលី ព័ន្ធព័ន្ធអំពីកិច្ចការនៃសមាគមនេះ ដែលបំរុងនឹងបង្កើតពុទ្ធិកសមាគម មជ្ឈមណ្ឌលភូមិភាគមួយ ដែលមានការគោរពនឹងគ្នានឹងពុទ្ធិកសមាគម ពិភពលោកនោះ ។

លុះសន្ទនាគ្នាស្រេចហើយ វេយ្យាវច្ចរ ៣០ ដែលមានជោត ទន់ សាសនាជាកិត្តិយសផង ក៏បានជូនដំណើរក្រៀវជាធម្មតានេះទៅកាន់ មហាសន្ថាគារ "ឡ្រ៉ាយ៉ាល់" ដើម្បីសំពាក ។

មហាបណ្ឌិតថ្វាយទង់ពុទ្ធសាសនា បំពោះព្រះមហាក្សត្រ

លុះដល់ថ្ងៃទី ១៨ ខែឧសភា ពេលម៉ោង ១០ ព្រឹក មហាបណ្ឌិត ម៉ាណ៉ាល់:សេសេរ ចូលគាល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដោយ មានឯកឧត្តម នាល-ផ្ទែង រដ្ឋមន្ត្រីក្រសួងការពារទេសនាំចូលក្រាប បង្គំគាល់ ។

ក្នុងពេលនោះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ធ្វើបដិ-សណ្ឋារៈ ដល់មហាបណ្ឌិត បានទ្រង់ត្រាស់ព្រះពុទ្ធានុភាពសម្ផស្ស ជាកិត្តិយសដល់លោក ហើយទ្រង់សន្ទនាយ៉ាងពាក់ព័ន្ធអស់ពេលដ៏យូរ ។ មុននឹងក្រាបថ្វាយបង្គំលា, មហាបណ្ឌិតបានថ្វាយទង់ពុទ្ធសាសនា បំពោះព្រះមហាក្សត្រ ។ ទង់នោះគឺអ្នកតំណាងប្រទេសចិនឲ្យ

ដែលកាន់ព្រះពុទ្ធសាសនាក្នុងពិភពលោកទាំងមូល ដែលមានប្រទេសកម្ពុជាជាសមាជិកដែរនោះ បានយល់ព្រមបង្កើតឲ្យមានឡើង ក្នុងកិច្ចសន្និសិទពុទ្ធសាសនាទៅលង្កាទ្វីប កាលពីថ្ងៃទី ២៥ ខែឧសភា ទៅថ្ងៃទី ៦ មិថុនា ឆ្នាំ គ ស ១៩៥០ ។

ទង់ពុទ្ធសាសនានេះ មាន ៦ ពណ៌ ជាផ្ទាំងបញ្ឈរតំរៀបគ្នាដូច្នេះ គឺផ្ទាំងពណ៌ខៀវ លឿង - ក្រហម - ស - ហង្សាជាត ហើយផ្ទាំងខាងចុងដែលមានទំហំប៉ុនគ្នានឹងផ្ទាំងខាងដើមដែរនោះ ត្រូវតំរៀបពណ៌ដដែលនេះពីលើចុះមកក្រោមដូច្នេះ គឺខៀវ, លឿង, ក្រហម, ស និងហង្សាជាត គេហៅថា ពណ៌ផ្កែកឬពណ៌ចំរុះ ។

ក្រៅពីទង់ពុទ្ធសាសនា ដែលលោកបានថ្វាយជាផ្លូវការក្នុងនាមនៃពុទ្ធិកសមាគមពិភពលោក ដើម្បីសុំឲ្យប្រទេសកម្ពុជាទទួលប្រើប្រាស់ផងនេះ, មានសៀវភៅផ្សេង ។ ទៀតដែលលោកបានថ្វាយ ចំពោះព្រះមហាក្សត្រ ប្រយោជន៍ជាអនុស្សាវរីយ៍ក្នុងដំណើរបស់លោក ។

មហាបណ្ឌិតប្លូលថ្វាយបង្គំ
សម្តេចសង្ឃនាយក និង ឧត្តមប្រឹក្សា

នៅពេលរសៀលម៉ោង ១៥ នៃថ្ងៃទី ១៨ ឧសភានោះ លោកបានចូលទៅថ្វាយបង្គំសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក គណៈមហានិកាយនិងព្រះរាជគណៈហានានុក្រម ដែលគង់ចាំទទួលក្នុងវិហារ

វត្តទុណ្ណាលោម ដោយមានទុបាសកទុបាសិកាចំណុះវត្តមកជួបជុំយ៉ាងកុះករ ។ សម្តេចបានសន្ទនានឹងមហាបណ្ឌិតនេះជាភាសាបាលីដោយទុគ្ឃាសនសព្ទ មហាបណ្ឌិតក៏បានថ្លែងតបជាភាសាបាលីដែរ ។

បន្ទាប់មក មហាបណ្ឌិតបានអញ្ជើញទៅថ្វាយបង្គំសម្តេច សុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តវត្តបទុមវតី និងសម្តេចព្រះធម្មលិខិតទុត្តមប្រិក្សា ល្វី ឯម វត្តលង្កា ដែលមានព្រះសង្ឃទុបាសកទុបាសិកាជាច្រើន ចាំទទួល ។

មហាបណ្ឌិតទៅទស្សនាសាលាបាលីជាន់ខ្ពស់

បន្ទាប់មកទៀត មហាបណ្ឌិត អញ្ជើញទៅកាន់មន្ទីរស្តីការវជ្ជមន្ត្រីក្រសួងធម្មការ ដែលមានអ្នកពាក់ការក្នុងក្រុមនេះ ចាំទទួលលោកយ៉ាងអឺកអធឹក ។ លុះលោកទស្សនាទូទៅក្រុមផ្សេងៗ ក្នុងក្រសួងនេះរួចហើយ លោកអញ្ជើញទៅមើលសាលាបាលីជាន់ខ្ពស់ ។ នៅទីនេះព្រះតេជព្រះគុណព្រះពោធិវង្ស ហួត - តាត ចាងហ្វាងសាលា, និងព្រះតេជព្រះគុណ ព្រះមហាព្រហ្មមុនី ខេត-អ៊ី ជាចាងហ្វាងរងទៅចាំទទួល ហើយអញ្ជើញលោកទៅមើលក្រុមដំទុំព្រះវិន័យទៀត ។

នៅម៉ោង ១៨ កន្លះ មហាបណ្ឌិតបានអញ្ជើញទៅជួបនឹងក្រុមអគ្គាចារ្យនៃសមាគមមិត្តសាលាបាលី នៅយ៉ាសាលាបាលីជាន់ខ្ពស់ ដែលមានមហាជនជាងពីរពាន់នាក់បានទៅរួមផង ។ ក្នុងពេលនោះលោក

ភ័ឃ - ប៊ុក ជាអធិបតីនៃសមាគមមិត្តសាលាចាស់ បានថ្លែងចាប់ផ្តើមជាសង្ខេបមួយជាភាសាខ្មែរ ដំណាមហាបណ្ឌិតឲ្យជ្រាបអំពីពុទ្ធសាសនានៅប្រទេសកម្ពុជារដ្ឋ ដូចតទៅនេះ :-

សូមដំណាបលោកមហាបណ្ឌិតជាអធិបតីពុទ្ធិកសមាគមពិភពលោក !

ខ្ញុំជាតំណាងសមាគមមិត្តសាលាចាស់កម្ពុជារដ្ឋ, សូមអរគុណដ៏ក្រៃលែងចំពោះលោក ដែលបានអញ្ជើញមកទស្សនាប្រទេសកម្ពុជា ។ ដ្បិតដំណើរមកនៃលោកនេះ ទុកជាមង្គលដ៏ប្រសើរចំពោះព្រះពុទ្ធសាសនា នៅទីនេះ ។

មហាបណ្ឌិត ! ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាបានចំរើនរឿងកាលពីដើមមក ។ រដ្ឋបាល បានស្ថាបនាសាលាចាស់ជាន់ខ្ពស់មួយ នៅក្រុងភ្នំពេញ ទឹងសាលាចាស់រងចំនួន ២៤៨ ខ្នង ទឹងសាលាធម្មវិន័យជាច្រើន តាមវត្តក្នុងខែត្រស្រុកឃុំ ។ មានសិស្សប្រឡងចេញអំពីសាលាចាស់រងនោះ ក្នុងមួយឆ្នាំៗជាង ២០០០ រូប ។ ឯសាលាចាស់ជាន់ខ្ពស់នេះ កើតឡើងពីពុទ្ធសកាជ ២៤៥៧ គិតទៅបាន ៣៧ ឆ្នាំ ។ សាលាធម្មវិន័យបានកើតឡើងដោយកម្លាំងនៃពុទ្ធមាមកជន ដោយមានព្រះរាជក្រឹត្យអនុញ្ញាតឲ្យបង្កើតទៅក្រោមព្រះបរមរាជូបត្ថម្ភ នៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង ប្រទេសកម្ពុជា ។ សាលាទាំងនោះ

ស្មុគ្គតែជាវិជ្ជាស្ថានសំរាប់អប់រំវិជ្ជាខាងព្រះពុទ្ធសាសនា ដើម្បីសួយព្រះពុទ្ធសាសនា ឲ្យដើរទៅកាន់សេចក្តីចំរើនគាន់កាលសម័យ ។

មួយទៀត ពួកពុទ្ធមាមកជននៅក្រៅកំពេញ បានផ្តើមបង្កើតពុទ្ធិកសមាគម តាំងពីថ្ងៃទី ១៣ ខែតុលាឆ្នាំ ព.ស. ២៤៨១ មកម្ល៉ះហើយ តែសមាគមនោះតាំងនៅបានត្រឹម ៥ ឆ្នាំហើយក៏ថយកម្លាំងដូចជារលត់ទៅ ។ លុះអកជល់ថ្ងៃទី ២៨ ខែសីហា ឆ្នាំ ព.ស. ២៤៨២ ក៏មានសមាគមមួយទៀត បានចាប់បដិសន្ធិឡើងជាថ្មី មហាសន្និបាតឲ្យនាមថា "សមាគមមិត្តសាលាបាលី" ដែលកើតឡើងដោយកម្លាំងនៃសេចក្តីព្យាយាមរបស់ពួកពុទ្ធបរិសទ្យបានផ្តួចផ្តើមឡើង ។ សមាគមនេះមានវ័យនៅក្មេង ពុំទាន់មានសម្ភារៈគ្រប់គ្រាន់ ពុំទាន់មានទីសំណាក់ការសមស្មនៅឡើយ ព្រមទាំងជនជាន់នៃសមាគមមិត្តសាលាបាលី ក៏នៅស្តួចស្តើងណាស់ មិនទាន់មានកំឡាំងមួនមាំ គ្រាន់តែមានដំណើរប្រព្រឹត្តទៅមិនជាច់ប៉ុណ្ណោះ ។ ពីឆ្នាំទៅមុំញ គណៈប្រតិភូខ្មែរកម្ពុជវដ្ឋ ទាំងគ្រហស្ថ ទាំងបព្វជិត មានសម្តេចព្រះមហាសុមេធាធិបត៌សង្ឃនាយកជាប្រធាន បានទៅកាន់មហាពុទ្ធិកសមាគមពិភពលោកនៅលង្កាទ្វីប ។ តាំងពីកាលប្រតិភូខ្មែរត្រឡប់មកពីលង្កាទ្វីបនោះវិញ ពុទ្ធសាសនិកជនខ្មែរមានបំណងបំរុងនឹងរៀបចំនូវពុទ្ធិកសមាគម មជ្ឈមណ្ឌលកូមិភាគ នៅកម្ពុជវដ្ឋមួយទៀត ។ សម្រាប់ប្រសិយផ្តាល់ចំពោះពុទ្ធិកសមាគមពិភពលោក

នៅលង្កាទ្វីប តែមិនទាន់រៀបចំរួចនៅឡើយ ។ ដូចនេះ ខ្ញុំសូមជំរាបលោកមហាបណ្ឌិតថា ពួកពុទ្ធមាមកជននៅទីនេះនឹងខំព្យាយាមចាត់ការបង្កើតសមាគមនេះ ត្រាតែកើតតាមបំណង ។

កង់បរិយោសាននេះ ខ្ញុំសូមធ្វើសច្ចវាចាថា "ដោយអានុភាពព្រះត្រៃរត្នៈនឹងអានុភាពវត្ថុសក្តិសិទ្ធិ សូមធម៌បួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ចំរើនដល់លោកនឹងអ្នកលង្កាទ្វីបសព្វកាលកុំបីឃ្លាតឡើយ! សូមទេវតាដែលរក្សាលង្កាទ្វីប នឹងទេវតាដែលរក្សាកម្ពុជរដ្ឋ ចាប់ដៃគ្នាដោយសាមគ្គីធម៌ការពារព្រះពុទ្ធសាសនាក្នុងសាកលលោក ឲ្យបានប្រកបដោយវឌ្ឍនធម៌ទៅអនាគតហោង" ។

បន្ទាប់មក លោកឌិន - ហ្ពត ជាសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ បានប្រែជាបាលីថាភាសាខ្មែរនេះ ទៅជាភាសាបាលីជូនលោកមហាបណ្ឌិតស្តាប់ ដូចយើងនាំមកចុះតទៅនេះ :-

សុទ្ធរកថាបរិវត្តំ

សកលលោកស្ស មហាពុទ្ធិកសមាគមស្ស អធិបតិ មហាបណ្ឌិត! អហំ កម្ពុជរដ្ឋេ បាលិសិក្ខាគារមិត្តសមាគមស្ស បតិកូ, កម្ពុជរដ្ឋស្ស ទស្សនាយ តុម្ហាកំ អាគមនំ អតិវិយ តុដ្ឋម្ហិ ។ ឥទំ បន តុម្ហាកំ អាគមនំ ឥធ ពុទ្ធសាសនស្ស សុភមង្គលំ ហោតិ ។

ឥមស្មឹ ខេសេ មហាបណ្ឌិត ពុទ្ធសាសនំ អនុក្កមេន វឌ្ឍតិ ។ កុំពេញ- ពាជធានីយំ វេជ្ជបាលកា ឥស្សរជនា ឧត្តមបាលិសិក្ខាគារំ បតិដ្ឋាបេត្វា គាមនិគមជនបទេសុ វិហារេសុ អដ្ឋចត្តាឡីសុត្តន្ទិសតានិ អនុបាលិសិក្ខាគាពនិ ច ធម្មវិនយសិក្ខាគាពនិ ច បតិដ្ឋាបេសុំ ។ សំវច្ឆរេ សំវច្ឆរេ តេហិ អនុបាលិសិក្ខាគារេហិ ទ្វិសហស្សមត្តា សិស្សា អត្តនោ អត្តនោ សិក្ខំ និដ្ឋាទេសុំ ។ ឥទំ បន ឧត្តមបាលិសិក្ខាគារំ សត្តបញ្ញាសុត្តរចតុស្សតាធិកទ្វិសហស្សពុទ្ធសកេ ឧប្បន្នំ ។ ឥតោ បដ្ឋាយ យាវជ្ជតនា សត្តត្តឹស សំវច្ឆរានិ បរិបុណ្ណានិ ។ អបរានិបិ ធម្មវិនយសិក្ខាគារានិ ពជាន្តរំ និស្សាយ បរមរាជូបត្ថម្ភេ បតិដ្ឋាបិតានិ ។ តានិ សិក្ខាគារានិ ពុទ្ធសាសនេ ធម្មវិនយសិក្ខាបនដ្ឋានានិ ច ហោន្តិ ពុទ្ធសាសនស្ស វុឌ្ឍឹ វ៉ៃប៊ុល្លឹ សម្បាបនានិ ច ។

អបិ ច កុំពេញ- នគរេ ពុទ្ធមាមកា ឯកាសីត្យុត្តរចតុស្សតាធិក-ទ្វិសហស្សពុទ្ធសកេ ឯកំ ពុទ្ធិកសមាគមំ បតិដ្ឋាបេសុំ ។ សោបិ-ខោ បញ្ច សំវច្ឆរានិ បត្វា បរិហីនសទិសោ អហោសិ ។ អបរេន សមយេន ទ្វេនវុត្យុត្តរចតុស្សតាធិកទ្វិសហស្សពុទ្ធសកេ ឯកោ ពុទ្ធិក សមាគមោ វជ្ជីរាសិនោ ពុទ្ធមាមកេ និស្សាយ បុន ឧប្បជ្ជតិ ។ ឥមស្ស កម្មជវោហារេន "សមាគមមិត្តសាលាបាលី" ឥតិ នាមំ ករីសុ ។ អយញ្ច អតិនវោ ពុទ្ធិកសមាគមោ ន តាវ មហប្ផលោ ហោតិ នេវ មហន្តោ ។ អវិច្ឆិន្នំ បន សំវត្តតិ ។

អតីតសំវច្ឆរេ មហាសុមេធាជដិលតិសង្ឃនាយកត្ថេរប្បមុខា គហដ្ឋ-ប្បព្វជិតា កម្មជវដ្ដពុទ្ធមាមកានំ បតិកូ ហុត្វា លង្កាទីបេ សកលលោកស្ស មហាពុទ្ធិកសមាគមំ គមីសុ ។ តតោ និវត្តនកាលេ តស្ស មហាពុទ្ធិកសមាគមស្ស បរិវារំ ចុល្លពុទ្ធិកសមាគមំ គមិស្សឹ រដ្ឋបតិដ្ឋាបេតុកាមា ហោន្តិ ។ សោ បន ឥមានិ ន តាវ ឧប្បជ្ជតិ ។ ឥធ បន មហាបណ្ឌិត ពុទ្ធមាមកា តំ អវិដ្ឋហិត្វា បតិដ្ឋាបេតុំ វាយមន្តិ ។ សោ សមាគមោ ឧប្បជ្ជិស្សតិ យេវ ។

កថាបរិយោសានេ វត្តនត្ថយស្សានុភាវេន ចេវ សកលលោកេ មហាទិកវត្តមិ អានុភាវេន ច "អាយុ វណ្ណា សុខំ ពលំ" ឥតិ ចត្តារោ ធម្មា តុម្ហាកញ្ច លង្កាទីបវាសិនញ្ច វឌ្ឍន្តូ'តិ សច្ចវចនំ ភណាមិ ។

លង្កាទីបវាសិកា ច កម្មជវដ្ដវាសិកា ទេវតា ច មេត្តចិត្តេន អញ្ញមញ្ញស្ស ហត្ថេ គហេត្វា សមគ្គា ហុត្វា ពុទ្ធសាសនំ វុឌ្ឍាបេន្តិ ។

(មហាវង្ស)

តាន្តិសទិយា

ទស្សនាវដ្តី ផ្សាយធំណាំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែសីហា លេខ ៨

ព. ស. ២៤៩៤ — គ. ស. ១៩៥១



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
ពុទ្ធសាសនានឹងគ្រឹស្តសាសនា (សន្និសិទ លោកវេជ្ជបណ្ឌិតមីគូត៍) (តមក)...	លោកភ័យ-ប៊ុក	៥៦៤
ពន្លឺអាស៊ីទូប (តមក).....	លោកភ័យ-ប៊ុក	៥៧០
ឃរាវាសធម្មកថា	ព្រះគ្រូមុនីសោភ័ណ សេខ-នាង..	៥៧៥
ផ្នែកអក្សរសាស្ត្រ		
ការបណ្តុះនិស្ស័យ (តមក).....	ព្រះមហាឧត្តមវិជ្ជា ប៊ុង-ម៉ម	៥៨៤
អឺវ្កែណា-សិម្ប៉ាណា (តមក).....	លោកផេង-ជ្រើរ.....	៥៩៣
រឿងសាមកុក (តមក).....	ឧកញ៉ា ឆ្ង-កន.....	៦០១
ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក)..	ឧកញ៉ា ឈឹម-ក្រសេម	៦១៤
រឿងអារក្សថ្លែងរឿងម្តែប្រាំ (តមក)....	លោកសាង-សារ៉ាត	៦១៩
កំណត់ទឹកប្រាក់ក្នុងការណ៍		
ដំណើរមកកាន់ប្រទេសកម្ពុជានៃមហាបណ្ឌិត គុណបាលបិយសេន ម៉ាល៉ាល់ះសេកេរៈ (តមក) ពុទ្ធសាសនបណ្ឌិត្យ.....		៦២៨

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដាវ ១៤.៥ រ.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE — Pages

Bouddhisme et Christianisme (Conférence du Docteur A. Migot) (suite)	M. RAY-BUC	564
La Lumière de l'Asie (suite)	M. RAY-BUC	570
Gharàvàsa dhammakathà	PREAH KROU MONISOBHANA SEK-NEANG	575

PARTIE LITTERAIRE

Education morale (suite)	Prah Maha PEUNG-PAM	584
Histoire d'Hélèna-Simiana (suite)	M. PHENG-CHRIEU	593
Histoire de SAMKOK (suite)	Oknha NOU-KAN	601
Histoire du Royaume du Cambodge (suite)	Oknha CHHIM-KRASEM	614
Les vingt-cinq récits du mauvais génie «Conte indien» (suite)	M. SANG-SAVATH	619

NOTES ET CHRONIQUES

Voyage au Cambodge du Dr. G.P. Malalasekera, Président du Centre mondial des Bouddhistes de Ceylan (suite	Institut Bouddhique	628

Prix d'abonnement annuel comprenant 12 numéros: 145$00

ប្រទេសកម្ពុជា ចូលជាសមាជិក

នៃពុទ្ធិកសមាគមពិភពលោក នៅលង្កាទ្វីប

បាប់តាំងពីឆ្នាំ ១៩៥១ នេះតទៅ

កាលនៅថ្ងៃទី ២៥ ខែឧសភាឆ្នាំ ១៩៥១ ពុទ្ធិកសមាគមពិភពលោក បានធ្វើមហាសន្និបាត ដោយការអញ្ជើញប្រទេសកាន់ពុទ្ធសាសនាចំនួន ៣២, មានអ្នកតំណាង ១៣២ នាក់ទៅជួបជុំ ។ ក្នុងមហាសន្និបាតនោះ គណៈប្រតិភូខាងព្រះពុទ្ធសាសនានៃប្រទេសខ្មែរយើង មានសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកជាប្រធាន បានសុំឲ្យប្រទេសកម្ពុជាចូលជាសមាជិក នៃពុទ្ធិកសមាគមពិភពលោក នៅលង្កាទ្វីប ។ ឯប្រាក់មួយពាន់រូពី (រូពិយ)ដែលប្រទេសជាសមាជិកត្រូវបង់រៀងរាល់ឆ្នាំ ដើម្បីចំណាយក្នុងការផ្សាយពុទ្ធសាសនាទៅក្នុងសាកលលោក នោះប្រទេសកម្ពុជានឹងផ្ញើទៅជូនពុទ្ធិកសមាគមពិភពលោកក្នុងបុណ្យឆ្នាំ ១៩៥១ នេះ ។

ពុទ្ធសាសនបណ្ឌិត្យ

ពុទ្ធសាសនា និង ក្រិស្តសាសនា

សន្ទនាទំនោរវេជ្ជបណ្ឌិត មីគ្លូត

លោក ភ័យ-ប៊ិក ក្រុមការ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីទស្សនាវដ្តី « ហ្វង់អាស៊ី » ខែមិថុនា ឆ្នាំ ១៩៥០

(តមក)

តាមលទ្ធិមហាយាន, យើងអាចស្វែងរកយើញនូវឧត្តមគតិព្រះពោធិសត្វ ដែលព្រះអង្គទ្រង់ទេសនាចំពោះសីលធម៌ខាងព្រះពុទ្ធសាសនា អាចវិវត្តន៍ទៅកាន់ព្រហ្មវិហារដ៏ជាថ្នាក់ខ្ពស់បំផុត ។ សាវកមិនបានស្វែងរកព្រះនិព្វានចំពោះអាត្មា តែឡប់ទៅអធិដ្ឋានក្នុងចិត្តថា នឹងជួយស្រោចស្រង់សត្វលោក ប្រកាសបំណងព្រះពោធិសត្វដែលមានអត្ថបទមួយសំដែងដោយក្បោះក្បាយថា : "តើនៅ[1] ក្នុងចក្រវាឡនេះ, ខ្ញុំអាចតាំងខ្លួនជាអ្នកស្រោចស្រង់សត្វលោកបានឬ? តើខ្ញុំអាចយល់បានថាពួកសត្វលោកនេះជាមាតា, ជាបិតា, ជាបងស្រី, ជាបងប្រុសរបស់ខ្ញុំ ហើយខ្ញុំអាចជាមគ្គុទ្ទេសក៍នៃសត្វទាំងអស់ ឲ្យឆ្ពោះកាត់មហាសាគរទៅកាន់កោះគឺនិព្វានបានឬ? ។ តាំងពីនោះមក ព្រះពោធិសត្វទ្រង់បានប្រព្រឹត្តនូវគុណធម៌ដ៏ឧត្តមតាមថ្នាក់តាមជាន់ ដើម្បីនឹងឲ្យព្រះអង្គទ្រង់ផុតចាកវដ្តសង្សារទៅកាន់ព្រះនិព្វាន ។ តែក្នុងពេលដែលព្រះអង្គទ្រង់

---

១ ពោធិចរិយាវតារ ។

អន្ទោលយកកំណើតក្នុងភព ទ្រង់តែងមានទុក្ខចិត្តជានិរន្តរកាលចំពោះ
សត្វលោកដែលវង់ទុក្ខលំបាក ទ្រង់មានព្រះទ័យមេត្តាករុណាចំពោះ
សព្វសត្វ ។ ដោយទ្រង់ទំព្យាយាមបំពេញពុទ្ធការកធម៌ជាច្រើនជាតិ
ទ្រង់បានសម្រេចនូវព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ ហើយទ្រង់ក៏លះបង់
ប្រយោជន៍ផ្ទាល់ព្រះអង្គ ដើម្បីប្រយោជន៍សត្វក្នុងសាកលលោក, ទ្រង់
ស្ថិតនៅក្នុងវដ្តសង្សារ ដើម្បីទំនុកជួយស្រោចស្រង់សត្វឲ្យផុតចាកទុក្ខ ។
ឧត្តមគតិនៃព្រះមហាបុរសប្រកបដោយវីរភាព , មានពណ៌នានៅក្នុងអត្ថ-
បទជាច្រើន ។ ចំណែកខាងគម្ពីរ "សិក្សាសមុច្ច័យ" ពោលថា: ត្រូវ
តែអាត្មាទទួលកាន់ការខាងមិនបានចំពោះការ: គឺទុក្ខលំបាករបស់សត្វ
លោក ។ ដោយមិនបានគិតតឹមតែការរួចផុតស្រឡះពីវដ្តសង្សារចំពោះ
អាត្មាទេ អាត្មាមានសទ្ធុះចិត្តយ៉ាងមាំ ចង់ដឹកនាំសត្វឲ្យទៅកាន់ព្រះប្រាជ្ញ
ញាណនៃព្រះសម្មាសម្ពុទ្ធទៀតផង ។ ត្រូវតែអាត្មាទទួលទុក្ខលំបាករបស់
សត្វលោកទាំងអស់; អាត្មាអាចប្រើរូបនេះ ឲ្យទទួលនូវទុក្ខរបស់ប្រជា
ការទាំងអស់ ដើម្បីនឹងធ្វើលោកឲ្យផុតចាកទុក្ខ, បានជាអាត្មាមានចិត្ត
ប្រាថ្នាចង់ត្រាស់ជាពុទ្ធភូមិ" ។ តើគេអាចយល់ឃើញបាន តាមព្រះ
បរមពុទ្ធាភិនីហារលើនេះនូវសីលធម៌ដ៏វិសេស ដែលកើតឡើងដោយ
បហានធម៌ ដូចគេបានឃើញនូវការប្រែប្រួលខាងសីលធម៌នៃព្រះ
គ្រិស្តដែរឬ? រឿងដែលពណ៌នានេះមិនគឺពីលើកម្មដែលមានន័យខាង

ព្រះគ្រិស្ត កុងមហាយ័ញ (Rédemption) ដើម្បីនឹងធ្វើឲ្យមនុស្សទាំងអស់កុងលោកបានរួចផុតពាកទុក្ខទាំងពួងឬ? ។

អ្នកយើញថា: សីលធម៌ទាងព្រះពុទ្ធសាសនា គឺមិនមែនសីលធម៌ប្រកបដោយអកម្មនឹងថ្មីជាសាម័ញ្ញ ដែលគេតែងពោលជាញឹកញយដោយគ្មានយល់នូវអត្ថរសនឹងទម្រង់នៃសីលធម៌នោះឡើយ ។ សីលធម៌នោះ មិនមែនមានសភាពអន់ខន់ខ្សោយជាងការប្រៀនប្រដៅទាងគ្រិស្តសាសនានោះទេ ។ តែគេមិនដែលបានយើញទាងការប្រៀនប្រដៅនៃព្រះពុទ្ធតែងការប្រើការុណកម្ម, បញ្ចេញនូវសេចក្តីក្រោធភ្លាម។ តំនុំព្យាបាទហើយនឹងពោលពាក្យផរុសវាចា ដែលគេទុកជាអន្តរាយកាសកុងការប្រព្រឹត្តិនូវកំណាចដោយផ្ទាល់ខ្លួនឬច្រើនគ្នា ដែលមិនគួរនឹងយកមកពណ៌នានៅទីនេះ[1] ។ ការសិក្សានៃព្រះពុទ្ធសាសនាឲ្យកើតសទ្ធិភាព នឹងវិមុត្តិភាព ដែលទាងគម្ពីរគ្រិស្តសាសនាមិនដែលមានពោលសោះ ។

---

១ ខ្ញុំបងំពោលអំពីពាក្យផរុសវាចាសម្បើមអស្ចារ្យនៃព្រះយេស៊ូ ដែលពណ៌នាចំពោះជនសុីហ្វ ។ ពាក្យផរុសវាចានោះ គឺជាលេសមួយក្នុងចំណោមលេសទាងអស់ដែលតំាឲ្យលទ្ធិអងសេមីទិស្ម (លទ្ធិដែលយល់ផ្ទុយគ្នាពីយោបល់ជាតិសុីហ្វឬហេប្រ៊ី) ដែលតំាឲ្យវិនាសដោយធ្វើឲ្យលោហិតហូរក្នុងពិភពលោកមានខមហាសង្គ្រាមលើកក្រោយជាដើម ។ មានអ្នកនិពន្ធមានប្រាជ្ញាម្នាក់ បានពោលក្នុងសៀវភៅមួយដែលមានសង្ឃឹមញ្ញាតពីបើរសភាកតូលិក បានបញ្ជាក់អំពីការធ្វើឃាតកម្មពួកសុីហ្វនៅទារុណកម្មស្ថាន (Campd'extermination) នៃពួកណាស៊ី (nagi) ពន្យល់ថា ទារុណកម្មនៃជាតិសុីហ្វនេះអាចិទេវបញ្ជូត្ត អ្នកនិពន្ធនេះ: មិនបានពោលបំពោះអាចិទេវបំណងបំពោះអ្នកពិឃាតឯទៀត (ស.អ៊ិសាអាក់អ្នកនិពន្ធរឿង "សេស៊ុលនិងអ៊ីស្រាអែល" ដោះពុម្ពនៅបណ្ណាគារអាបាំងមីសែលប៉ារីស) ។

មានន័យមួយដែលធ្វើឲ្យសីលធម៌ខាងព្រះពុទ្ធសាសនា មានវឌ្ឍនធម៌ឲ្យពិតប្រាកដឡើង គឺលទ្ធិអហឹសាភាព (non violence), សិក្ខាបទ ទី ១ នៃវិន័យខាងសាសនាស៊ុយដាអ៊ិកគឺដូចគ្នានឹងសិក្ខាបទទី ១ ខាងពុទ្ធបញ្ញត្តដែរ : "ឯងមិនត្រូវសំម្លាប់សត្វទេ" ។ ព្រះគ្រិស្តបានពន្យល់អំពីតម្លៃនៃសិក្ខាបទនេះ ហើយបានបញ្ចូលគ្រិស្តោវាទឯទៀតជាច្រើនដែលពាក់ព័ន្ធអំពីជាដំហាវ្យព្រះគ្រិស្តដោយអំណាចនៃព្រហ្មវិហារ កុំឲ្យតបតនឹងការយោរយៅអ្នកដទៃ : "បើគេវាយថ្ពាល់ស្តាំត្រូវបង្ហាញថ្ពាល់ស្តាំឲ្យគេវាយទៀត ត្រូវឲ្យស្រឡាញ់បច្ចាមិត្រ" ។ ពិភពលោកបានប្រកាសរឿងនេះច្រាំមួយសតវត្សមកហើយមុនព្រះគ្រិស្ត ។ យើងបានយកឧទាហរណ៍ជាច្រើនមកពណ៌នា, យើងនឹងអាចយកឧទាហរណ៍ឯទៀតមកសំដែងនៅទីនេះទៀតក៏បាន, គេបានឃើញជាពិសេសតាមទម្រង់ផ្សេងៗ ខ្លះគម្ពីរជាតកគ្រប់ទំព័រ គេបានពណ៌នាអំពីរឿងរ៉ាវនៃសីលធម៌ខាងពុទ្ធសាសនាដោយក្បោះក្បាយ ។

ព្រះពុទ្ធសាសនាបានរក្សាខ្លួវការសិក្សាខាងលើនេះ ទុកជាការសិក្សាសំខាន់ ។ សម័យបច្ចុប្បន្នដូចជាពីសម័យអតីតដែរ បើមានសង្គមណាមានអន្តរាគាសយ៉ាងណាក៏ដោយ ព្រះពុទ្ធសាសនាទុកការពិយោតនេះ ជាកិច្ចលាមកបំផុត ។ សង្គ្រាមកន្លងលោក, ការឈ្លក់ចិត្តទៅក្នុងយោធាយ ឬមនោសញ្ចេតនា, កិច្ចដែលត្រូវការពារខ្លួនៗឯង នឹងការ

ជំនុំជំរះសាលាតុលាការ មិនអាចឃាត់មនុស្សមិនឲ្យសម្លាប់គ្នា ឬបន្ទុយ នូវការពិឃាតឲ្យមានសភាពថយចុះសោះឡើយ ហើយការហាមមិនឲ្យពិឃាតនោះមិនមែនមានព្រំដែនត្រឹមតែមនុស្សទេ គឺរាប់ទន័យនោះដល់សត្វលោកទាំងអស់រហូតដល់សាមញ្ញសត្វ ។ ពួកពុទ្ធមាមកជនពិតៗ មិនទៅបរបាញ់ទេ, មិនសម្លាប់សត្វសោះឡើយ ហើយស្វែងរកទុំបាយ មិនធ្វើទុក្ខលំបាកដល់សត្វដែលមានជីវិតសោះឡើយ ។

ឯពួកគ្រិស្តសាសនិកជនអនុម័តិថាសិក្ខាបទ "មិនពិឃាតសត្វ" ទៅជាទោសវិញ ពាល់តែសិក្ខាបទនោះរលុបរលាយ គ្មានជាអវសាន ។ ពួកនិកាយខាងគ្រិស្តសាសន៍សម័យបច្ចុប្បន្ន យល់ថាសិក្ខាបទនេះមានន័យផ្ទុយគ្នានឹងគ្រិស្តាវាទ ។ ដោយវិចារណញ្ញាណខាងន្យោបាយ ពួកនិកាយនេះបានបញ្ជាក់ថា ការពិឃាតប្រកបដោយសមូហភាពជាកិច្ចដ៏ប្រសើរ ដោយយល់ថាលទ្ធិបែបនេះគេទុកជា "សង្គ្រាមប្រកបដោយសច្ចៈ" ។ និកាយនេះ បានសរសើរនូវភក្តីនាមនៃពួកយោធា បានទុកថាពួកនេះ ដែលអនិច្ចកម្មកន្លងទីសមរភូមិ ជាទុក្ករបុគ្គលដ៏វិសេស, យកគ្រឿងសស្ត្រាវុធសម្លាប់ពិឃាតជាប្រធាន, និកាយនេះ បានយកអន្តរោកាសប្រកបដោយមនុស្សភាពទៅកាន់សង្គ្រាម ដោយយកប្រទេសដទៃ ធ្វើជាអាណានិគម ឬសង្គ្រាមដោយប្រើលទ្ធកម្មខាងអាវុធ ។ កិច្ចនេះនាំឲ្យរំដួលជាខ្លាំងខាងផ្លូវប្រជា. ក្នុងសម័យបច្ចុប្បន្ន គេទុកសង្គ្រាម

ថាជាកិច្ចវៀលដ៏សំខាន់ចំពោះប្រជាពលរដ្ឋ ដែលគ្មានសំឡេងណាមួយ ហ៊ានបញ្ចេញចំពោះអ្នកតំណាងជាផ្លូវការមួយខាងគ្រិស្តសាសនា ដើម្បីនឹងពោលពាក្យបន្ទោសចំពោះមុខពេញលក្ខណៈ ពីរឿងការសង្គ្រាមទាំងអស់ ក្នុងសាកលលោកព្រមទាំងអ្នកដែលបង្កនូវសង្គ្រាមទាំងនោះបានឡើយ បើទុកជាអ្នកទាំងនោះបានឲ្យអន្តរកាសយ៉ាងណាក៏ដោយ ។

តែដែលនាំឲ្យពុទ្ធមាមកជនទាំងឡាយរំជួលជាខ្លាំង គឺសង្គ្រាមខាងសាសនា ។ ព្រោះហេតុដូម្តេច បានជាគ្រិស្តសាសនិកជនពិឃាតគ្នាទៅវិញទៅមក ដោយអាងថាអំពើទុក្ខដ្ឋនេះ គឺធ្វើទៅតាមវិចារណញ្ញាណខាងសាសនា, ហើយកងឬរមនាមនៃព្រះអាទិទេព? ។ សង្គ្រាមសាសនា ការនាំកងទ័ពទៅច្បាំងដណ្តើមយកបូជនីយដ្ឋានព្រះគ្រិស្តទៅពីក្រុងសេរុយសាលិម (croisades) នឹងយកក្រុមតុលាការខាងគ្រិស្តសាសនាឬគ្រិស្តសកា (inquisitions) នោះ បើតាមសេចក្តីយល់ខាងពួកបូពាជាតិ ថាជាការប្រតិបត្តិផ្ទុយនឹងព្រះគ្រិស្តនឹងគ្រិស្តោវាទពិតៗ ។ ចំណែកខាងប្រទេសដែលកាន់ព្រះពុទ្ធសាសនា មិនដែលបានជួបប្រទះនូវសេចក្តីវង្វេងកាន់ច្រឡំបែបនេះសោះឡើយ ។

(មាន)

វគ្គទី ៣

La Lumière de l'Asie

លោក ស៊ីរ-អេតវ៉ាន់ អាណូលត៍ តែង

លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

ក្នុងប៉ុន្មានឆ្នាំនេះ ព្រះបាទសុទ្ធោទន: ទ្រង់មានព្រះទ័យព្រួយជាអនេកប្បការ ព្រោះទ្រង់ធ្លាប់ព្រះសណ្ដាប់នូវព្រះសូរសៀងព្រមទាំងទតនូវព្រះរូបនៃព្រះពាជនុរសរបស់ព្រះអង្គ ក្នុងចំណោមនៃមន្ត្រីធំៗក្នុងព្រះពាជវង្សានុវង្ស ។ ចំណែកព្រះនាងយសោធរាទ្រង់ព្រួយព្រះពាជហ្ឫទ័យពន់ពេក ដោយព្រះនាងឃ្លាតចាកព្រះស្វាមីជាម្ចាស់ជាច្រើនឆ្នាំ ហើយតាំងពីនោះមក ព្រះនាងមិនដែលបានក្រែបនូវឧជារសនៃសេចក្ដីសប្បាយក្នុងដីវិភាពសោះឡើយ ។ ដួនកាលមានឮដំណឹងថាមានពួកដំរីអូដក្នុងវាលខ្សាច់ទឹងពួកពាណិជដែលស្វែងលាភឆ្ងាយពីផ្លូវធម្មតា ពោលអំពីឥសីម្នាក់ដែលស្ថិតនៅស្រុកឆ្ងាយជាច់សង្វែង ។ ព្រះពាជបម្រើនៃព្រះមហាក្សត្រិបានទៅស្វែងរកគ្រប់តំបន់ ហើយត្រឡប់មកវិញថ្លែងថាឃើញតែតាបសឥសីជាច្រើនស្ថិតនៅតែឯកឯងគ្មានគេហដ្ឋាន; តែគេមិនបានតំណឹងពីព្រះពាជនុរស ដែលជាទីគោរពនៃព្រះពាជវង្សានុវង្សក្នុង

ព្រះបរមរាជវាំងក្រុងកបិលវស្តុ, ជាកិត្តិគុណនឹងសេចក្តីសង្ឃឹមនៃព្រះមហាក្សត្រិយ៍ជាព្រះបរមរាជបិតា ហើយជាទីពេញព្រះរាជហឫទ័យនៃព្រះនាងយសោធរា; ព្រះរាជនុរសនោះទ្រង់យាងទៅតំបន់ឆ្ងាយ, ទ្រង់ក្តេចនឹកនាមការណ៍ព្រះរាជនិវេសនដ្ឋាន ទ្រង់បែបព្រះរាជហឫទ័យជាខ្លាំង, ប្រហែលជាទ្រង់ទំនឹងត្រឡប់ហើយទេដឹង? ។ តែមានកាលមួយថ្ងៃ ក្នុងវស្សានរដូវ គឺរដូវដែលភ្លៀងធ្លាក់ស្រាយមានពន្លកត្រួយពណ៌សក្តឹដូចថ្នាក់ ហើយដែលក្រឡាប្រថពីពេញពាសដោយស្មឹកឈើខៀវខ្ចីស្រស់ បុប្ផជាតិមានបុប្ផាគ្រប់ពណ៌ ព្រះនាងទ្រង់គង់ជិតទីដែលមានទឹកហូរ ចែងចាំងក្នុងព្រះរាជឧទ្យានមានដើមបទុមដុះដេរជាស, ទ្រង់ព្រះចិន្តានឹកស្រមៃទៅឃើញដល់អតីតកាល ដែលព្រះនាងទ្រង់យាងទៅក្រសាលជាមួយនឹងព្រះស្វាមី យល់ព្រះស្វាមីយកព្រះហត្ថានុបស្នេហ៍ស្ទិទ្ធព្រះនាង ព្រមទាំងយករឹមព្រះនុស្ងច្ចុម្ពិតសើចស្រួលជាយ៉ាងក្រៃលែង ។ ដោយព្រះនាងទ្រង់ព្រះកន្សែងជាញឹកញាយ គ្របកព្រះនេត្រក៏ទន់ទោរខ្សោយជាលំដាប់, ព្រះគណ្ឋៈ (ថ្ពាល់) ដែលមានសម្ផស្សគួរឲ្យចេតនាទៅជាស្តាំងស្តម, រឹមព្រះនុស្ងដែលមានទ្រង់ទ្រាយស្រស់បំព្រង ឥឡូវស្ងួតស្រពោនដោយសេចក្តីទុក្ខលំបាក, ព្រះកេសាមានពន្ធីចាំងចែងតែងមានចុងក្បូចមូលដូចស្រមៃយ៉ាងកាន់ទុក្ខ, ព្រះនាងមិនបានទ្រង់នូវគ្រឿងអលង្ការ ហើយគ្មានគ្រឿងមាសអ្វីជាលំអនៃព្រះពស្ត្រកាន់ទុក្ខដែលមាន

សភាពគ្រែម មានពណ៌ស ដែលមានចុងព័ទ្ធរុំមកខាងព្រះខ្យូព្រះ
នាង ។ ព្រះចុងាព្រះនាងមានសភាពតូចល្អសម, ពីដើមធ្លាប់រហ័ស
រហួនដូចសត្វឈ្លូស (gazelle) ឬស្វឹកផ្កាកុលាបស្រាលហើរលើអាកាស
ក្នុងពេលដែលព្រះស្វាមីទ្រង់មានព្រះរាជតម្រិសមកម្តង។, ឥឡូវទៅជាកំ
រើកមិនរួច ។ ព្រះនេត្រព្រះនាងមានស្មើប្រកបដោយសេចក្តីស្នេហា,
ពីដើមដូចជាព្រះសុរិយាចាំងចែងក្នុងទីងងឹតអន្ធការ, តែឥឡូវមានពណ៌
ស្រអាប់ ហើយទតមិនយល់ទិសតំបន់; ព្រះនេត្រនេះពិនិត្យមិនបាន
ឃើញសព្វគ្រប់នូវអច្ឆរិយភាព នៃនិគាយ:រដូវដែលទើបនឹងបដិសន្ធិថ្មី។
ដោយហេតុថាត្របកព្រះនេត្រដែលមានព្រះលោមភ្ញីចាល ធ្លាក់ស្រ-
យង់ក្បែតជិតពីលើវង្វង់ព្រះចក្ខុ ។ នៅព្រះហស្តម្ខាង ព្រះនាងទ្រង់
កាន់ព្រះកាយពន្ធន៍ (ceinture) ដែលមានជាំគជ្យង់របស់ព្រះសិទ្ធត្ថ
ដែលព្រះនាងទ្រង់ចាន រក្សាទុកតាំងពីព្រះពោធិសត្វទ្រង់យាងទៅបព្វជា
កងវែលាក្រៃមកម្ល៉ះ ។ នុយប់នោះដោយប់ប្រកបដោយសេចក្តីទុក្ខ
លំបាកដ៏លើសលុប! តើស្នេចក្តីស្នេហារបស់ខ្ញុំ បើប្រៀបធៀបនឹង
សេចក្តីស្នេហារបស់ព្រះអង្គដែលមានចំពោះខ្ញុំ នឹងមានព្រំដែនទៅតាម
ដំរែភាពប៉ុណ្ណាទៅ? ។ ព្រះហស្តម្ខាងទៀត, ព្រះនាងទ្រង់ដឹកព្រះ
រាជបុត្រ ១ អង្គ មានលំអជាទិព្វដែលជាព្រះកេរ្តិ៍នៃព្រះសិទ្ធត្ថជាព្រះរាជ-
ស្វាមី; ព្រះរាជបុត្រនោះព្រះនាម "រាហុល" មានព្រះជន្មាយុ ៧ ឆ្នាំ

កន្លងពេលនោះ ។ ព្រះពជនុរសទ្រង់យាងដឹកព្រះវរមាតា ដោយព្រះទ័យសោមនស្សពន់ពេក ព្រោះទ្រង់ទតឃើញលុក្ខាលតាវល្ងិមានផ្លាវែក ស៊ុះស្គាយពាសពេញពិតពណ៌កន្លងនិទាយ:ដូរ ។

ព្រះវរមាតានឹងព្រះពជបុត្រ បានយាងទៅប្រថាប់នៅក្បែរស្រះបោក្ខរណីដែលមានជាំបទុម; ព្រះរាហុលទ្រង់មានសោមនស្សជាខ្លាំង ហើយទ្រង់ចាប់អង្គុយទៅឲ្យមច្ឆជាតិមានពណ៌ខៀវផ្ទៃមេឃ នឹងក្រហមឆ្អៅ; ព្រះនាងទ្រង់ឆ្ងៀងព្រះនេត្រ ដោយព្រះទ័យទុក្ខព្រួយបារម្ភជាខ្លាំង មើលទៅបក្សាក្រៀលដែលហើរលឿនលើនភាល័យ ហើយទ្រង់អដ្ឋសរ (ថ្លូ) ថា: "នុបក្សាអើយ! កន្លងពេលដែលអ្នកធ្វើដំណើរ បើអ្នកបានឃើញនូវទីកន្លែងដែលព្រះស្វាមីជាទីពេញចិត្តរបស់ខ្ញុំ ស្ថិតលាក់បំពួននៅត្រង់ណា សូមអ្នកទៅឲ្យដំណឹងព្រះអង្គផងថា បើសិនណាជានាងយសោធរាបានឮសូរសៀងព្រះនន្ទព្រះពជស្វាមី ឬទ្រង់បរាមាស (អង្អែល) ដោយព្រះហស្តដ៏ទន់តែមួយស្របក់ នាងស៊ូមរណាឥតស្តាយជីវិតសោះឡើយ" ។

កន្លងនុកាសដែលព្រះវរមាតាកំពុងទ្រង់ពិលាប ព្រះពជបុត្រកំពុងទ្រង់ក្រសាលសប្បាយ, មានពួកស្រីស្នំកន្លងព្រះបរមពជរាំងបានមកក្រាបបង្គំទូលព្រះនាងថា: "សូមក្រាបបង្គំទូលព្រះនាងទ្រង់ជ្រាប មានពួកពាណិជមកពីស្រុក ហស្តមុរ (Hastinpour) ឈ្មោះត្របុស្ស (តបុស្ស)

ទឹងកល្អក: (កល្អិក:) ចូលតាមទ្វារ ព្រះបរមរាជពាំងខាងត្បូង ជានាយ
ពាណិជធ្លាប់ធ្វើដំណើរតាមមាត់សមុទ្រ ដែលមានរលកបោកជាខ្លាំង
បានដឹកនាំសំពត់កោសេយ្យពស្ត្រ, លំពែងមានចុងលាបលនដោយមាស,
ថូស្ពាន់ធ្លាក់ភ្លុក, គ្រឿងទេស, ស្វឹកឈើឫសថ្នាំផ្សេងៗ, បក្សាដែល
កម្រទឹងបានឃើញ ទឹងកោគទ្រព្យនៃពួកប្រជាជនស្រុកឆ្ងាយ មកលក់
នៅទីនេះ តែពួកពាណិជទាំងនោះបានឃើញច្បាស់ដោយមំសចក្ខុ
ទ្វារតន:អស្ចារ្យវិសេសជាងរតន:ទាំងអស់ក្នុងលោក ។ រតន:នោះគឺ
ព្រះពាជស្វាមីរបស់ព្រះនាងជាម្ចាស់នៃយើងខ្ញុំទាំងអស់គ្នា, មហាបុរសជាទី
សង្ឃឹមនៃប្រទេសជាតិក្នុងអនាគតគឺព្រះសិទ្ធត្ថនោះឯង ។ ពួកទាំងនេះ
បានឃើញទ្វារព្រះអង្គហើយ ធ្វើការកិច្ចដោយអញ្ជលីព្រមទាំងបានបូជា
ព្រះអង្គដោយគ្រឿងអាមិសផ្សេងៗ ព្រោះព្រះអង្គដូចជាគេបាននិទាន
តាមពុទ្ធព្យាករណ៍ពីមុន, ទ្រង់ត្រឡប់ទៅជាព្រះបរមគ្រូជាម្ចាស់ បាន
ទំស្វែងរកឃើញអរិយធម៌ ជាក់ច្បាស់ដោយព្រះអង្គឯង, ជាមហាបុគ្គល
ដែលពិភពលោកតែងគោរពបូជា, ជាសន្តបុគ្គល មានព្រះប្រាជ្ញាញាណ
រកទីបំផុតគ្មាន ជាព្រះសម្មាសម្ពុទ្ធដែលបានជួយស្រោចស្រង់មនុស្ស
ឲ្យផុតពីទុក្ខ ហើយបានទុបត្ថម្ភពួកសត្វ ដោយពុទ្ធោវាទនឹងដោយ
ព្រះមេត្តាករុណាគុណដ៏ធំទូលាយ ជាអនេកប្បការជាសាធារណៈ.បើដូច
មេឃ ហើយឥឡូវពួកពាណិជនោះបានពណ៌នា អំពីព្រះអង្គដែលខ្លួន
បានឃើញទ្រង់គង់នៅទីកន្លែងនោះ ។ (មាន)

ឃពាសធម្មកថា

ព្រះគ្រូមុនីសោភ័ណ សេរ - ផាង សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ ភ្នំពេញ

ទេសនាជាវិប្បោសនៈ ពុទ្ធបរិទេសកម្ពុជា កាលពីថ្ងៃ ១៥ កើត ខែអស្សុជ ឆ្នាំកុរឧព្វស័ក ព.ស. ២៤៩ (២៩-១-៤៥)

ឥមោ តសរ្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សូមនមស្សការចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ត្រមាំងព្រះធម្មនិងព្រះអរិយសង្ឃដោយគោរព) ។

វេលានេះ អាត្មាភាពនឹងសំដែងអំពីឃពាសធម្ម ដើម្បីជាគ្រឿងប្រដាប់សតិប្បញ្ញា នៃពុទ្ធសាសនិកជនតទៅ ។

មុននឹងសំដែងញែកជាមេមាតិកានៃធម្មនេះ សូមអធិប្បាយពាក្យថា ឃពាសធម្មសិន ។

ឃពាសធម្ម ប្រែថា "ប្បាប់សម្រាប់បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ" ។ ការនៅជាប់ជាក់ជង្គា ជោយស្វាមី ភរិយា - មាតា - បិតា - បុត្រ ធីតា របស់បុរសស្ត្រីអ្នកនៅគ្រប់គ្រងផ្ទះ ហៅថាឃពាសៗ ដែលនៅរួបរួមគ្នាជាសង្គមមួយៗ រមែងមានការប៉ះទង្គិចប្រែប្រួលជាធម្មតា ប្រៀបដូចបានមួយពាវនៅកន្លែងជាមួយគ្នា រមែងវណ្តុំគ្នា ប៉ុន្តែគង់មានប្រដាប់សម្រាប់គ្រប់កុំឲ្យប៉ះទង្គិចគ្នាបាន ។

ឯចានកាលបើមានវត្ថុអ្វីមួយ ជាទ្រនាប់សម្រាប់រុំខ្ចប់អបស្ងួបហើយ គេអាចដឹកនាំទៅកាន់ទីជិត-ឆ្ងាយបានដោយស្រួលតាមប្រាថ្នា ឥតមានរណ្តំគ្នាឬប្រែស្រាំឆែបឆាឡើយ មានគួរនាយ៉ាងណាមិញ មានគួរនាដូចជាបុគ្គលអ្នកគ្រប់គ្រងផ្ទះ ក៏ត្រូវមានឃាវ៉ាសធម៌នេះជាទ្រនាប់ គឺជាច្បាប់សម្រាប់ប្រតិបត្តិ មិនឲ្យឃ្លាងគំនិតគ្នា ដើម្បីឲ្យកើតសេចក្តីសុខស្រួលក្នុងសង្គមនីមួយៗ ដូច្នោះដែរ ។

ឃាវ៉ាសធម៌នោះ តាមច្បាប់ព្រះពុទ្ធសាសនាមានច្រើនយ៉ាង ។ ក្នុងទីនេះ ទំនងសំដែងតែឃាវ៉ាសធម៌ ៤ យ៉ាង ដែលមាននៅក្នុងគម្ពីរព្រះសុត្តន្តបិដក ភាគ ៣០ ត្រង់ឃក្ខសំយុត្ត ។

ឃាវ៉ាសធម៌ ៤ យ៉ាងនោះ គឺ :

១ -	សច្ចៈ	ការទៀងត្រង់
២ -	ទម:	ការទូន្មាន
៣ -	ចាគ:	ការបរិច្ចាគ ។

សូមអធិប្បាយមួយម្តងៗ ឲ្យសមគួរដល់ភាពជាឃាវ៉ាសធម៌ ដើម្បីជាសាធារណៈប្រតិបត្តិតទៅ ។

សច្ចៈ - ការធ្វើកាយ - វាចា - ចិត្តឲ្យទៀងត្រង់ ស្មោះចំពោះដល់គ្នានឹងគ្នា ហៅថាសច្ចៈ។ នេះ ចានដល់ភាពនៃបុគ្គលជាអ្នកទៀងត្រង់នឹង

សំឡាញ់ មិនត្រូវស្គាល់តែមានចិត្តស្មោះត្រង់នឹងគ្នា, – ទៀងត្រង់ចំពោះ
កាលវេលា ដែលជាពេលត្រូវចូលត្រូវចេញ, – ទៀងត្រង់ចំពោះកិច្ច
ការដែលជាមុខក្រសួងខ្លួនត្រូវធ្វើ ។ ដូចជាទាសកម្មករត្រូវទៀងត្រង់
នឹងចៅហ្វាយនាយ។ ត្រូវទៀងត្រង់នឹងទាសកម្មករ, ស្វាមីនឹងភរិយាត្រូវ
ត្រង់នឹងគ្នាពប់រកគ្នាមិនក្បត់ចិត្តគ្នា, មាតា-បិតានឹងបុត្រ-ធីតា ត្រូវ
ទៀងត្រង់នឹងគ្នា, ប្រជាជនត្រូវទៀងត្រង់គោរពកោតក្រែងចំពោះ
រាជការរដ្ឋាភិបាល ។ ចំណែករាជការរដ្ឋាភិបាល ត្រូវទៀងត្រង់នឹង
ប្រជាជនដែលជាពលរដ្ឋ ដោយការគ្រប់គ្រងរក្សាគ្រប់កាលវេលា ដូច
ជាមាតា-បិតាបីបាច់រក្សាបុត្រ-ធីតាដូច្នោះ ឲ្យមានការទំនុកទុកចិត្តទៅវិញ
ទៅមក, ការទៀងត្រង់ទាំងអស់នេះ ហៅថាសច្ចៈ ។

សច្ចៈនេះ ជាគុណអាចធ្វើបុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ ឲ្យជាទីគោរព
កោតក្រែងនៃជនដទៃ ដូចសេចក្តីដែលពោលមកនេះ ហេតុនោះទើប
ឈ្មោះថា ឃរាវាសធម៌ ដោយប្រការដូច្នេះ ។

ទម – ការហឹកហឺនខ្លួនខ្លួនឲ្យប្រាសចាកភ័យអន្តរាយ ឲ្យប្រាស
ចាកការគ្នាំគ្នង់ថោកទាប ដើម្បីឲ្យមានបែបបទសណ្តាប់ធ្នាប់ ចរិយាល្អ
ឈ្មោះថាទម:។ នេះ លោកនៃប្រាប់សេចក្តីផ្សេង។ គ្នា គឺជួនកាលលោក
ប្រាប់ថាបានដល់តន្ត្រីយសំរេ: "ការសង្កើមតន្ត្រីយ", ជួនកាលថាបាន
ដល់វិបស្សនាបញ្ញា "ប្រាជ្ញាជាគ្រឿងឃើញច្បាស់" ។ តែកន្លែងនេះ

សំដៅយកការហាត់ពត់កាយ - វាចា - ចិត្ត ឲ្យមានចរិយាល្អ សុភសុភាព ភបសា កុំឲ្យប្រព្រឹត្តទុច្ចរិតផ្សេងៗ កុំឲ្យប្រព្រឹត្តនូវអបាយមុខដែលជាផ្លូវនាំឲ្យវិនាស ខិលខូចប្រឡែសបើសដើរលេងល្បែងផ្សេងៗ ដោយប្រការណាក៏ឥតប្រយោជន៍ ។

មួយទៀតបុគ្គលត្រូវបង្ហឹកខ្លួន ឲ្យបានសមគួរដល់វ័យទាំង ៣ គឺវ័យទី ១ ត្រូវខំប្រឹងសង្វាតរកវិជ្ជា កុំបណ្តោយឲ្យវ័យទី ១ កន្លងទៅឥតប្រយោជន៍, វ័យទី ២ ត្រូវចុះដៃធ្វើការស្វែងរកទ្រព្យសម្បត្តិឲ្យបានគាន់វ័យនៅមានកម្លាំង កុំខ្ជិលទម្រេតដំអក់ទម្រន់, វ័យទី ៣ ត្រូវមើមាស្រាវរកធម៌ មកប្រតិបត្តិបម្រុងប្រាណឲ្យបានជាទីពឹងទៅកន្លងលោកខាងមុខ; ការបង្ហាន់ខ្លួនកន្លងវ័យទាំង ៣ នេះ ហៅថាទម: ។

មែនពិត ពួកមនុស្សតាមតែក្នុងប្រទេសណា ជម្ឈន់ណាក៏ដោយ បើប្រាសចាកធម៌ទម:នេះហើយ មិនយូរប៉ុន្មានទេ ពួកមនុស្សនៅក្នុងប្រទេសនោះ ជម្ឈន់នោះ មុខជានឹងវិវរយើការយោគគ្នានសណ្តាប់ធ្នាប់ ជាហេតុឲ្យចោកជាតិ ខាបវាសនាថយចុះស្រឡឹមទៅតាមលំដាប់ រហូតដល់បានឈ្មោះថា ជាមនុស្សកំពោលឬមនុស្សព្រៃ អំពីសំណាក់លោកអ្នកប្រាជ្ញគ្រប់សម័យ ។

ទម:នេះ ជាគុណធ្វើមនុស្សចោកខាប ឲ្យបានខ្ពង់ខ្ពស់មានសណ្តាប់ធ្នាប់ចរិយាល្អ អាចក្រៃឡែជាតិ តែវាសនា ឲ្យក្លាយទៅជាអរិយៈទី ១

ក្នុងអរិយៈ៣ ៤ ពួក គឺ: អាចារិយៈ (ខ្ពង់ខ្ពស់មារយាទ) ១, ទស្សនារិយៈ (ខ្ពង់ខ្ពស់ដោយការឃើញ) ១, លិង្គារិយៈ (ខ្ពង់ខ្ពស់កេទ) ១, បដិវេធារិយៈ (ខ្ពង់ខ្ពស់ដោយការត្រាស់ដឹង) ១ ។ អ្នកដែលបានដល់នូវភាពដ៏ថ្លៃថ្នូរយ៉ាងនេះ ក៏ដោយមានទមធមិនៅប្រចាំក្នុងចិត្ត ហេតុនោះទើបឈ្មោះថា យាវ៉ាសធមិ ដោយប្រការដូច្នេះ ។

បិពិ– ការទប់ចិត្តចំពោះសេចក្តីទុក្ខ ដែលជាហេតុឲ្យកើតសោក: រោស: មោហ: ហៅថាបិតិ ឬហៅថាខន្តិ (សេចក្តីអត់ធន់) ក៏បាន ។

ការអត់ធន់ចំពោះសេចក្តីទុក្ខ ដែលជាហេតុឲ្យកើតសោក:នោះ បានដល់ការអត់ធន់ចំពោះចំណង់ផ្សេង ។ ដែលកើតឡើងក្នុងទ្វារទាំង ៦ មានការអត់ធន់មិនប្រព្រឹត្តទុច្ចរិតតាមចំណង់ ឬសេចក្តីស្រេកឃ្លានោះ។ ព្រោះបុគ្គលអ្នកមិនចេះអត់ធន់នឹងចំណង់ ឬសេចក្តីស្រេកឃ្លានហើយ មុខជានឹងលួចឆក់ដណ្តើមបំបាត់ប្រព័ន្ធទ្រព្យសម្បត្តិរបស់គេ, កាលបើប្រព្រឹត្តទុច្ចរិតដូច្នោះ រមែងជួបប្រទះនឹងសេចក្តីទុក្ខព្រួយ ដែលជាផលរបស់ទុច្ចរិតនោះ។ មានត្រូវរោសជាប់គុកជាប់ច្រវាក់ជាដើម ។ បុគ្គលឯណា ចេះទប់ចិត្តមិនរវែរវាមហួសពេក បុគ្គលនោះឯងតែងជួបប្រទះនឹងសេចក្តីសុខ-ចំរើន ។ ការអត់ធន់យ៉ាងនេះ ហៅថាអត់ធន់ចំពោះលោក: ។

ការអត់ធន់ចំពោះទុក្ខ ដែលជាហេតុឲ្យកើតរោស:នោះ បានខាងការអត់ធ្មត់នឹងពាក្យបរប្បាទដែលបុគ្គលដទៃស្តីថា តួះតិះដៀល ឬអត់ធន់

ចំពោះបុគ្គលដទៃបៀតបៀន ដែលជាហេតុឲ្យកើតទោសៈ ដូចនៅក្នុងសង្គមនីមួយៗ គឺស្វាមីនឹងភរិយា ត្រូវមានសេចក្តីអត់ធន់ទៅវិញទៅមកវាគ្នា មាតាបិតានឹងបុត្រធីតា ចាស់ក្មេងនឹងចៅហ្វាយនាយ, ប្រជាជននឹងរាជការរដ្ឋាភិបាល ក៏ត្រូវមានសេចក្តីអត់ធន់ មានការគោរពរាប់អានគ្នាជាទីទុក្ខចិត្តគាំទៅវិញទៅមក យ៉ាងនេះជាដើម ហៅថាការអត់ធន់ចំពោះទោសៈ ។

ឯសេចក្តីអត់ធន់ចំពោះសេចក្តីទុក្ខ ដែលជាហេតុឲ្យកើតមោហៈ នោះបានដល់ការអត់ទ្រាំនឹងទុក្ខវេទនាលំបាកផ្សេងៗ ដែលកើតឡើងក្នុងកាយនឹងចិត្ត មិនឲ្យលុះក្នុងអំណាចទុក្ខវេទនាហើយទៅប្រព្រឹត្តទុច្ចរិតឡើយ ។ សូម្បីការអត់ទ្រាំនឹងទុក្ខវេទនាក្នុងវេលាឈឺថ្កាត់នោះសោតក៏ជាហេតុជួយឧបត្ថម្ភឲ្យមានសតិសម្បជញ្ញៈ គឺសេចក្តីរឭកនឹងសេចក្តីដឹងខ្លួនដែលជាគុណវិសេសគួរឲ្យមានក្នុងចិត្តគ្រប់កាលទាំងពួង ។ ពុំនោះសោតក្នុងវេលាមានព្យាធិ ដែលជាហេតុឲ្យដល់មរណៈ ក៏ត្រូវតែមានការអត់ធន់ទានមិនបាន ព្រោះថា បុគ្គលណាកាលបើបណ្តោយឲ្យមោហៈគឺសេចក្តីវង្វេងកើតឡើង ទីងធ្វើការអ្វី ក៏ធ្វើទាំងកំរោលទាំងងងឹត, គិតការអ្វីក៏គិតទាំងបំពាន បុគ្គលនោះរមែងទទួលផលនៃសេចក្តីទុក្ខដោយពិត ។

បុគ្គលឯណាអត់ទ្រាំចំពោះទុក្ខវេទនា ដែលជាហេតុឲ្យប្រព្រឹត្តទុច្ចរិតផ្សេងៗ, បុគ្គលនោះ រមែងទទួលផលនៃសេចក្តីសុខចំរើន បើមិនច្រើនក៏តិចពុំខាន ។ ការអត់ធន់បែបនេះ ហៅថាអត់ធន់ចំពោះមោហៈ ។

ការបញ្ឈប់ទប់ចិត្តចំពោះសេចក្តីទុក្ខ ដែលជាហេតុឲ្យកើតលោភៈ
ទោសៈ មោហៈ ដូចពោលមកហើយថាបឋិតិ។ នេះ ជាគុណធ្វើបុគ្គលអ្នក
គ្រប់គ្រងផ្ទះ ឲ្យជាទីស្រឡាញ់ពេញចិត្តនៃជនច្រើនគ្នា, មិនឲ្យមាន
ពៀរវែងច្រើន មិនឲ្យមានទោសច្រើន មិនឲ្យភ្ញាំងភ្លេចស្មារតីក្នុងវេលា
ជិតស្លាប់, លុះស្លាប់ហើយទៅកាន់លោកខាងមុខ នឹងបានកើតក្នុងសុគតិ-
ភព ហេតុនោះ ទើបឈ្មោះថា ឃរាវាសធម៌ ដោយប្រការដូច្នេះ ។

បាគៈ – ការចំណាយទ្រព្យសម្បត្តិ ទំនុកបម្រុងព្រះពុទ្ធសាសនា
កសាងសេនាសនៈ លើកថ្កល់ សង់ស្ពាន ជីកអណ្តូងទឹក សង់សាលា
សម្រាប់បម្រុងការសិក្សារៀនសូត្រ សង់មន្ទីរពេទ្យ សម្រាប់ព្យាបាលអ្នក
ជម្ងឺជាដើម ហៅថាបាគៈ ។

ពុទ្ធសាសនិកជន ជាអ្នកមានកតញ្ញូកតវេទី គោរពរាប់អានព្រះពុទ្ធ-
សាសនា តែងតែចំណាយធនធានបូជាព្រះពុទ្ធសាសនា ដូចជាកសាង
កុដិ-សាលា-វិហារជាដើម ទើបឈ្មោះថាជាអ្នកគោរពចំពោះសាសនា
យ៉ាងណា ប្រជាជនដែលជាពលរដ្ឋ ក្នុងប្រទេសនីមួយៗក៏យ៉ាងនោះដែរ
គឺត្រូវតែបរិច្ចាគទ្រព្យបូជាជាកដពលី មានបង់ពន្ធជារាសម្រាប់ប្រទេសជា
ដើមទើបសមស័ក្តិខ្លួន ជាពលរដ្ឋរបស់ប្រទេស, ទាំងអស់នេះក៏ហៅថា
បាគៈដែរ ។

ចាគៈនេះទុកជាស្នេហ៍មុខធ្វើមនុស្សអ្នកនៅគ្រប់គ្រងផ្ទះ ឲ្យបានជាទីចាប់ចិត្តពាក់អាននៃទេវតានឹងមនុស្សពាំងឡាយ ហេតុនោះទើបឈ្មោះថាយកវាសធម៌ ដោយប្រការដូច្នេះ ។

ធម៌ទាំង៤ប្រការនេះ បើមានបរិបូណ៌ក្នុងបុគ្គលឯណា បុគ្គលនោះតែងបាននូវសេចក្តីសុខ-ចំរើន រីកាយមិនត្រឹមតែចិត្តក្នុងលោកនេះនឹងលោកខាងមុខដោយពិត ។ ព្រោះហេតុនោះបានជាព្រះទសពលត្រង់សំដែងថា:

យស្សេតេ ចតុរោ ធម្មា សទ្ធស្ស ឃរមាសិនោ
សច្ចំ ទមោ ធិតិ ចាគោ សវេ បេច្ច ន សោចតិ
ឥង្ឃ អញ្ញេបិ បុច្ឆស្សុ បុថូ សមណព្រាហ្មណេ
យទិ សច្ចា ទមា ចាគា ខន្តិ កិំយោ ឥធ វិជ្ជតិ ។

"បុគ្គលដែលមានសទ្ធាគ្រប់គ្រងផ្ទះ ត្រូវមានធម៌៤ប្រការនេះគឺ: សច្ចៈ (ការទៀងត្រង់) ១, ទមៈ (ការទូន្មាន) ១, ធិតិ (ការទប់ចិត្ត) ១, ចាគៈ (ការបរិច្ចាគ) ១, រមែងមិនសៅសោកក្នុងលោកខាងមុខដោយពិត, បើដូច្នោះ អ្នកចូរសួរសមណព្រាហ្មណ៍ឯទៀតឲ្យច្រើនគ្នាចុះ ក្រែងមានធម៌ណាក្នុងលោកនេះវិសេសជាង សច្ចៈ ទមៈ ចាគៈ ខន្តិ ទៅទៀត" ។

ធម៌មានសច្ចៈជាដើមនោះ ឈ្មោះថាឃាវសធម៌គឺច្បាប់សម្រាប់បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ ប្រតិបត្តិដើម្បីកុំឲ្យមានការប៉ះទង្គិចប្រែធាវៈច្បាប់សម្រាប់តផ្សាយទូវសង្គមនីមួយ។ ឲ្យមានសាមគ្គី សេចក្តីព្រមព្រៀងគ្នា ឲ្យមានសេចក្តីគោរពរាប់អានគ្នា មានទំនុកទុកចិត្តគ្នាជាបំផុត ។

ពណ៌នាធម្មកថាអំពីឃាវសធម៌ ៤ យ៉ាង កំសូមសន្និតបញ្ចប់ត្រឹមប៉ុណ្ណេះ, សូមជូនពរចំពោះអស់លោក-អ្នកទាំងឡាយ ឲ្យបានប្រកបដោយឥដ្ឋមន្តផលគ្រប់ៗគ្នា ។

ទុក្ខប្បត្តា ច និទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្ពេបិ ចាណិនោ

សព្វសត្វទាំងឡាយ ដែលដល់នូវសេចក្តីទុក្ខ សូមឲ្យជាអ្នកឥតទុក្ខទៅ! ដែលដល់នូវភ័យ សូមឲ្យជាអ្នកឥតភ័យទៅ! ដែលដល់នូវសោក សូមឲ្យជាអ្នកបាត់សោកទៅ! ។

រតនត្តយតេជេន ករោម្ហេ ជរដ្ឋភិសិនោ
ភុំ ភុំ ភុំ បហ្សាន្តុ សន្តិការាភ្យុ នាញ្ញថា

ដោយតេជៈនៃព្រះរតនត្រ័យ (ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ) សូមឲ្យប្រជាជនទាំងឡាយ អ្នកនៅក្នុងឥតម្ពុជរដ្ឋ ដល់នូវការលុតលាស់ចំរើន នឹងសន្តិភាព កុំបីឃ្លាតក្លាយទៅជាបកាវដទៃឡើយ! ។

ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាចាលីវង្ស វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ណានុរក្ស ប៊ូ ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យអ្នកពិនិត្យកែ

(តមក)

២) កិរិយារម្យទម — នៅត្រង់ការសូមស្បៃម, ការរៀបរយ, ការសុភាពរាបសា, ការស្គាល់ច្រមាណខ្លួន, ការនុបអរសាទរ, មេត្តាករុណានឹងការអើពើទទួលអញ្ជើញរាក់ទាក់ ។ ការតាំងនៅក្នុងត្រកូលខ្ពង់ខ្ពស់នៃស័លធមិដូចពោលមកនេះ ចាត់ថា "កិរិយារម្យទម" ព្រោះជារបស់ល្អ ទឹង គួរមើលនៃជនទូទៅ ។ ដ្បិតអាការរម្យទមនោះ ជាកិរិយាមិនរឹងត្អឹង, មិនច្រេងច្រាង, មិនអាក្រក់ថោកទាប ទឹង មិនឈ្លើយច្រឡើសបើស ។

មនុស្សនិស្ស័យរឹងត្អឹង តែងសំដែងកិរិយាថោកទាបច្រេងច្រាង មើលងាយមនុស្សដទៃ ដូចយ៉ាងឈរបង្កាប់ ឈរឲ្យឬហុចរបស់អ្វីឲ្យគេ ដោយអាការក្រអឺតក្រទម ព្រមទាំងនិយាយពាក្យមិនគួរស្តាប់ជាដើម ឬក៏ដើរចៀសពីគេទៅ ដោយអាការប៉ះទង្គិច កកិតកកោស; ដើរជិតឬឈរជិតអ្នកដែលអង្គុយ ដោយទំនងដូចជាកន្ធងស័ស: ឬដូចជាឈរច្រត់ស័ស:គេ, ចួនកាលក៏ឥតពិចារណា រៀកគេចេញទៅ ដោយឥត

សូមទោសឬប្រាប់គេជាមុន, កាលអង្គុយឬឈរទេតើនផ្លូវឃើញគេទៅមក ដែលខ្លួនគួរចៀស ក៏ធ្វើព្រងើយមិនចៀស, បើមានកៀវទៅមក ដែលខ្លួនគួរសំដែងកិរិយាហៅរកពាក់ពាក់ប្រស័យ ដោយអធ្យាស្រ័យដ៏ល្អ ក៏ត្រឡប់ជាឈរមើលដោយក្អែកអាត្រកក់ទៅវិញ, សូម្បីបានឮគេនិយាយអ្វី ក៏បដិសេធរបស់គេចោលត្រប់យ៉ាង ។

មនុស្សនិស្ស័យច្រេងច្រាំង តែងសំដែងកិរិយាឆ័ន្ទរសមើលងាយលើកខ្លួនសង្កត់អ្នកដទៃគាំងអស់ នឹងធ្វើអ្វីក៏មិនផុតអំពីការពាយដំឡៃខ្លួនឲ្យលើសមនុស្សដទៃឡើយ ។ សូម្បីនឹងធ្វើសេចក្តីល្អ ក៏មិនសូវមាននរណាគេស្រឡាញ់គាប់ចិត្តដែរ ហើយចូលចិត្តប្រកាន់ខ្លួនលើកដំកើងខ្លួនជានិច្ច ព្រោះសំគាល់ខុសថា "ការទុនលំទោនជាការមើលងាយខ្លួនឯង ជាការមិនពាប់អាន់ខ្លួនឯង" ។ តាមពិត ការប្រព្រឹត្តិទុនលំទោននោះ គឺការមិនប្រកាន់ខ្លួនឲ្យហួសប្រមាណ នឹង មិនបន្ទាបខ្លួនគួរសមហួសពេក ។ ការប្រព្រឹត្តិល្អបែបនេះ ជាឧបាយបិទផ្លូវមិនឲ្យអ្នកដទៃមើលងាយខ្លួនបាន មិនមែនជាការមិនពាប់អាន់ខ្លួនឯងឡើយ ។ តែព្រោះនិស្ស័យច្រេងច្រាំង នាំឲ្យចូលចិត្តខុស ទើបពាប់អាន់ខ្លួនឯងហួសហេតុ ទាល់តែធ្វើខ្លួនឲ្យមានកិរិយាច្រេងច្រាំង ក្លាយទៅជាសត្រូវចំពោះខ្លួនឯងវិញ ។

អ្នកឆ័ន្ទរស ឆ័ន្ទគ្នឹង ប្រជែងគ្រ
មិនគោរព និករ ជនខ្ពស់ខាប

ដើរប្រៃប្រែត គេឯង មិនមើលភាព
គង់បានជ្រាប ពាក្យដេរ ពីគេវិញ ។

អ្នកមានទិស្សយ័រឹងត្អឹងទឹងច្រេងច្រងាង មានកិរិយាអាក្រក់ថោកទាប រមែងធ្វើឲ្យមនុស្សដទៃស្អប់ខ្ពើមទឹកមុខ មិនចង់រាយស្និទ្ធជិតដិត តាំងជាការបានបណ្តេញខ្លួនឯងឲ្យចេញចាកសមាគមផង ។ ឯអ្នកដែលមានកិរិយាល្អវិញ កិរិយានោះនឹងជាគ្រឿងប្រដាប់ដឹកនាំ ឲ្យមានមនុស្សដទៃនិយមរាប់អានស្រឡាញ់ជាថ្នាសេពគប់ ។ តាមពិត កិរិយាអាក្រក់រមែងជាសត្រូវចំពោះខ្លួនឯង ។ សេចក្តីល្អពិតៗក៏ដោយ បើយើងធ្វើដោយអាការអាក្រក់ហើយ. សេចក្តីល្អនោះ គឺត្រូវនិងាសបាត់បង់ទៅវិញ ។ កិរិយាល្អឈ្មោះថាជាមិត្តរបស់ខ្លួនឯង អាចជួយជាកំឡាំងក្នុងការតស៊ូចំពោះទុបស័គ្គផ្សេងៗ, ធ្វើសេចក្តីចូលចិត្ត ព្រមព្រៀងគ្នា ឲ្យដំណើរទៅដោយរៀបរយ ប្រៀបដូចដៃដែលសម្រាប់ជួយរៀបចំការងារខាងមុខឲ្យរៀបរយដូច្នោះ ។

ការសំដែងកិរិយាមារយាទចំពោះគ្នានឹងគ្នា ជាការសំខាន់បំផុត គួរប្រយ័ត្នថែរក្សាឲ្យមែនទែន ដូចយ៉ាងមិត្តភក្តិក្នុងភូមិ គេមានកិច្ចរវល់យ៉ាងណាមួយ ហើយគេមកសូមជំនួយអំពីយើង ។ បើយើងឲ្យគេដោយអាការអាក្រក់ ដោយអាការខឹសឆាល់ឬដោយអាការមុខក្រញូវហើយ ក៏ជាហេតុនាំឲ្យគេធុញយើញដល់ទៅអញ្ជើស័យរបស់យើងថា

យើងមិនពេញចិត្តនឹងឲ្យគេ ។ នេះឈ្មោះថាធ្វើគុណដោយសេចក្តីទើសទាល់ ។ គុណដែលយើងនឹងគប្បីបានទទួលមកវិញនោះ សូម្បីច្រើនក៏ញុះញុះមកនៅតែមិនគ្រប់ ។ បើយើងឲ្យដោយអាការល្អវិញ ក៏អាចសំដែងឲ្យគេយើញច្បាស់ថា "យើងឲ្យដោយទឹកចិត្តដ៏ប្រកបដោយមេត្តាករុណា ប្រាថ្នានឹងសង្គ្រោះកង់កាលគេមានទុក្ខធុរៈនឹង មានទុបស័គ្គពិតៗ ឥតចង់បានប្រយោជន៍ណាមួយអំពីគេមែន" ។ នេះឯងឈ្មោះថាធ្វើគុណដោយមិត្តភាព ។ ការធ្វើទុបការៈបែបនេះ សូម្បីតែបន្តិចបន្តួច ក៏អាចនឹងបន្ធូរចិត្តអ្នកទទួល ឲ្យកើតសេចក្តីស្រឡាញ់កក្តី នឹង មានកតញ្ញូចំពោះយើងបាន ។

កិរិយាល្អ ជាគ្រឿងចង់ចិត្តមិត្តកក្តិ នឹង ការប្រមូលអ្នកដទៃកង់លោកឲ្យចូលមកសេពគប់នឹងយើង ធ្វើឲ្យយើងមានមិត្តភក្តិពួកម៉ាកច្រើនគ្នា ។ ចំណែកកិរិយាអាក្រក់វិញជាគ្រឿងបណ្តុះសត្រូវ បណ្តេញខ្លួនឯងឲ្យចេញទៅឆ្ងាយអំពីមនុស្សដទៃៗ កង់លោក ធ្វើខ្លួនឲ្យបានទទួលសេចក្តីទុក្ខក្តៅក្រហាយតែម្នាក់ឯង ។ ដូច្នេះ យើងគួរអប់រំកិរិយាល្អទុក ដោយកុំមានទិដ្ឋិមានប្រកាន់ខ្លួន មើលងាយគេ កុំប្រើកិរិយាវង៍រូសនឹងកិរិយាច្រណែនច្រងាង គួរស្គាល់ប្រមាណខ្លួន ដូចគោជាក់ស្នែងឬអាសិរពិសដែលគេដកចង្កឹមចេញ ។ បើយើងមានកិរិយាជាមនុស្សល្អហើយ ក៏នឹងទៅជាទីជួយលើកទឹកចិត្តនៃគ្នានឹងគ្នា ជាទីស្រឡាញ់ចូលចិត្តនៃគ្នានឹង

គ្នា នឹងជាទីបង់ចិត្តនៃគ្នានឹងគ្នា ឲ្យមានការជិតជិតស្និទ្ធស្នាលនឹងស្គាល់គ្នាឯងបាន ដូចជាញាតិដែលជិតជិតដូច្នោះ ។ បើយើងមានកិរិយាល្អ, សូប់ស្ងៀមរៀបរយពេញទីហើយ ឥតមានអ្វីអាចធ្វើឲ្យយើងប្រែប្រួលអំពីសេចក្តីសូប់ស្ងៀមរៀបរយបានឡើយ ។

មានកេរ្តិ៍ឈ្មោះ	ខ្ពស់ខ្ពង់	វង្សស្អុកស្តុម
កុំច្រឡំ	កន្តុដ្រួស	ហួសយសសក្តិ
គួរឲ្យស្គាល់	ប្រមាណ	ឋានជាន់ថ្នាក់
ទើបកេរ្តិ៍ឈ្មោះ	ជៀងជាក់	ល្បីសុសសាយ ។
បើលំទោន	ខុនតួ	គួរសមផង
កេរ្តិ៍ឈ្មោះរឹត	តឹកតង់	ល្បីទៅឆ្ងាយ
គ្រាមនិគម	ជនបទ	ផងតំាងឡាយ
សឹងប្រញាយ	ចុះបួល	មូលមេត្រី ។
បើសក្តិខ្ពស់	ដ្រួសឫក	ក្ងឹកក្ងេចអង្គ
ខ្វើសខ្វែងដំ	យង់ឃ្នង	ជងអប្រិយ
កិត្តិយស	ខ្ពស់ខ្ពង់	តង់ដេកដី
អ្នកក្រក្រី	មិនខ្ចី	តំាងខ្លាចផង ។

គ) កិរិយាខឹងលំទោង — នៅត្រង់ការសំដែងអាការចេញមកជាកិរិយាសម្ងាត់ការរវៈនុនលំទោង គោរពប្រណិប័តន៍ចំពោះអ្នកស្តុកស្តម្ភ

អ្នកជំនឿអ្នកស្មើគ្នា ព្រមទាំងអ្នកតូច ឬអ្នកមានហាន:ខាបជាង, មិនលំបាកប្រដៅ មិនអួតអាងមិនរើសរួស មិនមើលងាយគេ មិនប្រកាន់ដោយទិដ្ឋិមានៈ ។

មនុស្សប្រដៅក្រ មើលងាយគេ ចូលចិត្តសំដែងកិរិយាលើកដំកើងខ្លួនឯងហើយបន្ទាបគេ ជាមនុស្សរើងភ្នើង អាក្រក់ដូចជាតិ មុខរ៉ង ទាំងកែកយកក្នុងចិត្តតែខាងការមើលងាយគេ ទឹងការឃើញឃង់ មិនបង្អោនខ្លួនគោរពដឿស្តាប់នរណា សំគាល់ខ្លួនថាជាមនុស្សល្អ មនុស្សឆ្លាសជាងគេទាំងអស់, បើឃើញនរណាមួយហើយ ច្រើនតែតាំងលំនាំរាយប្រកក្រអឺតក្រទម, ដើម្បីឲ្យគេគោរពខ្លួនមុនជានិច្ច សូម្បីធ្លាប់ស្គាល់ទឹងធ្លាប់គោរពគ្នាកុងកីកន្លែងដទៃខ្លះមកហើយក៏ដោយ តែកាលបានជួបគ្នា កុងកីដទៃទៀត ក៏ប្រដាល់រាយប្រកប្រកាន់ខ្លួន ធ្វើជាពើមិនស្គាល់ លែងគោរពគ្នាទៅវិញទៅមកទៀត ឬបើទុកជាធ្វើសេចក្តីគោរពក៏គ្រាន់តែធ្វើទៅដោយសារអំណាចឬបុណ្យវាសនាប្តូរបៀប ពុំនោះគ្រោះច្បាប់បង្ខាប់ឲ្យធ្វើប៉ុណ្ណោះ មិនបានធ្វើដោយសុទ្ធចិត្តឡើយ ។

មនុស្សមើលងាយគេ មានលក្ខណៈដំឡើងប្រកាន់ រាយប្រកជានិច្ច មានចិត្តក្តើតក្តើនហេហា សំគាល់ថាមិនមាននរណាប្រសើរជាងខ្លួន ទាំងចូលចិត្តមើលងាយ លុបគុណអ្នកដទៃ សំគាល់ឃើញថាគេថោកខាបជាងខ្លួនទាំងអស់ មិនចេះថែរក្សាកិរិយាអធ្យាស្រ័យ ចំពោះអ្នកដទៃ

តាមដែលគួរឡើយ ចាំងមិនស្គាល់ប្រមាណខ្លួន លើកកំពស់ខ្លួនហួសប្រមាណ រាយឫកត្រអឺតតាមតែគំនិតដែលខ្លួនយល់ឃើញថាល្អថាគួរ ។ តែអ្នកជាទៃ គេឃើញថា ជាឫកអាក្រក់គួរខ្ពើម គួរជិន គួរស្អប់ទៅវិញ ប្រៀបដូចសត្វអម្ពិលអម្ពែក ចង់រាយឫកឲ្យស្មើនឹងព្រះចន្ទ ។ កិរិយាច្រឡើសបើសចាំងនេះ ជាក្រសែនៃសេចក្តីវិនាស ដូចពុទ្ធភាសិតក្នុងបាកវគ្គសូត្រថា :

ជនឯណា កឋកតិត កំណើតខ្ពស់
មានទ្រព្យច្រើន កើតយស ត្រកូលស្តុក
តែមើលងាយ ញាតិខ្លួន ដែលមានទុក្ខ
នេះជាហេតុ បាកមុខ នៃជននោះ ។

កិរិយាខ្នះខ្នែងលំទោន ជាក្រសែនៃសេចក្តីចំរើន ជាគ្រឿងសំគាល់របស់មនុស្សល្អ, កាលបើមាននៅក្នុងសន្តានរបស់អ្នកណាហើយ ក៏អាចបង្ហាញឲ្យគេឃើញបានថា អ្នកនោះជាមនុស្សល្អ, បើមិនមាននៅក្នុងខ្លួនអ្នកណាហើយ ក៏ធ្វើអ្នកនោះឲ្យអាប់ឱសី ប្រៀបដូចផ្ទះអ្នកណាដែលមិនមានកន្ទែងសម្រាប់ធ្វើសក្ការបូជា ក៏អាចបង្ហាញឲ្យគេដឹងថា អ្នកនោះមិនមែនជាពុទ្ធសាសនិកជន ។ ចំណែកការប្រមាថមើលងាយគេ ជាគន្ធងផ្លូវនៃហាយន: ។ បើយើងមិនចង់បានសេចក្តីវិនាសទេ ក៏ចូរសំដែងតែកិរិយាខ្នះខ្នែងលំទោនចំពោះមនុស្សទូទៅចុះ កុំសំដែងកិរិយាដំកើងខ្លួន រើសរូស ច្រេងច្រាង ប្រមាថមើលងាយគេឡើយ ។

កិរិយាល្អ កិរិយារម្យទមនឹងកិរិយានុនលំទោននេះឯង ចាត់ជា កិរិយាសុភាព ។ ការសំដែងអាការចំពោះមនុស្សដទៃ ដោយកិរិយា សុភាពនេះ បើយើងប្រតិបត្តិតាមដោយត្រឹមត្រូវជានិច្ច ទាំងក្នុងទី ចំពោះមុខទាំងក្នុងទីកំបាំងមុខ ទាំងចេះជឿចេះស្តាប់គ្នាទៅវិញទៅមកបាន ហើយ ក៏អាចបរិហារការពារពួកគណៈរបស់ខ្លួនឲ្យផុតភ័យវិបត្តិ នឹងឲ្យ វឌ្ឍនាការជាស្ថាពរតទៅទៀតបាន ចាត់ថាជាប្រយោជន៍ចំពោះពួក មនុស្សច្រើន នឹងជាទីស្រឡាញ់នៃគ្នានឹងគ្នាទៀត មិននិយមថ្នាក់និយម ជាន់ឡើយ ។ អ្នកតូច រមែងជាទីស្រឡាញ់នៃមនុស្សអ្នកធំ ហើយ នឹងបានទទួលការទុបត្ថម្ភគាំពារអំពីអ្នកធំ ។ មនុស្សស្មើគ្នានឹងបានជា ទីអាស្រ័យពឹងពាក់នូវគ្នានឹងគ្នា ។ អ្នកធំ ក៏នឹងបានអ្នកតូចជួយជាកំឡាំង សូម្បីកាលមានកិច្ចកើតឡើង អ្នកតូចក៏នឹងតាំងចិត្តធ្វើឲ្យសម្រេច ដោយ សេចក្តីពេញចិត្ត, នេះសំដែងឲ្យឃើញថា "ការសុភាព មិនរមែងជា ប្រយោជន៍ចំពោះតែខ្លួន ១ ចំណែកឡើយ គឺរមែងជាប្រយោជន៍យ៉ាងធំ ចំពោះពួកគណៈរហូតដល់ប្រទេសជាតិទៀតផង" ។

ដូច្នេះ លោក-អ្នកទាំងឡាយ គួរសំដែងកិរិយាសុភាពចំពោះ មនុស្សទាំងពួងដោយស្មើមុខគ្នា មិនត្រូវរើសមុខថាគេមានឋានៈខ្ពស់ជាង, ស្មើគ្នា, តាបជាង ឬថោកតាបជាងយ៉ាងណាឡើយ ។ បើធ្វើបាន ដូច្នេះហើយ នឹងបានឈ្មោះថាជាអ្នកបំពេញសប់ខាងការថែរក្សាខ្លួនឲ្យ

សមគួរដល់បរិស័ទ អាចផ្សារបុគ្គលនឹងបុគ្គល, ពួកមនុស្សនឹងពួកមនុស្ស, រហូតដល់ប្រទេសជាតិ ឲ្យជាប់តគ្នាបាន ។ តែកុំប្រើកិរិយាថោកទាប, កិរិយាអាក្រក់ នឹងកិរិយាច្រេងច្រាំង, លើកដំកើងប្រជាក្រ, រឹងត្អឹង ឬវាយឫកក្រអឺតក្រអោង ចំពោះនរណា ។ ឡើយ ។ ព្រោះកិរិយាបែបនេះ មិនមាននរណាចូលចិត្តទេ ។ មនុស្សដោយច្រើន តែងពោលរិះគន់មនុស្ស ដែលមានកិរិយាបែបនេះ ។

ទុនលំទោន ទើបមាន គេចូលចិត្ត
អ្នកសក្តិយស ហួសក្រឹត នាំសៅហ្មង
ព្រោះការទុន ជាពង្ស នៃមាសផង
តែឫកខ្ពស់ កន្ធង នាំលិចលង់ ។

(មានត)

អ័ឌ្សេណា - សិម្ប៉ាណា

"រឿងត្រែងប្រទេសរូម៉ានី"

លោក ផេង - ជ្រឿ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

(តមក)

នាង៉អ័ឌ្សេណា សិម្ប៉ាណា លុះបានស្តាប់សំដីនៃនាងបរិចារិការួចហើយ ក៏ដើរសំដៅទៅកន្លែងដែលឈប់ចាំនៅត្រង់កំពែងដើម្បីមើលស្បែកដើង ។ ប៉ុន្តែលុះនិយាយថាៈ ទំនិញនៅឯសំពៅមានល្អជាងនេះទៅទៀត ។ នាងឮដូច្នោះក៏តាមទៅមើលឯសំពៅ ។ អាល័យតែរើសទំនិញ នាងមិនដឹងជាសំពៅចេញពីច្រាំង, ហើយដោយសារព្រះជាម្ចាស់បញ្ជូនខ្យល់មកផង សំពៅបើកចេញមានសន្ទុះយ៉ាងលឿនដូចជាហើរ ។ នាង៉អ័ឌ្សេណា - សិម្ប៉ាណា ដឹងថាដល់កណ្តាលសមុទ្រហើយក៏ធ្វើជាមិនដឹង ហើយចាប់ផ្តើមសួរអំពីការបញ្ឆោតនេះ ។ តែក្នុងចិត្តនាងមានសេចក្តីត្រេកអរជាអនេក ដោយការបានរួចផុតពីដៃយក្សចង្រៃនេះ ។

សំពៅបានដល់ត្រើយយ៉ាងស្រួល ។ ប៉ុន្តែម្ចាស់យក្សដឹងដំណឹងតាមស្រីអ្នកបំរើថាបាត់ថា "នាង៉អ័ឌ្សេណា - សិម្ប៉ាណា មានល្បិចមកលួចពន្លត់តាមសមុទ្រយកទៅបាត់ហើយ" ក៏ដេញតាមឥតបង្អង់ឡើយ ។

គ្រាន់តែឡើងពីសំពៅសឹងតែមិនទាន់ ព្រះរាជធីតាទ្រង់ជ្រាបក្នុងថា ដូចជាមានអ្វីដេញតាមខាងក្រោយ រូបកងដូចជាសឹង្ហ ហាមាត់យ៉ាងធំ ពីដីដល់មេឃព្រួសសុទ្ធតែអណ្តាតភ្លើង ។

នាងអ័ឡេណា - សិម្ប៉ាណា ដឹងមួយរំពេចថាជ្រូកដជាមេយក្ខិនដេញតាមមែន ។ នាងនិយាយរឿងសព្វគ្រប់ប្រាប់ឈ្មួញដែលជាក់ឲ្យអង្គុយលើខ្នងសេះពីក្រោយខ្នង រួចនាងយំខ្សឹកខ្សួលទឹកភ្នែកហូរហាម ។

ព្រះរាជធីតាសួរសុរ្យាបកាអំពីកិច្ចដែលត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីដោះខ្លួនឲ្យរួចពីអណ្តាតភ្លើងដែលព្រួសមកលើ ។ សេះក្រាបបង្គំទូលថា: សូមទ្រង់ខ្ទេះយកតង្វាយពេជ្រមួយដុំដែលនៅកងត្រចៀកឆ្វែង របស់ទូលព្រះបង្គំ ហើយទ្រង់ចោលទៅក្រោយទៅ ។ ព្រះនាងក៏ធ្វើតាមបង្គាប់សេះ ហើយនាំគ្នាធ្វើដំណើរតទៅ ។ ចំណែកខាងក្រោយនាងស្រាប់តែដុះកំថូតាំងពីដីដល់មេឃ សម្បាប់រាងផ្ទួរយក្ស ។

មេយក្ខិនីទំប្រវាវឡើងកំពីដុំថ្មមួយទៅដុំថ្មមួយ មិនយូរប៉ុន្មានក៏បានឆ្ងងផុតកំហើយចាប់ដេញតាមនាងកិតៗទៅទៀត ។ នាងអ័ឡេណា - សិម្ប៉ាណា ឃើញដូច្នោះក៏ឲ្យដំណឹងដល់ឈ្មួញ។ ធ្វើតាមបណ្តាំសេះ លូកយកច្រាសមួយពីរន្ធត្រចៀកសេះ ហើយបោះចោលទៅក្រោយទៀត ។ ស្រាប់តែមានព្រៃលេចឡើងយ៉ាងជិតស្និទ្ធ ព្រៃនុះសូម្បីតែសត្វអ្វីមួយក៏រកចូលមិនរួច ។

មេយក្ខិនីកំទេចដើមឈើចាំងឡាយ តោងពីមែកមួយទៅមែកមួយ លោតផ្លោះពីចុងមួយទៅចុងមួយ រួចបានធ្វើងផុតទៀត ហើយតាំងហោះដេញតាមងងឹតមេឃ ដូចជាខ្យល់ព្យុះ ។ ព្រះពជធីតាបានទតព្រះនេត្រឃើញដូច្នោះ សួរសេះម្ចាងទៀតថា: តើត្រូវធ្វើដូចម្តេច? ។ សេះថ្លែងប្រាប់ថា: ត្រូវដោះចិញ្ចៀនពីដៃនាងអ័ឡេណាសម្ប៉ាណា ចោលទៅក្រោយម្ខាងទៀត ។ ចិញ្ចៀនធ្លាក់សឹងមិនដល់ដី ស្រាប់តែដុះកំពែងថ្មបាយក្រៀមឡើង ចាប់តាំងពីប្រថពីទៅទល់មេឃ សម្រាប់ពាំងផ្លូវមិនឲ្យយក្សទៅតាមបាន ។

មេយក្ខិនីដឹងច្បាស់ថា: អាគ្នាមុខជាធ្វើងកំពែងនេះមិនផុតបំពាក់មិនបែកហើយគិតតែស៊ូដេកនៀលស្ងាប់នៅទីនោះ ។ ចាំងក្រោធចាំងខ្ញុក្ខព្រួយ ក៏ចំអើតកដល់ត្រឹមប្រហោងចិញ្ចៀនដែលក្លាយជាកំពែងហើយចំប្រឹងព្រួសអណ្តាតភ្លើងតាមចន្លោះនោះ ដើម្បីដុតកំទេចពួករមត់ចាំងប៉ុន្មាន ប៉ុន្តែពួកនេះថយមកនៅអង្គុយក្បែរកំពែង មិនធ្វើជាដឹងអំពីភ្លើងរបស់យក្សឡើយ ។

មេយក្ខិនីចំផ្ទុំចំព្រួសអណ្តាតភ្លើង ដោយកំហឹងកាន់តែខ្លាំងឡើងៗ ចាល់តែបែកទ្រូងស្ងាប់នៅនឹងកន្លែង ។ ព្រះពជធីតាទ្រង់ជ្រាបច្បាស់ថា យក្ខិនីក្ស័យជន្មពិតប្រាកដហើយ, ទ្រង់យកព្រាមព្រះហស្តទៅស៊ីតត្រង់រន្ធចិញ្ចៀនតាមសំដីសេះ, កំពែងក៏វិនាសអន្តរាយបាត់, ចិញ្ចៀន

ជាប់មកនៅក្នុងអង្គុលីវិញ ។ ទុកខ្មោចយកកិនីចោល ឲ្យសត្វក្អែកគ្នាត
ស៊ី ព្រះនាងធ្វើដំណើរមកទៀត រហូតបានដល់ទន្លេព្រះចៅពារាណសី ។

ជនទាំងអស់គ្នាឡើងទៅក្រាបបង្គំគាល់ព្រះចៅ។ ទ្រង់ទទួលជា
ឧឡារិក ហើយទ្រង់មានព្រះរាជឫទ័យសប្បាយជាអស្ចារ្យ ព្រមទាំង
ប្រគបដោយសេចក្តីស្នេហាចំពោះនាងអ័ឡេណា - សិម្ប៉ាណា មួយរំពេច
និមិត្តតែទ្រង់ទតឃើញក្លាម ។ ប៉ុន្តែសាម៉ីខ្លួននាងអ័ឡេណា-សិម្ប៉ាណា
មិនសប្បាយចិត្តសោះ មានតែសេចក្តីទុក្ខព្រួយ ព្រោះនាងនឹកតូចចិត្ត
នឹងព្រៃឥសានាអាស្រមរបស់នាង ប្តីណាក៏ដូចប្តីណា មិនដែលមាន
រូបឆោមល្អពេញចិត្តឡើយ ។ ចិត្តរបស់នាងឆ្ពោះទៅរកតែព្រះអង្គម្ចាស់
ហារហាន ដែលបានដោះនាងឲ្យបានរួចផុតពីកណ្តាប់ដៃយក្ស ហើយ
នាងចេះតែសំឡឹងទៅរកព្រះអង្គម្ចាស់ខ្ទុះសឹងមិនដាក់កែក ។

លុះព្រះចៅពារាណសីកំហែងបង្ខំនាងឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយ
នឹងព្រះអង្គ នាងធ្វើយថា "បពិត្រព្រះមហាក្សត្រិយ៍ដ៏មានវិជ្ជាលើកពា
ផែនដី! សូមទ្រង់សោយរាជ្យជាសុខក្នុងព្រះរាជវង្ស ។ ចំណែកខ្ញុ
ព្រះបង្គំមិនអាចរៀបអាពាហ៍ពិពាហ៍នឹងព្រះអង្គទេ វេលាណាដែលគេ
មិនទាន់ប្រមូលមេសេះ នឹងសេះឈ្មោលរបស់ខ្ញុំព្រះបង្គំយកមកឲ្យនៅ
ជួបជុំគ្នា" ។

ព្រះចៅត្រាស់ឲ្យហៅព្រះអង្គម្ចាស់ហារហានទៀត ហើយទ្រង់មាន
ព្រះរាជឱង្ការបង្គាប់ថា: "ចូរឯងទៅរកប្រមូលសេះទាំងឡាយរបស់បិយ-

នាវរបស់យើងមក គឺថាត្រូវរកឲ្យបានគ្រប់គ្រាន់ទាំងញីទាំងឈ្មោលមកជាកុំខាន" ។

ព្រះពជធីតាក្រាបបង្គំទូលតបវិញថា: "បពិត្រព្រះចៅដ៏ទ្រង់ទ្រព្រះគុណភាពខ្ពង់ខ្ពស់! ទូលព្រះបង្គំ ខើបតែបំពេញកិច្ចមួយដែលជាការរបស់ទ្រង់ផ្ញើឲ្យមក ប្រកបដោយសេចក្តីលំបាកយ៉ាងធំបំផុត ដោយយកជីវិតប្តូរ ។ ចុះទៅក្នុងព្រះបរមរាជវាំងនេះ ខ្ញុំអ្នកព្រះរាជបុត្រហាវហានរបស់ព្រះពជាជវៃទាំងឡាយ ។ អ្នកផងទាំងពួងតែងនិយាយថា ព្រះករុណាថ្លៃវិសេសប្រកបដោយទសពិធរាជធម៌ គោរពព្រះជាម្ចាស់ បើដូច្នេះ សូមទ្រង់ព្រះមេត្តាផ្ទេរការៈថ្មីនេះទៅលើព្រះរាជបុត្រណាមួយផង តើបានឬទេ? តើទូលព្រះបង្គំនឹងអាចទៅរកមេសេះទាំងនោះដូចម្តេចបាន? ហើយតើមេសេះនោះនៅទីស្ថានណាប្រមូលមកយ៉ាងដូចម្តេចទៅ?" ។

ព្រះចៅទ្រង់ធ្វើយឡើងថា: "យើងមិនដឹងទេ! ឯងចេះតែយកព័ត៌មានដីក៏ដោយ ព័ត៌មានស្មៅក៏ដោយ ស្រែចលើរូបឯងចេះធ្វើ ; យើងដឹងតែត្រូវឲ្យបានមេសេះទាំងនោះមក ទៅភ្លាមទៅកុំតក់ក៏ខ្វៃត" ។

ព្រះពជធីតាទទួលព្រមហើយក្រាបថ្វាយបង្គំលាចុះមក ។ ព្រះនាងយកដំណឹងដែលខើបទទួលមកនេះ ទៅថ្វាយក្រាបសុរាបការ។ ក្រាបជា: "សូមព្រះនាងជាម្ចាស់ទៅរកស្បែកក្រមីប្រាំបួនលាបដ៏រយ៉ាងស្អាត

ហើយយកមកគ្របលើខ្លួនទូលព្រះបង្គំ ។ សូមព្រះនាងកុំកិតក្រែងឲ្យ
សោះ ដោយអាស្រ័យការជំនួយនៃព្រះជាម្ចាស់ ព្រះនាងគង់នឹងអាច
ញ៉ាំងការៈនេះឲ្យសម្រេចបានជាមិនខាន ។ ប៉ុន្តែសូមព្រះនាងទ្រង់
ជ្រាបចុះថា: ព្រះចៅវាជាធំជាងតែត្រូវបង់ខាតជាយ៉ាងខ្លាំង ដោយ
សារតែកិរិយាមារយាទមិនសុចរិតនៃព្រះអង្គដែរ" ។

ព្រះនាងសៅធ្មេចតាមតែពាក្យអស្សពាហន៍បង្គាប់ ហើយក៏នាំគ្នាចេញ
ទៅ ។ ខាងក្រោយការធ្វើដំណើរយ៉ាងឆ្ងាយនឹងយ៉ាងវេទនា ជនទាំងពីរ
បានដល់ឆ្នេរសមុទ្រដែលហ្វូងសេះញីកំពុងស៊ីស្មៅនៅនោះ ។ ព្រះ
នាងសៅទ្រង់បានដួចនឹងយក្ស ដែលជាអ្នកលួចឆក់ទូវនាងអ័ឡែណា-
សិម្ប៉ាណាលើកមុន កំពុងតែដើរចុះដើរឡើង ដូចមនុស្សឆ្កួត ដើម្បី
ស្វែងរកហ្វូងមេសេះ។ លុះបានដំណឹងថា នាងអ័ឡែណា-សិម្ប៉ាណា គេ
លួចដណ្តើមយកពីវាទៅទៀតហើយ។ ម្ចាយវាបានដល់ទូវសេចក្តីមរណៈ
ដោយការឈឺចិត្ត ព្រោះតាមអ្នកលួចមិនទាន់ យក្សនុ៎ះឯងគិតតែពីព្រួស
អណ្តាតភ្លើង ពាសវាលពាសកាល ដោយចិត្តកំហឹងតាមតែស្វាប់
អាណាក៏ដោយ ។ ហើយកាលណាដឹងថា អ្នកលួចនាងអ័ឡែណា-
សិម្ប៉ាណា មកនៅចំពោះមុខវា សេចក្តីក្រោធនឹងសេចក្តីខ្ពើមធ្វើវាឲ្យ
វង្វេងស្មារតី ។ ស្រែកដូចសត្វសឹង្ហ យក្សនុ៎ះសុះលោតសំដៅព្រះពជ-
ធ័តា ដែលជាក្សត្រីបែកចាជាយសតិវង្វិលនឹងសេចក្តីក្លាហានដ៏ខ្ពស់ ។

ប្រយុទ្ធគ្នាលើកនេះរកអ្វីប្រៀបគ្មាន ។ ព្រះពជមនោម័យទំជួយការពារព្រះនាងនឹងអាវុធយក្ស គឺថាកាលណាសេះឃើញយក្សបំរុងនឹងកាប់នាងហើយ វាស្ទុះហោះទៅលើឲ្យផុតហួសសេះយក្ស ហើយអាវុធយក្សកាប់ត្រូវតែខ្យល់ ។ ប៉ុន្តែបើកាលណា ព្រះនាងរៀបលើកព្រះខ័នបំរុងហើយសុរ្យាបកាដាយសំរុកទង្គិចសេះយក្សមួយរំពេច ម្ល៉ោះហើយអាវុធរបស់ព្រះនាងរៀបកាប់ត្រូវបច្ចាមិត្តមិនដែលខាន ។ ជនទាំងពីរច្បាំងគ្នាស្ទើរស្រុតប្រថពី ដើមឈើតូចធំនឹងគិរីបពិតទាំងឡាយ សឹងញាប់ញ័រផ្ដើលអស់សត្វនានា អាវ៌ក្ស ខេត្តា យក្ស គន្ធព្វ រត់ខ្ចាត់ខ្ចាយរកតែទីជ្រកវៀងខ្លួន ។ មហាសាគរកើតជារលកបោកបែកផ្ដាំត្រែងនាវាទាំងឡាយសឹងលិចលង់ មនុស្សទាំងឡាយជល់នូវសេចក្ដីស្ញាប់ជាអនេក មច្ឆានឹងជលសត្វទាំងឡាយហែលមុជរកទីពឹងក្នងសាយនឹងក្នងរូងថ្មស្ទើរពុំទាន់ ។ លុះទីបំផុតព្រះពជធីតា ទ្រង់ផ្ទៀងព្រះកាយត្រលែងស្ទេចអស្ចារមួយព្រះខ័នជ័យត្រូវជាប់ក ។ រួចទុកខ្មោចយក្សចោលឲ្យជាអាហារដល់ក្អែកនឹងត្មាត ហើយសេះនឹងព្រះនាងក៏បន្តដំណើរទៅទៀត ទើបស្ដេចបានដល់កន្លែងហ្វូងមេសេះទាំងឡាយ ។

ដល់ទីនោះ សេះប្ញាប់ព្រះនាងឲ្យឡើងដើមឈើ ហើយលបចាំមើលពីចុងឈើ ។ ព្រះនាងក៏ធ្វើតាម ។ ខណៈនោះសុរ្យាបកាស្រែកកញ្ជ្រៀវបីដង, សេះញីទាំងប៉ុន្មានប្រមូលគ្នាមកជុំ ។ មិនយូរប៉ុន្មាន

លេចសេះឈ្មោលមួយមក បែកពពុះមាត់សំពោង ស្រែកកញ្ជ្រៀវ
ទាំងកំហឹង ផាយជាក់មកពីនាយ ។ ឯានឃើញមេសេះទាំងឡាយ
របស់ខ្លួននៅព័ទ្ធជុំវិញសុរ្យាបភាដូច្នោះ សេះនុ៎ះផាយសំរុកជាក់គ្នានគិតគូរ
ហើយការតយុទ្ធរវាងសេះឈ្មោលទាំងពីរ តាំងឡើងយ៉ាងស្ងប់ស្ងៀង ។
កាលណាសេះនោះទាំសុរ្យាបភាគឺទាំត្រូវតែស្បែកក្រៃបី បើកាលណា
សុរ្យាបភាទាំសេះនោះវិញ គឺទាំត្រូវចំសាច់មែន។ ។ ការប្រទាំគ្នា
រវាងសេះទាំងពីរតាំងនៅអស់ពេលដ៏យូរ ។ លុះទីបំផុតសេះត្រៃជាច់
រុះរយាយឈាមជាបខ្លួន ហើយបរាជ័យ ។ ចំណែកសុរ្យាបភាឥត
មានរងិតអ្វីបន្តិចឡើយ ដោយសារបុណ្យស្បែកក្រៃបី ។ វេលានោះ
ព្រះពជធីតាទ្រង់ស្តេចចុះពីដើមឈើ ជិះលើសុរ្យាបភាបរកៀងហ្វូងសេះ
ញីទាំងនោះទៅ ឯសេះឈ្មោលនោះបាលតាមក្រោយគេអង្គុយ។
ស្ទើរតែមិនរួច ។

ព្រះនាងពៅកៀងសេះទាំងប៉ុន្មានចូលក្នុងព្រះបរមរាជវាំង ហើយ
ឡើងទៅគ្រាបបង្គំទូលថ្វាយដំណឹងដល់ព្រះបាទាជាធិរាជ ។ នាង
អ៊ីឡេណា - សិម្ប៉ាណា ចេញពីប្រាសាទមកហើយហៅសេះរបស់នាង
តាមឈ្មោះរៀងខ្លួន ។ គ្រាន់តែឮសំឡេងនាងអ៊ីឡេណា - សិម្ប៉ាណា
សេះឈ្មោលនោះគ្រវែងខ្លួនភ្លាម ហើយស្ទុះមកបួសទាំងឡាយកំរោលស
ចាត់អស់ ត្រឡប់ជាមានកម្លាំងដូចដើមវិញ ។

(មានត)

កុណ្ឌធី ៩

ទកញ្ជ័រវិលរាជសេនា ន្ធូ-កន ប្រែរៀបរៀង

(ភទ៣)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ធំងបេះទុបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ចូត្ងូបែរមុខចេញហើយលើកដៃចង្អុលថ្កាប់ថា ចូត្ងូដុះលឿនតែ់ទៅ
ខាងណោះ ។ លីចោ"មិនបានសង្កេតគ្មានសង្ស័យគិតថាពិត កំបរសេះ
តឡប់ទៅខាងក្រោយ ។ ចូត្ងូត្រែកអរណាស់ បរសេះរះចេញទៅទិស
ខាងកើត ខ្មើបដួបប្រទះនឹងតៀនអ៊ុយ។ត្រែកអរ. ក៏នាំចូត្ងូឆ្ពោះមានចេញ
ទៅដល់មាត់ភ្នារ ឃើញគំនរទុសដែលក្តើងនេះនោះនៅទទឹងផ្លូវ ក្តើងក៏នៅ
ពាលនេះប៉ាមកំពែងស្មែងហោណាំងខ្ពាំងឡើង ។ តៀនអ៊ុយក៏យកដួនចាក់
ក្តើងដែលនេះគំនរទុសនោះចេញអស់ពីផ្លូវ ហើយនាំចូត្ងូស្ទុះទៅដល់មាត់
ភ្នារ។ កាលចូត្ងូទៅដល់មាត់ភ្នារនោះ ទតួលក្តើងនេះរបេះធ្មឹមក្តោងភ្នារជាប់

មកត្រូវដើងសេះដែលចូធ្លូដុះដួលទៅលើគំនរក្លើងស្ងាប់ ។ ចូធ្លូក៏សុះលោតប្រញាប់ផុតពីគំនរក្លើង តែអាវនឹងសក់ពុកមាត់ចូធ្លូត្រូវអណ្តាតក្លើងធាបឆេះពេញអស់ទាំងខ្លួនច្បាណា ចូធ្លូទាញកន្ត្រាក់ហែកអាវនោះចោះចោលទៅ ហើយយកដៃទាំងឆ្វេងស្តាំបន្ទុំចោសលត់ក្លើង ដែលឆេះសក់នឹងពុកមាត់នោះទាល់តែរលត់ ទើបរត់ចេញទៅផុតមាត់ទ្វារ ។

តៀនអ៊ុយមើលមកក្រោយឃើញដូច្នោះ ក៏សុះលោតព័ទ្ធលើសេះចុះមក ខ្នួលហែហួអៀនទៅទាន់ ក៏ជួយគ្រាប់នាំចូធ្លូឲ្យឡើងជិះសេះរបស់ហែហួអៀនទៅ ។

ឯណ :នោះ ទាហានលីចុ"សុះតាមទៅជាច្រើនណាស់ តៀនអ៊ុយនឹងហែហួអៀន រាមកការពារតទល់ទាល់តែទៅដល់មុខបន្ទាយ លុះព្រឹកឡើងក្រឡេកឃើញទាហានតូចធំដែលចាក់បែករត់ដែកមកបាន ក៏បបួលគ្នាទៅស្មរចូធ្លូ។ អស់សំណើចសើចក្អាកក្អាយហើយថា គ្រានេះយើងខូចសេចក្តីចេះអស់ ចាន់ថ្មោះខូចខាតសេនាទាហានជាច្រើន បើខ្លួនយើងនៅមិនទាន់ស្លាប់ទេ យើងត្រូវតែគិតសងសឹកលីចុ"វិញឲ្យបាន ។

គុយតែឆ្លើយថា បើលោកនឹងគិតសងសឹកលីចុ"ត្រូវខំគិតឲ្យឆាប់ ។ ចូធ្លូឆ្លើយតបថា ដែលលោកជាស់តឿនខ្លួនយើងដូច្នេះ ត្រូវណាស់, ឯកុំមា"ឡែងនោះមានចំពោះតែផ្លូវដើរ យើងនឹងលើកទាហានទៅបង្កាច់តាមច្រកកុំ ហើយនឹងឲ្យទាហានទាំងពួងដែលនៅកងបន្ទាយនោះ

ស្ងៀកសពាក់សធ្វើជាយំសោកលើកអាល័យយើងថា ក្មេងនេះពេលជាទម្ងន់ខ្ទុនខ្ទុពណាស់ នាំមកដល់បន្ទាយវេលាណាក៏អនិច្ចកម្មទៅ បើកិត្តិសព្ទពាំងនេះ ដឹងទៅដល់លីហ្គោ។ ទើងកំរើកលើកទាហានមកវាយបន្ទាយយើងតាមផ្លូវក្តុំមា"ឡេង នោះយើងត្រូវសម្ងំឲ្យស្ងៀម បើយើញកងទ័ពមុខលើកលែងហួសទៅដល់មាត់ផ្លូវវេលាណា សឹមយើងលើកសេនាទាហានចេញវាយកាត់កងទ័ពលីហ្គោ" យើងមុខជាទើងចាប់ខ្លួនលីហ្គោបានដោយងាយ ។ គុយកែឆ្លើយថា ដែលលោកគិតនោះល្អណាស់ គ្មាននរណាស្មើបាន ។ ខណៈនោះ ចូឆូបង្គាប់ទាហានពាំងពួងឲ្យស្ងៀកសពាក់សហើយឲ្យនាំគ្នាយំសោកអាណិតថា ចូឆូក្មេងនេះលំបាកវេទនាលុះត្រាហ៍មកដល់បន្ទាយពេលយប់ ក៏ទទួលអនិច្ចកម្ម ដូច្នេះ ដើម្បីឲ្យកិត្តិសព្ទពាំងនេះឮទៅដល់ទាហានលីហ្គោ" ។ ទាហានពាំងពួងបាននាំគ្នាធ្វើតាម ។ ចូឆូក៏រៀបចាត់ចែងទាហានឲ្យលើកទៅបង្កប់នៅក្តុំមា"ឡេង ។

ឯទាហានលីហ្គោឮកិត្តិសព្ទថាចូឆូស្លាប់ ក៏នាំយកដំណឹងនោះទៅប្រាប់លីហ្គោ។ បានស្តាប់សំគាល់ក្នុងចិត្តថាពិតប្រាកដ ទើបថា "គ្រានេះមុខជាសមប្រកបតាមគំនិតរបស់យើងហើយ យើងនឹងលើកទៅវាយទាហានចូឆូទុកជាកំឡាំង" ថាហើយលើកទ័ពទាំងអស់ទៅឲ្យដល់ក្តុំមា"ឡេង ។ ទាហានកងមុខនោះលើកកន្ទុងចេញទៅដល់មាត់ផ្លូវជិតបន្ទាយចូឆូ ។ ឯចូឆូឃើញថាបានការ ក៏ឲ្យអុជផ្ការជាសញ្ញាឡើង ហើយ

លើកទាហានចេញវាយស្កាត់ពាក់កណ្តាលខួបព័ទ្ធជុំវិញ ។ លីប៉ាចេញ
ទៅតទល់ដោយអង់អាចកណ្តាលទ័ព ទាហានស្លាប់ខូចខាតជាច្រើន ។
លីប៉ាក៏នាំទាហានដែលនៅសល់នោះ លើកពុះពារត្រឡប់ក្រោយចូល
ដល់ស្រុកចាក់អៀងវិញ ហើយបង្គាប់ឲ្យទាហានទាំងពួងឡើងត្រួតត្រា
រក្សាសើនបន្ទាយដោយមាំមួន ចំណែកចូឆូលើកទាហានចូលបន្ទាយវិញ ។

កន្លងសម័យនោះ អាណាខែត្រទាំងទិសឯកើតកើតមានសត្វដង្កូវជា
ច្រើន ស៊ីអស់ស្រូវកន្លងមកស្រែនឹងស្ទឹមកណ្តាប់ត្រចៀនដំបន់ ស្រូវឡើង
ថ្លៃ ១ ថាំង ៥ រៀល ។ អស់អាណាប្រជានុកស្តុកទាំងពួង ត្រូវត់
អត់ឃ្លានជាច់ពោះស្ងាប់ជាច្រើន ។ មនុស្សខ្លះគាប់សម្លាប់គ្នា អារយក
សាច់មកបរិភោគជាអាហារ ។ ឯទាហានកងទ័ពចូឆូជាច់ស្បៀង
អាហារយូរថ្ងៃ ចូឆូទើបលើកទ័ពទៅបញ្ឈប់កងស្រុកអៀនសៀ ។ លីប៉ា
ឃើញដូច្នោះ ក៏លើកទាហានចេញទៅរក្សាគយប្រទល់ដែនខែត្រចាក់-
អៀនត្រាប់ដំបន់ ។

ភាគទី ១០

ចាប់តាំងពីគោកៀមប្រឹក្សានឹងបិតុកថា ខែត្រឈើដីវនេះ យើងត្រូវប្រគល់ឲ្យខ្មៅពីត្រប់ត្រង ។ លុះដល់គោកៀមអនិច្ចកម្មទៅ ខែត្រឈើដីវក៏បានមកខ្មៅពីត្រប់ត្រងមែន ។ ចូរឆ្ងល់ចិត្តខ្លាំង ព្រោះមិនបានសម្លាប់គោកៀមដាវសងសឹក ទាំងឃើញស្រុកឈើដីវបានទៅខ្មៅពីកាន់កាប់ ដោយគ្មានស្រក់ឈាម ទើបរៀបកងទ័ពដោយបំណងនឹងទៅវាយខ្មៅពី . . . រៀងរហូតដល់លើបោះជ្រាំងចាញ់ចូរឆ្ងូ ហើយទៅសុំនៅនឹងខ្មៅពី ។

ពេលនោះ គោកៀមចៅហ្វាយស្រុកឈើដីវ អាយុ ៦៣ ឆ្នាំ មានជម្ងឺឈឺធ្ងន់ណាស់ ទើបឲ្យហៅបិតុកនឹងតាន់តេងមកប្រឹក្សាថា ខ្លួនខ្ញុំជរហើយថែមទាំងមានជម្ងឺឈឺធ្ងន់ទៀត បើជាមានសឹកសាមមកមុខជានឹងធុតសង្ឃឹមសោះ ។ បិតុកឆ្លើយថា ដែលលោកគិតដូច្នោះក៏ត្រូវហើយព្រោះខ្ញុំដឹងថា ទ័ពចូរឆ្ងូដែលលើកទៅច្បាំងនឹងលីចាំ"លើកនេះជាសេចក្តីហួងហែង បានជាលីចាំ"លើកទ័ពទៅវាយយកស្រុកគុនដីវ ចូរឆ្ងូនឹងលីចាចច្បាំងគ្នាដូច្នេះទទួលស្លូវក៏ថ្លៃ បានជាចូរឆ្ងូលើកទ័ពទៅតាំងនៅស្រុកអៀនសៀ បើដល់ចូលឆ្នាំថ្មី ស្រូវអង្កាបរបិបូណ៌ហើយ មុខជាចូរឆ្ងូនឹងលើកទ័ពមកធ្វើសង្គ្រាមនឹងលីចាំទៀត បើដូច្នេះសូមឲ្យលោកអញ្ជើញខ្មៅពីមក និយាយអង្វរលន់តួប្រគល់ស្រុកនេះឲ្យខ្មៅពីចុះពេលនេះប្រហែលខ្មៅពីព្រមទទួលមិនខាន បើបានដូច្នេះអស់បណ្តាពស្តុកនឹងបានសេចក្តីសុខតទៅ ។

គោកៀមយល់ឃើញត្រូវ ក៏ឲ្យបំរើចេញទៅអញ្ជើញឡោពីពីស្រុក សៀវផាយឲ្យចូលមក ។ ឡៅពីឃើញបំរើទៅ ជាប់ក៏ប្រញាប់រៀបខ្លួនចូលមកជាមួយនឹងកូនអ្នក តៀវហ៊ុយ ហើយចូលទៅរកគោកៀម។ ក៏ឲ្យអញ្ជើញឡៅពីចូលទៅក្នុង ហើយនិយាយថា សព្វថ្ងៃខ្លួនខ្ញុំកាន់តែចាស់ជរាភេគាពាធបង្កើតមានជាមួយ មិនដឹងជាសេចក្តីស្លាប់នឹងមកដល់វេលាណាទេ ខ្ញុំមានតែសេចក្តីបរិតក្តនឹងស្រុកឈឺជីវនេះ ព្រោះមិនមានអ្នកឯណានឹងត្រួតត្រាក្សា ជាន់ឲ្យអញ្ជើញអ្នកមកជ្រាបនឹងលើកប្រគល់ឲ្យអ្នក។ ចូរមានសេចក្តីអាសូរកុំណាដល់ខ្ញុំ ទទួលយកត្រាសម្រាប់ងារចុះ ដើម្បីនឹងជាន់ជួយទំនុកបំរុងបណ្តាពស្តួអ្នកស្រុកឲ្យបានសេចក្តីសុខតទៅ ។ ឡៅពីតបថា លោកមានបុត្រាពេញការទាំងពីរនាក់គឺគោស៊ុងជាបង គោអេងជាប្អូន ហេតុម្តេចមិនប្រគល់ការពារជាការកូនស្រុកនេះជាជំនួសលោក? ។ គោកៀមឆ្លើយថា បុត្រខ្ញុំទាំងពីរនេះល្ងង់គ្មានសតិប្បញ្ញាសោះ ស៊ីនឹងប្រគល់ឲ្យកាន់ការឃើញថាធ្វើមិនកើត យូរទៅគង់នឹងមានទុក្ខដល់អាណាប្រជានុរស្តួមិនខាន ខ្ញុំឃើញតែអ្នកនឹងទទួលការបាន។ ជាឲ្យអញ្ជើញមក, បើខ្ញុំអស់ជីវិតវេលាណា កុំឲ្យអ្នកប្រគល់ការឲ្យបុត្រាខ្ញុំទាំងពីរនេះឡើយ ។

ឡៅពីឆ្លើយថា ខ្លួនខ្ញុំកំឡាំងតិចណាស់ ដែលនឹងទទួលធ្វើជាចៅហ្វាយស្រុកនេះ ឃើញថានឹងផុតឥតសង្ឃឹមសោះ ។ គោកៀម

ថា "តាហានក្នុងស្រុកនេះមានច្រើន ខ្ញុំនឹងឲ្យស៊ុនខៀនចៅហ្វាយស្រុកបាក់ហៃមកជាទីប្រឹក្សាផង" ដូច្នេះហើយនិយាយនឹងចិតុកថា បើឡៅពីទទួលធ្វើជាចៅហ្វាយខែត្តគេ ឲ្យអ្នកចៅផ្ទៃខ្នងធ្វើពុតការជាមួយនឹងឡៅពីចុះ ។ ឯឡៅពីក៏ទៅមិនចាន់ទទួលពាក្យគោកៀមថាម្តេច ។

ខណៈនោះ ភេគគោកៀមកាន់តែបណ្តាលកំរើបឡើង នឹងចរចាក៏ពុំបាន យកតែមាមដៃចង្អុលត្រង់ខ្លួនហើយជាច់ខ្យល់ស្លាប់ ។ សេនាតាហានគោកៀមតាំងប៉ុន្មាន ក៏លើកយកគ្រាស់មាប់ងាមកប្រគល់ឲ្យឡៅពីៗ មិនព្រមទទួល ។ សម័យនោះ បណ្តាអ្នកស្រុកក្នុងទីចំណុះខែត្តបានដឹង នាំគ្នាចូលមកគំនាប់ឡៅពីហើយនិយាយអង្វរលន់តួថា ដែលលោកមិនព្រមទទួលធ្វើជាចៅហ្វាយខែត្តឈឺដីវនេះ អំណើះតទៅយើងខ្ញុំតាំងឡាយនឹងបានសេចក្តីទុក្ខក្តៅខ្លាំងណាស់ ។ កួនអ៊ូ តៀហ៊ុយ យើញដូច្នោះក៏ជួយនិយាយទៀត ដោយហេតុមានចិត្តអាណិតអាសូរអាណាប្រជានុពស្តពន់ប្រមាណថា សូមឲ្យលោកទទួលយកគ្រាធ្វើចៅហ្វាយខែត្តឈឺដីវ ។ ឡៅពីបានស្តាប់ពាក្យ កួនអ៊ូ តៀវហុយ ក៏ព្រមទទួលគ្រាកុងខណៈនោះ ហើយតាំងស៊ុនខៀនទឹងចិតុកទុកជាទីប្រឹក្សាធ្វេងស្តាំ, ឲ្យកួនអ៊ូ តៀវហ៊ុយចៅឈរវរក្សាស្រុកសៀវផាយ ហើយនាំយកតាហានចូលមកកុងស្រុកឈឺដីវតាំងអស់ ។ ឡៅពីនឹងសេនាតាហាននៅអស់បណ្តាពស្តុកុងស្រុកនោះ ក៏ស្រុះស្រួលបបួលគ្នា

ស្មៀតពាក់សកាន់ទុក្ខ ហើយឲ្យរៀបតែងការសពគោកៀមតាមទំនៀម រួចនាំយកសពនោះដង្ហែទៅបញ្ចុះទុកនៅតំបន់អ៊ុយហោ ។ ឡៅពីរើយកសំបុត្រដែលគោកៀមធ្វើទុកនោះ មកប្តឹងចូលទៅស្រុកក្រុងឲ្យយកសេចក្តីក្រាបបង្គំទូលព្រះចៅហៀនតេ ។ ក្នុងសេចក្តីសំបុត្រនោះថា: "គោកៀមមានអាការជពកាត ទើបលើកខែត្រឈ្មីដីវប្រគល់ឲ្យឡៅពីធ្វើរាជការដំនួស" ។ ព្រះចៅហៀនតេជ្រាបសេចក្តីហើយ ក៏មិនបានត្រាស់ថាប្រការម្តេច ។

ឯបូធូនៅស្រុកអៀនសៀតុដំណឹងថា គោកៀមចៅហ្វាយខែត្រឈ្មីដីវអនិច្ចកម្ម, ឡៅពីបានធ្វើជាចៅហ្វាយខែត្រនោះ ដូច្នេះហើយទឹងណាស់ថា "យើងមានសេចក្តីក្តៅក្រហាយនឹងគោកៀម ព្រោះមិនទាន់បានសងសឹកគោកៀមសោះ ស្រាប់តែវាអស់ជីវិតទៅ, ឯឡៅពីនោះសោតក៏មិនបានធ្វើសឹកសង្គ្រាម ឲ្យខូចខាតទាហាននឹងព្រញាធ្ង១ឡើយ ហើយមកបានជាចៅហ្វាយស្រុកស្រណុកដោយងាយ ដូច្នេះ យើងនឹងលើកទ័ពទៅសម្លាប់ឡៅពីចេញហើយលើកសពគោកៀមឡើងវិញ ចិញ្ចុំឲ្យស្អិតសាច់នឹងឆ្អឹង ទើបនឹងអស់សេចក្តីក្តៅ" ថាហើយក៏តាំងចាត់ចែងកេណ្ឌកងសេនាទាហានលើកទៅស្រុកឈ្មីដីវ ។

ស៊ុនហុកទីប្រឹក្សាឃើញដូច្នោះ និយាយហាមឃាត់បូធូថា ដែលលោកនឹងលើកទ័ពទៅវាយយកស្រុកឈ្មីដីវនោះ, ជាការកម្រណាស់

មួយរយនាក់ទើបគិតការនេះបានម្នាក់ ដូចកាលគ្រាព្រះចៅហាន់គោចោនឆ្នាំព្រះពាជវង្សបានសោយពាជ្យតជាលំដាប់គ្នាមកដល់ ១២ ព្រះអង្គ, ទទួលអង្គម៉ាំងគិតក្បត់ បានពាជសម្បត្តិដល់ ១៨ ឆ្នាំ, ហាន់កងប៊ូជាកូយព្រះមហាក្សត្រដែលទូចពាជសម្បត្តិដល់អង្គម៉ាំងនោះ ក៏សម្លាប់អង្គម៉ាំងចេញបានពាជសម្បត្តិមកវិញ បានសោយពាជ្យជាដំណាក់តែចំនួន ១២ ព្រះអង្គ ទើបដល់ព្រះចៅហៀនតេ, ឯសព្វថ្ងៃនេះ បើលោកនឹងគិតការធំៗមុខក៏ប្លែកទុកទុកឲ្យមាំដូចព្រះមហាក្សត្រពីដើម ទើបនឹងគិតការតៅបាន ឥឡូវលោកនឹងលើកទ័ពៗក់យស្រុកឈើដីវតែម្ដងនោះ ខ្ញុំឃើញថាពស្តេចាំងពួងនៅមានចិត្តស្រឡាញ់ឡៅពីច្រើន ឃើញថានឹងក់យយកស្រុកនោះមិនបានដោយងាយទេ ឯស្រុកអៀនសៀ បើលោកឲ្យគាហានៅរក្សានោះ លីចោ"ដឹងហើយក៏នឹងលើកទ័ពមកក់យយកទេសោះ លោកលើកៅខាងណោះបើមិនកើតការ នឹងត្រឡប់មកខាងណាក៏មានតែចាញ់ប្រៀបចាំងសងខាង ថែមចាំងទូចខាតគាហានគ្មានទីអង្ខោ"ហើយលោកក៏នឹងតាំងខ្លួនពិបាកណាស់, ទំពាំនឹងដុះក្រាស់ហើរបានឡើងវិញក៏យូរៅមុខ, ដែលលោកនឹងលះបង់ស្រុកទូលាយហើយៅរកទីបង្កើតវិញ នោះសូមឲ្យលោកត្រិះរិះមើលដោយគួរសមសិន ។

ចូរតូបថា អាណាវៃត្រខាងបូពាទិស សុទ្ធតែមនុស្សខ្វៃក្បាអត់ឃ្លានដោយស្បៀងអាហារ ដែលនឹងឲ្យរង់គិតការតៅក៏នៅកងព្រួយលំបាកព្រោះគាហានយើងមុខជាត្រូវអត់ឃ្លានស្បៀងអាហារស្ងាប់ពុំខាន ។

ស៊ុនហុកឆ្លើយថា ឥឡូវនេះខ្ញុំដឹងដំណឹងថា ហោងឹនឹងអ៊ុយសៀវ ឃុំនាំពួកចោរជួតក្បាលលឿងទៅនៅស្រុកអេងដីវ ពតត្បាតធ្វើទុក្ខបុក ម្នេញដល់អាណាប្រជានុរាស្ត្រខ្លាំងណាស់, បើលោកលើកទ័ពទៅវាយ ពួកចោរនោះបែក ក៏នឹងបានស្បៀងអាហារមកដល់លៀងសេនាទាហាន ក្រស្តាំងពួងក៏នឹងមានអំណរចុះចូលមកពឹងពារលោកមិនខាន ហើយ បំផ្លាញសេចក្តីនោះទៅដល់ព្រះចៅហ្នានតេទៀត ក៏នឹងបានសេចក្តី គាប់ប្រសើរដល់លោក ។ ចូតូបានស្តាប់ឃើញត្រូវ ក៏ឲ្យទៅប្រាប់ ហៅហ្ងុននឹងចោយនៅរក្សាស្រុក ឯខ្លួនចូតូឯងក៏បបួលសេនាទាហាន លើកទៅស្រុកអេងដីវ ។

ខណៈនោះ ហោងឹនឹងអ៊ុយសៀវជាមេចោរបានដឹង ក៏លើកពួក ចោរទៅចោះទ័ពនៅតំបន់ភ្នំអេងសាន់ ។ ចូតូដើរចេញទៅមើលពួក កងទ័ពចោរឃើញរបៀបខុសក្បួនសឹក ក៏ឲ្យតឿនអ៊ុយលើកទាហានទៅ ច្បាំងនឹងពួកចោរ ។ ហោងឹក៏ឲ្យទាហានចេញតទល់នឹងតឿនអ៊ុយបាន ៣ ភ្លេង, តឿនអ៊ុយយកខ្លួនចាក់ទាហានចូតូធ្លាក់ពីលើសេះស្ទាប់ ។ ចូតូក៏បរពលចូលប្រគាប់ពួកចោរ ទំលាយបន្ទាយនៅទីភ្នំនោះបែកខ្ចាត ខ្ចាយ ហើយតាំងចោះទ័ពនៅទីនោះ លុះវេលាព្រឹកឡើង អ៊ុយសៀវ ក៏លើកទាហានចេញមកដល់បន្ទាយចូតូ ។

ហោចាំ"ន់តាហានៈចារមានកំឡាំងខ្លាំង កាន់ដំបងដែកចេញមកមុខ តាហានហើយស្រែកប្រកាសថា នរណានឹងតស៊ូគ្នាក៏ឲ្យប្រញាប់ចេញមក ។ ចោហង៍ចាប់ពួកកំដរចូលទៅប្រយុទ្ធគ្នានឹងហោចាំ"ន់បាន ៥ ភ្លេង ចោហង៍ធ្វើជាចេះតែទៅក្រោយ ចោចាំ"ន់ក៏រែងដំបង់ចោលសំដៅទៅចោហង៍ ។ គេចផុត ស្ទុះចូលមកកាប់ហោចាំ"ន់ជាច់ពាក់កណ្តាលខ្លួនស្លាប់នៅទីនោះ ។ លីតៀនឃើញដូច្នោះ ក៏បរសេះកំណួនដេញកាប់ពួកចោរចូលទៅចាប់ខ្លួនអ៊ុយសៀវបាន ។ ចូធូក៏លើកតាហាន តាមចូលទៅដល់បន្ទាយចោរ។ ក៏តត់ព្រាត់ព្រាយភ្លាត់ភ្លាយអស់ទៅ តាហានចូធូក៏ប្រមូលរើសយកទ្រព្យរបស់ចោរបានជាច្រើន ។

ហោងីមេចោរនាំពួកកៀនប្រមាណ ២០០ ភ្លាយរត់ចេញពីបន្ទាយទៅដល់កុំ ១ ក្រឡេកឃើញទៅធូដឹះសេះគាន់ជាវឈរខាំងផ្លូវ ។ ហោងីបំផាយសេះចូលប្រយុទ្ធនឹងទៅធូបាន ១ ភ្លេង ទៅធូចាប់ហោងីបាន ។ ឯពួកចោរទាំងប៉ុន្មានក៏ចុះចូលមកជាពួកទៅធូទាំងអស់ ទៅធូនាំហោងីនឹងពួកចោរចូលទៅទៅកងរូងកុំ ដែលភ្ជាប់នៅសំណាក់ ។ ចូធូឃើញៈហោងីរត់ទៅដូច្នោះក៏ឲ្យតៀនអ៊ុយតាមទៅចាប់ខ្លួន ។ តៀនអ៊ុយបរសេះលើកតាហានទៅដល់ដើងកុំ ឃើញទៅធូនាំពួកម៉ាកចេញមកឈរស្កាត់ទទឹងផ្លូវ ។ តៀនអ៊ុយសួរថា អ្នកនេះជាពួកចោរដួតក្បាលលឿងឬ? ។ ទៅធូតបថា យើងមិនមែនពួកចោរទេ, ឯពួកចោរដួត

ក្បាលលឿងនោះយើងចាប់បានមេវាម្នាក់មកទុកក្នុងរូងភ្នំ ។ តៀនអ៊ុយសួរថា បើដូច្នោះ ចូរអ្នកទៅយកពួកចោរនោះមកឲ្យយើងជាឆាប់ ។ ទៅធូឆ្លើយថា បើអ្នកយកក្បាលរង៍ទួលជាវយើងនេះបាន ទើបយើងប្រគល់ពួកចោរឲ្យ ។ តៀនអ៊ុយឮសំដីដូច្នោះ ក៏ខឹងណាស់ បរសេះកំដាវចូលទៅ ប្រយុទ្ធនឹងទៅធូតាំងពីព្រឹកលុះដល់ថ្ងៃត្រង់មិនចាញ់មិនឈ្នះ, ទាំងសងខាងក៏ថយឈប់សម្រាកកម្លាំង ហើយគ្រាកឡើងបបួលគ្នាប្រយុទ្ធទៀតតាំងពីថ្ងៃត្រង់ដល់រសៀលល្ងាច សេះក៏អស់កំឡាំង ទៅធូឲ្យឈប់វិលចូលទៅក្នុងរូងភ្នំវិញ ។ តៀនអ៊ុយឲ្យទាហាននាំយកសេចក្តីទាំងនោះទៅថ្វាយចូនួ។ ចូនួដឹងដូច្នោះលើកទាហានចេញទៅទាំងពេលយប់ ។

លុះពេលព្រឹកព្រហាមទៅធូនាំយកពួកចេញពីក្នុងរូងភ្នំ ។ ចូនួឃើញរូបរាងទៅធូមានខ្ពស់ប្រហែល ៦ ហត្ថសមជាទាហាន ក៏គិតចង់បានទៅធូទុក ។ ទើបបង្គាប់តៀនអ៊ុយថា អ្នកចូរទៅតយុទ្ធម្តងទៀត ហើយធ្វើជាចាយរត់ត្រឡប់មកគ្រាយវិញ ។ តៀនអ៊ុយក៏ធ្វើតាម លុះប្រយុទ្ធគ្នាបាន ៣០ ក្មេង ក៏ថយត្រឡប់មកគ្រាយដោយរហ័ស, ទៅធូក៏បំផាយសេះដេញតាម, ចូនួឃើញដូច្នោះបង្គាប់ឲ្យទាហានចាញ់ធ្វើចម្រុះទៅ ទៅធូឃើញកម្លាំងនឹងតទល់ពុំបាន ញាក់សេះបរត្រឡប់នាំបក្សពួកចូលទៅក្នុងរូងភ្នំវិញ ។ លុះដល់ភោលអាត្រស្វាត់ ចូនួ

បង្គាប់ឲ្យដឹកវល្ទុង ហើយយកអន្លាក់ជាក់នៅមាត់វល្ទុងនោះ ហើយយកស្មៅកយជាក់ពីលើមាត់រណ្តៅមិនឲ្យស្គាល់បាន ។ ដល់ព្រឹកព្រាងឡើង ចូធូក៏ចាត់តៀនអ៊ុយឲ្យលើកគាហាន ១០០ ចូលទៅស្រែកដេរដៀមជាមនៅមាត់រូង បើឃើញទៅធូចេញមកឲ្យតែលប់បញ្ចោតថយមកត្រង់វល្ទុងនោះ ។ តៀនអ៊ុយលើកគាហាន ១០០ ទៅធ្វើតាមចូធូបង្គាប់ ទៅធូបានឮលើកបក្សពួកចេញមក ឃើញទៀនអ៊ុយហើយស្រែកថា "អាគាហានដិះសេះនេះនឹងមកលេងគ្នានឹងអញទៀតឬ?" ហើយក៏បាសេះចូលទៅច្រយុទ្ធនឹងតៀនអ៊ុយបាន ១០ ភ្លេត ទៀនអ៊ុយធ្វើជាញាក់សេះថយរត់ទៅខាងវល្ទុងនោះ ទៅធូមិនដឹងកល។ បាយបំផាយសេះដេញតាមទៅ សេះនោះកំផុងធ្លាក់កងវល្ទុងជាមួយនឹងទៅធូ អន្លាក់នោះជាប់ជើងទៅធូជាមួយនឹងពួកម្នាក់ គាហានចូធូកន្ត្រាក់ខ្សែទុក ហើយចូលទៅឡោមព័ទ្ធចាប់ដើងដៃទៅធូចង នាំទៅឲ្យចូធូ ។ ឃើញដូច្នោះកំធ្វើជាក្លាក់ខ្លួន ហើយគ្រាកចុះទៅស្រាយចំណងពីដើងដៃទៅធូចេញអស់ ឲ្យយកសំលៀកបំពាក់យ៉ាងល្អមកឲ្យទៅធូស្លៀកពាក់ ហើយគាញដៃមកឲ្យអង្គុយហើយសួរថា អ្នកឯងឈ្មោះអ្វី? កំណើតនឹងលំនៅទៅស្រុកណា? ហេតុម្តេចទើបមកនៅនឹងរូងភ្នំ? ។

(មានត)

ភាគទី ២

សម័យឧត្តរាំង

ឧកញ៉ាទេពពិទូរ ឈឹម - ក្រសែម រៀបរៀង

(តទៅ)

ព្រះចាន់ទន្ទ្រីវ័ន្ទទី ២

ព.ស. ១៧៦៨ - ១៧៨៤ (១) ត.ស. ១៦០៥ - ១៦៤៥

ព្រះចាន់ទន្ទ្រីវ័ន្ទទី ២ ជាព្រះរាជនុរស់របស់ព្រះចាន់ជយវ័ន្ទទី ៧ និងព្រះនាងជយរាជទេវី អគ្គមហេសី ។ កាលនៅកុមារគេហៅព្រះនាម "លវៀតយេស" ក៏មាន "ស្រីវិន្ទ្រកុមារ" ក៏មាន, កាលទ្រង់បានសោយរាជ្យ គេថ្វាយព្រះបរមនាមជា "ព្រះចាន់ទន្ទ្រីវ័ន្ទ" រាប់ជាទី ២, ទ្រង់មានព្រះអគ្គមហេសី ព្រះនាមដូចម្តេច និងមានព្រះរាជនុរសព្រះរាជធីតាប្អូនទេ មិនអាចដឹងបាន ។

ការងើងជ័ — ព្រះចាន់ទន្ទ្រីវ័ន្ទទី ២ ទ្រង់មានព្រះសមត្ថភាពនឹងព្រះរាជចរិយាវត្ត ប្រហែលនឹងព្រះបរមរាជបិតា ទាំងព្រះរូបកំទ្រង់ស្អាតហាប់យ៉ាងព្រះបរមជនកនាថ កាលនៅកុមារ ក្នុងពេលដែលព្រះរាជបិតាទៅគង់នៅក្រុងចាម្ប៉ា ទ្រង់បានជួយចាំងព្រះចាន់យសោវ័ន្ទទី ២

---

(១) ក្នុងប្រវត្តិសាលវៃថា ព. ស. ១៧៤៤ - ១៧៦៣ ។

កម្ពុជាតតាហ្ម ដែលមកដណ្តើមរាជបល្ល័ង្ករបស់ព្រះបាទយសោវរ្ម័ន
បានទ្វេជ័យជំនះ ក្រោយនោះមកទ្រង់បានចម្បាំងតស៊ូនឹងពួក ព្រះ
ត្រីភុវនាទិត្យ ដែលកាត់ព្រះបាទយសោវរ្ម័នទី ២ ទៀត តែគ្រានេះ
ទ្រង់មិនអាចយកជ័យជំនះបាន សត្រូវបានលុកចូលក្នុងព្រះបរមរាជវាំង
ធ្វើគតព្រះបាទយសោវរ្ម័នបង់ ។ កាលព្រះរាជបិតាបានសោយរាជ្យហើយ
ព្រះស្រីវិន្ទ្រកុមារ បានទ្រង់តំណែងជាមេទ័ពចេញច្បាំងកម្ពុជាមួយនឹងព្រះរាជបិតាដែលជាអគ្គសេនាប្រមុខ ជាបដល់មានជ័យជំនះ
យ៉ាងធំ ។ ដោយទ្រង់មានសគុណចំណាចយ៉ាងនេះ ព្រះបាទជយ-
វរ្ម័នទី ៧ ទើបទ្រង់សាងព្រះរាជបន្ទាយឆ្នាំរនៅក្នុងខេត្តកំពង់ចាម្ប
ក្នុងជាអនុស្សាវរីយ៍ ដល់ព្រះអង្គស្រីវិន្ទ្រកុមារ ។

កាលទ្រង់បានសោយរាជ្យឡើងហើយ ទ្រង់បានគ្រប់គ្រងរក្សាព្រះ
អាណាចក្រ នឹងអាណានិគម ឲ្យគង់វៀងដូចដើម ។

លុះមកដល់ ព. ស. ១៧៤៦ ព្រះបាទឥន្ទ្រវរ្ម័នទ្រង់លើកទ័ពទៅ
កម្ពុជាម្ប ដែលកើតឧស្សាហ៍បះបោរមកតាំងពីក្នុងឆ្នាំ ១៧៣៦ បាន
សម្រេច ចាម្បក្លាក់មកជាអាណានិគមខ្មែរយ៉ាងដើមវិញ ។ កាល
ស្រេចការកម្ពុជាទៅចម្ប៉ាហើយ ទ្រង់លើកទ័ពឡើង ទៅកម្ពុជាកៅដី
(យួន) ទៀត ដោយហេតុពួកយួននេះ តែងរុកពាននៅតាមជាយព្រះរាជ-
អាណាចក្រ ប៉ះកាងលើនោះជាញឹកញាយ ។ ន័យ ១ ទៀត ក្នុងពេល

នោះ មានកើតទុរយស ដោយមានសេនាបតីយួន ១ នាក់បង្កហេតុក្បត់ផែនដីយួនផង ទ្រង់លើកកងទ័ពចូលវាយលុកហួតទៅដល់ខែត្រង៉ែអានហើយ ទើបលើកទ័ពត្រឡប់មកកាន់វៀងចន្ទន៍ ហួងព្រះបាង ដែលជាអាណានិគមមួយ, ទ្រង់កម្រាបពួកលាវដែលបង្កហេតុបះបោរ ឲ្យរាបថាបហើយស្តេចលើកទ័ពត្រឡប់ព្រះមហានគរ ដោយសុវត្ថិភាព ។

មកដល់ ព. ស. ๑๗๙๐ ក្សត្រិយ៍ប្រទេសចិន បានតែងរាជទូតឲ្យនាំរាជសារនឹងរាជបណ្ណាការ មកសុំចងសម្ពន្ធមេត្រីភាពជាមួយនឹងប្រទេសកម្ពុជា ។ ខាងប្រទេសកម្ពុជា ក៏ព្រមទទួលសម្ពន្ធមេត្រីភាពនេះ យ៉ាងរាក់ទាក់ ។ ប្រទេសចិននឹងប្រទេសកម្ពុជា បានចងជាសម្ពន្ធមិត្តផងគ្នា ទៅវិញទៅមកតាំងពីកងសម័យនគរកុំ រាប់ជាគ្រាទី ๗ ក្នុងរជ្ជកាលនេះ ។

លុះមកដល់ ព. ស. ๑๗๖๓ មិនដឹងជាដោយហេតុអ្វី ស្រាប់តែប្រាកដថា ប្រទេសកម្ពុជាបះបង់ចោលចម្ប៉ា បណ្តាយឲ្យតាំងខ្លួនជាឯករាជ្យឡើងវិញ ។ តអំពីនោះមក ចាម្ប៉ាលែងបានមកនៅកងក្នុងអំណាចព្យាបាលខ្មែរហើយ តែឯករាជ្យរបស់ចាម្ប៉ា ក៏មិនស្ថិតស្ថាពរដែរ ព្រោះក្រោយនោះមិនយូរប៉ុន្មាន ត្រូវពួកយួនកំចេញអស់រលីងផែនចម្ប៉ាក៏ធ្លាក់ទៅជាសម្បត្តិរបស់យួន ជាតិចាម្ប៉ាគោងខ្ចាត់ខ្ចាយទៅជ្រកនៅតាមប្រទេសជាំងឡាយក្នុងទ្វីបអាស៊ី មានប្រទេសកម្ពុជាជាដើមរាបមកដល់សព្វថ្ងៃនេះ ។

ប្រវត្តិសាស្ត្រ របស់ចាម្ប៉ាដែលគួរនាំមកពណ៌នាក្នុងទីនេះ គឺជាជាតិអ្នកចំបាំងដ៏ក្លាហាន១ ហើយតាំងខ្លួនជាគូសត្រូវនឹងជាតិខ្មែរ នៅដិតខ្មែរ តែមិនដែលសុំចង់សម្ពន្ធមេត្រីភាពយ៉ាងចិន មានតែលើកទ័ពមកវាយប្រទេសកម្ពុជាញឹកញាយ ដូចមានប្រាកដក្នុងប្រវត្តិសាស្ត្រស្រាប់ ចាំងនេះ ដោយអំណាចសេចក្តីប្រាថ្នានឹងសេចក្តីលោភចង់បានមហាភោគទ្រព្យរបស់ខ្មែរទៅជាសម្បត្តិរបស់ខ្លួន តែអំពើចចើងនេះ ទំនងដូចជាមមាចចូលភ្លើង ។

ការព្រះសាសនា – ព្រះបាទឥន្ទ្រវរ្ម័ន ទ្រង់កាន់ព្រះពុទ្ធសាសនាតាមយ៉ាងព្រះរាជបិតា នឹងព្រះរាជជននីនាថ ការកសាងវត្តស្ថានប្រហែលជាទ្រង់បានសាងតុកខ្លះដែរ តែមិនប្រាកដឈ្មោះប៉ុណ្ណោះ ។

មកដល់ឆ្នាំ ព. ស. ๑๗๘๖ ព្រះបាទឥន្ទ្រវរ្ម័នទី ๒ សោយទិវង្គតទៅ ក្រុងស្រីយសោធរបុរៈគេថ្វាយព្រះនាមព្រះបរមសព្វដូចម្តេចមិនប្រាកដ។ ព្រះមហាក្សត្រិយ៍អង្គនេះរាប់ជា ពាជាធិរាជ ๑ ក្នុងប្រវត្តិសាស្ត្រ ។

ព្រះបាទជយវរ្ម័នទី ๘

ព. ស. ๑๗๘๘ ๑๘๓๘-๙, គ. ស. ๑๒๔๕-๑๒๔๕-๖

ប្រវត្តិសាស្ត្រប្រទេសកម្ពុជា តាំងអំពីដើមរហូតដល់ក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័នទី ๒ មានអាការប្រៀបដូចឡើងស្ពានគឺថាព្រះមហាក្សត្រិយ៍ទាំងឡាយ រមែងមានព្រះតេជានុភាពនឹងព្រះសមត្ថភាព

អាចគ្រប់គ្រងប្រទេស ឲ្យគង់នៅជាមហាប្រទេស មហាអំណាចជាដរាបមក បើទុកជាមានថ្ងាះធ្លាយខ្លះ ក៏អាចកែខ្លួនឡើងវិញបានភ្លាមៗ ។ ល្មមមកដល់កន្លងបុង់សម័យនគរធំគឺពីត្រឹមរជ្ជកាល ព្រះបាទជយវរ្ម័នទី ៨ នេះទៅ ប្រទេសកម្ពុជាមានអាការៈប្រៀបដូចចុះពីស្ថាន គឺអំពីនេះទៅប្រទេសកម្ពុជាសន្យឹមៗ ថយអានុភាពចុះដោយលំដាប់ កន្លងបំផុតក៏ធ្លាក់ទៅជាអនុប្រទេស ដូចជានឹងមានប្រាកដទៅខាងក្រោយ ។

ព្រះបាទជយវរ្ម័នទី ៨ អង្គនេះ មិនដឹងជាតវង្សអំពីព្រះមហាក្សត្រិយ៍អង្គណាជាប្រាកដទេ តាមផ្លូវសន្និដ្ឋានថាគង់ជាតវង្សមកអំពីព្រះបាទជយវរ្ម័នទី ៧ នោះឯង ទ្រង់មានព្រះអគ្គមហេសីព្រះនាមដូចម្តេចមិនប្រាកដ, មានព្រះរាជនុរសប្អូនទេមិនប្រាកដ, ប្រាកដតែថាទ្រង់មានព្រះរាជធីតា ២ អង្គ, មួយអង្គបានទៅព្រះបាទស្រីន្ទ្រវរ្ម័នទី ២ មួយអង្គទៀតបានទៅព្រះស្រីបតិន្ទ្រវរ្ម័នទី ៣ ក្សត្រិយ៍ថៃនៅសុខោទ័យ ។

មកដល់កន្លងឆ្នាំ ព. ស. ១៨០០ ព្រះបាទជយវរ្ម័នទី ៨ បានទ្រង់ព្រះមេត្តាប្រោសតែងតាំងក្សត្រិយ៍ថៃ ១ អង្គ ព្រះនាមឃុនផាមឿង ឲ្យជាស្តេចប្រទេសរាជ នៅក្រុងសុខោទ័យ គ្រប់គ្រងអាណានិគមខ្មែរភាគខាងទិសពាយ័ព្យជាដំបូង ។ មុននឹងបញ្ជាក់ពីហេតុផលដែលទ្រង់ព្រះមេត្តាប្រោសតាំងឃុនផាមឿងជាប្រទេសរាជ គួរពណ៌នាអំពីប្រវត្តិរបស់ជាតិថៃ (សៀម) ទុកក្នុងទីនេះដោយសង្ខេបផង ។

(មានត)

រឿងអារក្សថ្លែងរឿងវិញ្ញាណ

លោកសាង - សារ៉ាត ៖ លេខាធិការ ក្រសួងហិរញ្ញវត្ថុ

ប្រែពីភាសាចាវ៉ាមកជាខ្មែរ

(ភាគ៣)

កាលលោកអាចារ្យបានស្តាប់ព្រះធម្មទេសនារបស់ព្រះមហាក្សត្រ នឹងពាក្យរបស់ពួកអាមាត្យទាំងអស់ហើយ ក៏យល់ថា: "ព្រះអង្គទ្រង់ខ្វះខ្លែងជាពន់ពេក ដើម្បីកុំឲ្យលោកធ្វើសមណធម៌បាន" ។ លុះយល់ដូច្នោះ លោកអាចារ្យក៏រត់ចេញផុតព្រះពាជធានី ហើយសម្លាប់កូននោះទៅ រួចត្រឡប់ទៅនៅកន្លែងវិញ ដូចមុនទៀត ។ ចំនួនច្រើនថ្ងៃក្រោយមក ស្តេចទ្រង់ទិវង្គត ឯអ្នកធ្មប់ក៏តាំងសីលតទៅ ។

នេះរបស់រឿងនេះដូច្នេះ : មានជនបីនាក់ កើតពេលម៉ោងតែមួយ កន្លែងតែមួយ គឺម្នាក់នោះកើតក្នុងផ្ទះស្តេច, ជនទីពីរកើតក្នុងផ្ទះអ្នកជំនួញលក់ប្រែង, ជនទីបីគឺអ្នកធ្មប់ដែលបានទៅកើតក្នុងផ្ទះនាយសន្ទុះ ។ ជនទីមួយសោយជាព្យាទៅទីនេះ, កូនអ្នកជំនួញប្រែងសោយជាព្យាទៅកន្លែងហានេះ, កូននាយសន្ទុះបានសាងសីល ។ សន្ទុះនេះបានសម្លាប់ឈ្មួញប្រែង រួចក្លាយទៅជាអារក្សមួយអាត្រកដែលស្ថិតនៅកន្លែងជ្រោះ ព្យាក្បាលចុះមកក្រោម នៅលើដើមឈើមួយ, ឥឡូវកើតទុក្ខមិនសុខចិត្តនឹងខ្លួនវាស្លាប់នេះ ។ បើប្រសិន

ណាអ្នកចៀសវាងវាបាន អ្នកនឹងបានសោយរាជ្យ យើងប្រាប់អ្នក
ជាមុន ចូរអ្នកប្រុងប្រយ័ត្នចុះ ។ លុះនិយាយយ៉ាងដូច្នោះហើយ
អារក្សក៏ចេញទៅ ព្រះរាជាក៏យាងចូលទៅក្នុងព្រះបរមរាជវាំងដែរ ។
លុះព្រឹកឡើង ព្រះអង្គទ្រង់យាងចេញមក ហើយប្រទង់បង្គាប់ឲ្យប្រជាជន
ប្រជុំគ្នា ។ ជនទាំងអស់ នោះមន្ត្រីក្តីរាស្ត្រក្តី ក៏ចូលទៅគាល់ព្រះមហា-
ក្សត្រ ហើយយកដង្វាយទៅថ្វាយដល់ព្រះអង្គ ។ សូរក្អេងតូរ្យតន្ត្រី
ក៏លាន់ឮរំពងឡើង ។ ព្រះរាជធានីទាំងមូលដំកល់នៅក្នុងសេចក្តីរីក
រាយសប្បាយជាពន់ពេក ដែលកាន់តែធំឡើង។ ។ រួចស្តេចក៏ចាប់
ត្រងរាជ្យសម្បត្តិដោយយុត្តិធម៌តទៅ ។

គេនិទានថា: ថ្ងៃមួយនោះ មានអ្នកធុតង្គមាក់ឈ្មោះស្ហន្តស្ហិល
(Shant-Shil) មកកាន់ព្រះបរមរាជវាំង បានកាន់ផ្លែឈើមួយក្នុងដៃយកមក
ថ្វាយព្រះមហាក្សត្រដោយខ្លួនឯង។ អ្នកធុតង្គនោះលុះបានគ្រាលក្រាល
របស់ខ្លួនហើយក៏អង្គុយចុះ ។ កន្លងមួយមោងក្រោយមកក៏ចេញទៅវិញ
ទៅ ។ លុះអ្នកធុតង្គទៅបាត់ ព្រះមហាក្សត្រទ្រង់នឹកថា: "តើមិនមែនអ្នក
ធុតង្គដែលអារក្ស (démon) និយាយប្រាប់អញទេឬអ្វី" លុះទ្រង់ឆ្លុះក្នុង
ព្រះទ័យដូច្នោះទ្រង់ក៏មិនសោយផ្លែឈើនោះ តែទ្រង់មានព្រះបន្ទូលហៅ
នាយដំនិតព្រះអង្គមក ទ្រង់ប្រទានផ្លែឈើនោះទៅ ដោយទ្រង់គ្រាស់
បង្គាប់ឲ្យយកទៅរក្សាទុកឲ្យស្រួល ។ ប៉ុន្តែអ្នកធុតង្គតែងត្រឡប់មក
រកព្រះអង្គជាដរាប ហើយបានថ្វាយផ្លែឈើមួយ ។ រៀងរាល់ថ្ងៃ ។

ថ្ងៃមួយនោះ ទ្រង់ស្តេចយាងទៅទតគ្រាលពជពាដី ដោយមានអ្នកបំរើជាច្រើនហែហមជាបរិវារទៅផង ។ អ្នកធុតង្គក៏យកផ្លែឈើមកថ្វាយព្រះអង្គទៀត ។ ព្រះអង្គទ្រង់ទទួលផ្លែឈើមក ទ្រង់គ្រវត់ចោលទៅលើអាកាស ប៉ុន្តែស្រាប់តែផ្លែឈើនោះ ធ្លាក់ពីព្រះហស្តព្រះអង្គទៅចំលើព្រះអង្គ ស្តេចក៏ទ្រង់ដួលទៅលើពសុធា ។ មានស្វាមួយរើសយកផ្លែឈើនោះទៅចំបែក ស្រាប់តែជួរតន្ត្រីពេជមួយគ្រាប់ដែលមានពន្ធឹជាអស្ចារ្យ ពាល់តែព្រះមហាក្សត្រនឹងមិត្រព្រះអង្គទាំងអស់ខ្លួនស្រឡាំងកាំងគ្រប់គ្នា ។ ព្រះអង្គទ្រង់មានព្រះរាជឧង្ការទៅកាន់អ្នកធុតង្គថា: "ហេតុអ្វីបានជាអ្នកឲ្យតន្ត្រីពេជនេះមកយើង?" ។ អ្នកធុតង្គក្រើយថា: បពិត្រព្រះមហាក្សត្រដ៏ឧត្តម! គម្ពីរបានចែងថា;

"គេមិនត្រូវចូលទៅកន្លែងកំណាស្តេច, កន្លែងអាចារ្យ, កន្លែងហោរ, កន្លែងពេទ្យឬកន្លែងនារីតែមុំណា ដោយដៃទេនោះទេ" អាស្រ័យហេតុនេះហើយ បានជាទូលព្រះបង្គំមកកន្លែងនេះវេលាណា កាន់ផ្លែឈើមួយជានិច្ចមកផង សូមទ្រង់ព្រះមេត្តាប្រោស! តើព្រះអង្គមានព្រះរាជឧង្ការដល់គ្រាប់ពេជតែមួយធ្វើអ្វី? កន្លែងដែលទូលព្រះបង្គំយកផ្លែឈើមកថ្វាយទាំងអស់សុទ្ធតែមានត្បូងដ៏ថ្លៃថ្លា ។

លុះព្រះរាជាទ្រង់ព្រះសណ្តាប់ហើយ ទ្រង់បង្គាប់ឲ្យនាយដំនិតព្រះមុខ្ន យកផ្លែឈើទាំងអស់ដែលអ្នកធុតង្គថ្វាយរួចមកហើយ លុះ

បំបែកផ្លែឈើទាំងនោះទៅ ក៏ឃើញមានគ្រាប់ត្បូងពេជ្រចេញមកគ្រប់ផ្លែឈើមែន ។

កាលទ្រង់ទតឃើញត្បូងទាំងអស់នោះហើយ ព្រះអង្គមានព្រះហឫទ័យរីករាយជាពន់ប្រមាណ ទ្រង់គាស់ឲ្យហៅជាងថ្មមក ដើម្បីពិនិត្យមើលថ្មពេជ្រនោះ ហើយមានព្រះរាជឱង្ការទៅជាងថ្មថា : "យើងគ្មានបានយកអ្វីទៅផងទេក្នុងលោកនេះ, សេចក្តីស្មោះត្រង់ជាវត្ថុមួយដ៏បំផុតនៃស្ថានកណ្តាលនេះ; ហេតុដូច្នេះ ចូរអ្នកនិយាយឲ្យត្រង់មើល តើថ្មនេះមួយៗ ដម្លៃប៉ុន្មាន?" ។ លុះស្តាប់ព្រះរាជឱង្ការចប់ហើយ ជាងថ្មក្រាបទូលថា : "សូមទ្រង់ព្រះមេត្តាជ្រាស! ព្រះអង្គទ្រង់មានព្រះរាជឱង្ការតាមផ្លូវពិត, ជនណាមានគុណធម៌ ជននោះគេទុកជាអ្នកមានបំផុត; គុណធម៌តែងដឹកនាំយើងទៅកាន់សេចក្តីល្អជាដរាប គុណធម៌នេះដួយទ្រទ្រង់យើងក្នុងលោកទាំងពីរ; សូមក្រាបទូលទ្រង់! ថ្មមួយៗនោះ មានតម្លៃ, ទម្ងន់ទឹងទ្រង់ទ្រាយនៅពេញជាល្អណាស់, បើប្រសិនជាទូលព្រះបង្គំថា ថ្មមួយ ។ ថ្លៃ ១០ សែនកហាបណៈ នោះក៏នៅតែតិចជាងជម្លៃពិតរបស់ថ្មនេះ, ដោយពិតទៅ ថ្មមួយៗនេះថ្លៃស្មើមួយភាគក្នុងភាគ ៧ នៃពិភពលោកយើងនេះ ។

ព្រះករុណាលុះទ្រង់ព្រះសណ្តាប់ហើយ ទ្រង់មានព្រះហឫទ័យរីករាយមនស្សជាទីបំផុត ហើយទ្រង់ប្រទានអាវុសក្តីមួយទៅជាងថ្មនោះ

ទើបទ្រង់បង្គាប់ឲ្យចេញពីទីនោះទៅ ។ ព្រះអង្គទ្រង់ចាប់ដៃអ្នកធុតង្គ ហើយឲ្យអ្នកធុតង្គនោះអង្គុយក្រោមស្មៅតូចតែ រួចទ្រង់មានព្រះពាជនុង្ការ ថា: "ព្រះពាជអាណាចក្ររបស់ខ្ញុំតាំងមូល តម្លៃមិនស្មើនឹងតម្លៃថ្នរបស់អ្នកមួយគាប់ផង, សូមអ្នកជ្រាបខ្ញុំ ហេតុម្តេចអ្នកនៅខ្ជិនទេ? ហេតុដូចម្តេច បានជាអ្នកឲ្យតម្លៃថ្មនេះមកខ្ញុំ?" ។

– សូមទ្រង់ព្រះមេត្តាជ្រាស! ទូលព្រះបង្គំគង់នឹងទូលព្រះករុណាឲ្យទ្រង់ជ្រាប តែទូលឥឡូវនេះមិនទាន់បាន ដ្បិតរឿងសិល្បសាស្ត្រ, រឿងសម្ភាសន៍, រឿងសាសនា, រឿងកំប្លែងផ្ទះ, រឿងមិនគប្បីដូចជាការស្រែកឃ្វានដោយតណ្ហា, រឿងពាលនិទានដែលយើងបានពុំ ទាំងនេះគមិនត្រូវនិយាយក្នុងកណ្តាលជំនុំទេ, សូមព្រះករុណាទ្រង់ជ្រាបថា: កាលណាពាក្យមួយម៉ាត់ចូលទៅក្នុងត្រចៀកទាំង ៦ ពាក្យនោះមិននៅកំបាំងទេ, បើប្រសិនណាជាពាក្យនេះធ្លាក់ទៅក្នុងត្រចៀកទាំង ៤ ពាក្យនោះគ្មានអ្នកណាមួយពុំទេ, ចុះបើប្រសិនណាជាពាក្យនេះធ្លាក់ទៅក្នុងត្រចៀក ២, ពាក្យនោះ (Brahma) ព្រះព្រហ្មខ្ជិនព្រះអង្គក៏មិនស្គាល់ដែរ, តើមនុស្សយើងចាំបាច់ធ្វើអ្វី? ។

លុះស្តេចទ្រង់ព្រះសណ្តាប់ហើយ ព្រះអង្គនាំអ្នកធុតង្គទៅតែឯង រួចមានព្រះពាជនុង្ការថា: "ឧ! សន្តបុគ្គល (saint) គួរជាទីគោរព!

អ្នកបានឲ្យតួង្វែងថ្មអស់នេះមកខ្ញុំ ឯខ្ញុំគ្មានដែលបានឲ្យអ្នកបរិភោគក្នុងថ្ងៃណាមួយសោះ ខ្ញុំខ្មាសណាស់ តើអ្នកចង់បានអ្វី?"

អ្នកធុតង្គទូលព្រះអង្គវិញថា: "បពិត្រព្រះមហាក្សត្រ នៅតំបន់ជ្រោងជ្រាំមួយ នាមាត់ទន្លេគោទាវរី (Godavery) ខ្ញុំធ្លាប់លី ហើយខ្ញុំសូត្រអាគមន៍គាថា ដែលខ្ញុំបានឈានទាំង៨, អាស្រ័យហេតុនេះទូលព្រះបង្គំសុំតែនៅជិតនឹងព្រះអង្គចំនួនមួយយប់ទេ, ដោយសារព្រះអង្គគង់នៅជិតនេះ សីលរបស់ទូលព្រះបង្គំនឹងបានសម្រេចមិនខាន" ។

ព្រះកុណ្ឌធ្លេតបវិញថា: "មិនជាអ្វីទេ ចាំខ្ញុំត្រឡប់មកវិញ, ចូរអ្នកជ្រាប់ខ្ញុំ តើថ្ងៃណាដែលខ្ញុំត្រូវទៅនៅជិតអ្នក?" ។

– សូមព្រះកុណ្ឌស្តេចយាងមកវេខ្ញុំព្រះអង្គតែម្នាក់ឯង ហើយជាក់អាវុធមកផង ក្នុងយប់ថ្ងៃអង្គារ ១៤ កេច ខែសីហា ។

ព្រះកុណ្ឌមានព្រះរាជឧង្ការថា: "អ្នកអញ្ជើញទៅចុះ ខ្ញុំជ្រាបដជាទៅម្នាក់ឯង" ។

អ្នកធុតង្គបានក្រាប់ព្រះទ័យព្រះមហាក្សត្រ ដោយពាក្យសន្យានេះរួចចូលទៅកន្លែងវិហាររបស់លោក, លុះរៀបចំអស់គ្រឿងប្រដាប់ដែលលោកត្រូវការហើយ លោកក៏ទៅអង្គុយនៅទីជ្រាំមួយ ។

លុះដល់កាលកំណត់ ព្រះមហាក្សត្រស្តេចចេញទៅតែមួយព្រះអង្គឯងកណ្តាលរាត្រី ជានសៀតជាវេនឹងព្រះអង្គទៅផង ដើម្បីទ្រង់

យ៉ាងទៅដិតអ្នកធុតង្គ ។ លុះស្តេចទៅដល់ អ្នកធុតង្គបានវន្ទាចំពោះ
ទ្រង់ៗ ក៏តំនាំអ្នកធុតង្គៗ ក្រាបទូលថា: "សូមទ្រង់គង់នៅទីនេះចុះ" ។
ព្រះរាជាលុះទ្រង់គង់នៅទីនោះ ស្រាប់តែទតឃើញអារក្ស ខ្មោចព្រាយ
គ្រប់បែប ស្ទុះពាក់គួរឲ្យខ្លាច ចាំគ្រប់ទិស ។ អ្នកធុតង្គដែលនៅ
អង្គុយចំកណ្តាលហ្វូងបិសាចនោះក៏ញ៉ងធ្មឹងក្បាលខ្មោចពីរ ។ ព្រះមហា-
ក្សត្រទ្រង់សណ្តិតនៅពីមុខទស្សនីយភាព (spectacle) នេះគ្មានញ័ររំភើប
ខ្លាចអ្វីសោះ ប៉ានទ្រង់សួរទៅអ្នកធុតង្គអំពីវត្ថុបំណងដែលចង់បាន
ព្រះអង្គ ។ អ្នកធុតង្គនិយាយថា: "បពិត្រព្រះមហាក្សត្រ! បើ
ទ្រង់យាងមកយ៉ាងនេះហើយ សូមទ្រង់បំពេញព្រះពជកវណីយកិច្ចដូច
ខាងក្រោម: ចម្ងាយចំនួនពីរគីឡូម៉ែត្រអំពីទីនេះទៅខាងត្បូង មានប៉ាធា
មួយ ដែលមានខ្មោចមួយក្បាលនៅលើដើមឈើ សូមទ្រង់យកខ្មោច
នោះមកឲ្យទូលព្រះបង្គំ ដើម្បីទូលព្រះបង្គំធ្វើតាមលំដាប់" ។ ព្រះរាជា
ក៏ស្តេចទៅត្រង់ទីនោះ ។ អ្នកធុតង្គធ្វើព្រងើយ ហើយតាំងបួញ
មាត់សូត្រធម៌ ។

យប់នោះជាយប់ងងឹតគួរឲ្យខ្លាចណាស់ ។ ភ្លៀងធ្លាក់យ៉ាងខ្លាំង
ហាក់ដូចជាឈប់ភ្លៀងតែពីថ្ងៃនោះទៅ ឯខ្មោចនឹងព្រាយផ្តើមបណ្តាល
សូរសៃពួកគួរស្បើមខ្លាច ទោះបីអាទិទេពក្តី វីរបុរស (héros) យ៉ាងក្លាហានក្តី
កាលបើឮដូច្នោះហើយ ក៏មិនអាចនឹងចំយាន់នូវការភ័យញាប់ញ័រ

ឡើយ ។ ប៉ុន្តែព្រះពាជាទ្រង់យាងទៅមិនមានតក់ស្លុត ។ មានសត្វពស់
លូនមកជិតរុំដុំវិញព្រះបាទ ព្រះអង្គទ្រង់ដេញវាចេញ ដោយបានសូត្រ
គាថាមួយ ។ ព្រះមហាក្សត្រលុះឆ្ងាត់ព្រៃតាំងស្រលតាំងលំបាក
ស្រេចហើយ ក៏បានស្តេចទៅដល់ប៉ា"នានោះ ហើយទ្រង់ឃើញអាវ័ក្ស
ចាប់មនុស្សជាច្រើន យកមកវាយពាល់តែស្ងាប់ ។ ព្រះពាជាទ្រង់ទត
ឃើញព្រាយស៊ីប្រមាត់ពួកកូនក្មេង សត្វខ្លាយំ ជំរីពេង ។ លុះ
ព្រះពាជាទ្រង់ទតឃើញដើមឈើហើយ ទើបពិនិត្យដោយហ្មត់ចត់ទៅ
ឃើញថា: មែកនីមួយៗ ស្វឹកនីមួយៗ តាំងពីគល់ដល់ចុងមានក្តីងនេះ
យ៉ាងសន្ធោសន្ធៅ, គ្រប់ទិសទាំង ៤ លាន់ឮសូរស័ព្ទមិនឈប់ថា
សម្លាប់! សម្លាប់! ចាប់ផ់មក ចាប់ផ់មក! ប្រយ័ត្នកុំឲ្យវារត់រួច? ។
នៅពីមុខទស្សនីយភាពនេះ ព្រះមហាក្សត្រគ្មានញាប់ញ័រចិត្តទេ ប៉ុន្តែ
ទ្រង់ព្រះតម្រិះថា: "ប្រហែលជាអ្នកធុតង្គវៃស្រែកចាប់ព្រះអង្គទេដឹង?"
លុះទ្រង់យាងទៅជិត ទ្រង់ទតឃើញខ្លោចមួយដែលចងដោយខ្សែព្រួរព្យួរ
ក្បាលចុះមកដី ។

ព្រះមហាក្សត្រទ្រង់មានព្រះទ័យសោមនស្ស ដោយទ្រង់ឃើញថា
កំលាំងដែលព្រះអង្គទំស្តេចទៅនោះ បានសម្រេច ។ ទ្រង់យកដាវ
នឹងខ្សែលយាងយ៉ាងរហ័សទៅលើដើមឈើ រួចហូតដាវនោះកាត់ខ្សែព្រួរ
ឯរូបខ្លោចនោះក៏ធ្លាក់ចុះមកដល់ដីហើយទ្រហោយំ រួចទាំងធ្វើញញឹតៗ

ផង ។ ព្រះពាជាទ្រង់ទតឃើញដូច្នោះ ក៏មានព្រះទ័យសោមនស្ស ដោយទ្រង់ព្រះរាតក្តុះថា: មនុស្សនេះនៅរស់ទេ ។ ដល់ទ្រង់ចុះពីលើដើមឈើមកវិញទ្រង់សួរថា: "ឯងជាអ្នកណា ?" ។

ខ្មោចកាលបើឮដូច្នោះ ក៏តាំងសើចភ្លាកភ្លាយ ដែលជាហេតុនាំឲ្យព្រះមហាក្សត្រធ្លាល់ពន់ពេក លុះសើចហើយក៏ឡើងទៅលើដើមឈើឰ្យវិនដូចមុនវិញ ។ ព្រះករុណាបានស្តេចទៅតាមក្រោម ចាប់ដៃខ្មោចនោះនាំចុះមកដី ហើយមានព្រះពាជឪ្កាថា: "អាខ្មោច! ឆ្កាប់អញមកមើល តើឯងជាអ្វី?" ។ តែទ្រង់គ្មានបានទទួលចម្លើយពីខ្មោចនោះវិញទេ ។ ទ្រង់ព្រះចិន្តាថា: "ប្រហែលជាអ្នកលក់ប្រែង ដែលអាវ័ក្សនិយាយឆ្កាប់អញ ហើយដែលអ្នកធុតង្គបានយកមកទុកក្នុងប៉ាធានេះទេដឹង!" ។ លុះទ្រង់ព្រះចិន្តាឃើញដូច្នេះ ទើបទ្រង់រុះខ្មោចនោះក្នុងសំពត់ជរាឆ្កាប់មួយ ហើយទ្រង់លីយកទៅ ។ អាវ័ក្សសួរព្រះអង្គវិញថា: "ឯងជាអ្នកណា ? រួចឯងនាំអញទៅណា ?" ។ ព្រះពាជាទ្រង់តបវិញថា: "យើងជាស្តេចពិករ័ន (Bikran) យើងនាំអ្នកទៅកេអ្នកធុតង្គ" ។ អាវ័ក្សឆ្លើយវិញថា: "ទូលព្រះបង្គំទៅបាន ប៉ុន្តែទូលព្រះបង្គំសុំអនុញ្ញាត ១ ឱ គឺសូមកុំឲ្យទ្រង់មានព្រះពាជឪ្កាវ ក្នុងពេលកំពុងស្តេចទៅ, បើប្រសិនជាមានព្រះពាជឪ្កាវ ទូលព្រះបង្គំនឹងត្រឡប់ទៅដើមឈើរបស់ទូលព្រះបង្គំវិញ" ។

(មានត)

ដំណើរមកកាន់ប្រទេសកម្ពុជា

នៃមហាបណ្ឌិត គុណបាលបិយសេន មាឡាឡ៉ៈសេកេរៈ

ជាអធិបតីពុទ្ធិកសមាគមពិភពលោកនៅលង្កាទ្វីប

របស់ពុទ្ធសាសនបណ្ឌិត្យ

(តមក)

បន្ទាប់មកលោកមាឡាឡ៉ៈសេកេរៈ ថ្លែងសុន្ទរកថាតទៅថា

មួយគបវិញជាភាសាបាឡី, សេចក្តីនៃសុន្ទរកថានោះដូចខ្លះ ៖

អស់លោកអ្នកខាងឡាយ! ខ្ញុំសូមថ្លែងអំណរគុណដល់សមាគមមិត្តសាលាបាឡី ដែលបានផ្តួចគិតយសដល់ខ្លួនខ្ញុំដោយការទទួលយ៉ាងអ្នកអធិកនេះ ។ ខ្ញុំមានសេចក្តីត្រេកអរក្នុងចិត្តពន់ពេក ដោយការបានដឹងអំពាវនាវមកថា ការសិក្សាពុទ្ធសាសនានៅប្រទេសកម្ពុជា មានសាលារៀនយ៉ាងក្រាស់ក្រែលដែលនៅក្នុងការទុបត្ថម្ភនៃរាជការ ហើយមានព្រះសង្ឃចេះដឹងជ្រៅជ្រះជាច្រើន ខាងជាអ្នកច្រតិបត្តិយ៉ាងតឹងរឹងតាមព្រះវិន័យ; ប៉ុន្តែខ្ញុំមានអំណរជាទីបំផុតនោះ គ្រង់ដែលថាប្រទេសកម្ពុជាបំរុងនឹងបង្កើតពុទ្ធិកសមាគមមជ្ឈមណ្ឌលភូមិភាគ មានសហការជាប់នឹងពុទ្ធិកសមាគមពិភពលោក ដែលមានទីសំណាក់ការតាំងនៅលង្កាទ្វីបសព្វថ្ងៃនេះ ។ កិច្ចនេះហើយដែលអាចញ៉ាំងសាមគ្គីជមិត្យកើតមានរវាងប្រទេសកាន់ពុទ្ធសាសនាខាងឡាយ ហើយជាកំពាំងមួយយ៉ាងធំ ដែល

អាចនឹងទាំយើងឲ្យបង្កើតក្រុមបេសកកម្មខាងផ្សាយសាសនា ដូចជាពួក
សាសនាគ្រិស្តជាប់បំពេញមកនោះបាន ។

ចំណែកការប្រែស្រ័យទាក់ទងគ្នាក្នុងផ្លូវសាសនារវាងប្រទេសកម្ពុជា
នឹងលង្កាទ្វីបនេះ សឹងមានចែងច្បាស់នៅក្នុងប្រវត្តិសាស្ត្រថាមានជាយូរ
អង្វែងមកហើយ ។ ក្រោយដែលប្រទេសកម្ពុជាបានទទួលព្រះត្រៃបិដក
ជាភាសាបាលី ដែលជារបស់ផ្ទេបាទ រៀបយកអំពីសំពៅព្រះបាទអនុរុធ
មហារាជ (ព្រះបៅធ្វើនម៉ែ) ដែលចំឡងពីលង្កាទ្វីប ហើយសំពៅនោះ
មកកៀងនៅប្រទេសខ្មែរនេះ ។ ព្រះបាទសុរិយវ៉ន៌ទីពីរ ក៏បានបញ្ជូនព្រះ
សង្ឃខ្មែរ ៨ រូប; ក្នុងចំនួននេះ មានព្រះពជបុត្រជាទីប្រុសច្បាណ
របស់ព្រះអង្គ ១ អង្គផង ដែលមានព្រះនាមធាយាថា ញាណសិទ្ធិ ។
ព្រះសង្ឃទាំង ៨ រូបនេះ បានបួសថ្មែងជាថ្មីទៀតនៅលង្កាទ្វីប ព្រោះ
ពេលនោះប្រទេសកម្ពុជា មានសុទ្ធតែពួកមហាយាន ដែលចេះតែ
ភាសាសំស្ក្រឹត ។ ព្រះសង្ឃទាំង ៨ រូបនេះ បានទៅសិក្សាភាសាបាលី
នឹងវិជ្ជាជាផ្សេង។ ជាយូរឆ្នាំទៅមហាវិទ្យាល័យពុទ្ធសាសនា នៃវត្តមហា
វិហារកុដ៏អនុរាធបុរៈ ។ លុះសិក្សាបានចេះដឹងសព្វគ្រប់ហើយ លោក
ទាំងអស់គ្នាត្រឡប់មកផ្សាយសាសនានៅប្រទេសកម្ពុជាវិញ ជាពិសេសបាន
ជ័យដ៏ឧត្តុង្គឧត្តមលើពួកមហាយាន ។ វត្តមហាវិហារនេះហើយ ដែលកុក
ហ្វាហៀនដ៏ជាសមណទូតចិនបានទៅនៅសិក្សាអស់ពេលជាយូរ ។ រឿង

នេះ មិនមែនមានចែងតែក្នុងប្រទេសលង្កាទេ គឺមានសេចក្តីពិស្តារនៅក្នុងចារិកសព្យាណីនៃប្រទេសភូមាផង ។

ដើម្បីទំនើរើរេបៀបធាក់ទង្គាដោយការសិក្សានេះឡើងវិញ រដ្ឋាភិបាលលង្កាមានបំណងនឹងបង្កើត មហាវិទ្យាល័យពុទ្ធសាសនាមួយនៅលង្កាខ្លួន សំរាប់ទទួលសិស្សមកពីប្រទេសនានា ។ សាលានុះមានគោលបំណងយ៉ាងធំ សំរាប់អប់រំព្រះសង្ឃឲ្យធ្វើជាគណាចារ្យក្នុងការផ្សាយសាសនាទៅនានាប្រទេស ។ បើប្រសិនជាសាលានេះបានកើតឡើងដូចបំណងហើយ នោះមុខជាត្រូវទទួលឲ្យព្រះសង្ឃពីប្រទេសកម្ពុជាទៅសិក្សាផងជាពុំខាន ។

បងប្អូនរួមសាសនាទាំងឡាយ! យើងពួកពុទ្ធសាសនាគួរខ្មាសពួកសាសនាជាតិដទៃណាស់ ព្រោះគេហ៊ានស៊ូប្តូរជីវិត ក្នុងការបំពេញបេសកកម្មផ្សាយសាសនា គួយ៉ាងការផ្សាយសាសនាគ្រិស្តទៅអាហ្វ្រិក ដែលសុទ្ធតែជាជាតិកាចសាហាវ សឹងមានគណាចារ្យខ្លះបានទទួលគ្រោះ ត្រូវពួកនេះសម្លាប់ ។

ចំពោះពុទ្ធសាសនាយើងវិញ កាលពីដើមមានអ្នកកាន់តិចទៀតផ្សេងនេះ មានប្រទេសដល់ទៅ ២៨ បានកាប់អានោះ ក៏មកពីគណាចារ្យបុរាណ ដែលមានមហាវិទ្យាល័យនៅលង្កា (ឥណ្ឌា) ទើមហាវិទ្យាល័យមហាវិហារជាអ្នកបង្កើត ហើយទើក្រុមគណាចារ្យ

បច្ចុប្បន្នដែលមានប្រទេសលង្កាជាអ្នកខ្វះខ្វែងបំផុត ។ ការដែលពុទ្ធ-
សាសនាយើងក្រីក៏ទៅនេះ មិនមែនមកពីខ្វះអ្នកជឿទេ គឺខ្វះគណាចារ្យ
ដែលមានសមត្ថភាពនឹងខ្វះធនធាន ។ ដូច្នេះហើយបានជាយើងត្រូវតែ
ចងចាប់គ្នាយ៉ាងធំ ដើម្បីនឹងផ្សាយពុទ្ធសាសនារបស់យើងទៅឲ្យប្រទេស
អឺរុបនឹងប្រទេសដទៃទៀត ដែលគេផ្សាយសាសនារបស់គេមកឲ្យ
យើង ជាកិច្ចតបស្នងទៅគេវិញផង ។

ដើម្បីនឹងញ៉ាំងផែនការណ៍នេះឲ្យសម្រេចទៅបាន ខ្ញុំមានសេចក្តី
សង្ឃឹមយ៉ាងមាំ លើសេចក្តីខ្វល់ខ្វាយនៃសមាគមមិត្តសាលាចាលីនឹងកិច្ច
សិក្សានៃព្រះសង្ឃ ដែលខ្ញុំបានឃើញនៅសាលាចាលីជាន់ខ្ពស់នេះ ។
ប៉ុន្តែខ្ញុំសូមរំពឹកថា : ដើម្បីនឹងធ្វើជាអ្នកប្រកាសផ្សាយសាសនានោះ គេ
មិនមែនរៀនតែភាសាចាលី សំស្ក្រឹតនឹងព្រះត្រៃបិដកប៉ុណ្ណោះទេ គឺត្រូវ
រៀនភាសាណាដែលគេនិយមប្រើក្នុងលោក វិទ្យាសាស្ត្រផ្សេងៗនឹង
លទ្ធិសាសនាគេប្លែកទៀតទម្ងាប់ស្រុកទេសគេផង ព្រោះថាបើយើងមិន
ចេះសាសនាគេប្លែកទៀតទម្ងាប់ស្រុកគេទេ យើងក៏មិនអាចនឹងទៅប្រដៅ
គេបានឡើយ ។

ចំពោះបេសកកម្មបស់ខ្ញុំក្នុងពេលនេះ ខ្ញុំគ្មានចំណង់អ្វីក្រៅពីយក
ចិត្តទុកដាក់សាសនាទៅដូនប្រទេសដែលកាន់ពុទ្ធសាសនា ដើម្បីសុំឲ្យប្រកាស
ប្រើជាផ្លូវការ ហើយនឹងការក្រើនពុទ្ធបរិស័ទឲ្យសាមគ្គីគ្នា លែងប្រ-

កាន់និកាយ ដើម្បីនឹងផ្សាយសាសនា សុំឲ្យប្រទេសទាំងឡាយ តាំងពុទ្ធិកសមាគមមជ្ឈមណ្ឌលកូមិកាគឡើង ប្រយោជន៍នឹងជួយផ្គត់ផ្គង់គ្នា ។ សូមអស់លោកខេមរជាតិជ្រាបថា : ក្នុងថ្ងៃនេះជាឧកាសធ្វើពិធីបុណ្យវិសាខបូជា, ប្រទេសកាន់ពុទ្ធសាសនាទាំងឡាយ នឹងលើកទង់សាសនាថ្មីនុ៎ះ ក្នុងថ្ងៃនេះព្រមគ្នា សូម្បីប្រទេសជប៉ុនដែលកាលពីដើមមក ពុំដែលធ្វើវិសាខបូជាសោះ ក៏ក្នុងពេលនេះនឹងធ្វើពិធីនេះដែរ ។ ។

មហាបណ្ឌិតបានបញ្ចប់សុន្ទរកថានេះ ដោយថ្លែងអំណរជាថ្មីទៀតដល់លោកអ្នកស្តាប់ទាំងឡាយដែលបានដួនឧកាសយ៉ាងវែងឲ្យលោក ។

ក្នុងពេលដែលលោកអញ្ជើញមកទស្សនាការនេះ ពុទ្ធសាសនបណ្ឌិត្យ, សាលាចាលីជាន់ខ្ពស់ នឹងសមាគមមិត្តសាលាចាលី បានដួនសៀវភៅផ្សេងៗ ដល់លោកដើម្បីទុកជាទីរឭក ។

លោកម៉ាលាឡេ:សេកេរ:ប្លូលមើល ពិពិធភណ្ឌអាលប៊ែរសារ៉ូត៍ និង សាលារបស់

កាលពីថ្ងៃសៅរ៍ទី ១៩ ខែឧសភា នៅពេលម៉ោង ៨ នឹង ៣០ នាទី លោកម៉ាលាឡេ:សេកេរ: បានអញ្ជើញទៅមើលមន្ទីរពិពិធភណ្ឌ "អាល់ប៊ែរសារ៉ូត៍" និងសាលារបស់ ដោយមានឯកឧត្តមរដ្ឋមន្ត្រីក្រសួងសិក្សាធិការនឹងសិល្បការរង់ចាំទទួល ។ មហាបណ្ឌិតបានជំនិត្យ

ឬពណ៌វត្ថុវបស់យើងយ៉ាងជាប់ចិត្ត, រួចលោកអញ្ជើញទៅមើលសាលាវចនា ។ ក្នុងពេលនោះសិស្សគ្រប់ផ្នែកកំពុងតែធ្វើតង្ហិតង្ហង់មេរៀនរៀងខ្លួន ។ នៅទីនេះ មហាបណ្ឌិតមានប្រសាស្តរំឭកសន្និបាត ជាពាក្យមានន័យដូចជាឧត្តមគតិនៃមហត្ថ:គន្ធីថា: "យើងអ្នកកាន់ពុទ្ធសាសនាគួរតែតែនាំគ្នាធ្វើសំពត់ប្រើប្រាស់ដោយខ្លួនយើង មិនគួរយើងលក់សំឡីសូត្រដែលយើងធ្វើបាន ដោយលំបាកកាយយ៉ាងខ្លាំងនោះទៅប្រគេនយ៉ាងថោកៗដល់គេធ្វើជាសំពត់យកមកលក់ឲ្យយើងវិញយ៉ាងថ្លៃៗនេះទេ" ។

នៅពេលនោះ លោករដ្ឋមន្ត្រីបានជូនទុកជាទីរំឭកដល់ក្មៀវនេះនូវវត្ថុវចនាជាច្រើនមុខ គឺខ្សែក្រាក់ក្បាច់ផ្នែកក្រចៅ ១, ខ្សែ ២, ឡេវដៃអាវបញ្ចុះថ្នាំ ២, កន្ទាស់ក ១ សុទ្ធតែធ្វើអំពីប្រាក់ ដែលប្រទេសលង្កាប់អានថាជាវបស់មានដំឡៃលើសជាងមាស ហើយនឹងសំពត់ហូល ២ ដែលគ្បាញជាព្រះពុទ្ធរូបសំរាប់តាំង ។

លោកម៉ាល៉ាល៉:សេកេរៈទស្សនាវិទ្យាល័យស៊ីសុវត្ថិ

បន្ទាប់មក មហាបណ្ឌិតនេះបានអញ្ជើញទៅទស្សនាវិទ្យាល័យស៊ីសុវត្ថិ ។ វេលានោះ សិស្សទាំងឡាយនឹងគ្រូបាំង - ខ្មែរ ច្រើនរយនាក់កំពុងឈរព័ទ្ធជុំវិញ ។ លុះបានធ្វើពិធីលើកទង់ជាតិដោយមានច្រៀងបទនគរាជរួចហើយ មានសិស្សម្នាក់ចុងថ្នៃងសុន្ទរកថាមួយជាភាសាខ្មែរ រំឭកអំពីមេត្រីភាពខាងផ្លូវសាសនាដែលប្រទេសកម្ពុជា នឹងប្រទេសលង្កា

ឆ្ងាប់ធ្លើមកជាមួយគ្នាតាំងពីបុរាណកាល ហើយនឹងបញ្ជាក់ឲ្យឃើញអំពី
សេចក្តីគោរពចំពោះពុទ្ធសាសនារបស់ពួកសិស្ស ដោយមានការធ្វើកឋិន
នឹងវិសាខបូជាជាដើមតាមប្រពៃណី ។ សុន្ទរកថានេះបានបញ្ចប់ដោយ
ដួនសព្ទសាធុការពរ ដល់ភ្ញៀវនេះ ហើយលោកញ៉ុក-ថែមបានប្រែ
ជាភាសាចាល ។

លោកម៉ាល: សេកេរៈ បានថ្លែងសុន្ទរកថាឥតព្រាងមួយវិញ ជា
ភាសាចាល ។ សេចក្តីសង្ខេបនៃសុន្ទរកថានោះថា: សុំឲ្យគ្រូនឹងសិស្ស
ទាំងឡាយសើរើយកមេត្តីភាព ដែលប្រទេសទាំងពីរនេះធ្លាប់មាននឹងគ្នា
កាលពីដើមនោះមកឡើងវិញ ។ លោកបានបញ្ជាក់ថា: ការសិក្សាដែល
មានសេចក្តីគោរពយ៉ាងមាំ កងសេចក្តីស្នេហាជាតិនេះហើយ ដែលអាច
ជួនផលមកឲ្យប្រទេសជាតិខ្លួនបាន ។ ឯវត្ថុបំណងយ៉ាងមាំធំបំផុតក្នុង
បេសកកម្មរបស់ខ្ញុំ គឺការបបួលប្រទេសកាន់ពុទ្ធសាសនាទាំងឡាយ
ឲ្យរួបរួមគ្នាលើងប្រកាន់ពួកគណៈហីនយានឬមហាយាន ដើម្បីនឹងឲ្យ
ជាបក្ខពួកមួយដែលមានតេជានុភាពយ៉ាងធំបំផុតក្នុងអនាគត ។ ប្រទេស
កាន់ពុទ្ធសាសនាទាំងឡាយ ដែលបានធ្លាក់ចេញកងសេចក្តីថោកទាបជា
ច្រើនរយឆ្នាំមក ហើយដែលគួរឲ្យមានសេចក្តីខ្មាសជាទីបំផុតនេះ មក
តែអំពីការមិនចេះចងចាប់គ្នា ដូច្នេះយើងត្រូវតែឈរមុខទៅរកសាមគ្គី
ដែលមានខ្លឹមសារនោះ មិនត្រូវរួញរាឲ្យសោះ" ។

ក្នុងសន្និបាតនេះ គាលមហាបណ្ឌិតថ្លែងជាភាសាបារាំងចប់ហើយ តមកលោកថ្លែងជាភាសាអង់គ្លេសទៀត ដោយមានលោកក្ងេម៉ងបកប្រែជាភាសាបារាំង ។

លោកម៉ាល៉ាល៉ៈសេកេរៈទស្សនាអនុវិទ្យាល័យនារី

ក្នុងថ្ងៃដដែលនេះ លោកម៉ាល៉ាល៉ៈសេកេរៈ បានបន្តដំណើរទៅទស្សនាអនុវិទ្យាល័យនារីទៀត ដែលមានលោកស្រីបវរណោជាចាងហ្វាងសាលានេះនៅចាំទទួល ។ សិស្សនារីយើងចំនួន ១៩០ នាក់ បានស្វែកពាក់ឯកសណ្ឋានជាគ្រឿងសំគាល់សាលា ចាំទទួលលោក ។ លោកម៉ាល៉ាល៉ៈសេកេរៈបានសួរអំពីកម្មវិធីនៃការបង្រៀន, អំពីអត្ថពលកម្មនិងស៊ីវិឡៃអ្វីខ្លះដែលមាននៅក្នុងសាលានេះ ។ ដោយឃើញចំនួនស្រីខ្មែរដែលសិក្សានៅសាលាជាន់ខ្ពស់នេះតិចពេក, លោកក៏លាន់មាត់សួរលោកស្រីចាងហ្វាង ។ លោកស្រីបានតបថា ពួកស្រីខ្មែរទើបតែផ្តើមស្រឡាញ់ការសិក្សាទេ ហើយច្រើនតែចូលចិត្តឈប់រៀនក្នុងពេលដែលប្រឡងបានសញ្ញាបត្របឋមសិក្សាជាំងខ្មែរ ។ ត្រង់នេះ មហាបណ្ឌិតបានធ្វើតអួតថា នៅស្រុកលោក មានស្រីរៀននៅមហាវិទ្យាល័យដល់ទៅជាងពីរពាន់នាក់ ។

លោកម៉ាល៉ាល៉ៈសេកេរៈធ្វើសន្និសិទនៅព្រះវិមរកត

នៅម៉ោង ១៧ នៃថ្ងៃនោះ មហាបណ្ឌិតបានធ្វើសន្និសិទនៅមន្ទីរព្រះ

សទ្ធម្មនៃវត្តព្រះកែវមរកត ។ ក្នុងមហាសន្និបាតនេះមានព្រះសង្ឃ គណៈមហានិកាយ ធម្មយុត្តិ នឹងពួកគហស្ថប្រុសស្រីខ្មែរកម្ពុជចំនួនប្រហែលជាង ៦.០០០ នាក់ ។ ក្នុងព័ធីនេះ ឯកទត្តមសមញ្ញាណបានអញ្ជើញទៅជាអធិបតី ជាមួយនឹងសម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ សម្តេចព្រះធម្មលិខិតទត្តមប្រិក្សា ល្វី-ឯម នឹងព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត ចាងហ្វាងសាលាចាលីជាន់ខ្ពស់ ។

លុះដួចដុំហើយ មហាបណ្ឌិតបានថ្លែងសុន្ទរកថាជាភាសាចាលី ដោយមានព្រះគ្រូសំសត្តាប៉ុណ្ណ-សម្ភាជ ជាអ្នកបកប្រែ ដូចមានសេចក្តីដែលយើងសរសេរសម្រួលតទៅនេះ :-

បពិត្រលោកដ៏ចំរើនទាំងឡាយ !

ខ្ញុំមានចិត្តត្រេកអរណាស់ ដែលបានទទួលកិត្តិយសយ៉ាងធំខ្ពស់ក្នុងការសំដែងធម្មទេសនាជាទីក្រៃ ដែលមានព្រះតេជព្រះគុណគ្រប់ព្រះអង្គនឹងលោកអ្នកសប្បុរសទាំងឡាយ មកជួបជុំជាចំនួនច្រើនយ៉ាងនេះ ។ ខ្ញុំស្មានខុសថាសេចក្តីរុងរឿងនៃពុទ្ធសាសនានៅប្រទេសកម្ពុជា មុខជាមិនប្រសើរដល់ថ្នាក់នេះទេ ប៉ុន្តែដំណើរទស្សនាការរបស់ខ្ញុំនេះ បានបន្ទោបពស្តាងឲ្យឃើញជាក់ច្បាស់ថាគ្មានប្រទេសកាន់ពុទ្ធសាសនាណាមួយក្នុងលោក ថ្លៃថ្លូរដូចជាប្រទេសនេះឡើយ គឺប្រទេសកម្ពុជាមានពុទ្ធ

បដិមាមាសសុទ្ធយ៉ាងធំៗ ដែលខ្ញុំទើបនឹងឃើញអំបាញ់មិញនៅក្នុងព្រះ-
វិហារនៃអាគមនេះ ហើយដែលខ្ញុំមិនធ្លាប់ជួបប្រទះនៅក្នុងប្រទេសណា
សោះ ។ ខ្ញុំបានឃើញកិច្ចការយ៉ាងសំខាន់ៗ ជាច្រើនទៀតជាច្រើន ដូច
ជាកិច្ចការនៃក្រុមដំនុំប្រែព្រះត្រៃបិដក ដែលប្រទេសណាមួយមិនទាន់
មានសោះ ហើយនឹងកិច្ចការរៀនសូត្រខាងផ្លូវសាសនា ដែលមាន
សាលាថ្នាលជាន់ខ្ពស់, សាលាថ្នាលរងនឹងសាលាធម្មនិន្ន័យ នៅក្នុងកិច្ច
ចាត់ការយ៉ាងបុនប្រសប់នៃរដ្ឋាភិបាល ។ អំពីសេចក្តីពាក់ព័ន្ធវិញ ខ្ញុំ
គ្មានឃើញប្រទេសណាមួយដែលខ្ញុំធ្លាប់ដំណើរឆ្លងកាត់មកលើកនេះ ជួន
កិត្តិយសដល់ខ្ញុំដែលជាធម្មទូតនៃសមាគមពីកពលោក ដែលហៅ "លោក
ពុទ្ធសម្មេលនៈ" ដូចជាប្រទេសកម្ពុជានេះទេ គឺនៅទីកន្លែងណាក៏ដោយ
ប្រជាជនតែងមានមុខញញឹម ហើយទទួលយ៉ាងអ៊ិកអធិក ។

ចំណែកសេចក្តីប្រតិបត្តិនៃព្រះសង្ឃក៏ឃើញថាមានរបៀបរៀបរយ
ណាស់ដែរ ព្រោះនៅតាមផ្លូវ ខ្ញុំមិនសូវឃើញព្រះសង្ឃនិមន្តរហែត
រហូតទេ ហើយការនាន់ការហូរដោយតឿមចិន ក៏ខ្ញុំមិនជួបប្រទះ ដូចជា
នៅប្រទេសខ្លះ ដែលខ្ញុំបានដើរកាត់មកនោះឡើយ ។ ដូច្នេះ ពុទ្ធសាស-
នានៅប្រទេសកម្ពុជាចាត់ថាមាន សេចក្តីរុងរឿងជាបំផុត ដោយមាន
ព្រះមហាក្សត្រដ៏ជាអគ្គសាសនូបត្ថម្ភ ។

លោកអ្នកសប្បុរសទាំងឡាយ ប្រហែលជានឹកឆ្ងល់នឹងបេសកកម្ម
របស់ខ្ញុំនេះខ្លះដែរមើន! ប៉ុន្តែបើលោក-អ្នកបានជ្រាបអំពីដំណើរសន្ទិសិទ

ពុទ្ធសាសនានៅលង្កាទ្វីប ដែលសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក ប្រទានទូលកត្តិយសជាប្រធាននោះ មុខជានឹងប្រាត់ធ្លាក់ពុំខាន ។ ខ្ញុំគ្មានប្រាថ្នាអ្វីក្រៅអំពីសុំក្រើនប្រទេសពុទ្ធសាសនាទាំងឡាយ ឲ្យរួបរួមគ្នាកសាងការបង្កើនកម្លាំងសមាគមពិភពលោក ដែលសព្វថ្ងៃនេះមានជាស្រេចទៅហើយនៅប្រទេសលង្កានោះទេ គឺសុំឲ្យពួកពុទ្ធសាសនិកជនគ្រប់និកាយ ទោះជាមហាយានក្តី ហីនយានក្តី រួបរួមកម្លាំងគ្នាបង្កើតជាពុទ្ធិកសមាគមមជ្ឈមណ្ឌលកូម៉ាគឡើង ដែលហៅថា "សាខាសាម័គ្គិ" ដែលត្រូវមានកិច្ចខាត់ខែងនឹងពុទ្ធិកសមាគមពិភពលោកនោះ ។ ការធ្វើដូច្នោះ គឺដើម្បីនឹងបំពេញបេសកកម្មក្នុងការផ្សាយពុទ្ធសាសនា ទៅនានាប្រទេស ។ ប៉ុន្តែដែលនឹងធ្វើដូច្នេះបាន លុះណាតែយើងបង្កើតការសិក្សា សម្រាប់ព្រះសង្ឃឲ្យបានមាំមួនសិន ដែលត្រូវតែបង្កើតមហាវិទ្យាល័យពុទ្ធសាសនាមួយ នៅប្រទេសលង្កាសំរាប់អប់រំគណាចារ្យ ។ រដ្ឋបាលលង្កាបានព្រមឲ្យបង្កើតសាលានេះ, សមាគមពិភពលោកនឹងទូលទំនុកបំរុងយ៉ាងមុតមាំនូវសាលានេះ ព្រមទាំងទូលសិស្សពីប្រទេសនានាមានប្រទេសកម្ពុជាជាដើមឲ្យទៅរៀនផង ។

លោកអ្នកសប្បុរសទាំងឡាយ! ក្នុងសម័យបុរាណ ប្រទេសកម្ពុជា ធ្លាប់មានសម្ពន្ធកិច្ចខាងផ្លូវសាសនា យ៉ាងជិតស្និទ្ធនឹងប្រទេសលង្កា ។ មានព្រះសង្ឃខ្មែរច្រើនរូប បានទៅរៀនទៅមហាវិទ្យាល័យ

មហាវិហារក្នុងអនុរាធបុរី ដើម្បីចំឡងយកលទ្ធិហីនយាន ។ ប៉ុន្តែដល់ក្រោយមក កិច្ចការទាំងនោះក៏បានបាត់បង់អស់ទៅវិញ ដោយសារប្រទេសយើងតាំងពីរជ្រាក់ទៅក្នុងអាណាព្យាបាលប្រទេសដទៃ ។ សូម្បីដូច្នោះ ការប្រស្រ័យគ្នាខាងសមណទូត ក៏នៅតែមានទៅវិញទៅមកជាបដល់មុនសង្គ្រាមលោកលើកទីពីរនេះ កស្តុតាងដូចមានព្រះសង្ឃលង្កានាំយកព្រះពោធិព្រឹក្សនិងព្រះសារីរិកធាតុ មកប្រតិស្ឋាននៅប្រទេសកម្ពុជាជាដើម ។

សូមអស់លោកអ្នកជាប: នៅប្រទេសលង្កា មានគម្ពីរស្លឹករឹតជាអក្សរខ្មែរ ដែលគេដំកល់ទុកយ៉ាងប្រពៃ ។ អ្នកលង្កាដែលចេះភាសាបាលី ច្រើនតែនិយមរៀនអក្សរខ្មែរដែរ គ្រាន់តែងមើលគម្ពីរទាំងនោះ ។ ចំណែកខ្លួនខ្ញុំក៏អាចមើលអក្សរខ្មែរជាភាសាបាលីបានដែរ ។ ដូច្នេះឃើញថា មេត្រីភាពនៃប្រទេសយើងតាំងពីរ ដែលបាត់បង់ទៅជាយូរហើយនោះ ហាក់ដូចជាមានជីវភាពជាបដល់សព្វថ្ងៃនេះ ។

អស់លោកទាំងឡាយ ! ខ្ញុំមានសេចក្តីត្រេកអរណាស់ ដែលបានឃើញមេត្រីភាពខាងសាសនានេះ មានរូបរាងឡើងវិញ ក្នុងពេលដែលខ្ញុំចូលក្រាបថ្វាយបង្គំព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដើម្បីថ្វាយទង់សាសនា ហើយបានទទួលព្រះបដិសណ្ឋារយ៉ាងខ្ពស់បំផុត ។ ទង់សាសនានេះ គឺមហាសន្និបាតពុទ្ធសាសនា ដែលមានប្រទេស

កម្ពុជាជាសមាជិកដែរនោះ បានសម្រេចយល់ព្រម ហើយប្រទេសទាំងឡាយដែលកាន់ពុទ្ធសាសនាចំនួន ๖๔ ប្រទេស នឹងលើកទង់នេះប្រើព្រមគ្នាក្នុងថ្ងៃវិសាខបូជានេះផង ។

ខ្ញុំសូមរំឭកអស់លោក - អ្នកជាពុទ្ធបរិស័ទ្យទាំងឡាយ, សូមអស់លោកយកចិត្តទុកដាក់ក្នុងការផ្សាយសាសនាទៅនានាប្រទេស ព្រោះព្រះធម៌វិន័យរបស់ព្រះពុទ្ធម្ចាស់ ជារបស់កណ្តាល មិនមែនប្រដៅចំពោះតែប្រទេសណាមួយ ឬចំពោះតែបុគ្គលណាមួយទេ ។ មួយទៀតព្រះធម៌នោះជារបស់មិនចេះស្អាប់ មិនចេះហួសសម័យ ហើយជាទីមនោរម្យនៃសត្វទាំងពួង ។

សូមអស់លោកទាំងឡាយ បណ្តុះសាមគ្គីធម៌ លះបង់មាន: កុំប្រកាន់ពួក កុំប្រកាន់និកាយ ព្រោះយើងជាកូននៃព្រះពុទ្ធតែមួយព្រះអង្គ ដែលយើងត្រូវជាបងប្អូនបង្កើតនឹងគ្នាខាងផ្លូវចិត្ត ក្នុងការប្រតិបត្តិព្រះធម៌ ដែលចេញមកពីព្រះឧស្សរបស់ព្រះពុទ្ធតែមួយអង្គដែរ ។

អស់លោកទាំងឡាយ ! កាលសម្តេចព្រះមហាសុមជាធិបតី និមន្តទៅលង្កាទ្វីបនោះ ប្រជាជនលង្កាមានសេចក្តីសរសើរនឹងសេចក្តីដែលថ្លាពាក់អានគ្រប់គ្នា ។

(មានត)

ភ្នំពេញសុទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែកញ្ញា លេខ ៩

ព. ស. ២៤៩៤ — គ. ស. ១៩៥១



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
ពុទ្ធសាសនានឹងគ្រឹស្តសាសនា (សន្និសិទ លោកវេដ្ឋបណ្ឌិតមីតូត៍) (តមក)...	លោកវ៉ាយ-ប៊ុក	៦៤៣
ពន្ធីអាស៊ីទ្វីប (តមក).....	លោកវ៉ាយ-ប៊ុក	៦៤៧
វិនយកថា.....	ព្រះជាឧត្តរអរិយកស្សបតុង—ឈួន	៦៥៣

ផ្នែកអក្សរសាស្ត្រ		
ការបណ្តុះនិស្ស័យ (តមក).....	ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម	៦៥៩
អ័ឡេណា-សិមប៉ាណា (តចប់).....	លោកផេង-ជ្រើរ.....	៦៦០
រឿងសាមកុក (តមក).....	ឧកញ៉ា ទូ-កន.....	៦៦៨
ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក)..	ឧកញ៉ា ឈឹម-ក្រសេម	៦៩៣
រឿងអារក្សថ្លែងរឿងម្តៃប្រាំ (តមក)....	លោកសាង-សាភ័ត	៧០០

កំណត់ទឹងប្រវត្តិការណ៍		
ដំណើរមកកាន់ប្រទេសកម្ពុជានៃមហាបណ្ឌិត គុណបាលបិយសេន ម៉ាល៉ាឡ៉ះសេកេរៈ (តមក) ពុទ្ធសាសនបណ្ឌិត្យ.....		៧១០

មួយឆ្នាំមាន ១២ សៀវភៅ — ជំនៀតដារ ១៤៥.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE — Pages

Bouddhisme et Christianisme (Conférence du Docteur A. Migot) (suite)	M. RAY-BUC	643
La Lumière de l'Asie (suite)	M. RAY-BUC	647
Vinayakatha	Vén. KONG-CHHUON	653

PARTIE LITTERAIRE

Education morale (suite)	Vén. PENG-PAM	659
Histoire d'Hélèna-Simiana (suite)	M. PHENG-CHRIEU	670
Histoire de SAMKOK (suite)	Oknha NOU-KAN	678
Histoire du Royaume du Cambodge (suite)	Oknha CHHIM-KRASEM	693
Les vingt-cinq récits du mauvais génie (suite)	M. SANG-SAVATH	700

NOTES ET CHRONIQUES

Voyage au Cambodge du Dr. G.P. Malalasekera, Président du Centre mondial des Bouddhistes de Ceylan (suite)	Institut Bouddhique	710

Prix d'abonnement annuel comprenant 12 numéros: 145$00

ពុទ្ធសាសនា នឹង ក្រិស្តសាសនា

សន្ទិសទលោកផ្ញើជូបណ្ឌិត មីគ្លូត៍

លោក ភ័យ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ កុំពេញ

ប្រែពីទស្សនាវដ្តី « ហ្វ្រង់អាស៊ី » ខែមិថុនា ឆ្នាំ ១៩៥០

(ត្រឡប)

សង្គ្រាមខាងសាសនាគឺជាបេសកកាម ដែលផ្សាយចេញពីមនោ-សញ្ចេតនាដែលជ្រួតជ្រាបទៅក្នុងស៊ុីវិល្យាខាងបស្ចិមប្រទេស ដែលកើតឡើងដោយគ្មានការសន្តោសគ្នាទៅវិញទៅមក ។ គតិពួកបច្ចុប្បន្នជាតិមានន័យបែបនេះ គឺថាបើអនុម័តនូវមតិនយោបាយ ឬសាសនាណាមួយ ពួកនេះទុកមតិដែលខ្លួនយល់ថាជាធម៌សច្ចៈយ៉ាងខ្ពស់ ចំណែកមតិឯទៀតមានសភាពទុស មានន័យផ្សេងទាំងអស់ ។ វត្តុដែលលំបាកជាងគេ គឺពួកនេះយល់ថា ការដែលកំហែងបង្ខំដោយប្រើវិធាណញ្ញាណឲ្យអ្នកឯទៀតយល់ដូចខ្លួន ជាការប្រសើរ, ហើយបើការប្រើបែបនេះមិនសម្រេចទៅតាមចំណង់ ត្រូវការប្រើពលភាពតទៅទៀត ។ កិច្ចដែលត្រូវការខាងមិនបាន ដោយប្រាថ្នាឲ្យអ្នកដទៃបានសេចក្តីសុខ ដោយអ្នកដទៃនោះមិនព្រមយល់តាម ឬការបង្ខំឲ្យអ្នកដទៃទទួលប្រតិបត្តិតាមយោបល់របស់ខ្លួនចំពោះស៊ុីវិល្យា (អារ្យធម៌) ចំពោះជីវភាពកងសង្គម, សាសនានេះជាមូលដ្ឋានទាំងឲ្យកើតនូវសង្គ្រាមស៊ុីវិលនឹងសង្គ្រាមសាសនា

ក្នុងលោក ឬសង្គ្រាមរវាងប្រជាជាតិ ជាបុព្វហេតុនៃគតិអាណានិគមនិយម បណ្តាលឲ្យកើតសង្គ្រាមសេដ្ឋកិច្ចនឹងបេសកកម្ម ។

ចំណែកខាងបូព៌ាប្រទេស មិនដែលស្គាល់នូវរឿងរ៉ាវដ៏លាមកបែបនេះទេ ។ ប្រជាជននៃទ្វីបអាស៊ីមានស៊ីវិឡៃដោយឡែកពីគ្នា មានប្រពៃណីទំនៀមទម្លាប់សាសនាផ្សេងៗគ្នាដែលពួកនេះបានប្រកាន់ខ្ជាប់, តែមិនបានអួតអាងថាសភាពដែលពណ៌នាខាងលើនេះ ជាសច្ចធម៌ប្រកបដោយឯកភាពដូច្នេះឡើយ ។ ពួកនេះតែងយល់ថា គង់មានអ្នកដទៃទៀតមានចិត្តគតិផ្សេងពីខ្លួន ហើយគង់មានយោបល់ប្រកបទៅតាមវិចារណញ្ញាណមិនលែងឡើយ ។ ពួកនេះ តែងមានគំនិតផ្សេងពីគំនិតអ្នកដែលមិនមានការពិចារណាផ្ទុយគ្នា ដូចការពិចារណាទៅតាមការណាការណ៍វិទ្យា (Logique) នៃបណ្ឌិតអារិស្តូត តែវិទ្យានេះមិនបានធ្វើឲ្យពួកទាំងនោះមានអាកប្បកិរិយាមិនស្របគ្នា ដែលជាបុព្វហេតុនាំឲ្យកើតនូវសង្គ្រាមនឹងសេចក្តីស្អប់គ្នាទៅមកទេ ។ ពួកទាំងនេះ មិនមានអំនួតដើម្បីនឹងកំហែងបង្ខំឲ្យសាកលលោកធ្វើតាមគំនិតខ្លួនឡើយ, ហើយយល់ថា គំនិតបង្ខំប្រើអំណាចហួសប្រមាណនៃពួកបស្ចិមជាតិ ចំពោះរឿងនេះទុកដូចជាអាសន្នីយកិច្ចដែលមកពីការអប់រំអាក្រក់ ។

កាលខ្ញុំអាស្រ័យនៅកោះសីឡង់ ខ្ញុំមានសេចក្តីរឿងឆ្ងល់ពន់ពេក ដោយបានឃើញនៅបន្ទប់កុដិនៃចៅអធិការវត្តដែលខ្ញុំអាស្រ័យ មានរូប

ព្រះគ្រិស្តស្ថិតនៅដិតព្រះពុទ្ធរូប ។ លោកចៅអធិការធ្លាប់ចំពោះអាកប្បកិរិយាខ្ញុំដែលធ្លាប់អំពីការប្រព្រឹត្តបែបនេះ, ហើយលោកបានពោលសរសើរចំពោះព្រះគ្រិស្តនឹងការសិក្សានៃព្រះគ្រិស្ត ។ តាំងពីនោះមក ខ្ញុំបានឃើញជាញឹកញាយថាពួកពុទ្ធមាមកជន មិនប្រកាន់ច័ក្ខុពួកនិកាយឡើយ ។ ពួកនេះតែងអប់រំសន្ដានកុំឲ្យរៀបរៃហើយសរសើរដោយស្មោះស្ម័គ្រនូវសាសនាដទៃ, ពិនិត្យឲ្យយល់ជាក់ច្បាស់នូវសាសនានោះដោយសមានចិត្ត ។ ប្រជាជ្រាលជ្រៅដ៏ធំទូលាយនេះ ច្រើនចៀសវាងពីការប្រើបញ្ចុះបញ្ចូលអ្នកឯទៀត ឲ្យមកកាន់សាសនារបស់ខ្លួន; បើមានអ្នកណាពេញចិត្តខាងសាសនាដែលពួកនេះកាន់, ពួកនេះតែងមានចិត្តសន្ដោសព្រមបង្ហាត់បង្ហាញ ឲ្យពួកនោះបានចេះដឹងនូវវិជ្ជាខាងព្រះពុទ្ធ-សាសនា តែមិនមានបំណងនឹងបញ្ចុះបញ្ចូល ឲ្យមកកាន់សាសនាខ្លួនឡើយ ។ ពួកពុទ្ធមាមកជនតែងមានចិត្តគោរពកោតខ្លាច ចំពោះចិន្តាអ្នកដទៃហើយមិនមានគំនិតយល់ថា សាសនាដែលខ្លួនកាន់ជាសាសនាវិសេសប្រកបដោយសច្ចធម៌ តែមួយឯកឯង, ពួកនេះគិតថាសាសនាទាំងអស់តែងខ្ចប់នូវធម៌ពិតមែនដូចគ្នាទាំងអស់ តែក្នុងសាសនានីមួយៗតែងយកសច្ចធម៌នោះទៅប្រតិស្ឋានជារូបភាព ប្រកបទៅតាមចរិតជាតិ, ប្រពៃណីគួរជាទីគោរព ។ តើមានប្រយោជន៍អ្វីតែងការប្រែប្រួលសាសនានោះ ព្រោះសាសនាទាំងអស់មានវត្ថុបំណងដូចគ្នាទាំងអស់

សាសនាមានអត្ថរសតែមួយ តែផ្លូវដែលទៅកាន់ទីនោះមានសភាព
ខុសគ្នាប៉ុណ្ណោះ?

គេអាចឆ្លើយធ្លល់ដោយឃើញថា ពួកគ្រិស្តសាសនិកជននឹងពុទ្ធ-
មាមកជនប្រតិបត្តិតាមគោលការណ៍នៃសីលធម៌ដូចគ្នាសោះ តែបែរទៅ
ជាមានអាកប្បកិរិយាខុសគ្នាដោយចំណុចសំខាន់នៃសីលធម៌ គឺអហឹស-
ភាព (កិរិយាមិនបៀតបៀនអ្នកដទៃ) នឹងគតិលទ្ធកម្មដោយអាវុធ esprit de
conquête គោរពនៃចិត្តាអ្នកដទៃដែលប្រព្រឹត្តទៅនាំឲ្យកើតផលដ៏លាមក
គឺសង្គ្រាម ។ ខ្ញុំយល់ថាគំនិតខុសគ្នានេះមានហេតុដ៏សំខាន់គឺចំណុច
មួយដ៏ធំខាងលទ្ធិពុទ្ធសាសនា ដែលខ្ញុំមានបំណងដំរាបលោក-អ្នកចាំង
អស់គ្នាក្នុងពេលនេះ គឺលទ្ធិអនត្តា (មិនមែនរបស់ខ្លួន non-égo) ។

ព្រះពុទ្ធសាសនាបន្ទូលថា វត្ថុទាំងឡាយ, សត្វលោកទាំងអស់
ដែលនៅជុំវិញយើង គឺមិនមែនជាជីវសត្វស្ថិរវន្តប្រកបដោយនិច្ចតាភាពទេ
តែមានសមាសភាពជាសំណុំធាតុ មានធាតុប្រមូលប្រសំយោគគ្នា
ចេញចូលជានិរន្តរភាព ។ (ម

សូមរាំងខ្លួនដោយសុភាសិតនេះ

ហាត់ឆ្លើយពេក កុំដេកប្លួស
ជំណេក កុំនិយាយនឹងស្រី

ពន្លឺអាស៊ីទ្វីប

វគ្គទី ៣

La Lumière de l'Asie

លោកស៊ីរ - អេឌវ៉ាំងអារណ្ឌលត៍ តែង

លោក ប៉ាយ - ប៊ុក ក្រមការប្រែរៀបរៀង

(តទៅ)

ក្នុងពេលនោះ ព្រះនាងយសោធរាទ្រង់ព្រះសណ្តាប់នូវពាក្យខាងលើនេះ ទ្រង់មានព្រះលោហិតស្រោចស្រប់ព្រះភ័ក្ត្រ ដោយព្រះទ័យសោមនស្សពន់ពេក ប្រៀបដូចទឹកស្ទឹងគង្គាហូរខ្លាំងនៅក្នុងគុហាភ្នំ, ពេលទឹកកកលាយជាខ្លាំង, ព្រះនាងទ្រង់តើនឡើងបានទះព្រះហស្តរណ្តំគ្នាហើយទ្រង់សប្បាយព្រះទ័យពន់ពេក ទាល់តែហូរជលនេត្រ ។ ព្រះនាងទ្រង់មានព្រះបន្ទូលទៅកាន់ស្រីព្រះស្នំថា "ត្រូវនាងចាត់ឲ្យហៅពួកពាណិជមកទីនេះជាប្រញាប់ ត្រង់ម្ខាងកំឡុង (ពុរដាហ៍)[1] ព្រោះត្រចៀកខ្ញុំចង់ក្រែបផឹកនូវដំណឹងដែលពីរោះពិសា ប្រៀបដូចបុគ្គលមានបំពង់កស្ងួតចង់ផឹកទឹកដូច្នោះ, ចូរនាងប្រាប់ពួកពាណិជទាំងនោះឲ្យចូលមកដោយរួសរាន់នៅទីនេះ ហើយប្រាប់ថា បើរឿងដែលខ្លួននិទាននោះពិតដូចនាងឯងពណ៌នា ប្រាប់ខ្ញុំៗ នឹងឲ្យអ្នកទាំងនោះនូវមាសនឹងត្បូងផ្សេងៗ

---

១ ទំនៀមនៅប្រទេសឥណ្ឌៀខាងដើង ពួកស្ត្រីដែលមានវណ្ណៈខ្ពស់មិនត្រូវបង្ហាញរូបឲ្យជនបរជាតិឃើញទេ បើត្រូវការបរទាំងនឹងពួកទាំងនោះត្រូវឲ្យជនបរទេសឈរឬអង្គុយនៅម្ខាងរនាំងឬភាំងនន ។

ដែលព្រះមហាក្សត្រិយ៍គ្រប់អង្គពេញព្រះរាជហឫទ័យ ចូរនាងទាំងអស់គ្នាកុំភ្លេចមកជាមួយនឹងពួកពាណិជផង ខ្ញុំនឹងឲ្យទេយ្យវត្ថុដល់នាងក្នុងពេលនោះ ដែលជាទេយ្យវត្ថុសំដែងសេចក្តីអនុគ្រោះរបស់ខ្ញុំ ចំពោះនាងទាំងអស់គ្នា" ។

ពួកពាណិជក៏ទៅកាន់ព្រះរាជដំណាក់របស់ព្រះនាង ដោយជំហានរង្វើលៗ តាមវីថីក្នុងព្រះបរមរាជវាំង បានជួបប្រទះនឹងពួកស្រីស្នំជាច្រើននាក់ដែលឈរមើលមកដោយស្ងៀមស្ងាត់ ។ ពួកពាណិជបានលាន់មាត់សរសើរព្រះបរមរាជវាំងដែលមានច្រាសាទសន្ធោសន្ធៅអស្ចារ្យ ។ លុះពួកពាណិជទៅដល់គ្រោយនាំងនោះ បានឮសូរសៀងស្ត្រីមានសភាពទន់ផ្អែមល្ហែម, មិនសូវច្បាស់, ញ័រតែពីរោះពន់ពេកថា: "នុអ្នកដ៏ចំរើនទាំងឡាយ! អ្នកទាំងអស់គ្នា បានអញ្ជើញមកពីស្រុកឆ្ងាយ, ឮថាអ្នកបានឃើញព្រះរាជស្វាមីខ្ញុំ ហើយបានគ្រាបថ្វាយបង្គំ ឮថាព្រះអង្គទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ទ្រង់ជាសាស្តាចារ្យនៃទេវតានឹងមនុស្សទាំងឡាយ, ជាសន្តបុគ្គល ជានិយ្យានិកបុរសដែលជួយស្រោចស្រង់មនុស្សពិភពលោកឲ្យផុតចាកទុក្ខលំបាក ហើយព្រះអង្គទ្រង់គង់នៅទីនោះ, ចូរអ្នកថ្លាប់ខ្ញុំ បើពិតជាអ្នកទាំងអស់បានជួបនឹងព្រះអង្គមែន អ្នកឯងជាទីពឹងអាននៃខ្ញុំ ខ្ញុំគួរទទួលអ្នកទាំងអស់ដោយសេចក្តីពាក់ព័ន្ធផង ដោយចិត្តស្មោះស្ម័គ្រផង" ។

ត្របុស្ស:ទូលព្រះនាងថា "សូមក្រាបបង្គំព្រះនាង, ទូលព្រះបង្គំទាំង
អស់បានឃើញព្រះបរមគ្រូជាទីគោរពមែន ! ទូលបង្គំទាំងអស់គ្នាបាន
ថ្វាយបង្គំព្រះអង្គ ព្រោះថាព្រះអង្គដែលពីដើមជាព្រះអង្គម្ចាស់ ឥឡូវទ្រង់
បានកិត្តិនាមខ្ពង់ខ្ពស់ជាងព្រះមហាក្សត្រិយ៍ទៅទៀត ។ ព្រះអង្គទ្រង់បាន
សម្រេចនូវសម្មាសម្ពោធិញ្ញាណ នៅក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរខាង
មាត់ស្ទឹងផង្គុ ហើយទ្រង់អាចស្រោចស្រង់សត្វលោកដោយព្រះអង្គឯង
ទ្រង់ជាមហាមិត្តចំពោះសត្វនិករ ហើយទ្រង់ជាសាស្តាចារ្យនៃមនុស្ស
ទាំងអស់ក្នុងលោក ព្រះអង្គទ្រង់ជាមហាបុរស ទ្រង់បានធ្វើទុក្ករកិរិយា
ដោយលំបាកពន់ពេក ទ្រង់បានទតយល់ពន្លឺដោយព្រះប្រាជ្ញាញាណ
ទ្រង់បានព្រះពុទ្ធទាន្តទុកឲ្យសត្វប្រតិបត្តិតាម ។ សូមព្រះនាងទ្រង់
ជ្រាបថា ព្រះពុទ្ធស្វាមីព្រះនាងទ្រង់ប្រកបដោយសុខភាព ដូចបុគ្គលដ៏
ប្រសើរស្ថិតនៅពីលើទុក្ខទាំងពួង ព្រះអង្គជាព្រះអាទិទេពអាចធ្វើឲ្យសាប
សូន្យនូវទុក្ខនៃមនុស្សលោក, ព្រះអង្គប្រកបដោយធម្មណ្ណវង្សីផ្សាយចេញ
ពីអរិយសច្ច:ដែលទ្រង់បានជ្រាបច្បាស់, ទ្រង់មានឆវីវណ្ណភ្លឺចាំងចែងដូច
មាស ។ បើព្រះអង្គទ្រង់គ្រាច់ពីទីក្រុងមួយទៅទីក្រុងមួយ ទ្រង់បាន
ទេសនាពន្យល់សព្វសត្វអំពីមធ្យោបាយផ្សេង។ ដឹកនាំសត្វទៅកាន់សន្តិ-
សុខ, ចិត្តរបស់មនុស្សទាំងអស់គ្រាច់ទៅតាមក្រោយព្រះអង្គ ដូចជាស្លឹក
ឈើប្រមូលទៅតាមអំណាចព្រះពាយុបោកបក់ ឬដូចជាបសុសត្វដើរតាម

មេហ្វូងដែលស្គាល់រាល់ស្មៅ ។ ទូលព្រះបង្គំទាំងអស់គ្នាបានស្តាប់ដោយ
គោរពនូវព្រះធម្មទេសនាព្រះអង្គពីរោះពីសាអស្ចារ្យ ឯគយាកស្សបទ្យានជាវនិតក:
(Tchîranika), ព្រះអង្គទ្រង់យាងមកកាន់ទីនេះមុនរដូវក្តៅជាដំបូង" ។

តបុស្ស:ក្រាបទូលព្រះនាងយសោធរាបួចហើយ, ព្រះនាងទ្រង់
មានព្រះទ័យសោមនស្សជាខ្លាំង ហើយទ្រង់មិនអាចតបឆ្លើយទៅពាណិជវិញបួច: "សូមអ្នកនៅសុខជានិរន្តរ៍តាលក្នុងទីនេះចុះ, ឧម្មក! អ្នក
ដែលបានឲ្យដំណឹងពីរោះដល់ខ្ញុំៗ អរណាស់, ចុះអ្នកបានដឹងនូវទុក្ករកិច្ច
របស់ព្រះអង្គយ៉ាងណាខ្លះ? ។"

រួចពីនោះមក, កល្លក:បានក្រាបទូលព្រះនាងតាមដែលខ្លួនបានដឹង
ពីពួកដែលនៅជ្រោះភ្នំ. គឺទូលអំពីព្រះអង្គទ្រង់តស៊ូទឹកចិត្តមារព្រមទាំងសេនាមារក្នុងវេលាយប់ដែលអាកាសធាតុសពោញមេឃា, ផែនដី
ញាប់ញ័រជាខ្លាំង ហើយរលកទឹកក្នុងស្ទឹងគង្គាបោកបក់វាយលុសម្បើម
ដោយសេចក្តីក្រោធនៃមារធំពេកនោះ ។ កល្លក:នោះក្រាបទូលព្រះនាង
តទៅទៀតអំពីព្រះច្បាប់ញាណ ដែលប្រៀបដូចជាបុព្វណ្ហសម័យដ៏
ប្រកបដោយរស្មីកំពូលចែងអស្ចារ្យ ចេញពីម្ខាងមេឃធ្វើឲ្យកើតសេចក្តី
សង្វឹមចំពោះមនុស្សក្នុងសាកលលោក ព្រមទាំងបានឃើញព្រះសម្ម-
សម្ពុទ្ធជាបរមគ្រូគង់នៅក្រោមដើមអជបាលនិគ្រោធ ទ្រង់ក្រេបនូវវិមុត្តិ-
សុខនៃសម្មាសម្ពោធិញ្ញាណ ។ តែព្រះអង្គទ្រង់គង់ស្ងៀមជាច្រើនថ្ងៃ

ពិចារណានូវពុទ្ធកិច្ចត្រង់ការស្រោចស្រង់សត្វឲ្យផុតចាកទុក្ខ ដែលស្ថិតនៅក្នុងព្រះពុទ្ធហឫទ័យព្រះអង្គដូចជាមាសមួយដុំ ព្រោះព្រះអង្គចង់បង្ហាញផ្លូវសត្វឲ្យច្បាស់ចាកសេចក្តីសង្ស័យ ដើម្បីនឹងដឹកនាំសត្វទៅកាន់មាត់ស្ទឹងអរិយសច្ច ព្រោះព្រះអង្គទ្រង់ព្រះតម្រិះថាធ្វើម្តេចហ្ន៎ឲ្យមនុស្សទាំងអស់ដែលធ្លាប់ពេញចិត្តខាងការប្រព្រឹត្តិបាបអកុសល ដែលធ្លាប់ជាប់ចំពាក់នឹងកាមារម្មណ៍ផ្សេងៗ ដែលធ្លាប់ក្រែបន្ទូរនុជារសកាន់ច្រឡំនៃប្រកតមួយពាន់កន្ទែង ដែលធ្លាប់គ្មានច្បាស់ ឬគ្មានថាមពលអាចបំបាក់នូវបំណងៗសបាន, ធ្វើម្តេចឲ្យសត្វយល់នូវធម៌និទាន: ១២ យ៉ាង(១) នឹងវិន័យដែលស្រោចស្រង់សត្វដែលជាប់កង្វល់ក្នុងវដ្តសង្សារ នាំឲ្យមនុស្សលោកភ័យខ្លាច ដូចជាបក្សានៅក្នុងទ្រុងចាកចេញពីទ្វារទ្រុងរបើកចំហបាន? ព្រោះហេតុដូចនេះ យើងមិនអាចទទួលផលល្អអំពីជោគជ័យនោះទេ បើនៅលើផែនដីនេះគ្មានអ្វីជាសរណៈទីពឹង ។ ព្រះពុទ្ធដែលទ្រង់បាន

---

១ និទាន: ១២ នោះគឺឫកពោលនៃដីវភាពដែលមានបច្ច័យទាក់ទងគ្នាដោយហេតុផលបានដល់ការដែលឃើញជាសំខាន់គឺទុក្ខដាប់ដិតជាមតាមបុគ្គល, ហេតុនៃទុក្ខគឺការកើត, ហេតុនាំឲ្យកើតមកពីជាតិ, ហេតុដែលកើតជាតិគឺតណ្ហាៗ មកពីវេទនាៗ មកពីផស្សៈៗ មកពីសឡាយតនៈៗ មកពីនាមរូបៗ មកពីវិញ្ញាណៗ មកពីសង្ខារៗ មកពីអវិជ្ជា ។ ព្រោះហេតុថ្លែងនេះត្រូវបំបាត់អវិជ្ជា ទើបបានដល់នូវិសុទ្ធ ។ (គម្ពីរខ្លះថា បដិច្ចសមុប្បាទឬបច្ចយាការ) ។ បើតាមធម៌បដិច្ចសមុប្បាទក្នុងគម្ពីរអភិធម្មសង្គហៈ គឺ ដរាមរណៈដាបច្ច័យឲ្យកើតជាតិ ។ ជាតិឲ្យកើតភពៗ ឧបាទានៗ តណ្ហាៗ វេទនាៗ ផស្សៈៗ សឡាយតនៈៗ នាមរូបៗ វិញ្ញាណៗ សង្ខារៗ នាំឲ្យកើតអវិជ្ជា ។

រកឃើញនូវមគ្គសច្ច យល់ឃើញថានេះជាមគ្គសច្ច, ចំពោះជនជាតិសាម័ញ្ញលំបាកនឹងដើរពន់ពេក ហើយទ្រង់តែងតែមួយព្រះអង្គឯង គ្មានបុគ្គលណាដើរតាមពីក្រោយព្រះអង្គ ។ បានជាព្រះសម្មាសម្ពុទ្ធជាសាស្តាចារ្យរបស់យើង - ដោយព្រះអង្គមានព្រះទ័យករុណាដល់សត្វសព្វទ្រង់ព្រះតម្រិះជាមុនសិន, តែកន្លងពេលនោះមានសំឡេងមួយស្រែកពីលើអាកាសឮសព្វសូរជាខ្លាំង ប្រៀបដូចជាស្ត្រីស្រែកក្នុងពេលដែលប្រសូតបុត្រ ប្រៀបដូចជានាងគន្ធិនីព្រះនាមវាសិដ្ឋីថា: "ប្រាកដហើយ, ខ្ញុំនឹងសត្វលោកទាំងអស់មុខជាសាបសូន្យមិនខាន" ។ រួចដល់ស្បែមមួយស្របក់, ស្រាប់តែព្រះពាយខាងទិសបស្ចិមពោលដោយសេចក្តីអង្វរថា: "នុព្រះទេសពលញ្ញាណ ! សូមព្រះអង្គសំដែងធម៌ប្រាសសត្វផង" ។ ព្រោះហេតុដូចនេះព្រះបរមគ្រូទ្រង់ទតទៅកាន់សព្វសត្វ, រួចទ្រង់បានជ្រាបច្បាស់ថា មានសត្វខ្លះមានឧបនិស្ស័យចាស់ក្លា មានសត្វខ្លះឧបនិស្ស័យនៅអន់ទន់ខ្សោយ ត្រូវរង់ចាំពេលទៅថ្ងៃក្រោយ ដូចជាព្រះសុរិយាកំពុងក្តៅខ្លាំង ចោលរស្មីទៅកាន់ទឹកស្រះដែលមានបទុមជុះពាសពេញដឹងច្បាស់ថាបុប្ផាបទុមណាបម្រុងនឹងរីកដោយរស្មីនេះ ឬថាបុប្ផាបទុមណាមិនទាន់ពន្លកចេញពីដើមផង ។ ព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះទ័យសោមនស្សពន់ពេក ទ្រង់លាន់ព្រះឧស្ឋថា: "តថាគតនឹងទៅទេសនាប្រាសសត្វចំពោះអ្នកណាដែលទំផ្សឹងត្រចៀកស្តាប់ ឬព្យាយាមរៀនធម៌" ។

(មានត)

វិនយកថា

ព្រះធម្មវត្តាត់អរិយកសព្ទបៈ ភ្នំពេញ-ឈ្មួញ វត្តបទុមវតី ក្រុងភ្នំពេញ

ទេសនាជាភាសាខ្មែរយោសនសព្ទនៃប្រទេសកម្ពុជា

កាលពីថ្ងៃ ១៤ កើតខែកត្តិក ឆ្នាំកុរនព្វសក ព. ស. ២៤៩០ (២៧ - ១១ - ៤៧)

ជមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

វេលានេះ, អាត្មាភាព ត្រូវវេនសំដែងវិន្យធម្មទេសនាចែកជូនអស់លោក-អ្នកសប្បុរសទាំងឡាយស្តាប់ ។

អាត្មាភាពនឹងសំដែងអំពីវិនយកថា ពណ៌នាអំពីចម្បាប់ ។

សួរថា: អ្វីដែលហៅថា វិន័យ? ឆ្លើយថា: ចម្បាប់ដែលអ្នកប្រាជ្ញតែងតាំងឡើង ទុកសម្រាប់ប្រដៅមនុស្សទូទៅ ឲ្យមានសណ្តាប់ធ្នាប់ល្អ ជាបែបផែនតែមួយ ហៅថា វិន័យ; ការនាំចេញនូវទោសកំហុសផ្សេងៗ ក៏ហៅថា វិន័យ ដែរ ។

វិន័យនេះ យើងត្រូវសិក្សាសូត្រវៀនឲ្យចេះចាំស្ទាត់គ្រប់វេយ: មាត្រា, បើចេះចាំហើយត្រូវមានសញ្ញាការកត់សំគាល់ថ្នាក់ជាន់ឲ្យស្គាល់ប្រាកដ ។ បើស្គាល់មុះមុតហើយ ទើបអាចដូនានពត់កាយ-វាចាជាបដល់ចិត្តឲ្យមានរបៀបរាបសារមារយាទមារ្យល្អទៅបាន ពុំច្រឡើសបើស ពុំឆ្គាំឆ្គងខុសកាល:ទេស: ។ ព្រោះថា មនុស្សក្នុងសកលលោកមិនថាស្ត្រី-បុរស គ្រហស្ថបព្វជិតទេ សុទ្ធតែប្រាថ្នាសេចក្តីល្អ សេចក្តី

សុខ សេចក្តីចំរើនគ្រប់ៗ រូប ។ ឯគុណគឺសេចក្តីល្អទាំងនោះ ពុំមែនកើតឡើងឯងៗ តែម្តងទេ; លុះតែមនុស្សណាកសាងសន្សំប្រតិបត្តិតាមវិន័យ ទើបគុណគឺសេចក្តីល្អទាំងនោះកើតមានដល់អ្នកនោះ ។ ការដែលគេយើងទាំងអស់គ្នានឹងប្រតិបត្តិវិន័យនោះ ត្រូវចេះត្រូវស្គាល់វិន័យជាមុនសិន ទើបប្រតិបត្តិបានស្រួល ។

ដូចក្រមគ្រូសារឬវង្សត្រកូលនីមួយៗ ដែលនឹងមានបុកពាមារយាទសណ្តាប់ធ្នាប់ល្អ ចរិយាល្អ ពុំប្រឡាំងខាមនោះ ក៏ព្រោះតែក្រមគ្រូសារវង្សត្រកូលនោះមានវិន័យ គឺគេចេះចាំស្គាល់ច្បាស់ហើយគោរពប្រតិបត្តិថែមទៀត ទើបគេបានទទួលផលគឺសេចក្តីល្អទាំងនោះ ។ តែបើចេះចាំស្គាល់ហើយ ។ ពុំព្រមបង្អោនខ្លួនគោរពវិន័យយកមកជាប្រតិបត្តិទេ នោះក៏ពុំអាចនឹងរកសេចក្តីល្អ ឬដួបប្រទះនឹងសុន្ទរចរិយាបានឡើយ ។

វិន័យដែលថានាំចេញនូវទោសកំហុសផ្សេងៗ នោះ បានដល់ទោសគឺកំហុសដែលនឹងកើតមានឡើង ព្រោះវាពិសកាយ-វាចានឹងកាន់តំនិត ។ ចុះបើយើងព្រមសុខចិត្តបង្អោនវិន័យយកមកប្រតិបត្តិ ឲ្យត្រូវតាមរយៈមាត្រានឹងថ្នាក់ជាន់សព្វគ្រប់ហើយ តើទោសសេចក្តីទុក្ខនឹងកើតឡើងតាមផ្លូវណាបាន ។ ហេតុនេះបានជាពោលថា វិន័យនាំចេញនូវទោសកំហុសផ្សេងៗ ។

វិន័យតាមផ្លូវពុទ្ធសាសនា ព្រះសម្ពុទ្ធទ្រង់ប្រដៅជាសាធារណៈខ្លះៗពុំមានលំក្នុងំណាទេ, ទុកជាមនុស្សថ្នាក់ណាជាន់ណាឬសាសន៍ណា

ជាតិណាក៏ដោយ ចេះតែបង្អោនមកជាទវត្តប្រតិបត្តិបាន ធ្វើទុនឲ្យបាន
ទទួលសន្តិសុខដូចៗគ្នា ។

វិន័យចំណែកខាងអាណាចក្រវិញ ដែលលោកតែងតាំងឡើងត្រូវ
មានលំដាប់ណា; ព្រោះមនុស្សបែងចែកជា ៤ វណ្ណៈ គឺ: ក្សត្រិយ៍,
ព្រាហ្មណ៍, វេស្សៈ, សុទ្ទៈ ។

ក្សត្រិយ៍នឹងព្រាហ្មណ៍ពប់ថាជាត្រកូលខ្ពង់ខ្ពស់; វេស្សៈនឹងសុទ្ទៈ
ពប់ថាជាត្រកូលថោកថយចុះមកទៀត តែវេស្សៈគង់នៅគាន់បើជាង
សុទ្ទៈ ។ សូម្បីដូច្នោះ វណ្ណៈទាំង ៤ នេះក៏ត្រូវប្រតិបត្តិវិន័យដូចគ្នាដែរ,
តែគេគង់តែរពាប់អានលើកតំកើងត្តិយត្រកូលជាទីបំផុត ព្រោះគេទុក
ជាតំណាងជាតិនឹងប្រមុខនៃជាតិរបស់គេ ។

ម្យ៉ាងទៀត វិន័យតាមផ្លូវអាណាចក្រ គេតែងតាំងឡើងពុំសាជា-
វណៈទូទៅដល់រដ្ឋដទៃៗឡើយ គឺជាច្បាប់សម្រាប់ដែនរបស់គេៗប៉ុណ្ណោះ,
ពួកមនុស្សទាំងអស់ ក្នុងរដ្ឋមណ្ឌលនោះៗ ត្រូវតែនាំគ្នាប្រតិបត្តិតាម
ទើបដំណើរទៅតាមផ្លូវស្អួ ទាំងគេចរៀនឲ្យផុតអំពីទោសសេចក្តីទុស
ទៅបាន ។

សេចក្តីល្អបំផុត គឺពួកមនុស្សទាំងអស់ក្នុងរដ្ឋមណ្ឌលនោះៗ ព្រម
សុខចិត្តជាក់ទុនឲ្យតាំងនៅក្រោមវិន័យ ដែលតែងតាំងឡើងជាច្បាប់
សម្រាប់រដ្ឋនោះៗ ។

ការដែលយើងនឹងប្រគល់ខ្លួនឲ្យតាំងនៅក្រោមវិន័យ ស៊ប់សួនបាន នោះ លុះតែខំបណ្តុះនូវហិរោត្តប្បធម៌ ឲ្យលូតលាស់ចំរើនឡើងក្នុងសន្តាន របស់យើងជាជំនួយផង, ព្រោះហិរោត្តប្បធម៌នេះ លោកពោលថាថាធម៌ គ្រប់គ្រងលោកទាំងមូល ឲ្យដំណើរទៅកាន់អារ្យធម៌និងវឌ្ឍនធម៌បាន ។

ចុះអ្វីដែលហៅថាហិរោត្តប្បធម៌? សេចក្តីខ្មាសនឹងសេចក្តីខ្លាចអំពើ អាក្រក់គ្រប់យ៉ាងហៅថាហិរោត្តប្បធម៌ ។ បើពួកមនុស្សទាំងអស់ក្នុង រដ្ឋមណ្ឌលនោះ។ បានបង្អោនធម៌ទាំងពីរនេះ មកផ្គុំកក្នុងសន្តានបាន ហើយ នឹងអាចឧបត្ថម្ភខ្លួនឲ្យតាំងនៅក្រោមវិន័យទៅអនាគតបានវែង អួយ, ហើយនឹងបានជាគតិល្អរបស់បច្ចាជនតាជន គឺជនដែលកើតខាង ក្រោយតៗមក ។

ក្នុងដែននីមួយ។ ដែលនឹងដំណើរទៅកាន់អារ្យធម៌បាននោះ លុះ តែអស់លោកជាវជ្ជកិច្ចាល នឹងជាឥស្សរជន នឹងប្រជានិករួមមូលចិត្ត គំនិតគ្នាគោរពប្រតិបត្តិវិន័យដែលតែងតាំងឡើង ដោយមានហិរោត្តប្ប-ធម៌ជារណបផង ។ បើថាពុំព្រមមូលចិត្តគំនិតគ្នាឲ្យរឹងប៉ឹងក្នុងការប្រតិ-បត្តិវិន័យទេ, ដែននោះមុខជានឹងបែរមុខទៅកាន់បល្ជង្ឃធម៌ គឺសេចក្តី អាប់ឧនចុះថយទៅពុំខានឡើយ ។

ហេតុនេះ សូមអស់លោកជាឥស្សរជន ព្រមទាំងប្រជាជនក្នុង ខេមរដ្ឋទាំងមូល សូមជួយណែនាំពន្យល់គ្នាឲ្យចេះគោរពប្រតិបត្តិវិន័យ

ដោយមានហិរញ្ញវត្ថុប្បធម៌ជាដំនួយឲ្យរឹងប៉ឹងគ្រប់ៗ គ្នាឡើង ទើបខេមរាជ្ជ
យើង នឹងធ្វើដំណើរស្ទុះលឿនដើរទៅកាន់វឌ្ឍនធម៌បានឆាប់រហ័ស ។

កាលបើអស់លោក-អ្នកមានសមត្ថភាព បានជ្រាបអត្ថប្រយោជន៍នៃវិន័យ
ច្បាស់លាស់ហើយ ត្រូវពិនិត្យមើលមនុស្សទាំងអស់ក្នុងចំណោមខេមរាជ្ជ
យើង តើសព្វថ្ងៃនេះ 'សម្បុរណាអ្នកគោរពប្រតិបត្តិវិន័យ ដោយមាន
ហិរញ្ញវត្ថុប្បធម៌ជាសម្ភៀកបំពាក់ហើយឬនៅ? បើសម្បុរណាគ្រប់គ្រាន់
ហើយ ក៏សូមជួយគាំពារកូរឲ្យរឹងតែតែមាំមួនឡើង, បើមិនសម្បុរណា
ទេ សូមជួយណែនាំពន្យល់ឲ្យយកចិត្តទុកដាក់ ក្នុងការគោរពប្រតិបត្តិ
វិន័យឲ្យពេញដំហរគ្រប់ៗ គ្នាឡើង ។

ព្រោះខេមរាជ្ជយើងសម័យនេះ មិនថារូបណាជារូបណាទេ គឺ
ត្រមត្រៀងគ្នាទាំងអស់ មានព្រះពាជាជាប្រមុខ សុខព្រះទ័យ សុខចិត្ត
បង្អោនកាយទាំងស្រុងឲ្យតាំងនៅក្រោមច្បាប់សម្រាប់ដែន ដោយ
យល់ថាជាវិន័យសម្រាប់ខេមរាជ្ជ ដែលនឹងប្រជៅមនុស្សឲ្យមានសណ្តាប់
ធ្នាប់ល្អ មានបែបផែនល្អ ។

វិន័យនេះនឹងចេះដឹងឯងក៏ទេដែរ ត្រូវតែប្រឹងរៀនសូត្រទន្ទេញ
ទើបអាចនឹងចេះចាំបាន ។ ហេតុនេះ សូមនរជននឹងនារីកោតព្រមទាំង
យុវជននឹងយុវនារីរួមជាតិ ដែលកាន់លទ្ធិពុទ្ធសាសនាដូចគ្នាទាំងឡាយ
ចូរអ្នកស្ទុះក្រោកចាកសេចក្តីខ្ជិលច្រអូស ដែលជាគ្រឿងមន្ទិលសៅហ្មង

ដល់ជាតិរបស់អ្នក ។ ចូរអ្នកទាំងឧបាសក៍ប្រកបកិច្ចរបស់អ្នកឲ្យអស់ពីចិត្ត, ឲ្យពេញកំឡាំងគ្រប់គ្នាឡើងតាំងពីឥឡូវនេះទៅ ដោយសមត្ថភាពនឹងសាមគ្គីធម៌ ទើបអ្នកនឹងបានដល់នូវសុខចំរើនគ្រប់ប្រការ ។

ក្នុងទីបំផុតនេះ, សូមថ្វាយព្រះពរព្រះរាជសិរីសួស្តីព្រះជន្មសុខគ្រប់ប្រការ ចូរមានដល់សម្តេចព្រះបរមបពិត្រព្រះរាជសម្ភារ ជាឯកអគ្គសាសនូបត្ថម្ភក៍ដ៏ឧត្តមនូវព្រះគុណធម៌មហាប្រសើរពាល់យប់ថ្ងៃ នឹងសូមអស់ពួកប្រជានិករក្នុងខេមររដ្ឋទាំងមូលគ្រប់កូមិគ្រប់ជាន់ ចូរសាមគ្គីព្រមព្រៀងយ៉ាងសុខសប្បាយ ប្រសព្វពរទាំង ៤ ប្រការគ្រប់ពិនពិភពត្រីបុរ ។

សំដែងមកក្នុងវិនយកថា ពោលអំពីច្បាប់សម្រាប់ប្រដៅមនុស្សទាំងគ្រហស្ថបព្វជិតឲ្យមានរបៀបរៀបរយល្អ មានសណ្តាប់ធ្នាប់ល្អដោយសង្ខេបប៉ុណ្ណេះ ឯវំ ។

ចប់វិនយកថា

ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីវគ្គ វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃ្លាបណ្ណាគុរ៉ាក្យ ប៊ុ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យអ្នកពិនិត្យកែ

(តមក)

វិចារសុភាព— ភាចាជាគ្រឿងនាំឲ្យដឹងដល់បំណងគ្នាបាន, បើមិនមានភាចាពាក្យសំដីទេ សូម្បីមានសេចក្តីចេះដឹង សេចក្តីចូលចិត្តយ៉ាងណា ក៏មិនអាចនឹងធ្លាប់ឲ្យសេចក្តីចេះដឹង សេចក្តីចូលចិត្តនោះដល់គ្នាបានឡើយ ។ ព្រោះភាចាជាឱតាំងនៃវត្ថុទាំងពួង, វត្ថុទាំងពួងរមែងចេញទៅអំពីភាចា ។ សូម្បីយើងអាចស្គាល់វត្ថុទាំងនោះបានក៏ដោយអាស្រ័យភាចាដែរ ទើបគួរចាត់ភាចាថាជារបស់មានដំឡៃដ៏ខ្ពង់ខ្ពស់ ។ មើលចុះក្នុងខ្លួនយើងទាំងមូល រមែងមានមាត់ជាវត្ថុសំខាន់, ព្រោះមនុស្សគ្រប់គ្នា តែងត្រូវការស្តាប់សង្កេតយកពាក្យសំដីក្នុងខណៈដែលយើងនិយាយ ទាំងខាងល្អទាំងខាងអាក្រក់ ដូចក្នុងតួដំរីទាំងអស់ឥតមានអ្វីបានដំឡៃជាងក្តួកដូច្នោះ ។ ទើបបុរាណពោលថា : "មនុស្សគេយកសំដី ដំរីគេយកក្តួក" ។

ភាចាល្អ បើយើងនិយាយចេញមក សូម្បីតែ ១ ម៉ាត់ក៏មានដំឡៃស្មើនឹងនគរ, អាចធ្វើឲ្យបានផ្ទះ ឲ្យបានស្រុក ឲ្យបាននគរ ឲ្យបាន

ប្រាក់ ឲ្យបានមាស ឬធ្វើមនុស្សដែលខាសខែងគ្នា ឲ្យត្រឡប់ជាមិត្ត ទឹងគ្នាបាន ដូចពាក្យបុរាណថា "និយាយល្អ ជាសិរីចំពោះខ្លួន" ឬ "និយាយល្អ ជាប្រាក់ជាមាស" ។ រាល់អាក្រក់ បើយើងនិយាយ ចេញមកតែមួយតែ ១ ម៉ាត់ ក៏នាំឲ្យមានរឿង នាំឲ្យកើតជាភ័យធំ នាំឲ្យ កើតវិវាទខាសខែង ឬកើតចលាចលកោលាហលដល់គ្នាវឹកវរ ឬនាំឲ្យ ខូចដល់ស្រុកដល់ទេសដល់ប្រាក់ ដល់មាសក៏មាន, ចូលក្នុងំខនងថា "និយាយអាក្រក់ នាំឲ្យអប្រិយចង្រៃ" ឬ "និយាយមិនល្អ ត្រូវខូចមាស ខូចប្រាក់" ។ បុរាណកាសិតថា "អណ្តាតជាអាវុធកន្តង ឋានសុខ ទុក្ខផង ពីព្រោះអណ្តាត" ។

រាល់ដែលល្អ ដែលត្រូវធម៌ ត្រូវនិន័យ ត្រូវច្បាប់ ត្រូវទំលាប់ មិនមែនដឹកនាំឲ្យប្រើអាជ្ញា មិននាំឲ្យចាប់សស្ត្រាវុធ មិននាំឲ្យកើត សេចក្តីប្រកួតប្រកាន់ មិននាំឲ្យកើតវិវាទ មិនញុះញង់ឲ្យគេឈ្លោះគ្នា ទេ គឺជារាល់ដឹកនាំឲ្យអ្នកស្តាប់ចូលចិត្ត ពេញចិត្ត គាប់ចិត្តតែម្យ៉ាង ។ ព្រោះការនិយាយល្អនោះ មានលំអង៏ខាងដើម ង៏កណ្តាល ង៏ខាងចុង, មានការនិយាយជារបៀប មានការនិយាយជាធម៌ មានការ និយាយជាទីគួរស្រឡាញ់ មានការនិយាយពិត មានការនិយាយត្រូវ កាលវេលា មានការនិយាយពីព្រោះផ្អែមល្ហែម មានការនិយាយជាប្រ-យោជន៍ នឹង មានការនិយាយដោយចិត្តមេត្តាជាលក្ខណៈ នេះជារាល់ថា

សុភាព ។ លក្ខណៈនៃវាចាសុភាពទាំងនេះ លោកសង្គ្រោះបូលក្នុងប្រភេទនៃវចីសុចរិត គឺប្រព្រឹត្តល្អដោយវាចា ៤ ប្រការ បានដល់វាចាពិត ១ វាចាផ្សះផ្សា ១ វាចាពីពោះ ១ វាចាមានប្រយោជន៍ ១ ។

១.— វិបាកពិត :- សំដៅយកពាក្យពិតដែលមានការស្មោះត្រង់ទៀងត្រង់ ខ្ជាប់ខ្ជួនជាលក្ខណៈ, មិនមែនជាសំដីវៀចវេរ បញ្ឆោត ឬកុហកកូតកររឡើយ ។ អ្នកមានសច្ចវាចាមែនទិយាយពាក្យពិត ដែលប្រកបដោយប្រយោជន៍ វៀរចាកពាក្យកុហកកូតករ ទឹងរឿងដែលមានទោសបូលចិត្តក្សាវាចាឲ្យពិត ឲ្យខ្ជាប់ខ្ជួន មិនឲ្យប្រែប្រួលទៅជាយ៉ាងដទៃ ។ បើវាចាដែលខ្លួនទិយាយទៅយ៉ាងណា ក៏តាំងចិត្តរក្សាឲ្យពិតតាមសំដីយ៉ាងនោះ មិនឲ្យឃ្លៀងឃាត តាំងមានគំនិតនឹងថ្លូមាត់ ព្រមតាំងសេចក្តីប្រព្រឹត្តត្រង់តាមគ្នាតាំងអស់ គួរជាទីជឿ ជាទីកាន់យក នៃមនុស្សតាំងពួងបាន ។ បំណែកមនុស្សមិនមានវាចាពិតវិញ រមែងមានគតិអាក្រក់ជាច្រើនយ៉ាង ដូចជានិយាយមិនពិតខ្លះ មិនត្រង់ខ្លះ វៀចវេរខ្លះ មាយាខ្លះ ត្រឡប់ត្រឡិនខ្លះ, និយាយទៅមុខ៉ាង គិតទៅមុខ៉ាង កិរិយាដែលប្រព្រឹត្ត ក៏បែរទៅជាមុខ៉ាងទៀត ជាហេតុឲ្យគេជឿទុកចិត្តឬកាន់យកតាមផងពុំបាន ។ លោកអ្នកមិនត្រូវធ្វើជាមនុស្សដូច្នោះទេ ចូរគោរពបូជាសច្ចវាចាទុកទៅចុះ ។ ព្រោះសេចក្តីពិត ជាឫសគល់នៃសេចក្តីល្អ ចូរថែរក្សាឫសដែលបង្កឲ្យកើតសេចក្តីល្អនោះដោយសេចក្តីពិត កុំថែរក្សា

ឫសគល់នៃការកុហកកូតកវឡើយ ព្រោះការកុហកជាឫសគល់នៃការ
វៀចវេរ ។

ក្នុងការអប់រំចិត្ត ឬ ចិត្តានុភាព ត្រូវមានសច្ចវាចាជាឧបការៈយ៉ាង
សំខាន់បំផុត ។ ព្រោះសច្ចវាចា អាចធ្វើឲ្យមនុស្សចូលចិត្តនិយាយពិត
ចូលចិត្តគោរពបូជាសេចក្តីពិត ជាវាចាមានមនុស្សគោតព្រែកង ស្រ-
ឡាញ់ គោរពរាប់អាន ។ អ្នកចូលចិត្តនិយាយមុសាវាទ ឈ្មោះថាអប់
រំខ្លួនឲ្យជាមនុស្សមិនក្លាហាន នឹងបង្អន់ចិត្តានុភាពរបស់ខ្លួនឲ្យអន់កំឡាំង
អាប់រាសី ។ ក្នុងតំរាចិត្តសាស្ត្រចានពោលថា "បើនរណាមិនខ្ជាប់ខ្ជួន
ក្នុងសំដីរបស់ខ្លួនត្រឹមណា អ្នកនោះប៉ុនគ្នានឹងព្យាយាមអប់រំខ្លួនឲ្យមាន
កំឡាំងចិត្តខ្សោយចុះ ឬព្យាយាមអប់រំខ្លួនឲ្យជាមនុស្សចាញ់ខ្លួនឯងត្រឹម
នោះ" ។ បើនរណាចាញ់ខ្លួនឯងហើយ អ្នកនោះនឹងត្រូវចាញ់អ្នកដទៃ
ទៀត ថែមទាំងបាននឿយថាជាអ្នកចាញ់មនុស្សក្នុងលោក ចាញ់
ជោគវាសនា ចាញ់ហេតុការណ៍ ចាញ់អ្វីៗ គ្រប់យ៉ាង តាំងពីលោកនេះ
រហូតដល់លោកខាងមុខផង ។ បើមនុស្សយើងឈ្នះខ្លួនឯងហើយ ក៏អាច
ថាជាមនុស្សប្រសើរព្រែកលែង ។ ក្នុងសៀវភៅគោបុត្រសៀម បាន
ពោលចោទអ្នកនិយាយកុហកថាអាក្រក់ព្រែកលែងជាងសត្វព្រៃទៅទៀត ។

មនុស្សវៀចវេរ មិនចេះ អស់កូតុកវ
កុហកហើយ គួរ ហ៊ានជានា

ព្រោះចំណង់ ចង់ឈ្នះ ជនពាល់គ្នា
ចិត្តដូចជា ទេវទត្ត មាត់ទេវតា ។
នរណាក៏ត់ សរសើរ មនុស្សបែបនេះ
មុខជាចេះ តែស្លាប់ ដោយវាចា
ច្នេះត្រូវដឹង ថាមនុស្ស គ្មានសច្ចា
សត្វតិរច្ឆាន ចានការ ប្រសើរជាង ។

បើលោកអ្នកខូចសច្ចៈហើយ លោកអ្នកក៏នឹងទៅជាមនុស្សស្លាប់មុនស្លាប់ (ស្លាប់ក្តៅឈ្មោះ) ។ សូម្បីលោកអ្នកមានជីវិតរស់នៅ ក៏មិនមាននរណាមួយនឹងពាប់អានចុះចុកចិត្តលោកអ្នកបាន ។ លុះតែលោកអ្នករក្សាវាចាពិតឲ្យជានាទីរបស់ខ្លួន នឹង ថែរក្សាសេចក្តីពិតនោះទុកឲ្យបានខ្ជាប់ខ្ជួនស្មើដោយជីវិត ទើបខ្លួនលោកអ្នកទៅជាទីគួរគោរពពាប់អានចុះចុកចិត្ត នឹង គួរសរសើរនៃពួកជនអស់កាលយូរលង់ តាំងក្តៅឈ្មោះកំសៀច្រាកដូចរំទៅមិនសាបសូន្យ ។ មនុស្សវង្សតើកមកខាងក្រោយ គង់នឹកវាឡុកនឹងពណ៌នាឈ្មោះលោកអ្នកដោយសេចក្តីគោរពពាប់អាន, លោកអ្នកក៏នឹងបានឈ្មោះថាជាអ្នកមិនស្លាប់ (មិនស្លាប់ក្តៅឈ្មោះ) ។ សូមមើលរឿងកមក្តៅ ត្រង់ព្រះកមនឹងព្រះបាទមាលីវ គង់ជ្រាបបាន ។

រឿងព្រះកមនោះ មានពួកប្រជានិករ នាំគ្នានិយមពាប់អានថា "ជាកំពូលនៃពួកមនុស្ស" រហូតដល់នាំគ្នាលើកតំកើងថា "ជាព្រះ

នាពាយណ៍ថែងកាត" ផង ។ ព្រោះព្រះពាមរាប់អានសេចក្តីពិតយ៉ាងខ្លាំង
ក្លា ជាង[ថ្វាយ]ពរជសម្បត្តិឬសេចក្តីសុខទៅទៀត ។ កាលព្រះបាទជតវថ
ជាព្រះពរជបិតាបានផ្តាំប្តេជ្ញារឿងពិតយ៉ាងណា ព្រះពាមក៏ទំរក្សាសេចក្តីពិត
នោះឲ្យ[ប្រពឹត្ត]ទៅយ៉ាងនោះគ្រប់ប្រការ ។ លុះព្រះពរជបិតាអស់ព្រះ
ជន្មទៅ សូម្បីព្រះកីរុតនីងមហេសីទាំង ៣ ព្រះអង្គ ព្រមទាំងអាមាត្យមុខ
មន្ត្រីក្នុងក្រុងអយុជ្ឈា នាំគ្នាចេញទៅអញ្ជើញឲ្យស្តេចត្រឡប់ចូលមក
កាន់នគរវិញ ក៏ព្រះពាមមិនព្រមទទួលពាក្យអញ្ជើញនោះឡើយ សុខ
ចិត្តទំាគ្រលំបាកនៅក្នុងព្រៃជរាចជល់លើសពី ១៤ ឆ្នាំ តាមកំណត់
ដែលព្រះពរជបិតាបានត្រាស់សន្យាទុក ។ សូម្បីព្រះបាទមាលីរាជ
ដែលយើងពោល[ថ្វាយ]ជល់ដោយសេចក្តីនិយមរាប់អានថា "ជាមនុស្ស
មានវាចាពិត" នោះក៏ព្រោះព្រះអង្គមានព្រះបន្ទូលតែពាក្យពិតគ្រប់
ពេល ។ ពួកពលរបស់ព្រះអង្គ ទុកជាមិនចាំបាច់កាន់អាវុធ ក៏គង់
មានមនុស្សគោតខ្លាច ទាំងពួកឃ្លាងពួកទេវតាទៀតក៏ខ្លាចដែរ ។
រឿងនេះ សំដែងឲ្យឃើញថា សច្ចវាចាជាគេជះអំណាចរបស់អ្នកដែល
ទ្រទ្រង់ទុក ជាអាភរណៈដ៏ប្រសើរ ជាសិរីដ៏ថ្លៃថ្លា លើកតំកើងអ្នក
ដែលនិយាយឲ្យមានពន្ធឹរស្មើជាទីគួរគោរព គួរប្រាប់អាន គួរស្រឡាញ់ គួរ
ជឿ គួរស្តាប់ នៃមនុស្សគ្រប់ជាន់ទួទៅបានឆ្ងាយនឹងយូរអង្វែង ។ ដូច្នេះ
បើលោកអ្នក [ថ្វាយ]នឹងរឹកតិគុណរបស់ខ្លួនទុកកងលោក ឲ្យមហាជន

និយមកាប់អានរហូតដល់កល្បាវសាន ត្រូវកុំធ្វើជាមនុស្សមេករវឥតខ្មាសមេលង់ខ្លៅ មិនអៀនអន់ឡើយ កុំសំដែងការមិនពិត អួតអាងខ្លួនឲ្យមនុស្សជឿស្តាប់ កុំបង្កើតរឿងមិនពិតឡើងឲ្យគេជឿខុស ឲ្យកានយកខុសតាម កុំលាយសេចក្តីពិតដែលមានមែន កុំបន្ថែរឿង កុំដោយកពិតច្រែកជភ្លាមៗ កុំបំផ្លើសរឿងដែលពិតឲ្យច្រើនជាងហេតុ កុំមាក់ងាយក្នុងការប្រើសំដីលេងសំខ្លួន នឹង កុំបណ្តាយឲ្យធ្លាប់មាត់ខាងការនិយាយកុហកឡើយ ។ ចូរកក្សាសច្ចវាចាទុកឲ្យខ្ជាប់ខ្ជួន ចូរអប់មាត់ឲ្យក្រែអូបដោយការនិយាយតែពាក្យពិត ។ ព្រោះព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងទុកមកថា "ពាក្យសច្ចៈមានរសក្រៃលែងជាងរសទាំងឡាយ, ពាក្យសត្យជាវាចាមិនចេះស្លាប់, មនុស្សដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ ក៏ព្រោះពាក្យសច្ចៈ" ។

ចូរពោលពិត ឲ្យស្មើគ្នា ជានិស្ស័យ
ទោះនៅកុង វង់ដៃ នៃសត្រូវ
ដែលកំញើញ ឲ្យពោល យោលខុសផ្លូវ
ក៏ពុំត្រូវ ក្លែងពោល ឲ្យឃ្លាតពិត ។
ទាំងកិច្ចការ គួចធំ សព្វសារពើ
ក៏ត្រូវធ្វើ ឲ្យត្រង់ តាមគំនិត
ទោះយ៉ាងណា ក៏កុំ លះរឿងពិត
ទើបហៅថា បណ្ឌិត ពិតកង់លោក ។

๒– រឿងផ្សេងផ្សំ[๑].– ជាវិធីចងមិត្តនឹងផ្សារសាមគ្គី[๑] ។ មនុស្សនិយាយរាប់ចាផ្សេងផ្សំ គឺរាប់ចាមិនញុះញង់ រមែងមានមេត្តាករុណាជាគូមិធមិប្រចាំចិត្ត ឥតមានសេចក្តីឫស្សា ចំពោះនរណាមួយនៅក្នុងចិត្តឡើយ, ចូលចិត្តនិយាយតែពាក្យដែលភ្ជាប់មិត្តនឹងភ្ជាប់សាមគ្គី, នៅកន្លែណា ធ្វើខ្លួនឲ្យជាមិត្តរបស់ពួកគណៈកន្លែនោះ ចាត់ថាមានខ្លួនជាអណ្តូងកើតនៃសន្តិសុខ នឹង ឲ្យប្រជុំជនអាស្រ័យបានសន្តិសុខផង ។ ពិតមែន ការចរចារឿងស្រុកទេសពីប្រទេសមួយទៅមួយនោះ ត្រូវមានខ្លួតដែលស្មោះត្រង់ជាអ្នកតំណាងប្រទេសក្នុងការស្តីដណ្តឹង ត្រូវមានចាស់ទុំជាអ្នកចាត់ការ ។ ឯក្នុងការបែងចែកទ្រព្យសម្បត្តិមតិកំត្រូវមានមនុស្សជាកណ្តាល ជាអ្នកវិនិច្ឆ័យ ។ បើខ្លួតអ្នកចាស់ទុំនឹងមនុស្សជាកណ្តាលនោះជាអ្នកឈ្លាសវៃ ចេះចរចា ចេះចាត់ការ ចេះវិនិច្ឆ័យហើយ, ការសង្គ្រាមរវាងប្រទេស ការប្រាក់បែកគ្នារវាងប្តីប្រពន្ធ ការខាស់ខែងបែកបាក់រវាងក្រុមញាតិមិត្ត ឬអ្នកធំនឹងអ្នកតូច ក៏មិនអាចនឹងកើតមានឡើងបានឡើយ ។

អ្នកណាឈ្លាសវៃអង់អាច ចេះនិយាយបញ្ចុះបញ្ចូលទឹកចិត្តរបស់ពួកគណៈ ចេះចងមិត្តនឹងភ្ជាប់សាមគ្គីទុកដោយកុសលោបាយ មិនធ្វើឲ្យពួកគណៈបែកគ្នា ដោយពាក្យសំដីចាក់រុក សូម្បីបានឮពាក្យដែលនាំឲ្យពួកគណៈកើតខាស់ខែងខ្វែងគំនិតគ្នាក្នុងពីរនេះ ក៏មិននាំយកទៅនិយាយ

---

๑ ពាក្យ "ផ្សេងផ្សំ" នឹង "ផ្សារសាមគ្គី" មតិខ្ញុំថាគួរប្រើឲ្យត្រូវគ្នា ។ ឃ. អ. ។

ក្នុងទីណាៗទៀត មានតែពោលពាក្យដែលនាំឲ្យកើតសាមគ្គីដល់ពួកគណៈតែម្យ៉ាង អ្នកនោះសូម្បីនៅក្នុងពួកគណៈដែលធំ ដែលចាត់ថាជាប្រទេសជាតិ ក៏គង់បានទទួលការលើកតំកើងឲ្យធ្វើជាធំ ជាទីគោរពរាប់អានរបស់ពួកគណៈក្នុងទីនោះ ។ ចាំងពួកគណៈនោះសោត ក៏នឹងមានកម្លាំងមាំមួន ប្រកបដោយសន្តិសុខវឌ្ឍនាការ ជាស្ថាពរតទៅជាយូរអង្វែង ។

បើលោកអ្នក ចង់ឲ្យប្រទេសជាតិចំរើនរុងរឿង នឹង ចង់ឲ្យខ្លួនជាទីគោរពរាប់អាននៃពួកគណៈ ត្រូវប្រយ័ត្នកុំពោលពាក្យស្អប់ខ្ពើមដែលជាហេតុទំលាយមនុស្សអ្នកនៅរួមគ្នាឲ្យបែកបាក់គ្នា កាត់មេត្រីរបស់គេឲ្យដាច់ នឹង ធ្វើការខាត់ខន់របស់គេឲ្យសាបសូន្យឡើយ កុំដឹកនាំឲ្យគេលិចលង់ កុំចាក់រុកឲ្យគេកើតប្រកួតប្រកាន់ខឹងតូចចិត្តឈឺចិត្តអន់ចិត្តចំពោះគ្នានឹងគ្នា កុំនិយាយខ្សឹបខ្សៀវដាក់ត្រចៀកគេឲ្យគេវង្វេងដើម្បីថាពិតតាមសំដីដែលយើងនិយាយ ។

បើលោកអ្នកបានលះវៀរពាក្យ ដែលហាមប្រាមទាំងនេះហើយ ចូរនិយាយផ្សះផ្សាមនុស្សដែលបែកគ្នាឲ្យជាប់គ្នាវិញ, ចូរនិយាយបន្ធូរបន្ធន់ចិត្តមនុស្ស ដែលល្អនឹងគ្នា ឬសិក្សាលចំពោះគ្នារួចហើយឲ្យរឹងតែតែងជិតជិតនឹងគ្នា ដូចមាសរលាយសាប់មួយតទៅទៀត, ចូរនិយាយណែនាំមនុស្សដែលល្អនឹងគ្នាឲ្យមានសេចក្តីសាមគ្គីព្រមព្រៀងគ្នា, ចូរ


និយាយអនុគ្រោះមនុស្សដែលមានសាមគ្គីនឹងគ្នាហើយ ឲ្យរឹងតែតែសុំឲ្យស្និទ្ធស្នាលនឹងគ្នាតទៅទៀត, ចូរនិយាយដឹកនាំមនុស្សដែលមិនទាន់ស្គាល់គ្នាឲ្យស្គាល់គ្នា នឹង ចូរនិយាយណែនាំមនុស្សដែលស្គាល់គ្នាហើយ តែនៅមិនទាន់ស្និទ្ធស្នាលនឹងគ្នា ឲ្យស្រឡាញ់ស្និទ្ធស្នាលនឹងគ្នា ។

សូមកុំភ្លេច! សូមរំពឹកខ្លួនឯងជានិច្ចថា "មនុស្សនិយាយស៊ីកសៀតជាមនុស្សមេបំបែកបំបាក់ មានន័យជាអ្នកបំបែរពួក, ចូលទៅណាត្រូវបែកពួកក្នុងទីនោះ, មានមាត់ជាមេរោគ មានមាត់ជាក្រចកសម្រាប់ខ្វារដំបៅ, ចូលចិត្តតែនិយាយដើមគេ ដើម្បីនឹងគាស់សេចក្តីឲ្យរឹងហើយនិន្ទាថាអាក្រក់, នាំយករឿងអាក្រក់ពីខាងណោះទៅប្រាប់ខាងណោះ យករឿងអាក្រក់ពីខាងណោះមកប្រាប់ខាងណោះ ហើយថាកុំឲ្យអ្នកទាំងសងខាងកើតប្រឈោះទាស់ខែងបែកសាមគ្គីគ្នាឡើយ ទើបបានឈ្មោះថាចូលទៅទីណា មានរឿងអាក្រក់ក្នុងទីនោះ" ។

មេរោគមាត់ ជាមេនាំឲ្យមាត់ដំបៅ នឹង នាំឲ្យក្រចកគឺមាត់នៅស្ងៀមមិនបាន ត្រូវព្រួសពិសចេញមករឿយៗ ។ គេថាយើងនឹងដេរមាត់ចង់ប្រើចេសត្រឹម១សរសៃក៏ល្មម តែបើដេរមាត់មនុស្សដែលខូចមាត់វិញ សូម្បីចេសច្រើនត្រសាល់ក៏មិនល្មម ។ លោកអ្នកមិនត្រូវនៅរឹតរវែងនឹងគេទេ, ដេកញួនសំនឹងនៅក្នុងច្រកកំពែងតូច ។ ល្អជាងការនៅក្នុងគ្រឹះស្ថានពាក់ព័ន្ធ ។ ជាមួយនឹងមនុស្សបែបនោះ ។ យើងគួរប្រយ័ត្នមាត់យើងកុំឲ្យដំបៅបាន ។

ការស្លាប់ ១ មឺនដង កំតង់ប្រសើរជាងការរស់នៅមានដំបៅមាត់ដែរ ។ ព្រោះក្តីឈ្មោះ នៅត្រង់មាត់ល្ហ ។ បើមាត់ដំបៅហើយ លោកក៏ឈ្មោះថាមានមាត់សម្រាប់សំឡាប់ខ្លួន ដូចឱ្យឆ្ងន់ឆ្ងឹងអណ្តើក ។

បើលោកអ្នកវៀរបង់ស្លែងតីពាក្យស៊ីកសៀត ហើយនិយាយតែពាក្យផ្អែមផ្អាម ពាក្យមិនស៊ីកសៀតញុះញង់ហើយ មាត់របស់លោកអ្នកក៏នឹងទៅជាមាត់ប្រាសចាកពោគ ជាមាត់អនាម័យ ឬមាត់និរ៌ាយ ។ មាត់អនាម័យនោះ បើនិយាយកន្លែងណា ក៏ធ្វើឱ្យកើតសេចក្តីរីករាយឡើងក្នុងទីនោះ ។ ពិតមែន កាលបើលោកអ្នកឱ្យសេចក្តីរីករាយដល់គេហើយ សេចក្តីរីករាយនោះ ក៏នឹងត្រឡប់មកកាន់លោកអ្នកវិញ ។ សូមប្រយ័ត្នអណ្តាតទុកចុះ មនុស្សដែលបរិភោគឆ្អែតហើយ នៅតែមិនឃើញល្អនោះ គឺមនុស្សខ្ជាប់ប្រើអណ្តាតតិះដៀលនិន្ទាមនុស្សទាំងពួង ។ បើលោកអ្នកមិនប្រយ័ត្នអណ្តាតរបស់ខ្លួនទេ មិនយូរឡើយ មុខជាអណ្តាតនោះ កាត់បង់ឫសគល់របស់លោកអ្នកពុំខាន ។ (មានន)



អ័ឌ្ឍណា - សិម្ប៉ាណា

"រឿងព្រៃនប្រទេសរូម៉ានី"

លោក ផេង - ជឿរ សាស្ត្រាចារ្យ នៅសាលាគរុកិច្ច ភ្នំពេញ

ប្រែរៀបរៀង

(ចប់)

នាងអ័ឌ្ឍណា - សិម្ប៉ាណា ក្រាបបង្គំទូលព្រះចៅថា: សូមចាត់ឲ្យមនុស្សតែយកទឹកដោះមេសេះតាំងពាយដើម្បីឆ្ងូត ។ ប៉ុន្តែគ្មាននរណាអាចចូលជិតមេសេះតាំងនោះបានទេ តែអ្នកណាប្រហែស មុខជាវាច្បាយរុះរោះជាមិនខាន ។ ព្រះចៅឃើញអាការៈមិនស្រួលដូច្នោះ មានព្រះរាជឱង្ការបង្គាប់ឲ្យព្រះអង្គម្ចាស់ហាវហានជាអ្នកតែទឹកដោះសេះទៀត ។

ព្រះនាងក៏ស្តុតព្រះហឫទ័យដោយឃើញថា "កិច្ចការអ្វីយ៉ាងធ្ងន់ៗ សុទ្ធតែធ្លាក់មកលើព្រះនាងតាំងអស់" ហើយព្រះនាងតាំងស្មារតីយ៉ាងមាំ សូមអង្វរព្រះជាម្ចាស់ឲ្យជួយព្រះនាងម្តងនេះទៀត ។ រួចស្រាប់តែមានក្អែងធ្លាក់មកយ៉ាងច្រើនទាល់តែលិចដើងសេះត្រឹមជង្គង់, ទឹកក្អែងនេះក្លាយជាទឹកកកដ៏ធំដូចថ្ម សេះរកកំរើកជើងមិនបាន ។ ព្រះនាងឃើញហេតុអស្ចារ្យដូច្នោះ មុនដំបូងសូមអរព្រះគុណនឹងជំនួយនៃព្រះជាម្ចាស់ រួចក៏តាំងចាប់តែទឹកដោះសេះជាខាងក្រោយ ។

ព្រះចៅភជាធិពជមានព្រះហ្ឫទ័យរោលរាលដោយភគគ្គិ ចំពោះនាងអ័ឡៃណា - សិម្ប៉ាណាជាកែវភេត ព្រះចៅស្តេចឡើងក្រឡេកមើលនាងដូចជាគេក្រឡេកឃើញផ្ទៃម្ចាស់ពុំ ។ ប៉ុន្តែនាងអ័ឡៃណា-សិម្ប៉ាណាគ្មានអាណិតដល់ព្រះហ្ឫទ័យនៃព្រះអង្គបន្តិចសោះ ហើយចេះតែអាងលេសអ្វីបន្តិចបន្តួច រួចរកឿនពន្យារអាពាហ៍ពិពាហ៍ ពីថ្ងៃមួយទៅថ្ងៃមួយ ។ លុះទីបំផុត នាងក្រាបបង្គំទូលថា: "បពិត្រព្រះមហាក្សត្រិយ៍ដ៏ប្តុរង្គ! ទូលព្រះបង្គំដឹងថា ពាររបស់ទូលព្រះបង្គំគឺព្រះចៅបានបំពេញសព្វគ្រប់ហើយ ។ ទូលព្រះបង្គំនៅសល់ពារមួយទៀត ហៅថាបច្ចិមពារ កាលណាពារនេះសម្រេចហើយ ទូលព្រះបង្គំនឹងទូលរៀបមង្គលការជាមួយនឹងព្រះអង្គជាទៀងប្រាកដ ទូលព្រះបង្គំសូមសន្យាច្បាយ គឺសេចក្តីសន្យាខាងចុងក្រោយបង្អស" ។

ព្រះចៅមានព្រះតម្រាស់សួរថា: "ម្នាលនាវ៉ាមាសបង! ព្រះរាជវង្សន៍ឯងបង សូមតាំងនៅក្រោមបទបញ្ជានៃអូនទាំងអស់ ។ ចូរនាងកុំបង្អង់ឲ្យយូរដល់មួយមោងកង្គកការបញ្ចេញសេចក្តីបំណង ដ្បិតអីដូចនាងឃើញស្រាប់ បងមានចិត្តប្រតិព័ទ្ធលើរូបនាងស្ទើរជាច់ដីវិតកង្គកាលគ្មួរនេះ គ្រាន់តែឃើញក្អែកបេះនាងបែបត្រួយ ខ្លួនបងកើតទុក្ខស្ទើរបាត់ស្មារតីមិនដឹងគិតទៅផ្លូវណា ខ្លួនបងទៅជាមនុស្សល្ងីល្ងើ ដោយសារតែអូនឯង" ។

នាងអ័ឡណា - សិម្យាណា ក្រាបបង្គំទូលស្នងថា: "បើដូច្នេះ, សូមព្រះអង្គយកផ្តិលពរដ៏យមួយ ដែលនៅឯព្រះវិហារតូចជាខាងនាយប្រទេស (ជ្រលងដែន) មក រួចទូលព្រះបង្គំនឹងព្រមធ្វើជាអគ្គមហេសីនៃព្រះអង្គជាពិតប្រាកដ" ។

ព្រះចៅរាជាធិរាជស្តេចទ្រង់ត្រាស់បង្គាប់ឲ្យហៅព្រះអង្គម្ចាស់ហាវហានមកទៀត ហើយទ្រង់បង្គាប់ឲ្យធ្វើដូចម្តេច បំពេញបំណងនៃនាងអ័ឡណា - សិម្យ៉ាណាឲ្យបានហ័សរួសរាន់ទាន់ចិត្ត ។ ព្រះនាងទៅរកសេះមួយរំពេច ។ សុរ្យាបគាក្រាបបង្គំទូលថា: "បពិត្រព្រះនាងជាម្ចាស់! នេះហើយជាបច្ចាមិកិច្ច ហើយជាកិច្ចយ៉ាងក្រៃបំផុត ប៉ុន្តែសូមព្រះនាងមានសេចក្តីទុកចិត្តលើព្រះជាម្ចាស់ យើងជិតផុតទុក្ខហើយ។ ព្រះចៅក៏ស្តេចចង់អស់បុណ្យដែរ" ។ ជនទាំងពីរលៀបប្រជាប់សព្វគ្រប់ រួចនាំគ្នាចេញទៅ ។

សេះដែលដឹងអស់អាថ៌សព្វគ្រប់ និយាយប្រាប់ព្រះនាងពៅថា: "ផ្តិលពរដ៏យនោះស្ថិតនៅលើត្រែកក្នុងកូនព្រះវិហារមួយ នៅក្រោមការព្យាបាលនៃលោកសង្ឃជាច្រើនអង្គដែលមិនសឹងទាំងយប់ទាំងថ្ងៃ ។ ប៉ុន្តែយូរៗ សម្តេចសង្ឃរាជមកទេសនាឲ្យទ្រាំទ្រដល់លោកទាំងនេះម្តងហើយនៅមានតែកិកុមួយអង្គជាអ្នកនៅចាំរក្សាផ្តិល ។ បើប្រសិនយើងទៅដល់ត្រូវចំលើពេលនោះ គឺជាវាសនាល្អរបស់យើង បើមិនដូច្នោះទេ

យើងតោងនៅត្រាំចាំមើល ហើយមិនដឹងជាពេលណាផង ព្រោះមានមធ្យោបាយតែមួយហ្នឹង" ។

អ្នកដំណើរទាំងពីរបានដល់ប្រទេសជួរដែន ឆ្ងងផុតទីនេះទៅ រួចទើបបានដល់កូនព្រះវិហារនោះ ។ ព្រឹងវាសនារបស់ព្រះពជ្ជតីតាធ្វើឲ្យសម្តេចសង្ឃមកដល់មុនព្រះនាងបន្តិច ហើយហៅពួកអ្នកបួសទាំងប៉ុន្មានឲ្យទៅស្តាប់ជម្រឹ ។ កិក្ខុជាអ្នកឆ្នាំផ្តិល អស់កម្លាំងដោយសារចាំយាមយូរពេក ក៏ងងុយសឹង ។ ប៉ុន្តែដោយសេចក្តីប្រយ័ត្ន លោកសឹងទទឹងមាត់ទ្វារ ព្រោះគិតថាគ្មានទណាអាចលួចបាន ។

សុរាបតាត្រាប់ចាយដល់ព្រះអង្គម្ចាស់ក្សត្រី តើត្រូវធ្វើបែបណាដើម្បីលួចយកផ្តិលពរជ័យឲ្យបាន ។ ព្រះនាងពៅទ្រង់យាងសន្សឹមៗរហូតដល់ជញ្ជាំង ហើយដើរចំអើតព្រះបាទ សៀវៗជញ្ជាំងចុះដល់ទ្វារ ។ ខណៈនោះ ព្រះនាងទ្រង់លោតកន្ទុងមាត់ទ្វារហ៊ាសដូចឆ្មាគ្មានទាំងប្រាប់តលោកកិក្ខុដែលកំពុងសឹងស្រមុក កាន់យកផ្តិលត្រឡប់មកវិញ ធ្វើដូចកាលដែលចូលទៅ, ផែលឡើងលើខ្នងសេះ រួចទាញបង្ហើរបំបែរក្បាលព្រះពជ្ជអស្សាចាណ៍បត់រត់ទៅវិញ ។

កិក្ខុភ្ញាក់ឡើងដោយសារសូរសន្ធឹក សុះតើនឡើងដឹងថាចោរក្អាមក៏ស្រែកធោឡោឡើង ។ សំរែកនោះសឹងធ្វើឲ្យរួញប្រមាត់ ។ ពួកលោកសង្ឃដទៃតត់មកឈូឆរជុំគ្នាស្រែកទ្រហោយំ ដោយសេចក្តីទុក

ដែលមកពាល់ត្រូវ ។ ចំណែកសម្តេចសង្ឃរាជជ្រាបថា សេចក្តីអន្តរាយមានដល់ផ្តិលពរដ៏យ៉ាហើយ បែរព្រះភ័ក្ត្រចំពោះទៅទិសដែលព្រះរាជធីតានឹងសុរាបាហោះទៅ, លុតជង្គង់លើកព្រះហស្តទាំងពីរឡើង រួចជាក់បណ្តាសាថា: "បពិត្រព្រះជាម្ចាស់ដ៏ចំរើន! សូមព្រះអង្គធ្វើមនុស្សទុច្ចរិតក្រៅសាសនា ដែលមានចិត្តឃោរឃៅហ៊ានលើកដៃចាប់កាន់យកផ្តិលរបស់ព្រះអង្គនេះ ឲ្យក្លាយកេតជាស្រី បើប្រុស, ហើយឲ្យក្លាយជាប្រុស បើស្រី" ។ ការបន់ស្រន់របស់សម្តេចសង្ឃ ក៏ប៉ានសម្រេចរួសពន់ពាន់ចិត្ត, ព្រះរាជធីតាក្លាយកេតជាមាណពមួយ មានរូបយ៉ាងឆើតឆាយជាទីក្រៃឡែកមើល ។

កាលណាព្រះរាជបុត្រឡើងទៅគាល់ព្រះចៅរាជាធិរាជ ព្រះអង្គទ្រង់ឆ្ងល់ពេកអំពីការផ្លាស់ប្តូរកេតដូច្នេះ ។ ព្រះចៅបែបទ្រង់ជាមិនពាន់ដឿនៅឡើយ ព្រោះអ្នកបំរើព្រះអង្គហាក់ដូចជាប្លែក ព្រមទាំងឮកាន់អាការក្លាហាន មិនដូចពីកាលធ្លាប់ដំណើរចេញទៅ ។

យកផ្តិលពរដ៏យ៉ាហើយ ព្រះអង្គម្ចាស់ហាវហានក្រាបទូលថា: "បពិត្រព្រះចៅដ៏ទ្រង់នូវមហិទ្ធិរិទ្ធិ! ទូលព្រះបង្គំបានបំពេញការៈសព្វគ្រប់ថ្វាយព្រះអង្គហើយ ។ ឥឡូវនេះ ទូលព្រះបង្គំគិតឃើញថា កិច្ចបំរើរបស់ទូលព្រះបង្គំចំពោះព្រះចៅក៏ផុតត្រឹមហ្នឹងហើយ ។ សូមព្រះអង្គប្រកបដោយសេចក្តីសុខ ប្រកបដោយសេចក្តីសប្បាយ ហើយសូមព្រះ

អង្គខ្ញែន់សោយរាជសម្បត្តិជាសន្តិសុខ ឲ្យបានអង្វែងតទៅមុខតាមបំណងនៃសេចក្តីមេត្តានៃព្រះជាម្ចាស់" ។

ព្រះចៅរាជាធិរាជមានព្រះបន្ទូលសួរសីហនាទតបថា: "យើងគ្រែកអរចំពោះកិច្ចចំរើរបស់ចៅជាកៃក្រលែង ។ ចូរចៅចាំចុះថាខាងក្រោយការទិវង្គតរបស់យើង គឺចៅឯងហើយដែលនឹងត្រូវសោយរាជ្យជំនួស ព្រោះយើងទាំងពីរនេះ គ្មានព្រះរាជបុត្រជាទាយាទ ។ បើព្រះជាម្ចាស់ប្រទានឲ្យមួយ ក៏ចៅឯងត្រូវទៅជាដៃស្តាំរបស់យើងដែរ" ។

ព្រះរាជទង្វាយនេះស្តេចខ្ញែន់ធ្វើទៅកណ្តាលពួកសេនាបតី នឹងព្រះរាជបុត្រទាំងប៉ុន្មាននៃស្តេចប្រទេសរាជ ។

នាងអីឡែណា-សិម្ប៉ាណា លុះបានឃើញបច្ចឹមពាររបស់នាងសម្រេចហើយ ទើបសម្រេចក្នុងចិត្តថា "ត្រូវតែបំផ្លាញព្រះចៅចោលចេញព្រោះព្រះអង្គគិតតែពីប្រើព្រះអង្គម្ចាស់ហាវហាន ជាសំឡាញ់របស់នាងឲ្យទៅបំពេញកិច្ចយ៉ាងក្រៃ ប្រកបដោយគ្រោះថ្នាក់ដែលអាចស្លាប់ខ្លួនក៏មាន" ។ នាងគិតតែក្នុងចិត្តថា ចុះហេតុអ្វីក៏ព្រះចៅមិនស្តេចទៅស្វែងរកផ្តិលពរជ័យ ដោយព្រះអង្គឯង? កិច្ចនេះគឺងាយដល់ព្រះអង្គលោកពន់ពេកណាស់ ដ្បិតលោកទាំងមូលស្តាប់បង្គាប់ព្រះអង្គទាំងអស់ ។

នាងអីឡែណា-សិម្ប៉ាណា បង្គាប់ឲ្យមនុស្សយកទឹកដោះសេះទៅកំដៅ ដើម្បីព្រះចៅរាជាធិរាជនឹងព្រះនាងស្រែងជាមួយគ្នា ។ រៀលដែល

ជនទាំងពីរកំពុងឆ្ងូត នាងអ័ឡេណា សម្បាណា ហៅសេះឈ្មោលឲ្យ
ផ្ទុំទឹកដោះឲ្យត្រជាក់ ។ ប៉ុន្តែសេះនោះផ្ទុំឲ្យល់ត្រជាក់ត្រង់កន្ទែងរបស់នាង
ដោយរន្ធច្រមុះម្ខាង, ផ្ទុំនូវឲ្យល់យ៉ាងក្តៅ ត្រង់កន្ទែងរបស់ព្រះចៅ
ដោយរន្ធច្រមុះម្ខាងទៀត ។ ព្រះរាជាក្តៅពេកខាល់តែព្រះអង្គនៃព្រះ
មហាក្សត្រិយ៍ឈួយ ហើយព្រះអង្គក៏ទ្រង់ព្រះសុវណ្ណគតកង្ខណៈនោះ
មួយរំពេច ។

ព្រះរាជទិវង្គតនៃព្រះមហាក្សត្រាធិរាជ ភ្ញាក់ខ្លួនមួយរំពេចពេញ
វង្គាំងមួល ហើយមហាជនមកជាអ្នកអធិកព័ទ្ធផ្សង ។ ដើម្បីធ្វើបុណ្យ
បូជាព្រះសពនៃព្រះចៅ ។ រួចនាងអ័ឡេណា សម្បាណា មានវាចាទៅ
កាន់ព្រះអង្គម្ចាស់ហារហានថា: "តើព្រះអង្គហើយដែលបាននាំទូលព្រះ
បង្គំមកកន្លែងនេះ បាននាំមេសេះទាំងឡាយមកឲ្យទូលព្រះបង្គំ បាន
សម្ងាប់យក្សដែលឆក់ទូលព្រះបង្គំ បានយកផ្តិលពារជ័យមកឲ្យទូលព្រះ
បង្គំ, បើដូច្នេះ តើទ្រង់ហ្នឹងហើយនឹងជាព្រះស្វាមីរបស់ទូលព្រះបង្គំ! ត្រូវ
យើងចុះស្រង់ទឹកដោះជាមួយគ្នា រួចកិច្ចនេះហើយកាលណា យើងនឹង
រៀបអាពាហ៍ពិពាហ៍មង្គលផ្សំផ្គុំគ្នាជាស្វាមីភរិយា" ។

ព្រះអង្គម្ចាស់ហារហាន ទ្រង់មានព្រះរាជឧង្ការឆ្លើយតបថា: "អើ
បើនាងមើលចំលើខ្ញុំនេះហើយ យើងនឹងយកនាងជាមហេសី ។
ប៉ុន្តែកុងកន្ទែងយើង សូមនាងជ្រាបថា: យើងចង់ឲ្យមានឈ្មោលទេ
ជាអ្នករងារ" ។

ជនទាំងពីរមានសេចក្តីព្រមព្រៀងគ្នាកើតហើយ ។ ក៏ចុះស្រង់ទឹកដោះទាំងពីរព្រះអង្គ ។ នាងអ៊ីឡេណា - សិម្ប៉ាណា ហៅសេះឈ្មោលរបស់នាងមកឲ្យផ្ទុំទឹកដោះឲ្យ, ព្រះចៅពាជាធិពជថ្មីហៅសុរ្យាបកាមកឲ្យផ្ទុំដែរ, ម្ន៉ោះហើយសត្វទាំងពីរប្រកួតប្រណាំងនឹងគ្នា ដើម្បីធ្វើឲ្យម្ចាស់រៀងខ្លួនបានសុខស្រួល ។

លុះព្រឹកឡើងអាពហវ៉ាក់ហាមង្គលរាងជនទាំងពីរ ក៏តាំងឡើងជាអ៊ីកអធិក ។ រួចព្រះអង្គម្ចាស់ហាវ៉ាហាន ទ្រង់ស្តេចឡើងសោយរាជសម្បត្តិជាស្តេចចក្រពត្តាធិពជស្នងព្រះចៅពាជាធិពជ ដែលទ្រង់ទិវង្គតហើយ ។ រីឯរៀបមង្គលការតាំងនៅអស់ ៣ សប្តាហ៍ ហើយមនុស្សម្នាប្រជាជនបានសេចក្តីរីករាយដោយសារឥទ្ធិពល នឹងផលបុណ្យបារមីនៃព្រះចៅថ្មីដែលព្រះជាម្ចាស់ប្រទានថ្វាយ ។

ស្តេចទាំងពីរព្រះអង្គ គឺ ស្វាមីនឹងអគ្គមហេសី សោយរាជ្យជាសុខ ប្រកបដោយទសពិធរាជធម៌ ទំនុកបំរុងប្រជាជនដែលកំសត់ទុគ៌តបង្ហាញមធ្យោបាយដែលនាំឲ្យកើតទ្រព្យសម្បត្តិ ហើយមិនដែលធ្វើទុក្ខបុកម្នេញបីជានិទ្ទូវអ្នកណាឡើយ ។

ចប់

រឿងសាមកុក

កណ្ឌទី ១០

ឧកញ៉ាវិបុលរាជសេនា ឆ្លៀត-កន ប្រែរៀបរៀង

(តទៅ)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបានឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ខៅធូដំរាបថា ខ្ញុំបាទឈ្មោះខៅធូកើតនៅស្រុកចៀវកុក, កាលគ្រាកើតពួកចោរដួតកាលលឿងខ្ញុំបាននាំគ្រប់គ្រងទ័ពក្បាលពួកប្រហែល ៥០០ នាក់ រត់មកលាក់ខ្លួនពួននៅក្នុងរូងភ្នំនេះ ហើយឲ្យទ័ពក្បាលពួកជញ្ជូនយកដុំថ្មមកគរទុកនៅមាត់រូងជាច្រើន សម្រាប់តស៊ូនឹងពួកចោរ, លុះមកដល់ថ្ងៃ ១ នោះ ពួកចោរលើកគ្នាមកវាយពួកខ្ញុំបាទ។ បានយកដុំថ្មណាចោលទៅត្រូវពួកចោរស្លាប់គ្រប់ដុំថ្មនោះ, ពួកចោរស្លាប់អន្តរាយជាច្រើន ចោរដែលសល់ពីស្លាប់នោះលើកគ្នាថយទៅវិញអស់, អំណើះពីនោះមក ខ្ញុំបាទនឹងទ័ពក្បាលពួកជាច់ស្បៀងអាហារ, មានចោរ ១ ពួកលើកគ្នាមកឃើញគោខ្ញុំបាទ ទើបយកស្បៀងមកដូរយកគោ ១ នឹម។ ខ្ញុំបាទក៏ព្រមដូរឲ្យ,

លុះចោរនាំយកគោទៅចម្ងាយផ្លូវ ៤១ សិន (២ គី.ម.) គោផ្តើលចោលចូលទៅក្នុងព្រៃ, ខ្ញុំបាទក៏តាមទៅ ហើយចាប់កន្ទុយគោម្ខាង ១ អូសមកដល់មាត់រូងភ្នំ ពួកចោរឃើញខ្ញុំបាទមានកម្លាំងក៏មិនអាចតាមមក ។

ចូរធ្លុតបថា យើងបានភ្ជួលឈ្នួះអ្នកយូរមកហើយ, ការជួបឃើញមុខគ្នាថ្ងៃនេះ ជាបុណ្យភ័ព្វរបស់យើង។ នឹងចិញ្ចឹមក្បាអ្នកទុកជាភាហាន, អ្នកក៏ត្រូវមានចិត្តគិតស្រឡាញ់យើងហើយព្រមធ្វើពដការជាមួយចុះ ។ ខៅធ្លូឆ្លើយថា "ដែលលោកមានប្រសាសន៍មកដូច្នេះ ព្រះគុណធ្ងន់មិនមានទីបំផុត ខ្ញុំបាទសុខចិត្តព្រមចូលនៅធ្វើការជាមួយនឹងលោកតទៅ" ដូច្នេះហើយ ក៏ប្រើពួករបស់ខ្លួនម្នាក់ឲ្យរួលទៅនាំយកគ្រឹប់គ្រួនឹងស្មៅគ្រប់ក្បុកនឹងហោងឹនឹងប័ក្បភ្លុកចោរ ២០០ ជាយ ចេញមកចូលនៅនឹងចូរធ្លូ។ ឃើញដូច្នោះ ក៏មានសេចក្តីត្រេកអរពន់ប្រមាណ ទើបតាំងខៅធ្លូជាមេភាហានឯក (ពាក្យចិនហៅថា តោអ៊ុយ) ហើយឲ្យមាសជាក់គ្រឿងសម្ងៀកបំពាក់ដល់ប័ក្បពួកខៅធ្លូថែមទៀត ។ ឯខ្លួនហោងឹនឹងអ៊ុយសៀវនោះ ចូរធ្លូឲ្យនាំយកទៅសូម្បាប់ចេញ ហើយឲ្យកាត់ក្បាលយកមកដោតទុកនៅមុខបន្ទាយ មិនឲ្យអ្នកឯទៀតយកជាបែបយ៉ាង ។ រួចហើយចូរធ្លូក៏លើកទាហានទៅស្រុកអៀនសៀ ។

ហៃហ្ជុនឮដំណឹងដូច្នេះ ក៏នាំគ្នាចេញមកទទួលចូរធ្លូចូលទៅក្នុងស្រុក ហើយជំរាបចូរធ្លូថាខ្ញុំបាទបានឮកិត្តិស័ព្ទថា លីហងនឹង

ស៊ីឡាន់ ដែលលើកប្តីឲ្យទៅនៅរក្សាស្រុកគុនដីវានោះ ឥឡូវនេះពួកទាហាន អត់ស្បៀងអាហារណាស់ តែងលើកគ្នាចេញទៅរកតស្ពាតវាយដណ្តើមយកទ្រព្យរបស់អាណាប្រជានុរាស្ត្រ, ឯពួកទាហានក្នុងស្រុកនោះក៏មានស្តួចស្តើងដែរ ដូច្នេះសុំឲ្យលោកលើកពលរេហ៍ត្រឡប់ទៅវាយយកស្រុកគុនដីវានោះកំនត់ឯងបានដោយងាយ ។ ចូរឆ្ងាយល់ព្រមតាមក៏លើកទាហានទាំងឡាយទៅវាយយកស្រុកគុនដីវានោះ ។

ឯលីហង់នឹងស៊ីឡាន់ បានឃើញកងទ័ពចូរឆ្លើកទៅព័ទ្ធស្រុកក៏លើកទាហានចេញមកតទល់នឹងទ័ពចូរឆ្ង ទៅឆ្ងឃើញដូច្នោះសុំខ្លួនចេញទៅតទល់យកអាសា ចូរឆ្ងត្រេកអរណាស់ចាត់ទៅឆ្ងឲ្យចេញទៅ ។ ទៅឆ្ងដឹះសេះកំណែនចេញទៅតយុទ្ធនឹងលីហង់បាន ៣ ភ្លេង, យកខ្លួនចាក់លីហង់ធ្លាក់ពីលើសេះស្លាប់ ។ ស៊ីឡាន់ឃើញដូច្នោះមានសេចក្តីភ័យណាស់ ប្រាសគេចខ្លួនទាំពួកទាហានវិលចូលទៅក្នុងកំពែងស្រុកវិញ, ទទួលជួបប្រទះនឹងលីតៀន លើកទាហានស្កាត់ជាប់ពីមុខត្រង់គូកំពែងស្រុក, ស៊ីឡាន់ក៏ញាក់សេះបែរមុខចូលទៅក្នុងវិញ្ញ ។ ទទួលលីយ៉ាយឃើញក៏ដឹះសេះសុះមកស្លាក់ ហើយលើកធ្នូបាញ់ត្រូវស៊ីឡាន់ធ្លាក់ពីលើសេះស្លាប់ ។ កងទ័ពស៊ីឡាន់ក៏បែកបាក់ខ្ចាត់ខ្ចាយអស់ទៅ ។

ខណៈនោះ ចូរឆ្ងក៏វាយយកស្រុកគុនដីវាបាន ហើយឲ្យទៅឆ្ងនឹងតៀនអ៊ុយលើកពលទាហានជាកងមុខ, ឲ្យហៃហ្វុងនឹងហៃហ្វូងអៀន

ជាកង់ស្តាំ, ឲ្យលីតៀនទឹង៉ាក់ដៃនជាកង់ឆ្វេង, ខ្លួនចូឆ្លងឯជាកង់លួង, អ៊ុំកមនឹងលីយ៉ាយជាកង់ក្រោយ លើកទ័ពទៅកាយយកស្រុកចាក់អៀង ។

ឯលីចោ"បានដឹងដូច្នោះ ក៏លើកទាហានចេញមកទល់ទ័ពចូឆ្លូ ។ តាន់កុងហាមលីចោ"ថា ដែលលោកនឹងស្រុតលើកទ័ពចេញទៅនោះ ខ្ញុំបានឃើញការណ៍មិនស្រួល សុំឈប់បង្អង់ចាំពួកទាហានដែលចេញទៅរកស្បៀងអាហារនោះវិលត្រឡប់មកដួបជុំគ្នាសិន សឹមលើកចេញទៅចាំជនឹងចូឆ្លូចុះ ។ លីចោ"តបថា កើតមកជាជាតិទាហានហើយ ឯងត្រូវគោតខ្លាចសឹកសង្គ្រាមធ្វើអ្វី ។ លីចោ"មិនព្រមស្តាប់ពាក្យតាន់កុងរំលឹក ក៏លើកទាហានចេញពីស្រុកទៅ ។ លីចោ"ដឹងសេះកំលួនទៅដល់មុខកង់ទ័ពចូឆ្លូហើយស្រែកប្រកាសថា នរណាមានថ្វីដៃខ្លាំងពូកែតស៊ូនឹងយើងបាន ក៏ឲ្យរៀបខ្លួនចេញមកចុះ ។ ទៅឆ្លូបានឮដូច្នោះខឹងណាស់ បរសេះកំលួនចេញមកប្រយុទ្ធគ្នានឹងលីចោ"បាន ២០ ក្បែង មិនបានចាញ់ឈ្នះគ្នា ។ ចូឆ្លូឃើញថាទៅឆ្លូម្នាក់ឯងយកជ័យដំនះពីលីចោ"មិនបាន ក៏ប្រើតៀនអ៊ុយចេញទៅជួយទៅឆ្លូតនឹងលីចោ"ទៀត ។ ឯហៃហ្គុន, ហៃហ្គូអៀន, ង៉ាក់ដៃននឹងលីតៀនដែលជាកង់ឆ្វេងស្តាំ នាំគ្នាបរសេះចេញទៅចោមព័ទ្ធលីចោ"ជុំវិញ ។ លីចោ"កាប់ឆ្ការពាទំលាយកង់ចំណោមទ័ពគ្រប់មេទាំង ៦ លុះឃើញថាកំឡាំងខ្លួននឹងទប់ទល់ពុំឈ្នះ ក៏ពានបញ្ជះសុំរចេញទៅបាន ហើយវិលចូលទៅដល់កំពែង ។ ឯតៀនស៊ី

ដែលនៅលើសែនបន្ទាយ ឃើញលីប៉ោរត់ត្រឡប់ចូលមកកំបង្គំឲ្យប៉ក្យ ពួកចេញទៅអូសកន្ត្រាក់ស្ពានធ្វើកំពែងនោះឆ្ងាក់អស់ មិនឲ្យលីប៉ោសុះចូលទៅបាន ។ លីប៉ោបរសេះរន្ទាន់ទៅទើនធំមាត់ទ្វារក៏ស្រែកនោះឡាឲ្យគាហានខាងក្នុងលើកស្ពានទទួល ។ តៀនស៊ីឡើយពីក្នុងកំពែងមកវិញថា យើងចូលទៅខាងឆ្ងូចហើយ អ្នកកុំចូលមកស្រុកយើងមិនបានទេ ។ លីប៉ោបានឮច្បាស់ខ្លឹងណាស់ ស្រែកដេរតៀនស៊ីជាពាក្យអាស្រូវគាសផ្រែង ។ ហើយបរសេះនាំគាហានសុះកាត់ត្រឡប់ទៅស្រុកតាន់លីវ ។ គាន់កុងឃើញដូច្នោះ ក៏ន៎ាំគ្រប់គ្រួលីប៉ោរតាមទៅ ។

ចូឆ្ងូក៏លើកកងទ័ពចូលទៅក្នុងស្រុកប៉ាក់អៀងបាន ហើយឲ្យហៅខ្លួនតៀនស៊ីមកនិយាយថា ដែលតៀនស៊ីមានសំបុត្រទៅបញ្ជោតយើងឲ្យលើកទ័ពមកចាញ់ប្រៀបលីប៉ោពីជាន់មុន នោះមានទោសជាធំហ៊ាន់ណាស់; គ្រានេះតៀនស៊ីបានធ្វើសេចក្តីគាប់លុបទោសចាស់ឲ្យមនុស្សអូសកន្ត្រាក់ស្ពានមិនឲ្យលីប៉ោឆ្ងងទៅបាន នេះជាគុណនាំឲ្យលុបទោសអស់ហើយ ។

ឡៅហួនិយាយនឹងចូឆ្ងូថា ដែលលីប៉ោរត់ទៅគ្រានេះ បើលោកនឹងឲ្យលះចោលយូរយើញថា នឹងមានកំម៉ាំងគិតការឡើងវិញបាន ឧបមាដូចយកខ្លាទៅលែងក្នុងព្រៃ យូរទៅនឹងចាប់យកមកវិញដោយលំបាក ។ ចូឆ្ងូស្តាប់ឃើញត្រូវ ទើបចាត់ឲ្យឡៅហួជាមេរក្សាទាហានទៅការពារ

ស្រុកចាំក់អៀង ។ ខ្ញុំបចូឆ្ងល់ប្រមូលសេនាភាហានតូចធំផ្ញុំជាកងទ័ព លើកតាមលីចោ"ទៅស្រុកតាន់លីវ ។

ឯតៀវលៀវ, ចុងចា", ហោសេង, គោស៊ុន ដែលជាសេនាលីចោ"ផ្ញុំនាំភាហានទៅរកស្បៀងអាហារនោះមិនបានដឹងថា លីចោ"បែកទ័ពតែត្រឡប់ទៅស្រុកតាន់លីវសោះ ក៏នាំគ្នាភតភ្លាតរយៈចម្ងាយប្រមាណ ៦០ គីឡូម៉ែត្រ ទៅដល់ស្រុកចាំក់អៀង ជាចលាចល ពួកស្រុកបានសេចក្តីទុក្ខលំបាកណាស់ ។

កាលលីចោ"តេ៉ពីបចូឆ្ងទៅដល់ស្រុកតាន់លីវនោះ លុះដឹងថាបចូឆ្ងលើកទ័ពតាមមក ក៏មិនបានចេញតតាំង សំងំនៅក្នុងកំពែងស្រុក គ្រាន់តែប្រឹក្សាទីតៀវមេ"ជាចៅហ្វាយស្រុក ហើយឲ្យភាហានឡើងយាមល្បាតលើសែនបន្ទាយរាយប្រយ័ត្នការជ្រុំវិញ ។ ឯបចូឆ្ងនោះមិញប្រើសេនាភាហានឲ្យលើកបចូលទៅបោះទ័ពលំនឹងដើងកំពែង ចំនួន ១០ ថ្ងៃមិនឃើញលីចោ"ចេញមកតសោះ ។ ខុតបចូឆ្ងនោះ ក៏ជាប់ស្បៀងអាហារ, ខ្វះខែសការស្រូវគោជន៍សាលីខៀបទទឹងពុំ បចូឆ្ងក៏ប្រមូលផ្ញុំកងទ័ពលើកត្រឡប់ទៅវិញនៅចម្ងាយពីស្រុកនោះប្រហែល ៤.០០ សិន (១៦ គី.ម.) ឲ្យភាហានគាន់កណ្តៀវចុះច្រូតស្រូវគោជន៍សាលីរបស់អ្នកស្រុកពេញស្រែនិមួយៗ ហើយនាំយកមកបុកជានឲ្យភាហានបរិភោគ្តា ។ ខណៈនោះ មានមនុស្សទៅប្តឹងលីចោ"ថា ភាហានបចូឆ្ងជាប់ស្បៀង

អាហារ ថយទ័ពត្រឡប់ទៅច្រូតស្រូវ ។ លីចោ"ក៏នាំទាហានទៅចាប់មនុស្សច្រូតស្រូវ, ទាហានចូធ្លូនោះ លុះឃើញលីចោ"នាំគ្នារត់ចូលបន្ទាយ, លីចោ"បរសេះស្ទុះដេញតាមទៅដល់ទល់នឹងបន្ទាយចូធ្លូ ឃើញខាងធ្វេងផ្លូវមានព្រៃធំ ក៏គិតថារម្ដែកងចូធ្លូបង្កប់ទាហានទៅទីនោះ លីចោ"ក៏ត្រឡប់សេះនាំទាហានចូលកងកំពែងវិញ ។

ចូធ្លូដឹងដូច្នោះ ក៏ប្រឹក្សានឹងសេនាទាហានថា ដែលលីចោ"ចេញមកដេញមនុស្សច្រូតស្រូវ ហើយវិលត្រឡប់ទៅជាច្រញាប់នោះ ច្បៀលគិតថែងថាយើងបង្កប់ទាហានទុកកងព្រៃ ឥឡូវនេះយើងឲ្យយកទង់ជ័យទៅដោតរាយក្នុងព្រៃឲ្យច្រើន ឲ្យទាហានទៅក្នុងបន្ទាយតែ ៥០ នាក់ យើងនឹងទាហានទាំងអស់នាំគ្នាទៅបង្កប់ក្នុងអូរក្រោយបន្ទាយវិញ បើលីចោ"មកឃើញគង់នឹងយកក្ដៅអុជព្រៃឆេះអស់ ហើយចូលហួសទៅក្បែរបន្ទាយឃើញទាហានទាំងឡាយទៅស្ដីង ក៏នឹងលើកចូលទៅរាយយកបន្ទាយនោះ យើងត្រូវឲ្យទាហានរាយគងឃ្មោះនឹងស្គរជាសញ្ញាឲ្យឮខ្ទរខ្ទារឡើង ហើយសឹមលើកទាហានដែលបង្កប់ពីក្រោយចេញព័ទ្ធបណ្ដាយមក ឃើញថានឹងចាប់លីចោ"បានដោយងាយ ។ ទាហានក្នុងកងទ័ពស្ដាប់ឃើញត្រូវ; លុះពេលយប់ជ្រៅ ចូធ្លូក៏ប្រើឲ្យទៅធ្វើតាមដែលគិតទុកនោះគ្រប់ប្រការ ។

លុះពេលព្រឹកភ្លឺស្រាង លីចោ"ប្រឹក្សានឹងគាន់កុងថា ពីមុំលមិញយើងបានទៅដេញចាប់ទាហានចូធ្លូដែលលួចច្រូតស្រូវ យើងដឹងថា

ចូរឲ្យបង្កប់គាហានទៅក្នុងដែលជាច្រើនបានជាត្រឡប់មកវិញ ថ្ងៃនេះយើងនឹងលើកគាហានទាំងអស់ទៅដុតដែល ដែលបង្កប់គាហាននោះឲ្យនេះអស់ ហើយសិមលើកទំពាំងប៉ះព័យយកបន្ទាយចូរឲ្យបាន ។ តាន់កុងយាត់ថា ចូរនោះមានគំនិតគិតក្នុងកលសង្គ្រាមជាច្រើនណាស់, ដែលលោកនឹងលើកទំពាំងចេញទៅប្លាំង ត្រូវតែរកំងមើលកល់ការឲ្យស្រួលបួលសិន ។ លីប៉ោមិនព្រមស្តាប់ពាក្យតាន់កុង ឲ្យតាន់កុងនៅរក្សាស្រុកជាមួយនឹងតៀរមៅ ។ ខ្លួនលីប៉ោឯងលើកគាហានចេញទៅពីស្រុកដល់ទៅព្រៃខាងឆ្វេងផ្លូវ ឃើញទំដំយដោតនៅជាច្រើនក៏គិតថា "ប្រហែលចូរឲ្យគាហាននៅក្នុងព្រៃនោះ" ហើយក៏លើកទំពាយឲ្យប់ដុំវិញពីក្រៅ ហើយឲ្យយកភ្លើងដុតព្រៃនោះនៅឡើងទាំង ៤ ទិស, មិនឃើញមានមនុស្សម្នាក់សោះ ក្រឡេកមើលទៅក្នុងបន្ទាយស្ងាត់ជ្រងំ ទំលើកគាហានចូលទៅ ស្រាប់តែឮសំឡេងឃ្មោះគងចូងកេរី, លីប៉ោតក់ស្លុតឈប់ស្តាប់នៅទីនោះ ស្រាប់តែឮសម្លឹកកងទំពាក្រែកហោក្រែយបន្ទាយ ហើយពាយគាហានព័ទ្ធមក លីប៉ោគ្រាន់តែនបរសេះបួលទៅតយុទ្ធ ស្រាប់តែឮជាវអុជឡើងដុំវិញខ្លួន ។ ហៃហួនុន ហៃហួអៀន ទៅធួ តៀនអ៊ុយ លីតៀនទឹងង៉ាក់ជិន ទាំង ៦ នាក់នេះក៏លើកគាហានឡើងពីកងអូរឈូរចេញមកព័ទ្ធដុំវិញលីប៉ោ។ ក៏ពក្រាប់ជាប់ដៃទំងសងខាង ឃើញកំឡាំងនឹងតាំងតពុំបាន ក៏បង្ខិសចោលគាហានរត់ចេញទៅជាមួយនឹង

សេងកៀម ។ ដាក់ដំនៃ ឃើញដូច្នោះ ក៏បរសេះដេញតាមពីក្រោយ ហើយយិតធ្នូបាញ់ត្រូវសេងកៀម ធ្លាក់ពីលើសេះស្លាប់ ។ ឯពាហន លីប៉ោក៏របួសពិការស្លាប់ជាច្រើន, ដែលសល់នៅប៉ុន្មាន ក៏បំពានរត់យកតែខ្លួនទៅចូលក្នុងកំពែងស្រុកវិញ ហើយយកសេចក្តីនោះប្រាប់តាន់-កុងគ្រប់ប្រការ ។ ឯតាន់កុងក៏ស្តុតរន្ធត់ចិត្តគិតថា "ពាហានក្នុងស្រុកតាន់លីវានេះនៅតិចណាស់ ឃើញថាទឹងតលន់ទឹងកងទ័ពចូឆូមិនបាន" ហើយក៏នាំគ្រប់គ្រលីប៉ោរត់ដោះខ្លួនចេញពីស្រុកនោះទៅ ។

ចំណែកចូឆូ លើកកងទ័ពមកឡប់វាយយកស្រុកតាន់លីវានោះបាន ហើយឲ្យពាហានយកភ្លើងដុតបំផ្លាញផ្ទះសម្បែងអ្នកស្រុកឆេះអស់ ។ តៀវចៀវានោះសុះរត់ទៅមិនពានក៏ស្លាប់ក្នុងភ្លើង ។ ឯតៀវមេ៉ាចៅហ្វាយស្រុកនោះក៏រត់ទៅទៅទឹងអ៊ីនសុតចៅហ្វាយស្រុកឡាំយ៉ុង; អស់បណ្តាពស្តូដែលនៅក្នុងស្រុកតាន់លីវាទាំងប៉ុន្មាន បាននាំគ្នាចុះចូលទៅនៅជាពួកមាក របស់ចូឆូទាំងអស់ ។ ឯចូឆូនោះក៏ត្រឡប់បានជាធំ ក្នុងអាណាខែត្រទិសបូពាជាច្រើនតំបន់ ហើយឲ្យតែងតាំងធ្វើបន្ទាយរាយតកំពែងដីកគូអូរស្នាមក្លោះ ទុកគ្រប់ចន្លោះខែត្រនីមួយៗ ហើយឲ្យហ្វឹកហាត់សេនាពាហានបានជាច្រើន ។

ឯលីប៉ោរត់ទៅដល់កណ្តាលផ្លូវ ឧស្ថលដួបប្រទះនឹងតៀវលៀវ ចុង-ប៉ា ហោសេង នឹងគោស៊ុន ដែលលើកទៅរកស្បៀងអាហារ តាំងពីគ្រា

ដែលនៅក្នុងស្រុកប៉ាក់អៀងនោះ ។ លីប៉ោពណិនាពាយរឿងប្រាប់មិនទាន់ចប់ពាក្យ ឯាកទៅឃើញតាន់កុងនាំគ្រប់គ្រងតាមទៅទាន់ លីប៉ោក៏បានអន់ស្រាកកំហឹងទុក្ខព្រួយ ហើយនាំគ្រប់គ្រងទឹងសេនាឥហានទៅតាំងបន្ទាយនៅក្បែរមាត់ទន្លេដែនស្រុកតាន់លីវ ហើយប្រកាន់ទឹងតាន់កុងទឹងសេនាឥហានតាំង ៤ នាយថា យើងបែកទ័ពនឹងចូឡូតមកគ្រានេះមិនត្រូវគិតកេតញើតញើតរាំទៅទេ ត្រូវគិតធ្វើតរកឧបាយនឹងលើកទ័ពត្រឡប់ទៅចាំងនឹងចូឡូ យកស្រុកយើងវិញឲ្យបាន ។

តាន់កុងឃាត់ថា ឥឡូវនេះចូឡូមានឥហានរហ័ពលជាច្រើនណាស់, ខាងអាណាខែត្របូព៌ាទិស នៅក្នុងអំណាចត្រួតត្រាពួកការរបស់ចូឡូទាំងអស់; ឥហានរបស់យើងក៏មានតិចណាស់ មិនឆ្លងការហើយកំពុងហត់ទៀយ, ដែលលោកនឹងបង្ខំលើកទៅតាំងចាំងការយកដោយរហ័ស មិនមែនបានដោយងាយទេ ត្រូវតែនាំគ្រប់គ្រងទៅរកទីសំណាក់អាស្រ័យឲ្យមាំមួនសិន រួចសឹមគិតការតទៅ ។ លីប៉ោស្តាប់ឃើញត្រូវក៏សួរតាន់កុងថា បើយើងនឹងនាំគ្រប់គ្រងទៅពឹងពាក់សំណាក់នៅទឹងអ្នងសៀវហ្វាយស្រុកគីជីវ អ្នកនឹងឃើញយ៉ាងដូចម្តេច? ។ តាន់កុងឆ្លើយថា ដែលលោកគិតនោះគួរហើយ តែសុំឲ្យចាត់បំរើទៅស៊ើបស្តាប់កិត្តិស័ព្ទអ្នកស្រុកគីជីវឲ្យដឹងសិន ជាអ្នងសៀវនឹងព្រមឲ្យយើងនៅដែរឬទេ? ។ លីប៉ោក៏យល់ព្រម ទើបចាត់បំរើឲ្យចេញទៅស្រុកគីជីវ ។

ឯអ្នកសៀវចៅហ្វាយស្រុកគឺដីវគាំងពីព្នកិត្តិស័ព្ទថា ចូរចូនឆីលីចោ" ច្បាំងគ្នានៅស្រុកចា"កអៀង ទើបប្រឹក្សានឹងសុឹមផួយថា លីចោ"នឹងចូរច្បាំងគ្នាគ្រានេះ បើខាងលីចោ"ឈ្នះចូរ តើអ្នកនឹងយល់ឃើញយ៉ាងម្តេច ? ។ សុឹមផួយឆ្លើយថា ឯសន្តានចិត្តលីចោ"នោះជាមនុស្សកាចសាហាវដូចខ្លា បើបានស្រុកចា"កអៀងហើយ គង់នឹងភ័រើបចិត្តគិតកន្ទុងមកវាយយកស្រុកយើងទៀតមិនខាន សូមឲ្យលោកកេណ្ឌខាហាន ៥ ម៉ឺន លើកទៅជួយចូរច្បាំងសម្លាប់លីចោ"ចេញឲ្យបាន ទើបស្រុកយើងនឹងបានសេចក្តីសុខ ។ អ្នកសៀវយល់ត្រូវ ក៏ឲ្យងា"ន់លៀងលើកខាហាន ៥ ហ្មឺនទៅជួយចូរ ។

ខណៈនោះបំរើលីចោ" ដែលទៅស៊ើបស័ព្ទស្តាប់ដំណឹងឯស្រុកគឺដីវនោះ ទើបនឹងទៅដល់ពាក់កណ្តាលផ្លូវបានដឹងព្នដូច្នោះ ក៏នាំសេចក្តីនោះវិលមកថ្វាយលីចោ"វិញថា ឥឡូវនេះអ្នកសៀវឲ្យងា"ន់លៀងនាំខាហានទៅជួយចូរច្បាំងតនឹងលោកហើយ ។ លីចោ"ព្នដូច្នោះ ក៏ភ័យណាស់ សួរគាន់កុងថា បើអ្នកសៀវជាចិត្តមួយនឹងចូរហើយ តើយើងនឹងគិតយ៉ាងម្តេច ? ។ គាន់កុងថា ខ្ញុំបានព្នដំណឹងច្បាស់ថា តោកៀមលើកស្រុកឈើដីវឲ្យទៅពីធ្លើចៅហ្វាយស្រុកហើយ ទៅពីនោះជាមនុស្សចិត្តល្អធ្លូវខ្លួលាយពេះពាយរាប់អានអ្នកទាំងព្នងណាស់ សូមលោកនាំគ្រប់គ្រួ ទៅអាស្រ័យនៅនឹងទៅពីកងក្រុងឈើដីវចុះ ម្យ៉ាងជា

ខ្មៅតិមិនសូន្យផ្លូវមេត្រីនឹងលោកទេ ។ លីចោ"យល់ត្រូវក៏នាំគ្រប់គ្នា
ទៅរកខ្មៅតិ លុះចូលទៅដល់ស្រុកឈើដីវហើយ ក៏ឲ្យបំរើចូលទៅ
ជំរាបខ្មៅតិថា លីចោ"នឹងសូមមកសំណាក់តិងពាក់នៅនឹងលោកតទៅ ។

ខ្មៅតិប្រឹក្សានឹងបីតុកថា លីចោ"បារម្ភនឹងដៃចូរ្ច ឥឡូវនេះវត់
មកតិតិងនៅនឹងយើង ។ ត្រូវតែចេញទៅទទួលឲ្យចូលមកក្នុងស្រុក ។
បីតុកឆ្លើយថា សន្តានចិត្តលីចោ"នោះខុរយសំណាចការសាហាវដូចខ្លា,
ឥឡូវនេះខ្លួនវាដូចខ្លាធ្លាក់អណ្តូង បើលោកនឹងយោងលើកយកមកឲ្យ
ចំណីផ្តាំង លុះវាមានកម្លាំងការណានឹងទំពាក្បាលយើងវិញ ។
ខ្មៅតិតបថា ចូរ្ចនោះក៏ជាមនុស្សការចចិត្តអាក្រក់ ឥឡូវនេះបានជាធំ
ត្រួតលើអាណាខ្មែរខាងទិសបូរ្ចាំងអស់ បើលីចោ"វាយយកបានស្រុក
គុនដីវិញ ស្រុកយើងក៏គង់នឹងបានសេចក្តីសុខផង ចូរ្ចក៏មិនអាច
រំលងមកវាយស្រុកយើងទេ ឥឡូវនេះ លីចោ"បានជាបែរមុខមករកយើង
ហើយ បើយើងព្រងើយកន្តើយក៏ដូចគ្មានមេត្តាសោះ ។ តៀវហ៊ុយ
ឆ្លើយថា ចិត្តរបស់លោកវាមែងធូរទូលាយរោះរាយរាប់អានមនុស្សទាំង
វៀចទាំងត្រង់ បើលោកនឹងចង់ទទួលយកលីចោ"មកទុកក៏តាមអធ្យាស្រ័យ
លោកចុះ តែឲ្យគិតរវាំងហេតុផលឲ្យល្អ ។

ខ្មៅតិក៏នាំកូនអូ តៀវហ៊ុយ នឹងទាហានទាំងពួង ចេញមកទទួល
លីចោ" ចម្ងាយផ្លូវប្រហែល ៣០០ សិន (១២ គី.ម.) ហើយនាំត្រឡប់

ចូលមកក្នុងស្រុក រួចអញ្ជើញលីប៉ោ"ឲ្យអង្គុយក្នុងទីសមគួរ ។ លីប៉ោ" កំពុងនិយាយប្រាប្រឿងឲ្យខ្ញុំស្តាប់គ្រប់ប្រការថា ពីដើមអង់អ៊ុនទន់ខ្លួនខ្ញុំគិតគ្នាប្រាថ្នាសម្លាប់តាំងតុ:ដែលជាសត្រូវពុំសម្បត្តិ ក៏បានដូចចិត្ត, លុះលើឈុយគុយតីបានជាធំឡើង ក៏ឲ្យរកឧបាយទន់សម្លាប់ខ្ញុំវិញ ខ្ញុំបានដឹងការណ៍ខាន់ក៏រត់ចេញពីទីក្រុងមក បានទៅរកទីពឹងនៅជាច្រើនតំបន់ ក៏មិនសម្រេចតាមប្រាថ្នា លុះខ្ញុំបានទៅនៅនឹងតៀវមៅ"ចៅហ្វាយស្រុកគាន់លីរវៀលាណា ចូរគ្រប់លើកទ័ពតាមព្យាបាទទៅវាយយកស្រុកនោះបាន ខ្ញុំបានស៊ើបដឹងថា លោកលើកទ័ពមកជួយគោកៀម ខ្ញុំក៏មានសេចក្តីត្រេកអរ បានជារលើកទ័ពទៅវាយយកស្រុកគុនជីវឲ្យជាកង្វល់ដើម្បីនឹងជួយផ្តល់កុំឲ្យមានរវល់ដល់ស្រុកបានឡើយ គ្រានេះខ្ញុំក៏បានបែកទ័ពចេញជំយឹនឹងចូរគ្នាមកទៀត ខ្ញុំចរាតចាហានក៏ច្រើន បានជាចូលមកទីពឹងអាស្រ័យនឹងលោក ដើម្បីនឹងឈប់សំណាក់ កាលណាស្រួយធូរ ក៏នឹងគិតការធំតទៅទៀត តែថាឥឡូវនេះខ្ញុំមិនខាន់បានដឹងច្បាស់ជាចិត្តលោកព្រមរួមគិតគំនិតមួយនឹងខ្ញុំដែរឬទេ? ។

ឡៅពីតបថា "គោកៀមអនិច្ចកម្មទៅ ស្រុកឈីជីវក៏នៅលើដៃខ្ញុំ ខាន់កាប់រក្សាបណ្តោះអាសន្ន ព្រោះនឹងរកអ្នកឯណាចេះដឹងគ្រាន់ឲ្យធ្វើជំនួសមិនបាន, ឥឡូវនេះ អ្នកមកដល់ទីហានេះក៏សមគួរនឹងធ្វើការពារជាការបាន ខ្ញុំក៏មានសេចក្តីត្រេកអរនឹងលើកស្រុកឈីជីវនេះ ឲ្យអ្នកធ្វើជាចៅហ្វាយ

ស្រុកចុះ ថាហើយក៏លើកគ្រាសមាប់ដាវនោះឲ្យលីហ៊ោ។ កំរើកដៃនឹងទទួលយកគ្រា តែចោលភ្នែកទៅឃើញកួនអ៊ូ តៀវហ៊ុយ ដែលឈរក្រោយទៀតពីបែបទឹងសំបុ លីហ៊ោ ធ្វើជាសើចហើយធ្វើយថា ខ្ញុំទ្បើតមែតែឪពុកមានទឹងទទួលនិយាយការវៃត្រង់ណាតែម្តង ឃើញលើសសតិប្បញ្ញាណាស់ ។

តាន់កុងបានឮដូច្នោះក៏និយាយថា ធម្មតាជាភ្ញៀវមករកលោកជាម្ចាស់ផ្ទះ ណាឡើយនឹងបានរួតរះរើសយករបស់ទ្បើយទៅជាមួយផងនោះក៏ជាសេចក្តីមិនគួរទេ, ឯកូនលីហ៊ោដែលមកសុំសំណាក់នៅនឹងលោកនេះ នឹងបានតាំងចិត្តគិតដណ្តើមយកស្រុកក៏ទេ លោកមិនត្រូវសង្ស័យអ្វីឡើយ ។ ទៀតពីស្តាប់ហើយក៏រៀបលៀងអាហារ អញ្ជើញលីហ៊ោនឹងសេនាបរិវារ ហើយចាត់ចែងទីលំនៅឲ្យលីហ៊ោសំណាក់ ។ លុះព្រឹកឡើងលីហ៊ោរៀបលៀងអាហារ អញ្ជើញទៀតពី កួនអ៊ូ តៀវហ៊ុយទៅបរិភោគវិញ លុះបរិភោគរួចក៏អញ្ជើញទៀតពីទៅខាងកុង ។ កួនអ៊ូ តៀវហ៊ុយតាមទៅជាមួយ ។ ពេលនោះលីហ៊ោឲ្យបុត្រកំរិយាចេញមកគំនាប់ទៀតពីៗ រឹងខ្លួនក៏ហាមឃាត់ថា កុំឲ្យគំនាប់ឡើយ ។ លីហ៊ោនិយាយថា លោកឪពុនកុំព្រួយនឹងយើងដែលឲ្យកំរិយាបុត្រគំនាប់នេះ ។

តៀវហ៊ុយបានឮដូច្នោះក៏ទឹងញ័រ ស្រែកកំទរថាខ្លួនឯងហេតុម្តេចបានជាហ៊ានហៅបងអញថាឪពុន បងអញគេញាតូចព្រះពជវង្ស ឧបមា

ដូចដើមឈើស្វឹកមាស, ដែលខ្លួនអួតអាងថាខ្លាំងពូកែនោះ ចូរវៀបខ្លួនចេញទៅល្បងថ្លៃដៃមើលចុះ ។

ខ្លាតបែរទៅនិយាយឃាត់តៀវហ៊ុយដាប្រញាប់. កួនអ៊ីក៏ចាប់ដឹកដៃតៀវហ៊ុយចេញមកក្រៅ ។ ខ្លាតនិយាយនឹងលីចោ"ថា ដែលតៀវហ៊ុយនិយាយទ្រគោះឲ្យអ្នកអម្បាញ់មិញនេះ ព្រោះសេតសុភស្រវឹងខ្លាំងណាស់ យើងសុំសំពះកុំឲ្យយកទោសឡើយ ។ លីចោ"គ្រវីក្បាលហើយមិនឆ្លើយសោះ ។ ខ្លាតក៏លាលីចោ"ទៅវិញ លុះទៅដល់កណ្តាលផ្លូវតៀវហ៊ុយ . ក៏បរសេះវេះត្រឡប់ទៅដល់មុខផ្ទះលីចោ"ហើយស្រែកថា អម្បាញ់មិញអញខ្វាចបងអញទេ ឥឡូវនេះបងអញទៅហើយ ឲ្យលីចោ"ចេញមកធាប់នឹងល្បងថ្លៃដៃគ្នាមើលបាន ២-៣ ក្លេង ។ ខ្លាតក្រឡេកមកក្រោយមិនឃើញតៀវហ៊ុយ ក៏ឲ្យកួនអ៊ីតាម់ទៅហៅយកខ្លួនតៀវហ៊ុយមកវិញ ។

លុះវេលាត្រឹកឡើង លីចោ"ទៅនិយាយនឹងខ្លាតីថា ពីដើមខ្ញុំមកសុំអាស្រ័យនៅនឹងលោកៗ ក៏ព្រមឲ្យនៅហើយ តែឥឡូវនេះតៀវហ៊ុយបួនលោកនោះទៅនិយាយពាក្យអាក្រក់មើលងាយខ្ញុំខ្លាំងណាស់ ខ្ញុំនឹងនៅតទៅក៏គង់នឹងមានទាស់ចិត្តលោក បើដូច្នេះខ្ញុំនឹងលាលោកទៅរកទីដទៃនៅវិញចុះ ។

(មានត)

ភាគទី ២

សម័យនគរធំ

ឧកញ៉ាទេពពិទូរ ឈឹម - ក្រសេម រៀបរៀង

(ត្រួច)

ប្រវត្តិជាតិថៃ (សៀម)

ប្រវត្តិជាតិថៃនោះ មានអ្នកប្រាជ្ញជាតិថៃក្នុងបច្ចុប្បន្ន ជាន់ស្រាវជ្រាវ នឹង រៀបរៀងទុកជាច្រើនបែប - ច្រើនច្បាប់ ដូចយ៉ាង:

១- រឿងប្រវត្តិថៃ ដែលសម្តេចក្រុមព្រះយ៉ាំងជាវរាជានុភាព ទ្រង់និពន្ធរួមនៅក្នុងព្រះរាជពង្សាវតារ ច្បាប់ព្រះរាជហត្ថលេខា ទំព័រ ៥៧ ។

២- រឿងប្រវត្តិសាស្ត្រសាកល ភាគទី ១ របស់ហ្វូងវិចិត្រវាទការ ។

៣- ប្រជុំសិលាចារឹកស្យាម សម័យក្រុងសុខោទ័យ ភាគ ១ ដែលលោកសាស្ត្រាចារ្យ ហ្ស៊ីក្លូដេសរួបរួម ខ្មែរ រៀបរៀង ចោះពុម្ព ជាភាសាថៃក្នុងឆ្នាំជូត ព. ស. ២៤៦៧ ។ ល ។

លំដាប់នេះ ខ្មែរពណ៌នាប្រវត្តិជាតិថៃ ឬហៅថា សៀម ដោយសង្ខេប ។ តាមប្រាកដនៅក្នុងរឿងព្រះដែលចេញឈ្មោះមកខាងលើនេះថា ជាតិថៃដើមឡើយបានតាំងឥស្សរភាពនៅក្នុងប្រទេសហ៊ុនណាំ

ប្តូយុណាន នៅកង់ដែនចិនភាគខាងត្បូង ដែលឥឡូវនេះធ្លាក់ទៅជា
របស់ចិនអស់ហើយ ។

ប្រមាណតាំងពី ព. ស. ១៩០០ មក ជាតិថៃបានត្រូវជាតិចិនរុក
រានជាយ៉ាងខ្លាំង ហើយញឹកៗ ណាស់ផង ក្នុងទីបំផុតប្រទេសថៃក៏ធ្លាក់
ទៅជាសម្បត្តិរបស់ចិនដរាបដល់សព្វថ្ងៃនេះ ។ ដោយហេតុត្រូវគេរុករាន
យ៉ាងនេះ កាលពេលនោះៗ មានជនជាតិថៃភាគខ្លះ ក៏នៅក្នុងប្រទេស
របស់ខ្លួនពុំបាន ក៏នាំគ្នាចុះមកអាស្រ័យនៅក្នុងប្រទេសបែកខាងត្បូងជា
ច្រើនលើក ច្រើនដង ដរាបដល់ ព. ស. ១៧០០, ពោលដោយចំពោះ
តែចុះមកអាស្រ័យនៅ តាមជាយព្រះរាជអាណាចក្រកម្ពុជាភាគខាងលើ
រៀងទៅដល់កង់ដែនមុន ។ គ្រាដែលពួកថៃមកអាស្រ័យក្នុងប្រទេស
កម្ពុជានេះ ព្រះមហាក្សត្រិយ៍ខ្មែរទ្រង់ព្រះមេត្តាប្រោសឲ្យនៅដោយ
ស្រួល តែនៅកង់ហាន:ជាចំណុះខ្មែរ គ្មានអំណាចអ្វីក្នុងផ្នែកគ្រប់គ្រងទេ
គ្រាន់តែកង់តំបន់ណាមានជនជាតិថៃច្រើន រដ្ឋាភិបាលក៏តាំងថៃ ១ នាក់
ជាមេឲ្យត្រួតត្រាគ្នាឯងក្នុងតំបន់នោះ ទំនងដូចដែលរាជការតាំងមេចិនក្នុង
បច្ចុប្បន្ន ។ ការគ្រប់គ្រងរបស់ខ្មែរកង់សម័យនោះ ប្រព្រឹត្តទៅយ៉ាងធូរៗ
គ្មានការបៀតបៀនប្លន់បាន់អ្វីឡើយ ។ ពួកថៃដែលមកនៅក្នុងប្រទេស
ខ្មែរ បានទទួលយកនូវអារ្យធម៌ធំវឌ្ឍនភាពអំពីខ្មែរ គ្រប់មុខគ្រប់យ៉ាង
មានអក្សរសាស្ត្រ លក្ខិណៈខ្មែរ ទំនៀមទំលាប់ សាសនាជាដើម ។

លុះមកដល់កន្លែងរដ្ឋការ ព្រះបាទជយវរ្ម័នទី ៦ នៃប្រទេសកម្ពុជា ដែលសោយរាជ្យក្នុងរវាង ព. ស. ១៦៧២ ដល់ ១៦៩០ មានជាតិថៃ ១ នាក់ឈ្មោះ ពង្គ្រាជ ដែលក្នុងប្រវត្តិថៃថាជាតិជាក្សត្រិយ៍ បានផ្តើមតាំងឥស្សរភាពឡើងនៅស្រុកលានណា សឹងនៅកន្លែងសង្កាត់អាណានិគមរបស់ខ្មែរ ។ កាលព្រះបាទជយវរ្ម័នទី ៦ ទ្រង់ជាបរឿងនោះ កំត្រាស់ឲ្យលើកកងទ័ពតូចទៅកំចាយចេញ ក្នុងឆ្នាំ ព. ស. ១៦៤០, ព្រះពង្គ្រាជមិនហានតស៊ូក៏រត់ចូលព្រៃបាត់ទៅ ស្រុកនោះក៏ត្រឡប់មកជាអាណានិគមខ្មែរដូចដើមវិញ ។

រយៈពេលតមក ក្នុងរដ្ឋការ ព្រះបាទធរណីន្ទ្រវរ្ម័នទី ២ ប្រទេសកម្ពុជា មានសង្គ្រាមកើតឡើងក្នុងខាងក្នុង ព្រះនគរ ដោយមានក្សត្រិយ៍ទឹងក្សត្រិយ៍ដណ្តើមរាជបល្ល័ង្ក ។ ក្នុងពេលនោះ ព្រះសូរ្យវរ្ម័នសិង ជាព្រះរាជវង្ស ១ អង្គ យើញក្សត្រិយ៍ទឹងក្សត្រិយ៍ដណ្តើមរាជបល្ល័ង្កគ្នាដូច្នោះ ទ្រង់ព្រះចិន្តាថា តែកាលណាមានសង្គ្រាមក្នុងប្រទេស តែងតែមានសឹកពីប្រទេសក្រៅលើកមករាយដួនចែមទៀត យ៉ាងហោចណាស់ក៏គង់មានស្រុកអាណានិគមបណ្តាលបះបោរឡើង ព្រោះដូច្នោះ ទើបទ្រង់រួបរួមកងទ័ពលើកទៅកម្ចាត់ក្សត្រិយ៍អ្នកវិវាទគ្នាឲ្យរាបទាបទៅ ហើយទ្រង់ឡើងគ្រងរាជបល្ល័ង្កមានព្រះបរមនាមថា ព្រះបាទសូរ្យវរ្ម័នទី ២(១) ក្នុង ព. ស. ១៦៥៦ - ១៦៨៨ ។

---

១ ជាក្សត្រិយ៍រាជធិរាជ ដែលសាងប្រាសាទនគរវត្ត តែក្សត្រិយ៍ដែលពាក្យសាមញ្ញហៅថា ព្រះបទុមសុរិយវង្ស ។

ក្នុងពេលដែលមានការណ៍ចះចោរក្នុងព្រៃនគរនោះ ព្រះត្រពាំងជានុរសរបស់ព្រះពង្គាជ ឃើញថានុកាស កំរួចរួមរៀបពលលើកមកវាយដណ្តើមយកស្រុកលានណាអំពីខ្មែរ ជំនួសព្រះបិតាដែលរត់ចូលព្រៃទៅនោះ វាយបានស្រុកហ្វាង-ដៀងវ៉ាយ ស្រុកពានឬផាន ស្រុកពយ៉ា ស្រុកងាំវ លំបាង នឹងស្រែថើន (សឹងនៅក្នុងមណ្ឌលភាយ័ព្យរបស់ថៃសព្វថ្ងៃនេះ) មកនៅក្នុងកណ្តាប់ដៃរបស់ខ្លួន មិនតឹមតែប៉ុណ្ណោះ បានលើកទ័ពមកវុកពានរដ្ឋដលៀង (កំពែងពេជ្រ) ទៀត ។

កាលព្រះបាទសូរ្យវរ្ម័នទី ២ ដែលជាក្សត្រិយ៍សឹកបានឡើងសោយរាជ្យហើយ ទ្រង់បានលើកទ័ពទៅកម្ចាបប្រទេសកៅដីប្រទេសចម្ប៉ានឹងរដ្ឋលានណានេះ ឲ្យរាបទាប នៅត្រាមតទ្ធិពលខ្មែរដូចដើមវិញ ដូចមានសំដែងហើយក្នុងព្រះរាជពង្សាវតារ ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ២ ស្រាប់ ។

បែបាទទ្វូលស្តាបនាជាប្រទេសរាជ

កន្ទងមកដល់ ព. ស. ១. ៨០០ ក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី ៨ នៃប្រទេសកម្ពុជា មានសេចក្តីប្រាកដនៅសិលាចារឹកក្រុងសុខោទ័យ ។

អំពីនេះ នឹងពណ៌នាទៅតាមន័យនៃសិលាចារឹកនោះ ក្នុងឆ្នាំ ព. ស. ១.៨០០ ព្រះមហាក្សត្រិយ៍ខ្មែរ (គឺព្រះបាទជយវរ្ម័នទី ៨) ទ្រង់

ប៉ាន់ស្មាបនាក្យត្រៃយ៍ថៃ ព្រះនាម «ផាមឿង» ថៃហៅថា ឃុនផាមឿង(១) ឲ្យគ្រងក្រុងសុខោទ័យ កន្លងបាន:ជាប្រទេសពាជរបស់កម្ពុជា, ទ្រង់ព្រះពាជទានឧទ្ទិសនាមថា «កម្រតេង្គអញ្ជើសឥន្ទ្របតិន្ទ្រាទិត្យ» (ហៅខ្លីថា ស្រីឥន្ទ្រាទិត្យ) នឹង ព្រះពាជទានព្រះពាជធីតា ព្រះនាមព្រះនាង៍សីវរមហាទេវី ឲ្យជាមហេសីរបស់ឃុនផាមឿង ។

ឃុនផាមឿងនេះ ជាបុត្រឃុនស្រីណាវ ។ ឃុនផាមឿង ក៏គឺបុរសដែលខ្មែរហៅថាពញាពេង, ថៃហៅ ព្រះរួង ។ កាលដែលតាំង៍ឃុនផាមឿងជាស្តេចគ្រប់គ្រងក្រុងសុខោទ័យនោះ ប៉ានទ្រង់ព្រះមេត្តាប្រោសឲ្យមន្ត្រីខ្មែរអ្នកធំ ឈ្មោះខ្ញុំញាលំពង់ ដែលធ្លាប់គ្រប់គ្រងក្រុងសុខោទ័យមកមុននេះ នៅធ្វើពាជការអមព្រះស្រីឥន្ទ្របតិន្ទ្រាទិត្យផង ។

ការដែលព្រះប៉ានជយវរ្ម័នទី ៨ ទ្រង់ព្រះមេត្តាប្រោសតាំង៍ឃុនផាមឿងជាប្រទេសពាជគ្រានេះ ដោយទ្រង់ឃើញថាជាតិថៃមកជ្រកនៅក្រោមព្រះបរមពោធិសម្ភារក៏ច្រើនសតវត្សហើយ, ចំពោះរូបឃុនផាមឿងប៉ានធ្វើជាមេគ្រប់គ្រងជាតិថៃដោយសេចក្តីស្មាមីភក្តិ. មិនដែលមានផ្ទុលរមាស់, ព្រះពាជទើបទ្រង់ព្រះមេត្តាប្រោសតាំង៍ជាស្តេចគ្រាញ់ ១ ក្នុងព្រះពាជអាណាចក្រ ។ ការតាំង៍គ្រានេះជាហេតុឲ្យជាតិថៃប៉ានឥស្សរភាពជាឯកពាជ្យក្នុងអនាគតមិនយូរប៉ុន្មាន លុះមកដល់ប្រមាណ ព ស. ១៨២០

---

១ ក្នុងសម័យសុខោទ័យ ថៃហៅស្តេចផែនដី ថា ឃុន, មកដល់សម័យ ស្រីអយុធ្យា ហៅថា ពញា ។

ឃុនកមកំហែងជានុរសព្រះស្រីឥន្ទ្រាទិត្យ (ពញាភេង) ឬនសោយរាជ្យ
នៅសុខោទ័យជារដ្ឋការលទី ៣ ឬនដកខ្លួនចេញពីអំណាចគ្រប់គ្រងរបស់
ខ្មែរស្រឡះ ឡើងជាឯករាជ្យតេញទី នៅក្នុងព្រះរាជអាណាចក្រខ្មែរ ។
ព្រោះក្នុងសម័យនោះ ជាតិថៃកំពុងប្រឹងប្រែងតស៊ូដើម្បីឯករាជ្យយ៉ាង
ខ្លាំង ។ ចំណែកព្រះមហាក្សត្រិយ៍ខ្មែរ រាប់តាំងពីព្រះបាទជយវរ្ម័នទី ៨
មកចេះតែថយព្រះតេជានុភាពដោយលំដាប់ ។ ព្រះចៅរាមកំហែងនេះជា
អ្នកមានថ្វីដៃក្នុងការសង្គ្រាម ទើបអាចតាំងឯករាជ្យឡើងបាន ។ ថែមទាំង
ក្នុងសម័យនោះ មានក្សត្រិយ៍ថៃ ២ អង្គទៀត នៅយោនកដៀងសែន
ក៏ឬនផ្តើមតាំងសាងខ្លួនឡើងដែរ គឺមួយអង្គព្រះនាម "ព្រះចៅ ង៉ាំមឿង"
តាំងរាជធានីនៅមឿងពយៅ (គឺស្រុកពយៅក្នុងកាលឥឡូវនេះ) ។ មួយ
អង្គទៀតព្រះនាម "ព្រះចៅ មេងរ៉ាយ" តាំងរាជធានីនៅមឿងធើនយ៉ាង
នៅខាងលើស្រុកដៀងសែនបន្តិច ។ រាប់តាំងព្រះចៅរាមកំហែង រួមជា
៣ អង្គ ។ ស្តេចទាំង ៣ អង្គនេះជាមិត្តផងគ្នា ។

ក្នុងគ្រានោះ បែកខាងព្រះចៅមេងរ៉ាយរួបរួមរៀបចំពលឬនសមគួរ
ហើយ ក៏លើកទៅតាំងរាជធានីថ្មី នៅដៀងរ៉ាយ ការឃើញថា គ្មាន
អ្នកណាមករុករានបៀតបៀនទេ ក៏រួបរួមរៀបចំពលជាថ្មីទៀត លើក
កាត់ដែនព្រះចៅង៉ាំមឿងចុះមកខាងនិរតី មកឬននគរទេលាង្គនិងនគរ
លំផាង (សឹងជាទីក្រុងចាស់ ដែលព្រះរាជនុរសរបស់ព្រះនាងចាមទើ

ក្សត្រិយ៍ខ្មែរមានសាងទុកពីយូរមកហើយ) ដោយគ្មានអ្នកណាតស៊ូផង, កាលបាននគរតាំងពីនេះក៏រួបរួមកងទ័ពបានចំនួនជាងមុន ហើយលើកមកវាយនគរហរិកុញ្ជ័យ ដែលក្នុងវេលានោះមានក្សត្រិយ៍ខ្មែរជាព្រះពជវង្ស ខាងព្រះនាងចាមទេវី ព្រះនាមបាញ្ញាពជ នៅគ្រប់គ្រង ។ ព្រះអគ្គបាញ្ញាពជ បែហែលជាមិនសូវមានឥទ្ធិពលនឹងគ្នានការតស៊ូឲ្យមុឺងម៉ាត់ទេ ទើបព្រះចៅមេងព៉ាយយកព្រះនគរបាន ក្នុងគ្រានេះដោយស្រួល ។

ភូមិមណ្ឌលគាគាយ៍ព្យនេះ មានផ្ទៃផែនដីធំទូលាយ មានស្រុកជាច្រើនរហូតទៅដល់នគរជៀងមៃ បានមកជាសម្បត្តិរបស់ខ្មែរតាំងពីពុទ្ធសករាជ ១.៦០០ ។ កាលដំបូងនោះព្រះមហាក្សត្រិយ៍ខ្មែរបានទ្រង់តាំងព្រះនាងចាមទេវី ជាព្រះពជធីតា នៃព្រះបាទចក្រពត្តិអ្នកគ្រប់គ្រងរដ្ឋទ្វារវតីដែលតាំងរាជធានីនៅលពបុរី ឲ្យទៅគ្រប់គ្រងកុងធ្នាំដូចមានខាងលើនេះ តាំងរាជធានីនៅនគរហរិកុញ្ជ័យឬហៅថាលំពូ ។ កាលព្រះនាងចាមទេវីទិវង្គតទៅហើយ ព្រះពជវង្សរបស់ព្រះនាងបានគ្រប់គ្រងរដ្ឋហរិកុញ្ជ័យ តមកដល់រដ្ឋកាលព្រះអគ្គបាញ្ញាពជ រួមជា ៩០ រដ្ឋកាល រួមវេលាជា ៦៣១ ឆ្នាំ ទើបបានធ្លាក់ទៅក្នុងកណ្តាប់ដៃ ហើយលែងបានមកខ្មែរវិញពីគ្រឹមនោះមក ។

ព្រះបាទជយវរ្ម័នទី ៨ នៅក្នុងរាជសម្បត្តិមកដល់ ព. ស. ១៨៣៨ ឬ ១៨៣៩ ក៏សោយទិវង្គត ។ គេថ្វាយព្រះនាមព្រះបរមសពដូចម្តេចមិនច្បាស់ ។

(មានត)

រឿងអាវ័ក្សថ្មែងរឿងវិញ្ញត្តិ

លោកសាង-សារ៉ាត លេខាធិការក្រសួងបរិញ្ញវត្ថុ

ប្រែពីភាសាចាវ៉ាំងមកជាខ្មែរ

(ត្រង់)

ព្រះមហាក្សត្រទ្រង់យល់ព្រមតាមពាក្យលើនេះ រួចទ្រង់យកអាវ័ក្ស នោះទៅជាមួយព្រះអង្គ ។ អាវ័ក្សនិយាយបន្ថែមទៀតថា: "បពិត្រព្រះមហាក្សត្រ! មនុស្សចេះដឹង មានប្រាជ្ញាឈ្លាសវៃ រាល់ថ្ងៃតែងតែសោយទីវត្តម្រែកនៃចម្រៀង នឹងការសិក្សា, ការអានសៀវភៅធម៌ ។ ឯពួកសត្វតិរច្ឆាននឹងពួកកំជិល រាល់ថ្ងៃតែងតែដេកលេងសប្បាយឥតប្រយោជន៍ ។ ក្នុងដំណើរនេះ ត្រូវតែព្រះអង្គនឹងទូលបង្គំពិភាក្សាគ្នាអំពីធម៌ដែលមានប្រយោជន៍, ទូលព្រះបង្គំនឹងនិទានរឿងថ្វាយ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ ដូចខាងក្រោមនេះ" ។

រឿងទី ១

ស្ដេចស្រុកបេណារេស (Bénarès) ព្រះនាមប្រាតាប-មុកាត (Pratâp-Mukat) មានអគ្គមហេសីព្រះនាមមហាទេវី (Mohâdévi) មានព្រះរាជបុត្រមួយព្រះអង្គព្រះនាមពជី-មុកាត (Baji-Mukat) ។ ថ្ងៃមួយ ព្រះអង្គម្ចាស់នោះ បានយាងទៅបរបាញ់សត្វជាមួយកូនប្រុសរបស់នាយករដ្ឋមន្ត្រី (រដ្ឋមន្ត្រីទី ១) ហើយស្ដេចយាងរុកចូលទៅកណ្ដាលព្រៃជ្រៅ ។ មួយស្របក់

ទៅទៀត ស្តេចបានយាងទៅដល់ត្រពាំងទឹក ១ ល្អអស្ចារ្យ ។ នៅលើមាត់ត្រពាំងនោះ មានសត្វក្ងាន, ប្រចៀក, មាន់ទឹក, ទាញី, ទាឈ្មោល នូវសត្វក្រួចនឹងសត្វគ្រប់យ៉ាង កំពុងតែទះស្លាបលេង ។ នៅជុំវិញ ទាំង ៤ មានខ្នើនធ្លើអំពីឥដ្ឋលេចឡើងយ៉ាងប្រចក្ស ។ ផ្កាឈូកវែកហង់នៅក្នុងគង្គា ។ ជំនោរត្រជាក់ បក់តាមម្ជុំព្រឹក្សានានា ដែលដុះនៅទីនោះ ។ បក្សីទាំងឡាយ យំកញ្ជ្រៀវលេងសប្បាយតាមមែកព្រឹក្ស ។ បុប្ផាគ្រប់ប្រភេទប្រកបដោយកិរិនឹងពណ៌ស្រស់ច្រមុះយ មានហួងឃ្មុំរ៉ែតកុះករគ្រប់លំអងផ្កាពាសពេញព្រៃ ។ គ្រានោះ ព្រះអង្គម្ចាស់នឹងមិត្រវបស់ទ្រង់ ក៏ចុះតម្រង់ទៅមាត់បឹង ដើម្បីលុបលាងព្រះហស្តនឹងលុបលាងហត្ថា ។ លុះឡើងមកវិញ ជនទាំងពីរ បានដើរតម្រង់ផ្ងោះទៅកាន់គ្រីហាវបស់មហាទេវី ដោយបានបង់សេះបញ្ឈប់ទុកឲ្យដើរស៊ីស្មៅ រួចទើបចូលទៅកន្លែងគ្រីហានោះ, លុះថ្ងាយដង្ហាយរួចជាស្រេច ក៏ចេញមកក្រៅវិញភ្លាម ។ ក្នុងពេលដែលទ្រង់កំពុងសូត្រធម៌ ស្រាប់តែបុត្រីមួយព្រះអង្គរបស់ស្តេច បានយាងមកលេងនៅទីមាត់បឹងនោះជាមួយស្រីស្នំជាច្រើន ដើម្បីលុបលាងអង្គកាយផង ដើម្បីបំពេញករណីយកិច្ចខាងសាលាផង ។ លុះព្រះនាងបានលុបលាងព្រះកាយនឹងសង្ឃឹមចិត្តគំនិតបន់ស្រន់រួចស្រេច ព្រះនាងក៏យាងត្រសាលសប្បាយក្រោមម្ជុំឈើជាមួយស្រីស្នំទាំងនោះ ។

ក្នុងពេលនោះ កូនរដ្ឋមន្ត្រីទៅអង្គុយសៀម, ឯព្រះអង្គម្ចាស់ស្តេចយាងចុះទៅ។ ស្រាប់តែព្រះនេត្រចស់ទ្រង់ ដួចប្រទះគ្នានឹងព្រះនេត្រចស់ព្រះនាងខត្តិយា ។ ព្រះអង្គម្ចាស់ទ្រង់ស្គុតព្រះស្មារតី ហើយទ្រង់ត្អូញថា: "ឧកាម! (Kàma) ម្តេចក៏អ្នកធ្វើឲ្យខ្ញុំវង្វេងដូច្នេះ" ។

ឯព្រះនាងក្សត្រី លុះឃើញព្រះអង្គម្ចាស់នោះហើយ ព្រះនាងកំហូតយកផ្កាឈូកដែលជាក់លើព្រះកេសា ទៅសៀតត្រង់ព្រះកាណ៌វិញ រួចយកមកទាំនឹងព្រះទន្តហើយទើបជាន់ចោលទៅ ។ ក្រោយមក ព្រះនាងបានរើសយកមកវិញ ហើយយកទៅជាក់លើដើមទ្រូងព្រះនាង ។ លុះធ្វើដូច្នោះហើយ ទើបព្រះនាងយាងត្រឡប់ទៅទីស្នានវិញ ព្រមទាំងស្រីសំឡាំងអស់ផង ។ ចំណែកខាងព្រះអង្គម្ចាស់ ដោយទ្រង់អស់សេចក្តីសង្ឃឹមតទៅទៀត ទើបនាំឲ្យទ្រង់មានទុក្ខជាខ្លាំងព្រោះការឃ្លាតឃ្លាំងនេះ ហើយស្តេចយាងទៅជិតកូនលោករដ្ឋមន្ត្រី ទ្រង់សារសំពួរថ្កាប់អំពីរឿងដែលកើតឡើងនោះដូចមានតទៅនេះ: "នែសម្លាញ់! ខ្ញុំឃើញនារីម្នាក់ល្អអស្ចារ្យ, ខ្ញុំមិនបានស្គាល់ឈ្មោះនឹងទីលំនៅរបស់គេទេ ប៉ុន្តែខ្ញុំស្រឡាញ់គេឥតអ្វីប្រៀបបាន ហើយបើប្រសិនជាខ្ញុំមិនបាននាងនោះធ្វើជាភរិយាទេ ជីវិតខ្ញុំមុខជាមិនរស់ឡើយ" ។

កូនលោករដ្ឋមន្ត្រីលុះដឹងរឿងនេះ ហើយក៏នាំព្រះអង្គម្ចាស់ឲ្យគង់លើសេះហើយនាំស្តេចវិលត្រឡប់ចូលថ្កាសាទវិញ ប៉ុន្តែទុក្ខព្រួយព្រោះ

ការឃ្លាតឆ្ងាយ ជាន់ធ្វើឲ្យទ្រង់ទ្រមទ្រេមយ៉ាងខ្លាំង នាំឲ្យទ្រង់គង់នៅស្ងៀមឥតសរសេរ ឥតមើលសៀវភៅ ឥតផ្ទុំ ឥតសោយទឹកនឹងអាហារអ្វីសោះ, ទ្រង់ចោលកិច្ចការផែនដីគ្មានសល់តន្ទៃឯណា ។ ព្រះអង្គម្ចាស់ជាន់គួរបូជនាងរួចទ្រង់គង់មើល ដោយមានទឹកព្រះនេត្រហូរវាហាម, ពុំមានព្រះទន្ទ្រានសូម្បីតែមួយម៉ាត់ ព្រមទាំងទ្រង់លែងព្រះសណ្តាប់អ្វីទាំងអស់ ។

កូនលោកវដ្ឋមន្ត្រី កាលណាឃើញព្រះអង្គទ្រង់គង់ក្នុងហាន:នៃសេចក្តីឃ្លាតឃ្យាសឆ្កត់សង្កិនដូច្នោះ ក៏ទូលថា "ជនណាយកដើងជាន់លើផ្លូវស្នេហា ជនោះមិនជាន់ឈ្មោះថាមានជីវិតរស់នៅទេ, ទោះបីជនោះរស់នៅក៏ដោយ ក៏គង់មានទុក្ខធំបំផុតពុំខានឡើយ" ។

ព្រះអង្គម្ចាស់លុះទ្រង់ព្រះសណ្តាប់ពាក្យដូច្នោះ ក៏មានព្រះរាជឧទ្ធារតបវិញថា: "ថ្វីបើខ្ញុំដើរតាមផ្លូវនោះ ឲ្យតែខ្ញុំអាចរកសេចក្តីសប្បាយឃើញ ក៏ទុកដូចជាខ្ញុំរកសេចក្តីទុក្ខឃើញដែរ" ។

កូនលោកវដ្ឋមន្ត្រីទូលទៀតថា "ឧត្តមអង្គម្ចាស់! កាលព្រះនាងចេញអំពីព្រះអង្គទៅ តើព្រះនាងមានព្រះបន្ទូលអ្វីខ្លះនឹងព្រះអង្គឬទេ? ចាំងព្រះអង្គវិញសោត តើទ្រង់មានព្រះបន្ទូលអ្វីខ្លះទៅកព្រះនាងដែរ?" ។

ព្រះអង្គម្ចាស់ឆ្លើយថា "ទេ! ខ្ញុំឥតនិយាយអ្វីនឹងនាងទេ ឯរូបនាងក៏ឥតនិយាយអ្វីនឹងខ្ញុំដែរ" ។

កូនលោកវដ្ឋមន្ត្រីទូលថា "បើដូច្នោះ តំបាកនឹងដួបព្រះនាង ណាស់" ។

ព្រះអង្គម្ចាស់មានព្រះបន្ទូលថា "បើប្រសិនណាជាខ្ញុំឃើញនាង ខ្ញុំ អាចរស់នៅតទៅទៀតហ្ន, បើមិនឃើញទេ ដីរតខ្ញុំមុខជាវិលត់ពុំខាន" ។

កូនលោកវដ្ឋមន្ត្រីសួរថា "តើព្រះនាងគ្មានធ្វើសញ្ញាអ្វីមួយទេឬ!"

ព្រះអង្គម្ចាស់ឆ្លើយថា : "កាលនាងឃើញខ្ញុំ នាងហូតផ្កាឈូកពី ក្បាលយកទៅជាក់នឹងត្រចៀក រួចនាងទាំនឹងឆ្មេញ ហើយយកទៅជាន់ នឹងដើង, ទីបំផុត នាងយកផ្កានោះទៅជាក់លើដើមទ្រូងវិញ" ។

កូនលោកវដ្ឋមន្ត្រីនិយាយថា "បើដូច្នោះ ទូលព្រះបង្គំយល់សញ្ញា អស់នោះហើយ, ឥឡូវនេះ ទូលព្រះបង្គំស្គាល់ព្រះនាមនឹងទីលំនៅរបស់ ព្រះនាងជាច្បាស់ជ" ។

ព្រះអង្គម្ចាស់មានព្រះបន្ទូលថា "បើដូច្នោះ ចូរមិត្រអាណិតច្បាប់ ខ្ញុំផង" ។ បុរសក៏ចាប់ផ្តើមទូលរឿងនោះ ដូច្នេះថា: "សូមស្តេចទ្រង់ ព្រះសណ្តាប់! កាលដែលព្រះនាងហូតផ្កាឈូកអំពីព្រះសិរ ហើយយក ទៅសៀតនៅត្រចៀកវិញ នោះព្រះនាងចង់ច្បាប់ថា "ខ្ញុំជាអ្នកស្រុក ចនិតិច (Cornatic), កាលដែលព្រះនាងយកផ្កាឈូកទៅទាំនឹងឆ្មេញ ព្រះនាងចង់ទូលព្រះអង្គថា "ខ្ញុំជាបុត្រីស្តេចទន្ត-ពត (Dan-bat) (ទ្បាយ ដែលមានក្បាច់ដូចឆ្មេញ)", កាលដែលព្រះនាងយកផ្កាទៅជាន់នឹងដើង

ព្រះនាងចង់ទូលព្រះអង្គថា "ខ្ញុំឈ្មោះបទ្មាវតី (Padmavati) អ្នកស្រឡាញ់ផ្កាឈូក)", កាលដែលព្រះនាងយកផ្កាទៅជាក់លើដើមទ្រូងនោះ គឺព្រះនាងចង់ទូលព្រះអង្គថា "ព្រះនាងត្រូវចិត្តនឹងព្រះអង្គណាស់" ។

លុះនិយាយដូច្នោះរួច ជនទាំងពីរនោះក៏ស្ទុះតភ្ជាក់ជាក់គ្រឿងអាវុធនឹងយកមាសពេជ្រចន្ទិចចន្ទួចទៅជាប់ផង ហើយនាំគ្នាឡើងដំរះទៅសំដៅស្រុកដែលនាងនៅ ។ កាលកន្លងច្រើនថ្ងៃមក ទើបបានទៅដល់ស្រុកចន្ទិតិច កាត់តម្រង់ទៅរកទីក្រុង ទើបបានទៅដល់កំផែងស្តេច ហើយបានប្រទះនឹងយាយចាស់ម្នាក់ ដែលកំពុងអង្គុយរវៃអម្បោះនៅមាត់ទ្វារ ។ ជនទាំងពីរក៏ចុះពីលើខ្នងសេះ ចូលទៅជិតយាយនោះ ហើយនិយាយថា: "នែអ្នកម្តាយអើយ ! យើងខ្ញុំនេះជាអ្នកដំណើរ ហើយជាឈ្មួញផង ។ ឯទ្រព្យរបស់ដែលយើងខ្ញុំជួញនោះ មកតាមក្រោយឯណោះ ប៉ុន្តែយើងខ្ញុំមកមុនដើម្បីរកកន្លែងនៅសំណាក់អាស្រ័យ ។ ហេតុដូច្នេះ សូមលោកម្តាយមេត្តាជ្រាបកន្លែងណាមួយ ដែលយើងខ្ញុំអាចនៅបានផង" ។

កាលយាយចាស់ឮសំដីដូច្នោះ ទើបសំឡឹងមើលមុខជនទាំងពីរ ហើយនិយាយថា: "ផ្ទះនេះគឺជាផ្ទះរបស់អ្នកហើយ, អ្នកអាចនៅយូរបានតាមចិត្ត" ។

និមិត្តតែឮពាក្យដូច្នោះ ជនទាំងពីរក៏ចូលទៅនៅក្នុងផ្ទះនោះទៅ, លុះមួយស្របក់ក្រោយមក យាយចាស់ក៏ទៅអង្គុយជិត ហើយនិយាយលេង

ជាមួយយ៉ាង់ស្ងួនស្អាល ។ ឯកូនលោកវង្គម្ត្រីបានសាកសួរអំពីកូនចៅ ក្រុមគ្រួសាររបស់យាយនោះ ទើងអំពីផលរបរដែលគាត់រកចិញ្ចឹមជីវិត ។

- នែចៅ ! កូនប្រុសរបស់ខ្ញុំដែលនៅចំរើស្តេច ជាអ្នកមានមុខងារ ប្រសើរណាស់, ឯព្រះនាង៍បទ្មវត្តី ជាពជុត្តីបានចៅដោះខ្ញុំ ។ ឥឡូវ នេះ ខ្ញុំចាស់ហើយ, ដែលខ្ញុំនៅក្នុងផ្ទះនេះ គឺដោយព្រះករុណាជាម្ចាស់ ជីវិតស្តេចគ្រង់គ្រប់គ្រងចិញ្ចឹមខ្ញុំ ។ រាល់ថ្ងៃខ្ញុំតែង៍តែទៅមើលរក្សាព្រះ នាង៍ ប៉ុន្តែកន្លងពេលដែលខ្ញុំត្រឡប់មកវិញ ចិត្តរបស់ខ្ញុំព្រួយខ្លាំង៍ណាស់ ។

លុះក្រោយដូច្នោះ ព្រះអង្គម្ចាស់មានព្រះហឫទ័យរីករាយ ហើយទ្រង់មាន ព្រះបន្ទូលទៅកាន់យាយនោះថា: "ដល់ថ្ងៃស្អែក, កន្លងពេលដែលយាយ អញ្ជើញទៅមើលនាង៍ តើយាយហ៊ានទទួលសារបស់ខ្ញុំមួយឬទេ?" ។

យាយចាស់ឆ្លើយតបថា: "ម្តេចក៏អ្នកថាចាំដល់ថ្ងៃស្អែក? ទោះអ្នក និយាយយ៉ាង៍ណាក៏ដោយ ក៏ខ្ញុំអាចយកសារបស់អ្នកទៅឲ្យនាង៍ឥឡូវ-នេះបានដែរ" ។

ព្រះអង្គម្ចាស់តបទៅវិញថា: "បើដូច្នោះ ចូរលោកយាយទៅទូល ព្រះនាង៍ថា: "ស្តេចដែលព្រះនាង៍ឃើញនៅមាត់ត្រពាំង៍ពីថ្ងៃ ៥ កើត ខែមិថុនា (Jèth) នោះ ឥឡូវនេះទ្រង់យាង៍មកដល់ហើយ" ។

យាយចាស់បានទទួលបង្គាប់នោះ រួចក៏កាន់ឈើច្រត់ដើរចូលទៅ កន្លែងព្រះបរមរាជវាំង៍, ឃើញព្រះនាង៍គង់នៅម្នាក់ឯង៍, កាលគាត់ទៅ

ដល់មុខព្រះនាងហើយ ព្រះនាងក៏គំនាប់គាត់ៗ ក៏បានឲ្យពរសួរសុខទុក្ខដល់ព្រះនាង រួចនិយាយថា: "នែកូនស្រីសំឡាញ់! កាលនាងនៅតូច ខ្ញុំបានបំរើនាង, បំបៅដោះនាង! ឥឡូវនេះ ដោយគុណបុណ្យព្រះ នាងធំឡើង, ខ្លួនខ្ញុំមុខជាបានសប្បាយចិត្តដោយសារនាងពុំខាន បើប្រសិនណាជាយុវជនរបស់នាងប្រកបដោយសុខសួស្តី" លុះចប់ពាក្យដំអួញនោះហើយ ទើបគាត់និយាយទៀតថា: "ព្រះអង្គម្ចាស់ ដែលនាងចាប់ចិត្តជាប់កាលពីថ្ងៃ ៩ រោច ខែមិថុនានៅមាត់ត្រពាំង ឥឡូវនេះស្តេចបានឲ្យខ្ញុំនាំសារមកប្រាប់នាងថា: "បងមកដល់ហើយ សូមប្អូនបំពេញកិច្ច ដែលនាងបានសន្យានឹងព្រះអង្គម្ចាស់នោះកុងពេលនេះ", ចំណែកខ្ញុំវិញ ខ្ញុំសូមនិយាយនឹងនាងថា: "ដោយពិតទៅ ស្តេចនោះត្រូវជាគូទីនាងហើយ, គេល្អដូចនាងដែរ ហើយមានសន្តចរិយាគ្រប់បែបផង" ។

ដោយខ្លាំងជាខ្លាំង, កាលពួកគាត់និយាយនោះហើយ ព្រះនាងក៏យកឈើក្រអូប ១ ដុំរួយយាយនោះ រួចសើចថា: "ចេញអំពីដំណាក់យើងឲ្យឆាប់ យាយចាស់អប្រិយ!" ។

ឯយាយចាស់នោះ អាក់អន់ចិត្តជាខ្លាំងទើបចូលទៅរកព្រះអង្គម្ចាស់ ហើយនិទានរឿងអាក្រក់នោះប្រាប់ដោយសព្វគ្រប់ ។ ព្រះអង្គម្ចាស់តក់ស័យជាខ្លាំង ប៉ុន្តែកូនលោកវេដ្ឋមន្ត្រីក្រាបទូលថា: "សូមទ្រង់កុំគិតដល់រឿងនោះឲ្យសោះ ព្រោះទ្រង់យល់មិនទាន់ដល់ទេ" ។

ព្រះអគ្គមហេសីតបវិញថា: បើដូច្នោះ ចូរមិត្រពន្យល់ខ្ញុំផង, ចូរមិត្រធ្វើឲ្យបញ្ហារបស់ខ្ញុំបានស្រួលផង" ។

- កាលនាងយកម្រាមដៃទាំង ១០ ទាប់ដុំឈើត្រអូបហើយរាយចំមុខយាយនោះ នាងចង់ពន្យល់ថា: "កូនរាត់ដប់ថ្ងៃទៀមុខទៀត ព្រះអគ្គមហេសីនឹងនាងត្រូវទៅជួបគ្នាតណ្ហាលត្រីនឹត ។

លុះបាន ១០ ថ្ងៃហើយ យាយចាស់ទៅថ្វាយដំណឹងអំពីព្រះអគ្គមហេសីប្រាប់ព្រះនាង ។ ឯនារីបានយកម្រាមដៃ ៣ ផ្ទាត់យាយចាស់ហើយនិយាយថា: "ចេញអំពីដំណាក់យើងទៅ!" ។

ដោយមិនដឹងធ្វើអ្វី យាយចាស់ក៏ចេញមកវិញ ហើយទៅនិទានរឿងនោះទូលព្រះអគ្គមហេសី ។ ព្រះអគ្គមហេសីមានព្រះទ័យរីករាយតែត្រង់ព្រោះបានឮពាក្យរបស់យាយ ។ កូនលោកវដ្ដមន្ត្រី កាលបានឃើញដូច្នោះ ក្រាបទូលព្រះអគ្គមហេសីថា: "សូមទ្រង់ព្រះមេត្តាប្រោស! សូមព្រះអង្គកុំព្រួយ, ន័យរបស់រឿងនេះ ពិតជាផ្សេងស្រឡះ អំពីព្រះតម្រិះរបស់ព្រះអង្គ" ។

ព្រះរាជាមានព្រះបន្ទូលថា: "សូមមិត្រនិយាយឲ្យឆាប់ទៅមើល! ព្រោះសញ្ញារបស់ខ្ញុំចារម្ភខ្លាំងណាស់" ។ កូនលោកវដ្ដមន្ត្រីនិយាយថា: "នាងទៅកន្លងផុតនៃស្ត្រី, ដោយហេតុនេះហើយ នាងនឹងត្រូវធ្វើតាមកិច្ចសន្យារបស់នាងកន្លងរាត់ ៣ ថ្ងៃទៀត សូមព្រះអង្គរង់ចាំដល់ថ្ងៃទី ៤ សិន" ។

លុះបាន ៣ ថ្ងៃក្រោយមក យាយចាស់ក៏ទៅយកដំណឹងសុខ-ទុក្ខ អំពីព្រះមាឯកល្យាណីក្សត្រី ។ ប៉ុន្តែព្រះនាងទ្រង់ទ្រាល់ បាននាំយាយចាស់នោះសំដៅទៅមាត់ទ្វារខាងថ្ងៃលិច ហើយបានធ្វើប់គាត់ឲ្យចេញទៅខាងក្រៅ ។ យាយចាស់ត្រឡប់មកវិញ បានអធិប្បាយរឿងនោះទូលព្រះអគ្គម្ចាស់ ដែលកំពុងមានព្រះទ័យព្រួយពន់ពេក ។ ប៉ុន្តែកូនលោកវដ្ឋមន្ត្រីនិយាយទៀតថា : "ឯរឿងនោះដូច្នេះទេ : ស្ងួត, នៅវេលាយប់ គេនឹងឲ្យព្រះអគ្គម្ចាស់យាងទៅត្រង់មាត់ទ្វារនោះឯង" ។ និមិត្តតែឮពាក្យនោះ ព្រះអគ្គម្ចាស់ទ្រង់រីករាយជាពន់ពេក ។

កាលដល់កំណត់ពេលហើយ ជនទាំងពីរនាក់ឃុនស្ងៀកខ្មៅពាក់ខ្មៅជូតក្បាលស្លូលបួលជាស្រេច ហើយប្រដាប់គ្រឿងអាវុធគ្រប់គ្រាន់រៀងៗខ្លួន ។ គ្រាន់តែរៀបចំរួច រយៈពេលមោង ៣ ក៏ត្រូវជួបមក ។ សោតឯពេលនោះជាពេលស្ងប់ស្ងាត់ណាស់ ។ ជនទាំងពីរនាក់ចេញទៅយ៉ាងស្ងៀមស្ងាត់ឥតនិយាយគ្នាឡើយ ។ លុះទៅដល់ជិតមាត់ទ្វារហើយ កូនលោកវដ្ឋមន្ត្រីក៏នៅខាងក្រៅ ព្រះអគ្គម្ចាស់យាងចូលទៅតែមួយព្រះអង្គឯង ទ្រង់ឃើញព្រះនាងកំពុងតែឈរចាំព្រះអង្គ ។ កាលណាទេតាទាំងពីរព្រះអង្គជួបគ្នាហើយ ព្រះនាងវត្តិយានីក៏ទ្រង់ញញឹមហើយបិទទ្វារ រួចទើបនាំព្រះចេស្តាចូលទៅក្នុងបន្ទប់មួយ ដែលព្រះនាងបានរៀបចំរួច ទុកសម្រាប់ជាទីតម្រេកដោយកាមតណ្ហា ។

(មានត)

ដំណើរមកកាន់ប្រទេសកម្ពុជា

នៃមហាបណ្ឌិតគុណបាលបិយសេន ម៉ាល៉ាឡ៉ៈសេកេរៈ

ជាអធិបតីពុទ្ធិកសមាគមពិភពលោកនៅលង្កាទ្វីប

...របស់ពុទ្ធសាសនបណ្ឌិត្យ

(តកម)

កងពេលដែលខ្ញុំមកកាន់ប្រទេសខ្មែរនេះ ខ្ញុំឃើញជនជាតិខ្មែរមានសន្តានល្អជាបំផុត ព្រោះខ្ញុំទៅកន្លែងណា ក៏គេចេះតែមានទឹកមុខញញឹមទទួលខ្ញុំជានិច្ច ។ ដូច្នេះ បើលោកអ្នកមានឧកាស សូមអញ្ជើញទៅលេងស្រុកខ្ញុំម្ដង ខ្ញុំនឹងទទួលវិញ ដោយពាក់ពាក់យ៉ាងនេះដែរ ។

កងទីបំផុតសេចក្ដីនេះ ខ្ញុំសូមគោរពយ៉ាងខ្ពង់ខ្ពស់ ចំពោះព្រះមហាក្សត្រ ហើយសូមប្រសិទ្ធិពរដើម្បីព្រះអង្គបានប្រកបដោយសេចក្ដីសុខកងសិរីរាជសម្បត្តិជាអង្វែងតទៅ, មួយទៀតសូមសំដែងសេចក្ដីគោរពចំពោះរាជរដ្ឋាភិបាលនឹងបណ្ដាជនទាំងឡាយ ដែលបានជួនសេចក្ដីរាប់អានយ៉ាងខ្ពង់ខ្ពស់ដល់ខ្ញុំ ។

គាលលោកម៉ាល៉ាឡ៉ៈសេកេរៈ ថ្លែងសន្ទិសិទនេះចប់ហើយ សម្ដេចព្រះមហាសុមេធាធិបតី ក៏ប្រកាសសុំឲ្យព្រះសង្ឃទាំងឡាយសូត្របូជាវិសាខ នៅម៉ោង ៨ ព្រឹកនៃថ្ងៃ ១ រោចខែវិសាខ គឺជាថ្ងៃដែលមហាសន្និបាត ពុទ្ធសាសនាបានកំណត់ ព្រោះព្រះសម្ពុទ្ធគ្រង់ចូលនិព្វានទៅ

ពេលបែកបច្ចុសពេញបូណ៌មីខែវិសាខ គឺជិតក្លឹងថ្ងៃ ១ ភេចខែនេះឯង ប៉ុន្តែត្រូវរៀបគ្រឿងសក្ការៈ ធ្វើពិធីផ្សេងៗ តាមទំនៀមតាំងពីថ្ងៃទី ១៥ ទៅ ហើយនៅពេលសូត្របូជារួច សូមឲ្យនាំគ្នារំពឹងផ្សាយមេត្តាចិត្ត ចំនួន ២ នាទីថា "សូមឲ្យពិភពលោកទាំងមូលបាននូវសេចក្តីសុខទៅ" ។

ការផ្សាយមេត្តាចិត្តនេះ ជាពិធីមួយដែលប្រទេសកាន់ពុទ្ធសាសនាទាំង ៦៤ ស្រុះគ្នាធ្វើក្នុងពេលតែមួយដូចគ្នា ដើម្បីឲ្យកម្ទាំងចិត្តអាចនឹងគ្របដណ្តប់អស្ចារ្យសុខបាន ។

សម្តេចបានមានថេរដីកាបញ្ជាក់ទៀតថា នៅវត្តខ្ញុំណ្ហាលោម ខ្ញុំនឹងចាត់ចែងធ្វើវិសាខបូជានេះ ៦ ថ្ងៃ គឺតាំងពីយប់ថ្ងៃ ១៥ កើតទៅយប់ថ្ងៃ ១ ភេច ។

បុណ្យសម្ពោធ្យខឿនព្រះពោធិព្រឹក្ស

ព្រះពោធិព្រឹក្សដែលប្រតិស្ឋាននៅមុខសាលាចាលីជាន់ខ្ពស់កុំពេញនោះជាកេរ្តិ៍នៃព្រះនារទត្ថេរ លោកបានទាំពីលង្កាទ្វីបមកដូនពុទ្ធសាសនបណ្ឌិត្យ កុងឆ្នាំ ព.ស. ២៤៨១ រដ្ឋកាលព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ។ ដល់មកកុងឆ្នាំ ព.ស. ២៤៨៤ នេះ មានពុទ្ធបរិស័ទច្រើននាក់ផ្តើមកសាងខឿន ធ្វើពីស៊ីមងឹតនឹងឥដ្ឋដ៏វិចិត្រដោយក្បាច់ចនាគួរមិលមើល ។ ឯនាមអ្នកផ្តើមសាងនោះគឺ លោកជ័យ-ម្ងៀប អ្នកស្រីមុជ, លោកពុត-អ៊ុម អ្នកស្រីសន, លោកស្រី-ជិន អ្នកស្រីយ៉ា,

ទឹងលោកក្រុមប្រឹក្សាសុខ - ភៃ ។ នាមនៃលោក អ្នកតាំងនោះ សឹង មានចារឹកទុកក្នុងបន្ទៅខឿនព្រះពោធិព្រឹក្ស ដ្រុងខាងកើតចំស្រាប់ ។

កាលពីថ្ងៃទី ២០ ខែឧសភាឆ្នាំ ១៩៥១ ពេលម៉ោង ៤ កន្លះ រសៀល ពុទ្ធបរិស័ទ្យបានរៀបពិធីសម្ពោធ្យខឿនព្រះពោធិព្រឹក្សនោះ ។ ក្នុងពិធីនេះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានទ្រង់ស្តេចយាងមក ជាព្រះរាជាធិបតី ។ មានគាហានក្រុមរក្សាព្រះអង្គនឹងក្រុមក្មេងនៃ គាហាននេះចាំធ្វើគារវកិច្ចតាមទំនៀម ។ ឯកឧត្តម អ៊ុំ - ឈាងស៊ុនជា នាយករដ្ឋមន្ត្រី នឹងឯកឧត្តមសម - ញាណ ជារដ្ឋមន្ត្រីក្រសួងជម្ការ បានអញ្ជើញទៅចាំក្រាបបង្គំគាល់ព្រះរាជា ជាមួយនឹងឥស្សរជនដទៃ ទៀតជាច្រើន ។

លុះដួបជុំគ្នាហើយ សម្តេចព្រះមហាសុមេធាធិបតី ជួន - ណាត ជាសង្ឃនាយក បានថ្លែងអំពីប្រវត្តិនៃព្រះពោធិព្រឹក្សនេះ ព្រមទាំងបាន ថ្លែងអំណរយ៉ាងក្រៃលែង ក្នុងនាមនៃពុទ្ធបរិស័ទ្យជាអ្នកចាត់ចែងបុណ្យ ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់បានព្រះរាជទាន កិត្តិយសដ៏ខ្ពង់ខ្ពស់ដល់ពិធីនេះ ។

នៅទីបំផុត សម្តេចបានប្រសិទ្ធិពរក្នុងនាមនៃពុទ្ធបរិស័ទ្យទាំងអស់ ថ្វាយចំពោះព្រះមហាក្សត្រ, ចំពោះព្រះបរមរាជបិតា, ចំពោះព្រះបរម-ជននីនាថ នឹងចំពោះព្រះរាជវង្សានុវង្សទាំងឡាយ ។

បន្ទាប់មក មហាបណ្ឌិត ម៉ាល៉ាឡាសេកេរ៉ា ចាត់ថ្លែងសុន្ទរកថាសង្ខេប ដែលឥតព្រាងមួយ ជាភាសាអង់គ្លេសនៅចំពោះព្រះភក្ត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដោយមានលោក ភ្លេម៉ិង-ចាន់ ជាអ្នកបកប្រែជាខ្មែរ មានសេចក្តីដូចយើងសរសេរសម្រួលជូនមើល តទៅនេះ:-

សូមព្រះតេជះដ៏កល់លើត្បូង,

សូមព្រះពរជាន់ក្រាបបង្គំទូល ព្រះករុណាជាអម្ចាស់ជីវិត សូមទ្រង់ជ្រាប ក្រែមលន្លង់ធូលីព្រះបាទ!

ទូលព្រះបង្គំជាខ្ញុំ មានបំណងនឹងមកកាន់ប្រទេសខ្មែរជាយូរហើយ តែទើបនឹងបានសម្រេចបំណងនោះក្នុងពេលនេះ ដោយសារត្រូវបំពេញបេសកកម្មខាងពុទ្ធសាសនា ។ ទូលព្រះបង្គំជាខ្ញុំមានសេចក្តីត្រេកអរជាទីបំផុត ចំពោះសំណាងទូលព្រះបង្គំ ដែលបានមកចូលរួមនឹងពិធីបុណ្យដ៏ឧឡារិកនេះ ដែលមានតាំងការធ្វើនៃព្រះពោធិព្រឹក្ស តាំងពិធីវិសាខបូជា ជាបុណ្យដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូងបានប្រោសព្រះពរជាន់កិត្តិយស ដោយទ្រង់ស្តេចមកជាព្រះពរជាធិបតី ។

ដើមពោធិព្រឹក្សនេះ ប្រាកដជាមានពូជធាមកពីពោធិព្រឹក្សបុរាណដែលជាទីគោរពដ៏ជ្រាលជ្រៅនៃព្រះសម្មាសម្ពុទ្ធ ហើយដែលពុទ្ធបរិស័ទាំងឡាយគោរពកាន់តាប់ប្រទេស ដរាបដល់សព្វថ្ងៃនេះ ។ តាមប្រវត្តិសាស្ត្រថា: កន្លងពេលដែលព្រះសាស្តាបរិនិព្វានទៅបាន ២៣៦ ឆ្នាំ ព្រះសង្ឃ

មិត្តាថេរី ដែលជាព្រះពជបុត្រីនៃព្រះបាទអសោក បានសាកយកមែកនៅ
ទិសខាងត្បូងនៃពោធិព្រឹក្សាចាស់នោះ ទៅប្រតិស្ឋាននៅក្រុងអនុរាធបុរៈ
ក្នុងរាជ្យព្រះបាទទេវានម្បិយតិស្ស ។ កន្លងកាលមកបន្តិច ពោធិចាស់
ដែលនៅឥណ្ហៀនោះក៏វិនាសទៅ ដោយត្រូវពួកគាន់សាសនាជវៃ
បំផ្លាញ ។ ដូច្នេះ ប្រជាជនលង្កា ក៏មានសេចក្តីត្រេកអរណាស់ដោយ
ឃើញថាមានតែប្រទេសខ្ញុំនមួយប៉ុណ្ណោះទេ ដែលមានសំណាងបានរក្សា
ពូជព្រះពោធិព្រឹក្សាចាស់នោះឲ្យគង់វង្ស ហើយដែលអាចបំបែកពូជនា
ទៅប្រតិស្ឋាននៅនានាប្រទេសទៀតបាន ។ មានប្រទេសជាច្រើន
បានទៅចំឡងយកពូជពោធិព្រឹក្សានេះ ។

ឋពិត្រព្រះសម្មតិទេវរង្ស! ព្រះពោធិព្រឹក្សានៅលង្កានោះ មាន
អាយុជាង ២ ០០០ ឆ្នាំហើយ, អ្នកស្រុកលង្កាធ្វើសក្ការៈគោរពដើម
ពោធិ៍នោះជាខ្លាំបំផុត ។ កាលពីឆ្នាំមុន មានគេយករបស់មិនស្អាតទៅ
ចងព្យួរនៅដើមពោធិព្រឹក្ស ដែលជាហេតុនាំឲ្យព្រះពោធិ៍នោះសៅហ្មង,
អស់កាលមិនយូរប៉ុន្មាន ហេតុកេរមិនស្រួលផ្សេងៗ ក៏បណ្តាលកើតមាន
ឡើងក្នុងប្រទេសលង្កា ។ ទូលព្រះបង្គំជាខ្ញុំដឿថា បើដើមពោធិព្រឹក្ស
នេះ មានជីវិតនៅដរាបណា សាសនារបស់ព្រះសម្មាសម្ពុទ្ធ ក៏មាន
នៅដរាបនោះដែរ ។ តាមព្រះពុទ្ធតំរាស់ដែលបានផ្តាំទុកមកថា: រូប
កាយនៃដើមពោធិ៍នេះ ក៏ទុកដូចជារូបកាយនៃមនុស្សដែរ ព្រោះអាចជា

តំណាងអង្គនៃព្រះអង្គបាន សំរាប់ឲ្យពួកពុទ្ធបរិស័ទ្ធធ្វើសក្ការបូជាទៅ អនាគត ។

សូមទ្រង់ព្រះមេត្តាប្រោស ! កាលពីឆ្នាំ ១.៥០០ មុននេះ ប្រទេសឡែនធីប្រទេសលង្កា ឋានចង់មេត្រីភាពនឹងគ្នាយ៉ាងជិតស្និទ្ធ ។ អ្នកប្រាជ្ញខ្មែរ ក៏បានអញ្ជើញទៅលង្កា . អ្នកប្រាជ្ញលង្កាក៏បានអញ្ជើញមកស្រុកខ្មែរ ដើម្បីបំពេញកិច្ចសាសនាវៀងច្រើន ។ ទូលព្រះបង្គំជាខ្ញុំស្តាយជាទីបំផុត ចំពោះមេត្រីភាពនៃប្រទេសទាំងពីរនេះ ដែលឃ្លាតចេញពីគ្នាចំនួន ២០០ ឆ្នាំមកហើយ ព្រោះហេតុតែប្រទេសទាំងពីរ ធ្លាក់ចុះទៅក្នុងអាណាព្យាបាលនៃប្រទេសដទៃ ។ ក្នុងសម័យនេះប្រទេសទាំងពីរនេះ មិនមានជិតដិតនឹងគ្នាដូចពីមុនឡើងវិញទេ ។

ពិធីសម្ពោធ្យដ៏ឧឡារិកនេះ ជារូបនិម្មិត ១ នៃមេត្រីភាពនោះ ដែលនឹងចាប់ផ្តើមមានឡើងវិញជាថ្មី តាំងពីឥឡូវនេះទៅ ហើយជាហេតុដែលនាំឲ្យទូលព្រះបង្គំជាខ្ញុំ មានសេចក្តីចាប់អារម្មណ៍មិនក្តេចក្នុងដំណើរបេសកកម្មនេះផង ។

ម្យ៉ាងទៀត ក្នុងពេលដែលប្រទេសនានា កំពុងតែត្រូវភ្លើងសង្គ្រាមឆាបឆេះនេះ ប្រទេសកម្ពុជាមានអស្ចារ្យតែមួយក្នុង ១០ ប៉ុណ្ណោះទេ ដោយព្រះបរិញ្ញាណនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់ជាអគ្គសាសនូបត្ថម្ភយ៉ាងប្រសើរ ។ នេះទុកជាកត្តាយ៉ាងប្រសើរនៃប្រទេសកម្ពុជាដែលនាំឲ្យព្រះបង្គំជាខ្ញុំ មានសេចក្តីរីករាយជាមួយផង ។

ថ្ងៃមង្គលនេះ មិនមែនគ្រាន់តែជានក្ខត្តឫក្ស សំរាប់ការធ្វើនៃ
ព្រះពោធិព្រឹក្សតែម្យ៉ាងឡើយ គឺជាថ្ងៃដែលប្រទេសកាន់ពុទ្ធសាសនា
ចាំង ៦៤ កន្លះលោក ចាប់ផ្តើមប្រើទង់សាសនា ហើយនឹងធ្វើសាខ
បូជា កន្លះថ្ងៃជាមួយគ្នា ដើម្បីទុកជាកត្តាងនៃសាមគ្គីទៅអនាគត ។

កន្លះអវសានៃសេចក្តីនេះ ទូលព្រះបង្គំជាខ្ញុំមានចិត្តសោមនស្សជា
ទំបំផុត ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលបានទ្រង់ព្រះ
រាជទានព្រះរាជវរោកាសជាកិត្តិយស ដល់សុន្ទរកថារបស់ទូលព្រះបង្គំជា
ខ្ញុំនេះផង សូមសំដែងអំណរគុណចំពោះលោក-អ្នកសប្បុរសចាំងឡាយ
ដែលបានអញ្ជើញមកជួបជុំយ៉ាងកុះករកន្លះនេះផង ។

បន្ទាប់ពីសុន្ទរកថានេះមក, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បាន
ស្តេចយាងលើបុរាសន: ទៅកាន់ព្រះពោធិព្រឹក្សដំទង់ដែលមានរុំគល់
ដោយសំពត់លឿង ហើយប្រដាប់ដោយទង់សាសន៍ទៅជុំវិញជាកិត្តិ-
យស ។ នៅលើខ្នើនមានដំកល់ទឹកអប់ក្នុងផ្តិលប្រាក់ធំៗ នៅគ្រប់ទិស
ចាំង ៨ ។ ព្រះរាជទ្រង់ប្រទក្សិណដើមពោធិ៍ ដោយមានលោកឯកឧត្តម
នាយករដ្ឋមន្ត្រី, ឯ.ឧ.សម-ញ្ញា ណ, សម្តេចសង្ឃនាយកជួន-ណាត,
ព្រះតេជព្រះគុណព្រះពោធិវង្សហួត-តាត ចាងហ្វាងសាលាចុលាជាន់
ខ្ពស់, ព្រះកិត្តិប៉ាង-ខាត់ ទីឯព្រះគ្រូសំសត្តា ប៉ុណ្ណ-សម្ភាជ ដែលជា
សាក្សីពេជ្រញ្ញាណនៃពិធីនេះ ព្រមទាំងលោកម៉ាល៉ាល:សេតេវ:តាម

ហៅជាមួយផង ។ ព្រះករុណាទ្រង់ទទួលភួងផ្កាដែលនារីពីរនាក់ថ្វាយនៅ
ត្រង់អាសនៈដែលដំកល់ពីខាងកើតដើមពោធិ៍ ហើយទ្រង់បូជាចំពោះ
ព្រះពោធិ៍ ព្រមទាំងយកសុគន្ធភារីច្រោះព្រំផង ។

តពីនោះមកទៀត ឯកឧត្តម អ៊ុំ-ឈាងស៊ុន លោកមហាបណ្ឌិត
ម៉ាល៉ាឡ៉ៈសេកេរៈ, ឯកឧត្តមសម-ញ៉ាណ បានទទួលកិត្តិយសច្រោះព្រំ
ជាលំដាប់គ្នា ស្រែចហើយទើបពុទ្ធបរិស័ទ្យ នាំគ្នាទៅធ្វើនមស្សការ
ដោយដុំជិត ។

ក្នុងឧកាសដែលព្រះរាជាប្រទានសុគន្ធភារីនេះ មានព្រះសង្ឃ ៨០
អង្គ ដែលតម្រូវតាមព្រះជន្មនៃព្រះសម្មាសម្ពុទ្ធ សូធ្យាយធម៌ជយន្តោ
បសិទ្ធិពរជោគជ័យមង្គលជល់ដើមពោធិព្រឹក្ស ។ លុះស្រែចកិច្ចនេះ
ហើយ, ព្រះរាជាស្តេចយាងទៅកាន់ព្រះរាជនិវេសន៍វិញ ។

សន្និសិទលោកម៉ាល៉ាឡ៉ៈសេកេរៈ
ធ្វើនៅសាលាបាលីជាន់ខ្ពស់ ភ្នំពេញ

កាលពីថ្ងៃទី ២០ ខែឧសភា គ. ស. ១៩៥១ នេះ ក្រោយដែលបាន
ធ្វើពិធីសម្ពោធព្រះពោធិព្រឹក្សរួច លោកម៉ាល៉ាឡ៉ៈសេកេរៈ បានធ្វើ
សន្និសិទមួយ អំពីរឿងប្រជុំមហាសន្និបាតពុទ្ធសាសនានៅលង្កាទ្វីបតាម
សេចក្តីអញ្ជើញនៃសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក ។ ក្នុង
បរិវេណសាលាបាលីជាន់ខ្ពស់ទាំងមូល មានព្រះសង្ឃនឹងគ្រហស្ថ ទាំង

ស្រីតាំងប្រុស ប្រហែល ៧·០០០ នាក់ បានស្តាប់សន្និសិទនេះ ដោយ
សេចក្តីរីករាយ ។

មហាបណ្ឌិតនេះ បានថ្លែងបាឋកថាឥតឆ្លងជាភាសាអង់គ្លេស
ដោយមានលោក ក្លេម៉ង់-ហ៊ាន់ ជាអ្នកបកប្រែជាភាសាខ្មែរ ។ បាឋកថា
នោះមានសេចក្តីសង្ខេប ដូចតទៅនេះ :—

បងប្អូនរួមសាសនាតាំងឡាយ !

ខ្ញុំត្រេកអរណាស់ ចំពោះកិច្ចដែលអស់លោក - អ្នកបានជូនកិត្តិ-
យសដ៏ខ្ពង់ខ្ពស់ដល់ខ្ញុំ ដើម្បីនឹងឲ្យព័ទ៌មានអំពីបុព្វហេតុនៃការប្រជុំពុទ្ធ-
សាសនានៅលង្កាទ្វីប ដែលបានធ្វើកាលពីឆ្នាំទៅមិញ ។ ក្នុងពេលប្រជុំ
នោះប្រទេសខ្មែរក៏ជាសមាជិកផងដែរ ។

ខ្ញុំសូមជំរាបថា : ការប្រជុំនេះមានចំណងនឹងធ្វើតាំងពីឆ្នាំ គ.ស.
១៩៤៩ មកម្ល៉ែះ ដោយបានគ្រោងសេចក្តីអញ្ជើញប្រទេសកាន់ពុទ្ធសា-
សនាតាំងអស់ ទៅប្រជុំនៅលង្កាទ្វីប ។ តែកិច្ចការនេះ បានឡាយពេល
ដំរាបមកដល់ខែឧសភាឆ្នាំ គ.ស. ១៩៥០ ទើបសម្រេច ព្រោះមាន
ឧបស័គ្គជាច្រើនយ៉ាង ។ កាលពីឆ្នាំទៅបានជាមិនបានប្រជុំសម្រេចនៅ
ខាងដើមនៃខែឧសភា ព្រោះអាកាសនៅលង្កាទ្វីបកំពុងក្តៅហែង ជា
ពេលដែលមិនអាចទន់ភ្ញាក់សេចក្តីរីករាយឲ្យកើតមានដល់ពិធីប្រជុំបាន ។
ពាល់តែដល់មកថ្ងៃទី ២៥ ឧសភា ឆ្នាំ ១៩៥០ ជាសម័យដែលមាន

ធម្មជាតិចាំងពួងស្រស់ប្រឹមប្រិយ ដោយសារអាកាសត្រជាក់នៃរដូវ
ក្តៅ ហើយដែលមានត្រួយឈើនឹងផ្កាឈើ ទើបនឹងពន្លកលេចឡើង
ជាហេតុឲ្យកើតមនោរម្យដល់អ្នកដំណើរចាំងខោះ ។ គណៈកម្មការក៏បាន
ណាត់យកពេលនេះជាឧកាសសន្និបាតធំ ។ មិនមែនគ្រាន់តែតម្រូវ
យកអាកាសត្រជាក់ដើម្បីឲ្យស្រួលដល់ក្តៅបរទេសប៉ុណ្ណោះទេ គឺបាន
ចាំងតម្រូវយកថ្ងៃដែលព្រះមហាមហិន្ទ្រតេរ នាំព្រះពុទ្ធសាសនាទៅ
ប្រតិស្ឋាននៅលង្កាទ្វីប ដែលជាថ្ងៃសំខាន់បំផុតក្នុងប្រវត្តិសាស្ត្រផង ។

ម្យ៉ាងទៀត ខែឧសភា នឹងខែមិថុនានេះ ជាខែដែលមានបុណ្យធំ
មួយ ហៅថា "ជយន្តី" គឺបុណ្យវិសាខបូជា ដែលអាចនឹងឲ្យអ្នក
តំណាងប្រទេសកាន់ពុទ្ធសាសនាចាំងប៉ុន្មាន មានឧកាសបានធ្វើកុងធីជា
មួយគ្នាផង ដែលជាបឋមកិច្ចក្នុងការរួបរួមថ្ងៃធ្វើវិសាខបូជាឲ្យបានត្រូវគ្នា
ព្រោះកាលពីមុននេះ ប្រទេសប៉ែកខាងមហាយាន គេបានធ្វើមុនពួក
ហីនយានមួយអាទិត្យ ។

នៅលង្កាទ្វីប បុណ្យវិសាខបូជានេះ គេបានធ្វើជា ๒ ឡាវិកណាស់ ។
អ្នកពាក់ការឈប់ប្រកបកិច្ចការក្នុងមុខជំនួរបស់ខ្លួន ។ ក្នុងថ្ងៃបុណ្យនេះ
គ្មានវត្តណាមួយឬគេហដ្ឋានណាមួយដែលមិនធ្វើពិធីនេះទេ ។ ពេល
យប់ គេតែងភ្លើងយ៉ាងរន្ទាលច្រាលផ្លៅនៅតាមវត្ត តាមគ្រឹះស្ថាន
រាជការ នឹងតាមគេហដ្ឋានផ្សេងៗ ព្រមទាំងមានការដង្ហែព្រះចង្កូមកែវ

ដែលមានក្បួនដំរីយ៉ាងច្រើន ក្នុងពេលយប់នោះទៀតផង ។ ចំណែក
ព្រះពោធិព្រឹក្សនោះសោត ក៏គេតាក់តែងសក្ការៈយ៉ាងខ្ពង់ខ្ពស់បំផុត ។
មិនតែប៉ុណ្ណោះឡើយ ពួកគ្រហស្ថតែងនាំគ្នាធ្វើម្ហូបអាហារយកទៅ
ជាក់ឆានដល់អ្នកកំសត់ទុគ៌ត ក្នុងពេលយប់នោះនឹងពេលព្រឹកឡើង ។

អំពីការឈប់សំពកវិញ, ពិធីប៉ុណ្ណាដ៏សំខាន់នេះ មិនមែនបើកទុកាស
ឲ្យតែអ្នករាជការប៉ុណ្ណោះទេ គឺត្រូវបានឈប់សំពកការងារទាំងបណ្តាក្រសួ
ទាំងកម្មករ ទាំងសត្វពាហនៈ ទាំងអ្នកជាប់ទុក្ខទោស ។

ក្នុងពេលធ្វើមហាសន្និបាតនោះ មាន ៣២ ប្រទេសបានទៅប្រជុំ
ដែលមានអ្នកតំណាងទាំងអស់ ១៣២ នាក់ គឺកូមា, ចិន, ទីបេត, ម៉ុងគោលី,
ជប៉ុន, អូស្ត្រាលី, កូហាន, លង្កា, ម៉ាឡេហ្ស៊ី (សិង្ហប៊ុរីនឹងពិណាំង), នេប៉ាល់,
កម្ពុជា, ថៃ, វៀតណាម, ចាំគីស្ថាន, ឥណ្ឌូ, ស៊ុកគីម, ហាវ៉ៃ, អស្សាំ,
អាហ្វ្រិក, អាមេរិក ហើយនឹងប្រទេសប៉ែកខាងអឺរុប គឺអង់គ្លេស, ចាវ៉ង,
អាលឡឺម៉ង់, ស៊ុយស, ណារវែស, ឆេកូស្លូវ៉ាគី, ដាណឺម៉ាក, ។ល។ មាន
តែប្រទេសមួយទេ ដែលមិនបានមកប្រជុំ គឺប្រទេសរុស្ស៊ី ។ ក្នុង
ចំនួនប្រទេសទាំងនេះ ប្រទេសខ្មែរមានអ្នកតំណាង ៥រូបគឺ សម្តេចព្រះ
មហាសុមេធាធិបតី ជួន - ណាត, ព្រះគ្រូសំសត្តា ប៉ុណ្ណ - សម្ភរ,
ឯកឧត្តមជ្រាក់ - សារិន នឹងឥស្សរជន ២ នាក់ទៀត ។

(មានត)

ភាវនាសុទ្ធិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែតុលា លេខ ១០

ព. ស. ២៤៩៤ — គ. ស. ១៩៥១



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
ពុទ្ធសាសនានឹងត្រូស្តសាសនា (សន្ទនាសិទ្ធ លោកវេដ្ឋបណ្ឌិតមីគូត៍) (តមក)	លោកវ៉ាយ-ប៊ុក	៧២៣
ពន្ធអាស៊ីទ្វីប (តមក)	លោកវ៉ាយ-ប៊ុក	៧២៧
សម្មាទិដ្ឋិកថា	ព្រះអាចារ្យ អាំ-សាមុល	៧៣១
ផ្នែកអក្សរសាស្ត្រ		
រឿងមនុស្សថ្មី	លោកផេង-ជ្រឹវ	៧៤១
ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម	៧៥៦
រឿងសាមកុក (តមក)	ឧកញ៉ា គួ-កន	៧៦៣
ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក)	ឧកញ៉ា ឈឹម-ក្រសេម	៧៧១
រឿងអារក្សថ្លែងរឿងម្តៃជ្រាំ (តមក)	លោកសាង-សាវ៉ាត	៧៧៧
កំណត់ទីនប្រវត្តិការណ៍		
ដំណើរមកកាន់ប្រទេសកម្ពុជានៃមហាបណ្ឌិត		
គុណបាលបិយសេន ម៉ាណ៉ាល៉ះសេកេរៈ (តចប់) ពុទ្ធសាសនបណ្ឌិត្យ		៧៨៧

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដារ ១៤៥ រ. ០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE — Pages

Bouddhisme et Christianisme (Conférence du Docteur A. Migot) (suite)	M. RAY-BUC	723
La Lumière de l'Asie (suite)	M. RAY-BUC	727
Sammâditthikathâ'	VÉN. AM SAMOL	731

PARTIE LITTERAIRE

La Légende de l'homme de pierre (contes et légendes roumains) . . .	M. PHENG-CHRIEU	741
Education morale (suite)	Vén. PENG-PAM	756
Histoire de SAMKOK (suite)	Oknha NOU-KAN	763
Histoire du Royaume du Cambodge (suite)	Oknha CHHIM-KRASEM . . .	771
Les vingt-cinq récits du mauvais génie (suite)	M. SANG-SAVATH	777

NOTES ET CHRONIQUES

Voyage au Cambodge du Dr. G.P. Malalasekera, Président du Centre mondial des Bouddhistes de Ceylan (suite et fin)	Institut Bouddhique	787

Prix d'abonnement annuel comprenant 12 numéros: 145$00

ពុទ្ធសាសនា និង គ្រិស្តសាសនា

សន្និសិទលោកផ្ដិបណ្ឌិត មីគ្យត

លោក ព័ុយ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ កំពង់ឆ្នាំង

ប្រែពីទស្សនាវដ្ដី « ហ្រ្វង់អាស៊ុ » ខែមិថុនា ឆ្នាំ ១៩៥០

(តមក)

ជីវសត្វគ្មានជីវិតន្ទ្រិយចំពោះខ្លួនពិតប្រាកដ ដោយយល់ថាជីវសត្វនេះកើតឡើងពីហេតុ ហើយមានហេតុផ្សេងៗទៀត ជាអ្នកបង្កើតពីមុនមកប្រែកបដោយអនិច្ចតាធម៌ ។ ដូចជាព្រលឹង, បើតាមន័យខាងគ្រិស្តសាសនាថា ជាជីវសត្វស្ថិរវន្តប្រែកបដោយនិច្ចតាភាព កកើតឡើងជាពិសេសសម្រាប់យើង តាំងពីបដិសន្ធិហើយស្ថិតនៅជានិច្ចដដែល ស្ថិតស្ថេរកន្លងពេលដែលជីវិតរស់នៅ ហើយក៏លះបង់យើងក្នុងពេលមរណភាព ទៅកាន់ស្ថានសួគ៌ ។ យោបល់នេះ បើតាមពួកពុទ្ធសាសនិកជនថាជាការកាន់ច្រឡំដោយពិត ។ ដែលយើងហៅថាព្រលឹង, អត្តា (égo) នោះគឺបានន័យថា ជាតុប្រមូលជាសំណុំវិលចុះឡើងជានិច្ច ដែលហៅថា

---

១ ការយល់តាមព្រះពុទ្ធសាសនា អំពីធម្មជាតិនៃជីវសត្វមានអត្តនឹងព្យញ្ជនៈ ប្រហែលនឹងប្រាជ្ញាគួរដាក់ទីគោរពដែលពណ៌នាក្នុងទតិសម័យទំនើប នៃវិជ្ជាសាស្ត្រចំពោះសមាសភាពនៃវត្ថុធាតុនឹងរូបធាតុវិទ្យាខាងបរមាណូ ឲ្យប្រៀបធៀបរឿងនេះនឹងបណ្ឌិត រ័ម — លិស្សសេន ដែលតែងសៀវភៅមួយឈ្មោះថា: ព្រះពុទ្ធសាសនានឹងវិទ្យាសាស្ត្រទំនើប ដែលបានចុះផ្សាយក្នុងទស្សនាវដ្ដី ហ្រ្វង្ស . អាស៊ុ, ខែមករា — កុម្ភៈ ១៩៥០ ទំព័រ ៦៥៨ ។

សញ្ញា, វេទនា, បដិមារូប, ចិន្តា ចូលចេញចាត់ៗ យើញៗ ដោយមាន
ការចលនាទៅតាមអារម្មណ៍របស់ចិត្តនឹងមនោសញ្ចេតនា ហើយក្លាយ
ទៅជាវត្ថុមួយថ្មី ដែលប្រមូលទៅហៅថានាមធម៌ (personne Psychique) ។
ចំពោះការផ្ទាស់ប្តូរធាតុជានិច្ច ជាបញ្ហាយ៉ាងជ្រាលជ្រៅ លំបាកនឹង
យល់នឹងដោះស្រាយណាស់ គ្មានវត្ថុអ្វីមានសភាពពិតសោះឡើយ មាន
តែស្មារតីនឹងការបន្តនូវធាតុប្រែប្រួលពីវត្ថុចាស់ទៅជាវត្ថុថ្មីផ្សេង ដែលនាំ
ឲ្យយល់ថា មានអត្តាមួយនៅស្ថិតស្ថេរជាប់ជានិច្ច ដូចជាទឹកជ្រោះដែល
ហូរចុះពីលើខ្នងភ្នំ ជាទឹកនឹង មានលក្ខណៈស្ថិរភ្ជ ដោយស្មានថា បើ
តាមពិនិត្យចំពោះសភាពបន្តនៃរូបធាតុ ។

លទ្ធិទស្សនវិជ្ជានាំឲ្យបានផលខាងសីលធម៌ដ៏សំខាន់ហើយ, បើ
យកលទ្ធិនេះទៅអនុវត្តន៍ ធ្វើឲ្យមនុស្សយើងឲ្យអាចដកគំរើងនូវទំនាំងនៃ
អត្តទត្ថភាព (égoisime អំពីហេយវត្ថុបុព្វមនោធម៌បាន ។ តើនឹងពោល
ពាក្យថា: "ខ្ញុំ" ថា "អត្តា" ឯណាកើត បើ "អត្តា" នោះមិនមាន,
បើ "អត្តា" នោះជាអូរប្រឡាយមួយ កន្លងចំណោមប្រឡាយទាំងអស់
មានច្រើនជាអនេកប្បការ ដែលរួបរួមទៅហៅថា ទន្លេនៃជីវភាពក្នុង
ចក្រវាឡ? ។ ចំពោះគ្រិស្តសាសនិកជន, បើតាមន័យផ្ទុយវិញថា យើង
មានព្រលឹងដែលព្រះអាទិទេព ចាត់បង្កើតមកជាពិសេស ស្ថិតទៅក្នុងខ្លួន
យើងម្នាក់ៗ ទាំងអស់គ្នា យើងមានជោគវាសនាចំពោះខ្លួនដែលនៅក្រោម

បង្គាប់បញ្ជារបស់ព្រះអាទិទេព ជានាយកពាសេសត្រួតត្រាសម្រេចជាអាំការពីលើ ។ ចំពោះមតិនេះ ដូចជាមានវត្ថុអ្វីមួយមកពាំងធ្វើឲ្យយើងឃ្លាតឆ្ងាយពីវត្ថុដទៃទៀត គឺជាប្រកពនៃអត្តទត្ថភាព, ជាបុព្វហេតុអាចធ្វើឲ្យ "អត្តារបស់យើងឈ្លោះទាស់នៃងនឹងអត្តាបងប្អូនញាតិមិត្តរបស់យើង" ។

ខ្ញុំដឹងថាមានសិក្ខាបទរបស់អាទិទេពថា: "ចូរអ្នកស្រឡាញ់ទៅវិញ-មក" ។ ចុះហេតុម្តេចក៏យើងត្រូវស្រឡាញ់គ្នា បើយើងជាដីវសត្វតាំងអស់មានសភាពផ្សេងៗគ្នា ហើយមានជោគវាសនានៅក្រៅមបញ្ជានៃអាទិទេពទេ? ។ ដើម្បីនឹងតស៊ូនូវអត្តទត្ថភាព ដែលស្ថិតនៅជាធម្មតា, ត្រូវតែលះបង់គំនិតចំពោះ "អត្តា" ដែលដុះពីកំណើតហើយត្រូវយើងកុំភ្លេចថាខ្លួនយើងជាកូនអាទិទេព មានសេស្សាយទាក់ទងទៅកងអាទិទេព ។ តាមលទ្ធិពុទ្ធសាសនា, ធម៌ "អនត្តា" មានចំណងចង់តស៊ូដោយចំពោះ ដើម្បីនឹងដកគាស់រំលើងនូវបុព្វហេតុនៃអត្តទត្ថភាពឲ្យលើងចេញពីសន្តានចិត្ត, យើងមិនមែនគ្រាន់តែជាបងប្អូនសាច់សាលោហិតជាមួយគ្នាប៉ុណ្ណោះទេ, យើងមានសភាពខ្ពង់ខ្ពស់ជាងនេះទៀត គឺយើងនឹងសត្វដែលមានជីវិតរស់នៅតាំងអស់ មានសភាពតែមួយដូចគ្នា ។ គេអាចយល់បានថា ការដែលយល់ផ្សេងអំពីមតិនៃទស្សនវិជ្ជាចំពោះ 'អត្តា" ជាកិច្ចសារវន្ត (essentiel) ដែលជាហេតុឲ្យមានយោបល់ខុសគ្នាខាងបច្ចាប់សីលធម៌ ដែលយើងបានអធិប្បាយពីមុន

មក ។ លទ្ធផលខាងបច្ចឹមប្រទេស, តាមគោលការណ៍, សិក្ខាបទ ត្រង់ព្រហ្មវិហារត្រឡប់ទៅជាវិសាមញ្ញភាព (Anachronisme) អត្តទត្ថភាព នឹងការសង្គ្រាមនៃជីវភាព ទៅជាមានបទបញ្ញត្តិតឹងរឹងពន់ពេកចំពោះបុគ្គលនឹងប្រជារាស្ត្រ ដែលគេទុកជាសភាពផ្ទុយនឹងលទ្ធិពុទ្ធសាសនាជាសាសនាស្ងួតជាមជ្ឈិមាបដិបទា ដែលយើងនឹងពណ៌នាទៅខាងក្រោយ ។

ខ្ញុំខំព្យាយាមបង្ហាញអ្នក តើព្រះពុទ្ធសាសនាដោយពិតយ៉ាងណាខ្លះ? ខ្ញុំមិនអាចនឹងពណ៌នាឲ្យបានសព្វគ្រប់ អំពីព្រះពុទ្ធសាសនាដែលពួកពុទ្ធសាសនិកជនជាប់និយមកាន់នោះឡើយ ។ ពិតមែនតែពួកបុថុជ្ជនជាតិ, បើពិនិត្យឲ្យច្បាស់លាស់តាមន័យធម្មតា ឃើញថាជាអ្នកពេញចិត្តខាងសាសនាជាងពួកបច្ចឹមជាតិ តែអ្នកដែលយល់ទូវសាសនា ដែលខ្លួនប្រតិបត្តិតាមសភាពដ៏ទុគ្គមកម្រនឹងមាន, ហើយពួកឧបាសកនឹងឧបាសិកាតែងពេញចិត្តខាងការធ្វើបុណ្យកុសលតាមទំនៀមទម្លាប់ ដែលមានសភាពងាយស្រួលជាការគ្រាប់ទៅតាមផ្លូវកន្លាង ដែលមានចង្អុកច្រើនខាងធម៌សមាធិកម្មដ្ឋាន ។ នាងក្បែត្រកានីនី (Cultivatrice) ខ្មែរដែលអុជធូបបូជាព្រះពុទ្ធរូប គឺជាភាតរជនិកា (sœur) នៃនាងក្បែត្រកានីនីនៅភូមិភាគប្រឹតាញដែលអុជទៀនបូជារូបសាំង អង់តូនដឺប៉ាឌូ (Saint. Antoine de Padoue) តែពួកឫស្សីប្រទេសឥណ្ឌាបែតដែលស្ថិតនៅក្នុងព្រៃរហាល់យជាភាតរជន (Frère) ចំពោះមនោធម៌នៃគ្រិស្តសាសនិកជនដែលស្ថិតក្នុងកុដិ នៅវិហារសារធី ។ (មានត)

ពន្លឺអាស៊ីឬ

វគ្គទី ៣

La Lumière de l'Asie

លោកស៊ីរ - អេតវ៉ាំងអារណ្យលត៍ តែង

លោក រ៉ាយ - ប៊ុក ក្រុមការ ប្រែរៀបរៀង

(ត ន ក)

បន្ទាប់មកពួកពាណិជនោះក្រាបទូលព្រះនាងតទៅទៀតថា : រួច ព្រះបរមគ្រូជាម្ចាស់ខ្ញុំធ្វើកាត់ក្តុំ ដើម្បីនឹងស្តេចទៅកាន់ទីក្រុងបេ-ណារេស (ពារាណសី) ទៅប្រាសបញ្ចុះគ្គិយពន្យល់អំពីរបៀបធ្វើជីវិត នឹងសេចក្តីស្ងប់ឲ្យសាបសូន្យ ហើយមនុស្សទាំងអស់ត្រូវទទួលជោគ-វាសនា ចំពោះអតីតកម្មកាពរបស់ខ្លួន, គ្មាននរកអ្វីក្រៅពីនរកដែលខ្លួនធ្វើ, មិនមានស្ថានសួគ៌ឯណាខ្ពស់ហួសប្រមាណ អំពីបុគ្គលដែលគ្មានប្រព្រឹត្តបាបអកុសល ។ កុងពេលនោះគឺថ្ងៃ ១៥ ខែវ័យសា(១) ពេលរសៀល ហើយយប់នោះជាថ្ងៃពេញបុណ៌មី ។ កុងចំណោមពួកឫស្សី, កិត្តិកោណ្ឌញ្ញបានត្រាស់ដឹងនូវចតុរាយសច្ច ព្រមទាំងឃើញធម៌មុនគេ, រួចតមកកន្ទេយ: (កន្ទិយ:), អស្សជិ (អស្សជិ), ពសវ: (វប្ប:) មហានាម បានសម្រេច ។ នៅកុងទន្សានប្រើស (ប្រហែលជាព្រៃឫស៊ីបតន:?) ព្រះអគ្គម្ចាស់យស (យសកុលបុត្រ) ទ្រង់បានតង់ព្រះសណ្តាប់ធម៌ទេសនានៃព្រះបរមគ្រូ ព្រមទាំងបរិវារ ៥៤ នាក់,

---

១ ខែនេះត្រូវនឹងបុងខែ ១សកានឹងដើមខែមិថុនា ។

ថ្វាយបង្គំព្រះអង្គហើយក៏សម្រេចដើរតាមក្រោយព្រះអង្គ; ព្រោះសន្ទុ-
ភាពនឹងវិទ្យាសាស្ត្រនៃសម័យថ្មី ចានបើកដោយសេរីចំពោះមនុស្ស-
លោក ហើយកើតមានឡើងនៅក្នុងហទយវត្ថុនៃបុគ្គលដែលចានស្គាប់
នូវពុទ្ធោវាទ ដូចជាបុប្ផានឹងរុក្ខជាតិព័ណ៌ខៀវស្រងាត់ជុះពោសពេញ
កាលណាទឹកហូរចូលទៅក្នុងវាលទ្បាប់ ។

ពាណិជនោះចានក្រាបទូលព្រះនាងតទៅទៀតថា: ពួកសាវកចាំង
៦០ អង្គ, ក្រោយដែលចានសម្រេចមគ្គផល ព្រះសម្មាសម្ពុទ្ធចានចាត់
ឲ្យទៅផ្សាយព្រះពុទ្ធសាសនា ពន្យល់ផ្លូវដែលទៅកាន់បរមសុខ ។
ចំណែកខាងព្រះអង្គវិញ ទ្រង់ចានចាកចេញពីទ្បាននៃសត្វប្រើស
នឹងព្រៃឥសីបតនៈ ដើម្បីនឹងទ្រង់យាងទៅកាន់ខាងត្បូងយស្ហតិ (Yashti)
នឹងព្រះរាជអាណាចក្រព្រះចានពិម្ពិសារ ទ្រង់ចានទេសនាជាច្រើនថ្ងៃ
ទៅទីនោះ ។ ព្រះចានពិម្ពិសារនឹងប្រជាពលក៏ចានទទួលនូវត្រៃយ
សរណាគមន៍, ចានសិក្សាវៀនសូត្រនូវច្បាប់ព្រហ្មវិហារនឹងវិធានៃ
ដីវភាព ព្រមទាំងថ្វាយចំពោះទៅព្រះបរមគ្រូជាម្ចាស់ (ដោយទ្រង់ចាន
ចាត់ព្រះសុគន្ធរសក្នុងព្រះហស្តនៃព្រះសម្ពុទ្ធ)(១) នូវទ្បាននៃដើមឫស្សី
ឈ្មោះវេឡុវ័នដែលមានស្ទឹងគង្គា គុហា នឹងព្រៃរះចាន, ហើយព្រះមហា-
ក្សត្រចានតំកល់សិលាមួយដុំចារឹកថា: "ហេតុផលនៃដីវភាព, ព្រះ

---

១ សភាពទេយ្យទានតាមច្បាប់បុរាណហិណ្ឌូ ។

តថាគត[1] បានទេសនាដូន្មានយើង ហើយដោយច្បាស់លាស់, ធម៌អ្វី ដែលធ្វើសត្វឲ្យចាកចេញពីសេចក្តីទុក្ខនៃដីវភាព, ព្រះបរមគ្រូបានព្រះ ភជ្ជានុភាពហើយ" ។

ពាណិជចាំង ២ នាក់ទៀតទៅទៀតថា: នៅក្នុងទន្សាននេះមាន មហាសន្ទិប្បាតមួយ ដែលព្រះបរមគ្រូទ្រង់បានទេសនាអំពីតតិបណ្ឌិត, លទ្ធិផ្សេងៗ ធ្វើឲ្យចិត្តអ្នកដែលស្តាប់មានសភាពជ្រះថ្លាពន់ពេក ទាល់តែមានមនុស្ស ៤០០ នាក់ បានឧបសម្បទាជាភិក្ខុដូចព្រះបរមគ្រូ ហើយ នាំគ្នាផ្សាយក្បួនច្បាប់ធម៌វិន័យរបស់ព្រះអង្គ ហើយទ្រង់បានបញ្ចប់ ព្រះឧភតថា: "បាននាំឲ្យចំរើនបំណុលដែលត្រូវតែសង, បុណ្យនាំ មនុស្សឲ្យចេញចាកផុតពីបំណុលដោយសង់បំណុលជ្រះស្រឡះ កុំធ្វើ បាប, ឲ្យប្រព្រឹត្តបុណ្យ, រក្សាចិត្តឲ្យផូរផង់: នេះជាផ្លូវវិសេស" ។

ដល់ពាណិជនោះពោលចប់ហើយ, ព្រះនាងទ្រង់បានចែកទេយ្យ-ទាន ទាំងមានព្រះឧស្សាហ៍ពោះពីសាជាងរតន:ទៅទៀតទៅកាន់ពាណិជ ។ ព្រះនាងទ្រង់សួរទៅពួកពាណិជថា: "ចុះព្រះសាស្តាចារ្យទ្រង់យាង មកតាមផ្លូវណា, លោកគា? ។ ពួកពាណិជក្រាបទូលព្រះនាងថា: ព្រះអង្គទ្រង់ស្ថិតនៅក្នុងទីមួយចម្ងាយពីកំពែងព្រះភជ្ជានី ៦០ យោជន៍ ហើយទ្រង់រៀបយាងទៅកាន់ក្រុងភជ្ជនីះ ដែនមានផ្លូវមួយបែកទៅទីក្រុង

---

១ អ្នកដែលធ្វើតាមគ្នា គឺដាតាមនៃព្រះសិទ្ធត្ថ ថាព្រះអង្គទ្រង់បានត្រាច់តាមផ្លូវដូចគ្នានៃ ព្រះពុទ្ធពីបុរាណ ។

សោណៈនឹងគិរីដាច្រើន ។ គោទូលព្រះបង្គំទាំងអស់គ្នាបានធ្វើដំណើរមកពីទីនោះប្រាំបីកុសក្នុង ១ ថ្ងៃ ឋានមកដល់ទីក្រុងក្នុងរវាង ១ ខែ" ។

ព្រះមហាក្សត្រទ្រង់ជ្រាបតំណឹងនេះ ឋានចាត់ពាជអាមាត្យក្នុងព្រះបរមពាជវាំងដ៏សេះ, ពាជបេសកជន ៩ នាក់ទឹងអគ្គពាជទូតម្នាក់ៗ ឋានទទួលព្រះពាជឧង្ការទូវព្រះបន្ទូលសួរសីហនាទៅគ្រាបទូលព្រះសម្មាសម្ពុទ្ធថា: អញចាស់ជរាទន់ខ្សោយជាខ្លាំង ដោយសារអញមិនបានយល់ឮវព្រះរូបព្រះសាស្តាក្នុងវយៈរវាល ៧ ឆ្នាំ ហើយអញតែងចាត់ឲ្យស្វែងរកព្រះសម្ពុទ្ធគ្រប់ទិវាពត្រីមិនដែលដាច់, ឲ្យកូនអញត្រឡប់មកគ្រងប្រជារាស្ត្រនៃព្រះពាជអាណាចក្រ ដែលបានសោកព្រួយថ្លូវចំពោះកូនអញ ព្រោះប្រជារាស្ត្រទាំងអស់ខ្ចាចកូនអញមរណៈមុន មិនបានឃើញមុខកូនអញ" ។

(មានត)

គុណនៃការស្នេហាជាតិ

ស្រឡាញ់អ្វីពុំប្រសើរស្មើនឹងស្រឡាញ់ជាតិ
ព្រោះជាគុណអាចរាតត្បាវិហារសាធារណ៍ទៅ
ផ្សាយពេញដែនខែត្រខេត្តដល់ជាតិខ្មែរគោរពលូនខ្លៅ
ដោយចិត្តដៅប្រឹងស្ងួយជួយយកតយោងចាកអាយ័ត ។

យូរ - អ៊ុន

សម្មាទិដ្ឋិកថា

ព្រះអារាមរួម អាំ - សាម៉ុល វត្តមហាមន្ត្រី ភ្នំពេញ

ទេសនាជាកិច្ចឃោសនាសព្វនៃប្រទេសកម្ពុជា ក្នុងពិធីថ្ងៃ ១៥ រោចខែកត្តិកឆ្នាំកុរនព្វស័ក ព. ស. ២៤៩០ ត្រូវនឹងថ្ងៃ ១២ ធ្នូ ឆ្នាំ ១៩៤៧

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះអរហំសម្មាសម្ពុទ្ធជាម្ចាស់ ព្រមទាំងព្រះសទ្ធម្មនិងព្រះសង្ឃ ដោយសេចក្តីគោរព ។

ពេលនេះ អាត្មាភាពត្រូវនេសំដែងធម្មទេសនាផ្សាយតាមវិស័យ អាត្មាភាពនឹងសំដែងអំពី សម្មាទិដ្ឋិ គឺអង្គទី១ ក្នុងអដ្ឋង្គិកមគ្គ ដើម្បីចែកជូនពុទ្ធសាសនិកជន ដូចតទៅនេះ :-

ទិដ្ឋិ ប្រែថា "សេចក្តីយល់ឃើញ"; សម្មា ប្រែថា "ប្រពៃ, ត្រូវ" សម្មាទិដ្ឋិ ប្រែថា "សេចក្តីយល់ឃើញត្រូវ, យល់ឃើញប្រពៃ" ។ សម្មាទិដ្ឋិនោះ បានខាងបញ្ញា ដែលជាសោភនចេតសិកដ៏ក្លាហានគោងយកព្រះនិព្វានមកជាអារម្មណ៍ ដឹងច្បាស់ក្នុងអរិយសច្ច-ទាំង ៤ មានទុក្ខសច្ចជាដើម ហើយប្រតិបត្តិដឹកគាស់រំលើងបង់នូវអវិជ្ជានិងតណ្ហាឲ្យអស់ទៅ ។ សម្មាទិដ្ឋិនេះជាគូសត្រូវ ឬជាទំនាស់នឹងមិច្ឆាទិដ្ឋិ ។ ឯមិច្ឆាទិដ្ឋិ ប្រែថា "សេចក្តីយល់ឃើញខុស,

ពុំឃើញច្បៃពៃ" ។ ដែលពុំឃើញប្រៃពៃដូច្នេះតើមកអំពីអ្វី? គឺមកតែអំពី
អវិជ្ជា ។ ឯសម្មាទិដ្ឋិ ដែលថាយល់ឃើញត្រូវនោះ ព្រោះមានវិជ្ជា ។

ចុះអវិជ្ជាជាឈ្មោះរបស់អ្វី? វិជ្ជាជាឈ្មោះរបស់អ្វី? ទោសទីធ
អានិសង្សរបស់អវិជ្ជានឹងវិជ្ជានោះដូចម្តេច?

អវិជ្ជាជាឈ្មោះរបស់សេចក្តីមិនចេះដឹង, សេចក្តីមិនចេះមិនដឹង
ហៅថា សេចក្តីល្ងង់, បើមិនចេះអក្សរនឹងលេខ ហៅថា ល្ងង់កង់អក្ស
រនឹងលេខ, មិនចេះធ្វើការណា ហៅថា ល្ងង់កង់ការនោះ, បើមិនចេះគិត
ហៅថា ល្ងង់កង់ការគិត, អ្នកណាមានសេចក្តីល្ងង់ អ្នកនោះឈ្មោះ
ថាមនុស្សឥតមានចំណេះវិជ្ជា, អ្នកណាឥតមានចំណេះវិជ្ជា អ្នកនោះ
ឈ្មោះថាមនុស្សល្ងង់ៗ នោះបើនឹងធ្វើការអ្វី ការនោះច្រើនតែមិនកើត បើ
ទុកជាកើតក៏ច្រើនតែមិនល្អ. បើនឹងនិយាយពាក្យណា ពាក្យនោះច្រើន
មិនប្រាកដ, បើនឹងគិតហេតុណា ហេតុនោះមិនចេញមកសំដែងឲ្យប្រាកដ.
ថាខុស ឬត្រូវបានទេ ។ មនុស្សល្ងង់ឧបមាដូចមនុស្សខ្វាក់ ជម្មតា
មនុស្សខ្វាក់កម្រនឹងដើរតាមផ្លូវឲ្យត្រង់នឹងរហ័សនាប់បានឡើយ ព្រោះ
មានសេចក្តីញាញើតញាញើមរួញរាស្ទាក់ស្ទើរក្នុងចិត្តជានិច្ច ម្ល៉ោះហើយ
សេចក្តីមិនប្រាកដក្នុងចិត្តនោះ ធ្វើដំណើរមិនឲ្យប្រាកដថាទៅមុខ ឬទៅ
ខាង ច្រើនទីសឋាសដូចគ្នានឹងមនុស្សល្ងង់ បើនឹងធ្វើ ឬនិយាយ ឬគិត
ក៏ឥតមានប្រាកដក្នុងចិត្ត. សេចក្តីមិនប្រាកដនេះឯង មិនអាចនឹងធ្វើ
ប្រយោជន៍ដែលខ្ជួនត្រូវការឲ្យសម្រេចបានឡើយ ។

មានពុទ្ធភាសិតមួយកន្លែងសំដែងថា: មោហៈគឺសេចក្តីល្ងង់ បើមានច្រើនកង់សន្ធានចិត្តអ្នកណាមួយហើយ អាចនឹងធ្វើអ្នកនោះមិនឲ្យស្គាល់សេចក្តីអាក្រក់ល្អនឹងការខុសត្រូវបានឡើយ ។

មានសុភាសិតមួយបទទៀតសំដែងថា

វិជ្ជាវិសេសលើសទ្រព្យធន ចោរមិនអាចប្លន់ឆក់លួចបាន
វិជ្ជាគ្មានថ្លៃនឹងប្រមាណ ប្រើចេះតែបានគ្រប់វេលា ។

បណ្តាទ្រព្យសម្បត្តិទាំងអស់ដែលមានក្នុងលោកនេះ គោះជារបស់ឥតវិញ្ញាណដូចយ៉ាងលុយកាក់ ឬបាក់កាសតែវែងជាដើមក្តី គោះជារបស់មានវិញ្ញាណដូចយ៉ាងខ្ញុំកំដរប្រុសស្រីគោក្របីសេះដំរីជាដើមក្តីវិជ្ជាចំណេះការចេះដឹងកង់អក្សរ ក្នុងលេខនព្វន្តគុណហារ ក្នុងភាសាជនជាតិភាសាប្រទេសផ្សេងៗ ក្នុងការគូររាំសន្ធាក់ក្សរក្សាច់ចេនា ចំណេះវិជ្ជាខាងហត្ថកម្មកសិកម្មវណិជ្ជកម្មជាដើមនេះឯង ប្រសើរវិសេសថ្លៃថ្លាជាងទ្រព្យសម្បត្តិគ្រប់មុខ ដែលជាទ្រព្យឥតវិញ្ញាណមានវិញ្ញាណនោះវិញ ព្រោះថាទ្រព្យសម្បត្តិទាំងនោះ មិនជារបស់មានខ្ចឹមសារបិតបៀរយូរប៉ុន្មាន គង់មានវិនាសទៅដោយភ័យច្រើនប្រការ ដូចយ៉ាងភ័យអំពីចោរលួចប្លន់ឆក់ជាដើម, ភ័យអំពីភ្លើងឆេះផ្ទះសម្បែង, ភ័យអំពីទឹកលិច, ឬវិនាសទៅដោយល្បែងបៀជាដើម ។ ឯចំណេះវិជ្ជានេះ ផុតស្រឡះអំពីភ័យទាំងឡាយមានចោរភ័យជាដើមនោះ គឺថាភ័យទាំងឡាយមានចោរភ័យ

ជាដើមនោះមិនអាចនឹងបៀតបៀនចំណេះវិជ្ជា ដោយការលួចប្លន់ឆក់ដណ្តើម កំហែងគម្រាមម្ចាស់ចំណេះវិជ្ជានោះបានឡើយ ដោយហេតុនេះហើយបានជាពោលថា ចំណេះវិជ្ជានោះវិសេសថ្លៃថ្លាជាងទ្រព្យសម្បត្តិទាំងអស់ ។

ម្យ៉ាងទៀត ចំណេះវិជ្ជានេះនឹងកាត់ថ្លៃថាមានដំឡៃប៉ុណ្ណេះប៉ុណ្ណេះមិនទាំងបានផង, ព្រោះថាជនណាមួយជាអ្នកមានទ្រព្យសម្បត្តិធនធានច្រើន តែជាអ្នកខ្វិលច្រអូសក្នុងការរៀនសូត្រ ជននោះចង់បានចំណេះវិជ្ជាហើយយកច្បាក់កាសមានចំនួនច្រើនពាន់ច្រើនហ្មឺន ទៅដូរឬទិញចំណេះវិជ្ជានោះអំពីអ្នកណាមួយ ហើយប៉ងនឹងផ្ទេរចំណេះវិជ្ជានោះឲ្យរតឹបចូលទៅក្នុងមាត់ឬក្នុងពោះ ដោយមិនចាប់រៀនសូត្រនោះមិនបានឡើយ កុំថាតែគ្រូឬអ្នកមានចំណេះវិជ្ជានោះ នៅជាបុថុជ្ជនដូចយ៉ាងយើងក៏ល់រូបឡើយ សូម្បីតែព្រះលោកនាថជាម្ចាស់ ដែលព្រះអង្គជាឯកអគ្គបុគ្គលជាឆ្នើមជន ជាអគ្គអរហន្តយ៉ាងថ្លៃថ្លា វិសេសទាំងអម្បាលហ្នឹង ក៏ព្រះអង្គមិនអាចនឹងចាប់ទាញចំណេះវិជ្ជាជាលោកិយឬលោកុត្តរៈ ច្រកបញ្ចូលឲ្យចូលទៅក្នុងមាត់ឬក្នុងពោះនៃមនុស្សខ្វិលនោះបានទេ កុំថាដល់ទៅចំណេះវិជ្ជាដែលធំៗ ដែលថ្លៃថ្លានោះឡើយ សូម្បីតែកំទេចកំទីចំណេះវិជ្ជា ដែលជារបស់ទន់ខ្ចាបថោកថយ នោះនឹងយកច្បាក់ចំនួនពាន់ហ្មឺនទៅទិញក៏ពុំបាន តែខ្វិលរៀនហើយកុំសង្ឃឹម មុខជាខានបានវិជ្ជា ។

ដោយហេតុនេះហើយបានជាថាចំណេះវិជ្ជាគាត់ថ្លៃមិនបាន ។ ម្យ៉ាងទៀត ទ្រព្យសម្បត្តិចាំងពួងប្រែចេះតែអស់ទៅ។ តិចទៅ។, បើមិនរកថែមទៀត បានតែខាងចាយម្យ៉ាងនោះ ក៏មុខជាអានប្រើប្រាស់ ។ ឯចំណេះវិជ្ជាវិញមិនដូច្នោះទេ ប្រើច្រើនទៅក៏រឹងតែចំរើនឡើង។ មិនចេះថយ មិនចេះស្រក មិនចេះអស់, ដូចអ្នកចេះចំណេះវិជ្ជាខាងច្បាប់ទម្លាប់, អ្នកនោះ បើបានទៅសំដែងប្រាប់ឬពន្យល់អ្នកណា ឬទៅបង្រៀនគេហើយ ច្បាប់ទម្លាប់នោះ ក៏រឹងតែចាំស្ទាត់ប្រាកដឡើង រឹងតែតែបែកព្រោងព្រាតឡើង; ឬក៏ដូចជាអ្នកចេះអក្សរកាព្យឃ្លោង, អ្នកនោះបើបានសំដែងប្រាប់ពន្យល់ ឬតែងញឹកញាយហើយ អក្សរនឹងកាព្យឃ្លោងនោះ ក៏រឹងតែស្ទាត់ជំនាញសរសេរហ័សរហួន ឯកាព្យឃ្លោងកាន់តែពីពេរឡើង។ បែកឡើង។ លែងចាំបាច់នឹកនា គ្រាន់តែថាបាន។ ។ ដោយហេតុនេះហើយបានជាថា ចំណេះវិជ្ជាប្រើមិនចេះអស់ទេ ចេះតែចំរើនទៅខាងមុខជានិច្ច ។

មិនតែប៉ុណ្ណោះ ចំណេះវិជ្ជាអាចផ្តល់ប្រយោជន៍ឲ្យគ្រប់ពេលវេលា ដោយហេតុនេះហើយ បានជាថាចំណេះវិជ្ជានេះជាមិត្តទីមួយ របស់មនុស្សប្រុសស្រី ។ មួយវិញទៀត ចំណេះវិជ្ជាអាចនឹងធ្វើអ្នកខ្វះខ្ជិនឲ្យគេគោតខ្ចាចគោរពប្រណិប័តន៍ គឺថាជនណាមួយដែលមានពូជពង្សថោកទាប ប្រមានរូបរឹតលវិការៈយ៉ាងណាក៏ដោយ បើមានចំណេះវិជ្ជា

ចេះជ្រើសរើសក្បាលក្បាយហើយ ជននោះបើទៅក្នុងចំណាមមួយចំណោះវិជ្ជានេះ ក៏ហាក់ដូចជាទៅចាប់ខាញ់មនុស្សប្រុសស្រីឲ្យក្រោកចាកចិត្តខ្លួនឯងដែរ គោរពប្រណិប័តន៍កោតក្រែងចំពោះជននោះឯង ។

ម្យ៉ាងទៀតចំណេះវិជ្ជានេះ អាចនឹងធ្វើមនុស្សម្នាក់ឲ្យមានដំឡៃស្មើនឹងមនុស្សមួយពាន់នាក់មួយហ្មឺននាក់ ឬច្រើនជាងនេះទៅទៀត សេចក្តីនេះយ៉ាងណា ? ថាដូចជាអ្នកណាមួយ ដែលគេចេះចំណេះផ្លូវលោកផ្លូវធម៌សព្វគ្រប់គ្មានចន្លោះ ព្រមទាំងចំណេះវិជ្ជាសម្រាប់ស្រុកស្រែខេសរបស់ខ្លួន នឹងចំណេះវិជ្ជាសម្រាប់តាងប្រទេសផ្សេងៗ ហើយអ្នកនោះក៏បានទទួលនូវតំណែងយសក្រោតជាធំ បើប្រសិនជាមានកំហុសអ្វីគួរដល់បញ្ជាជនីយកម្មក្តី គួរផ្តាច់បង់ជីវិតក្តី, មនុស្សប្រុសស្រីទាំងឡាយ ទាំងពាន់ហ្មឺននាក់គួរប្រថុយជីវិតឬរង្គំនូវមនុស្សម្នាក់នេះដែរ នេះដោយហេតុអ្វី ? គឺដោយហេតុតែចំណេះវិជ្ជានេះហើយ ដែលធ្វើមនុស្សម្នាក់ឲ្យមានដំឡៃប្រហែលនឹងមនុស្សទាំងពាន់ទាំងហ្មឺននាក់នេះឯង គួរឲ្យអស្ចារ្យណាស់ហ្ន៎! ចំណេះវិជ្ជានេះមានគុណប្រយោជន៍ច្រើនប្រការណាស់ ដោយហេតុនេះហើយ គួរតែសាធុជនប្រុសស្រីក្មេងចាស់គ្រហស្ថបព្វជិត ខំសូរសៃរកវៀនចំណេះវិជ្ជាផ្លូវលោកផ្លូវធម៌ ឲ្យបានចេះដឹងគ្រប់ៗ គ្នាទៀង កុំគប្បីធ្វេសប្រហែសឡើយ ។

ម្យ៉ាងទៀតអ្នកដែលមានកូន ត្រូវរំពឹកជាស់តឿនកូនឲ្យរៀនចំណេះវិជ្ជាឲ្យបានចេះដឹងទៀង ព្រោះកូនដែលគ្មានចំណេះវិជ្ជា ជាមនុស្ស

លួងមិនប្រព្រឹត្តតាមច្បាប់ នឹងមានប្រយោជន៍អ្វីដោយសារកូនដូច្នោះ ប្រៀបដូចមាដូចក្អែកខ្វាក់ នឹងមានប្រយោជន៍អ្វីដោយក្អែកខ្វាក់នោះ មានតែសេចក្តីអផ្សុកព្រួយចិត្តតែម្យ៉ាង ។

កូនមាន ៣ គឺកូនដែលមិនទាន់កើត ១, កូនដែលកើតហើយស្លាប់បាត់ទៅវិញ ១, កូនដែលកើតហើយនៅរស់ តែជាមនុស្សលួងខ្លៅ ១, បណ្តាកូនទាំង ៣ នេះ គួរយកកូន ២ ខាងដើម ព្រោះថាបើមានទុក្ខព្រួយក៏មានតែមួយលើកក៏បាត់ទៅ, ឯកូនមួយទីបំផុតនោះមិនគួរយកឡើយ ព្រោះកូននោះនឹងនាំបុណ្ណាលឲ្យមានសេចក្តីទុក្ខព្រួយជានិច្ច ។

ក្នុងគម្ពីរលោកនីតិបករណៈសំដែងថា ៖

មានកូនមិនឲ្យកូនសូត្រវៀន ចំណេះវិជ្ជាគ្រានានា
មាតាលោកថាជាវៃរ បិតាទុកជាសត្រូវធំ ។
កូនពេញវ័យមិនឈ្លាសឆ្លៀវ ហៅថាមិនថ្លៃក្នុងជំនុំ
ប្រៀបដូចកុកគ្រោងចូលទ្រនំ កណ្តាលជំនុំនៃពួជន ។

ដែលនាំសុភាសិតខ្លះមកទុកក្នុងទីនេះ ដើម្បីឲ្យឃើញថា សេចក្តីលួងនេះ បើកើតមានដល់អ្នកណាហើយ នឹងត្រឡប់ទៅជាទោស ធ្វើអ្នកនោះឲ្យបានដល់នូវសេចក្តីមិនចំរើន នឹងទន់ខាបថយថោក តាំងពីជាតិនេះជាបដល់ជាតិខាងមុខ ។ ឯទោសនៃសេចក្តីលួងដែលនឹងឃើញក្នុងជាតិនេះ ដូច្នេះ :-

๑ – បើលួងក្នុងវិធីអក្សរ គឺមិនចេះសរសេរ មិនចេះមើល នឹងនាំឲ្យខាតបង់នូវប្រយោជន៍ដូច្នេះ គឺមិនអាចមើលសាស្ត្រា ឬសៀវភៅដែលមានច្បាប់ប្រដៅនាំឲ្យកើតគំនិតប្រាជ្ញា ឬមិនអាចសរសេរសំបុត្រកត់ហេតុណានីមួយ ដែលខ្លួនត្រូវការផ្ញើទៅញាតិមិត្តបាន ។

๒ – អ្នកដែលមិនមានចំណេះវិជ្ជាអ្វី បើនៅអាស្រ័យជែកគោនក្នុងសំណាក់អ្នកធំហើយ ចេះគោរពប្រណិប័តន៍យ៉ាងណាក៏ដោយ អ្នកធំនោះក៏មិនអាចលើកតំកើងអ្នកនោះ ឲ្យមានកេរ្តិ៍ឈ្មោះយសស័ក្តិបានឡើយ ព្រោះលោកយល់ថាជាមនុស្សល្ងង់ បើគ្រាន់បើណាស់ បានតែមានសេចក្តីសុខជាន់ទាបប៉ុណ្ណោះ តែក៏គង់មិនរួចអំពីទីជាអ្នកបំរើគេដែរ ។

๓ – មនុស្សល្ងង់នោះ បើមានយសស័ក្តិ ដោយអំណាចព្រៃងសំណាងជួយឧបត្ថម្ភ បើនិយាយការអ្វីទៅរកគេ គេពុំសូវជឿតាមពុំកោតខ្លាច ព្រោះគេដឹងថា ខ្លួនជាមនុស្សល្ងង់ ។

๔ – មនុស្សល្ងង់ ជាមនុស្សខ្វាត់មិត្តសំឡាញ់ ព្រោះគេមិនសូវត្រូវការយកខ្លួនធ្វើជាមិត្តសំឡាញ់ឡើយ ព្រោះហេតុអ្វី? ព្រោះគេដឹងថាខ្លួនជាមនុស្សល្ងង់ បើនឹងពឹងរកយកទៅធ្វើការអ្វី ឬជួយពិគ្រោះការអ្វីក៏មិនកើតទាំងអស់ . បើនុគណាជាមានមិត្តសំឡាញ់ ក៏ច្រើនតែបានមិត្តសំឡាញ់ដែលជាមនុស្សល្ងង់ដូចគ្នា ។

๕ – មនុស្សល្ងង់បើជាអ្នករកស៊ី ក៏មិនអាចនឹងធ្វើសម្បត្តិឲ្យចំរើនដូចអ្នកដែលចេះដឹងបានឡើយ ព្រោះខ្លួនមិនស្គាល់កាលគួរនឹងកាលមិនគួរ ។

៦- មនុស្សល្ងង់មិនដែលបាននេចក្តីសរសើរ អំពីសំណាក់អ្នកឲ្យជាណាមួយដល់ម្តងឡើយ ប្រើបានសរសើរខ្លះតែអំពីសំណាក់នៃមនុស្សល្ងង់ជាង២ខួន ។ ពោសនៃនេចក្តីល្ងង់សឆ្កេបខ្លីតែប៉ុណ្ណោះ ។

អានិសង្សនៃការចេះដឹង ដែលឃើញបា្លស់ក្នុងជាតិនេះ ដូចខ្នះ :-

១- បើចេះវិធីលេខឬអក្សរ គឺចេះសរសេរឬមើល នឹងនាំឲ្យមានប្រយោជន៍អាចមើលសាស្តាឬសៀវភៅ ដែលជាច្បាប់ប្រដៅ នាំឲ្យកើតគំនិតឲ្យជ្រាជ្រៅ ឬអាចសរសេរសំបុត្រកត់ហេតុណាមួយ ដែលខ្លួនត្រូវការផ្ញើទៅញាតិមិត្តបាន ។

២- អ្នកដែលមានចំណេះវិជ្ជា បើនៅធ្វើការក្នុងសំណាក់អ្នកធំដោយយកចិត្តទុកដាក់ អ្នកធំនោះលោកនឹងស្រឡាញ់ពាប់អាន ហើយអាចទំនុកបំរុងឲ្យមានក្តីឈ្មោះ យសស័ក្តិថ្កើងថ្កានឡើងបាន ព្រោះលោកយល់ថាខ្លួនមានចំណេះវិជ្ជា ។

៣- អ្នកមានចំណេះវិជ្ជា បើជាអ្នកមានយសស័ក្តិ ក៏មានសេចក្តីថ្កុំថ្កើងរុងរឿងក្នុងទីប្រជុំ បើនិយាយការអ្វីៗ គេក៏ផ្ទៀងស្តាប់តាម ព្រោះគេយល់ថាជាអ្នកចេះ ។

៤- អ្នកចេះ ជាមនុស្សសម្បូណ៌ដោយមិត្តសំឡាញ់ ព្រោះថាអ្នកឯទៀតគេចិនត្រូវការយកអ្នកមានចំណេះវិជ្ជានោះ ធ្វើជាទីពឹងក្នុងពេលដែលមានកិច្ចធុរៈអ្វីៗបាន ។

៥ – អ្នកចេះ ប៉ើតាំងខ្លួនជាអ្នករកស៊ីតាមធម្មតាវិញ ក៏មានសេចក្តីចំរើនក្នុងការរកស៊ីនោះ ព្រោះជាអ្នកមានគំនិតចេះគិតស្គាល់ទំនងនៃការរកស៊ី មានស្គាល់ការគួរនឹងមិនគួរជាដើម ។

៦ – អ្នកមានចំណេះវិជ្ជា រមែងបានទទួលនូវសេចក្តីសរសើរ អំពីសំណាក់អ្នកប្រាជ្ញជារឿយៗ ។

ហេតុដូច្នេះ អស់លោកទាំងឡាយគួរខ្ចីម គួរស្តាប់សេចក្តីល្អដ៏ កុំបណ្តោយចិត្តឲ្យសេចក្តីល្អដ៏ចូលមកលុកលុយបានឡើយ គួរតាំងសេចក្តីព្យាយាម ច្រឹងច្រែងស្វះស្វែងរករៀនចំណេះវិជ្ជា មកទុកជាកំកងខ្លួនដើម្បីនឹងបំបាត់បង់នូវសេចក្តីល្អដ៏ចេញបន្តិចម្តងៗ ជាលំដាប់តទៅ ។

វិជ្ជាជាឈ្មោះរបស់សេចក្តីចេះដឹង បើអ្នកណាមានចំណេះវិជ្ជាហើយ អ្នកនោះរមែងបានទូវអានិសង្សដ្ចូចពណ៌នាមកនេះ ។ ហេតុដូច្នេះ ចូរពួកយុវជន យុវនារីតាំងឡាយ ខំរករៀនចំណេះវិជ្ជា ឲ្យបានចេះដឹងមាំមួនដើម្បីនឹងជួយជ្រោមជ្រែងជាតិ សាសនា មហាក្សត្រ របស់យើងឲ្យបានប្តូចប្តើងរុងរឿង ឲ្យបានដើរទាន់សម័យទំនើបគេឡើង ។

អាត្មាភាពសំដែងអរិយមគ្គទី ១ គឺសម្មាទិដ្ឋិ ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

រឿងមនុស្សថ្មី

លោកធើង-ជ្រើរ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែពីសៀវភៅ «កុង អេ ឡេហ្សង់ ឌុយប៉េអ៊ី រូម៉ុងត្រាឌ្វីប៉ាអេ អាជាប្តេ ប៉ា ប.នរទីន»

កុងកាលដ៏កន្លងទៅយូរអង្វែងហើយ. ព្រះពជាមួយព្រះអង្គ មានមហេសីពីរព្រះអង្គនៅក្នុង ។ ទ្រង់នូវព្រះរូបធោមធាយាស្អាតល្អដូចគ្នា តែមិនមានព្រះពជបុត្រ ។

ថ្ងៃមួយ មានព្នង់ខ្មៅម្នាក់ចូលមកក្រាបថ្វាយបង្គំព្រះពជា ហើយទូលថា: « បពិត្រព្រះមហាពជដ៏ទ្រង់យស! ទូលព្រះបង្គំបានដឹងថាព្រះអគ្គមហេសីគ្មានព្រះពជបុត្រ បើដូច្នេះ សូមឲ្យព្រះនាងសោយទឹកស្មៅនេះនោះព្រះនាងនឹងមានព្រះពជបុត្រជាបុាកជ" ។ ព្រះពជាទ្រង់ប្រទានសេះមួយយ៉ាងល្អ ទឹងសំពត់អាវដ៏មានតម្លៃដល់ព្នង់នោះ ហើយទ្រង់ប្រទានថ្នាំនោះឲ្យទៅព្រះមហេសី ។ ព្រះនាងទ្រង់មានព្រះសុវនីយ៍ហៅនាយពិសេសស្ត្រីម្នាក់មក ហើយប្រគល់ស្មៅនោះឲ្យយកទៅស្ងោយកទឹកថ្វាយទ្រង់ តែមិនបានប្រាប់រឿងហេតុនៃថ្នាំនោះទេ ។ នាងពិសេសក៏ធ្វើតាមព្រះពជបញ្ជា ហើយមុនទឹងយកទឹកទុសថមកថ្វាយព្រះនាងស្រីបំរើក្រែបមើលបន្តិច ។ លុះកាលកន្លងទៅ ព្រះអគ្គមហេសីទឹងនាងពិសេសប្រសូតបានកូនប្រុសមួយម្នាក់ល្អៗដូចគ្នា មួយឈ្មោះតាជិន មួយឈ្មោះ អាវិន ។

ថ្ងៃមួយ ព្រះពជាទ្រង់យាងចេញទៅធ្វើសឹកសង្គ្រាម ប្រគានសិទ្ធិ
ឲ្យព្រះពជបុត្រជាអ្នកគ្រប់គ្រងស្នងព្រះអង្គ ប្រគល់កូនសោមួយចង្កោម
ដំឲ្យផង ហើយទ្រង់មានព្រះបន្ទូលថា: "ម្នាលកូនសំឡាញ់ឪពុក! កូន
សោទាំងប៉ុន្មាននេះអាចចាក់បើកបន្ទប់បានទាំងអស់ ហើយកូនអាចចូល
បានគ្រប់ ។ ប៉ុន្តែ បន្ទប់មួយដែលចាក់បើកបានដោយកូនសោមាស កូន
កុំចូលក្នុងបន្ទប់នោះឲ្យសោះ ព្រោះបើកូនឯងចូលក្នុងបន្ទប់នោះ សេចក្តី
ទុក្ខនឹងមានដល់ខ្លួន" ។

ខាងក្រោយការធ្វើដំណើរចេញទៅនៃព្រះពជា ព្រះពជកុមារយាង
ទតគ្រប់បន្ទប់ផ្សេងៗ ទាំងអស់ ទ្រង់ប្រទះសុទ្ធតែគំនរគ្បួងពេជ្រយ៉ាង
ធំតៗ ប៉ុន្តែសម្បត្តិទាំងនេះ ទ្រង់គ្មានត្រូវការសោះ ។ ទ្រង់ឈរឈប់
នៅមុខបន្ទប់កូនសោមាស ហើយនឹកដល់ព្រះពជនុឆ្ការនៃព្រះវរបិតា ។
អទ្ធិធម៌ចេះតែទន្ទ្រានលុកលុយក្នុងចិត្តព្រះពជកុមារ។ ក៏ចូលក្នុងបន្ទប់
ដែលហាមនោះ, ក្នុងបន្ទប់នោះមានរ៉ែនតាតែវចរណៃមួយ ។ កាលណា
ព្រះពជកុមារទតកងរ៉ែនតា ទ្រង់បានឃើញប្រាសាទមួយជារិការនៃមាស
ក្តីចិញ្ចេចចិញ្ចែងជាងពន្លឺថ្ងៃ ។ ក្នុងប្រាសាទនោះ មានព្រះពជធីតា
មួយព្រះអង្គព្រះនាម "កីឡាលីណា" ល្អដូចស្រីទេពអប្សរ ។

ព្រះពជកុមារទ្រង់ទតសំឡឹងកងរ៉ែនតាអស់អំឡុងជាយ៉ាងយូរ ទើប
ដាក់រ៉ែនតាចុះត្រង់កន្លែងដើម ហើយយាងចេញចាកបន្ទប់កូនសោមាស
ដោយមានព្រះភ័ក្ត្រពោរពេញដោយព្រះជលនេត្រ ។

ព្រះពាជាមានដំយកាលណា ទ្រង់ស្តេចត្រឡប់មកវិញពុំហានបង្អន់, ប៉ុន្តែលុះស្តេចមកដល់ ព្រះអង្គមិនយើញព្រះពាជបុត្រសំឡាញ់ចេញមកទទួលព្រះអង្គដោយសេចក្តីរីករាយ យើញតែព្រះវរពាជជាយាតែម្នាក់ឯងចេញមកទទួល ។ ព្រះអគ្គមហេសីក្រាបបង្គំទូលថា: ព្រះពាជកុមារទ្រង់ប្រឈួន ។ ព្រះពាជាទ្រង់ជាបក្កង់ព្រះហ្ឫទ័យមួយរំពេចទូវហេតុនៃការប្រឈួននោះ ទើបទ្រង់ឲ្យគេហៅអស់គ្រូពេទ្យយ៉ាងជំនាញមក, ប៉ុន្តែគ្រូពេទ្យទាំងនោះក្រាបបង្គំទូលថា: ព្រះពាជកុមារលុះតែបានព្រះនាងកីឡាលីណា មកឆ្អែជាព្រះអគ្គទេពី ទើបជាសះស្បើយ ។ ព្រះបៅទ្រង់បញ្ជូនទូតបន្តកន្ទុយគ្នា ដើម្បីយកដំណឹងអំពីសំណាក់នាងកីឡាលីណា ប៉ុន្តែជាកិច្ចឥតអំពើ ព្រោះព្រះវរពាជបិតានៃព្រះនាងមិនចង់ឲ្យព្រះនាងមានព្រះស្វាមី ។

លុះបានដំណឹងអនិដ្ឋារម្មណ៍ដូច្នេះ ព្រះពាជកុមារសម្រេចក្នុងព្រះហ្ឫទ័យថា នឹងស្តេចទៅដណ្តឹងព្រះនាងដោយព្រះអង្គឯង ។ រួចទ្រង់បានមានបន្ទូលថ្កាប់អានៃជាសំឡាញ់ ទូរវៀនហេតុភាន់ភាល់នេះ ដែលជាការបណ្តាលឲ្យទ្រង់មានទុក្ខយ៉ាងធ្ងន់ ។ ថ្ងៃមួយជនទាំងពីរនាក់ ក៏ធ្វើដំណើរចេញទៅ ទោះបីព្រះពាជបិតា - មាតាឃាត់យ៉ាងណាក៏មិនស្តាប់ ។ ជនទាំងពីរត្រែចង្អៀតលេចក់លចូលព្រៃ លេចព្រៃចូលក់ល អស់អំឡុងថ្ងៃនឹងខែដំយូរ ទើបបានដល់ខួមយាយចាស់ម្នាក់ ឈ្មោះ តិរ៉ាត ។

ព្រះអង្គម្ចាស់គោះទ្វារ, យាយចាស់ចេញមក ហើយសួរសាកនូវដំណើរ ដើមទង្គសព្វគ្រប់ប្រការ, ព្រះអង្គម្ចាស់ទ្រង់សុំទូមគាត់សំណាក់មួយយប់ ទំពាំដល់ព្រឹកហើយឲ្យគាត់ប្រាប់ផ្លូវ ដែលទៅកាន់ព្រះរាជវាំងព្រះអង្គម្ចាស់ ក្សត្រីព្រះនាមកីឡាលីណាផង ។

យាយចាស់ឃើញកុមារទាំងពីរក៏មានចិត្តមេត្តាអាណិត ហើយ និយាយថា: នែចៅ! យាយឲ្យចៅឯងចូលសំណាក់ទៅនេះបានក្នុង មួយយប់ ប៉ុន្តែយាយខ្លាចត្រែងកាលណាកូនយាយមក វាធ្វើចៅឯងឲ្យ ក្លាយទៅជាដុំទឹកកក ។ បើដូច្នេះចូរចៅទៅឯផ្ទះបួនស្រីរបស់យាយវិញ ល្អជាជាង ដ្បិតវាប្រហែលនឹងអាចធ្វើនូវបដិសណ្ឋារៈដល់ចៅបានហើយ អាចបង្ហាញផ្លូវឲ្យទៀតផង ។

ព្រះរាជកុមារធ្វើដំណើរទៅទៀត បានដល់ផ្ទះយាយម្នាក់ឈ្មោះ កោធវ៉ាត ប៉ុន្តែទ្រង់មិនអាចឈប់នៅទីនោះបានយូរ រួចស្តេចទៅដល់ទូម យាយ ហិមវ៉ាត ។ ព្រះរាជកុមារគោះទ្វារហៅ, ស្រីម្នាក់ពងស្តើងរូបស្អាត បានបើកទ្វារចេញមក លុះឃើញព្រះរាជកុមារ គិមានវាចាថា: "បពិត្រ ព្រះអង្គម្ចាស់ហាវហាន! ទូលព្រះបង្គំដឹងជាមុនថា ទ្រង់ត្រូវការទៅ ជណ្តឹងព្រះនាងកីឡាលីណា ប៉ុន្តែលុះតែទ្រង់ប្រសើយជាមួយនឹងកូន ទូលព្រះបង្គំ ទើបអាចស្តេចទៅដល់នគរព្រះនាងបាន ។ បើដូច្នេះ សូម ទ្រង់សំណាក់ក្នុងទីនេះជាមួយនឹងសំឡាញ់របស់ទ្រង់សិន ។ ប៉ុន្តែត្រូវ

ទូលព្រះបង្គំយកទ្រង់ព្រមទាំងសំឡាញ់លាក់ឲ្យល្អត្រឹមត្រូវ បើពុំដូច្នេះទេ គាល់ណាកូនទូលព្រះបង្គំមកដល់ ហើយដឹងថាមានមនុស្សលោកនៅក្នុងទីនេះ នោះពុំនឹងសំឡាប់ខ្ញុំចោលជាអសារបង់ ។

ខណៈនោះ យាយហិមវ៉ាត ទះដៃបីដង ស្រាប់តែសកុណាមាសក្អែកតូចមកដល់ចំពុះត្បូងពេជ្រហើរលោតចុះមក យកស្លាបទាំងសងខាងគ្របក្តោបកុមារទាំងពីរ ហើយហើរស្ទុះលោតឡើងទៅលើទ្រនំវិញ ។

គ្រាន់តែកិច្ចការនេះរួចសព្វគ្រប់ហើយ គេឮសូរសន្ធឹកឮល់ត្រជាក់បក់មកមានទាំងក្លិនពិជោរផ្កាកូឡាប ឱនតិណ្ណជាតិផ្សេង ។ ដោយមកផងរួចគ្នារួមក៏របើកឯង គេឃើញមនុស្សកំឡោះម្នាក់រូបស្អាតដើរចូលមកសក់វែងក្រហម ស្បាបច្រាក់ ដៃកាន់ស្មៅនឹងផ្កាបុប្ផជាតិគ្រប់មុខ ។ ចូលមកដល់ស្ទើរតែមិនទាន់ឃើញក៏សួរថា: ម៉ែ! នៅទីនេះជុំក្លិនមនុស្សលោកម្ល៉េះ? ។

- កូនសំឡាញ់! ឯងធុំក្លិនមនុស្ស តើមនុស្សមកធ្វើអ្វីនៅទីនេះ ។

ព្រះពាយនៅស្ងៀមវិញ ចាប់បរិភោគអាហារ ។ ខាងក្រោយដៃលបានផឹកទឹកដោះពពែមួយកែវនឹងមេរ៉យមួយចាន លោកនិយាយរឿងកំសាន្តលេងដោយសប្បាយតាមធម្មតា ជាមួយនឹងម្តាយលោក ។ ម្តាយឃើញទុកាសស្រួលហើយ សួរថា: ម្ចាលកូន! ចូរឯងប្រាប់ម្តាយតើព្រះពរជ្រោរបស់ព្រះនាង ភីឡាលីណា នៅឯណា? ហើយម្យ៉ាងទៀតតើត្រូវធ្វើដូចម្តេច ដើម្បីយកនាងធ្វើជាមហេសីបាន? ។

ព្រះពាយធ្វើយថា: នុលោកម្ចាយ! សំនួរនេះមិនល្អធ្វើយច្រាប់ទេ, ប៉ុន្តែណ្ហើយ ដើម្បីបំពេញទឹកចិត្តលោកម្ចាយ ខ្ញុំសូមដំរាបបន្តិចទៅចុះ . . . ។

"ព្រះពាជរង្គានៃព្រះពាជធីតា ព្រះនាម "កិឡាលីណា" នៅឆ្ងាយអនេកអនន្តពេក បើទៅដោយការធ្វើដំណើរតាមផ្លូវធម្មតា គេត្រូវដើរអស់រាង៨ជាតិទើបបានដល់ ។ ប៉ុន្តែគេអាចទៅតែមួយប៉ព្រិចភ្នែកឲ្យបានដល់ ដោយគាត់តាមវិព្រតាឡវន ដែលនៅក្នុងនោះ មានជ្រោះទឹកលោហជាតិហូរច្រាញ់ចេញសុទ្ធតែដុំថ្មនឹងអណ្តាតភ្លើងទៅដល់កណ្តាលអាកាស ជ្រោះនោះគេត្រូវដើរលើដើមឈើមួយកំណាត់ ជារបស់ព្រាយទាំងឡាយដែលតែងធ្លាក់ជ្រោះនោះ . . . ។

"ប៉ុន្តែ បើជនណាបានឮខ្ញុំនិយាយ ហើយនាំយកទៅច្រាប់អ្នកដទៃ, ដើងនៃជននោះនឹងត្រូវក្លាយជាចំរុះតិចដល់ផង្គន់ . . . ។

"កាលណាបានទៅដល់ព្រះពាជរង្គាព្រះនាងហើយ អ្នកហាវហានត្រូវយកកំណាត់ឈើនោះ ធ្វើឲ្យក្លាយជាប្រើសមាស ហើយចូលតួនខាងក្នុង ដើម្បីឲ្យងាយបានទៅដល់ព្រះពាជដំណាក់នៃព្រះនាង នឹងលួចព្រះនាងមក . . . ។

"ប៉ុន្តែ បើជនណាបានឮខ្ញុំនិយាយ ហើយយកទៅច្រាប់អ្នកដទៃ, ដងខ្លួននៃជននោះនឹងត្រូវក្លាយជាឫស្សីមចង្រៃ . . . ។

"កាលណាអ្នកហាវហ្មានបានសេពសម្ផូពនឹងព្រះនាងហើយ យាយ
តិរ៉ាតឈឺចិត្ត នឹងបញ្ជូនឈ្មួញម្នាក់ឲ្យទៅលក់អាវនោះ ។ ព្រះនាងកីឡាលីណា នឹងទិញអាវនោះ,
ហើយមើមុននឹងពាក់ ព្រះនាងមិនបានយកអាវនោះទៅដុតកំចាត់ទឹកត្នែកសត្វលលកសិនទេ, នោះនឹងសុគតមួយរំពេច ក្នុងពេលដែលព្រះនាងគ្រាន់តែលើកអាវឡើងនឹងខ្លួន . . . ។

"អ្នកណាដឹងរឿងត្រង់នេះ ហើយយកទៅប្រាប់អ្នកដទៃ, ខ្លួននៃអ្នកនោះនឹងក្លាយជាថ្នាំងពីដើងរហូតដល់ក្បាល" ។

កាលយាយនិយាយរឿងនេះ ព្រះពជកុមារខ្លាំងផ្ទុលក់ ប៉ុន្តែសំឡាញ់របស់ខ្លួនដែលមិនដេក ចាន់ឮរឿងសព្វគ្រប់គ្មានសល់ ។

ភ្លើឡើង ព្រះនាងចេញផុតទៅ ។ ទាជិនជាព្រះពជបុត្រសួរម្តាយព្រះនាងថា: តើយាយនឹងអាចប្រាប់ដំណឹងអ្វីខ្លះដែរឬ? ។ យាយហ៊ឺមក៏ត ខ្លាចក្រែងក្លាយខ្លួនទៅជាថ្ម ក៏ក្រាបបង្គំទូលព្រះពជកុមារវិញថា: ខ្ញុំគ្មានបានអ្វីថ្លាយជាដំណឹងឡើយ ។

ខណៈនោះ កុមារតាំងពីរបានធ្វើដំណើរតទៅទៀតអស់កាលជ័យរួ។ ទៅពេលព្រះអាទិត្យជិតនឹងអស្តង្គត មាណពតាំងពីរបានឮសំរែកដ៏ខ្លាំងគឺជាសួរកេស្តាប់អ្វីមិនឮ ហើយបានឃើញគ្រាន់ទឹកលោហធាតុមួយ

យ៉ាងដំ នេះចេញអណ្តាតភ្លើងដែលផ្ទុះដុំចូទៅលើរហូតដល់អាកាស ។ ព្រះរាជកុមារឃើញហេតុដ៏ប្លែកអស្ចារ្យដូច្នោះ មានព្រះហឫទ័យតក់ស័យមហិមា ។ ប៉ុន្តែ អាវិនជាកូនមេនាយពិសេសក្រាបបង្គំទូលថា: សូមទ្រង់កុំព្រួយព្រះរាជហឫទ័យអ្វីឡើយ សូមស្តេចយាងចូលក្នុងវិមានជាមួយនឹងទូលព្រះបង្គំ ហើយទ្រង់នឹងឆ្លើយអ្វី ធ្វើតាមតែសេចក្តីបង្គាប់របស់ទូលព្រះបង្គំ ។

លុះដល់កណ្តាលភាឡែន អាវិនបានឃើញដើមឈើមួយកំណាត់ផ្តេកចោលនៅនោះ ។ មាណពទាំងពីរនាក់នាំគ្នាឡើងលើកំណាត់ឈើ ហើយគោះឈើនោះនឹងកែងដើមបីដង, កំណាត់ឈើក៏ក្លាយជារថមួយទឹមដោយអស្វាស្បាយហ៊ានដប់ពីរ។ គាត់រថនោះយ៉ាងលឿនដូចខ្យល់ទៅលើអាកាសរហាស, រួចមួយស្របក់ ក៏ចុះចំពីខាងមុខទ្វារច្រកសាទព្រះនាងតឹណាលីណា ។

មាណពទាំងពីរនាំគ្នាចុះពីរថ ចំណែករថនោះក៏ត្រឡប់ក្លាយទៅជាកំណាត់ឈើដូចដើមវិញ ។ គាជាន់ទទឹងអាវិនស្ថិតនៅត្រង់ទីជាខាងមុខច្រកសាទតែវ ។ ព្រះរាជធីតា គង់នៅក្បែរព្រះស័ហបញ្ជរ ទ្រង់ព្រះស្តង់ប៉ាក់ដោយខ្សែសូយមាសគ្មិចភ្លាច ។ គ្រាន់តែក្រឡេកឃើញព្រះរាជបុត្រតាលណា ព្រះនាងក៏តមានព្រះហឫទ័យប្រតិព័ទ្ធ ស្ទើរក្រុយព្រះជន្មមួយរំពេច ។ ទ្រង់ប្រឈួនពុំសោយព្រះក្រយាស្ងួយ ហើយផ្ទំលក់តែម្តង ។

ព្រះវរពជបិតាបស់ព្រះនាងទំរកថ្មាំមកវក្សាភេគាព្រះពជធីតា តែ
ឥតប្រយោជន៍ទាំងអស់ ។ លុះទីបំផុតមានយាយចាស់ម្នាក់ចូលមកក្រាប
បង្គំទូលព្រះពជាថា: បពិត្រព្រះសម្មតិទេពដ៏ខ្ពង់ខ្ពស់ប្រពិទ្ធានុភាព! បើព្រះ
អនុណាថ្ងៃវិសេសមានព្រះពជបំណងចង់ឲ្យព្រះពជបុត្រីបានជាសះស្បើយ
នោះ សូមខ្ញុំវកប្រើសមាសដែលចេះច្រៀងដ៏ពីរោះជាងសត្វបក្សីទាំង
ពួងក្នុងលោក ហើយសូមព្រះអង្គវក្សាប្រើសនោះខុកក្នុងព្រះបរមពជវាំង
តែមួយថ្ងៃ នោះព្រះអនុណានឹងបានឃើញព្រះពជធីតា ជាសះស្បើយ
ជាមិនខាន ។

ព្រះពជាខ្ញុំព្រះបញ្ជាឲ្យពជអាមាត្យប៉ាវែងខ្លួងកេរីប្រាប់អស់បណ្តា
ជនឲ្យជួយស្វែងវកប្រើសមាស ។ ក្នុងថ្ងៃទី ៣ អារិនគោះកំណាត់ឈើបី
ដង កំណាត់ឈើនោះក៏ក្លាយជាប្រើសមាស រួចបញ្ចេញសំដីនៅក្នុង
ពោះ ហើយដឹកយកទៅបញ្ជូរនៅពីខាងមុខប្រាសាទព្រះពជា ។

ព្រះមហាក្សត្រិយ៍ លុះទតឃើញប្រើសមាស - ស្តេចយាងចុះមក
ដោយព្រះអង្គឯង ហើយសួរតើប្រើសមាសនេះ អ្នកត្រូវការលក់ឬទេ? ។
អារិនក្រាបទូលថា: សូមខ្ញុំព្រះមេត្តាប្រោស! មិនលក់ទេ បើជួល
បាន ។ ព្រះពជាខ្ញុំសួរទៀតថា: ម៉េចឯងជួលឲ្យយើងបីថ្ងៃ តើឯងយក
តម្លៃប៉ុន្មាន? ។ អារិនក្រាបទូលថា: សូមព្រះអនុណាថ្ងៃវិសេសជ្រាប!
យកតម្លៃជាប្រាក់មាសមួយពាន់រៀល ។

លុះការនិយាយថ្ងៃឈ្នួលស្រេចហើយក្ងាម, ព្រះអង្គបង្គាប់ឲ្យគេនាំប្រើសមាសចូលក្នុងបន្ទប់ព្រះនាងកីឡាលីណា ហើយទ្រង់ស្តេចយាងទៅឯព្រះពាជដំណាក់វិញ ។

ប្រើសមាស កាលណាដឹងថាអាត្មានៅតែឯកឯងហើយ ក៏ស្រែកច្រៀងដោយសូរសៀងយ៉ាងស្រទន់ស្រដោចអស្ចារ្យ សូម្បីជុំថ្ពាក់ក្បាលតារាល្ងិ ក៏អត់ទ្រាំមិនចេញទឹកភ្នែកមិនបាន ។ ព្រះនាងកីឡាលីណាទ្រង់ផ្ទួលក់, ចំណែកព្រះពាជបុត្របានស្តេចចេញពីពោះប្រើសមាស មកទូលថើបព្រះនាង ហើយត្រឡប់ចូលក្នុងពោះប្រើសមាសវិញ ។

លុះភ្ញើខ្លីដែរ ព្រះនាងមានវាចាច្រាប់ស្រីតាលៀងទាំងឡាយថា ពីយប់មិញ ខ្ញុំយល់សប្តិឃើញមាណពម្នាក់រូបយ៉ាងគើតចូលមកទូលថើបខ្លួនខ្ញុំ ។ ខណៈនោះ មានសំម្លាក់យល់ដើងការណ៍ ក៏ច្រាប់ព្រះនាងថា: បពិត្រម្ចាស់កែវ! កាលណាប្រើសមាសច្រៀងទៀត សូមម្ចាស់ធ្វើជាផ្ទួលក់ ហើយកាលណាព្រះនាងជ្រាបថាមានអ្នកណាមកទូលថើប សូមព្រះនាងយកព្រះហស្តចាប់ឲ្យជាប់ ។

រំលាភក្តី ប្រើសតាំងច្រៀងទៀតដោយសំឡេងគួរឲ្យអាណោចអធ័មរេក ។ ព្រះពាជធីតាធ្វើជាផ្ទួលក់ លុះព្រះពាជកុមារចេញមកទូលទៀត, ព្រះនាងចាប់ព្រះហស្តជាប់ ហើយមានព្រះបន្ទូលថា: ម្ខ្ញុំនេះ

ព្រះអង្គវត់ទៅណាលែងបានហើយ ទូលព្រះបង្គំចាំយូរណាស់ហើយ ! តមក គួសង្ឃរផ្ទំជាសុខជាមួយគ្នាវិញទៅ ។

ពេលថ្ងៃត្រង់ ព្រះពជាស្តេចយាងចូលមកជាមួយនឹងម្ចាស់ប្រើសដែលត្រូវគាត្រឡប់យកប្រើសវិញ ។ ចំណែកព្រះនាងទ្រង់កន្សែងហូរទឹកព្រះនេត្រហាម ព្រោះសេចក្តីអាល័យមិនចង់ឲ្យបែកចេញពីប្រើសសោះ ។ ខណៈនោះ អាវិនលួចខ្សឹបនឹងព្រះនាងថា: សូមព្រះនាងសុំលាព្រះវរពជបិតានឹងស្តេចយាងជូនប្រើសទៅដល់ខាងក្រោយក្រុង, ហើយនៅទីនោះ មានព្រះពជវចនីមអគ្យាស្សព្រាហ៍ចាំងជប់ពីរ សម្រាប់នាំយើងចាំងអស់គ្នាទៅកាន់ព្រះពជសីមានៃព្រះអគ្គម្ចាស់ហាវហាន ដែលជាគូស្នេហារបស់ព្រះនាង ។

ព្រះពជធីតាទ្រង់សុំព្រះចៅតាមពាក្យនៃអាវិន ព្រះមហាក្សត្រទ្រង់អនុញ្ញាតឲ្យមួយរំពេច ហើយគេនាំគ្នាដង្ហែប្រើសមាសជាអ្នកអធិកចេញរហូតដល់ទីបំផុតក្រុង ។ ក្បែរណោះ អាវិនគោះប្រើសបីដងប្រើសនោះក៏ក្លាយជាព្រះពជវចនីមដោយសេះគ្រហមចាំងជប់ពីរ ។ រួចវាគាន់ព្រះនាងដោយដៃម្ខាង ចាំជិនដោយដៃម្ខាងទៀត ហើយឆក់លោតឡើងលើព្រះពជវច ។ តែមួយសន្ទុះ ជនចាំងបី ឃ្លាតផុតបាត់ពីភ្នែកអ្នកចាំងពួង, មិនយូរប៉ុន្មាន ក៏បានទៅដល់ព្រះពជវង្សានៃព្រះចៅជាព្រះវរពជបិតានៃទាជិនពជកុមារ ។

កាលព្រះមហាក្សត្រិតបានជ្រាបការវិលត្រឡប់នៃព្រះពាជបុត្រ ទ្រង់ស្តេចមកទទួលព្រមដោយសេនាយោធាជាច្រើន ហើយទ្រង់នាំព្រះពាជបុត្រយាងចូលព្រះបរមរាជវាំង ។ គ្រានោះ ព្រះចៅទ្រង់រៀបព្រះពាជអាពាហ៍ពិពាហ៍ជាទក្ខិណា អស់កាលកំណត់បីថ្ងៃបីយប់ រួចអំពីកិច្ចនោះទ្រង់វេរាជសម្បត្តិប្រទានដល់ខាងដើន ព្រះពាជបុត្រក៏ទទួលសោយរាជ្យស្នងព្រះអង្គ ។

ថ្ងៃមួយ ព្រះនាងកីឡាលីណា ដែលគង់ត្រង់សីហបញ្ជរ បានទតឃើញឈ្វេញសំពាយម្នាក់ដើរលក់អាវទ្រនាប់ ។ ព្រះនាងប្រាប់ឲ្យគេហៅឈ្វេញនោះចូលមក ទ្រង់ទិញព្រះពស្ត្រទ្រនាប់ជាវិការៈអ្វី យ៉ាងធ្លាប់ជាងសរសៃពីងពាង ហើយក៏យកអាវនោះមកទ្រង់ភ្លាម ។ មិនយូរប៉ុន្មាន ព្រះនាងប្រឈួនសន្ធប់សន្ធឹង គេស្មានថាប្រហែលព្រះនាងនឹងពុំគង់ព្រះជន្មឡើយ ។

អាវិនដែលជាបុត្រនាងនាយពិសេសបានដឹងការណ៍ដូច្នោះ រៀបពាក់កណ្តាលអធ្រាត្រ ក៏លបលួចចូលក្នុងព្រះពាជបន្ទប់ដែលព្រះនាងគំពុងផ្ទំ យកទឹកក្អែកលាបមកប្រោះស្រប់ពីលើព្រះកាយព្រះនាង ហើយចេញទៅវិញបាត់ ។ ប៉ុន្តែ រឿងនេះមិនបាត់ស្ងាត់ឡើយ នាយឆ្មាំទ្វារទៅគាបទូលព្រះពាជាខាងដើន ថាទ្រង់មានយកមន្តវិជ្ជាគាថាអ្វី ទៅសូត្រផ្ចុងជាក់ពីលើព្រះសរីរកាយនៃព្រះអគ្គមហេសី ។

ព្រះចៅតាជំនូនខ្ញុំព្រះកំពេធ មានព្រះពាជនុង្ការបង្គាប់ឲ្យពេជ្ឈ-
ឃាតយកអាវិនជាកល្យាណមិត្តទៅកាត់ក្បាល ។ លុះបានទៅដល់
កន្លែងធ្វើគត់ អាវិនក្រាបទូលព្រះពាជាថា: "បពិត្រព្រះចៅ! សូមព្រះ
ជាម្ចាស់ជួយឲ្យខ្ញុំមានព្រះជន្មាយុ ស្ថិតនៅអស់កាលជាយូរអង្វែង ។
ដោយសេចក្តីស្នេហាជាកាតរកាត ដែលទូលព្រះបង្គំមានជានិច្ចចំពោះ
ខ្ញុំ, ទូលព្រះបង្គំសូមអង្វរ សូមព្រះតេជះបារមី សូមខ្ញុំប្រជុំអស់
នាម៉ឺនមុខមន្ត្រីធំៗ កុងព្រះនគរ ព្រោះទូលព្រះបង្គំមានកិច្ចមួយយ៉ាងធំ
ដែលទូលព្រះបង្គំត្រូវយកមកថ្វាយមិនបាន នៅចំពោះមុខនៃឥស្សរ-
ជនទាំងនោះ ។ រួចហើយ សូមខ្ញុំសម្លាប់ទូលព្រះបង្គំចុះ" ។

ព្រះពាជាខ្ញុំប្រជុំអស់នាម៉ឺនមុខមន្ត្រីមួយរំពេចឥតបង្អង់, ព្រះអគ្គ-
មហេសីកិឡាលីណាក៏ខ្ញុំយាងមកដែរ ។ រួចព្រះពាជាឲ្យគេនាំអាវិន
មក ហើយមានព្រះបន្ទូលថា: "ម្នាលអាចារចិត្តក្បត់! ឯងចង់និយាយ
ថាម៉េច ចូរឯងថាទៅ!"

កុងទុកាសនោះ អាវិនផ្តើមឡើងថាដូច្នេះ: "កុងកាលដ៏កន្លងហើយ
មានពេលម្តងព្រះពាជបុត្រមួយព្រះអង្គ មានព្រះហឫទ័យប្រដិព័ទ្ធកុងរូបព្រះ
អគ្គម្ចាស់ក្សត្រីយ៍មួយព្រះអង្គ នៅនានគរខាងនាយសមុទ្រ" ។ រួចរៀប
រាប់រឿងហូរហែតាំងពីដើមដល់ចុងគឺ អំពីកាលទៅនៅសំណាក់កុងផ្ទះ
យាយហិមវាត នឹង រាបានធ្វើដូចម្តេចខ្លះកុងទីនោះ ។ ប៉ុន្តែកាលណា រា

និយាយដល់ត្រង់កន្ទែង ដែលនាំគ្នាជិះច្រកគាវលើកំណាត់ឈើ ហើយ
ធ្វើជ្រោះលោហធាតុ អានិតក្លាយខ្លួនទៅជាឋ្មាពីដើងដល់ក្បាលជង្គង់ ។
ហើយវាចេះតែនិយាយតទៅទៀត, លុះដល់ត្រង់កន្ទែងដែលវាបញ្ចូល
ទាជិនទៅក្នុងពោះប្រើសមាស វាក្លាយជាឋ្មាហូតដល់ចង្កេះ . . . ។

ព្រះពជ្រាធិងព្រះពជ្រាយា ដែលទ្រង់យល់ឃើញការសូតត្រង់របស់
អានិន ក៏ទ្រង់ព្រះកន្ទែងទាំងពីរព្រះអង្គ ហើយអង្វរសុំឲ្យអានិនឈប់
និយាយត្រឹមហ្នឹងចុះ ។ ប៉ុន្តែ អានិនបន្តរឿងទៅទៀត, ហើយលុះកាលណា
វាបញ្ចប់រឿង អំពីធ្វើកិច្ចយ៉ាងដូចម្តេច ដើម្បីស្រង់ជីវិតព្រះនាងភីឡា-
លីណា គឺវាយកទឹកក្អែកសត្វលលកទៅច្រោះព្រំលើព្រះកាយព្រះនាង,
វាក៏ក្លាយខ្លួនទៅជាឋ្មាងពីដើងរហូតដល់ក្បាល ។

ព្រះពជ្រាទាជិន ទឹងព្រះអគ្គមហេសីទ្រង់ព្រះកន្ទែងស្តាយអានិន
អស់បីថ្ងៃបីយប់ ។ រួចក្រុតាំងពីព្រះអង្គ ទ្រង់បង្គាប់ឲ្យគេយករូបឋ្ម
នៃបុព្វការីបុគ្គលទៅដំកល់ទុកក្នុងព្រះពជ្រដំណាក់ ដើម្បីឲ្យទ្រង់អាចបាន
ទតឃើញរាល់ថ្ងៃរាល់យប់ ។

លុះឆ្នាំងាងឡាយកន្ទងទៅ ព្រះពជ្រាប្រសូតបានព្រះពជ្របុត្រមួយ
ព្រះអង្គ ។

រៀលាព្រឹកមួយ ព្រះចៅទាជិន ទ្រង់ថ្លែងប្រាប់ព្រះរាជាយាថា:
ទ្រង់ស្តេចសុបិនឃើញស្ត្រីម្នាក់ ស្ទុះសសាក់សរើរចូលមក, ស្ត្រីនោះ

និយាយថ្កាប់ថា: "បើទ្រង់មានបំណងចង់ឲ្យអាវិនជាបងមានជីវិតវិញ សូមទ្រង់សម្លាប់ព្រះពជបុត្រហើយយកឈាមទៅលាបដុំថ្ម" ។

ព្រះពជទេពីធ្វើយតបថា ព្រះនាងក៏ទ្រង់ព្រះសុបិនដូច្នោះដែរ ហើយមិនថ្កាប់ប្រឹក្សាច្រើន, ក្សត្រីង៉ងពីរ (ស្វាមី ភរិយា) យកព្រះពជបុត្រទៅសម្លាប់ក្នុង ។ គ្រាន់តែឈាមព្រះពជបុត្រទៅប៉ះ ដុំថ្មក៏ចាប់ញ័រមួយរំពេច រួចអាវិនក៏មានជីវិតឡើងវិញហើយនិយាយថា: អ៉ា! ទ្រង់ទូលព្រះបង្គំទទួលព្រះពជទានដំណេកអីក៏លក់យូរម្ល៉ះ? ។ ព្រះពជាធ្វើយថា: មែនហើយបង! បងនឹងដេកតទៅទៀត ប្រសិនបើយើងកុំសម្លាប់ព្រះពជបុត្រយកព្រះលោហិតមកប្រោះព្រំលើខ្លួនអ្នក ។

ខណៈនោះ អាវិនយកកាំបិតមកចោះម្រាមដៃ ហើយបង្ហូរឈាមទៅលើរូបសពព្រះពជបុត្រ។ ក៏ត្រឡប់មានព្រះជន្មាយុឡើងវិញភ្លាម ។

ព្រះពជាសប្បាយព្រះពជហ្ឫទ័យពេក ទ្រង់បង្គាប់ឲ្យអាណាប្រជាទុកស្តុក ក្នុងព្រះពជវង្សាតាំងមូលឈប់ធ្វើការងារ ហើយលេងសើចតាមចំណង់រៀងខ្លួនអស់ពេលដ៏យូរ ។

ចប់

ព្រះមហាឧត្តមវិជ្ជា ធីលញ្ញាណោ ប៊ុង-ប៉ម
អាចារ្យសាលាចាលីវង់ វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង
ឃុនបណ្ឌាន្តរ៉ក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យអ្នកពិនិត្យកែ

(តមក)

ក— វិបាកពីពោះ សំដៅយកពាក្យស្រដីស្រទន់គួរត្រង់ត្រាប់គួរគ្រែបធឹក ទន់ ពីពោះដល់ត្រចៀក ជាសំដីចេញមកអំពីចិត្តដ៏បរិសុទ្ធដូចទឹកថ្លាស្អាត, ជាសំដីដឹកនាំឲ្យអ្នកស្តាប់ត្រង់ត្រាប់ហើយ ធ្វើតាមបានមិនមានទោស អង្វរចិត្តអ្នកស្តាប់ឲ្យឃើញថា គួរកាន់យកជាតួយ៉ាង ទន់ ជួយថែរក្សាលើកកំឡាំងចិត្តរបស់អ្នកស្តាប់ឲ្យរីករាយ ប្រៀបដូចទឹកថ្លាដែលជួយកំឡាំងចិត្តរបស់អ្នកបរិភោគដូច្នោះ, ឧទា ជាវាចាមិនខុស មិនមានទោស, បេមនិយា ជាវាចាគួរស្រឡាញ់ ព្រោះល្អ មិននាំឲ្យអ្នកស្តាប់កើតសេចក្តីក្រោធ គឺនាំឲ្យកើតសេចក្តីស្រឡាញ់ចំពោះអ្នកនិយាយតែម្យ៉ាង, ហាទយង្គមា ជាវាចាគាប់ចិត្តត្រូវចិត្តប្លុចាប់ចិត្ត មិនខើសចិត្ត ចូលទៅដក់នៅក្នុងចិត្តបានដោយងាយ, កណ្ណសុខា ជាវាចាពីពោះឬស្រួលដល់ត្រចៀកនឹងងាយស្តាប់, ទោរី ជាសំដីសុភាពទន់ភ្លន់, ពហុជនកន្តា ជាវាចានាំឲ្យរីករាយដល់ជនគាំងពួង, ពហុជនមនាបា ជាសំដីត្រូវចិត្តនៃមនុស្សច្រើនគ្នា ។

ក់ចាពីកេះ ឈ្មោះថាជាមហាស្នេហ៍នឹងជាមហានិយម ។ បើតែនិយាយច្រើនទៀតទៅ ក៏ងឹតតែនាំឲ្យជាទីគោរពស្រឡាញ់ក់ចាប់អានៃអ្នកស្តាប់ច្រើនទៅទៀតដែរ ។ ព្រោះមនុស្សដទៃ កាលបានស្តាប់ហើយ ចេះតែគាប់ចិត្តជានិច្ច, សូម្បីបានស្តាប់ហើយ ក៏នៅតែចង់ស្តាប់ទៀត មិនចេះឆ្អែត មិនចេះឆ្អិល មិនធុញគ្រាន់ ព្រមទាំងចង់ធ្វើសមាគម ជាមិត្តសំឡាញ់នឹងយើងទៀតផង ។ ក្រៅពីនេះ ក់ចាពីកេះ គង់បានជាប្រយោជន៍ដល់ដួងចិត្តទៀត ព្រោះធ្វើចិត្តរបស់ខ្លួនឯងឲ្យទន់ភ្លន់ស្រឡាញ់រមៀប ចាត់ថាឲ្យគុណដល់ខ្លួននឹងឲ្យប្រយោជន៍ដល់អ្នកស្តាប់ ។ កងធម្មនីតិមានសំដែងគុណនៃក់ចាពីកេះ ទុកថា "យកឈ្នះសត្រូវបានដោយក់ចាទន់ភ្លន់, យកឈ្នះមនុស្សកាចយង់ឃ្នងបានដោយពាក្យទន់ភ្លន់, វត្ថុអ្វីមួយដែលមិនសម្រេចដោយពាក្យទន់ភ្លន់នោះគ្មានឡើយ, ត្រូវយកឈ្នះវត្ថុទាំងពួងបាន ដោយសារក់ចាទន់ភ្លន់ទាំងអស់" ។ ពិតមែន ព្រះពាយមិនដែលអាចនឹងចោកបក់គុម្ពស្មៅ ដែលខ្យោទន់ចាបទៅតាមឲ្យរលើងទៅបានឡើយ តើបក់រំលំបានតែដើមឈើដែលធំខ្ពស់ ១ ចំណែកប៉ុណ្ណោះ, សូម្បីអ្នកមានឥទ្ធានុភាព ក៏មិនអាចរំលាយ មនុស្សទុនលំខោនទន់ភ្លន់បានដែរ អាចរំលាយបានតែកំឡាំងរបស់អ្នកដែលមានឫទ្ធិខ្លាំងក្លាប៉ុណ្ណោះ ។

អាចយកឈ្នះ សត្រូវ នឹងជនកាច
បានដោយសារ អំណាច ពោលក់ចា

ផ្ដែមពីពេះ ខន់ភ្ងន់ ឆ្ងាញ់ពីសា
នេះតម្រា ពាក្យឆ្ងាញ់ ផ្ដាញ់មនុស្សកាច ។
ពាំងវត្ថុ សារពើ លើពសុធា
ផ្ដែលជនផង គ្រប់គ្នា ប្រឹងប្រសាច
តែមិនអាច ឲ្យកើត ដោយអំណាច
គង់តែអាច កើតបាន ដោយពាក្យផ្ដែម ។

សូម្បីការទទួលភ្ញៀវផ្ដែលទៅមកកេគ្នា ក៏គង់មានការសន្ទនាប្រស្រ័យដោយពាក្យពីពេះចំពោះគ្នានឹងគ្នាជារបស់សំខាន់ផែរ ហើយសំខាន់ក្រៃលែងជាងការទទួលភ្ញៀវដោយអាហារ ផ្ដែលមានតុជារសយ៉ាងប្រណីតបញ្ចង់ប្លែកអ្វីៗពាំងអស់ទៅទៀត ។ ព្រោះថាកាលបើម្ចាស់ផ្ទះឈ្វាសវៃ ចេះនិយាយប្រស្រ័យពីរោះផ្ដែមល្ហែមហើយ រមែងបានឈ្មោះថាជាអ្នកនាំយករសដ៏ឆ្ងាញ់ក្រៃលែងជាងរសជាតិទេ។ មកឲ្យភ្ញៀវ ។ ដ្បិតរសនៃវាចា ផ្ដែលផ្ដែមពីពេះនេះ ជាទីដក់ជាប់នៅក្នុងចិត្តរបស់អ្នកស្ដាប់ ធ្វើឲ្យអ្នកស្ដាប់កើតសេចក្ដីរីករាយសប្បាយក្រៃលែងជាងរបស់គ្រប់យ៉ាង ផ្ដែលយើងអាចដឹងបានដោយក្រែគ្រា ពាំងបានឈ្មោះថាជាគ្រឿងចងក្រងចិត្តរបស់អ្នកស្ដាប់ទុកដោយកុសលោបាយផង ។ តើបើជាអ្នកធំក៏នឹងចងមេត្រីឲ្យកើតខ្នើងក្នុងរវាងអ្នកតូចបានយ៉ាងល្អ ពាំងចងភ្ជាប់ទុរសេចក្ដីគោរពគោតក្រែងរបស់អ្នកតូចទុកបានផង ប្រសើរជាង

ការចង់ពន្ធទុកដោយអំណាច ឬការគ្រប់គ្រងយ៉ាងឯទៃទាំងអស់ ។ បើជាអ្នកតូច ក៏នឹងបានជាទីករុណាប្រណីរបស់អ្នកធំ តាំងបានអ្នកធំជាទីពឹងបត្តម្ភគាំទ្រខ្លួនឲ្យចំរើនរុងរឿង ។ បើជាអ្នកដំនួញ ក៏នឹងមានអ្នកចូលទិញច្រើន ។

បណ្ឌិតអ្នកមានប្រាជ្ញាស្គាល់ហេតុផល រមែងកាន់យកថាការប្រែស័យពីភេះ ជានាទីដ៏សំខាន់របស់អ្នកម្ចាស់ផ្ទះ ។ ក្រៀវដែលមកកាន់ផ្ទះ ទោះមកដោយល្អ ឬមកដោយអាក្រក់ ក៏មិនជាសំខាន់ឡើយ ។ ព្រះបាទវេស្សន្តរ ទ្រង់ត្រាស់ប្រែស័យនឹងព្រាហ្មណ៍ជូជកដែលមកសូមព្រះរាជបុត្រព្រះរាជធីតាទាំងពីរ ធ្វើឲ្យតាដីកើតសេចក្តីរីករាយដោយព្រះសូរសៀងពីភេះ ដូចយ៉ាងអញ្ជើញតាដីឲ្យលានដើង ឲ្យចូលទៅក្នុងអាស្រម ឲ្យបរិភោគមើមឈើផ្លែឈើ នឹងឲ្យបរិភោគទឹកថ្លាត្រជាក់តាមគាប់ចិត្តជាដើម ។ ទោះក៏ព្រោះព្រះអង្គទ្រង់កាន់យកការចរចាពីភេះថាជានាទីរបស់ព្រះអង្គ មិនបានឆ្លើសថា ជូជកជាយាចកថោកទាបឡើយ ។ នេះចាត់ថាថាតួយ៉ាងដ៏ប្រសើរនៃការប្រែស័យដ៏ពីភេះ ។

ពិតមែន ការទទួលប្រែស័យពាក់ព័ន្ធចំពោះគ្នានឹងគ្នា រមែងជាទុក្ខយ ប្រជាប់តុបតែងប្រោះព្រំទឹកចិត្តគ្នាឲ្យតាំងនៅក្នុងមិត្តភាព ចំរើនមេត្រីចិត្តមិត្តភាពឲ្យជិតស្និទ្ធស្នាប់ខ្ជួនមាំមួនកៃលែងឡើង ។ តែបើមិនឈ្វាសក្នុងការទទួលក្រៀវ ដែលមកដល់ផ្ទះរបស់ខ្លួនដោយកាលជាដើមទេ ក៏

នឹងត្រឡប់ឲ្យទោសដល់ខ្លួនឯងវិញ ។ មើលចុះ! ពួកសាក្យពាជមិនឈ្លាសក្នុងការទូលវិនូវកុមារដែលជាព្រះពាជនុសៃនៃព្រះបាទបសេនទិកោសល ទើបក្លាយទៅជាសាហេតុ នាំឲ្យព្រះពាជកុមារខ្ញង់ជ្រាបថាគេមើលងាយព្រះអង្គហើយក៏ខ្ញង់ក្រោធចំពោះពួកសាក្យពាជ ។ លុះខ្ញង់បានត្រងពាជ្យហើយ ក៏លើកកងទ័ពទៅកំទេចសក្កជនបទឲ្យតាំងនៅក្នុងព្រះពាជអំណាច ។ នេះជាផលនៃវាចាដែលអ្នកពោលមិនឈ្លាសវៃចាត់ថាជាពិសនាំឲ្យកើតទោសក្នុងកាលដែលនិយាយចប់ ។

ដូច្នេះ លោក-អ្នក ប្រុស-ស្រីទាំងឡាយ ចូរអប់មាត់របស់លោក-អ្នកឲ្យត្រអូបប្រហើរដោយវាចាដ៏ពីរោះចុះ កុំបណ្តាយឲ្យមាត់មានក្លិនស្អុយដោយសំដីអាក្រក់ឡើយ គឺកុំពោលពាក្យសំដីអាក្រក់ ចាក់រុក ស៊ីកសៀត ឬសំដីណាដែលជាហេតុនាំឲ្យអ្នកដទៃក្តៅចិត្ត ឈឺចិត្ត គួចចិត្ត ឬក្តៅក្រហាយតបមកលោកវិញ ។ សំដីអាក្រក់គ្មាននរណាចូលចិត្តទេ ។ បើលោកបណ្តាយវាចាមិនល្អនោះឲ្យចេញមកក្រៅ ឈ្មោះថា ស្តោះទឹកមាត់ជាក់អាកាស ។ បើស្តោះលេងញយ។ ប្រយ័ត្នទឹកមាត់នោះធ្លាក់មកលើសីស:ខ្លួនវិញ ។ ព្រោះការធ្លាប់មាត់នោះចូលក្នុងគតិថា "បើលោក-អ្នកវាល់របស់ឲ្យគេដោយនាឡិឯណា គេនឹងវាល់សងមកលោក-អ្នកដោយនាឡិនោះវិញ" ។ ហេតុនេះ ត្រូវតាំងស្មារតីថា នឹងមិនពោលពាក្យគ្រោតគ្រាតពាក្យចាក់រុក ពាក្យស៊ីកសៀត បំបែកនរណាពីនរណាឡើយ ។

បើលោក - អ្នកមិនពេញចិត្តចំពោះហាន:ខ្លួន ហើយបណ្តាយឲ្យមាត់និយាយពាក្យគ្រោតគ្រោតចាក់រុកអ្នកដទៃវិញ ត្រូវអំពីការស្តោះទឹកមាត់ដាក់អាកាសហើយ ក៏គង់ប៉ានណ្ហាះថា តែះថ្នមោយត្រចក, ចំពាស៊ីដុំដែកដោយធ្មេញ ឬព្យាយាមលេបដុំក្រួសដែលឆេះត្រហាមរន្ធាល ។ ត្រូវកុំតែះថ្នមោយត្រចក កុំចំពាស៊ីដុំដែកដោយធ្មេញ ឬកុំព្យាយាមលេបដុំក្រួសឡើយ ព្រោះនាំឲ្យរបេចត្រចក ចាក់ធ្មេញ រលាកមាត់, រលាកបំពង់ក ។ ចូរជាស់តឿនខ្លួនឲ្យចាស់តែចិត្តកើតហិរិឧត្តប្ប:លែងហ៊ានពោលពាក្យអាក្រក់ដូច្នោះតទៅទៀត ។ បើលោក - អ្នកតែនិស្ស័យវាចាអាក្រក់ឲ្យត្រឡប់ជាល្អបានហើយ, និស្ស័យអាក្រក់បែបដទៃ។ ទៀតជូចយ៉ាងនិស្ស័យបរិភោគគ្រឿងស្រវឹង និស្ស័យចូលចិត្តលេងល្បែងភ្នាល់ និស្ស័យខ្ជាប និស្ស័យខ្ជិល និស្ស័យមិនខ្មៀងត្រង់តាមពេលវេលា ឬសូម្បីតែនិស្ស័យលួចលូន ក៏លោកអាចតែឲ្យសម្រែចឲ្យល្អបានតាមចំនងនេះទាំងអស់ ។

កាលបើមាន	ក្រឿវចូលមក	វគអាត្ម
ចូរចរចា	តែពាក្យផ្អែម	យ៉ាងស្រស់ស្រាយ
កាវពាប់អាន	ប៉ានយ៉ាងនេះ	ធ្វាញ់មាល្បាយ
លើសលុបអស់	រសទាំងឡាយ	ក្នុងផែនភព ។
កាចរចា	ពាក្យចាក់រុក	ខុកដូចគាប់

អាត្រៃចៀក ឲ្យឈឺចាប់ គ្មានចេះឈប់
ចាំងភ្លឺនឹងផង គង់ហ្មងចិត្ត គិតលែងគប់
ឬកពេល ដែលនឹងទប់ តបវិញណា ។
ក្តីទុក្ខទោស កើតព្រោះមាត់ មានសន្ធឹក
សូមរឭក នឹកមើលចុះ មិនខុសថា
គង់ឃើញថ្នី ថាសំដី ធ្លាញ់ពីសា
នាំចិត្តា ជនអ្នកស្តាប់ ឲ្យចាប់ចិត្ត ។
កាលលោកជ្រាប ភាពសំដី ផ្អែមនឹងជូរ
ថាជាគូ មានទោសគុណ ខុសគ្នាពិត
គួរនិយាយ តែពាក្យផ្អែម ឲ្យទាល់ស្និទ្ធ
កុំជាប់ចិត្ត នឹងពាក្យជូរ ជាគ្រូឡើយ ។

(មានត)

កណ្ឌទី ១០

ឧកញ៉ាវិបុលរាជសេនា នួ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាប្រទីបស្រាស្ត្រ
អ្នករាំងរៀនសូបើបានអាន
ធំងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ខ្ញុំតិតបថា អ្នកនឹងទៅនៅទីជំនៃនោះ សេចក្តីគរហានិន្ទានឹងមានដល់យើង, ដែលតែវហ៊ិរនៅចិត្តពាលស្រាលសេចក្តី បានស្តីខ្ញុំគោះបោះបោកឲ្យអ្នកនោះ ថ្ងៃក្រោយខ្ញុំនឹងនាំខ្លួនទៅសុំទោសនឹងអ្នក បើអ្នកមិនចូលចិត្តទៅកងទីនេះក៏ចូលទៅនៅឯស្រុកសៀវផាយចុះ ព្រោះស្រុកនោះក៏ជាទីស្រុកតូចឡើងដល់ស្រុកនេះ, បើខ្វះខាតស្បៀងអាហារវត្ថុណា សូមយើងផ្ញើបញ្ជូនទៅឲ្យ ។

លីបោ៉ាបានស្តាប់ក៏មានអំណរសោទគំនាប់ខ្ញុំតិតហើយ ក៏នាំគ្រប់គ្រួទឹងសេនាចាហានទៅនៅស្រុកសៀវផាយ ។

កណ្ឌ ទី ១១

ចាប់តាំងពីបងធ្វើសំបុត្រទៅក្រាបទូលព្រះចៅហៀនតេថា ខ្លួនបានបង្ក្រាបសឹកសត្រូវនៅអាណាខែត្រទិសបូព៌ាជ្រុះស្រឡះហើយ រៀងរហូតដល់ព្រះចៅហៀនតេ ស្តេចយាងចូលទៅក្នុងក្រុងឡុកអៀង ហើយទតឃើញព្រះរាជតំណាក់ក្នុងព្រះរាជវាំងត្រូវភ្លើងឆេះអស់ ទើបទ្រង់សោកស្តាយ ។

ឯបងធូ កាលច្បាំងបានអាណាខែត្របែកខាងបូព៌ាទិស មកជាចំណុះខ្លួនវិញហើយ ក៏បានសំបុត្រចូលទៅក្រាបទូលព្រះចៅហៀនតេ ជាសេចក្តីថា "ទូលព្រះបង្គំជាខ្ញុំបងធូ បានបង្ក្រាបបាមសឹកសត្រូវនឹងពួកអាចោរកំណាច ក្នុងអាណាខែត្របូព៌ាទិស រាបតាបអស់ហើយ" ។ សំបុត្របកនោះ លីឈុយគុយគីទទួលហើយ ក៏ព្រងើយកន្តើយមិនបានយកទៅថ្វាយសោះ គិតតែងតបមែបព្រះតម្រាស់បញ្ជូនទៅឲ្យបងធូវិញថា បងធូមានសេចក្តីគាប់ប្រសើរ ធ្វើការចំរើនប្រយោជន៍ សូមទ្រង់ឲ្យឡើងទីជា "កៀនតិកបុង់កុះ" បែបថា "ឧកញ៉ាចំរើនអាយុ" ។ ខណៈនោះ លីឈុយនៅក្នុងស្រុកក្រងក៏តាំងខ្លួនជាធំ សម្រេចអាណាចក្រខាងទាហាន, គុយគីជាធំសម្រេចពាជការខាងភ្នាក់ងារវេជ្ជបាល ។ អ្នកទាំង ២ នេះបណ្តាលឲ្យកំរើកចិត្ត ប្រព្រឹត្តចាត់ចែងការពាជការជាកម្មសិទ្ធិលើខ្លួនទាំងអស់ មិនមានគោតខ្វាចព្រះចៅហៀនតេនឹងបណ្តានាហ្មឺនទាំងពួងសោះ, ពាជការផែនដីក៏វិប្បរិតប្រែប្រួលដូចកាលគ្រាតាំងតុះ ។

ខណៈនោះ អៀវពីវនឹងដូហ៊ុជានាហ្មឺនធំក្នុងស្រុកក្រុង ឃើញ
លើឈុយគុយគីតាំងខ្លួនជាធំ ហើយចាត់ចែងការពាជការជាខុច្ចរិតប្រព្រឹត្ត
អាក្រក់ ក៏យកសេចក្តីនេះលបក្រាបទូលព្រះចៅហៀនតេ ហើយថា ទូល
ព្រះបង្គំជាខ្ញុំយល់ឃើញចូធូជាមន្ត្រីមានសតិបញ្ញាក្លាហាន មានសេនា
ពាហនប្រហែល ៣០ ម៉ឺន ពួកសេនាខ្លាំងពូកែជាច្រើន ឥឡូវនេះ
បានជាធំខាងអាណាខែត្តបូព៌ាទិសទាំងអស់ បើបានចូធូនោះមកធ្វើ
ពាជការផ្ទាល់ព្រះអង្គក្នុងស្រុកក្រុង នឹងបានបង្ក្រាបពួកសត្រូវពាជសម្បត្តិ
ចេញបាន ទីព្រះពាជថានឹងអាណាខែត្តក្នុងក្រៅ ក៏នឹងនៅជាសុខ
ក្សេមក្សាន្តតទៅ ។ ព្រះចៅហៀនតេទ្រង់ព្រះសណ្តាប់ដូច្នោះ ក៏
ទៅមនុស្សក្នុងព្រះទ័យទ្រង់ព្រះតម្រែងសោកាអាណិតព្រះអង្គ ទើបទ្រង់
ត្រាស់តបថា សព្វថ្ងៃនេះយើងមានតែសេចក្តីពុំរៃ ក្នុងចិត្តខ្លួនជានិច្ចកាល
នឹងបណ្តាលហាមាត់និយាយមិនបាន បើមានអ្នកឯណាមានដំរេះច្បាស់
ចេះគិតរំលាងប្តូរមិត្រពាជសត្រូវនេះបាន ទើបយើងនឹងមានសេចក្តី
សប្បាយ ។

អៀវពីវទូលថា ទូលព្រះបង្គំជាខ្ញុំនឹងគិតកលៈបាយឲ្យលើឈុយ
នឹងគុយគីកើតចាស់ខែង ធ្វើចម្បាំងកាប់សម្លាប់គ្នាឲ្យបាន រួចសុំឲ្យ
មានព្រះតម្រាស់ទៅហៅចូធូឲ្យលើកវេហ៍ពលចូលមក ទើបនឹងបាន
រំលាងប៉ាក់ពួកអាកំណាចឲ្យអស់ចេញ ព្រះអង្គក៏នឹងបានសេចក្តីសុខវិញ
ពុំខាន ។

ព្រះចៅហៀនតេត្រាស់សួរអៀវពីវ៉ា កលៗបាយដែលគិតនោះ តើប្រការម្តេច ? ។ អៀវពីវក្រាបទូលថា ករិយាគុយគីនោះជាស្រីប្រច័ណ្ឌប្តីណាស់ ទូលព្រះបង្គំជាខ្ញុំនឹងប្រើស្រីម្នាក់ឲ្យទៅញុះញង់ករិយាគុយគី ឲ្យកើតសង្ឃឹះស្រង់ប្រយនឹងគ្នាឡើង ។ ព្រះចៅហៀនតេទ្រង់ព្រះសណ្តាប់ ក៏ជូរស្រួលក្នុងព្រះទ័យមានៈសេចក្តីត្រេកអរ ទើបទ្រង់ព្រះសុភអក្សរដែលនឹងឲ្យហៅចូរនោះ ប្រគល់ទៅឲ្យអៀវពីវក្សាទុក ហើយត្រាស់ផ្តាំថា បើកើតហេតុឡើងកាលណា អ្នកត្រូវចាត់បំរើឲ្យនាំសំបុត្រនេះទៅឲ្យចូរឆាប់វិលានោះ ។

អៀវពីវទទួលសុភអក្សរហើយក្រាបបង្គំលាថយមកវិញ នាំដូហ៊ីត្រឡប់ទៅផ្ទះហើយនិយាយពន្យល់ករិយាបស់ខ្លួនជាមាំមួន ហើយទើបប្រើឲ្យទៅសួរករិយាគុយគី ។ ករិយាអៀវពីវលុះឡើងទៅលើផ្ទះក៏គំនាប់តាមទំនៀមទម្លាប់ហើយនិយាយថា នាងខ្ញុំភ្ញកិត្តិស័ព្ទថា ស្វាមីរបស់អ្នកបានទៅលបស្ម័គ្រសហាយស្មន់នឹងប្រពន្ធលីឈុយ បើរឿងនេះដឹងដល់លីឈុយហើយ លីឈុយគង់នឹងធ្វើអន្តរាយដល់គុយគីជាស្វាមីអ្នកមិនខាន អ្នកត្រូវគិតគានហាមឃាត់ស្វាមីកុំឲ្យទៅប្រព្រឹត្តដូច្នោះទៀតវិញ ដែលខ្ញុំអាចកាត់ចិត្តចូលមកដាក់ដំណឹងអ្នកដូច្នេះ ព្រោះមានសេចក្តីអាណិតអ្នកណាស់ ។ ករិយាគុយគីបានឮដូច្នោះក៏ភ័យលោះព្រលឹងហើយនឹកខឹងក្នុងចិត្តខ្លាំងណាស់ ធ្វើយថា ប្តីខ្ញុំតែងទៅរកលីឈុយជាញឹក

ញយណាស់ ជួនកាលនៅដេកឯផ្ទះគេក៏មាន ខ្ញុំគិតថាកៀនគ័ក្តីអ្នកពាជ-
ការជាមួយគ្នា; ដែលប្តីខ្ញុំទៅលបបាទារការធំកិរយាលីឈុយនោះ ខ្ញុំ
ឥតដឹងសោះ អ្នកមានចិត្តសប្បុរសមតប្រាប់ខ្ញុំៗ អរគុណច្រើន អំណើះ
ពីថ្ងៃនេះទៅខ្ញុំនឹងត្រូវហាមមិនឲ្យប្តីខ្ញុំទៅផ្ទះលីឈុយទៀត ។ កិរយា
អៀវពីកើលរទៅផ្ទះខ្លួន ។

លុះកន្លងមកថ្ងៃ ១ លីឈុយឲ្យបំរើទៅអញ្ជើញគុយតីមកបរិភោគ
អាហារ ។ កិរយាគុយតីដឹងក៏អង្គុយឃាត់ប្តីថា ដែលអ្នកនឹងទៅសេពសុក
រមស់លីឈុយនោះ អ្នកនឹងលីឈុយមិនមែនចំណុះគ្នា សុទ្ធតែប្រកាន់
ខ្លួនជាធំរៀងខ្លួន ខ្ញុំគ្រែងអ្នកសេពសុកស្រីធំមិនដឹងខ្លួន ហើយលីឈុយ
នឹងលបជាក់ថ្នាំពុលឲ្យអ្នកធឹក អ្នកនឹងដល់សេចក្តីស្លាប់អសារឥតការ
ខ្លួនខ្ញុំជាស្រីនឹងបែរមុខទៅរកអ្នកឯណាបាន ។ គុយតីបានស្តាប់កិរយា
ឃាត់ក៏មិនបានទៅ ។ លីឈុយអង្គុយចាំបាយទាល់តែថ្ងៃរសៀលមិន
ឃើញគុយតីមក ទើបប្រើបំរើឲ្យយកម្ហូបចំណី ១ តុទៅជូនគុយតីដល់
ផ្ទះ ។ គុយតីនៅដេកមិនទាន់ក្បាត់ កិរយាក៏គ្រាកមីមាទៅទទួល
សម្រាប់នេះខុក ហើយលបយកថ្នាំពុលជាក់កន្លងបានម្ហូបនោះគ្រប់បាន ។
លុះគុយតីក្បាត់ឡើង មនុស្សបំរើកន្លងផ្ទះលើកម្ហូបនោះទៅឲ្យគុយតីបរិភោគ
ដំរាបថា តុនេះលីឈុយឲ្យបំរើយកមកជូន ។ កិរយាក៏មីមាសុះ
ទៅហាមឃាត់មិនឲ្យប្តីបរិភោគហើយថា "ចំណីនេះអ្នកកុំអាលពីសា ចូរ

ពិសោធមើលសិន" ថាហើយក៏ចាក់ឲ្យសុនខស៊ុ ។ សុនខនោះក៏ស្លាប់មួយរំពេច, គុយគីឃើញដូច្នោះក៏តតែសង្ស័យ ។

មានកាល ១ ថ្ងៃ លីឈុយចេញអំពីទីគាល់ហើយអញ្ជើញគុយគីទៅប្រឹក្សាការពារក្បាលផ្ទះ រួចលីឈុយអញ្ជើញគុយគីឲ្យបរិភោគអាហារ ។ គុយគីក្លែចរឿងដើម ទើបបរិភោគអាហារនោះរួចក៏លាទៅលុះទៅដល់ផ្ទះក៏បណ្តាលឲ្យឈឺក្នុងពោះ ។ ភរិយាសួរថា អ្នកចេញពីគាល់បានទៅឯណាខ្លះ? ។ គុយគីថា បានទៅប្រឹក្សាការពារក្បាលផ្ទះលីឈុយហើយគេរៀបចុាយទឹកឲ្យបរិភោគ ។ ភរិយាធ្វើជាតក់ស្លុតហើយថា "ខ្ញុំឃើញច្បាស់ម្ល៉ងហើយ ម្តេចទំទៅពីសាចុាយទឹករបស់គេទៀត គេមិនជាក់ថ្នាំបំពុលទេឬ?" ថាហើយក៏យកអាចម៍មកលាយនឹងទឹកហើយឲ្យគុយគីផឹកចូលទៅ គុយគីក៏ក្អួតចង្អោរចេញមកអស់ ពោះនោះក៏ចាត់ឈឺទៅវិញ ។

គុយគីក៏នឹកខឹងនឹងលីឈុយថា "យើងបង់កំឡាំងដែលបានរួមគំនិតគិតធ្វើការធំជាមួយគ្នាមកនោះសោះ ព្រោះលីឈុយនោះ មិនមែនត្រង់សុចរិតគិតប្រទូសរ៉ាយយើងវិញដូច្នោះ ត្រូវតែយើងគិតសម្លាប់វាចេញឲ្យបាន" គិតហើយក៏រៀបចាត់ចែងសេនាគាហាន នឹងលើកទៅព័ទ្ធចាប់លីឈុយក្នុងផ្ទះ ។

ពេលនោះមានមនុស្សរបទៅប្តឹងលីឈុយថា គុយគីនឹងលើកគាហានមកធ្វើអន្តរាយដល់ខ្លួនហើយ ។ លីឈុយភ្ញាក់ខ្លួនហើយថា "យើង

មិនមានទោសអ្វីនឹងគុយគីសោះ ហេតុម្តេចគុយគីអង់អាចគិតនឹងមកច្រ-
ឡូសក៉ាយយើងដូច្នេះ រឿងនេះយើងនឹងនៅស្ងៀមក៏ពុំបាន ត្រូវតែលើក
ទាហានទៅចាប់គុយគីសម្លាប់ជាមុន" គិតហើយក៏ប្រមូលផ្តុំទាហានលើក
ទៅប្រទះទ័ពគុយគី នៅក្បែរកំផែងស្រុក ក៏តាំងតយុទ្ធគ្នាទៅវិញទៅ
មកជាចលាចល ។ ពលទាហានទាំងសងខាង ក៏ធក់ជណ្តើមយក
ទៅប្រយុទ្ធរបស់អស់បណ្តាកស្តេតប់ផ្លុះ ។

ឯលីឈុយក៏ប្រើលីសៀមជាកូយ លើកទាហានទៅឡោមព័ទ្ធវាំង
ទុក ។ លីសៀមទើបប្រើការសៀងឲ្យយកព្រះពជវថ ២ ចេញមក ហើយ
អញ្ជើញព្រះចៅហៀនតេ ឲ្យឡើងគង់លើព្រះពជវថ ១ ឲ្យព្រះនាងហុក
ហៅដែលជាព្រះអគ្គមហេសីគង់ព្រះពជវថ ១ ហើយផ្ទាប់ពីក្រោយ ឲ្យ
ពួកព្រះស្នំនឹងក្រុមទ្វីបរចេញចាកព្រះពជវាំង តាមទ្វារព្រះស្នំចេញ
ទៅ ។ ឯលីឈុយនឹងគុយគីក៏តាំងតែចាំងគ្នាជាចលាចលរាល់ថ្ងៃ ។
កាលព្រះពជវថ បរចេញចាកព្រះពជវាំងទៅនោះ គុយគីក៏ក្រឡេក
ឃើញលីសៀមនឹងការសៀងលើកទាហានទាំស្តេចព្រះចៅហៀនតេ នឹង
ព្រះអគ្គមហេសីទ្វារស្រីព្រះស្នំចេញទៅដូច្នោះ ក៏បង្គាប់សេនាទាហានឲ្យ
ចាញ់ធ្នូរណ្តៅពីក្រោយ ព្រួញរត់បណ្តោយទៅត្រូវពលទាហានទឹងស្រីស្នំ
ស្លាប់អស់ជាច្រើន ។ លីឈុយដឹងដូច្នោះ ក៏លើកទាហានស្រួតទៅស្ទាក់
កាប់ចាក់ទាហានគុយគី។ តទល់ពុំឈ្នះ ក៏ប្រាស់ទ័ពលើកត្រឡប់មក

ក្រោយ ។ លំឈុយក៏នាំព្រះចៅហៀនតេនទឹងព្រះមហេសីស្រីព្រះស្នំ
ទៅតាំងដំរំទៅក្រៅក្រុង ១ អន្ទើ ។

ឯគុយគីក៏លើកទាហានចូលទៅក្នុងព្រះរាជវាំង រើយកទ្រព្យរបស់
ក្នុងផ្ទៃព្រះឃ្លាំង ហើយចាប់ពួកព្រះស្នំដែលលាក់ខ្លួនក្នុងព្រះរាជវាំង
នោះមកទុក រួចយកក្លៀងជុតព្រះរាជវាំងនេះរំខាសអស់ ។ លុះពេល
ក្រោកគុយគីដឹងថា លំឈុយនាំព្រះចៅហៀនតេ ទៅតាំងដំរំទៅក្រៅទី
ក្រុង ក៏លើកទាហានទៅតាមប្រទះទ័ពលំឈុយ ហើយប្រយុទ្ធគ្នាដណ្តើម
យកព្រះចៅហៀនតេ ។ លំឈុយក៏ដេញទាហានចូលតយុទ្ធនឹងកង
ទ័ពគុយគី។តទល់ពុំឈ្នះ ក៏ថ្កាសត្រឡប់ទ័ពទៅ ។

លំឈុយឃើញកងទ័ពគុយគីជយទៅវិញ ក៏អញ្ជើញព្រះចៅ
ហៀនតេនទឹងព្រះអគ្គមហេសីនឹងស្រីស្នំ ទៅប្រថាប់តង់ឯទីក្រុងវែលតាំង
តុ:កសាង ហើយបង្គាប់លំសៀមឲ្យនោមើលត្រួតត្រាការពារព្រះអង្គ កុំ
ឲ្យអ្នកឯណាយកចំណីគ្រឿងសាច់អ្វី។ ទៅឲ្យខន្ធីឬពួកស្រីស្នំបរិភោគឡើយ។
ព្រះចៅហៀនតេឃើញទុំពាជការតាំងស្រីប្រុស អត់ឃ្លានគ្មានអាហារ
ចំណីនឹងបរិភោគដូច្នោះ ក៏ទ្រង់មានសេចក្តីទោមនស្សអាណិតអាសូរ
ណាស់ ត្រាស់ប្រើខន្ធីឲ្យទៅសុំចុយនឹងសាច់គោពីលំឈុយ។ ទើនឹង
ព្រះចៅហៀនតេថា ចាននេះយូតប់រំលោះហើយ ហេតុម្តេចបានជាឲ្យ
ទៅសុំអាហារ នឹងឲ្យអ្នកឯណាស៊ីទៀត ។ (មានត)

ព្រះរាជពង្សាវតារប្រទេសកម្ពុជា

ភាគទី ២

សម័យនគរធំ

ឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(តមក)

ព្រះចានស្រីន្ទ្រវ័ន ទី ២

ព. ស. ១៨៣៨—១៨៥០, គ. ស. ១២៩៥—១៣០៧

កាលព្រះបាទជយវ៌ន្ទទី ៨ សោយទិវង្គតហើយ ព្រះស្រីន្ទ្រវ័ន ចានទទួលគ្រងរាជសម្បត្តិតមក មានព្រះបរមនាមថា "ព្រះចានស្រីន្ទ្រវ័ន្ទ" ពប់ជាទី ២ គង់នៅក្រុងស្រីយសោធរបុរៈ ។ ព្រះមហាក្សត្រីអគ្គនេះ ជាពជនុសនៃព្រះនាងស្រីន្ទ្រកូបេស្សរបូតា ហើយត្រូវជាព្រះពជនត្តោនៃព្រះបាទជយវ៌ន្ទទី ៨ ទ្រង់មានព្រះអគ្គមហេសីព្រះនាមដូចម្តេចមិនប្រាកដ តែព្រះអគ្គមហេសីនោះ ជាព្រះពជធីតាវបស់ព្រះបាទជយវ៌ន្ទទី ៨ ទ្រង់មានព្រះពជនុស ១ អង្គ ព្រះនាមស្រីន្ទ្រជយវ៌ន្ទ មានព្រះពជធីតា ១ អង្គ ព្រះនាមដូចម្តេចមិនប្រាកដ ប្រាកដតែថាព្រះនាងនោះជាទីប្រាសប្រាណរបស់ព្រះពជបិតាយ៉ាងក្រៃលែង ក្នុងឆ្នាំដែលទ្រង់ឡើងសោយពជ្យ ព្រះពជធីតានោះក៏មានព្រះពជស្វាមីហើយ, ក្រោយមក ព្រះជាមាតរកូនប្រសាប្រុសនេះត្រូវគោសយ៉ាងធ្ងន់ ព្រោះឲ្យលួចយកព្រះខ័នមាសរបស់ព្រះពជបិតាក្មេក ។

ការរៀបរៀង.– ក្នុងរជ្ជកាលនេះ មិនត្រូវបានកសាងរបស់សំខាន់អ្វីទុកទេ ផែនដីខ្មែរគាត់ខាងលើ គឺវៃត្រសុះខោះខ្ចយ នឹងវៃត្រជាវៃខ្លះទៀតដែលបានទៅក្នុងកណ្តាប់ដៃជាតិថៃ តាំងពីក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី ៨.ជាដើមមកនោះ ថៃក៏រឹតតែរុកពានយកបានធំឡើងៗក្នុងរជ្ជកាលនេះ ទ្រង់បានចាត់សេនាទាហានឲ្យទៅចាំរក្សាទប់ថៃដែរ តែឃើញដូចជាមិនសូវបានផល ។

ក្នុងឆ្នាំដែលព្រះបាទស្រីន្ទ្រវរ្ម័នសោយព្រះជន្មនោះ ខាងប្រទេសចិនមានស្តេច ១ អង្គ ព្រះនាម យួនចេង បានឡើងសោយរាជ្យក្នុងឆ្នាំជាមួយគ្នានេះដែរ ត្រូវជព្រះកិត្តិយសជារាជាធិរាជ បានចាត់រាជទូតឲ្យមកកាន់ប្រទេសកម្ពុជា ។ ការមកនៃរាជទូតចិនគ្រានេះ ឃើញដូចជាមិនមែនមកសុំចង់សម្ពន្ធមេត្រីភាពដូចក្នុងរជ្ជកាលមុនៗទេ គ្រាន់តែប្រកាសថា ប្រទេសចិនជាមហាប្រទេស ក្សត្រិយ៍ដែលសោយរាជ្យជារាជាធិរាជ ហើយក៏ត្រឡប់វិញ ។

ក្នុងឆ្នាំជាមួយគ្នានេះ មានអ្នកជំនួញចិន ១ នាក់ឈ្មោះ "ជាវ-តាកួន" បានមកកាន់ប្រទេសកម្ពុជា សំណាក់នៅក្នុងដែនក្រុងស្រីយសោធរបុរ.ជាង ១ ឆ្នាំ ទើបត្រឡប់ទៅប្រទេសចិនវិញ ។ ក្នុងពេលដែលមកនៅក្នុងប្រទេសនេះ បានធ្វើសេចក្តីកត់ហេតុផ្សេងៗរួមចាំង ៤០ រឿង ។ ក្នុងរឿងអំពាលនេះ មានរឿងខ្លះចាត់ចាមដោយព្រះពុទ្ធសាសនា រឿង

ខ្ទះតាក់តាមដោយទំនៀមទម្លាប់ ។ ល ។ នឹងស្រង់យកចំពោះតែរឿង ដែលតាក់តាមដោយព្រះពុទ្ធឃោសាចារ្យ នឹងទំនៀមទម្លាប់ខ្ទះមកសំដែងក្នុងទីនេះ ដូចតទៅនេះ :–

ពិយាយអំពីភាពនឹងលក្ខណៈ ព្រះបរមកុដកំពង់ស្រីយសោធរបុរៈ តាំងជាន់កណ្តាល តាំងជាន់ក្រៅ យ៉ាងល្អិតល្អន់ត្រូតគ្រប់ ឃើញត្រូវតាមភាពដែលប្រាកដនៅក្នុងបច្ចុប្បន្ននេះឥតល្អៀង ថាប្រាសាទសិលាក្នុងព្រះបរមកុដកំពង់នោះមានតំបូលសុទ្ធតែធបមាសប្រាលផ្លែ នឹងមានស្ពានមាសនៅក្នុងព្រះបរមកុដកំពង់នោះផង(១) ។

ព្រះមហាក្សត្រិយ៍ព្រះបាទស្រីន្ទ្រវ័ន្ត គង់នៅក្នុងព្រះបរមកុដកំពង់ជាន់កណ្តាល គឺព្រះពុទ្ធិវេសន៍តាំងនៅខាងលិចប្រាសាទមានអាកាសចម្ងាយ ១ លី ។ តាមធម្មតាព្រះមហាក្សត្រិយ៍ខ្មែរ ទ្រង់ព្រះពស្ត្រ (សំពត់) ដែលល្អជាបំផុត ព្រះពស្ត្រមួយៗ ជំនៃ ៦-៣ ដំឡឹងមាស, ព្រះសីរតែងប្រដាប់ដោយកម្រងផ្កាម្ទិះជានិច្ច រៀវតែក្នុងពេលដែលត្រូវទ្រង់មកុដ, បាតព្រះហស្តនឹងបាតព្រះបាទតែងលាបដោយបុណ្ណ្រក្រហម (Crème) (២) ពួកស្ត្រីអ្នកមានបណ្តាស័ក្តិនៅក្នុងព្រះបរមកុដកំពង់ក៏មានលាបបុណ្ណ្រក្រហមនេះដែរ ។

---

១ ស្ពានមាសនេះ គឺស្ពានថ្មី ដែលឆ្លងទៅប្រាសាទហេមាទ្រី (បាពួន) ។ ២ ទំនៀមប្រើក្រែមនេះ កើតឡើងនៅឥណ្ឌាដំបូង ហើយផ្សាយមកប្រទេសកម្ពុជានឹងប្រទេសចិន, ក្រោយអំពីនោះមក ទើបផ្សាយទៅប្រទេសអ៊ឺរ៉ុប ប្រើមកដល់សព្វថ្ងៃនេះ ។

ព្រះរាជពន្ធិតាធំរបស់ព្រះមហាក្សត្រិយ៍មានចំនួន ៥ អង្គ គឺ អង្គទី ១ មានតំណែងយសជា "ព្រះអគ្គមហេសី" ឬហៅ "ព្រះរាជិនី" (reine) នៅប្រចាំព្រះមហាក្សត្រិយ៍ជានិច្ច ។ បួនព្រះអង្គទៀត មានតំណែងយសជា "ព្រះរាជទេវី" ស្មើគ្នាទាំងអស់ នៅក្នុងប្រាសាទជាមួយនឹងព្រះមហាក្សត្រិយ៍ តែក្រលាព្រះបន្ទំផ្សេងគ្នា នៅតាមទិសធំទាំង ៤ អំពីព្រះមហាក្សត្រិយ៍ ។ ក្នុងក្សត្រីទាំង ៥ អង្គនេះ ព្រះអគ្គមហេសី ធៀបដូចព្រះរាជាម្ចាស់ផែនដី, ព្រះរាជទេវីទាំង ៤ ធៀបដូចមន្ត្រីចតុស្តម្ភ (សេនាបតី) ទាំង ៤ ។ អ្នកដែលនឹងបានជាព្រះអគ្គមហេសីក្តី ព្រះរាជទេវីក្តី ត្រូវមានព្រះជាតិជាក្សត្រិយ៍ បើមានជាតិជាក្សត្រិយ៍មកមុន ត្រូវតាំងលើកជាក្សត្រិយ៍សិនហើយ ទើបបានតាំងជាព្រះអគ្គមហេសីឬព្រះរាជទេវី ។ ក្រៅពី ៥ អង្គនេះ ទ្រង់រមែងមានព្រះរាជជាយាវឱ្យ មកទៀតជាតិជាក្សត្រិយ៍មានច្រើនរូបគ្មានកំណត់ ហៅរួមថា "ព្រះស្រីក្សារ"

ទំនៀមនេះ កាប់ថាជា ភាជប្រពៃណីរបស់ព្រះមហាក្សត្រិយ៍ខ្មែរសឹងមានមកពីបុរាណ ។ តែថា ព្រះមហាក្សត្រិយ៍ទាំងឡាយក្នុងអតីតកាលមិនមែនថា សុទ្ធតែទ្រង់គាន់តាមភាជប្រពៃណីនេះ គ្រប់ៗព្រះអង្គទេ គឺព្រះអង្គខ្លះ មានតែព្រះអគ្គមហេសី ១ អង្គគ្មានព្រះរាជទេវីសោះ ក៏មាន; ព្រះអង្គខ្លះមានព្រះរាជទេវីតែ ១ អង្គ ឬតែ ២ អង្គ ក៏មាន មិនជាការខ្វែងខាត់ណាស់ទេ ។

ជាវគាកួនថា ពួកស្ត្រីនៅក្នុងព្រះបរមរាជវាំង ក្នុងគ្រានោះ មានរូបឆោមល្អៗ ណាស់ សំបុរកាយដូចសាច់ឆ្មៃកែវប្តូដូចទឹកដោះ (គឺសំបុរសខ្លួន មិនមែនសំលៀកគ្នុះ) ស្បែកសំឡីយទុកសក់ឆ្លងគាំងអស់ ច្រមាណមើលរបៀបឆ្លងសក់ គង់មានវិចិត្រច្រើនបែប ទំនងដូចរូបភាពនាងរបាំ ឬនាងអប្សរដែលគេធ្វើក់ទុកនោះឯង ។ ពួកស្ត្រីក្រៅព្រះពជវាំង ក៏ទុកសក់ឆ្លងនឹងស្បែកពាក់ទំនងដូចគ្នានេះ ។ ពួកប្រុសសុទ្ធតែស្បែកសំពត់ចង្កេះ ។

ហ៊ានន្តរសក្តិរបស់មន្ត្រី: អ្នករាជការនៅប្រទេសកម្ពុជា ក្នុងសម័យនោះ មានច្រើនពួក គឺមានក្រុមប្រឹក្សាការផែនដី មានពួកមេទ័ព មានក្រុមហោរ ជាដើម ។ អ្នករាជការឆ្នែកជាន់ខ្ពស់ ចែកចេញជា ៤ ពួក មានគ្រឿងយសជាសំគាល់ផ្សេងគ្នា គឺ:

ពួកទី ១ - មានហ៊ានន្តរសក្តិខ្ពស់បំផុត មានសិទ្ធិប្រើរាមសនឹងជាំងកូរស់ដងមាសបួន ។

ពួកទី ២ - មានសិទ្ធិប្រើរាមស នឹងជាំងកូរស់ដងមាស ១ ។

ពួកទី ៣ - មានសិទ្ធិប្រើរប្ជាក់ ជាំងកូរស់ដងមាស ១ ។

ពួកទី ៤ - មានសិទ្ធិប្រើរប្ជាក់ ជាំងកូរស់ដងប្ជាក់ ១ ។

---

១ ខ្ញុំធ្លាប់បានឮថាស់ខ្ញុំក្នុងសម័យនេះ មានពួកជារត្ដដើមថា មហេសីរបស់ព្រះរាជាមាន ៣: ទី ១ ហៅ អារ្យអគ្គមហេសី, ទី ២ ហៅ អគ្គមហេសី, ទី ៣ ហៅ មហេសី, តែខ្ញុំសូមបដិសេធថា សេចក្តីយល់បែបនេះមិនត្រូវទេ ។

អ្នកពាក្យសាជាន់ចាបចុះមក នៅមានច្រើនពួក ច្រើនផ្នែក តាំង
មានគ្រឿងសំគាល់ផ្សេងទៀត តែមិនមានអធិប្បាយទុកឲ្យច្បាស់លាស់
ទើបសូមស្មែះទុកតែប៉ុណ្ណោះ ។

ពិធីទ្វាទសមាស.— ជាវគាកួន ក៏មានពោលដល់ខ្លះដែរតែមិន
បានសព្វគ្រប់តាំងអស់, ចំពោះពិធីចូលឆ្នាំរបស់ខ្មែរកន្លងសម័យនោះថា
ត្រូវត្រង់ខែទី ១០ របស់ចិន គិតធៀបតាមខែចិនទៅ ត្រូវត្រង់ខែកត្តិក
របស់ខ្មែរ ។ តាមដែលបានដឹងមកដោយពិស្តារនោះថា តាំងពីបុរាណ
កាលរហូតមកដល់ក្នុងរជ្ជកាលព្រះបាទស្រីន្ទ្រវរ្ម័នទី ២ ខ្មែរយើងចូលឆ្នាំ
ក្នុងរវាងជាច់ខែកត្តិក ចូលខែមិគសិរ តែពីដើមឯណោះ ខ្មែរយើងកប់
ខាងរនោចជាដើមខែ ខាងខ្នើតជាចុងខែ; ដូច្នេះ ថ្ងៃជាច់ឆ្នាំចាស់ នៅ
ត្រង់ថ្ងៃ ១៥ កើតខែកត្តិក ថ្ងៃ ១ រោចខែមិគសិរ ជាថ្ងៃទី ១ នៃឆ្នាំថ្មី
ព្រោះហេតុ[illegible]នេះ បុរាណទើបកំណត់យកខែមិគសិរជាខែលេខ ១,
លេខរៀងបែបនោះប្រើជាប់មកដល់សព្វថ្ងៃនេះ ។ ក្រោយអំពីរជ្ជកាល
នេះមកមិនយូរប៉ុន្មាន ខ្មែរយើងបានផ្ទាស់យកខាងខ្នើតជាដើមខែ ហើយ
ទុកជាក់ខាងរនោចជាចុងខែវិញ ព្រមទាំងផ្ទាស់ពេលចូលឆ្នាំទៅតាម
សុរិយគតិ គឺកំណត់ចែកជាច់ឆ្នាំចាស់ ចូលឆ្នាំថ្មីទៅត្រង់ថ្ងៃទី ១៥ មេសា
បែបនេះបានប្រើដរាបមកដល់កន្លងបច្ចុប្បន្ន[1] ។ (មានត)

---

๑ ចូរមើលសេចក្តីក្នុងព្រះរាជពិធីចូលឆ្នាំ ក្នុងសៀវភៅព្រះរាជពិធីទ្វាទសមាសរបស់ពុទ្ធ-
សាសនបណ្ឌិត្យ ។

រឿងអាវ័ត្តន៍ថ្ងៃងរឿងម្លៃទ្រាំ

លោកសាង · សារ៉ាត លេខាធិការ ក្រសួងបរិស្ថាន

ប្រែពីភាសាចាវ៉ាំងមកជាខ្មែរ

(តមក)

គ្រានោះ ក្បួនតាំងពីរអង្គបានបើបមថ្មមបើបគ្នាទៅវិញទៅមក, មានពួកស្រីស្ងួលអដោយសំលៀកបំពាក់ក្តីផ្កែកបំរុះពណ៌គ្រប់បែប ឈរជង្អែគ្នាជាជួរតុំបដៃដោយគោរព ។ នៅខាងម្ខាង មានគ្រែមួយពោរពេញដោយបុប្ផានឹងមានធើងឹកក្លិនឡាប ព្រមទាំងប្រអប់ក្លិនក្រអូបរៀបជាជួរផង ។ រួចគេយើញស្ងឹកក្លិនឡាបធំ ដែលលំអដោយក្បាច់ពណ៌មាសនឹងឈើឯមបម្រុះគ្នា ។ នៅម្ខាងទៀត មានប្រអប់តូចៗ ប្រកបដោយពណ៌ឆើតឆាយ, មានម្ហូបចំណីផ្ងាញ់ពីសានៅខាងណោះ គឺមានស្ករដុំគ្រប់បែប ។ មាត់ទ្វារនឹងជញ្ជាំង លំអពីលើដល់ក្រោមដោយផ្ទាំងគំនូរនឹងតួមនុស្ស ដែលអាចដឹកនាំដនអ្នកមើលឲ្យរីករាយសប្បាយពន់ពេក ។

រត្តីតាំងអស់ដែលជួបជុំគ្នា មានរបៀបរៀបចំល្អចំឡែក ជាហេតុនាំឲ្យមានតម្រេកពុំអាចនឹងពណ៌នាបានឡើយ ។ គឺកងទីនោះហើយដែលព្រះនាងនាំព្រះអង្គចូលទៅ ។

លុះព្រះអង្គម្ចាស់ស្តេចគង់ហើយ ព្រះនាងក៏លាងព្រះបាទព្រះអង្គម្ចាស់ហើយយកទឹកអប់មកប្រោះព្រំកាយ យកផ្កាកម្រងមកបំពាក់ថ្វាយ

រួចយកទឹកកូឡាបមកស្រែឡាបព្រះកាយ ៖ ហើយយកផ្ទៃតមកបក់ថ្វាយ
ទៀត ។

កាលទ្រង់ទតយល់ព្រះនាងធ្វើដូច្នោះ ៖ ទើបទ្រង់មានព្រះបន្ទូលថា
"នុប្អូនក្សារអើយ ! បងឃើញនាងពេលណា ចិត្តបងត្រជាក់តតុបមា
ណា ! ប៉ុន្តែដូចម្តេចក៏ប្អូនធ្វើខ្លួនឲ្យលំបាកដល់ម្ល៉េះ? ព្រះហស្តយ៉ាងទន់
ភ្លន់របស់នាង មិនមែនសម្រាប់កាន់ផ្ទៃតនេះទេ ! ឲ្យផ្ទៃតមកបង ! ហើយ
ចូរនាងនៅស្ងៀមចុះ" ។

ព្រះនាងបន្ទាតឆ្លើយថា: "បពិត្រព្រះសម្មតិទេព ! សូមទ្រង់
ព្រះមេត្តាប្រោស ! ព្រះអង្គទ្រង់យាងមករកខ្ញុំព្រះអង្គដោយលំបាកបំផុត
ដូច្នេះ ត្រូវតែទូលព្រះបង្គំបម្រើព្រះអង្គ នោះទើបសមគួរ" ។ ប៉ុន្តែ
មានស្រីស្នំម្នាក់ បានយកផ្ទៃតអំពីដៃជនទាំងពីរ ហើយនិយាយថា "នេះ
ជាការណីយកិច្ចរបស់ទូលព្រះបង្គំទេ ទូលព្រះបង្គំនឹងបក់ថ្វាយ សូម
ទ្រង់ទាំងពីរអង្គត្រេបលំអងនៃបេតីចុះ !" ។

ក្សត្រទាំងពីរព្រះអង្គក៏ទ្រង់សោយព្រះស្ងោយ ដោយបានពិភាក្សា
គ្នាទៅវិញទៅមកយ៉ាងស្នេហាបំផុត ។ ប៉ុន្តែដល់ពេលត្រីកព្រហាម
ឡើង ព្រះនាងវត្តិយានីក៏លាក់ព្រះអង្គ, លុះដល់វេលាភត្តិត្រឡប់
មកវិញ ក្សត្រទាំងពីរពង្រីកលិចលង់ក្នុងសេចក្តីសប្បាយគ្រប់ប្រការ ។
ចំនួនច្រើនថ្ងៃកន្លងទៅ ក៏នៅតែដូច្នោះ ។ កាលព្រះមហាក្សត្រមានព្រះ

បន្ទូលអំពីការត្រឡប់ទៅប្រទេសទ្រង់វិញ ព្រះនាងពុំព្រមព្រះទ័យផង
សោះ ។ ក្សត្រទាំងពីរមានវិស្សាសៈស្នេហារវាង១ទៃដោយទំនងនេះ
ទាល់តែព្រះមហាក្សត្រទុញតុះធុញថប់ព្រួយព្រះទ័យជាពន់ពេក ។

ថ្ងៃមួយនោះ ទ្រង់គង់ម្នាក់ឯង នៅពេលល្ងាច, ទ្រង់គិតដល់
មាតុភូមិព្រះអង្គ ទឹងពាសសម្បត្តិ, ព្រះរាជដំណាក់ព្រមទាំងវត្តទាំងប៉ុន្មាន
ដែលទ្រង់បានចាកចោល ទឹង ទឹកដល់សំឡាញ់ដែលបានជួយបំពេញ
កិច្ចយ៉ាងមុឺងម៉ាត់ ទាល់តែទ្រង់បានស្គាល់ស្នេហាធំបំផុតនេះ ហើយពុំ
ដែលបានទទួលដំណឹងអ្វីសោះ ។

ព្រះនាងឃើញព្រះអង្គព្រួយដូច្នោះ ទ្រង់មានព្រះបន្ទូលសួរថា:
"ឧព្រះបង្គំថ្លៃងបុណ្យ! តើទ្រង់មានទុក្ខអ្វីបានជាគង់នៅស្ងាត់ស្ងៀម
ដូច្នេះ? សូមទ្រង់មានព្រះបន្ទូលប្រាប់ប្អូនផង!!" ។

ព្រះមហាក្សត្រទ្រង់តបវិញថា: "បងមានសំឡាញ់មួយ, បង
ស្រឡាញ់ពេញចិត្តណាស់, គេជាកូនដេមទ្រី; ចំនួន ១ ខែមកហើយ
បងមិនបានដំណឹងអ្វីអំពីគេសោះ ។ ឯសំឡាញ់នោះមានប្រាជ្ញាណាស់
ទាំងចំណេះវិជ្ជាទៀតសោតក៏វិសេសដែរ គឺដោយសេចក្តីវៃឆ្លាតរបស់គេ
ហើយ ឬបានជាបងបានមកជួបនឹងប្អូនឯង ព្រោះគេបានពន្យល់បងអំពី
ការអាថ៌កំបាំង របស់ប្អូនដោយសព្វគ្រប់" ។

ព្រះនាងក្រាបបង្គំទូលតបទៅវិញថា: "បពិត្រ ព្រះបង្គំថ្លៃងប្អូន!
បើព្រះទ័យស្តេចស្ងប់នៅឯណោះហើយ តើស្តេចគង់នៅឯណោះ ម្តេច

ខ្ញុំយ៉ាងនឹងបានសប្បាយ, ត្រូវតែប្អូនឲ្យគេយកម្ហូបចំណីគ្រប់មុខ ដែលប្អូនបម្រុងទុកថ្វាយតម្រេចព្រះទ័យព្រះអង្គ; ឯទ្រង់ក៏យាងទៅដែរ រួចត្រូវព្រះអង្គនាំគេដប់លៀងឲ្យបានសប្បាយចិត្តគ្រប់គ្នា ដើម្បីបង្ហាញឲ្យឃើញថា: កន្លងពេលដែលព្រះអង្គយាងមករកប្អូនម្តងៗ តែងមានព្រះទ័យស្កប់ស្កល់ជាដរាប" ។

លុះទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ព្រះមហាក្សត្រទ្រង់ក្រោកឡើង រួចទ្រង់យាងចេញទៅ ។ ចំណែកព្រះនាងបទ្មាវតី កាលរៀបចំម្ហូបចំណីសព្វគ្រប់ហើយ បានលួចបង្កប់ថ្នាំពុលជាមួយផង រួចទើបបញ្ជូនទៅ ។

ព្រះអង្គម្ចាស់ពដី-មុកាត បានទៅដល់កូនលោកវដ្ឋមន្ត្រី ទ្រង់យាងទៅគង់ជិតបុរសនោះឯង ។ ក្នុងពេលនោះ ម្ហូបចំណីក៏មកដល់ ។ កូនលោកវដ្ឋមន្ត្រីសួរថា: "សូមទ្រង់ព្រះមេត្តាជ្រាប! តើម្ហូបចំណីនោះមកពីណា?" ។

ព្រះមហាក្សត្រទ្រង់ឆ្លើយថា: "ថ្ងៃមួយនោះ ខ្ញុំអង្គុយម្នាក់ឯងដោយក្រៀមក្រំ ព្រោះនឹកដល់សំឡាញ់ឯង ស្រាប់តែព្រះនាងបទ្មាវតីមកឃើញ ហើយសួរខ្ញុំអំពីដើមហេតុនៃទុក្ខនេះ ។ ខ្ញុំក៏និយាយអំពីតម្រេះរបស់សំឡាញ់ឯង ទំនងដំណើរដែលមិត្តឯងរកឃើញការអាថ៌កំបាំងរបស់នាង លុះនាងស្តាប់ខ្ញុំរួច នាងបើកច្បាប់ឲ្យខ្ញុំមកលេងនឹង

មិត្តឯង ហើយបានតាំងធ្លើរបស់នេះមកមិត្តផង ។ បរិភោគទៅ
សំឡាញ់! ចិត្តរបស់ខ្ញុំនឹងរីករាយសប្បាយព្រោះអ្នកពុំខាន!" ។

ប៉ុន្តែនៅពេលនោះ កូនលោកវរជ្ឈមន្ត្រីបានទូលព្រះអង្គវិញថា:
"ព្រះអង្គបានយកថ្នាំអាសិរពិសមកឲ្យទូលព្រះបង្គំ, គឺជាសំណាងល្អ
ណាស់ ហើយដែលទ្រង់មិនបានសោយរបស់នេះ សូមឲ្យតែបន្តិចបន្តួច,
សូមព្រះមហាក្សត្រដ៏ថ្កើងបុណ្យទ្រង់ព្រះសណ្តាប់ទូវាក្យ ដែលចេញ
អំពីមាត់ទូលព្រះបង្គំនេះចុះ: . ជាតិជាស្រីមិនដែលស្រឡាញ់របស់ប្តី
ខ្លួនទេ ចំណែកខាងព្រះអង្គ ពិតជាទ្រង់ឈ្វេងទាស់ ព្រោះទ្រង់ច្រាប់
ឈ្មោះទូលព្រះបង្គំដល់ព្រះនាង: ។

ព្រះមហាក្សត្រមានព្រះពាក្យឆ្លើយវិញថា: "ក្រៅអំពីមិត្ត គ្មានអ្នកណា
មួយហ៊ាននិយាយពាក្យអស់នេះច្រាប់ខ្ញុំទេ, បើមនុស្សមិនខ្លាចមនុស្ស
ក៏គង់មនុស្សខ្លាចខ្ពើមដែរ" ។ លុះមានព្រះបន្ទូលរួច ព្រះអង្គម្ចាស់
ប៉ានយកម្ហូបមួយមុខ ចោះទៅឲ្យឆ្កែស៊ី ឆ្កែនោះស៊ីរួចក៏ប្រកាច់ស្លាប់មួយ
រំពេចភ្លាម ។ កាលទ្រង់ឃើញដូច្នោះ ព្រះអង្គម្ចាស់ទ្រង់ខ្លាសជាពន់ពេក
ហើយមានព្រះបន្ទូលថា: "មិនគួរគាប់ទឹកចិត្តប្រសប់ជាមួយស្រីអាក្រក់
បែបនេះសោះ ។ តាំងពីថ្ងៃមុនមកដល់ថ្ងៃនេះ ខ្ញុំបានចិញ្ចឹមចិត្តស្រ
ឡាញ់នាងយ៉ាងស្មោះស្ម័គ្រ ប៉ុន្តែក្នុងពេលនេះរលត់អស់ហើយ" ។

- ឥឡូវនេះសូមព្រះអង្គធ្វើដូច្នេះវិញ, សូមស្តេចនាំនាងមកកាន់
ដំណាក់ព្រះអង្គឲ្យបាន ។

ព្រះមហាក្សត្រមានព្រះពាដនង្ការថា "មិនអីទេសំឡាញ់! បំណងរបស់អ្នកនឹងសម្រេចពុំខាន" ។

កូនលោករដ្ឋមន្ត្រីនិយាយទៀតថា "សូមព្រះអង្គទ្រង់ធ្វើឲ្យបានសម្រេចក្នុងថ្ងៃនេះ; សូមទ្រង់យាងត្រឡប់ទៅរកព្រះនាង ហើយសូមទ្រង់ធ្វើតាមពាក្យទូលព្រះបង្គំកុំខាន; លុះទៅដល់ដំតនាងហើយ សូមព្រះអង្គធ្វើហាក់ដូចជាស្រឡាញ់នាងលើសប្រមាណ, កាលណាព្រះនាងដួលក់ហើយ សូមទ្រង់ដោះយកគ្រឿងមាសពេជ្រអំពីព្រះនាងឲ្យអស់រួចត្រូវចាក់ភ្លៅព្រះនាងខាងឆ្វេង ១ ច្បុកដែលមានថ្នៃ ហើយត្រូវយាងត្រឡប់មកវិញយ៉ាងប្រញាប់ ។

កាលទ្រង់ព្រះសណ្តាប់សព្វគ្រប់ហើយ លុះដល់វេលាយប់ព្រះអង្គម្ចាស់ ក៏យាងទៅដំណាក់ព្រះនាងបទ្មវតី ហើយស្តេចទ្រង់មានព្រះពាដនង្ការយ៉ាងស្និទ្ធស្នាលទៅរកព្រះនាង, ស្រែចហើយក៏ផ្ទំលក់ទាំងពីរព្រះអង្គទៅ ។

បន្ទាប់មកព្រះមហាក្សត្រ ទ្រង់រង់ចាំគុកាស ឲ្យព្រះនាងលក់សិប់ លុះព្រះនាងផ្ទំលក់សិប់ហើយ ព្រះអង្គក៏ដោះយកគ្រឿងអលង្ការទាំងអស់រួចចាក់ភ្លៅឆ្វេងព្រះនាង ១ ច្បុក ទើបត្រឡប់មកដំណាក់ព្រះអង្គវិញភ្លាម ហើយបាននិទានរឿងប៉ាវនោះ ប្រាប់កូនលោករដ្ឋមន្ត្រី ព្រមទាំងបង្ហាញគ្រឿងអលង្ការទាំងអស់ផង ។ ឯកូនលោករដ្ឋមន្ត្រីបានយកគ្រឿង

អលង្ការនោះមកស្លៀកពាក់ជាអ្នកសង្ខ័ ដើរឆ្ពោះទៅកាន់ម៉ុងខ្មៅចជាមួយព្រះអង្គម្ចាស់ ហើយបានអង្គុយក្បែរម៉ុងនោះ ។ លុះទៅជាអ្នកសង្ខ័ហើយ គាំងបានធ្វើព្រះអង្គម្ចាស់ឲ្យទៅជាសាវកវិសេសស្រេច ទើបនិយាយទូលព្រះអង្គម្ចាស់ថា "សូមស្តេចយកគ្រឿងប្រដាប់នេះ ទៅលក់ឯផ្សារ បើប្រសិនជាមានអ្នកណាមកចាប់ព្រះអង្គ សូមទ្រង់នាំគេមករកទូលព្រះបង្គំចុះ" ។

កាលណោះ ព្រះអង្គម្ចាស់បានយកគ្រឿងអលង្ការគាំងប៉ុន្មានទៅឯទីក្រុង ហើយបានបង្ហាញដល់ជាងមាសម្នាក់ ដែលនៅជិតមាត់ទ្វារស្តេច ជាងមាសឃើញគ្រឿងប្រដាប់នោះក៏ស្គាល់ជាក់ហើយនិយាយថា: "គ្រឿងប្រដាប់នេះជារបស់ព្រះនាងកល្យាណីក្សត្រីទេ, ចូរអ្នកប្រាប់ការពិតមកខ្ញុំ តើអ្នកបានពីឯណាមក?" ។

កំពេលដែលជាងមាសនិយាយដូច្នោះ មានមនុស្សប៉ុន្មានពីជប់ទៅម្ខែនាក់បានមកដួបជុំគ្នាគ្រប់ៗគ្នា ឯលោកនាយកក្រុមព្រះនគរបាលលុះដឹងដំណឹងនេះហ្មាស់ប្រាកដ ក៏ចាប់ព្រះអង្គម្ចាស់ព្រមទាំងគ្រឿងអលង្ការនឹងជាងមាសទៅផង ហើយបានសួរព្រះអង្គម្ចាស់ថា "តើអ្នកបានគ្រឿងប្រដាប់នេះពីណាមក?" ។ ព្រះអង្គម្ចាស់ឆ្លើយថា: អ្នកសង្ខ័ឲ្យខ្ញុំយកមកលក់ ប៉ុន្តែខ្ញុំមិនបានដឹងជាគ្រឿងប្រដាប់នេះមកពីណាទេ" ។ គ្រានោះ លោកនាយកក្រុមព្រះនគរបាលក៏ចាប់អ្នកសង្ខ័មកទៀត

រួចបានបញ្ជូនជនទាំងពីរទៅថ្វាយព្រះមហាក្សត្រម្ចាស់ផែនដី ព្រមទាំងគ្រឿងប្រដាប់នោះផង ហើយបានក្រាបបង្គំទូលដោយសព្វគ្រប់ ។

លុះស្តេចទ្រង់ព្រះសណ្តាប់ហើយ ទ្រង់សួរទៅអ្នកសច្ចំថា: "តើលោកគាថានេះពីណាមក?" ។

– សូមទ្រង់ព្រះមេត្តាជ្រាស! ទូលព្រះបង្គំបានទៅក្នុងម៉ុងខ្មោចពីថ្ងៃ ១៤ រោចនេះ ដើម្បីទៅសូត្រមន្តអាគមគាថា ដែលត្រូវធ្វើឲ្យទូលព្រះបង្គំឃើញរូបព្រាយមួយ; លុះរូបព្រាយនោះមកដល់ហើយ ទូលព្រះបង្គំក៏បានដោះយកគ្រឿងប្រដាប់ទំនងសម្ងៀកបំពាក់ហើយបានទាំងចាក់ភ្លៅឆ្វេងវាមួយច្បូកដែលមានផ្លែ ៣ ផង ។ ដោយហេតុនេះហើយបានជាទូលព្រះបង្គំបានគ្រឿងប្រដាប់នេះមក ។

ព្រះករុណាទ្រង់ព្រះសណ្តាប់ពាក្យអ្នកសច្ចំហើយ ស្តេចទ្រង់ថយព្រះអង្គចូលទៅក្នុងព្រះដំណាក់វិញ ឯអ្នកសច្ចំក៏បត់ដើរទៅលើកម្រាលរបស់លោកជដែល ។ ក្នុងណោះព្រះមហាក្សត្រទ្រង់មានព្រះពាក្យនាំទៅព្រះអគ្គមហេសីថា: "ចូរអ្នកទៅមើល! តើភ្លៅឆ្វេងរបស់នាងបច្ចុប្បន្នតើ មានស្នាមឬទេ ហើយចូលសង្កេតមើល តើស្នាមយ៉ាងណា? ។ ព្រះពាជអគ្គមហេសីក៏យាងទៅ ហើយទ្រង់ទតឃើញស្នាមច្បូកធ្មេញ ៣ ។ លុះត្រឡប់មកវិញទើបមានព្រះសារន៍ទូលព្រះពាជាថា: "សូមទ្រង់ព្រះសណ្តាប់ ភ្លៅរបស់នាងមានស្នាម ៣ មើលទៅហាក់ដូចជាស្នាមច្បូកផ្លែ ៣ ហើយយ៉ាង? ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ស្តេចក៏យាងចេញមក រួចទ្រង់ត្រាស់បង្គាប់ទៅលោកនាយកក្រុមព្រះនគរបាល ឲ្យហៅអ្នកសង្ខំមកម្តងទៀត ។ ក្នុងពេលដែលលោកនាយកក្រុមព្រះនគរបាលកំពុងធ្វើតាមព្រះរាជបញ្ជានោះ ស្តេចទ្រង់ព្រះចិន្តាថា "មិនគួរឲ្យអ្នកណាមួយដឹងរឿងក្នុងព្រះបរមរាជវាំងសោះ ជាហេតុនាំឲ្យអាម៉ាស់មុខណាស់" ។

ក្នុងពេលនោះ រាជអាមាត្យបាននាំអ្នកសង្ខំមកដល់ហើយឲ្យអង្គុយកន្ទែងមួយដោយឡែក ទើបព្រះមហាក្សត្រទ្រង់សួរថា: "ឱ! អ្នកសង្ខំជាទេវតាអើយ! បើនិយាយតាមគម្ពីរនោះ តើទោសយ៉ាងណាដែលត្រូវដាក់ដល់រូបមនុស្សស្រី?" ។

អ្នកសង្ខំឆ្លើយទូលថា: "បពិត្រព្រះមហាក្សត្រដ៏ថ្កើងថ្កានមើ! គម្ពីរបានចែងសេចក្តីថា ព្រាហ្មណ៍, សេះ, ស្ត្រី, កូនក្មេង, ឬអ្នកណាក៏ដោយ ដែលនៅក្រោមអធិបតិភាពរបស់ព្រះអង្គ ហើយបានប្រព្រឹត្តអំពើអាក្រក់នោះ ត្រូវតែនិរទេសចោលដោយដាច់ខាត" ។

លុះព្រះមហាក្សត្រទ្រង់ឮដូច្នោះ ទើបទ្រង់មានព្រះរាជបញ្ជាឲ្យនាងបន្ទាត់ឡើងជិះរទេះមួយ រួចនិរទេសចោលក្នុងព្រៃទៅ ។ ឯព្រះអង្គម្ចាស់ទីឯកកូនលោកវដ្ដមន្ត្រី ក៏ឡើងជិះសេះ ១ ម្នាក់ទៅតាមព្រះនាងក្នុងព្រៃ ហើយនាំព្រះនាងទៅស្រុករបស់ខ្លួនទៅ ។ អស់ចំនួនប្រាំនថ្ងៃ ដនតាំងពីគេក៏បានទៅដួបមុខបិតារៀងៗខ្លួន ។ ឯអស់នាម៉ឺនសព្វ

មុខមន្ត្រីចាំងធំ-តូច ក៏បានស្គាល់សេចក្តីក្សេមក្សាន្តយ៉ាងធំ ព្រមទាំងមានការដប់លៀងយ៉ាងអឹកអធិកផង ។

លុះនិយាយរឿងនេះហើយ ទើបអាកាសទូលទៅកាន់ស្តេចពិករ៉ន់ថា: "មើល! បណ្តាជនទាំងអស់ តើអ្នកណាខ្លះគេអាចបន្ទោសបាន?, បើស្តេចធ្វើយមិនសមទេ ព្រះអង្គនឹងធ្លាក់ទៅកាន់អបិនរកពុំខាន" ។

ស្តេចពិករ៉ន់ឆ្លើយថា: "គឺព្រះមហាក្សត្រហើយដែលខុសនោះ" ។ អាកាសសួរទៀតថា: "ហេតុដូចម្តេចបានជាស្តេចខុស?" ។

ស្តេចពិករ៉ន់តបថា: "កូនលោកដែលមន្ត្រីបានដួយបំពេញកិច្ចឆ្ពោះទៅហ្វាយនាយរបស់ខ្លួន, មេនាយកក្រុមព្រះនគរបាល បានស្តាប់បង្គាប់ស្តេចរបស់ខ្លួន, ឯព្រះនាងកល្យាណីក្សត្រី បានឃើញបំណងរបស់នាងដែលសម្រេច ។ បើដូច្នោះ គឺស្តេចហើយដែលខុសនោះព្រោះស្តេចនិរទេសនាងដោយឥតគិត" ។ និមិត្តតែកិរិយាពន្លូវព្រះរាជឱង្ការនោះ អាកាសក៏ត្រឡប់ទៅដើមឈើរបស់ខ្លួនវិញ ។ ព្រះមហាក្សត្រលុះខតដុំវិញព្រះអង្គពុំឃើញអាកាសនោះ ក៏ទ្រង់ត្រឡប់ទៅកន្លែងចាស់ដែលព្រះអង្គយាងមក ទ្រង់ឡើងទៅលើដើមឈើនោះ បានចងអាកាសលើស្មារួចទើបយាងទៅទៀត ។

ចំណែកខាងអាកាសបានក្រាបបង្គំទូលព្រះអង្គថា: "ត! ព្រះមហាក្សត្រ! ឯរឿងទី ២ របស់ទូលព្រះបង្គំនោះមាន ដូចតទៅនេះ:-

(មានត)

ដំណើរមកកាន់ប្រទេសកម្ពុជា

នៃមហាបណ្ឌិតគុណាបាលបិយសេន ម៉ាលាឡែះសេកេរ៉ះ

ជាអធិបតីពុទ្ធិកសមាគមពិភពលោកនៅលង្កាទ្វីប

របស់ពុទ្ធសាសនបណ្ឌិត្យ

(តកម)

សម្តេចប្រទេសជប៉ុន ដែលមានអាគមជាចំណុះ ចំនួន ១៨.០០០ វត្ត ក៏បានទិមន្តទៅដែរ ។ គោះហាវ៉ៃដែលមានប្រជាជន ៧៥.០០០ នាក់ មានអ្នកតំណាង ២ នាក់ទៅប្រជុំ ។ យួនមានអ្នកតំណាង ៣ នាក់, ប៉ាគីស្ថានមាន ៤ នាក់ គឺ ២ នាក់ជាលោកសង្ឃ, ២ នាក់ទៀតជាឧបាសក ។

ខ្ញុំមិនឃាត់ដំណរឿងនេះឲ្យវែងតេកទេ ព្រោះលោក-អ្នកប្រហែលជាបានជ្រាបអំពីសម្តេចសង្ឃនាយកសព្វគ្រប់អស់ហើយ ។ ដូច្នេះខ្ញុំសូមដំណរតែអំពីទីកន្លែងដែលប្រជុំនោះវិញ ។

ទីកន្លែងនុ៎ះ មិនធ្លាប់បើកប្រជុំពីកាលណាមកទេ ទើបតែនឹងមានក្នុងពេលនេះដែលជាលើកដំបូងបង្អស់ ។ មុននឹងប្រជុំ គេបានទៅទិមន្តព្រះចង្កឹមតែរមកដំកល់ជាប្រធាន ។ ក្នុងពេលនោះគួរឲ្យអស្ចារ្យណាស់ មហាមេឃដែលហួតហែង ៥ ខែមកហើយ ក៏បង្អុរក្បែងយ៉ាងបង្អុរចំនួនកន្លះម៉ោង ហើយរុក្ខជាតិក៏បានស្រស់ញញឹមឡើង ដូចជាមានសេចក្តី

អបអរសាទរនឹងឧត្តមគតិនៃទីប្រជុំ ដែលមានការចង់ឲ្យរួបរួមគ្នា ជាគោលបំណងធំនោះផង ។ អាកាសក៏ត្រជាក់ស្រួល, ទេសភាពនៃទីក្រុងក៏បានប្រលោមចិត្តក្មេវតាំងនោះ ឲ្យចេះតែមានអធ្យាស្រ័យស្រុះស្រួលគ្នាជានិច្ច ។

ក្នុងថ្ងៃទីពីរ មានប្រជុំជំពូងទៀត ដែលមានលោកនាយករដ្ឋមន្ត្រីប្រទេសលង្កាបានអញ្ជើញទៅជាអធិបតី ។ ក្នុងពេលនោះ មានប្រជាជនទៅជួបជុំប្រហែល ២០. ០០០ នាក់ រួមទាំងសមាជិកដែលមកពីប្រទេសផ្សេងៗ យ៉ាងច្រើននោះផង ។ ដូច្នេះ ការដែលរើសរកទីកន្លែងឲ្យបានសមរម្យ ក៏ជាបញ្ហាមួយយ៉ាងលំបាកបំផុត ។ មានអ្នកខ្លះបន្លាសឲ្យថា ខ្ញុំមិនគួរនឹងយកវត្តំប្រណាំងសេះ ទៅធ្វើនោះទេ សន្និបាតព្រះពុទ្ធសាសនាដែលជាទីគោរពយ៉ាងខ្ពង់ខ្ពស់របស់ប្រជាជនដូច្នោះទេ ។ តែនឹងរឿងនេះ ខ្ញុំសូមឆ្លើយថា វាលវត្តំប្រណាំងសេះនោះ មិនមែនជាទីកន្លែងចោកខាបដូចស្មានទេ ព្រោះកន្លែងនេះក៏ដូចជាព្រះវិហារមួយដែរ ដ្បិតនៅពេលប្រជុំនោះ ខ្ញុំបានឲ្យយកព្រះពុទ្ធរូបទៅតាំង ដើម្បីឲ្យទីកន្លែងនោះឡើងឋានៈទៅជាព្រះវិហារមួយយ៉ាងសុទ្ធសាធ ។

ការពិភាក្សាបានធ្វើយ៉ាងយូរ តាំងពីថ្ងៃទី ២៥ ឧសភា ទៅថ្ងៃទី ៦ មិថុនា ទើបសម្រេច, រួចហើយក៏បាននាំគ្នា ទៅប្រជុំនៅអនុភពបុរៈដែលជាទីក្រុងចាស់នោះទៀត ដោយមានការរៀបចំទទួលយ៉ាងអឺងអធឹង ។

បរិយាកាសនៃការប្រជុំ ដែលបានធ្វើដោយការយោគយល់ចិត្តគ្នាជាបំផុត បានទាំឲ្យមេត្រីភាពដែលមានការមួយឆ្នាំជាយូរមកហើយនោះ បានកូរតែចះឡើងវិញ ព្រោះកៀវទាំងឡាយមានការពាក់ទាក់នឹងគ្នាដូចជាបងប្អូនបង្កើត ។ ការប្រែស្រីយគ្នា ដូចជាគ្មានប្រកួតប្រកាន់និកាយអ្វីទេក្នុងទីប្រជុំគ្នានេះ ។ ដូច្នេះ យើញថាកិច្ចនេះជាជំហានដំបូងបង្អស់របស់ពុទ្ធសាសនិកជនទាំងឡាយ ដែលឈរមុខទៅកាន់ការរួបរួមគ្នា ដែលបានចាត់បងជាច្រើនសតវត្សមកហើយ ។

ឯកស្តលោក - អ្នកដ៏ចំរើនទាំងឡាយ ! កុងពិភពលោកយើងនេះ អ្នកកាន់ពុទ្ធសាសនាមានចំនួន ៦៨,៦ % ។ ចំនួនេះ យើញថាច្រើនជាងអ្នកកាន់សាសនាដទៃ គឺអ្នកកាន់សាសនាគ្រិស្តមានចំនួនតែ ១៦,៧% អ្នកកាន់សាសនាព្រាហ្មណ៍ ១៨,៣ % អ្នកកាន់សាសនាឥស្លាម ១៣,៦ %-។ល។ ប៉ុន្តែបើធៀបនឹងចំនួនប្រជាជនកុងពិភពលោកទាំងមូល ដែលមានដល់ទៅ ២.២៦៥ លាននាក់ នាពេលនេះ អ្នកកាន់ពុទ្ធសាសនាសព្វថ្ងៃនេះមានតែ ៣៥០ លាននាក់ នៃប្រទេសចំនួន ៦២ នោះ ។ ដូច្នេះយើញថាមិនទាន់ធ្លុះឈ្មោះឡើយ ។ ប្រសិនបើប្រទេសទាំងឡាយ កុងពិភពលោកបានកាន់ពុទ្ធសាសនាទាំងអស់គ្នា ដែលជាសាសនាប្រដៅឲ្យលះលាក់អាវុធចេញ នោះមុខជាសន្តិភាពគ្មានកុងលោកទេ ព្រោះមិនអាចនឹងលុបលាយកំពែងនៃសាមគ្គីធម៌ របស់ពុទ្ធបរិសទ្យបានឡើយ ។

ក្នុងពេលដែលទ្រព្យគតិរបស់យើង កំពុងតែត្រូវការនឹងធ្វើដំណើរផ្សាយសាសនា តាមគន្ធនៃបុព្វបុរសរបស់យើងនោះ យើងគួរឲ្យមានសេចក្តីស្តាយជាទីបំផុត ចំពោះការណ៍ដែលប្រទេសកាន់ពុទ្ធសាសនាចាំងឡាយបានបែកសាមគ្គីគ្នា ព្រោះតែការប្រកាន់និកាយ ដែលមានទង្វើត្រូវបែកបក្តីខុសគ្នាបន្តិចបន្តួច ។

យើងជាកូនព្រះពុទ្ធតែមួយព្រះអង្គ សេចក្តីប្រតិបត្តិរបស់យើងក៏ធ្វើទៅតាមព្រះធម៌នៃព្រះពុទ្ធតែមួយព្រះអង្គដែរ; ដូច្នេះ យើងត្រូវជាបងប្អូនធំគ្នា ហើយទុកជាពេលណាក៏ដោយ ក៏យើងមិនត្រូវប្រកួតប្រកាន់គ្នាឡើយ ។

ការខ្វែងគំនិតគ្នាក្នុងផ្លូវប្រតិបត្តិ ជាហេតុមួយយ៉ាងធំក្នុងការនាំឲ្យបែកសាមគ្គីនេះ, គ្មានបណ្តាលមកពីអ្វីទេ បណ្តាលមកតែអំពីការរៀនសូត្រ ដែលមិនបានធ្វើឲ្យស្របយោបល់ជាមួយគ្នា ។ សព្វថ្ងៃនេះអ្នកកាន់ពុទ្ធសាសនាបែកទៅជា ២ និកាយ គឺពួកមហាយាននឹងពួកហីនយាន ។ ពួកហីនយានថាពួកមហាយានមិនសូវល្អទេ ព្រោះមានព្រះច្រើនព្រះអង្គណាស់, ប៉ុន្តែពួកហីនយានឯងក៏មានព្រះច្រើនណាស់ដែរ គឺមានដល់ទៅ ២៨ ព្រះអង្គ ហើយនឹងច្រើនជាងនេះទៅទៀត ដូចមានច្រាកដកឯងមក្នុងអដ្ឋកថាគាថា (ធម្មសង្គណី) ជាតួយ៉ាង ។ ខាងមហាយានថាពួកហីនយានឆាន់សាច់សត្វ មិនល្អទេ ។ ពួកហីនយានក៏លើកហេតុថា ពួកមហាយានឆាន់អាហារយប់មិនល្អដែរ ។

ឥឡូវបើយើងចេះតែងដែកគ្នារកខុសរកត្រូវ ហើយដណ្តើមយកតែត្រូវរៀងខ្លួនខោះ ក៏ចេះតែមានខុសតទៅទៀត ។ ដូច្នេះយើងគប្បីតែលើកលែងទោសគ្នា លែងប្រកួតប្រកាន់គ្នាខោះ ទើបនឹងអាចញុំងសាមគ្គីធម៌ឲ្យកើតឡើងបាន ។

អ្នកផងគង់បានជ្រាបហើយថាសាមគ្គីធម៌នេះ មិនអាចនឹងកើតមានបាន ក្រៅពីការប្រជុំសម្រុះសម្រួលគ្នាដោយយល់ចិត្តយល់ថ្លើមគ្នាខោះទេ ។ ដូច្នេះ ហើយបានជាសមាគមពិភពលោក អញ្ជើញប្រទេសទាំងឡាយដែលកាន់ពុទ្ធសាសនា ទៅរួមប្រជុំ ដើម្បីនឹងសំរុះសំរួលអំពីប្រស្នាដែលខ្វែងគំនិតគ្នាឆ្ងែៗ ។ មានប្រស្នាជាច្រើនណាស់ដែលបំរុងនឹងលើកយកមកដោះស្រាយ ប៉ុន្តែបញ្ហាដែលបានដោះស្រាយរួចហើយខោះ គឺការកំណត់ថ្ងៃធ្វើវិសាខបូជា ឲ្យបានត្រូវគ្នាហើយនឹងទស្សនា ។

វិសាខបូជានេះ ប្រទេសបែកខាងមហាយាន មានប្រទេសចិន, ជប៉ុន, ទីបេត ជាដើម ឃុនធ្លាមុនយើងមួយអាទិត្យ ហើយគេរិះគន់ថាពួកហីនយានកន្លងឆ្ងាយថ្ងៃបរិនិព្វានៃព្រះសម្មាសម្ពុទ្ធ ។ ខ្ញុំបានស្ទើរឿងនេះ ដោយសុំឲ្យពួកមហាយានកំណត់យកតាមថ្ងៃដែលពួកហីនយានធ្លាប់ធ្វើខោះវិញ ព្រោះយើញថាពួកហីនយាន មានធ្លាក់ហានគ្រប់គ្រាន់ជាង ។ សភាកុងត្រែស៍បានកំណត់យកតែលមៅង ៨ នៃថ្ងៃ ១

ពេចខែវិសាខ ជាពេលសំពាប់សូត្រគាថាបូជា ។ ប្រទេសទាំង ១៦ ក៏ ប្រានយល់ព្រមតាមសេចក្តីសំរេចនេះ ។

ចំណែកខាងខន់សាសនា ដែលមានឆ្នូងៗ គ្នា ទៅតាមសេចក្តី ពេញចិត្តនៃប្រទេសនោះៗ ក៏ប្រានត្រូវយកមកសំរេចក្នុងសន្និបាតនេះដែរ: មានសមាជិកគ្រប់ប្រទេស ប្រានស្មើខន់រៀងខ្លួន ។ លុះពិភាក្សាទៅ ក៏ប្រានសំរេចយកខន់ដូចមានរូបប្រាកដមកក្នុងពេលនេះ ដើម្បីឲ្យងាយ ធ្វើផង តម្រូវទៅតាមឆព្វណ្ណរង្សីនៃព្រះសម្មាសម្ពុទ្ធផង ។

គឺថ្ងៃវិសាខបូជានេះហើយ ដែលជាថ្ងៃបើកសកពជថ្មី នៃខន់ សាសនាដែលទើបនឹងបង្កើតនោះ ទៅគ្រប់ប្រទេសកាន់ពុទ្ធសាសនា ។ គេប្រានចាប់ផ្តើមដោតខន់នេះក្នុងថ្ងៃជាមួយគ្នា ហើយធ្វើវិសាខបូជាត្រូវថ្ងៃ គ្នាទៀត ។ ទៅប្រទេសសៀមនឹងកូមា, តែកាលណាគេដំឡើងខន់ ជាតិគេហើយ គេក៏ដំឡើងខន់សាសនានេះជាមួយផងដែរ ។

មានប្រស្នាចាក់ស្រែះជាច្រើនទៀត ដែលពុំទាន់ប្រានលើកយក មកដោះស្រាយ មានប្រស្នាខាងការប្រកាន់ពួកគណៈជាដើម ។ ទៅ ប្រទេសលង្កា ក៏មានព្រះសង្ឃបែកគ្នាជានិកាយដែរ មានដល់ទៅ ៣ ពួក គឺ សៀមនិកាយ, រាមញ្ញនិកាយ នឹងមរម្មនិកាយ ។ ព្រះសង្ឃក្នុង និកាយទាំងនេះ មិនប្រានរួបរួមសង្ឃកម្មគ្នាទេ ប៉ុន្តែខាងគ្រហស្ថប្រុស ស្រីមានសេចក្តីពាប់អាន គ្នាដូចបងប្អូនបង្កើត ដោយតតិតដល់ពួកគណៈ ណាមួយឡើយ ។

ទៅប្រទេសខ្លះ ព្រះសង្ឃដែលខុសនិកាយគ្នា មិនត្រមនាន់រួមគ្នាទេ ទុកជាមានការបង្ខំយ៉ាងណាក៏ដោយ ។ ការបែកខ្ញែកគ្នានេះ បើប្រសិនជាអ្នកណាមួយអាចរួបរួម ឲ្យបានសម្រេចដូចបំណងបានទោះ ក៏ជាការប្រសើរណាស់ ។ គួរឲ្យនឹកឆ្ងល់ណាស់ដែរ ! ពួកឧបាសក ឧបាសិកាដែលមានសំលៀកបំពាក់ប្លែកៗ គ្នា, គេចេះទៅមករកគ្នា ចេះប្រស័យគ្នា ដោយមេត្រីភាពយ៉ាងស្មោះសរ ដូចបងប្អូនបង្កើត ! ចុះចំណែកខាងព្រះសង្ឃក្នុងព្រះពុទ្ធសាសនាវិញ ដែលមានសំលៀកបំពាក់ដូចគ្នាផង កាន់សាសនាព្រះពុទ្ធតែវគ្គាផង ហេតុម្តេចក៏មិនទៅមករកគ្នា ? ហេតុអ្វីក៏ធ្វើកិរិយាព្រងើយកន្តើយនឹងគ្នា ដែលមិនសមថាជាបងប្អូនរួមសាសនាជាមួយគ្នាសោះ ? ។

កុំថាឡើយដល់ទៅសេចក្តីប្រតិបត្តិ, សូម្បីសំលៀកបំពាក់នៃព្រះសង្ឃសព្វថ្ងៃនេះ ក៏មិនត្រូវគ្នាដែរ, ខ្លះប្រើពណ៌ខ្មៅ, ខ្លះពណ៌លឿង, ខ្លះប្រើស្បង់ចីពរ, ខ្លះប្រើខោអាវ ។ ខ្ញុំមិនដឹងនឹងរកឧបាយធ្វើយ៉ាងដូចម្តេចទេ ដើម្បីឲ្យព្រះសង្ឃទាំងនេះជានឹងគ្នាវិញបាន, ប៉ុន្តែមានមធ្យោបាយមួយដែលខ្ញុំនឹកស្មានទៅ គឺគាល់តែបើកឲ្យមានការរៀនជាមួយគ្នា ហើយនឹងបើកប្រជុំគ្នាជាញឹកញយ ។ ដែលយើងមិនរៀនជាមួយគ្នា មិនប្រជុំញឹកញយនោះ ជាហេតុនាំឲ្យមានការលាក់គំនិតគ្នា ហើយនឹងបែកខ្ញែកយោបល់គ្នា កន្លងការប្រតិបត្តិផ្សេងៗ ។ តាមបំណងរបស់ខ្ញុំ,

ខ្ញុំចង់ខុកប្រទេសលង្កាជាមជ្ឈមណ្ឌលនៃការសិក្សា ព្រោះបើកាលណាព្រះសង្ឃទាំងឡាយនោះរៀនចេះដឹងត្រូវគ្នាហើយ នឹងបើកប្រជុំនិយាយគ្នាពីរឿងនេះ ។

ខ្ញុំបានដឹងច្បាស់ហើយថា ដែលនឹងមាននាទីនិយាយគ្នាពីរឿងនេះបាន គាល់តែសម្តេចសង្ឃនាយកនៃប្រទេសទាំងឡាយ, ព្រោះបើកាលណាអ្នកធំៗរួមគ្នាហើយ អ្នកតូចៗក៏មុខជានឹងរួមគ្នាទៅឯង ។ ប៉ុន្តែដើម្បីឲ្យងាយដល់ការរួបរួមជាងនេះទៅទៀត មានតែត្រូវរៀនសូត្រឲ្យចេះដឹងជូនគ្នាសិន ។

នៅប្រទេសយើង, ពួកក្មេងៗ ក៏កាន់សាសនាដែរ, តែបើគេសួរទៅវា ក៏មិនអាចនឹងឆ្លើយតបអ្វីបានឡើយ ។ យ៉ាងនេះនាំឲ្យការដោះស្រាយបញ្ហារបស់យើង ត្រូវងាកទៅរកវិបចំការអប់រំក្មេងនោះផង ព្រោះការអប់រំពីតូចៗជាការសំខាន់ណាស់ បែកខាងជំនឿ ។ សន្ដានរបស់ក្មេងងាយនឹងពត់ជាបំផុត ។ បើប្រសិនជាវាទៅរៀននៅសាលាឯទៀត ដែលមានបង្រៀនតែសាសនាដទៃ នោះវាក៏នឹងជាក់ចិត្តជឿតាមតែសាសនាណា ដែលគ្រូបានបង្ហាត់បង្រៀនវាដោយហ្មត់ចត់ គឺធម្មជាតិរបស់វាតែងតែរេរៀតាមគេញាក់ជាដរាប ។

តាមសេចក្តីសង្កេតរបស់ខ្ញុំ, ក្នុងជំណើរទស្សនាការ ដែលខ្ញុំទើបនឹងបានធ្វើមកនេះ យើញថានៅក្នុងសាលារៀនរាជការក្នុងប្រទេសកម្ពុជា

គ្មានបញ្ចូលដំបូន្មានខាងពុទ្ធសាសនា ទៅក្នុងកម្មវិធីនៃការបង្ហាត់បង្រៀន
ទេ ។ របៀបនេះ នឹងហុចផលមកឲ្យវិញផ្ទុយគ្នានឹងសេចក្តីត្រូវការ
របស់ប្រទេសយើង ព្រោះយូរទៅក្មួនចៅយើងមុខជានឹងរោតចិត្តលែងដឿ
ពុទ្ធសាសនាពុំខាន ។ ចំណែកនៅប្រទេសខ្ញុំ គេបានបញ្ចូលវិជ្ជាពុទ្ធ-
សាសនាទៅក្នុងឡាក់សូត្រនៃការសិក្សាជាតិដែរ មកជាយូរឆ្នាំហើយ ។

ម្យ៉ាងទៀត ខ្ញុំសង្កេតឃើញនៅប្រទេសកម្ពុជានេះ គ្រូបង្រៀន
ស្រីៗ នៅមានចំនួនតិចណាស់ ដែលត្រូវតែជួលគ្រូជាតិដទៃមកបង្ហាត់
បង្រៀន ។ ការជួលជាតិគេនេះ មិនជាការប្រពៃទេ ព្រោះគ្រូដែល
យើងជួលនោះ មុខជាមិនបង្រៀនសាសនា តាមសេចក្តីត្រូវការរបស់
យើងឡើយ ។ មិនមែនតែនៅប្រទេសកម្ពុជាទេ សូម្បីប្រទេសរបស់ខ្ញុំ
ក៏មានទំនងដូចគ្នានឹងប្រទេសនេះដែរ ។ ដូច្នេះ យើងត្រូវតែចំណោះ
ស្រាយបញ្ហានេះ ដោយពួតដៃរៀនសូត្រជាមួយគ្នា ពួតដៃបំរើ
ប្រទេសជាមួយគ្នាឡើង ដើម្បីជ្រោងអធិបតេយ្យនៃមាតុភូមិយើងឲ្យក្តី
ត្រចះ ដែលជាហេតុនាំឲ្យពុទ្ធសាសនា ចាប់រុងរឿងដោយសារផង ។

អស់លោកអ្នកជាំងឡាយ ! ព្រះពុទ្ធសាសនានេះ ជាមត៌កមួយ
ដ៏ប្រសើរ ដែលដូនតាយើងបែកឲ្យមក ហើយមានជាំងពេលខ្លះ លោក
ចាប់លះជីវិត ដើម្បីរក្សាសាសនានេះទុកមកឲ្យយើងផង ។ ដែលហៅ
ថាមនុស្សល្អ គឺមនុស្សដែលចេះរក្សាមត៌កនោះឲ្យបានគង់វង់ ។ ដូច្នេះ

យើងមិនត្រូវបោះបង់ព្រះពុទ្ធសាសនា ដែលជាទំនុកការៈរបស់ដូនតាយើងចោលឡើយ ។ ប៉ុន្តែបើយើងចង់ធ្វើឲ្យបានត្រឹមត្រូវ តាមតម្រាប់របស់បុព្វបុរសយើងនោះ យើងត្រូវតែនាំគ្នាទំនុកបម្រុងសាសនានេះ ឲ្យរីកសុះសាយទៅក្នុងពិភពលោកទាំងមូល ។ ព្រោះព្រះធម៌របស់ព្រះពុទ្ធមិនមែនជារបស់អាចំកំបាំង សំរាប់លាក់មិនផ្សាយនោះទេ មិនមែនជារបស់សំរាប់តែប្រទេសណា ឬប្រជាជនណាម្នាក់ៗទេ គឺសំរាប់ពិភពលោកទាំងមូល ។

កាលព្រះសម្ពុទ្ធទ្រង់គង់ព្រះជន្មនៅឡើយ ទ្រង់បានត្រាស់បង្គាប់សាវ័កថា "ត្រូវនាំគ្នាទំនុកបម្រុងដំបូន្មានរបស់តថាគតនេះ ក្នុងទីគ្រប់ទិសតាមដែលអាចធ្វើទៅបាន" ។

ក្នុងពុទ្ធប្រវត្តិថា លើកដំបូងមានតែព្រះសង្ឃ ៥ អង្គ (បញ្ចវគ្គិយ) ទេដែលទទួលការៈផ្សាយសាសនាផ្ទាល់ពីព្រះសម្មាសម្ពុទ្ធ ។ ព្រះសង្ឃ ៥ អង្គនេះ បាននិមន្តទៅបញ្ចុះបញ្ចូលបានសិស្សជាយ៉ាងច្រើន ដែលបានសាយភូជាជាតិបដល់សព្វថ្ងៃនេះ ដល់ទៅ ៣៥០ លាននាក់ ។ នេះគ្រាន់តែគណាចារ្យ ៥ រូបផង ។ ចុះប្រសិនបើ មានគណាចារ្យច្រើននាក់ទៅទៀត ដែលប្រទេសកាន់ពុទ្ធសាសនាទាំងឡាយរួមកម្លាំងគ្នាបង្កើតឡើងនោះ ប្រជាជនក្នុងពិភពលោកទាំងមូល ដែលមានចំនួន ២.៦៦៥ លាននាក់នោះ ក៏មុខជាទទឹងបានទទួលពន្លឺនៃពុទ្ធសាសនា

ទាំងអស់គ្នា ដោយធាប់រួសពន់ពុំខាន ។ ប៉ុន្តែខ្ញុំសូមរំលឹកថា ដើម្បី
នឹងចាត់វិធានការនេះឲ្យសំរេចទៅបាន ត្រូវតែយើងចំរើន, រៀនឲ្យ
ត្រមៗគ្នា ហើយប្រែកម្មវិធីនៃការសិក្សារបស់យើងឲ្យខាន់សម័យឡើង
ដើម្បីនឹងបង្កើតអាត្មនដែលបុិនប៉ាវ ទាំងខាងផ្លូវលោកទាំងខាងផ្លូវធម៌ អាច
នឹងធ្វើបដិវត្តជាមួយពួកបណ្ឌិតដែលមានវិជ្ជាជ្រៅជ្រះខាងផ្លូវលោក ក្នុង
បច្ចុប្បន្ននេះបាន ។ គេមិនត្រមជឿយើងទេ បើតាលណាយើងមាន
ចំណេះវិជ្ជាខ្ពស់ខ្ពាយជាងគេ ។ ការមិនជឿនេះ មិនអាចនឹងញុំាង
សេចក្តីសង្ឃឹយរបស់គេឲ្យអស់ទៅបាន ។ ត្រង់នេះហើយ ដែលខ្ញុំសូម
ក្រើនតុ្ទបរិស័ទទាំងឡាយ ឲ្យយើញច្បាស់នូវតំណែ្សសាមគមពិភពលោក
ដែលមានបំណងនឹងបង្កើតមជ្ឈមណ្ឌល នៃការសិក្សាពុទ្ធសាសនាឡើង
វិញជាថ្មី នៅប្រទេសលង្កាតាមតម្រាយដែលធ្លាប់មានមកហើយកាលពី
សម័យបុំពណ សឹងមានមហាវិទ្យាល័យពុទ្ធសាសនាមួយ នៅមហាវិហារ
ក្នុងអនុរាធបុរៈជាកស្តុតាង ។

អស់លោក - អ្នកជាបងប្អូនរួមសាសនាទាំងឡាយ? ក្នុងពេលដែល
លោកសន្ទនាស កំពុងតែត្រូវភ្លើងសង្គ្រាមឆេះយ៉ាងខ្លាំងនេះ មានអ្នក
នយោបាយជាច្រើននាក់ បានបញ្ចេញយោបល់ផ្សេងៗគ្នា អំពីបំណង
នឹងរំលត់ភ្លើងសង្គ្រាមនោះទៅវិញ ។ ខ្ញុះថាបើបង់ឲ្យបានសុខ ត្រូវធ្វើ
គាប់ប្រកបរមាណឲ្យបានច្រើន ខ្ញុះទៀតថា ត្រូវតែបង្កើតឲ្យមានពលការ

តែមួយនៅគ្រែមេឃនេះ ។ រឿងនេះមុខជាមិនបានសំរេចដូចបំណងទេ ព្រោះពៀរមិនអាចនឹងរម្ងាប់បានដោយការចងពៀរឡើយ ហើយដែលថាត្រូវតែដោះស្រាយ ដោយការបង្កើតភាពការតែមួយ ក្នុងពិភពលោកនោះវិញ ក៏មិនជាយូនឹងលត់ភ្លើងសង្គ្រាមឲ្យផុះស្រឡះក្នុងលោកទៅបានដែរ ព្រោះពួកគ្នាគេ មុខជាយកតែពួកគ្នាគេឲ្យធ្ងើធំ ដែលនាំឲ្យមានសេចក្តីមិនសុខចិត្តនឹងគ្នាកើតឡើងពុំខាន ។

ឯពួកយើងដែលជាអ្នកកាន់ពុទ្ធសាសនាវិញ គ្មានរឿងអ្វីទៅនិយាយនឹងគេទេ ព្រោះយើងមិនចេះធ្វើគ្រាប់បែកបរមាណូ ទាំងមិនចេះធ្វើកាភ្លើង ។ ដូច្នេះហើយបានជាយើងត្រូវការនិយាយគ្នាតែពីរឿងពុទ្ធសាសនាដែលប្រដៅមិនឲ្យលោភលន់ មិនឲ្យបៀតបៀនគ្នា ទាំងមិនឲ្យប្រើអំណាចសង្កត់សង្កិនបុគ្គលជាដៃប៉ុណ្ណោះ ។ ក្នុងលោកនេះ យើងពួកពុទ្ធសាសនាមានភាគច្រើនជាងគេ ហើយគេមានជ័យជំនះមកលើយើងតែខាងផ្លូវអាវុធប៉ុណ្ណោះទេ ; ចំណែកខាងផ្លូវសាសនាវិញ គ្មានអ្នកណាមួយនឹងអាចមកយកជ័យជំនះ លើកំភ្លើងជំនឿរបស់យើងបានឡើយ គឺកម្ងាន់ទឹកចិត្តយើងនៅតែមានឥទ្ធិពលជានិច្ច ។ ដូច្នេះយើងមិនត្រូវគិតថា វត្តបំណងដែលយើងគិតនោះ ជាការហួសវិស័យនឹងសំរេចដូច្នេះទេ បើប្រសិនណាជាយើងខំប្រឹងប្រែងទាំងអស់គ្នា ។

ម្យ៉ាងទៀត ប្រទេសកម្ពុជានេះ មានពុទ្ធសាសនាប្រតិស្ឋាននៅដោយមូតមាំណាស់ ។ គោលការណ៍របស់ពុទ្ធសាសនាគឺនវត្តដែល

រុងរឿងមានឈ្មោះល្បីសុះសាយទៅក្នុងពិភពលោក ។ តាំងពីដើមមកគ្មានប្រទេសណាមួយ មានគ្រឹះសំគាល់សាសនាយ៉ាងធំដុំ ដូចប្រទេសកម្ពុជាទេ ។ ប្រទេសនេះបានផ្សាយពុទ្ធសាសនាទៅក្នុងគ្រប់ខ្នងឆ្នាំនានា ស្ទើរតែគ្រប់តំបន់ទាំងអស់ក្នុងសុវណ្ណភូមិ ដូចមានបុព្វហេតុនៃជាតិនេះ នៅជាពស្តុតាងដកបដល់សព្វថ្ងៃ ។ ហេតុនេះ យើងដែលជាកូនចៅនៃអ្នកកាន់ពុទ្ធសាសនា ត្រូវតែយកតម្រាប់តាមដូនតាយើងមិនត្រូវបណ្តែតបណ្តោយឲ្យពេលវេលាដែលជាមាសច្រាក់លែងយើងហួសទៅទៀតឡើយ ។

ព្រះគុណជាអម្ចាស់ជីវិតលើតួង ឃានទ្រង់ជាបង្អែកយ៉ាងមាំក្នុងការដែលបើកឲ្យប្រជាពស្តុរបស់ព្រះអង្គ ប្រតិបត្តិព្រះពុទ្ធសាសនានេះ ។ ឯកឧត្តម រដ្ឋមន្ត្រីក្រសួងធម្មការ ក៏ឃានជួយការពារយើងយ៉ាងពេញបន្ទុក ។ យើងមិនត្រូវខ្លាច មិនត្រូវរួញរាទេ ត្រូវតែហ៊ានបរិច្ចាគធនធាន ដើម្បីសេចក្តីរុងរឿងពុទ្ធសាសនា ដែលជាទីគោរពរាប់អានរបស់យើង ។

ចំពោះការផ្សាយសាសនានេះ ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមាំលើកិច្ចសិក្សានៃព្រះសង្ឃខ្មែរទាំងឡាយ ដែលមានសាលាចាលីជាន់ខ្ពស់ជាគោល ។ ប៉ុន្តែខ្ញុំសូមរំឭកថា ត្រូវតែខំសិក្សាបន្តទៅមុខទៀត ដើម្បីឲ្យចំណេះយើងបានជ្រៅជ្រះ ។

អស់លោក - អ្នកទាំងឡាយ! ខ្ញុំបានដើរច្រើនស្រុកណាស់ហើយ មិនធ្លាប់ឃើញប្រជាជនកន្លែងណា មានអធ្យាស្រ័យល្អដូចប្រជាជនខ្មែរនេះទេ ។

ថ្ងៃនេះជាថ្ងៃដែលពុទ្ធបរិស័ទរួមគ្នាធ្វើសាទរបូជា, ដូច្នេះខ្ញុំសូមឲ្យ
អស់លោកទុកថ្ងៃនេះ ជាថ្ងៃចាប់ផ្តើមដ៏រីករាយថ្មីដែលយើងត្រូវតែរួបរួមគ្នា
ដោយការឥតច្រកាន់ពួកគណៈ ។

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណ យ៉ាងខ្ពស់ចំពោះព្រះករុណា
ជាអម្ចាស់ជីវិតលើត្បូង ចំពោះរដ្ឋាភិបាលដែលបានជួយឧបត្ថម្ភខ្ញុំ ឲ្យបាន
ប្រកបដោយសេចក្តីសុខស្រួលគ្រប់យ៉ាង; មិនតែប៉ុណ្ណោះ ខ្ញុំសូមថ្លែង
អំណរគុណយ៉ាងស្មោះចំពោះ ដល់លោកអ្នកសប្បុរសទាំងឡាយ ដែល
បានជួនកំណត់យសដល់ខ្ញុំ ដោយប្រឹងតាំនៅស្តាប់ចម្រៀងយ៉ាងវែង
របស់ខ្ញុំនេះដរាបដល់ចប់ ។ មួយទៀត ខ្ញុំមិនភ្លេចជូនពរសេចក្តីពាក់ព័ន្ធ
របស់ប្រទេសកម្ពុជានេះ ដល់បងប្អូនខ្ញុំ ដល់មិត្តភក្តិខ្ញុំ ដល់រដ្ឋាភិបាល
ខ្ញុំទេ ។ ខ្ញុំសូមសន្យាថា បើលោក-អ្នកមានឧកាសទំនងអញ្ជើញទៅលេង
លង្កាខ្លីប ដែលមានចម្ងាយតែរវាងបួនម៉ោងហ្នឹងយ៉ាងស្រាន់នោះ លោកអ្នកមុខជានឹង
បានទទួលបដិសណ្ឋារៈយ៉ាងពាក់ព័ន្ធ អំពីប្រជាជនលង្កាវិញពុំខាន ។

ចប់

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណាំងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែវិច្ឆិកា លេខ ១១

ព. ស. ២៤៨៤ — គ. ស. ១៩៤១

សេចក្តីជូនដំណឹងពិសេស

ពីក្រុមពុទ្ធសាសនបណ្ឌិត្យ

សៀវភៅ សត្តបរិត្ត—ទ្វាទសបរិត្ត នឹង ជាតិមោក្ខសង្ខេប ដែលជាវអស់ពីលើកមុន, ឥឡូវនេះ ជាន់រើបោះពុម្ពឡើងទៀត ជាច្រើនចប់ មានសម្រាប់ជាវដល់បណ្តាជនទូទៅ ។

ដូច្នេះ, អស់លោក-អ្នកពុទ្ធបរិស័ទ ដែលមានបំណងរន់ចាំជាវសៀវភៅនេះ សូមអញ្ជើញចូលទៅជាវតាមត្រកាល នៅក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ។

សៀវភៅ សត្តបរិត្ត-ទ្វាទសបរិត្ត ថ្លៃ ១៩.០០ កន ១ ក្បាល ។

— ជាតិមោក្ខសង្ខេប — ៧.៥០ កន ១ ក្បាល ។



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
ពុទ្ធសាសនានិងគ្រិស្តសាសនា (សន្និសិទលោកវេជ្ជបណ្ឌិតមីគូត៍) (តមក)	លោកវ៉ាយ-ប៊ុក	៨០៣
ពន្ធអាស៊ីទ្វីប (តមក)	លោកវ៉ាយ-ប៊ុក	៨០៨
ទិដ្ឋធម្មិកកថា	ព្រះអរិយាសប្ប កែវ-អ៊ូច	៨១២
ផ្នែកអក្សរសាស្ត្រ		
ប្រស្នាពិធីបុណ្យភ្ជោច	លោក ប៊ូ-ប៊ូ	៨១៨
រឿងស្តេចត្រី	លោកផេង-ជ្រឿ	៨៣១
ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម	៨៤៣
រឿងសាមកុក (តមក)	ឧកញ៉ា ឆូ-កន	៨៥១
ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក)	ឧកញ៉ា ឈឹម-ក្រសេម	៨៦១
រឿងអារក្សថ្លែងរឿងម្តែប្រាំ (តមក)	លោកសាង-សាវ៉ាត	៨៦៤
កំណត់ទឹកប្រវត្តិការណ៍		
អនិច្ចធម្មនៃព្រះទេពមុនី យូរ-ប៊ុណ្ណា	ព្រះទេពសត្ថា ស្មូរ-ហាយ	៨៧១

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដាវ ១៤៥ រ. ០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE — Pages

Bouddhisme et Christianisme (Conférence du Docteur A. Migot) (suite)	M. RAY-BUC	803
La Lumière de l'Asie (suite)	M. RAY-BUC	808
Dithidhammikal atha	Vén. KEO-OUCH	812

PARTIE LITTERAIRE

Différentes rites funéraires	M BOU-PO	818
Histoire du Roi-Poisson Contes et Légendes roumains)	M. PHENG CHRIEU	831
Education morale (suite)	Vén. PENG-PAM	843
Histoire de SAMKOK (suite)	Oknha NOU-KAN	851
Histoire du Royaume du Cambodge (suite)	Oknha CHHIM-KRASEM	861
Les vingt-cinq récits du mauvais Génie (suite)	M. SANG-SAVATH	864

NOTES ET CHRONIQUES

Décès de Brah Debamuni You-Pona	Vén. SO-HAY	871

Prix d'abonnement annuel comprenant 12 numéros: 145800

ពុទ្ធសាសនា និង គ្រិស្តសាសនា

សន្និសិទលោកផ្ដែបណ្ឌិត មីគ្លូត

លោក ប៉ាយ-ប៊ុក គ្រូមការ នៅពុទ្ធសាសនបណ្ឌិត្យ កុំពេញ

ប្រែពីទស្សនាវដ្ដី "ហ្រ្វង់ស៊ូ—អាស៊ី" ខែមិថុនា ឆ្នាំ ១៩៥០

(តមក)

អ្នកទាំងពីររស់នៅដោយសីលធម៌តែមួយដូចគ្នា ប្រព្រឹត្តធ្មត់ដូចគ្នា, ដើរតាមផ្លូវធម៌ដូចគ្នា, មានបំណងទៅកាន់អហេតុកជាតុដូចគ្នា ហើយមានសភាពរលាយមួលបួលគ្នាតែមួយ ប្រៀបដូចទឹកទន្លេថ្លាច្រើនដែលហូរមកពីទីបផ្សេង ។ ប្រមូលបួលទៅកាន់មហាសាគរតែមួយ ។

ខ្ញុំខំព្យាយាមបង្ហាញលោកអ្នកអំពីពួកអ្នកបច្ចឹមទ្វីប ដែលមានគំនិតយល់មិនបានសព្វគ្រប់ ហើយខ្វែងគំនិតចំពោះព្រះពុទ្ធសាសនា ។ យើងបានឃើញថា សីលធម៌ខាងព្រះពុទ្ធសាសនាមានសភាពដ៏ខ្ពង់ខ្ពស់ ជាងសីលធម៌ខាងគ្រិស្តសាសនា ហើយសីលធម៌នោះអាចមានពលភាពទៀងទៅដល់កំពូលនៃព្រហ្មវិហារធ៌ពលីកម្ម ។ យើងបានឃើញជាញឹកញាយនូវពួកគ្រែជាង (គ្រិស្តសាសនិកជន): ពិតមែនតែពួកនេះទទួលស្គាល់នូវសីលធម៌នៃព្រះពុទ្ធសាសនាថាមានសភាពល្អស្អាត, តែនៅយល់ថាព្រះពុទ្ធសាសនា ជាសាសនាមានសភាពមិនបានពេញលក្ខណៈ,

ហើយថាលុះតែត្រូវយកគ្រិស្តសាសនាមកអនុវត្តិផង ទើបបានជាសាសនាពេញលេញ ។ ដែលពួកនេះយល់ដូចនេះដោយសារការពិនិត្យឃើញថាព្រះពុទ្ធសាសនាមិនព្រមទទួលស្គាល់ព្រះអាទិទេព (អាទិទេវមិច្ឆាគតិ Athéisme) នឹងមិនព្រមអនុម័តិនូវព្រះអាទិទេពថាមានសភាពពិត ។ យើងបានពិនិត្យឃើញថាដែលស្របនឹងយោបល់នេះ ចំពោះព្រះពុទ្ធសាសនាខាងហីនយានមិនសូវជាត្រូវចំពិតណាស់ទេ, បើតាមលទ្ធិខាងមហាយាន មតិនេះគឺមានសភាពខុសពេញលក្ខណៈ ។ បើគេពិនិត្យព្រះពុទ្ធសាសនាតាំងមូលសព្វគ្រប់ទៅ គេអាចឃើញបានថាពេលដែលព្រះពុទ្ធសាសនាកំពុងវិវត្តិក្នុងពិភពលោក, ការបុច្ឆា-វិសជ្ជនាអំពីអាទិទេវគតិ នឹងបរមត្ថវិជ្ជាដែលមានសំដែងក្នុងគម្ពីរព្រះវិន័យជាដើម ខ្លះ ឃើញថាបញ្ហាមានអត្ថដ៏គម្លីរភាព រហូតដល់បញ្ហាអហេតុកធាតុនឹងព្រះអាទិទេព, ហើយគេអាចពិនិត្យទៅឃើញថា គ្មានសាសនាណាពណ៌នាអំពីរឿងនេះ ឲ្យច្បាស់លាស់ដាងព្រះពុទ្ធសាសនានេះឡើយ ។ បើតាមយោបល់របស់ខ្ញុំ បញ្ហាក្នុងអហេតុកធាតុខាងព្រះពុទ្ធសាសនា គេយកមកដោះស្រាយខាងផ្លូវប្រាជ្ញា ជាញឹកញាប់ជាងខាងគ្រិស្តសាសនា ។ ព្រោះហេតុដូចនេះ, ព្រះអាទិទេព តាមគម្ពីរគ្រិស្តសាសនា (Bible) ថាមានបុគ្គលិកលក្ខណៈជាមនុស្សសាមញ្ញ Vêtement anthropomophique) ប្រៀបដូចគ្នានឹងព្រះអាទិទេព ដែល

មានរូបនឹងនាមលក្ខណៈផ្ទៃកខាងព្រហ្មញ្ញសាសនា ។ ក្នុងរឿងនេះ, មានតែប្រទេសឥណ្ឌាតែមួយទេ ដែលអាចពិនិត្យទៅឃើញអហេតុកជាតុមួយ គ្មានសភាពប្រែប្រួល, ទៅពីលើ ៣រូបអាទិទេពដែលជាទីគោរព ហើយជារូបនិម្មិតផ្សាយចេញ ដោយឥទ្ធិពលអំពីអហេតុកជាតុ ។

គេអាចពោលអំពីព្រះពុទ្ធសាសនាតទៅទៀត ថាជាសាសនាមិនមែនប្រព្រឹត្តបានដោយងាយឡើយ គឺជាសាសនាគេលំបាកនឹងប្រតិបត្តិតាមជាងគ្រិស្តសាសនា (សាសនាកាតូលិក) ។ ពិតមែនតែសាសនាទាំងអស់មានវិធីប្រតិបត្តិជាសាមញ្ញលក្ខណៈងាយបំផុត គឺគ្រាន់តែប្រព្រឹត្តទៅតាមសទ្ធានឹងតាមវិធីប្រតិបត្តិជាពាហិរភាព ។ បើតាមពិត ការប្រព្រឹត្តធម៌ជាសុក្រិតភាព ត្រូវមានការព្យាយាមយ៉ាងម៉ឺងម៉ាត់ ដោយចិត្តក្លាហានអង់អាច ។

ខ្ញុំចង់ប្រៀបធៀបគ្នាខ្លះសាសនាទាំងពីរ អំពីតុំបំណងដែលសាសនានេះឬនកំណត់ទុក, តើសាសនាទាំងពីរបញ្ជាត្តិឲ្យសាវ័កប្រព្រឹត្តយ៉ាងណាខ្លះ? ។ ចំណែកខាងសាសនាកាតូលិក សន្តភាព (Sainteté) ជាឧត្តមគតិចំពោះបុគ្គលមានភាគតិច; សន្តភាពនេះ មិនមែនបញ្ជាត្តខ្លួទៅដល់ពួកសាមញ្ញជនទាំងអស់ទេ, តុំបំណងនៃសាសនានេះ គឺថ្នាក់ទៅកាន់សុគតិដោយប្រព្រឹត្តដីវភាពខ្លួន ទៅតាមបទបញ្ជាត្តិនៃព្រះអាទិទេពនឹងវត្តប្រតិបត្តិ ។ កម្មវិធីនេះ នាំឲ្យមានការប្រែឆ្លែង, តែការ

ប្រព្រឹត្តិនោះមានពួកសន្តបុគ្គល (Croyants) ដោយកាត់ច្រើនអាចធ្វើ
បានដោយងាយ, ហើយមានសារ័កខ្លះអាចប្រតិបត្តិឲ្យបានសម្រេចតាម
បំណង ។

បំណែកខាងពួកគ្រិស្តសាសនិកជន បើចង់ដោះខ្លួនឲ្យរួចពីទុក្ខ
ទាំងពួង មិនចាំបាច់ធ្វើខ្លួនឲ្យជាសន្តបុគ្គលទេ, ឯពួកពុទ្ធសាសនិកជន
ក៏ត្រូវតែសម្រេចខានមិនបាន នូវសម្មាសម្ពោធិញ្ញាណ គឺការត្រាស់ដឹង
ជាព្រះពុទ្ធមួយព្រះអង្គ ដើម្បីនឹងចេញចាកតណ្ហា ។ កិច្ចដែលត្រូវ
ធ្វើនេះជាកិច្ចតឹងរឹងពន់ពេក ។ គេអាចប្រព្រឹត្តធម៌ទៅតាមលំអាន ឬ
ប្រាថ្នាឲ្យបានសម្រេច ចំពោះជាតិនេះ ដូចជាពួកយោគាវចរខាងប្រទេស
ទីបេត ជាសារ័កខាងផ្លូវត្រង់ (Sentiredirect) ឬធ្វើឲ្យបានចម្រើនបន្តិច
ម្តងៗ ជាច្រើនជាតិ ចំពោះផ្លូវសាម័ញ្ញ ។ ធ្វើយ៉ាងដូចនេះ គ្រាន់
តែបន្ទរបន្ទុយនូវវត្តប្រតិបត្តិប៉ុណ្ណោះ; តែដល់អរិយានជាតិ ត្រូវតែព្យាយាម
ដោយក្លាហាន ប្រព្រឹត្តនូវធម៌ជាន់ខ្ពស់ ដើម្បីនឹងសម្រេចនូវពុទ្ធភូមិ ។

រឿងរ៉ាវទាំងប៉ុន្មាន ខ្ញុំបានពណ៌នាហើយ, តែបើខ្ញុំពោលថាខាង
បូព៌ាទ្វីបមានសុទ្ធតែរបស់ល្អ, ខាងបច្ឆិមទ្វីបមានសុទ្ធតែរបស់អាក្រក់
នោះគេនឹងទុកខ្ញុំជាពួកអធម្មយុត្តិកបុគ្គល ។ តាមពិតមនុស្សនៅគ្រប់ទី
កន្លែងពោរពេញទាំងអំពើល្អ ឬអំពើអាក្រក់ដូចគ្នា ។ ពួកខាងគ្រិស្តសាសនាដែល

ពោលថាកត្តិសព្ទនៃសាសនានេះមកពីព្រះគ្រិស្ត . តែគ្រែចនជាអ្នកមិនប្រព្រឹត្តតាមបទបញ្ញត្តិព្រះគ្រិស្តទេ ។ ចំណែកខាងព្រះពុទ្ធសាសនាជួនកាលត្រូវប្រែប្រួលខ្លះបទបញ្ញត្តិជាច្រើនកន្លែងដែរ, តែគេអាចដោះស្រាយខ្លះបញ្ហានេះ ដែលមានសភាពជ្រាយឆ្ងាយទូលាយ ជាអនេកប្បការមិនចេះចប់មិនចេះជាប់ស្រេច ។

ការពិនិត្យដើមឈើដោយយកផ្លែជាប្រមាណ ប្រហែលជាបញ្ហាមួយអាចនាំមនុស្សឲ្យដោះស្រាយបានដោយងាយ ។ តើនៅបច្ចុប្បន្នបុរេ, ព្រះគ្រិស្តសាសនាដែលផ្សាយបានម្ភៃសតវត្សរ៍មកហើយ ឃើញបានផលយ៉ាងណាទៅវា ចំពោះលោកតេ, ពិតមែនតែមានសន្តបុគ្គលជាច្រើន, តែនៅតែភ្លេចជួនវិញ្ញាណរបស់ខ្លួនចំពោះប្រជាជាតិប្រកបដោយពលភាព, ពេញចិត្តខាងសង្គ្រាម មិនសូវមានចិត្តសន្តោសមេត្តា, មានតែសេចក្តីប្រាថ្នាប្រយោជន៍ផ្ទាល់ខ្លួន, ចំពោះសង្គមមានតែអយុត្តិធម៌ ដែលមានប្រាជ្ញារលុបរលាយដោយគ្រឿងចក្រសង្កត់សង្កិនជាខ្លាំង ដែលមានគេនិយមតែកោតខ្លាចន៏ឥទ្ធិពលគ្រែ, អត្តទត្ថភាពចំពោះបុគ្គលនីមួយៗប្រជាជាតិទាំងនេះ នាំឲ្យកើតសង្គ្រាមកាន់តែញឹកញាយ, កាន់តែកាចសាហាវ ដែលមនុស្សប្រញ៉ាញ់ខ្លួនសភាវគតិដ៏ថោកទាបបំផុត; ដែលវិទ្យាសាស្ត្រគ្មានតែជាជំនួយកងកិច្ចធ្វើការណកម្ម ។

(មានត)

ពន្លឺអាស៊ីទ្វីប

វគ្គទី ៣

La Lumière de l'Asie

លោកស៊ែរ-អេតវីង អារណ្ឌលត៍ តែង
លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

ព្រះនាងយសោធរាទ្រង់ចាត់អស្សគោវិទ (Cavaliers) ៤នាក់ ឲ្យ
ទៅក្រាបទូលព្រះសម្ពុទ្ធៈ "អញ, មាតាភពុល, មានបំណងជាខ្លាំង ចង់
ឃើញព្រះកត្តព្រះអង្គ ប្រៀបដូចហទយវត្ថុដែលគោរពថ្នាំងឡើង ដោយ
យល់តាមថ្ងៃរំពឹងពីក្រោយព្រះចន្ទដូចជាផ្កាអសោក (Asoka) ក្រពុំ រង់ចាំ
នៅដើងនារី,(1) បើព្រះស្វាមីអញ ទ្រង់រកកំណប់ទ្រព្យដែលចាត់ទៅ
ហើយ ឃើញបានមកវិញ នោះអញនឹងសូមកំណប់ទ្រព្យនោះឲ្យរាហុល
កុមារ, សម្រាប់ខ្លួនអញ។ នឹងតាមការនូវព្រះអង្គលោកឲ្យបានជាស្វាមី
វិញ" ។ ពួកព្រះរាជវង្សសាក្យៈ បាននាំគ្នាទៅតាមព្រះរាជបញ្ជាដោយ
រួសរាន់ ទៅដល់វេឡុវនុយ្យាន (ឧទ្យានបុស្បី) នៅពេលមួយដែល

---

១ ក្នុងរឿងរាមាយណៈថ្លែងថា នាងសីតាបានរត់ទៅពួននៅក្រោមគុម្ពោតដើម អសោក
ក្នុងពេលដែលក្រុងរាពណ៍ទៅកំហែងចាប់ចង់នាង, តែនាងបានតស៊ូនឹងរាពណ៍ទាល់តែមាន
ដោតដំយក្នុងពេលនោះ, ហេតុនេះពួកស្រីហិណ្ឌូ ទើបគោរពដើមអសោកនេះណាស់ ។

ព្រះសម្មាសម្ពុទ្ធកំពុងសំដែងធម៌ទេសនា ។ ព្រះពាជវង្សទាំងនោះ កំពុងស្តាប់ព្រះធម៌ទេសនាដ៏ពីរោះនោះហើយ ក៏ភ្លេចនឹកដល់ព្រះពាជបណ្តាំ (សារលិខិត) នៃព្រះមហាកប្បត្រិយ៍ទ្រង់ព្រះនាងដែលកំពុងព្រួយចារម្ត ជាខ្លាំង ។ ពួកសាក្យៈទ្រង់ឮតែព្រះសូរសៀងដ៏ពីរោះអស្ចារ្យរបស់ព្រះបរមគ្រូ, ព្រះហ្ឫទ័យនៃទ្រង់ទាំងនោះស្ងប់ចុះ ដោយបានក្រែបន្ទូរសេចក្តីព្រះធម៌ដ៏ហូរចេញអំពីព្រះពុទ្ធនុស្ស សង្ឃប្រកបដោយព្រះគុណាទិគុណ នឹងឫទ្ធានុភាព សុក្កិតភាព បរិសុទ្ធស្អាត, អ្នកស្តាប់ទាំងនោះអាចជ្រួតជ្រាបនូវធម៌គ្រប់យ៉ាង ។

ចូរអ្នកឃើញ! ប្រៀបដូចកមពាជញ្ជក់ទឹកផ្អែមក្នុងសំបុកដែលមានរសជាតិផ្អែមឆ្ងាញ់ ភ្លេចគិតនឹកដល់អ្វីៗទាំងអស់ ទោះបីជាយប់យន់អន្ទការយ៉ាងណា ឬក៏មានភ្លៀងផ្គរយ៉ាងណាក៏ដោយ ពួកកមពាអំបាលនោះ ក៏ទំនៃតែជញ្ជក់យករសជាតិមធុរស ដែលកើតព័ន្ធុជាតិទាំងឡាយប៉ុណ្ណោះ ដូចម្តេចមិញ? ពួកអាមាត្យ[២] ដែលព្រះមហាកប្បត្រិយ៍ត្រាស់ប្រើឲ្យទៅនិមន្តព្រះសម្មាសម្ពុទ្ធពេលនោះ បានផ្ទៀងសោតប្រសាទស្តាប់ព្រះសទ្ធម្មទេសនារបស់ព្រះអង្គដែលពីរោះចាប់ចិត្តជាបំផុត ក៏នាំឲ្យភ្លាំងភ្លេចព្រះពាជបញ្ជាការអស់ ហើយក៏នៅក្នុងសំណាក់ព្រះអង្គ មិនបានត្រឡប់នាំសេចក្តីទៅក្រាបទូលព្រះមហាកប្បត្រិយ៍វិញ ក៏ដូច្នោះឯង ។

លំដាប់ពីនោះ ព្រះមហាកប្បត្រិយ៍បានត្រាស់បង្គាប់ឲ្យទាយីដែលជាមន្ត្រីធំក្នុងព្រះបរមពាជវាំង ហើយជាសំណប់របស់ព្រះអង្គ ទាំងជា

កល្យាណមិត្តរបស់ព្រះសិទ្ធត្ថកុងកាលនៅជាកុមារផង ឲ្យទៅនិមន្ត ។ ទុតាយីកាលចូលទៅកុងទុព្យានោះ ឃានបេះយកសំឡីកប្បាសមកចុកត្រចៀកខ្លួន ដើម្បីកុំឲ្យឮព្រះសទ្ធម្មទេសនារបស់ព្រះបរមគ្រូ ក្រែងនឹងខូចករណីយកិច្ចដូចពួកខ្លួនមុន ។ គ្រានោះទុតាយីឃានគ្រាបទូលតាមព្រះពាជសាររបស់ព្រះពាជបិតា នឹងព្រះនាងយសោធរា ។

ព្រះសម្មាសម្ពុទ្ធទ្រង់ឧទ្ទិសព្រះសិរី ហើយមានព្រះបន្ទូលទៅកាន់ទីប្រជុំថា "យើងនឹងទៅកុងពេលឆាប់ៗនេះ នេះគឺជាករណីយកិច្ចរបស់យើងផង ជាធម្មៈរបស់យើងផង; នរណាក៏ដោយមិនត្រូវក្លេចគោរពបុព្វបុរសដែលឲ្យកំណើតដល់ខ្លួន ដែលជាមធ្យោបាយសម្រាប់ពិចារណាចៀសឃាងពីការរស់នៅក្នុងលោក ហើយនឹងរកផ្លូវឃ្លាជាដែលឲ្យផុតពីសេចក្តីស្លាប់ ដើម្បីឆ្ពោះទៅកាន់ព្រះនិព្វាន, បើគេប្រតិបត្តិតឹមត្រូវតាមច្បាប់ បើគេហ៊ោះបង់ចោលនូវឃាបធម៌ពីអតីតជាតិ លែងប្រព្រឹត្តអំពើអកុសលក្នុងបច្ចុប្បន្នជាតិជាថ្មីថែមទៀត អាចទៅកាន់ព្រហ្មចរិយៈ ហើយនឹងសេចក្តីអាណិតអាសូរដល់សត្វសត្វ ដែលជាដែនខៃនធម៌ព្រហ្មវិហារនោះ ។ ចូរអ្នកទៅគ្រាបទូលព្រះពាជបិតា នឹងព្រះនាងយសោធរាវិញថា: យើងនឹងត្រឡប់ណើរទៅជួបព្រះពាជបិតា នឹងព្រះនាងជាមិនខាន! ។

កាលដំណឹងនេះជ្រួតជ្រាប់ទៅដល់ក្រុងកបិលពស្តុហើយ ប្រជាជនទៅក្នុងកំឡុងក្រុងកបិលពស្តុ ទឹងអ្នកទៅជិតខាងជុំវិញក្រុង ឃានប្រុង

ច្រៀបរៀបចំ ចាំទទួលព្រះរាជទេវៈយ៉ាងរុងរឿង ។ ខៅក្នុងព្រះវាង តូច គេបានសង់សាលាមួយ ប្រដាប់ដោយផ្កាកម្រង និងសំពត់ពណ៌ខៀវ ចាក់ដោយខ្ទិនមាស; គេបានយកនូវមែកត្រអូប នៃរុក្ខជាតិ "និម" (nim) និងមែកស្វាយដេរដាសពាសពេញផ្លូវ ហើយគេបានយកមុសស៊ីក្ខ (ចូរស្រែកតពៃញី) ដែលគេញៀវដោយទឹកអប់កំញាន និងផ្កាម្ទិះស្រោចស្រប់ សព្វវិធីព្រះរាជធានី ព្រមទាំងប្រដាប់ដោតដន់គ្រប់ទីកន្លែង ។

(មានត)

ចូរជួយខ្លួនអ្នក ទើបនេត្តាជួយអ្នក

ជួយខ្លួនឯង ដោយប្រឹងប្រែង រៀនវិជ្ជា
ប្រឹងធម្មា សុបរិត ផ្តិតនិស្ស័យ
ឲ្យក្តៅឈ្នោះ លាន់ពីរោះ ជាមនុស្សប្លែ
អ្នកកំភ័យ! គង់មានប្លែ ទេព្តាជួយ ។

សុភាសិត សង្ខិតថា "ខ្លួនពឹងខ្លួន
ពឹងគឺសួន ទំរកវៀន ប្រៀនខ្លួនមួយ
ឲ្យបានបទ ជាក់ប្រាកដ អ្នកកុំព្រួយ!
ទេព្តាជួយ ឲ្យជោគជ័យ ប្លែអន់គ្មា ។

យូរ - អ៊ុន

ធម្មទេសនា

ព្រះអរិយកស្សប កែវ-អ៊ូប វត្តបទុមវតី ភ្នំពេញ

ទេសនាជាវិទ្យុនៅថ្ងៃ ៨ កើតខែមិគសិរ ឆ្នាំកុរនព្ញស័ក ព. ស. ២៤៩០

ត្រូវនឹងថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៤៧

ឆ សិយា លោកវិឌ្ឍនោ

"បុគ្គលមិនគប្បីធ្វើខ្លួន ឲ្យជាមនុស្សបង្អៀតលោកទេ" ។

ពេលនេះ អាត្មាភាពត្រូវនេសំដែងធម្មទេសនាចែកជូនអស់លោកអ្នកស្តាប់តាមវិស្យុកម្ពុជា ។ អាត្មាភាពនឹងសំដែងទិដ្ឋធម្មិកធម៌ គឺធម៌ជាគ្រឿងនាំមកនូវផលប្រយោជន៍ដល់លោកក្នុងបច្ចុប្បន្នជាតិនេះ នឹងជាតិមុខ ដូចព្រះបាលីដែលមានមកក្នុងគម្ពីរខុទ្ទកនិកាយថា ឆ សិយា លោកវិឌ្ឍនោ អធិប្បាយសេចក្តីថា មនុស្សយើងដែលកើតមកក្នុងលោកនេះ មិនត្រូវធ្វើខ្លួនឲ្យជាមនុស្សបង្អៀតលោកទេ ត្រូវធ្វើខ្លួនឲ្យជាមនុស្សសាងលោកឲ្យចំរើន ត្រូវមានទាំសម្រាប់មនុស្សជាតិ សម្រាប់ប្រព្រឹត្តបដិបត្តិតាម គឺថាបើជាឃរាវាស ត្រូវនាំគ្នាប្រព្រឹត្តតាមកូមិយភាវាស ៣ យ៉ាង ។ ឯកូមិយភាវាស ៣ យ៉ាងនោះ គឺ :

១ – បើជាអ្នកធ្វើស្រែចំការ ត្រូវតាំងចិត្តជាអ្នកឧស្សាហ៍ព្យាយាមខំតែធ្វើការជានិច្ចកាល កុំគប្បីធ្វេសប្រហែសដោយសេចក្តីខ្ជិលច្រអូសនឹងសេចក្តីធុញទ្រាន់ឡើយ ព្រោះតាមទម្លាប់ខ្មែរជនយើង ច្រើនធ្វើការ

រកស៊ីគ្រាន់តែឲ្យល្មមមាត់ គ្រប់គ្រាន់ក្នុងគ្រួសារប៉ុណ្ណោះ មិនធ្វើឲ្យជាប្រយោជន៍ហូរហៀរដាសម្បត្តិនគរផង ហេតុដូច្នេះ ឋានជាខ្វះច្រើនខ្លួតខ្លាយជាងគេ នគរយើងទៀតក៏ទន់ខាបជាងគេដែរ, ទាហរណ៍ក្នុង ១ថ្ងៃៗ ត្រូវតែយើងចំណេីការឲ្យបានច្រើនម៉ាន ហើយយើងត្រូវនៅទំនេរនោះក៏ឲ្យតិចម៉ាន់ចុះមកដែរ ត្រូវឲ្យលៃយ៉ាងដូច្នេះពីឥឡូវនេះស្មើដរាបទៅ ទើបជាតិយើងនឹងដំណេីរទៅកាន់សេចក្តីចំរេីនបាន ។

២ – បើជាអ្នកធ្វើការពេជការ ត្រូវប្រតិបត្តតាមម៉ាងតាមពេលតាមនាទីដែលច្បាប់កំណត់ ; បើចូលដល់កន្លែងធ្វើការគាល់ណាហើយ គួរគោរពគោតខ្លាចច្បាប់ ត្រូវយកចិត្តទុកដាក់ក្នុងកិច្ចការរបស់ខ្លួន កុំបណ្តែតបណ្តោយបង្អង់ទុកឲ្យយឺតយូរទៅថ្ងៃក្រោយ ។

៣ – បើជាកុមារអ្នកសិក្សារៀនសូត្រ ត្រូវខំយកចិត្តទុកដាក់ក្នុងការរៀនឲ្យទាន់ពេលទាន់វេលា ត្រូវប្រតិបត្តិតាមច្បាប់គ្រូដែលដាក់តំរិតឲ្យ ទើបដំណេីរទៅរកសេចក្តីចំរេីនបាន ។

បើជាកូមិរបស់បព្វជិតវិញ ក៏ត្រូវមាននាទីដូចគ្នា គឺ បើចូលបួសជាកិក្ខុសាមណេរ ត្រូវខំសិក្សាសូត្រវៀនស្ទាត្បាយន៍ ធ្វើកិច្ចវត្ត ជ្រោសច្រាស តាមនាទីដែលលោកបង្គាប់ ។ បើជាចៅអធិការវិញ ក៏ត្រូវដឹងលក្ខណៈគ្រប់យ៉ាង គឺ ឲ្យស្គាល់សាវតារវត្ត ព្រំប្រទល់នៃផែនទីវត្ត ទឹងទំសម្រាប់វត្ត ឲ្យដឹងកិក្ខុសាមណេរក្នុងវត្ត មានសេចក្តីទុក្ខសុខដូចម្តេច

ខ្លះ ហើយទំយកចិត្តទុកដាក់ថែទាំបោសច្រាសព្រះវិហារកុដិសាលាៗណា ដែលបាក់បែក ត្រូវជួសជុលឡើងជាថ្មី ។ ត្រូវជាស់តឿនកិក្ខុសាមណេរក្នុងវត្ត ឲ្យទំស្វាធ្យាយន៍សូត្រវៀន គន្ថធុរៈ វិបស្សនាធុរៈ ទំធ្វើព្រះវិន័យ ទំធ្វើឲ្យទំថែទាំទីលំនៅ បោសច្រាសក្នុងព្រះវិហារ កុដិ តាមកិច្ចដែលត្រូវធ្វើឲ្យស្អាតបាតល្អ ។ នេះហើយជានាទីរបស់មនុស្ស ដែលត្រូវធ្វើឲ្យចំរើនលោកចំពេញលោកឲ្យបានដំណើរដឿនទៅមុខ ឲ្យទាន់ពេលទាន់សម័យ ។

ម្យ៉ាងទៀត បើប្រសិនណាជាអ្នកធ្វើស្រែ ចំការ តែមានសេចក្តីខ្ជិលច្រអូស ហើយមិនរវល់នឹងការងារដែលខ្លួនធ្វើ ដូចធ្វើស្រែគ្មានភ្លឺ ទឹកហូរអស់រលីង នាំដីជាតិក្នុងស្រែចេញទៅ តើស្រែវាធ្វើម្តេចនឹងបានចំរើន; ការដែលខ្ជិលច្រអូសឡៃឡុមិនប្រព្រឹត្តការងារឲ្យហ្មត់ចត់ កុងរបរកសិរបស់ខ្លួនសោះ ដូចដីស្រុកយើងនឹងជាជាតិអ្វីទៅក៏សុទ្ធតែដុះបានផលតិចច្រើនពុំខាន តែមកពីមានសេចក្តីខ្ជិលមិនធ្វើ បើធ្វើបានផលបន្តិចបន្តួចហើយឈប់ចង្អុរ, មានការដើរលេងអបាយមុខ ត្រឡប់មកផ្ទះវិញដេកផ្ងុំក្ងុយ អង្គុយសំឡឹងជង្រុកស្រែរំពាច់នឹងកាយរាល់ ដូរចំណីកងអំរែកចិន ដាច់ប់លុះអស់រលោណាក៏ដើរសូមទានគេ ដេកអង្គុយតាមផ្លូវថ្ល់ទូរមេឃ ស្រែកអាកាស មើលទៅគួរឲ្យខ្មាសដល់ជាតិជនៃជាទីបំផុត ។

ចំណែកអ្នករាជការគួរគិតថា បើយើងមិនខំប្រឹងធ្វើការឲ្យទាន់ពេលវេលា ក្នុង ១ ថ្ងៃឲ្យខ្លះ ១ ម៉ោងជាដរាប បើ ១០០ នាក់ ១ ថ្ងៃបាត ១០០

មោ៉ង តើខាតថ្លាក់ប៉ុន្មានទៅ ដែលទេគ្មានធ្វើការ?, ម្ល៉ោះហើយការ ដែលសល់ទៅចេះតែច្រើនឡើង ។

កុមារអ្នកសិក្សាសូត្រវៀន បើចៅឯងមិនខំប្រឹងស្វាធ្យាយន៍ទេញ តាមរបៀបគ្រូជាក់ឲ្យទេ គ្រាន់តែទៅអង្គុយកងសាលា, ចេញពីសាលាមក ដើរលេងអបាយមុខ ហើយទន្ទឹងចាំមើលតែថ្ងៃអាទិត្យនឹងថ្ងៃព្រហស្បតិ៍ ដូច្នេះតើដំរេះវិជ្ជានឹងកើតដូចម្តេចបាន? ឧចៅអើយ! ស្រុកយើងនឹងចំរើនឡើងបានមកពីដំរេះវិជ្ជា ដែលអ្នកឧស្សាហ៍រៀនសូត្រនេះឯង, ប៉ុន្តែចៅមិនខំប្រឹងហើយ ចៅឲ្យអ្នកណាខំប្រឹងជួស, ឧចៅ! លោកតាមានសេចក្តីសង្ឃឹមលើចៅឯងណាស់ ដូចសុភាសិតបុរាណថា "ឧចៅកំព្រា ពន្លកស្នងត្នោ សំឡាញ់ឪពុក បណ្តុះសាច់ត្រួយ តែមួយជាមុខ ផលក្តើគាលស្រុក ស្រែក្តីសាច់ដៅ" ។ ពាក្យនេះ ចូរចៅគិតមើលឲ្យវែងឆ្ងាយទៅចុះ ។ ចំណែកបព្វជិត បើមិនប្រតិបត្តិតាមកិច្ចដែលត្រូវប្រតិបត្តិទេតើដែលបួសមកនឹងមានប្រយោជន៍អ្វី? មនុស្សយើងត្រូវមានមុខនាទីកាន់កាប់ គឺជាបព្វជិត ត្រូវរក្សាព្រះពុទ្ធសាសនាឲ្យបានប្រុងប្រយ័ត្នរឹងឡើងទៅ, បើជាគ្រហស្ថ ត្រូវធ្វើការងារឲ្យចំរើនផែនដី ដើម្បីនឹងជួយទំនុកបំរុងជាតិ សាសនា មហាក្សត្រ ។ នេះជានាទីរបស់មនុស្សដែលមិនចង្អៀតលោក ។ មានមនុស្ស ១ ចំពូកទៀត គ្មាននាទីធ្វើអ្វីទេ ទៅអាស្រ័យនឹងអ្នកដទៃខ្លះ ទៅអាស្រ័យក្នុងវត្តលោកសង្ឃខ្លះ តែគ្មាន

របរកស៊ី ។ បើប្រែសិនជានៅវត្ត តែមានបេរកការងារ ពោះធ្វើការ
ពាជការក្តី ធ្វើជំនួញក្តី នៅបណ្តោះអាសន្នទម្រាំនឹងរកផ្ទះបាន នេះក៏មិន
ជាការអ្វីទេ ។ តែមនុស្សដែលចំនេះគ្មានការធ្វើសោះ ខ្លះអួតអាងថា
ខ្លួនចាស់ឈប់រកស៊ី អាស្រ័យនៅវត្តរក្សាសីល ខ្លះថាមិនទាន់ដល់ពេល
វេលានឹងរកស៊ី ។ មនុស្សចំពូកនេះអង្គុយសំឡឹង ចាំអាស្រ័យដោយ
សារលោកសង្ឃ មានច្រើនសឹងតែគ្រប់វត្ត គ្រប់កន្លែង ហេតុនេះគួរ
ជាតិខ្មៅរយើងលះគំនិតថោកទាបនេះចោលចេញ ទើបស្រួកមិនសាប
សូន្យ ។ សេចក្តីដូចសំដែងមកខាងលើនេះ សូមឲ្យយុវជនយុវតីរួម
ជាតិទាំងឡាយចំដុសខាត់កំចាត់ចេញ នូវសេចក្តីខ្ជិលច្រអូសទាំងប៉ុន្មាន
ឲ្យភ្លាត់ឆ្ងាយពីសន្តានចិត្តឲ្យអស់ ហើយខំតាំងខ្លួនរៀបខ្លួនច្របាច់ការងារ
តាមថ្នាក់តាមជាន់ឲ្យទាន់សម័យឡើង ដើម្បីនឹងបានជាកម្លាំងជួយសួយ
ជាតិសាសនានឹងមហាក្សត្រៃរបស់យើងឲ្យរុងរឿងតទៅ ។

ទុក្ខប្បត្តា ច ធិទុក្ខា ភយប្បត្តា ច ធិព្ភយា
សោកប្បត្តា ច ធិសោកា ហោន្តុ សព្វេបិ បាណិនោ

សត្វសត្វទាំងឡាយ ដែលដល់នូវសេចក្តីទុក្ខ សូមឲ្យជាអ្នកបាត់
ទុក្ខទៅ ! ដែលដល់នូវភ័យ សូមឲ្យជាអ្នកបាត់ភ័យទៅ ! ដែលដល់នូវ
សោក ក៏សូមឲ្យជាអ្នកបាត់សោកទៅ ! ។

ដោយតេជៈព្រះរតនត្រ័យ សូមឲ្យប្រជាជនចាំងឡាយ ដល់នូវការ
លុតលាស់ចំរើនធឹងសន្តិភាពកុំបីឲ្យឃ្លាត ក្លាយទៅជាប្រការអ្វីឡើយ ។

ខាងចុងបំផុតធម៌ទេសនានេះ យើងសូមប្រកាសដល់ទេវតាចាំង-
ឡាយថា: កន្លងនេះ ជានាទីរបស់ធម្មទេវបុត្តជាអ្នករក្សាលោកឲ្យបាន
សេចក្តីសុខ សេចក្តីចំរើន ហេតុនេះ យើងសូមរំលឹកដល់ធម្មទេវបុត្ត
ម្តងទៀត តាំងអំពីពេលត្រឹកស្អែកនេះទៅសូមឲ្យរាំងតាំងស្មារតីកុំឲ្យ
ធ្លេសប្រហែស ១ មីនុតសោះ ចូរទំរក្សាលោកយើងនេះឲ្យបានចំរើន
បានសេចក្តីសប្បាយ, បើមានបច្ចាមិត្តមកអំពីទីណាក្តី ចូរកើតឡើងក្នុង
មណ្ឌលក្រុងកម្ពុជានេះក្តី ក៏សូមទេវតាជួយកំចាត់បំបាត់ចិត្តអាក្រក់ល្អក់
កកររបស់បច្ចាមិត្តចាំងឡាយនោះ ឲ្យក្លាយទៅជាមិត្តភាពវិញ ហើយ
សូមជួយទំនុកបំរុងជាតិសាសនាធឹងព្រះមហាក្សត្រ ឲ្យបានថ្កុំថ្កើងរុងរឿង
តទៅខាងមុខ ។

អាត្មាភាពសំដែងមកក្នុង ទិដ្ឋធម្មិកធម៌ គឺធម៌ជាគ្រឿងនាំមកនូវ
ប្រយោជន៍ដល់លោក ក៏ល្មមសមគួរដោយពេលវេលាគ្រានេះឯង ឯវំ ។

ចប់

ប្រស្នាពិធីបុណ្យខ្មោច

ឃុនបណ្ណាគុរ៉ក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ

ស្រង់អំពីក្បួនចាស់បុរាណមករៀបរៀង

---

១ – ស. ការណ៍ដែលគេយកច្រាក់ដាក់ក្នុងមាត់ខ្មោច ដើម្បីប្រយោជន៍អ្វី?

១ – ឆ. មានរឿងគេដំណាលតៗគ្នាមកអំពីបុរាណថា មានបុរសប្តីប្រពន្ធ (ពីរនាក់) នៅជាមួយគ្នាតាំងពីក្មេងដល់ចាស់ មានមាសជាប់នឹងខ្លួនប្រមាណ ១ ជាង ។ ប្តីផ្តាំប្រពន្ធៗ ផ្តាំប្តីថា: បើអ្នកណាស្លាប់មុន ចូរយកមាសនេះដាក់មាត់ ។ ចំណែរតមកមិនយូរប៉ុន្មាន ប្តីស្លាប់មុនទៅ ប្រពន្ធក៏យកមាសនោះដាក់មាត់ប្តីហើយយកខ្មោចប្តីទៅដុត ក្លឹងឆេះមាសនោះខាតអស់នៅសល់តែត្រឹម ៣ ស្លឹង ។ សម័យមួយព្រះមហាក្សត្រមានលោភចិត្តគ្រប់សង្កត់ឲ្យរៃយកមាសក្នុងមួយផ្ទះ ១ ជាង ។ យាយជាប្រពន្ធរបស់ខ្មោចតានោះ ទៅរើសយកមាសដែលបង់មាត់ប្តីក្នុងគំនរផ្សែងនោះបានតែ ៣ ស្លឹង យកទៅថ្វាយព្រះមហាក្សត្រ ហើយក្រាបទូលថា "ពីដើមមាសនេះពេញ ១ ជាង ខ្ញុំបង់មាត់ឲ្យប្តី។ យកទៅមិនបាន, ក្លឹងឆេះអស់ខ្លះទៅនៅសល់តែប៉ុណ្ណេះ សូមព្រះអង្គជាទីពឹងខ្ញុំព្រះមេត្តាដល់សត្វគាល់ក្រចុះ" ។ ព្រះមហាក្សត្រទ្រង់ព្រះសណ្តាប់ក៏កើតធម្មសង្វេគស្តុតព្រះទ័យ ទើបទ្រង់ប្រកាសលើកលែងមិនឲ្យរៃយកមាសអំពីបណ្តាពស្ត្រ ។

អាស្រ័យហេតុនេះ អ្នកចាស់ពីបុរាណ ទើបយកមាសឬប្រាក់ដាក់ក្នុងមាត់ខ្មោចដើម្បីឲ្យពិចារណា ។ តែបើស្មានេះត្រូវពិចារណាថា សម្បត្តិទាំងអស់ យើងយកជាប់នឹងខ្លួនទៅបានខ្លះ តែកាលណៅនៅមានជីវិត, កាលបើស្លាប់ហើយ យកទៅមិនបានទេ; សូម្បីនៅរស់ក៏លំបាកនឹងយកសម្បត្តិទាំងអស់នោះ ជាប់ទៅជាមួយខ្លួនដែរ ព្រោះជួនកាលបណ្តាលឲ្យកើតអន្តរាយដោយសត្រូវលួចប្លន់ ឆក់ជាដើម យកទៅក៏មាន, ចំណង់បើមនុស្សស្លាប់ហើយ ធ្វើម៉េចនឹងយកទៅបាន លោកប្រាប់ថាជាអនិច្ច ជារបស់មិនទៀងទាត់ស្ថិតស្ថេរ ជាសម្បត្តិសាធារណៈ ឥតអ្នកណាជាម្ចាស់ឡើយ ។ យកប្រាក់ឬមាសបង់មាត់ខ្មោចសម្រាប់ឲ្យពិចារណានោះ ក៏មានជាប់រហូតមកដល់សព្វថ្ងៃនេះ ។

២– ស. ដែលគេយកផ្កានឹងទៀនធូបជាក់ក្នុងដៃខ្មោចនោះតើប្រាប្តាអ្វី?

២– ឆ. កាលពីមុន មានតិក្ខុមួយរូបមិនប្រាកដឈ្មោះ ។ ញោមប្រុសរបស់លោកធ្វើជាព្រានព្រៃ សម្លាប់សត្វច្រើនណាស់តាំងពីក្មេងដល់ចាស់ លុះវេលាជិតស្លាប់ក៏ភ្ញឹកស្មានតើទៅឃើញតែសត្វផ្សេងៗដែលខ្លួនធ្លាប់សម្លាប់ដោយអកុសលចិត្ត ទើបស្រែកប្រាប់ឲ្យលោកកូនជួយ ។ តិក្ខុជាកូនដឹងថាញោមកម្មច្រើន ប្រាកដជាភ្ញឹកទៅឃើញតែសត្វដូច្នោះ ទើបចាត់មនុស្សឲ្យរកផ្កាទៀនធូបជាក់ក្នុងដៃញោមប្រុសរួចប្រាប់

ថា "ញោមចូរសំឡឹងមើលផ្កាខៀនធូបនេះជាគ្រឿងបូជាព្រះរតនត្រ័យ" ។ ញោមប្រុសនៃកិកុនោះកើតសទ្ធាជ្រះថ្លាមានចិត្តជាកុសល បានធ្វើតាមពាក្យកូន លុះដល់ស្លាប់ហើយបានទៅកើតនៅនាស្ថានសួគ៌ ។ ព្រោះហេតុនេះ បានជាមនុស្សជាន់ក្រោយធ្វើតាមគ្នាមក ដោយជ្រាថ្នាំនឹងឲ្យអ្នកជម្ងឺដឹតស្លាប់សំពះបូជាគុណព្រះរតនត្រ័យយកជាទីពឹង ។ មានអ្នកស្រុកខ្លះនិយាយថា: ដើម្បីឲ្យមនុស្សឈឺដឹតស្លាប់បូជាព្រះចូឡាមណីចេតិយដែលនៅក្នុងស្ថានតាវត្តឹង្ស ។ សូម្បីថាយ៉ាងនេះក៏ពាក់ព័ន្ធក្នុងកិច្ចបូជាព្រះរតនត្រ័យដែរ ។ រឿងនេះបានជាប់ជាទំនៀមរហូតមកដល់សព្វថ្ងៃនេះ ។

៣ — ស. គេថាញាតិនាប ៣ ចំរៀកវាយក្អមទឹក ៣ នោះ តើព្រោះហេតុអ្វី?

៣ — ឆ. រឿងនេះ អ្នកជ្រាជ្រពីបុរាណបានធ្វើឲ្យជាប្រស្នាដល់ឲ្យមនុស្សជាន់ក្រោយគិតពិចារណា ។ គឺនាប ៣ ចំរៀកនោះ បានដល់ជាតិការកើតអាស្រ័យដោយកត ៣ គឺកាមកត ១ រូបកត ១ អរូបកត ១ ។ ឯក្អមទឹក ៣ នោះ បានដល់វ័យទាំង ៣ គឺបឋមវ័យ ១ មជ្ឈិមវ័យ ១ បច្ឆិមវ័យ ១ ។ សត្វដែលកើតក្នុងកត ៣ ត្រូវតែបែកធ្លាយស្លាប់ទៅក្នុងវ័យទាំង ៣ វ័យណាមួយជាមិនខាន មិនបានរស់នៅរហូតទៅទេ ។ ប៉ុន្តែរឿងនេះ មិនសូវមានគេធ្វើទេ ឃើញធ្វើតែវេលាសែងខ្មោច

ចេញពីផ្ទះទៅ គឺគេចោះក្អមទឹក ១ ទៅដើម្បីបែក ទឹងថ្ម ១ ដុំផង ។ សូម្បីធ្វើយ៉ាងនេះ ក៏ត្រូវតាមទំយាងលើនេះដែរ បានជាជាប់មានប្រពៃណីនេះតមក ។

៤ – ស. គេហាមមិនឲ្យសែងខ្នោចក្រោមធ្នឹមផ្ទះនោះតើ ព្រោះហេតុអ្វី?

៤ – ឆ. ព្រោះផ្ទះគេទាប ក្រែងអ្នកសែងខ្នោចទៅនោះទង្គិចក្បាលនឹងធ្នឹមផ្ទះគេ បានជាគេហាម ។

៥ – ស. គេហាមមិនឲ្យសែងខ្នោច ឬដឹកខ្នោចកាត់ស្រែចំការគេនោះតើ ព្រោះហេតុអ្វី?

៥ – ឆ. ព្រោះហេតុម្ចាស់ស្រែចំការនោះខ្វាចក្រែងអ្នកសែងខ្នោចដើរទៅជាន់ស្រូវឬដំណាំរបស់គេ បានជាគេហាមដូច្នោះ ។

៦ – ស. គេសែងខ្នោចប្រទក្សិណដើមថ្កូរ ៣ ដុំនោះ តើដើម្បីប្រយោជន៍អ្វី?

៦ – ឆ. អ្នកចាស់ពីបុរាណធ្វើឲ្យយើញជាប្រស្នាថា: បុថុជ្ជនគឺបុគ្គលដែលគ្រាស់ទៅដោយកិលេស រមែងកើតចាស់ឈឺស្លាប់វិលវល់នៅក្នុងវដ្តសង្សារ មិនរួចពីវដ្តសង្សារទៅបានឡើយ ។ ហេតុនោះបានជាលោកឲ្យប្រទក្សិណដើមថ្កូរ ដើម្បីឲ្យយល់យ៉ាងនេះ ។

៧ – ស. គេយកផ្លាកូនចូបទៀនទៅជាក់ឲ្យខ្នោចក្នុងពេលរៀបនឹងដុតនោះតើ ដោយហេតុដូចម្តេច?

៧ – ឆ. តាមប្រវត្តិពីបុរាណរបស់យើងប្រកាន់ថាជាការបុណ្យកុសលយ៉ាងច្រើន ។ លុះតមកដល់សម័យនេះសេចក្តីគាំងចិត្តដូច្នោះក៏ថយតិចទៅ រៀលទៅដុតខ្មោចយកផ្តាក្តីខ្លែងធ្លាប់ទៅសូមខមាទោសនឹងខ្មោចក្រែងខ្លួនបានប្រមាថមើលងាយប្តូចំអកចំអន់លេងសើចដោយសំដី ។ មួយទៀត អ្នកខ្លះគេតាក់តែងផ្តាជាក្បាច់រចនាផ្សេងៗ អស់ច្រើនដើម្បីឲ្យកើតកិត្តិយសដល់ខ្មោចនោះផង ដើម្បីតបគុណខ្មោចនោះផង គំនិតនេះចាត់ជាការបុណ្យកុសលបានដូចគ្នា ។

៨ – ស. គេសូមខមាទោសនឹងខ្មោចបានដែរឬអ្វី?

៨ – ឆ. បានក៏មាន មិនបានក៏មាន ។ ទោសស្រាលៗ ដូចយ៉ាងតប់ខ្មេះគ្នាលេងនឹងដៃ ឬក៏និយាយចំអកចំអន់គ្នាលេងនឹងមាត់ ដូច្នេះសូមខមាទោសបាន ។ ទោសធ្ងន់ៗ ដូចយ៉ាងកាប់សម្លាប់គេ លួចរបស់ទ្រព្យគេ លួចកូនប្រពន្ធគេ និយាយកុហកឬញុះញង់គេ ដូច្នេះសូមខមាទោសមិនបានទេ គឺថាទោសនោះមិនបាត់ឡើយ ។

៩ – ស. កាលនឹងដុតខ្មោច ហេតុអ្វីបានជាគេហាមមិនឲ្យអ្នកភ្លើងតពីគ្នា?

៩ – ឆ. រឿងនេះមិនមែនជាប្រស្នាក្នុងផ្លូវធម៌ទេ ហេតុតែអ្នកមានភ្លើងមុន ខ្លាចគាន់ឈរចាំឲ្យអ្នកគ្រោយអុជបន្តទៅទៀត ជាំនជាគេហាមដូច្នោះ ។ មួយទៀត ចាស់បុរាណគិតគ្រែងថា កាលបើចេះ

តែអុដបន្តគ្នាច្រើនៗទៅ អ្នកកាន់ក្តៀងឲ្យគេអុដនោះគឺនឹងកំដៅក្តៀងមិនបាន មុខជាចុះក្តៀងចោលទៅត្រូវគេរលាកសាច់ឬក៏នេះសំគាត់អាហេតុនេះបានជាគេហាមមិនឲ្យអុដក្តៀងបន្តពីគ្នា ។

១០ - ស. កាលនឹងដុតខ្មោច ហេតុអ្វីក៏ជាក់ឲ្យដេកផ្តាប់មុខរួចបានដុត គេមិនដុតផ្ងារ?

១០ - ឆ. បើឆ្លើយតាមផ្លូវធម៌ថា: ធម្មតាមនុស្សយើងកើតមកដោយអវិជ្ជា ស្លាប់ទៅវិញក៏ដោយអវិជ្ជា គឺសេចក្តីល្ងង់ខ្លៅមិនដឹងតាមពិតមកគ្រប់សង្កត់សន្ធាន មិនដឹងប្រមាណដល់សង្ឃារដូចជាបុគ្គលដែលដេកផ្តាប់មិនដឹងខ្លួនថានឹងមានភ័យអន្តរាយមកពីទិសទាងណា បានជាគេដុតខ្មោចផ្តាប់ដូច្នោះ ដើម្បីឲ្យកើតសង្វេគក្នុងធម៌ ។ បើឆ្លើយតាមផ្លូវលោកវិញថា: គេដុតផ្ងារមិនកើតទេ ព្រោះដល់ក្តៀងនេះខ្មោចទៅសរសៃសួញខ្លឹងទាញខ្មោចឲ្យក្រៀកបះឆ្អឹង, បើឲ្យផ្តាប់មុខហើយយកទុសជាក់សង្កត់ពីលើខ្នងឲ្យធ្ងន់ទៅ សរសៃទាញមិនរួច ហេតុនេះបានជាគេដុតខ្មោចតែផ្តាប់មុខ ។

- ១១ - ស. ដែលគេយកវៀរថ្ងាសចងក ចងកដៃ ចងកដើងខ្មោចនោះ តើដើម្បីប្រយោជន៍អ្វី?

១១ - ឆ. ដើម្បីឲ្យឃើញជាប្រស្នាតាមផ្លូវធម៌ដូចមានថ្លាលីថា: ប៊ុត្តោ គឺវៃ "កូនជាអន្ទាក់ឆ្កាក់ក" ធនំ ថ្លាទេ "ទ្រព្យជាអន្ទាក់ឆ្កាក់

ដើង" កវិយោ ហោតេ "ប្រពន្ធជាអន្លាក់ធ្លាក់ដៃ" ។ បើអ្នកណាផុតពីអន្លាក់ទាំង ៣ នេះបាន អ្នកនោះទើបផុតចាកសង្សារវដ្ត ។ ន័យមួយទៀតថា គេចង់កុំឲ្យខ្មោចនោះលាដៃដើងច្រេងច្រាង ។

១២- ស. កាលគេដុតខ្មោចសុះអស់ហើយ មុននឹងរើសឆ្អឹងហេតុអ្វីក៏ចាំប្រមូលធ្វើងធ្វើជារូបមនុស្សប្រែចុះប្រែឡើង?

១២- ឆ. ដែលគេធ្វើដូច្នោះហៅថា "ប្រែរូប" ដើម្បីនឹងឲ្យពិចារណាកម្មដ្ឋានតាមលំអានព្រះពុទ្ធដីកាថា ឲ្យកុំពិចារណាអសុភតាំងពីចុងដើងដល់ក្បាល តាំងពីក្បាលដល់ចុងដើង ។ ដែលគេធ្វើរូបឲ្យបែរក្បាលទៅទិសខាងលិចនោះ ដើម្បីនឹងឲ្យពិចារណាតាមអត្ថថា: អនិច្ចា វត សង្ខារា ។ល។ ដូច្នេះជាដើម ។ ដែលគេធ្វើរូបឲ្យបែរក្បាលទៅទិសខាងកើតនោះ ដើម្បីនឹងឲ្យពិចារណាតាមអត្ថថា អបិរំ វតយំ កាយោ ។ល។ ដូច្នេះជាដើម ដោយសេចក្តីកើតនឹងស្លាប់ជាគូគ្នា ។ ដែលគេធ្វើរូប ៣ ដងនោះ ដើម្បីនឹងឲ្យពិចារណាទៅតាមកពទាំង ៣ មានកាមកពជាដើម ។

១៣- ស. កាលគេនឹងដុតខ្មោច ហេតុអ្វីបានជាគេដាក់ក្បាលខ្មោចឲ្យបែរទៅទិសខាងលិច?

១៣- ឆ. រឿងនេះប្រែកាន់តែ គ្នាមកតាំងពីកាលព្រះឥសូរគោវដុកព្រះពិឃណេស ជាបុត្រ ដូចមានដំណាលតាមសាសនាព្រាហ្មណ៍

ថា: ព្រះឥសូរវៀបកោរដុតឲ្យព្រះពិឃណេសមិនបានច្បាប់ព្រះអង្គារ ឲ្យជាបផង ព្រះអង្គារខ្ចាល់ក៏បណ្តាលឲ្យកាំបិតកោរទៅ កាត់យកក្បាលព្រះពិឃណេសចោះចាលទៅកងសមុទ្រចាត់ទៅ ។ ព្រះឥសូរកំប្រើព្រះពិស្ណុកម្ម ឲ្យទៅកាត់យកក្បាលមនុស្សនឹងសត្វតិរច្ឆានដែលដេកបែរក្បាលទៅទិសខាងលិច ។ ព្រះពិស្ណុកម្មទៅរកមើលឃើញដំរីពីរដេកបែរក្បាលទៅទិសខាងលិច ក៏កាត់ក្បាលដំរីនោះយកមកតថ្វាយព្រះពិឃណេស បានជាព្រះពិឃណេសមានក្បាលជាដំរី ។ ព្រោះហេតុនេះ បានជាមនុស្សពាំងឆ្ងាយប្រកាន់តៗ គ្នាមកថា ដេកបែរក្បាលទៅទិសខាងលិចកើតអពមង្គល គេប្រកាន់ថាមនុស្សរស់គួរដេកបែរក្បាលទៅទិសខាងកើត មនុស្សស្លាប់ឲ្យដេកបែរក្បាលទៅទិសខាងលិច ក៏ជាប់ជាទំនៀមតៗ គ្នាមក ។

១៤ - ស. កាលដុតខ្មោចរួចហើយត្រឡប់មកផ្ទះវិញ ហេតុអ្វីក៏គេឲ្យងូតទឹក ?

១៤ - ឆ. គេឲ្យងូតទឹកតែពួកក្មុកជាអ្នកដុតខ្មោចប៉ុណ្ណោះទេ ព្រោះខ្លួនគេប្រឡាក់ប្រឡូស ចំណែកអ្នកឯទៀតបើងូតទឹកក៏ជាការល្អ ព្រោះការដម្រះញើសក្អែលរបស់ខ្លួនឲ្យស្អាត ជាហេតុឲ្យពាងកាយល្អផង ឥតសេចក្តីសុខផង ។

១៥ - ស. ខាងខ្លះត្រូវដុតគូ ខាងនោះត្រូវដុតសែស ខ្មោចដុតមនុស្ស ដុតខ្មោច នោះដូចម្តេច?

១៩-ធ. មានរឿងតំណាលថា: ដើមដំបូងកូនប្រុសសេដ្ឋីតូចទីក្រុង ជាសំឡាញ់នឹងកូនប្រុសសេដ្ឋីក្រៅក្រុង សំឡាញ់ទាំងពីរនាក់នោះស្រឡាញ់ស្រីតែម្នាក់រួមគ្នា ស្រីនោះបានប្តេជ្ញាថា "បើអ្នកព្រមស្លាប់ជាមួយគ្នាទើបខ្ញុំព្រមព្រៀងតាមប្រពៃណី" ។ សំឡាញ់ទាំងពីរក៏ទទួលប្តេជ្ញា ។ លុះយូរមកស្រីនោះស្លាប់ ញាតិសន្តានក៏ទាំសពទៅដុត ត្រូវលើថ្ងៃ ១៥ កើត ដុតរួចនាំគ្នាវិលមកផ្ទះវិញ ។ កូនសេដ្ឋីក្នុងក្រុងគ្រាន់តែដឹងហេតុនោះភ្លាម ក៏រត់ទៅលោតបូលក្នុងគំនរសៃដែលភ្លើងនៅមិនទាន់រលត់ ។ លុះដល់ព្រឹកឡើងថ្ងៃ១ភេច មនុស្សទាំងឡាយនាំគ្នាចេញទៅមើលក៏ឃើញមនុស្សស្លាប់ក្នុងគំនរភ្លើង ទើបនាំគ្នាសន្និដ្ឋានថា ដុតខ្មោចថ្ងៃសីលមិនល្អទេ បែរជាខ្មោចដុតមនុស្សវិញ ។ រួចក៏បបួលគ្នាដុតខ្មោចនោះឲ្យឆេះសុះអស់ទៅ ។ ហេតុនេះហើយបានជានាំគ្នាប្រាប្តថា ខាងខ្មែតត្រូវដុតសព ១ ខាងរនោចត្រូវដុតសព ២ ។ ពាក្យអ្នកស្រុកថា ខាងខ្មែតដុតគូ ខាងរនោចដុតសេស ជាប់រហូតមកដល់សព្វថ្ងៃនេះ ។

តមកមិនយូរប៉ុន្មាន កូនសេដ្ឋីក្រៅក្រុងដឹងហេតុនោះហើយ ក៏ប្រញាប់មករើសឆ្អឹងខ្មោចទាំងពីរ ដាក់ក្នុងក្អមបង្សួនទឹកទៅរកព្រះបូសី។ ក៏ដល់ស្រីជាប្រុសឡើង ។ បូសីសួរនាងនោះថា "នាងឯងបូលចិត្តនោជាមួយនឹងប្រុសណា" ។ នាងនោះឆ្លើយថា "ខ្ញុំបូលចិត្តនៅជាមួយនឹងប្រុសដែលស្លាប់ផងគ្នា" ។ បូសីក៏ប្រសិទ្ធិឆ្កុំឲ្យប្រុស

នោះទៅ ។ ប្រុសដែលយកឆ្នឹងចងកទៅឥតបានអ្វីសោះ ទើបមានពាក្យចំនៀមថា "សាច់មិនបានស៊ី ស្បែកមិនបានគាប់អង្កួយ ឆ្នឹងត្បូរក" ។

១៦– ស. គេធ្វើជណ្តើរ ៣ កាំ សំគាល់សេចក្តីថាអ្វី?

១៦– ឆ. លោកថា បានដល់តឋ ៣ គឺកាមតឋ ១ រូបតឋ ១ អរូបតឋ ១ ។ ជ្រុតមនុស្សបុថុជ្ជនត្រវិលវល់ឡើងចុះនៅក្នុងតឋ៣នេះ មិនទាន់ឈានទៅឲ្យផុតបានទេ ។

១៧– ស. ហេតុអ្វីបានជាគេស្បែកសំពត់ឲ្យខ្មោចយកថ្នក់ទៅខាងក្រោយខ្នងវិញ?

១៧– ឆ. លោកកែថា សត្វកើតដោយទិដ្ឋិ ស្លាប់ដោយទិដ្ឋិ មានអវិជ្ជាបិទមុខបិទក្រោយ ទើបមានតណ្ហាចាក់ស្រែះគ្នាទៅទៀត ។

១៨– ស. ដែលគេធ្វើអម្រែក ៣ មានអាហារចំណីនោះ តើគេយកទៅឲ្យអ្នកណា?

១៨– ឆ. កត្តាហារក្នុងអម្រែក ៣ នោះ ហៅតាមមគធភាសាថា មតកកត្តុ គឺកត្តុរបស់អ្នកស្លាប់ ជាអាហារដែលញាតិមិត្រ ទើបបញ្ជូនទៅឲ្យត្រង់កន្លែងដែលទៅវិលវល់ក្នុងតឋបី ។

១៩– ស. ហេតុអ្វីបានជាគេឲ្យកូនប្តូរថៅបួសមុខក្តៅដឹង?



១៩– ឆ. ហេតុតែជីដូនជីតាមាតាបិតាមានគុណ កូនចៅមានចិត្តកតញ្ញូកតវេទី ហើយបួសដើម្បីទុទ្ទិសផលផ្ញើសជូនទៅលោកអ្នកមានគុណដែលស្លាប់ទៅនោះ ។

២០ – ស. ដែលគេចំអាសទឹកខ្មោចតើ ដើម្បីប្រយោជន៍អ្វី? ហេតុអ្វីបានជាអ្នកម្ចាស់ខ្មោចហៅញាតិមិត្តឲ្យមកចំអាសទឹកខ្មោចនោះផង?

២០ – ឆ. រឿងចំអាសទឹកខ្មោចនោះ គេប្រកាន់តាមសេចក្តីយល់ឃើញប្លែកៗ គ្នា ។ ជាតិភូតគ្រប់ប្រកាន់ថាផ្តិតទឹកលាបមេម៉ាឲ្យខ្មោចស្អាតបាតហើយ កាលទៅកើតជាតិមុខទៀតនឹងមានរូបពណ៌ស្អាតល្អ ។ ពួកព្រាហ្មណ៍ប្រកាន់ថា ផ្តិតទឹកលាងបាបឲ្យ ដ្បិតព្រាហ្មណ៍ជឿថា ទឹកក្នុងស្ទឹងគង្គាជាទឹកលាងបាប មនុស្សឈឺដាច់ស្លាប់ឬស្លាប់ទៅហើយ ក៏នាំគ្នាទៅដងទឹកស្ទឹងគង្គាមកលាងបាបឲ្យអ្នកនោះដែរ ។ ឯពួកខ្មែរយើងជាអ្នកកាន់ព្រះពុទ្ធសាសនាលើកយកសេចក្តីកតញ្ញូជាធំ បានជានាំគ្នាមកផ្តិតទឹកឲ្យខ្មោច ដោយសេចក្តីត្រេកអរថាលោកជាអ្នកមានគុណ ព្រមទាំងមកសូមខមាទោសកុំឲ្យមានកម្មពៀរនឹងគ្នាផង ។

២១ – ស. ហេតុអ្វីបានជាគេនិមន្តលោកសូត្រព្រះធម្មតែ៤អង្គប៉ុណ្ណោះ? បើនិមន្តលោកឲ្យច្រើនលើសពី ៤ អង្គឡើងទៅបានឬទេ?

២១ – ឆ. ហេតុតែអ្នកម្ចាស់ខ្មោចប្រាថ្នាថាព្រឹកឡើងនឹងបានចាយសង្ឃទានគ្រប់ជាអង្គសង្ឃ ដើម្បីនឹងបានទុទ្ទិសចំណែកកុសលនោះទៅឲ្យអ្នកស្លាប់ ។ បើនិមន្តលោកឲ្យច្រើនលើសពី ៤ អង្គឡើងទៅប្តិចជាងនេះក៏បានត់តាស់ខុសអ្វីទេ បើវេជាសង្ឃទាន ក៏បានដូចគ្នា ។

២២ – ស. តាវដែលគេនិមន្តលោកមកសូត្រព្រះធម្មនោះតើ គឺសូត្រឲ្យមនុស្សរស់ស្តាប់ ឬឲ្យមនុស្សស្លាប់ស្តាប់?

២២ - ឆ. សូត្រឲ្យមនុស្សស្រេស្តាប់ ដើម្បីឲ្យពិចារណាកងមរណានុស្សតិថា តើតមកជារូបកងកាយរមែងមានសេចក្តីស្លាប់ជាទីបំផុត, ឯមនុស្សស្លាប់ស្តាប់មិនបានទេ ។

២៣ - ស. បើស្តាប់មិនបានដូច្នោះ ហេតុអ្វីបានជាគេគោះក្តារមឈូសច្រាប់ខ្ចោចឲ្យខ្លួលសីល?

២៣ - ឆ. រឿងនេះជាទិដ្ឋិរបស់ព្រាហ្មណាចារ្យក្នុងព្រះពុទ្ធសាសនាប្រកាន់ថាសត្វស្លាប់ហើយ ព្រលឹងឬអាត្មនរបស់សត្វនោះ មិនបានរលត់ទេ ប៉ុន្តែដែលគេធ្វើដូច្នោះ ខ្ញុំក៏មិនយល់មិនដឹងសេចក្តីបំណងយ៉ាងណារបស់គេដែរ ។

២៤ - ស. កងវេលាមានបុណ្យខ្ចោច គេស្រែកដណ្តប់សំពត់សខ្លះ ខ្មៅខ្លះ ឬមានសំពត់ខ្មៅបន្តិចសៀតនៅដៃអាវឬត្រង់ទ្រូងខ្លះ គេធ្វើយ៉ាងនោះតើ ព្រោះហេតុអ្វី?

២៤ - ឆ. ដែលគេស្រែកពាក់សនោះ ប្រហែលជាខ្នែរយើងយកតម្រាប់តាមចិន ព្រោះចិនគេប្រើរបស់សជាគ្រឿងកាន់ទុក្ខកងវេលាញាតិមិត្រស្លាប់ ឬមួយទៀតជួយបុណ្យសពគេឯទៀតក៏ប្រើសដែរ ។ ឯការស្រែកពាក់សនេះជាតិខ្នែរយើងមានច្រើនតែអ្នកកាន់សីល ។ ចំណែកការស្រែកពាក់ខ្មៅនោះ ប្រហែលជាយកតម្រាប់តាមពួកប្រទេសជិតដែលគេប្រកាន់ថា មនុស្សយើងកាលធ្វើបុណ្យខ្ចោចរបស់ខ្លួនក្តី ទៀ

ដួយគេក្តី គួរប្រើរបស់ខ្មៅ ព្រោះពណ៌ខ្មៅដាំពណ៌ស្វាយប៉ែបប្រួលទៅ
ទៀតមិនកើត ។ ចំណែរតមក លោកអ្នកខ្លះយល់ឃើញថាការស្លៀក
ពាក់ខ្មៅសុទ្ធ មិនជាការសំខាន់ណាស់ទេ គួរតែឲ្យមានរបស់ខ្មៅបន្តិច
ជាប់នឹងខ្លួនក៏បានហើយ ទើបនាំគ្នាធ្វើសំពត់ពណ៌ខ្មៅបន្តិចជាប់នឹងខ្លួន
រហូតមកដល់សព្វថ្ងៃនេះ ប៉ុន្តែអ្នកដែលស្លៀកពាក់សស្តុទ្ធឬខ្មៅសុទ្ធក៏មាន
គង់តែសំដែងខ្លួនថាជាអ្នកកាន់ខ្មែកងឹបុណ្យសពដូចគ្នា ។

២៥ – ស. ហេតុអ្វីបានជាគេបើកក្តារមឈូស បើមិនបើកបានឬទេ?

២៥ – ឆ. ដែលគេបើកនោះ ព្រោះពីដើមកាលបើមានមនុស្សស្លាប់
ហើយ គេយកដើមឈើមួយកំណាត់មកលុងជាប្រហោងឲ្យស្អាតល្អរួច
លើកខ្មោចដាក់ចូលទៅ ។ កាលបើទុកខ្មោចយូរថ្ងៃ ខ្មោចនោះហើម
ប៉ោងធំឡើងខាល់តែតឹងចង្អៀតក្តារមឈូស ខាងក្រោយមកបានជាគេ
បើកក្តារមឈូសឲ្យធំល្មាយជាមុនសិន រួចទើបយកខ្មោចដាក់ចូលទៅ
ដើម្បីការពារកុំឲ្យក្តារមឈូសបែកធ្លាយ ។ ដល់មកឥឡូវនេះគេបើក
ទាំងធំទាំងតូច ។ ប៉ុន្តែគួរបើកតែក្តារមឈូសតូច ឯក្តារធំស្រាប់ហើយ
មិនគួរបើកទេ ។

ប្រស្នាតិនិបុណ្យខ្មោចចប់ប៉ុណ្ណេះ

រឿងស្តេចត្រី

លោកធើង-ជ្រើរ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែពីសៀវភៅ «កុង អេ ឡេហ្សង់ ឌុយប៉េអ៊ី រូម៉ាំងត្រាគ្វី ប៉ាអេ អាជាប្តេ ប៉ា ប.នរតីន»

(តពីរឿងមនុស្សដូចមក)

កន្លងកាលដ៏កន្លងទៅហើយ មានបុរសម្នាក់រកស៊ីដោយការនេសាទត្រី, គាត់មានកូនប្រុសមួយដែលគាត់ចង់ឲ្យធ្វើជាអ្នកនេសាទដូចគាត់ទៀត ។ ថ្ងៃមួយ គាត់ទៅបង់សំណាញ់ជាមួយនឹងកូន បានត្រីមួយយ៉ាងល្អ ស្រកាភ្លឺដូចពេជ្រ ។ គាត់យកត្រីនោះដាក់ទុកនៅលើមាត់ត្រពាំង ឲ្យកូននៅចាំរក្សា ហើយត្រឡប់ទៅបង់សំណាញ់ទៀត ។

កាលដែលបុរសចេញផុតទៅ ត្រីក៏និយាយតួញាត្អែរ ទឹកត្អែកហូរ រហាមថា: បពិត្រកុមារ? ខ្ញុំជាស្តេចត្រី សូមអ្នកមេត្តាបោះខ្ញុំទៅកន្លែងទឹកវិញ ខ្ញុំនឹងដឹងគុណអ្នកទៅថ្ងៃក្រោយជាមិនខាន ។

ត្រីនោះចេះនិយាយតួញាសូម្បីតែដុំថ្មក៏ទន់តាមដែរ, កុមារអាណិតត្រីក្រៃពេកដោយឮសំដីដូច្នោះ ទើបចាប់បោះទៅក្នុងទឹកវិញទៅ ។ មច្ឆាត្រេតអរអរនេកអនន្ត ហែលប្រុះហែលទ្បើង មុជងើបៗ រាត់កន្ទុយបែកទឹកភ្លាយ រួចមុជទៅបាត់ ។

ប្រហែលមួយស្របក់ធំ អ្នកនេសាទត្រឡប់មកវិញ ទឹងអ៊ូចាំដេរនាយដេរអាយ ព្រោះបង់សំណាញ់ឥតបានត្រីសោះ សូម្បីតែបន្លា

មួយក៏គ្មាន សួរកូនថា នែអា.ណុប! ម៉េចគ្រីយើង ប្រវែលរួចមួយ ពេលបានឬទេ? ។

- ពុក! ខ្ញុំចាប់ផ្តើមតឹកវិញទៅហើយ វានិយាយនឹងខ្ញុំ ហើយ អង្វរខ្ញុំ សុំឲ្យលែងវា ដ្បិតវាជាស្តេចត្រី ។

អ្នកនេសាទ ឮដូច្នោះ ខឹងតូង ស្ទុះដាក់កូន ក្អូស។, តោះបីកូន ស្រែកអួយយ៉ាយ អួយយ៉ួយ ដូចម្តេចក៏ដោយ ក៏គាត់មិនឈប់ត្បាក ។ គាត់ត្បាកវាហូតទាល់តែរួយដៃ ឈឺម្រាមដៃទើបឈប់ ។ បុរសនុពុក ខឹងកូនត្រឡប់ទៅផ្ទះវិញដៃទទេ, ល្ងាចនោះគ្មានអ្វីធ្វើម្ហូបសោះ អត់ទាំង ប៉ាយទៀតផង ។

ព្រឹកឡើង បុរសនុពុកទាត់ជាក់កូនទៀត ដោយគ្មានរឿងហេតុអ្វី ។ លុះប៉ុនសេចក្តីទុក្ខខ្វាំងពេក ថ្ងៃមួយ កុមារកំសត់ទ្រាំនៅមិនបាន ក៏ លួចរត់ចេញពីផ្ទះអាគ្មាទៅ ។ កុមារនោះដើរទៅ ។ ដល់ទីត្រែងមួយ ។ គាន់តែចូលទៅដល់ភ្លាម មានអាតឿម្នាក់ដែលឈរផ្អែកនឹងកំពែង គេហស្ថានមួយ ដើរមកឲ្យពរ ទាំងសួស្តី ដល់ចៅកំសត់។ ដោយខ្លួន អនាថា លុះឃើញហេតុដ៏ល្អដូច្នោះ ត្រេកអរពេក ហើយសុំបងមិត្តភាព ជាមួយនឹងអាតឿ ។ រួចដនាំងពីរ ធ្វើកតិកាសញ្ញាទៅវិញទៅមក ថា យើងកុំបែកគ្នា ហើយចាប់តាំងពីពេលនេះទៅ បើយើងបានរត់ទុំអ្វី គោងបែកគ្នាបរិភោគ ។

ចែកគ្នា...? មែនហើយ ប៉ុន្តែចែកអ្វី? បើគ្មានមួយសេនចោះ ។ ខណៈនោះចៅកំសត់ទាំងពីរ សម្រែចគ្នានឹងទៅរកស៊ីឈ្លួសគេ ទើបនាំគ្នាទៅនៅស៊ីឈ្លួសនឹងផ្ទះចៅកែម្នាក់ ខាងក្រោយដែលបានសម្រែចថ្ងៃឈ្លួសហើយ ។

ថ្ងៃមួយ អាតឿកាលដែលបានធ្វើការរួចសព្វគ្រប់ហើយ ទៅឈរលេងនៅក្បែរមាត់ទ្វារកំពែង ហើយបានឃើញមនុស្សម្នាក់ដិះសេះ មានសេះដទៃទៀតជាន់ខ្ចីម្នាក់រត់តាមក្រោយ ។ ពួកឡើងមៅងដដែលមនុស្សដិះសេះទៅជាមួយនឹងខ្ចីរូបដទៃវិញ ។ ពួកស្អែកឡើងទៀតគេឃើញគាត់ទៅជាមួយនឹងខ្ចីផ្សេងពីថ្ងៃទីពីរ, ហើយដំណើរនេះតែងមានដូច្នេះតទៅ រៀងរាល់ថ្ងៃ ។ អាតឿចេះតែនឹកពិការាល់ក្នុងចិត្តថា: ចុះបាវមុនៗ តើគេយកទៅធ្វើអ្វីអេះ? ។ អាតឿដោះស្រាយប្រស្នានេះមិនរួចសោះ ។ លុះទីបំផុត ក៏ជាប់ចិត្តទៅតាមមនុស្សដិះសេះ ដើម្បីលួចយកការណ៍ឲ្យបានដឹងជាក់ ។

អាតឿទៅឯផ្សារ ហើយឈរពោលប់ចាំមើល ។ មិនយូរប៉ុន្មានលេចមនុស្សដិះសេះមកដល់ គឺជាគហបតីម្នាក់ ។ គាត់ជួលមនុស្សម្នាក់ ហើយឲ្យឡើងដិះសេះបរតាមពីក្រោយ ។ ចំណែកអាតឿចេះតែលបរតាមក្រោយជនខាងលើនេះ ។ មុនដំបូង គេត្រចតាមរាល់ស្នៀបកបដោយផ្លាកក្តូជាតិផ្សេងៗ ។ រួចគេចូលកន្លែងស្នាន

គេចរយ៉ាងយូរ ទើបទៅឈប់នៅក្បែរឈើមួយដើម ។ គេចុះពីសេះ ។ គហបតីទាញយកខ្សែព្រីការុង ចងភ្ជាប់នឹងដែកគោលមួយ ដែលចោះខុកនឹងដើមឈើនោះ ចោះកន្ទុយខ្សែរំលងកាត់មែកខាងលើ ហើយបង្គាប់ឲ្យអ្នកបំរើគោងកន្ទុយខ្សែនោះឡើងទៅ ។ អ្នកបំរើឡើងដល់ចុងឈើ ហើយបានឃើញកញ្ជ្រោងមួយដ៏ធំ ពេញដោយត្បូងពេជ្រមានជម្ងៃ ។ អ្នកនេះស្រែកពីលើដើមរេចមកថា: អ៊ា! លោកម្ចាស់! សុទ្ធតែត្បូងច្រើនណាស់ ។

គហបតីនិយាយថា: ដាក់ចុះមក! កុំស្រែកហ៊ោកញ្ជ្រៀវនៅលើហ្នឹងខ្លាំងពេក! ។ អ្នកបំរើដាក់កញ្ជើមក, ខាងក្រោយដែលចាក់ត្បូងកងការុង គហបតីហុចកញ្ជើតាមខ្សែទៅឲ្យខុកត្រង់កន្លែងដដែលវិញ ។ អ្នកស៊ីឈ្នួលធ្វើតាមសេចក្តីបង្គាប់របស់គហបតី, ប៉ុន្តែពេលដែលត្រូវចុះមកវិញរកខ្សែប្រគោងគ្មាន ។ វាស្រែកប្រាប់ថា: លោកម្ចាស់! ចោះខ្សែមកឲ្យខ្ញុំផង ដើម្បីនឹងចុះ, ខ្ញុំលោតចុះទៅមិនបានទេ មុខជាត្រូវបាក់ដើងឬបែកក្បាលស្លាប់ជាមិនខាន ។

កុដុម្ពីក៏គិតតែពីរៀបចំការុងចងមាត់ លើកដាក់លើខ្នងសេះ មិនរវល់ធ្វើយ ។ អ្នកបំរើស្រែកប្រាប់ទៀតថា នែលោកម្ចាស់! ឮឬទេ? លេងសើចប៉ុណ្ណឹងបានហើយ ។ អ្នកស៊ីឈ្នួលប្រឹងស្រែកប្រាប់ជាច្រើនម៉ាត់ ប៉ុន្តែគហបតីធ្វើដូចជាមិនដឹងមិនឮ លោតផែលឡើង

លើខ្នងសេះ ហើយបរសេះបំផាយទៅបាត់ ។ បុរសកំសត់ស្រែកឡើងថែមទៀតថា: នែលោកម្ចាស់! លោកម្ចាស់! ឈប់ ឈប់! សូមលោកវិលមកជួយជាក់ខ្ញុំចុះសិន មិនត្រូវយកខ្ញុំបាទមកទុកចោលក្នុងទីរហោឋានដូច្នេះទេ ។ គហបតីប្រឹងតែបំផាយសេះគ្មានស្តាប់អ្វីទាំងអស់ ។

ដឹងថាខ្លួនទៅតែឯងហើយ។ មិនគឺជាការលេងសើចពិត បុរសអកុសល តាំងស្រែកទ្រហោយំក្តែងៗ ក្នុងកណ្តាលដងព្រៃស្ងាត់ជ្រងំ ។ ចំណែកអាតឿមិនបង្ហាញខ្លួនឲ្យឃើញ ព្រោះត្រូវការចង់ដឹងរឿងតទៅទៀត ។ វេលានោះ កាលដែលបុរសកំសត់កំពុងយំបោចសក់គក់ទ្រូង មាននាគមួយមាត់ធំសម្បើមគួរស្ញែង ងើបចេញពីរូងក្បែរគល់ឈើលូនឡើងសិន្ធុំមែ។ រហូតដល់ចុងឈើ ហាមាត់ចង្អុង ធ្មេញប៉ុនប៉ែលហើយលេបបុរសនោះទាំងមូលតែម្តង ។ ខាងក្រោយដែលវាបានស៊ីមនុស្សហើយនាគនោះហាមាត់ជាថ្មីម្តងទៀត ខ្លាក់សុទ្ធតែត្បូងពេជ្រគ្រប់ពណ៌ មានក្រហម បៃតង ទទឹមជាដើម ទាល់តែកញ្ជើពេញជាថ្មីម្តងទៀត រួចវាលូនចុះមកវិញ ត្រឡប់ចូលក្នុងរូងបាត់ទៅ ។

នៅទុកាសនោះ ការភ័យតក់ស្លុតនឹងសេចក្តីអាណិតមេត្តា ធ្វើឲ្យអាតឿឈរនៅតែមួយកន្ទែងស្រឡាំងកាំងមិនហ៊ានកំរើកអាត្មា ហើយវាវាត់យ៉ាងឆាប់ត្រឡប់ទៅកាន់ទីក្រុងវិញ ។ លុះត្រឹកស្អែក កាលណាលោកគហបតីទៅឯផ្សារជាមួយនឹងសេះរបស់លោក តើលោកអ្នកអាន

ភាល់គ្នា នឹកស្មានថា នរណានឹងសុំស៊ីឈ្នួលលោកគហបតី ដើម្បីជាជំនួយដល់លោកក្នុងវៃ? គឺតួអាតឿនេះឯង ដែលវាបានដឹងរឿងវាសម្ងាត់សព្វគ្រប់ ហើយវាមានគំនិតអ្វីមួយ ក្នុងខួរក្បាលវា ។

កាលបើនិយាយថ្ងៃឈ្នួលត្រូវគ្នាហើយ អាតឿឡើងជិះសេះតាមលោកគហបតីទៅ ។ វាបរឆ្ងែងគាត់និក្រែងជាមួយលោកសេដ្ឋី ឆ្ងែងវាលស្មៅ គាត់តម្រង់ចូលវៃ ហើយបានដល់ដើមឈើដែលយើងនិយាយពីលើកមុន ។ លោកគហបតីបោះវៀសគោកក្តាម អាតឿឡើងភ្លែតយកចាំងកញ្ជើជាក់ចុះមក តាមសេចក្តីឲ្យការណ៍នៃលោកគហបតី ។

លោកសេដ្ឋីចាក់ត្បូងពេជ្រជាក់ក្នុងការុង ហើយមានចំណងចង់ឲ្យអាតឿឡើងយកកញ្ជើទៅទុកត្រង់កន្លែងដដែលវិញ ។ តែអាតឿប្រកែកថា: « ខ្ញុំវិលមុខណាស់ ឈប់ឡើងទៀតហើយ » ។

លោកគហបតីសួរចាំងខឹងថា: ចុះបើវិញ តើកញ្ជើឲ្យអញធ្វើដូចម្តេចទៅ អាតឿឆ្លើយឡើងថា: ចំណែកកញ្ជើមានពិបាកអី លោកឡើងខ្នងលោកយកទៅដាក់ទៅ តែប៉ុណ្ណឹងក៏ស្រេចហើយ ។

លោកសេដ្ឋីជញ្ជឹងថា: " បើប្រសិនជាលោកឡើងដោយខ្នងឯង នោះត្រូវតែត្រឡប់មកវិញ លោកមិនមែនឆ្កួតនោះទេលើកចុងឈើឲ្យនាគវាលេបឡើយ, ចុះបើត្រឡប់ចុះមកវិញ គ្មាននរណាម្នាក់នៅលើចំនោះៗសមខានបានត្បូងពេជ្រនោះទៀតក្រាយ " ។

លោកសេដ្ឋីនិយាយទៅកាន់អាតឿទៀតថា: ចូរឯងឡើងឲ្យអញមួយភ្លែតទៅ ឯងនឹងត្រូវបានពេជ្រមួយក្តាប់ជាមិនខាន ។

អាតឿឆ្លើយថា ទេ! ។

- ចូរឯងឡើងទៅ អញមិនថាកុហកឯងទេ ។

អាតឿដេកនៀលទៅដី ហើយស្រែកថ្ងូរប់លោកសេដ្ឋីថា: ឱលោកអើយ! ជីវិតក្បាច់ចក្រហើយ ។

លុះនិយាយទៅមកៗ មួយសន្ទុះមិនសម្រេចការ លោកសេដ្ឋីសុខចិត្តព្រមយកកញ្ជើឡើងទៅពុក ដោយខ្លួនឯង ។ គឺត្រង់ហ្នឹងហើយដែលអាតឿវាត្រូវការ ។ គាន់តែលោកសេដ្ឋីឡើងដល់ពុងឈើក្រាមអាតឿបាត់វិលមុខ ស្ទុះមកចាប់កន្ទុយខ្សែកន្ត្រាក់ចុះ ទុកឲ្យលោកសេដ្ឋីទៅជាប់ទើរលើពុងឈើ ។

លោកសេដ្ឋីស្រែកថា: ទុកខ្សែឲ្យអញ អាឯងធ្វើអីចឹង? ទុកខ្សែឲ្យអញដើម្បីអញចុះ! ។ អាតឿលោតដិះលើខ្នងសេះហើយថ្ងូរប់ថា: សូមលោកអញ្ជើញទៅលើពុងឈើហ្នឹងចុះ ស្រួលហើយ ។

- អាតឿ! អាតឿ! ពេជ្រគាំងការុង ឯងយកចុះ អាណិតតែយកខ្សែមកពាក់ឲ្យអញ ដើម្បីឲ្យអញចុះ ។

អាតឿមិនរវល់ស្តាប់ ។ កាលណាវាដិះលើតែបង្ហូរប្រាចនឹងបរថយចេញ រាបែរទៅរកសេដ្ឋីម្ខងទៀត ហើយស្រែកថ្ងូរប់ថា: "ម្ចាស

សំឡាញ់! ចូរឯងនៅទំលើចុងឈើហ្នឹងហើយ ចូរទៅសួរស្តីមានដល់ឯង" រួចវាគោះសេះបំផាយត្រឡប់វិលមកទីក្រុងវិញ ។

លោកគហបតី លោកកន្ត្រាំលអន្ទះអន្ទែងចោចសក់ឥតអំពើ នៅលើចុងព្រឹក្សា ព្រោះគ្មានផ្លូវអើសោះដើម្បីនឹងដោះខ្លួន ឥឡូវតែតនឹងលោតចុះ គង់តែភេសាច់កំណើតគ្មាន ។ ម្ល៉ោះហើយគាត់គិតតែពីយំខ្លួញខ្សឹកខ្សួលរហូតទាល់តែនាគព្រួសវា វាលូនឡើងមកហើយលេបចាំងរស់... ។ គឺជាសេចក្តីស្លាប់ចាំងវេទនារបស់គាត់ ។

ឥឡូវអាតឿចង់ទៅឯផ្ទះលោកគហបតី ប៉ុន្តែធ្វើដូចម្តេច? បើវាមិនស្គាល់ផ្ទះលោកសោះ ។ អាតឿបណ្តោយឲ្យសេះដើរតាមចិត្តវា ។ ដើរទាំទៅត្រង់ទីលំទៅលោកសេដ្ឋី ។ បុរសកន្ទុញឃើញវាបិទជិត លុះរកទៅរកមកវាប្រទះកូនសោមួយក្នុងការុង រួចវាចាក់សោចូលក្នុងផ្ទះ ។ អាតឿស្រឡាំងកាំងស្រាំងក្អែក ដោយឃើញសុទ្ធតែគំនរត្បូងពេជ្រភ្លឺចិញ្ចាច កន្លែងនេះគឺជាឃ្លាំងដែលសេដ្ឋីសម្រាប់យកត្បូងចាំងប៉ុន្មានមកលាក់ទុកដោយការសម្ងាត់ ។ អាតឿរៀបចំភ្លាម។ យកការុងត្បូងចាក់ចេញហើយ រត់ទៅរកសំឡាញ់របស់វា ។ អាតឿមកដល់ ឃើញកូនបុរសនេសាទមានមុខសូតក្រៃម ។ កុមារនេះកាលបើបានយល់សម្លាញ់ ក៏មានមុខរីករាយដូចបានឃើញព្រះជាម្ចាស់ ។ វាសួរហើយសួរទៀត ទូវអាតឿថា: ចុះឯងទៅណា? ឯងទៅធ្វើអ្វី? ឯងទៅណា

អ័យរម្ល៉ះ? ។ អាតឿឆ្លើយថា: អញនឹងនិយាយប្រាប់រឿងដល់សម្វាញ់ឥឡូវហ្នឹង ប៉ុន្តែចូរសំឡាញ់ទៅបើកប្រាក់ថ្លៃឈ្នួលយកមកហើយទៅជាមួយនឹងអញ ។ កូនអ្នកនេសាទទៅកន្ទាយចៅហ្វាយមួយរំពេច ហើយប្រាប់ថា វាឈប់ធ្វើការហើយ សុំបើកយកប្រាក់ថ្លៃឈ្នួល ។ ចៅកែជាចៅហ្វាយនាយសួរថា ចុះឯងវាជី មានរឿងអ្វី? តើរឿងអ្វី ធ្វើឯងឲ្យចង់ទៅណា យ៉ាងដូច្នេះគ្មានដឹងមុខប្លាត? ។ កូនអ្នកនេសាទឆ្លើយថា: ត្រូវឲ្យថ្លៃឈ្នួលខ្ញុំមក! ត្រូវឲ្យថ្លៃឈ្នួលខ្ញុំមកខ្ញុំលាទៅហើយ ។

ចៅកែនោះគិតថា: អានេះឆ្កួតទេតើ, បើដូច្នេះត្រូវចេញថ្លៃឈ្នួលដល់វាឲ្យគាប់ ហើយបណ្តេញវាចេញ មុនពេលដែលវាបង្កវឿងអាក្រក់អ្វីមួយដល់អញ . . . ។ នេះនែ អានាង (ចៅហ្វាយហុចថ្លៃឈ្នួលឲ្យ) ចូរឯងទៅចុះ សូមឲ្យព្រះជាម្ចាស់ជួយតាមរក្សាឯងឲ្យបានសេចក្តីសុខ ។

កូនអ្នកនេសាទចេញពីផ្ទះនោះ ហើយទៅជាមួយអាតឿសំដៅឃ្លាំងខ្ទេចលោកសេដ្ឋី ។ វាឈរនឹងប្តូរតែមួយកន្ទែងវេលាដែលបានឃើញគំនរទ្រព្យទាំងប៉ុន្មានដែលសម្វាញ់វាប្រាប់ថា ជារបស់វាទាំងពីរនាក់ ។

- អាហ៎សំឡាញ់! ឯងកុំនិយាយលេងដូច្នេះ ។
- ចឹងមែន អញមិនថាលេងទេ ។
- អីទ្រព្យទាំងអស់ហ្នឹងជារបស់ផងយើង? ។
- មែន ទាំងអស់ហ្នឹង ។

កូនអ្នកនេសាទ វេលាដែលអាតឿនិយាយរឿងប្រាប់សព្វគ្រប់ ក៏តបថា: អីដូច្នេះសំឡាញ់! ឯងមិនគ្រាន់បើណាស់ហើយ? ។

ក្នុងកាលនោះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ក្នុងព្រះនគរនោះ បានចាត់ឲ្យគេប៉ាវគង់ប្រាប់អស់អាណាប្រជារស្ត្រថា បើឈ្មោះណាបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងព្រះពជធីតាព្រះអង្គហើយ។ អាចបានអាស្រ័យតំណែកនៅជាមួយគ្នា ក្នុងបន្ទប់របស់នាងអស់មួយវាំតែរហូតទាល់ព្រះអុណារះឡើង នោះព្រះអង្គនឹងទុកអ្នកនោះជាព្រះសុណិសារបស់ទ្រង់ ដ្បិតព្រះពជធីតានោះ បានរៀបមង្គលការជាមួយនឹងបុរសអស់ចំនួនកៅសិបប្រាំបួនហើយ។ លុះព្រឹកឡើង គេរកស្វាមីមិនឃើញ។ តែគំនរឆ្អឹង ម្ល៉ោះហើយព្រះពជាមានព្រះហឫទ័យសង្វេគ មិនទ្រង់ជ្រាបថានរណាជាគូបច្ចាមិត្រសោះ ។

អាតឿបានដឹងដំណឹងដូច្នោះ យល់ដើងការណ៍ ក៏ទៅគាន់ព្រះពជ-វាំងភ្លាម ហើយក្រាបបង្គំទូលព្រះចៅថា សំឡាញ់របស់ទាបធំផ្សងភ័សនាល្បងធ្វើជាព្រះសុណិសានៃព្រះពជាលមើល ។ ព្រះពជាទ្រង់ទទួលដោយមានព្រះហឫទ័យរីករាយ ហើយមានព្រះពជឧដ្ឋារថា ចូរឲ្យគាមកយ៉ាងឆាប់ បើវាស្ទុះរួចបានមួយយប់ នោះកូនស្រីរបស់យើងនឹងត្រូវបានទៅវាធ្វើជាប្រពន្ធតទៅ ។

អាតឿត្រឡប់ទៅរកកូនអ្នកនេសាទជាសំឡាញ់ ដោយរួសរាន់ឥតបង្អង់ រួចនាំយកមកកុងព្រះពជវាំង ហើយវេលាពេលកាលណាសំឡាញ់

របស់ព្រះពុទ្ធតាន់គ្នាចូលក្នុងបន្ទប់ រួចក៏ទៅតាមក្នុងទីនោះដែរ ដេកនឹងដីក្បែរគ្នា ។

ពេលកណ្តាលអធ្រាត្រ អាត្មីក្រោកឡើង លើកបីសំឡាញ់ដែលកំពុងដេកលក់ទៅជាមួយនឹងព្រះអគ្គមហាសាវ័ក្យត្រីយកទៅដាក់លើគ្រែមួយដទៃ ទាញដាវចេញមកហើយអង្គុយចាំមើល ។ ក្នុងមួយស្របក់ស្រាប់មានពស់មួយយ៉ាងធំ គួរស្បថស្បែង វាចេញពីក្នុងរូបព្រះពុទ្ធតាមក ; អាត្មីព្រលែងមួយដាវដាច់ក ។ ខណៈនោះ វាស្ទុះទៅជាស់សំឡាញ់វា ហើយនិយាយថា : នែសំឡាញ់ ! ឯងចាំពាក្យខ្ញុំដែលយើងនិយាយគ្នាលើកមុនថា : បើយើងបានវត្ថុអ្វីត្រូវយើងចែងចែកគ្នាពាក់កណ្តាលម្នាក់ ឬទេ ? ។ កូនអ្នកនេសាទឆ្លើយថា : ពិតមែនហើយសំឡាញ់ ។

គ្រានោះអាត្មីដាវនៅដៃ ស្ទុះសំដៅព្រះអគ្គមហាសាវ័ក្យត្រី ដោយបញ្ចេញវាចីកេងថា នឹងពុះព្រះពុទ្ធតាជាពីរចំណែក ដើម្បីនឹងយកភាគរបស់ខ្លួន ។ ព្រះនាងព័យតក់ស្លុតរន្ធត់មហិមាទៅជាភ្លើក ហើយមានស៊ុតមួយផ្ទុះធ្លាក់ចេញពីព្រះឧស្ឋមក ។ អាត្មីធ្វើជាស្ទុះទៅម្ខាងទៀត បំរុងនឹងកាប់ពុះមែនទែន ។ ព្រះពុទ្ធតាក្លែងស៊ុតពីរចេញមកទៀត ។

អាត្មីនិយាយឃាត់សំឡាញ់ថា : ឥឡូវ ចូរឯងត្រឡប់យកបេពន្ធរបស់ឯងទៅវិញចុះ ហើយចូរនៅជាសុខតរៀងទៅ, ពស់ដែលអញ

ចុះសំឡាប់ហើយអម្បាញ់មិញនេះ ចានលាក់ស៊ុតបីនៅក្នុងព្រះទន្ទនៃព្រះនាង, ស៊ុតទាំងនេះនឹងញាស់ទៅជាពស់ទៀត ប៉ុន្តែឥឡូវនេះវាធ្លាក់ចេញមកអស់ហើយ ។

អាតឿនោះមិនគឺអ្នកណាដទៃឡើយ, គឺជាត្រីដែលកូនអ្នកនេសាទបានចោះទៅក្នុងទឹកវិញនោះឯង, ស្តេចត្រីនោះកាន់ពាក្យសត្យមកធ្វើឲ្យកុមារកំសត់មានសម្បត្តិ នឹង បានជាកូនប្រសាស្តេចផែនដី ។

អាតឿបានអធិប្បាយប្រាប់អំពីខ្លួនជាអ្វីសព្វគ្រប់ដល់កូនអ្នកនេសាទ ហើយប្រាប់ថា: "ឥឡូវនេះ អញសុំលាសំឡាញ់ឯងហើយ ចូរសំឡាញ់បរិភោគជាសុខសម្រាន្ត ទាំងកិរិយាទាំងទ្រព្យសម្បត្តិទាំងឡាយនោះចុះ" រួចក៏អន្តរធានបាត់ពីទីនោះទៅមួយរំពេច ។

លុះព្រះអរុណរះឡើង កាលណាព្រះរាជាទ្រង់ជ្រាបថា ជនទាំងពីរនាក់ (ស្វាមីភរិយា) នៅគង់វង្សដដែល ឥតមានរវិលអ្វីសោះ នោះព្រះអង្គមានព្រះរាជហឫទ័យសោមនស្សជាអនេកអនន្តរកទីបំផុតគ្មាន ។ គេធ្វើបុណ្យជាអធិកអធិក មានច្រើន មានពាំ នឹងល្បែងផ្សេងៗ សព្វគ្រប់អស់ប្រាំពីរយប់ប្រាំពីរថ្ងៃ ជាកិត្តិយសដល់គួស្រករថ្មី ។

ចប់

ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាចាស់វែង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ណាគុរ៉ក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យអ្នកពិនិត្យកែ

(តមក)

៤.— វិបាកមានប្រយោជន៍ គឺសំដីដែលអំណោយប្រយោជន៍ដល់ខ្លួននឹងអ្នកដទៃ មិនមែនជាសំដីនិយាយលេងប៉ប៉ះប៉ប៉ោះប៉ចប៉ាច់ប៉ប៉ោចឥតផលឥតប្រយោជន៍ទេ ។ នៅសំដីនិយាយ មានហេតុមានផលដែលវិញ្ញូជនចេះប្រកាន់ ប្រកាន់មិនបាន នឹងជាពាក្យនិយាយសមគួរដល់រឿងដែលពិត សមគួរដល់ភូមិធម៌របស់ខ្លួន សមគួរដល់កាលទេសៈ នឹងបុគ្គល អាចបំភ្លឺមនុស្សដែលល្ងង់ឲ្យជាមនុស្សឈ្លាសវៃ ជម្រះមនុស្សរើសឲ្យជាមនុស្សគុនលំទោន នឹងវិច្ចាប្បុជ្ជនឲ្យជាព្រះអរិយៈបាន, ធម្មវាទិតា ជាសំដីនិយាយប្រកបតែធម៌, វិនយវាទិតា ជាសំដីនិយាយប្រកបតែវិន័យ, និដ្ឋានវតី ជាសំដីមានគោលចាំក, សាបទេសា ជាសំដីមានសំអាងជាក់លាក់, កាលវាទិតា ជាសំដីត្រូវកាល, ភូតវាទិតា ជាសំដីពិត, អត្ថវាទិតា ជាសំដីមានទឹកដម, បរិយន្តវតី ជាសំដីមានលក្ខណៈតាមច្បាប់ប្រពៃណី, អត្ថសញ្ហិតា ជាសំដីមានប្រយោជន៍ ។ បើនិយាយឲ្យកើត

ប្រយោជន៍ ក៏កើតប្រយោជន៍. បើនិយាយឲ្យខូចប្រយោជន៍ ក៏ខូចប្រយោជន៍ ។ ហេតុនេះ មុននឹងនិយាយសូមលោក-អ្នកគិតឲ្យហើយសិនសឹមនិយាយ ។ ព្រោះការនិយាយមិនគិត តែងនាំឲ្យខូចប្រយោជន៍ធំកើតអន្តរាយ ។ គិតហើយទើបនិយាយ រមែងឲ្យកើតប្រយោជន៍យ៉ាងល្អក្រៃលែង ។ ចូរប្រើពាក្យសំដីដែលនាំឲ្យកើតប្រយោជន៍ដោយទំនងដែលដឹងដើមដឹងចុង ដឹងក្បាលដឹងកន្ទុយ គឺឲ្យស្គាល់ពាក្យសំដីដែលល្អឲ្យចេះជ្រើសរើសរកពាក្យនិយាយឲ្យសមគួរទើងពាក្យសំដីដែលនាំឲ្យកើតផលល្អឡើងតាំងខាងគេតាំងខាងយើង ។ បើលោក-អ្នកនិយាយមិនឲ្យខូចប្រយោជន៍ខ្លួនទើងប្រយោជន៍អ្នកដទៃយ៉ាងនេះ ទើបចាត់ថា លោក-អ្នកមានសំដីល្អ ។ បើប្រើវាចាដែលនាំឲ្យកើតប្រយោជន៍តែខាងខ្លួន ប៉ុន្តែប្រយោជន៍ខាងគេវិនាសនោះ មិនចាត់ថា មានសំដីល្អឡើយ ។ ព្រោះថាបើការចំរើនមានផ្លូវខ្ទាងហើយ ការវិនាសក៏មានផ្លូវខ្ទាងដែរ ។

អ្នកដែលនិយាយនាំឲ្យកើតប្រយោជន៍ ព្រះពុទ្ធជាម្ចាស់ទ្រង់ហៅថា បុប្ផកាឡី គឺជាមនុស្សមាត់ក្រអូប ដូចពួជឈើដែលមានកូនក្រអូបអាចបំពេញទំពក់ចិត្តឲ្យរីករាយស្រស់ស្រាយសប្បាយបាន. ទាំងទ្រង់ត្រាស់ថា មធុរកាឡី ជាអ្នកមានវាចាផ្អែមធ្វើឲ្យអ្នកស្តាប់ក្រៃចំពក់មិនចេះអស់ចំណង់ ដូចទឹកឃ្មុំយ៉ាងខាប់ក្នុងគម្ពីរដូរ ។ មនុស្សបែបនេះចាត់ថាជាអ្នកមានជំនឿតស៎ះនៅ ដើម្បីសួគ្គដល់មហាជន ព្រោះតែ

ព្យាយាមប្រើតែវាចាដ៏ជាប្រយោជន៍ ចៀសវាងរឿងដែលឥតប្រយោជន៍ ជ្រាបថាបង្អុលបង្ហាញហេតុដែលឲ្យច្បាស់ប្រាកដ តាំងក្នុងផ្លូវលោកតាំងក្នុងផ្លូវធម៌ ដោយសេចក្តីមេត្តាករុណា ដើម្បីឲ្យអ្នកស្តាប់មានសេចក្តីដឹងសេចក្តីចូលចិត្តបានត្រឹមត្រូវ ហើយកើតទុស្សាហ៍ក្នុងការប្រព្រឹត្តខ្លួនឲ្យផុតចាកសេចក្តីវិនាស ទីនាំខ្លួនទៅកាន់សេចក្តីចំរើនសួស្តីបានផង រហូតដល់ព្យាយាមពន្យល់រឿងជាន់ខ្ពស់ គឺណែនាំឲ្យស្គាល់ឲ្យឃើញទុក្ខរបស់លោកតាមសភាពពិត ឲ្យដឹងឲ្យឃើញថា អ្វីជាអណ្តាលកើតនៃទុក្ខ ឲ្យដឹងឲ្យឃើញការរលត់ទុក្ខ ទីឲ្យដឹងឲ្យឃើញវិធីផ្លូវដែលនាំទៅកាន់ការរលត់ទុក្ខ . ឈ្មោះថាជាអ្នកមានវាចាគ្រែគ្រងដ៏ទុកន្លួចគ្គមគតិដែលអ្នកស្តាប់គាំងឡាយគួរអនុលោមតាម ។

បើអស់លោក - អ្នកចង់ឲ្យសំដីរបស់ខ្លួនមានខ្លឹមសារ ដើម្បីឲ្យសម្រេចប្រយោជន៍ដល់ខ្លួនទីឯអ្នកស្តាប់ ចូរចេះដំកល់វាចាឲ្យតាំងនៅក្នុងមណ្ឌលនៃប្រយោជន៍ ទីឯរំថែរក្សាសំដីរបស់ខ្លួនឲ្យជារបស់មានដំរៀយ៉ាងវៃថ្លៃបំផុត ដោយការចេះវាចាឲ្យល្មមប្រមាណនិយាយឲ្យត្រូវកាលវេលា និយាយរឿងដែលមានពិត និយាយពាក្យដែលមានទឹកដម និយាយពាក្យប្រកបដោយធម៌នៃយ និយាយពាក្យមានគោលចាកតឹកតាង ទីឯនិយាយពាក្យមានលក្ខណៈតាមច្បាប់ប្រពៃណី ។ ព្រោះសំដីបែបនេះគាលបើនិយាយហើយ ក៏ឲ្យសម្រេចប្រយោជន៍របស់ខ្លួនទីឯរបស់អ្នក

ដទៃ ។ ហេតុនេះ ត្រូវកុំនិយាយពាក្យដែលនាំឲ្យខូចប្រយោជន៍ចំពោះ ចំណែក កុំបណ្តាយឲ្យមាត់និយាយសំដីសាបរលាបដោយការពោលឡេះឡោះ ឬនិយាយពាក្យអំនួតឡើយ ចូរនិយាយតែពាក្យដែលនាំឲ្យកើតសេចក្តីចេះដឹង សេចក្តីប្រពឹត្តិល្អដល់មនុស្សដទៃ ។

សូមកុំភ្លេចថា : សំឡេងដែលយើងនិយាយគ្នាដោយរឿងដ៏ល្អ ល្មមញ៉ាំងគុណប្រយោជន៍ឲ្យកើតឡើងដល់មិត្តភក្តិនោះ ពីពេលក្រៃលែងជាងជួរជន្លៀតទៀត ។ ព្រោះសំឡេងជួរជន្លៀតាំងឡាយ ដែលនិយមថាពីពេលនោះ កើតអំពីមនុស្សប្រតិស្ឋឡើង មិនមនកើតឯងទេ ហើយសូវគឹកកងនៃជួរជន្លៀនោះទៀត ពិពេលតែមួយភ្លែតក៏សូន្យទៅ ឯសំឡេងនៃពាក្យសំដីដែលនិយាយឬដឹកនាំគ្នាដោយរឿងដ៏ល្អវិញ ពីពេលឆ្ងាំទៅក្នុងត្រចៀកមិនចេះបាត់ ។ ដូច្នេះត្រូវមានសតិសម្បជញ្ញៈ កុំភ្លេចពិចារណាឡើយ ។ ព្រោះមនុស្សដែលមិនពិចារណា តែងយកចិត្តមកទុកនៅតែត្រង់អណ្តាត ។ ឯមនុស្សដែលមានការពិចារណាវិញ ទើបយកអណ្តាតទៅទុកត្រង់បេះដូង ។

បិត្តសុភាព — វត្ថុសំខាន់បំផុតក្នុងការធ្វើនឹងការនិយាយរបស់យើង គឺចិត្ត ។ អាកប្បកិរិយានឹងកាយដែលយើងសំដែងចេញមក រមែងជាផលនៃចិត្តដែលគិត ។ សូម្បីកិច្ចការឬសព្វវត្ថុ រូប ពណ៌ដែលយើងកសាងឡើងតាំងអស់ គឺជាផលកើតមកអំពីចិត្តគិតតាំងអស់ ។ ហេតុ

ការណ៍ដែលបណ្តាលឲ្យការធ្វើការនិយាយរបស់យើងសម្រេចជាផលល្អឬអាក្រក់នោះ មិនមានអ្វីក្រៅអំពីចិត្តដែលគិតត្រូវឬខុសឡើយ ។ ម៉ើលចុះ! ប្រាក់បើមិនមានដួងចិត្តជាអ្នកបាចនាទេ ក៏នៅជាដុំដដែល ។ ដំណែងចាន្តរៈ បើចិត្តអស់ចំណង់ហើយ ងារសក្តិ ម៉ៃដែយ ដែលនៅត្រង់ទ្រូងអាវរបស់លោកនោះ ក៏ប៉ុន្មានទឹងកំណាត់សំពត់ទេ ។ កុងការងារគ្រប់ផ្នែក បើមិនគិតខុតជាមុនរួចចាំធ្វើ រួចចាំនិយាយទេ ក៏មុខជានាំពួកគណៈទៅកាន់សេចក្តីវិនាសពុំខាន ។ ដូច្នេះ កិច្ចការគ្រប់ដំពូកទាំងគតិលោកទាំងគតិធម៌ ទើបរួមនៅត្រង់ចិត្ត ។ បើចិត្តយើងល្អ រមែងមានគុណជាអនេក ។ ចិត្តល្អឬអាម្មណ៍ល្អនេះឯង ចាត់ដាចិត្តសុភាព ។ ចិត្តសុភាពនេះ មានលក្ខណៈ ៥ ប្រការ គឺ:

១.- បិត្តសួប់សៀម - ចិត្តដែលសួប់សៀម ជាឫសគល់នៃសេចក្តីសួប់គ្រប់យ៉ាង ។ កាយវាចាដែលសួប់នោះ រមែងជាពន្លកឬជាមែកធាងបែកសាខាចេញមកពីចិត្តដែលសួប់ ។ បើយើងមានចិត្តសួប់ហើយ សូម្បីកាយវាចាក៏សួប់តាម ព្រោះចិត្តជាអ្នកនាំមុខ ចិត្តជានាយចៅហ្វាយ ចិត្តជាអ្នកត្រិះរិះពិចារណា ។ អ្នកមានចិត្តសួប់តែងជាមនុស្សមានអាម្មណ៍ល្អ សំដែងការយល់ចិត្តយល់ថ្នើមគ្នា សំដែងខ្លួនជាមិត្តរបស់មនុស្សជានៃ ឲ្យកើតសេចក្តីគាប់ចិត្តស្និទ្ធស្នាលចំពោះគ្នា អាចលុបលាងការរើងភ្លើង ទឹងការប្រកាន់អាម្មណ៍អាក្រក់ ដែលមាននៅក្នុងមនុស្ស

ដទៃឲ្យសាបសូន្យទៅបាន ។ សូម្បីមនុស្សមានអារម្មណ៍អាក្រក់អួតបុំ អួតល្អ អួតតេជះ អួតអំណាចយសសក្តិ ប្រើកំរ៉ាំងបង្អាប់បញ្ជាកំផ្លាញ់មនុស្សមានអារម្មណ៍ល្អមិនបាន គឺអ្នកមានអារម្មណ៍ល្អ ត្រូវផ្លាញ់អ្នកមានអារម្មណ៍អាក្រក់ដោយអារម្មណ៍ល្អរបស់ខ្លួន យកឈ្នះមនុស្សចិត្តក្តៅធ្ងន់បានដោយចិត្តត្រជាក់ត្រជំរបស់ខ្លួនជានិច្ច ជាអ្នកមានអំណាចលើវត្ថុគ្រប់យ៉ាង ។

ដូច្នេះអ្នកមានចិត្តស្លូត ទើបមានគុណសម្បត្តិនៅក្នុងខ្លួនច្រើនប្រការដូចយ៉ាងមានអធ្យាស្រ័យត្រជាក់ត្រជំមិនបង្កសេចក្តីរំខាន ជាមនុស្សមានបញ្ញាឈ្លាសវៃប្រសប់និយាយគ្រប់យ៉ាង មានការសង្រួមវាចាដំនួសការអួត តាំងខ្លួនជាកណ្តាលដំនួសការលំអៀងទៅក្នុងអគតិ រាប់អានមនុស្សដទៃដូចរាប់អានខ្លួនឯង ជាក់ខ្លួនដំនួសការវាយតំលៃខ្លួនថាប្រសើរជាងគេទាំងអស់ មានការគួរលំទោនដំនួសការរើងគ្នឹង មានចរិយាគួរស្រឡាញ់ហើយត្រូវធម៌ធង ឋានន់ស័ស:ចុះដោយការគោរព, ក្នុងគ្រាសម្បូរតែងមានទឹកចិត្តទន់ភ្លន់ល្អដូចផ្កាឈូក, ក្នុងគ្រាវិបត្តិ តែងមានទឹកចិត្តរឹងប៉ឹងដូចសិលាគាន់ មានកិរិយានឹងវាចារៀបរយចំពោះជនខ្លះ លះបង់ការស្រើយសមិនឱ្យឃោសកៀរ ឬ ចាក់រុកស៊ីតសៀតនរណាមួយ មិនឱ្យដើមអ្នកដទៃមានសេចក្តីតុណាចំពោះសត្វទាំងអស់ ជួយមនុស្សដែលមានទុក្ខធុរ: ឬ ទីពាល់ក្រ ត្រជាបត្រដួស មានកាយល្អដោយការធ្វើ

ឧបការៈចំពោះអ្នកដទៃ មិនមែនល្អដោយអាការណៈទេ មានដៃល្អដោយការបរិច្ចាគទានមិនមែនល្អដោយកងដៃ ឬ ខ្សែដៃទេ មានត្រចៀកល្អដោយការស្តាប់ត្រាប់ត្រងមិនមែនល្អដោយទំហូទេ មនុស្សបែបនេះចាត់ថាជាអ្នកមានលក្ខណៈស្ងប់នៅពេញខ្លួន ។

អស់លោកអ្នកខាំងឡាយ មានចិត្តស្ងប់ហើយឬ? សូមពិចារណាមើលខ្លួនឯងចុះ ។ បើចិត្តលោកអ្នកស្ងប់ពិតមែនហើយ លោកអ្នកមុខជាបានឃើញលក្ខណៈស្ងប់ នៅក្នុងខ្លួនលោកអ្នក ដូចជាធ្លើ និយាយនឹងគិតអ្វី កំដុំណើរទៅតាមផ្លូវដែលចំរើន ដែលរៀបរយដែលជាផ្លូវដើរបស់មនុស្សស្ងប់ មានអធ្យាស្រ័យត្រជាក់ត្រដុំ នឹងសុភាពរាបសាជាដើម ។ មនុស្សដែលមានចិត្តស្ងប់ហើយ រមែងមានជីវិតពេញទៅដោយផលដ៏ប្រសើរជាអណ្តើកតើតនៃសន្តិសុខនឹងសន្តិភាព មានកូមិធម៌សម្រាប់នៅដ៏ស្ងប់រៀបរយ ។ បើនៅក្នុងពួកណា ក៏ជួយបង្កសេចក្តីត្រជាក់ត្រដុំលែត់សេចក្តីក្តៅក្រហាយ ទុក្ខសោកម្លេះឯងគ្រប់យ៉ាង នឹងនាំយកសេចក្តីរុងរឿងថ្កុំថ្កើង សម្បូរសប្បាយសន្តិសុខ ចូលមកកាន់ពួកនោះ ។ បើទុក្ខជាថយចេញទៅ ក៏ធ្វើឲ្យពួកដែលនៅខាងក្រោយនោះ នាំគ្នាពុកសរសើរគុណ ។

២.— បិត្តិបអរសាទរ— អ្នកមានចិត្តឧបអរសាទរ ជាមនុស្សមានអធ្យាស្រ័យទូលំទូលាយ មានទឹកចិត្តអើពើមិនឃើញតែ

ប្រយោជន៍ចំពោះខ្លួន ជាមនុស្សយល់ចិត្តយល់ថ្លើមគេឯង ស្រឡាញ់រាប់អានគ្នា ជួយសង្គ្រោះឧបត្ថម្ភផងផ្តើមគ្នា មិនស្រាយកឲ្យបានតែខាងខ្លួន មានព្រហ្មវិហារ ៤ ជាផ្ទៃនៃអធ្យាស្រ័យ គឺមានមេត្តាប្រាថ្នាចង់ឲ្យអ្នកដទៃបានសុខ សូម្បីសេចក្តីសុខដែលគេត្រូវបាននោះ ឥតបានជាផលដល់ខ្លួនក៏ដោយ ក៏តាំងចិត្តជួយឲ្យគេបាន់សេចក្តីសុខសេចក្តីចំរើនកែលែងឡើងទៅ មានករុណាប្រាថ្នាចង់ជួយ មិនចង់ឲ្យគេបានទុក្ខ ឬ គេមានទុក្ខក្តៅក្រហាយ ក៏យកចិត្តទុក្ខជាក់ជួយឈឺឆ្អាល កំចាត់ទុក្ខវេទនា សូម្បីសេចក្តីទុក្ខដែលគេត្រូវបាន ឬបានហើយនោះ មិនជាប់ជាក់ចងនឹងខ្លួនក៏ដោយ ក៏តាំងចិត្តជួយឲ្យគេផុតទុក្ខនោះ, មានមុទិតាចេះរីករាយសប្បាយក្នុងកាលដែលគេបានសុខចំរើន ទុកជាខ្លួនមិនបានសុខចំរើនផង ឬត្រូវប់ខូចខឹងបត្ថូចតិចឆៅជាងគេក៏ដោយ ក៏តាំងចិត្តទុលបីតិត្រេកអរ រីករាយអនុមោទនាសាទរជាមួយនឹងគេ នឹងមានឧបេក្ខាមិនរីករាយក្នុងកាលឃើញគេបានទុក្ខ ទាំងមិនបន់ស្រន់ ប្លងសួងឲ្យគេវិនាសបាត់បង់សូម្បីអន្តរាយនោះ មិនខាក់ខាមនឹងខ្លួនឬខ្លួនត្រូវប់ឡើងថ្នាក់ខ្ពស់ហួសឆៅក៏ដោយ ក៏តាំងចិត្តជាកណ្តាលត្រង់ឯ។ មិនផ្តាសាផ្តន្ទាគេ ។

(មានត)

កណ្ឌទី ១១

ឧកញ៉ាវិបុលរាជសេនា ន្ធូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងវែឆ្លាសបើបានអាន
ទឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

លីឈុយក៏ឲ្យយកថាយដែលផ្អម នឹងសាច់គោស្មុយ ។ ប្រគល់ឲ្យទន្ទីនាំយកទៅថ្វាយ ។ ព្រះចៅហៀនតេឃើញដូច្នោះ ក៏ទ្រង់ព្រះក្រោធហើយត្រាស់ថា អាសត្រូវមើលងាយប្រមាថដល់អញខ្លាំងណាស់ ។

ខណៈនោះ អៀវពីរលបចូលទៅគាល់ ហើយក្រាបទូលឃាត់ថា លីឈុយមានចិត្តអាក្រក់ណាស់ គានេះព្រះអង្គនៅកងបង្គាប់ក៏ត្រូវតែទំអត់សង្កត់ព្រះទ័យសិនចុះ ។ ព្រះចៅហៀនតេមិនធ្វើយតបសោះ ទ្រង់ព្រះកន្សែងសោកាលតែស្នងព្រះអង្គនោះទឹកដោយទឹកព្រះនេត្រា ។

វេលានោះ មានមនុស្សលបចូលទៅ យកសេចក្តីក្រាបទូលព្រះចៅហៀនតេថា មានទ័ពលើកមកទន្ទួលស្តេច ។ ព្រះចៅហៀនតេប្រើទន្ទី

ឲ្យលបចេញទៅស្តាប់ការណ៍ ក៏ដឹងថាគុយគីលើកទ័ពមក ។ ព្រះចៅហៀនតេទ្រង់ព្រះដំរិះថា "គុយគីនឹងធ្វើអន្តរាយដល់យើងហើយ" ក៏រឹតតែទ្រង់ព្រះកន្ទែងឡើងទៀត ទទួលបានឆ្មាំឡងក្រៅកំពែង ស្រែកហ៊ោអឺអឺង ។ លីឈុយដឹងថាគុយគីលើកទ័ពមក ក៏ផ្តុតទ័ពលើកចេញទៅ ទើបយកវាគាតីសេះចង្កុលមុខគុយគីហើយស្រែកថា អញចិញ្ចឹមរក្សាឯងជល់ខ្ចាត ហេតុម្តេចឯងត្រឡប់គិតប្រមាថធ្វើអន្តរាយអញវិញ? ។

គុយគីតបថា ខ្ញុំឯងជាសត្រូវពដសម្បត្តិ ប្តូនជាអញគិតសម្លាប់ឯងចេញ ។ លីឈុយថា អញអញ្ជើញស្តេចព្រះចៅហៀនតេ ចេញមករក្សាទុក ហេតុម្តេចប្តូនជាឯងថាអញជាសត្រូវពដសម្បត្តិវិញ? ។ គុយគីតបថា ឯងឲ្យកូយហៅហានចូលទៅនាំស្តេចមក ធ្វើជាថ្នាំងធ្វើអន្តរាយព្រះអង្គចេញ លុះអញលើកទាហានតាមមក ឯងកែខ្ញុំនថានាំស្តេចមករក្សាទុក ។ លីឈុយទើងណាស់ស្រែកថា "កុំឲ្យក្តៅក្រហាយដល់សេនាទាហានឯទៀតឡើយ ឯងនឹងអញចេញមកតទល់គ្នាតែពួកចុះ បើឯងឈ្នះក៏នាំយកស្តេចទៅចុះ" ថាហើយបរសេះចេញទៅប្រយុទ្ធគ្នានឹងគុយគីប្តូន ១០ ភ្លេង មិនចាញ់មិនឈ្នះ ។

អៀវពីវដឹងថា អ្នកទាំង ២ កើតទោសទាស់គ្នាជាខ្លាំង ខុសពីគំនិតដែលគិតទុកនោះ ទើបនាំពួកនាហ្មឺនតូចធំប្រមែល ៦០ នាក់ ស្រូតរូតទៅ ឃើញលីឈុយគុយគីកំពុងច្បាំងគ្នា ។ អៀវពីវស្រែកឃាត់ថា

លោកតាំងពីរកុំច្បាំងគ្នាឡើយ ខ្ញុំទឹងនាហ្មឺនតាំងអស់គ្នាមកអង្វរសុំយាត់ឲ្យលោកតាំងពីរជាន់ឆ្នឹគ្នាដូចប្រក្រតីទៅវិញចុះ ។ លំឈុយគុយតីឃាន ស្តាប់ដូច្នោះ តាំងសង្ខាងក៏នាំតាហានត្រឡប់ថយរៀងខ្លួន ។ អៀវពីវនាំនាហ្មឺនតាំងនោះទៅតាមយាត់គុយតីៗ ឃើញនាហ្មឺនតាំងពួងមក ក៏បង្គាប់តាហានឲ្យចាប់ខ្លួននាហ្មឺនតាំងអស់ទៅដាក់គុកទុក ។ នាហ្មឺនតាំងអស់ប្រកែកថា យើងតាំងអស់គ្នាគ្មានទោសខុសពីអ្វីសោះ មកនេះគ្រាន់តែឃាត់ហាមលោកមិនឲ្យតាំងច្បាំងគ្នា ហេតុម្តេចបានជាយកយើងទៅដាក់គុកវិញ ។ គុយតីតបថា លីឈុយនាំយកព្រះចៅហៀនតេនឹងព្រះអគ្គមហេសីស្រីស្នំទៅឃុំឃាំងទុកខាងណោះ បានជាយើងត្រូវឃុំឃាំងអ្នកតាំងអស់ទុកខាងណេះ ។ អៀវពីវត្អើយថា បើលីឈុយនាំយកព្រះចៅហៀនតេទៅឃុំឃាំងទុកខាងណោះ ហើយលោកឃុំឃាំងយើងខាងណោះតើនឹងគិតធ្វើម្តេច? ។ គុយតីបានស្តាប់ទឹងណាស់ហូតគ្រប់ចេញប្រុងនឹងកាប់អៀវពីវ ខ្លួលតាហានគុយតីម្នាក់ស្ទុះទៅឃាត់ គុយតីក៏ឲ្យបើកលែងអៀវពីវនឹងដួហ៊ីចេញទៅ ក្រៅពីនោះក៏ឲ្យឃាត់ឃុំទុកក្នុងគុក ។ អៀវពីវនឹងដួហ៊ីដើរមកដល់កណ្តាលផ្លូវក៏ប្រឹក្សាគ្នាថា "យើងជានាហ្មឺនព្រះមហាក្សត្រ ខ្លួលបៀវត្សរ៍ដែលប្រោសព្រះពរជាន គ្រានេះព្រះចៅហៀនតេមានព្រះគ្រោះទៅវង្គុលំបាកជាទម្ងន់ណាស់ យើងនឹងក្រឡេចាលព្រះអង្គក៏ដូចមិនមានសេចក្តីកតញ្ញូសោះ ដូច្នេះត្រូវតែយើង

តិតទំនុកបំរុងផែនដី ឲ្យព្រះអង្គបានសេចក្តីសុខតទៅទើបគួរ" និយាយ ហើយក៏ក្រឡេកមកគ្នាយំតាល់តែដួលចុះក្នុងទីនោះ លុះដឹងស្មារតីក្រោកឡើងនាំគ្នាទៅទីលំនៅវិញខ្លួន ។ ឯដូហ៊ីនោះក៏មានជម្ងឺឈឺស្វាប់ទៅ ។

កាលលីឈុយនឹងគុយគីតតាំងប្លុំងគ្នានោះ ក៏ចេះតែប្លុំងគ្រប់ថ្ងៃមិនឈប់ប្រហែល ៤ ខែ ឥហានតាំងសង្ឃខាងសឹងស្វាប់វិនាសច្រើនណាស់ ។ ឯលីឈុយកាលនៅក្នុងបន្ទាយនោះដឿកាន់យកពាក្យ (អម៉ុតអថាវ) ។ កាសៀងឃាត់ហាមជាច្រើនគ្រាថា កុំឲ្យដឿស្តាប់ពាក្យមនុស្សជំពូកនេះ ។ លីឈុយមិនស្តាប់ ចង់ធ្វើអ្វី ក៏ធ្វើ (អថាវ) គ្រប់គ្រា ។

អៀវគីនាហ្វីនក្នុងហ្វូងដឹងដូច្នោះ ឡានលបចូលទៅក្រាបទូលព្រះចៅហៀនតេថា កាសៀងជាទីប្រឹក្សាលីឈុយ ការសៀងនិយាយការអ្វីលីឈុយមិនដែលធ្វើតាមសោះ ប្រហែលកាសៀងមានចិត្តស្វាមីភក្តិនឹងព្រះអង្គនៅទេឬយ សូមឲ្យហៅកាសៀងមកគាល់ហើយគ្រាស់ប្រាប់ពីកិច្ចការទាំងពួង ។ កំពុងតែនិយាយ ទន្លួលកាសៀងចូលទៅគាល់, ព្រះចៅហៀនតេទ្រង់ឲ្យបណ្តេញពួកខន្ធីទៅខាងក្រៅ ហើយទ្រង់ព្រះកន្សែងសោកពិលាបមានព្រះបន្ទូលនឹងកាសៀងថា "គ្រានេះយើងមានសេចក្តីទុក្ខលំបាកខ្លាំងណាស់ អ្នកចូរមានចិត្តស្វាមីភក្តិជួយធុរៈការផែនដីដោយសុចរិត ជួយយកអាយុជីវិតយើងឲ្យរួចផង ។

ការសៀងគ្រាបទូលព្រះនង្គ្លារថា សព្វថ្ងៃនេះ ទូលព្រះបង្គំជាខ្ញុំ គាំងចិត្តគិតធ្វើពុជការថ្វាយស្នងព្រះគេជព្រះគុណមិនមានក្លេចសោះ សូមព្រះអង្គកុំអាលត្រាស់ឲ្យសេចក្តីគាំងអស់បែកផ្សាយឡើយ ការគាំងនេះហើយជាភ្នាក់ងារទូលព្រះបង្គំជាខ្ញុំនឹងគិតឲ្យសម្រេច ។ ព្រះចៅហៀនតេទ្រង់រសាយព្រះទ័យ ទទួលលីឈុយកាន់គ្រប់ដើរចូលទៅ, ព្រះចៅហៀនតេក៏ស្តុតព្រះសតិ ។

លីឈុយក្រាបទូលព្រះចៅហៀនតេថា គ្រានេះ គុយគីគិតក្បត់នឹងព្រះអង្គ ចាប់ជាវាចាប់យកនាហ្មឺនច្រើននាក់ទៅដាក់គុកទុក ហើយវានឹងមកចាប់ព្រះអង្គយកទៅទៀត ដោយសារទូលព្រះបង្គំជាខ្ញុំនាំចង្រៃព្រះអង្គមក ចានជាព្រះអង្គរួចអំពីភ័យនេះ ។ ព្រះចៅហៀនតេយល់ថាពិតមែន ក៏គំនាប់លីឈុយហើយត្រាស់ថា ដែលអ្នកចានជួយខ្ញុំបត្តម្ភយើងជួរនេះ យើងមានអំណរគុណរកទីបំផុតគ្មាន ។ លីឈុយក៏ថ្វាយបង្គំលាទៅវិញ ។

ខណៈនោះហង៍ហ៊ូហៀបចូលទៅគាល់ព្រះចៅហៀនតេ។ ទ្រង់ព្រះដំរិះដឹងថា "ហង៍ហ៊ូហៀបមានសតិបញ្ញា ហើយធ្លាប់នៅស្រុកជាមួយគ្នានឹងលីឈុយ" ទើបទ្រង់មានឡាយព្រះហស្តលេខាឲ្យទៅហាមឃាត់លីឈុយគុយគីកុំឲ្យទាស់ទែងគ្នាតទៅ ។ ហង៍ហ៊ូហៀបទទួលយកឡាយព្រះហស្ត ហើយចូលទៅរកគុយគីក្នុងបន្ទាយ ។ គុយគីឃើញឡាយ

ព្រះហស្តហើយនិយាយថា បើលើឈុយបើកលែងព្រះចៅហៀនតេចេញ, យើងនឹងលែងពួកនាហ្នឹងដែលឃុំទុកនោះចេញដែរ យើងនឹងលើឈុយក៏នឹងប្រគល់គ្នាតទៅ ។ ហង់ហ៊ូហៀបបានស្តាប់ហើយ លាត្រឡប់ទៅរកលើឈុយក្នុងបន្ទាយនិយាយថា ខ្ញុំនឹងលោកជាពួកនៅស្រុកជាមួយគ្នា បានជាព្រះករុណាប្រើខ្ញុំឲ្យកាន់ឡាយព្រះហស្តនេះ មកហាមឃាត់លោកនឹងគុយគីកុំឲ្យតតាំងច្បាំងគ្នា ឯខាងគុយគីព្រមស្តាប់ព្រះតម្រាស់អស់ហើយ នៅឡើយតែខាងលោកឯនេះនឹងថាដូចម្តេច? ។ លើឈុយតបថា យើងបានទំនុកបំរុងមក ៤ ឆ្នាំហើយ សេចក្តីគាប់ប្រសើរក៏មានជាច្រើន, គុយគីគាន់តែជាមនុស្សកំណាចដើរលួចសោះ មកបានឡើងដល់ប៉ុណ្ណោះមិនគួរនឹងប្រកាន់ខ្លួនជាធំ ហើយយកនាហ្នឹនទាំងពួងទៅឃុំទុកក្នុងគុកហើយប្រទូសរ៉ាយដល់យើងៗ នឹងសម្លាប់រាចេញឲ្យបាន ។

ហង់ហ៊ូហៀបតបថា កាលគ្រាតាំងតុ:លើកខ្លួនជាធំនោះមិនបានធ្វើឲ្យទាហានម្នាក់ឈឺចសោះ តែចាប់គ្រោះគ្រៃលើប៉ោគ្មានកត្តញ្ញូ លបសម្លាប់តាំងតុ:បាន សព្វថ្ងៃនេះអាណាខ្លួនក្នុងគ្រៃទៅមិនទាន់ពេញបានប៉ុន្មានទេ លោកកុំអាលគ្នេរថាខ្លួនលោកជាធំជាងគេនោះឡើយ, ប្រការមួយបងប្អូនញាតិសន្តានរបស់លោក បានធ្លាក់ជាការជានាហ្នឹនមុខមន្ត្រីទាំងអស់ ព្រោះព្រះចៅហៀនគេទ្រង់ប្រទាំសប្រទានឲ្យលោកមានបណ្តាសក្តិជាធំដល់ខ្នាត ហេតុម្តេចលោកយកព្រះអង្គទៅបង្ខាំងទុកដោយអំណាច,

គុយគីយើញលោកធ្វើដូច្នេះ ចានជាយកនាហ្នឹងទាំងនោះទៅឃុំក្នុងគុក ដូចគ្នា លោកទាំងពីរនេះសុទ្ធតែជាអ្នកខំនុកបំរុងផែនដីរៀងមក ដែលមក ធ្វើដូច្នេះ មិនត្រូវសោះ នឹងថាខាងណាខុសខាងណាត្រូវក៏នៅថាមិន ចាន សូមឲ្យលោកវិនិច្ឆ័យគិតមើលចុះ ។

លីឈុយចានឮដូច្នោះក៏ងឹងលើសលុប ចាប់យកគ្រឿកាន់ហើយ ស្រែកគំហកថា ព្រះចៅហៀនតេប្រើខ្លួនឲ្យមកទ្រគោះចោះចោកឲ្យយើងឬ ចានជាខ្លួនហ៊ានិយាយដូច្នេះ? យើងនឹងកាត់ក្បាលខ្លួនឥឡូវនេះ ។ អៀវហង៍យើញដូច្នោះក៏ឃាត់ហាមថា ការដែលគុយគីនឹងលោកទាស់ទែង គ្នាជាធំមិនចាន់ដឹងដូចម្តេច គេចមកចង់សម្លាប់ហង៍ហ្ស៊ូហៀបជាព្រះពាជ បំរើទៀតមិនគួរសោះ បើសេចក្តីនោះដឹងទៅដល់អាណាខេត្តខាង ក្រៅ ហើយ មិនលែង ឡើយនឹងលើកទ័ពមកជួយខាងគុយគី ធ្វើឲ្យលោក ខ្វេចខ្វីមិនខាន ។ កាសៀង ក៏ចូលទៅឃាត់ហាមតាមសំដីអៀវហង៍ទៀត, លីឈុយក៏មិនបានសម្លាប់ហង៍ហ្ស៊ូហៀប, កាសៀង ក៏នាំហង៍ហ្ស៊ូហៀប ចេញទៅ ។ ហង៍ហ្ស៊ូហៀបស្រែកប្រកាសថា លីឈុយធ្វើការអាក្រក់ ណាស់ មានព្រះតម្រាស់បង្គាប់មកក៏មិនស្តាប់សោះ, ដែលធ្វើដូច្នោះប្រុង នឹងដណ្តើមយកពាជសម្បត្តិហើយ ។

ឧមៅពុហើយក៏ឃាត់ហាមកុំឲ្យនិយាយថាដូច្នេះ ក្រែងនឹងមាន អន្តរាយមកដល់ខ្លួន ។ ហង៍ហ្ស៊ូហៀបមិនស្តាប់ស្រែកគំហកថា "ខ្លួនជា

មន្ត្រីស៊ីប្រាក់ប្រៀតត្បៃដែលគ្រោសព្រះពាជទាន ឥឡូវនេះព្រះចៅហៀនតេ
មានទុក្ខលំបាកផ្សាល់ព្រះអង្គដូច្នេះ យើងជាខ្ញុំពាជការមិនត្រូវស្តាយជីវិត
ត្រូវតែគិតបស្ចង់ព្រះតេជព្រគុណ ខ្លួនមកនិយាយដូច្នេះ ជាមនុស្ស
អកតញ្ញូណាស់ ឬខ្លួនជាពួកអាក្បត់ដែរ” ថាហើយក៏ស្រែកដេរលើ-
ឈុយជាពាក្យអាស្រូវគាសហើយដើរទៅ ។

ព្រះចៅហៀនតេទ្រង់ជ្រាប ក៏ឲ្យហៅហង៍ហ៊ូហៀបចូលទៅគាល់
ហើយត្រាស់ថា អ្នកនឹងនៅក្នុងស្រុកក្រង៍នេះមិនបានទេ អន្តរាយនឹង
មានដល់ខ្លួនអ្នក បើដូច្នេះត្រូវតែដោះចេញឲ្យផុត ចូរទៅនៅស្រុកស៊ីឡុង
ចុះ ។ ហង៍ហ៊ូហៀបបានស្តាប់ព្រះតម្រាស់ក៏ក្រាបថ្វាយបង្គំលា ហើយ
និយាយបបួលពួកទាហានលីឈុយដែលមកពីស្រុកស៊ីឡុងថា លីឈុយ
គ្រានេះធ្វើការទុច្ចរិតគិតក្បត់ផែនដីហើយ អ្នកទាំងឡាយនៅជួកគោន
នឹងវាមិនបានទេ ម៉ោនៅហើយអន្តរាយទាំងពួងក៏គង់នឹងមានដល់ខ្លួន ។
ទាហានទាំងពួងបានឮហង៍ហ៊ូហៀបប្រាប់ដូច្នោះ ក៏គិតភ័យណាស់ នាំ
គ្នារត់ចេញពីផ្ទះលីឈុយទៅជាច្រើន ។

លីឈុយបានដឹងដំណើរក៏ច្រៀអង្វៀងលើកទាហានតាមចាប់ហង៍-
ហ៊ូហៀបមកវិញ ។ អង្វៀងលើកតាមទៅដល់តណ្តាលផ្លូវក៏គិតថា
“ហង៍ហ៊ូហៀបជាមនុស្សសុចរិតពិតត្រង់នឹងផែនដី បើតាមចាប់ខ្លួនបានមក
លីឈុយក៏ឲ្យសម្លាប់ជាអសារឥតការ សេចក្តីគេហានិន្ទាក៏នឹងមានដល់ខ្លួន

យើង" គិតហើយក៏លើកទឹកត្រឡប់មកវិញ ហើយចូលទៅច្រាប់លើឈុយ ថា ខ្ញុំបានបានតាមហង៍ហ៊ូហៀបទៅរកមិនឃើញទេ ។ លើឈុយមិនបានថា ប្រការម្តេច ។ ខណ នោះកាសៀងចូលទៅគ្រាបបង្គំគាល់ព្រះចៅហៀនតេ ហើយទូលថា លើឈុយធ្វើការដ៏ធំនេះ ជាផ្លូវប្រទូសព្រ័យអាក្រក់ធំផែនដីទាំងអស់ អស់សេនាមហានសឹងតែប្រែចិត្តរត់ចោលលើឈុយជាច្រើន សុំឲ្យមានព្រះតម្រាស់ជាទុបាយយកចិត្តគាំងឲ្យលើឈុយឡើងជាមហាឧបរាជចុះ ទូលព្រះបង្គំជាខ្ញុំនឹងសុំគាំងចិត្តគិតការតទៅ ។ ព្រះចៅហៀនតេទ្រង់យល់ឃើញត្រូវផង ក៏តាំងលើឈុយជាមហាឧបរាជ ។ លើឈុយមានសេចក្តីសោមនស្សណាស់ហើយថា "យើងបានឡើងទីគ្រានេះក៏ព្រោះ (អម្ចាស់អថាវ) ជួយ" ថាហើយយកមាសច្រាក់ទំងន់គ្រឿងសំលៀកបំពាក់ឲ្យដល់ (អម្ចាស់អថាវ) ជាច្រើន ។ ឯមហានឯទៀតលើឈុយទំងន់បានឲ្យរបស់អ្វីក៏ទេសោះ ។

អៀវហង៍ឃើញដូច្នោះខឹងណាស់ ទៅនិយាយនឹងសង៍កោថា យើងជាមហានលើឈុយបានធ្វើការសឹកសង្គ្រាមមក កំច្រើនដងច្រើនគ្រា លើឈុយនឹងបានឲ្យរង្វាន់ជាគុណបំណាច់អ្វីគ្មានសោះ លើកយករបស់ទៅបំពេញឲ្យ (អម្ចាស់អថាវ) វិញ ។

សង៍កោតបថា យើងក៏មានសេចក្តីតូចចិត្តណាស់ដែរ យើងនឹងគិតសម្លាប់លើឈុយចេញ ហើយចូលទៅគាល់បំរើព្រះចៅហៀនតេវិញ

ប្រសើរជាង ។ អៀវហង៍យល់យើញត្រូវថា យើងនឹងទៅបញ្ចុះបញ្ចូលគាហានឲ្យបានច្រើន រៀល ៣ ថ្ងៃនេះ អ្នកនៅខាងក្នុងត្រូវប្រុងយកភ្លើងដុតបន្ទាយឲ្យឆេះឡើង យើងលើកគាហានចូលមកចាប់លើឈុយសម្លាប់ចេញ ។ សង៍កោយល់ព្រម អៀវហង៍ក៏ចេញទៅពន្យល់គាហានក្រៅបន្ទាយ ។ មានគាហានម្នាក់ដឹងសេចក្តីក៏ចូលទៅប្រាប់លើឈុយតាមដំណើរអៀវហង៍នឹងសង៍កោគិតគ្នានោះ ។ លើឈុយឲ្យចាប់យកខ្លួនសង៍កោបាន ហើយនាំទៅសម្លាប់ ។ ឯអៀវហង៍ហ៊ឺកហាត់គាហានបាន ចាំមើលដល់យាម ៤ ភ្លាយ មិនបានឃើញពន្លឺភ្លើងឆេះឡើងសោះ ក៏ឲ្យគាហានចាំងអស់សម្បុរទៅ ។ ខណៈនោះលើឈុយលើកគាហានចេញពីបន្ទាយចូលប្រទះនឹងកងទ័ពអៀវហង៍ ក៏តាំងច្បាំងគ្នា ។ ចាំងសង៍ខាងមានរបួសពិការស្លាប់ជាច្រើន ។ អៀវហង៍ឃើញថាកម្លាំងនឹងគេលពុំឈ្នះ ក៏នាំគាហានដែលសល់នោះរត់ចេញទៅទិសឯលិច ។

ឯគុយគីលើកវេហ៍ពលមកតតាំងច្បាំងគ្នា នឹងទ័ពលើឈុយគ្រប់ៗថ្ងៃ, គាហានលើឈុយស្លាប់រលីងអស់ទៅ ដែលសល់នៅក៏រត់ចេញទៅខ្លះ ។

(មានត)

ភាគទី ២

សម័យនគរធំ

ឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(ត)

ការចេញនៃព្រះមហាក្សត្រិយ៍— ការចេញនៃព្រះមហាក្សត្រិយ៍នោះ គឺចេញចាកព្រះពជនិវេសន៍ទៅឋានរដ្ឋសភា ដ៏តាំងនៅក្នុងព្រះបរមពជរាំង នឹងចេញទៅក្រៅព្រះបរមពជរាំង តាមគាល ។

រដ្ឋសភាក្នុងទីនេះ គឺជាទីប្រជុំគ្រាបបង្គំគាល់របស់អ្នកពជការនឹងបណ្ដាពស្ត្រ ។ អ្នកពជការជាន់ខ្ពស់មានសេនាបតីជាដើម ត្រូវចូលទៅគ្រាបបង្គំគាល់នៅទីនោះជានិច្ចពាល់ថ្ងៃ, កាលបើមានហេតុការណ៍អ្វីដែលគួរគ្រាបបង្គំទូលដើម្បីឲ្យជ្រាប ក៏យកសេចក្ដីគ្រាបបង្គំទូលឡើង ។ ចំណែកពួកពស្ត្រ កាលអ្នកនីមួយកើតទុក្ខពុំសុខចិត្តពីរឿងអ្វី ហើយត្រូវការសុំព្រះពជវិនិច្ឆ័យ ក៏ត្រូវនាំគ្នាចូលទៅកាន់រដ្ឋសភា យកសេចក្ដីគ្រាបបង្គំទូលស្នើតាមដំណើរការណ៍, កាលឲ្យព្រះសណ្ដាប់ពាក្យស្នើហើយ ក៏ឲ្យវិនិច្ឆ័យសម្រេចតាមគួរនឹងការណ៍ ។ ប្រសិនគ្មានរឿងរ៉ាវផ្ទាល់ខ្លួន នោះនឹងចូលទៅគាល់ដើម្បីឃើញព្រះអង្គ ឬដើម្បីស្ដាប់សេចក្ដីព្រះពជវិនិច្ឆ័យក៏បាន ។ ព្រះពជពិធីធំៗ ដែលជាចំពូកព្រះពជពិធីគ្រា-

ទេសមាស កំត្រូវប្រដុំធ្វើនៅទីនេះ, ក្រៅពីពួកបរទេសដែលត្រូវការចូលក្រាបបង្គំគាល់ កំត្រូវចូលគាល់នៅក្នុងវដ្ឋសភានេះដែរ, ធៀបតាមទំនៀមទម្លាប់បច្ចុប្បន្ន ដូចព្រះទីន័ងទេវាវិនិច្ឆ័យ ។

វដ្ឋសភាសម័យក្រុងយសោធរៈបុរៈ តាំងនៅខាងមុខទ្វារព្រះបរមរាជវាំងជាន់ក្នុងទិន្នៅខាងលិចទីព្រះលាន, សព្វថ្ងៃនៅមានសំណេរសំណល់ជាកស្តូតាង គឺផ្ទៃទី ទិន្សសរខ្លះ, ។ តាមផែនទីនោះសង្កេតឃើញថា រូបវដ្ឋសភានោះ សណ្ឋានប្រហែលកេងថែវតាំងនៅទទឹងថ្ងៃបណ្តោយប្រមាណជាង ១០០ ម៉ែត្រ ទទឹងប្រមាណជាង ២០ ម៉ែត្រ គេលើកជាផ្ទៃខ្ពស់ឡើងប្រមាណជាង ១ ម៉ែត្រ ហើយទើបសង់វដ្ឋសភាលើផ្ទៃនោះ ។ តួវដ្ឋសភា សសរថ្ម ៤ ជ្រុង ប្រក់សំណ ឬក្បឿង? មានជណ្តើរឡើងពីខាងមុខ ៣ ពីខាងក្រោយ ៣ មានទ្វារ ៦ តាមចំនួនជណ្តើរ មានបង្អួចគ្រប់តាមចន្លោះសសរ ទ្វារនិងបង្អួចសុទ្ធតែបិទមាស មានកញ្ចក់ធ្នុះធ្នាំ ជាក់ដំកលលើសសរថ្ម ៤ ជ្រុងអមបង្អួច អំបាលនោះផង ។ តាមជំហរផ្ទៃទីពីខាងមុខ គឺសង់ខាងជណ្តើរតាំងបី ប្រដាប់ដោយក្បាច់រចនា និងរូបភាពផ្សេងៗ មានរូបដំរីនិងសីហៈជាដើម ។

រាជបល្ល័ង្កសម្រាប់ស្តេចគង់ តាំងនៅក្នុងវដ្ឋសភានេះ តែតាំងនៅត្រង់ណា មិនអាចដឹងច្បាស់ជាប្រាកដ, បើដោយសន្និដ្ឋានឃើញថាតាំងនៅត្រង់កណ្តាលស្រុងខាងក្បួងបំផុត ចៃរមុខទៅខាងដើង តាមបណ្តោយ

វដ្ដសភា, អ្នកចូលគាល់អង្គុយតំខាងដើង បែរមុខទៅរកពដបល្ង័ង្ក ។ ពដបល្ង័ង្កនោះចុងដោយសំពត់កាមញីក្រហមជាព្រះសាណិយា តែមានមុខសម្រាប់បើកបិទតាំង ៤ ទិស, លើផ្ទៃពដបល្ង័ង្កគ្រាលស្បែកពដសីហ៍ដែលជារបស់មានមកយូរហើយ, ផ្លូវឡើងទៅលើពដបល្ង័ង្ក មានតែតំខាងក្រោយ ១ ផ្លូវប៉ុណ្ណោះ ។

ស្តេចចេញប្លាជវដ្ដសភា - ពល់ៗថ្ងៃ បើស្តេចមិនទ្រឈួនឬមិនបានស្តេចយាងទៅក្រៅព្រះបរមពដកំងេ រមែងស្តេចយាងទៅប្លាន វដ្ដសភា ក្នុងមួយថ្ងៃ ២ វេលាជាដរាប ។ តាមសណ្ដាប់ព្រះមហាក្សត្រិយ៍កងសម័យនោះ វេលាស្តេចនឹងចេញចាកព្រះពដនិវេសន៍ រមែងទ្រង់កាន់ព្រះខ័នមាសខ្ចាប់នៅព្រះហស្តជានិច្ច ហើយពល់ពេលស្តេចចេញ គេតែងប្រគំក្លេង សូរក្លេងឮល្បើយៗ មកដល់វដ្ដសភា លុះផុតសព្ទក្លេងហើយ ទ្រង់ឡើងគង់វាសាស មានស្ត្រីក្រមុំ ៤ នាក់ សែងនឹងមានពួកស្ត្រីជាតម្រួតហែមុខ មានពួកស្ត្រីក្រមុំកាន់គ្រឿងពដបកោគហែតាមក្រោយ ។ ក្នុង ១ ស្របក់ ក៏ស្តេចយាងមកដល់វដ្ដសភា, ខណៈនោះ មានពួកព្រាហ្មណ៍ផ្ទុំសង្ឃទទួលថ្វាយជ័យ មានកុមារី ២ នាក់ឡើងទៅសើយបើកព្រះសាណិយាលើពដបល្ង័ង្ក, ផុតសំឡេងសង្ឃហើយស្តេចឡើងគង់លើពដបល្ង័ង្ក, ពួកមន្ត្រីខ្ញុំពដការនឹងបណ្ដាអ្នកចូលគាល់តាំងប៉ុន្មានថ្វាយបង្គំព្រមគ្នា ស្រេចហើយទើបព្រះមហាក្សត្រិយ៍ត្រាស់សួរពីសុខទុក្ខ នឹង ជំនុំការផែនដីតទៅ ។ (មានត)

រឿងអាវ៉ក្យថ្លែងរឿងផ្កែច្រា

លោកសាង-សារ៉ាត លេខាធិការ ក្រសួងបរិញ្ញាវត្ត

ប្រែពីភាសាចាវ៉ាំងមកជាខ្មែរ

(តមក)

រឿងទី ២

នៅឆ្នេរទន្លេជមនា(១) (Jamna) មានទីក្រុងមួយឈ្មោះដាម៉ូស្ថាល (Darmothal) ។ ស្តេចនៃក្រុងនេះព្រះនាម គុណាធីប (Gunadhip), នៅក្នុងសង្កាត់ក្រុងនេះ មានព្រាហ្មណ៍ម្នាក់ឈ្មោះកេស្ហាវ (Keshav) បានប្រព្រឹត្តសមណធម៌ នឹង បំពេញកិច្ចព្រះសាសនាទៅតាមឆ្នេរទន្លេនោះ ។ បុត្រីរបស់គាត់ឈ្មោះនាងមធុ-មាលិតី (Madhu-Maliti) មានរូបល្អអស្ចារ្យ ហើយមានអាយុដល់ខែត្រគប់ការផង ។ ឯមាតាបិតាបងប្អូនក៏យល់ថានាងល្អដែរ ។

មានថ្ងៃមួយ បិតារបស់នាងបានទៅកូនពិធីមង្គលការរបស់មិត្តភក្តិម្នាក់, ចំណែកឯបងរបស់នាងបានទៅអានគម្ពីរនៅផ្ទះអាចារ្យម្នាក់ ដែលនៅក្នុងភូមិមួយជិតនោះ ។ កាលជនទាំងពីរនេះចេញផុតទៅ កូនព្រាហ្មណ៍ម្នាក់បានទៅដល់ផ្ទះនាង ។ ឯមាតារបស់នាង កាលសង្កេតឃើញដំណែ នឹងរូបឆោមល្អឆើតឆាយរបស់ព្រាហ្មណ៍កម្លោះនោះ ក៏និយាយទៅនឹងថា "ខ្ញុំនឹងឲ្យកូនស្រីខ្ញុំទៅអ្នក" ។

---

១ ចិប់តែ យមុនា ទេដឹង? ។

ចំណែកខាងនុតុកនាងបានសន្យាថា នឹងឲ្យនាងទៅព្រាហ្មណ៍កំ-ឡោះម្នាក់ទៀត, បងប្រុសរបស់នាង ក៏បានប្តេជ្ញាថា នឹងឲ្យនាងទៅព្រាហ្មណ៍ម្នាក់ទៀត ដែលគេព្រមឲ្យប្អូនស្រីរបស់គេមកខ្ចីវិញដែរ ។ លុះកន្លងទៅច្រើនថ្ងៃ ជាខាងក្រោយមក នុតុកនឹងកូនប្រុស បាននាំយុវជនទាំងពីរមកផ្ទះខ្លួន ក៏ស្រាប់តែឃើញបុរសទី៣ទៅលើផ្ទះ ។ បុរសទី១ ឈ្មោះត្រីពិក្រម (Tribikram) ទី៣ឈ្មោះពាមាន (Baman), ទី២ឈ្មោះមធុសុទាន (Madhusudan) ។ បុរសទាំងបីរូបនេះ សុទ្ធសឹងតែមានរូបល្អ ទាំងចំណេះវិជ្ជានឹងប្រាជ្ញាក៏ស្មើៗគ្នា ។ ព្រាហ្មណ៍បិតាលុះបានឃើញបុរសទាំងនេះ ដែលមានចំណុចចំណង់ត្រង់គ្នាក៏រំពឹងគិតថា ស្ត្រីតែម្នាក់ មានបុរសអ្នកប្រតិព័ទ្ធផងដល់ទៅបីនាក់ ដូច្នេះតើអញគួរឲ្យអ្នកណា ? មិនឲ្យអ្នកណា ? ខាងគ្រួសារអញ៣នាក់ ប្រាកដជាព្រមព្រៀងឲ្យទៅម្នាក់ៗរួចទៅហើយ, នេះជាករណីដ៏ប្លែកចំឡែកណាស់ តើអញនឹងត្រូវលែងយ៉ាងណាទៅ ? ។ កន្លងណាដែលគាត់កំពុងអង្គុយជញ្ជឹងដូច្នេះ ខ្លួលមានឥសីពិសមកចឹកបុត្រីគាត់ស្លាប់ទៅ ។

លុះបានដំណឹងពីមរណភាពនេះ នុតុករបស់នាង បងប្រុសរបស់នាង នឹងបុរសសាមីខ្លួនទាំង៣នាក់ រួមជា៥នាក់ បានព្រមព្រៀងគ្នាទៅស្វែងរកគ្រូអាលម្ពាយទាំងឡាយ ដែលខ្លាំងពូកែអាចបន្សាបអាសុរិសឲ្យសាបសូន្យទៅបាន ដោយអំណាចឫទ្ធិនៃមន្ត ។ ជនទាំង៥នាក់

លុះបានចាត់ការព្យាបាលបែបនេះសព្វគ្រប់ហើយ ជីតាក៏មិនបាន
ត្រឡប់រស់ឡើងវិញដូចបំណងសោះ ។ ក្នុងគ្រូអំបាលនោះ គ្រូទី ១
បានថ្លែងហេតុថា "មនុស្សនីមួយៗ ដែលត្រូវពស់ចឹកក្នុងថ្ងៃទី ៥ ទី ៦ ទី ៨
ទី ៩ នឹងទី ១៤ គ្រូមិនអាចនឹងព្យាបាលឲ្យរស់ឡើងវិញទេ" ។ គ្រូ
ទី ២ ថ្លែងថា "ជនណាត្រូវពស់ចឹកក្នុងថ្ងៃសៅរ៍ ឬថ្ងៃអង្គារ គ្រូមិនអាចនឹង
ព្យាបាលឲ្យរស់ឡើងវិញឡើយ" ។ គ្រូទី ៣ អះអាងថា: "ពស់
ចឹកពិសចាប់កង់ថ្ងៃតាំងប៉ុន្មាន ដែលនៅកង់អំណាចតារាហិនី (Rôhini)
មាឃ (Magha) អាស្លេសា (Ashpsna) ពិសាខ (Bishakna) មូល
(Mul) នឹងក្រឹតិតះ (Kritita) គឺជាពិសដែលបណ្តាលឲ្យស្លាប់រហូតលែង
រស់វិញ" ។ គ្រូទី ៤ បានបញ្ជាក់ថា "បើកាលណាអវយវៈណាមួយ ដូច
ឃ្នាងបបូរមាត់ក្រោម ថ្ពាល កន្ទោះ ឬ សរសៃគោះ ត្រូវពិសឡើងដល់
ហើយ មនុស្សមិនអាចនឹងជាស់សេចក្តីស្លាប់ឲ្យរស់ឡើងវិញបានឡើយ"។
គ្រូទី ៥ ថា "ទោះបីខ្លួនលោកជាព្រះព្រហ្មវិញក៏ដោយ មិនអាចឲ្យលោក
រស់បានឡើយ" ។ តើយើងនឹងធ្វើម្តេចកើត? យើងសូមលាអ្នកសិន
ហើយ សុំឲ្យអ្នកគិតគូរធ្វើបុណ្យឈាបនកិច្ចតាមទម្លាប់ចុះ ។

លុះអះអាងរួចហើយ គ្រូអាលម្ភាយតាំងព្យាយនោះក៏ថយខ្លួន
ចេញទៅ ។ ចំណែកឯព្រាហ្មណ៍បាននាំយកសពនាងទៅកាន់ទីប៉ាន
មួយ ហើយបានចេញទៅចាត់ទៅ កងកាលក្រោយដែលដុតខ្មោចរួច ។

ក្រោយមក បុរសទាំងបីត្រឡប់មកដល់វិញ, បុរសទី ១ បានប្រមូលយកធាតុទាំងប៉ុន្មាននៅទីប៉ា នោះខ្ចប់យកទៅ ហើយតាំងខ្លួនជាអ្នកដើរសុំទាន ។ បុរសទី ២ បានប្រមូលយកផេះខ្ចប់បានមួយកញ្ចប់ ហើយបានសង់ខ្លួមមួយសំណាក់នៅកងទីនោះ ។ បុរសទី ៣ បានយកស្បង់មកស្ងៀកហើយស្ពាយថង់យាម ១ ផ្លាត់ទៅពីស្រុកមួយទៅស្រុកមួយ ។

ក្នុងថ្ងៃមួយ បុរសទី ៣ នេះបានទៅដល់ប្រទេសមួយហើយបានចូលទៅផ្ទះព្រាហ្មណ៍ម្នាក់ ដើម្បីសុំអាហារបរិភោគ ។ ឯព្រាហ្មណ៍ម្ចាស់ផ្ទះ ក៏បានអញ្ជើញឲ្យចូលបរិភោគជាមួយផង ។ ព្រាហ្មណ៍អ្នកដំណើរ លុះបានឮអ្នកម្ចាស់គ្រឹះស្ថានអញ្ជើញដូច្នោះ ក៏ចូលទៅអង្គុយលើផ្ទះ ។ កាលណាម្ហូបអាហារត្រៀមចំស្រេចហើយ ម្ចាស់ផ្ទះឲ្យព្រាហ្មណ៍នោះលាងដៃលាងជើង ហើយនាំទៅឲ្យអង្គុយក្នុងបន្ទប់មួយទាំងខ្លួនឯងក៏អង្គុយនៅទីនោះដែរ ។ ឯភរិយាអ្នកម្ចាស់ផ្ទះក៏មកបំរើដែនទាំងពីរ, កាលបរិភោគជាយថាន ប្រមាណពាក់កណ្តាល ស្រាប់តែកូនប្រុសតូចរបស់គាត់ក៏យំខ្លើង ហើយចាប់ជាយសំពត់របស់ម្តាយវ៉ា ទង់ទាញទុកមិនឲ្យទៅណា ។ ឯម្តាយខំប្រាន ប្រឡែះ តែកូននោះមិនព្រមលែងសោះ, នាងលួងលោមព្រមទាំងបញ្ជោតគ្រប់យ៉ាងហើយក៏នៅតែយំ, នាងព្រាហ្មណីខឹងក៏ចាប់កូននោះចោះទៅក្នុងគំនរភ្លើង ។ ផេះទៅជាផេះអស់ទៅ ។

ព្រាហ្មណ៍អ្នកដំណើរគាល់ឃើញដូច្នោះ តឹងទ្រូងខ្លាំងណាស់ដូច-ដង្វើមធំ ហើយគ្រាកឈរឡើង ។ អ្នកម្ចាស់ផ្ទះក៏សាកសួរអំពីហេតុដែលព្រាហ្មណ៍នេះមិនបរិភោគថ្ងៃ ។ ព្រាហ្មណ៍ឆ្លើយថា "តើអ្នកណាមួយហ្ន៎ អាចបរិភោគលេបរួចបាន បើនៅក្នុងផ្ទះមានអំពើយ៉ាងយោរយៅដូច្នេះ?" ។

ម្ចាស់ផ្ទះ លុះបានឮដូច្នោះ ក៏គ្រាកឈរឡើងដែរ ហើយដើរចូលទៅក្នុងបន្ទប់មួយទៀត យកក្បួន ១ ដែលជាតំរាស់ម្រាប់ច្រោះជីវិតដែលស្លាប់ហើយ ទើបស្វាធ្យាយន៍ពាយមន្តមួយស្របក់ទៅ, កុមារតូចនោះក៏រស់ឡើងវិញយ៉ាងអស្ចារ្យ ។ ចំណែកឯព្រាហ្មណ៍ដែលជាសាក្សីនៃការចំឡែកនេះ ក៏រំពឹងគិតក្នុងចិត្តឯងថា "ប្រសិនជាអញបានក្បួននេះអញនឹងច្រោះស្រីស្រស់ឱ្យរស់ឡើងវិញបានជាប្រាកដ" ។ កាលគិតដូច្នោះហើយ គាត់ក៏បរិភោគថ្ងៃតទៅទៀតហើយសំណាក់នៅក្នុងទីនោះ ។

លុះដល់ភត្តិ កាលបរិភោគអាហារល្ងាចហើយ រៀងខ្លួនក៏ដើរតម្រង់ទៅរកគ្រែដេកដោយសព្វខ្លួន ។ ព្រាហ្មណ៍អ្នកដំណើរចូលទៅសម្រាកក្នុងបន្ទប់មួយក្នុងផ្ទះនោះ ហើយនិយាយសន្ទនាគ្នាពីនេះពីនោះ ដកឋដល់ភាគធំនៃភត្តិកទ្វង់ទៅ ក៏លង់លក់ទៅ រៀវតែព្រាហ្មណ៍អ្នកដំណើរ មិនព្រមដេកឱ្យលក់ គ្រាន់តែសម្លឹងធ្លីហាក់ដូចជាដេកលក់, កាលគាត់ដឹងថា

តេដេកលក់អស់ហើយ ក៏ក្រោកឡើងលបចូលទៅក្នុងបន្ទប់ ១ ដែលទុកក្បួនច្បាប់ លួចយកបានហើយ ក៏រត់ទៅក្នុងព្រៃនោះ ធ្វើដំណើរទៅយ៉ាងស្រួតរួត តែគង់រៀលាជាច្រើនថ្ងៃ ទើបទៅដល់ទីប៉ាន់ដែលគេដុតសពធីតាព្រាហ្មណ៍ ឃើញព្រាហ្មណ៍ពីរនាក់ទៀត កំពុងនិយាយជជែកគ្នា ។ លុះព្រាហ្មណ៍ទាំងពីរក្រេកឃើញ ក៏ដើរចូលមកសួរយ៉ាងពាក់ព័ន្ធថា: "ចូរអ្នកច្បាប់យើងមើល! ព្រោះអ្នកបានត្រចស្ទះស្ទួនពីស្រុកមួយទៅស្រុកមួយ តើអ្នកបានចេះដឹងវិជ្ជាអ្វីខ្លះ" ។ ព្រាហ្មណ៍នោះឆ្លើយថា "ខ្ញុំចេះមន្តច្បាប់មនុស្សស្លាប់ឲ្យរស់ឡើងវិញ" ។ អ្នកទាំងពីរថា "ល្អហើយ បើអ្នកបានរៀនមន្តដូច្នោះមក ចូរអ្នកច្បាប់នារីដែលយើងស្រឡាញ់ទៅមើល" ។ ព្រាហ្មណ៍នោះបង្គាប់ថា "ចូរអ្នកទាំងពីរប្រមូលផែនឥដ្ឋឥដ្ឋរួមមួយគំនរឡើង ខ្ញុំនឹងច្បាប់ឥឡូវនេះ" ។ អ្នកទាំងពីរក៏ប្រមូលបានភ្លាម, ព្រាហ្មណ៍ក៏យកគម្ពីរមន្តមកសូត្រសែកជាសំមួយស្របក់ នាងនារីក៏រស់ពនមានជីវិតក្រោកឈរឡើងនៅចំពោះមុខ ។

ប៉ុន្តែព្រះកាមបានធ្វើអ្នកទាំងបីឲ្យភ្លាក់ទៅ ហើយក៏ចេះតែឈ្លោះប្រកែកជជែងគ្នា ។

កាលអាត្មាកំពុងនិយាយដំណាលមកដល់ត្រង់នេះ ក៏បែរទៅទូលសួរព្រះមហាក្សត្រិយ៍ថា "សូមទ្រង់ព្រះមេត្តាប្រោស! សូមព្រះអង្គទ្រង់វិនិច្ឆ័យមកមើល! កូនជនបីនាក់នោះ តើនរណាត្រូវបានគាង?" ។

ព្រះមហាក្សត្រិយ៍ត្រាស់ថា "នាងនោះត្រូវបានទៅព្រាហ្មណ៍ដែលសង់ខ្លួមសំណាក់នៅក្នុងទីប៉ាងានោះ" ។

អាវ័ក្សថា "បើព្រាហ្មណ៍ម្នាក់មិនបានរក្សាជាតុនាងទុក តាំងព្រាហ្មណ៍ទី ២ ក៏មិនបានចេះមន្តច្រោះមក តើនារីនោះអាចរស់ឡើងដូចម្តេចបាន?" ។

ព្រះរាជាត្រាស់ថា "អ្នកដែលទុកជាតុ គឺបានបំពេញកវណីយកិច្ចខ្លួន ក្នុងឋានៈជាបុត្រ, - អ្នកដែលបានច្រោះដីរតស់ទុកជាផ្ទុកវបស់នាង, អ្នកដែលបានប្រមូលផែះជាតុ តាំងបានសង់ខ្លួមនៅក្នុងទីនោះផងត្រូវបាននាងជាភរិយា" ។

អាវ័ក្សបានឮព្រះមហាក្សត្រិយ៍តបដូច្នេះ ក៏ហោះត្រឡប់ទៅឯដើមឈើរបស់ខ្លួនវិញ ។ ព្រះរាជាក៏ស្តេចទៅតាមចាប់អាវ័ក្សនោះចែកថង់យាមពាក់លើព្រះអង្សា ហើយយាងមកវិញ ។

(មានត)

អនិច្ចកម្មនៃព្រះទេពមុនី យូរ-ប៉ុណ្ណា

ព្រះទេពសត្តា សូរ-បាយ

ក្រុមដំនុំព្រះវិត្តបិដក នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

ព្រះទេពមុនី យូរ-ប៉ុណ្ណ វត្តទណ្ណាលោម ជាភជាគណៈថ្នាក់ទី ៤ ទទួលអនិច្ចធម្មនៅថ្ងៃអាទិត្យ ២ កើតខែស្រាពណ៍ ព.ស. ២៤៨៤ (១៩ សីហា ១៩៤១) វេលាម៉ោង ១១ ទឹង ៤០ នាទី ដោយកេតបេះដូងពិការ (ឈឺចាប់) ។

ពុទ្ធបរិស័ទតាំងបព្វជិតតាំងគ្រហស្ថ មានសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកព្រះនាម ជួន-ណាត ជាប្រធាន បានរៀបចំដាក់សពព្រះទេពមុនីទុក ៧ ថ្ងៃ នៅលើកុដិចាស់របស់សម្តេច ដើម្បីធ្វើទក្ខិណានុប្បទានរៀងរាល់ថ្ងៃភ្លាល់យប់ គឺ:ពេលថ្ងៃ និមន្តព្រះសង្ឃចំនួន ៦០ អង្គ ទទួលសង្ឃភត្ត, បង្សុកូល; ពេលយប់ និមន្តព្រះធម្មថឹកសំដែងធម្មទេសនា ជាក់ទៀបសពសព្វ ត្រឹមបំពងសំឡេង ។

កងកុដិដាក់សពនោះ មានត្រឹមប្រទីបផ្លាលា មានការតាក់តែងភ្លើងដោយពណ៌ ៥ មានភ្លើងពណ៌ខៀវជាដើម ព្រមទាំងត្រឹមគន្ធមាលាផ្កាក្រងផ្សែងៗ អំពីខាងលើនឹងព័ទ្ធដុំវិញក្តារមួស ។

ធ្វើឈាបនកិច្ច (បូជាសព) នៅថ្ងៃសៅរ៍ ៨ រោចខែស្រាពណ៌នោះ, វេលាម៉ោង ៤ រសៀល ព្រះសង្ឃភាជាគណៈ ឋានានុក្រម កិត្តិសាម-ណេរចំនួន ៨០០ អង្គ ក្នុងវត្តទាំងពីរ ព្រមទាំងអស់លោក អ្នកសប្បុរសជាគហស្ថ បានមកជួបជុំគ្នាដង្ហែសពអំពីកុដិយក ទៅដំកល់លើបាំពំកំពូលដែលរចនាដ៏វិចិត្រនៅមុខវិហារវត្តទាំងពីរ។ ក្នុងឧកាសបូជាសពនេះមានពុទ្ធបរិស័ទជាច្រើននាក់ មានឯកឧត្តម ហ៊ុយ-កន្ទុល អតីតរដ្ឋមន្ត្រី, លោកអ៊ូ-គង់ទីប្រឹក្សាព្រះរាជអាណាចក្រ ព្រមទាំងអស់លោក-អ្នកកង្ត្រីសួងពុទ្ធសាសនបណ្ឌិត្យ, ក្រសួងធម្មការ ទីធំសាលាចាស់ជាន់ខ្ពស់ជាដើម បានអញ្ជើញទៅជួយទ្រូលខ្ញាយអនុមោទនាដោយសេចក្តីសោមនស្ស។ លុះដំកល់សពលើបាំពំកំពូលរួចហើយ ទើបនិមន្តព្រះសង្ឃ ១០០ អង្គបង្សុកូល, បន្ទាប់មកព្រះពោធិវង្ស (ហួត-តាត) ថ្លែងសេចក្តីស្តាយស្រណោះចំពោះព្រះទេពមុនីដោយសេចក្តីសង្វេច។ បន្ទាប់មកទៀត លោកញង-សឿង ថ្លែងសុន្ទរកថា ក្នុងនាមពុទ្ធសាសន-បណ្ឌិត្យ ក្រុមដំទុំព្រះត្រៃបិដក ទីធំសាលាចាស់ជាន់ខ្ពស់ រៀបរាប់អំពីប្រវត្តិរូប ទីធំកិត្តិគុណនៃព្រះទេពមុនី ដោយសេចក្តីពិស្តារ។

ក្នុងឧកាសកំពុងបូជាសពនោះ បានប្រគេនចែកសៀវភៅជាវិរៈណកថាជាធម្មទាន ចំនួន ២.០០០សៀវភៅ ដល់បព្វជិតទីធំគហស្ថ ដើម្បីឧទ្ទិសកុសលធម្មទាន ប្រគេនចំពោះវិញ្ញាណក្ខន្ធនៃព្រះទេពមុនី។

សុន្ទរកថាដែលលោក ញូង - សឿង ប្ដែង

សម្តេច !

ព្រះករុណា គ្រប់អង្គ !

ព្រះតេជព្រះគុណនឹងអស់លោក - អ្នកពុទ្ធបរិស័ទ ចាំងឡាយ !

ខ្ញុំព្រះករុណាខ្ញុំបាទ ជាតំណាងនាមនៃព្រះថេរានុត្ថេរៈគ្រប់អង្គ, អស់លោក - អ្នកគ្រូសូងពុទ្ធសាសនបណ្ឌិត្យ, អស់លោកជាសមាជិកក្រុមដំនុំព្រះត្រៃបិដក នឹងលោកគ្រូ សាស្ត្រាចារ្យសាលាចាលីជាន់ខ្ពស់ ដែលបានអនុញ្ញាតឲ្យខ្ញុំព្រះករុណាខ្ញុំបាទ ថ្លែងរៀបរាប់ប្រវត្តិរូបនឹងកិត្តិគុណព្រមទាំងសេចក្តីសោកស្តាយ ចំពោះព្រះទេពមុនី យូរ - ប៉ុណ្ណ ដែលជាសមាជិកនៃក្រុមដំនុំព្រះត្រៃបិដក ព្រមទាំងការចូលកាន់មរណសញ្ញា ចំពោះវិញ្ញាណក្ខន្ធរបស់ព្រះថេរៈអង្គនេះ ដូចសេចក្តីតទៅ ៖

ប្រវត្តិរូបព្រះទេពមុនី យូរ - ប៉ុណ្ណ

ព្រះទេព៌មុនី (ឥន្ទសុវណ្ណ) យូរ - ប៉ុណ្ណ បិតានាមយូរ, មាតានាម ខៀវ, កើតនៅថ្ងៃ ៥ កើតខែបុស្ស ឆ្នាំខាលចត្វាស័ក ព.ស. ២៤៤៤, គ.ស. ១៩០២ ក្នុងឃុំកន្ទោរ ស្រុកកំពង់ត្រាច ខែត្រកំពត ។ កាលនៅពីកុមារ មាតាបិតាបាននាំយកទៅឲ្យនៅវត្តត្រៃពប់ ឃុំស្រុកខែត្រជាមួយគ្នា ដើម្បីឲ្យសិក្សាអក្សរសាស្ត្រខ្មែរតាមសម័យនិយម ក្នុងសំណាក់លោកគ្រូមេគណព្រះនាម មិន ។ កុមារយូរ - ប៉ុណ្ណ បានទទួលការសិក្សាអក្សរ,

លេខនព្វន្តល្មមមើលបាន សរសេរកើត ត្រមាំងធម៌អាថ៌ ។ លុះដល់អាយុ ១៣ ឆ្នាំ មាតាបិតាឲ្យបួសជាសាមណេរក្នុងវត្តព្រៃទប់នោះ, លោកគ្រូមេគណព្រះនាម មិន ជាព្រះឧបជ្ឈាយ៍ ។ កុមារ យូរ-ប៊ុណ្ណ បានទទួលបព្វជ្ជាជាសាមណេរ នៅថ្ងៃ ១៥ កើតខែពិសាខ ឆ្នាំខាលឆស័ក ព.ស. ២៤៥៦ ។ លុះដល់អាយុ ១៧ ឆ្នាំ ទើបលាចាកសិក្ខាបទពីសាមណេរ ។

បណ្ឌិតយូរ-ប៊ុណ្ណមានអាយុ ២១ ឆ្នាំ បានទទួលឧបសម្បទាជាភិក្ខុក្នុងព័ទ្ធសីមាវត្តអង្គស្រុកី ឃុំកន្ទោរនោរដែរ ។ មានឈ្មោះធម្មយោ ឥន្ទ-សុវណ្ណោ នៅថ្ងៃ ១៥ កើតខែទុតិយាសាធឆ្នាំចចត្វាស័ក ព.ស. ២៤៦៥, គ.ស. ១៩២៣, ព្រះបាឡាត់វតនមុនីសាគរ (ណាវ-ទិត) ជាព្រះឧបជ្ឈាយ៍, ព្រះសុវណ្ណត្ថេរ (ឈូក-សំ) ជាកម្មវាចាចារ្យ, ព្រះចន្ទត្ថេរ (ម៉ុម-សូរ) ជាអនុសាវនាចារ្យ ។

ភិក្ខុ យូរ-ប៊ុណ្ណ នៅក្នុងសំណាក់ព្រះឧបជ្ឈាយ៍បាន ២វស្សាគឺលោកគ្រូព្រះឧបជ្ឈាយ៍ លោកគ្រូសូត្រ មកសិក្សាព្រះបរិយត្តិធម៌នៅវត្តវិហារត្រាញ់ ឃុំព្រៃតស្វែង ស្រុកកណ្តាលស្ទឹង ខែត្រកណ្តាល, រៀនព្រះបរិយត្តិធម៌ក្នុងសំណាក់លោកគ្រូអាចារ្យព្រះនាម ប៊ុល-គង់ ជាចៅអធិការវត្តនោះ ។ ភិក្ខុ យូរ-ប៊ុណ្ណ បាននៅសំណាក់អាស្រ័យសិក្សាព្រះបរិយត្តិធម៌ក្នុងវត្តវិហារត្រាញ់នោះបាន ៤វស្សា, បានរៀនចប់គម្ពីរ

ធម្មបទដ្ឋកថាដោយសព្វគ្រប់ រួចលោកគ្រូអាចារ្យវត្តនោះ ត្រឡប់ទៅនៅឯវត្តស្រុកកំណើតរបស់ខ្លួនវិញ, បានទៅបង្រៀនសាស្ត្រាបាលី កិក្ខុ-សាមណេរឯវត្តអង្គសុរកីបាន ២ វស្សា ទើបលោកគ្រូចៅអធិការ ព្រះនាម ញ៉ង-ង៉ែត មកឯក្រុងភ្នំពេញ ។ ក្នុងកាលនោះលោកគ្រូចៅអធិការ ញ៉ង-ង៉ែត បាននាំលោកអាចារ្យ យូរ-ប៊ុណ្ណ មកផ្ទុកផ្តាក់ឲ្យនៅក្នុងសំណាក់សម្តេចព្រះមហាសុមេធាធិបតី កាលនៅជាព្រះសាសនសោភ័ណ ។ សម្តេចបានទទួលឲ្យនៅក្នុងកុដិជាមួយ ដោយសេចក្តីអនុគ្រោះ ។ អាចារ្យ យូរ-ប៊ុណ្ណ បានប្រឡងប្រជែងយកថ្នាក់រៀនក្នុងសាលាបាលីជាន់ខ្ពស់ពី គ. ស. ១៩៣៥, ប្រឡងចេញពី គ. ស. ១៩៣៨ បានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ។ ក្នុងឆ្នាំ ១៩៣៨ នេះក៏បានធ្វើជាក្រុមដំនុំព្រះវិនៃបិដក; បន្ទាប់មកបានឡើងសមណសក្តិជាព្រះសមុហ៍យោសាចារ្យ របស់សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក កាលនៅជាព្រះពុទ្ធយោសាចារ្យ, តមកបានឡើងជាព្រះឃោសាចារ្យ, តមកបានឡើងជាព្រះឧបាត្តពោធិកមរបស់សម្តេច កាលនៅជាព្រះពោធិវង្ស, លំដាប់មកទៀត បានឡើងជាព្រះវិនយធម្ម សម្រាប់វត្តទុណ្ណាលោម; ក្រោយមកទៀត បានឡើងសមណសក្តិជាពាជាគណៈថ្នាក់ទី ៤ ដោយព្រះរាជក្រឹត្យលេខ ១ ប៊. រ. ចុះថ្ងៃទី ២១ ខែឧសភា គ. ស. ១៩៤៨ ។

ព្រះទេពមុនី (យូរ-ប៊ុណ្ណ) ជាសមាជិកនៃក្រុមដំនុំព្រះវិនៃបិដក ជាសមាជិកនៃថេរសភាជាន់ខ្ពស់, ជាសមាជិកនៃក្រុមដំនុំប្រឡងសិស្ស

សាលាបាលីវេនឹងសាលាបាលីជាន់ខ្ពស់ ទាំងប្រឡងចូលនឹងប្រឡងចេញ, ជាសមាជិកនៃគណៈកម្មការតែងធម្មវិន័យ ។ ព្រះថេរៈអង្គនេះបានបំពេញកិច្ចការដែលត្រូវធ្វើ ដោយយកចិត្តទុកដាក់ឥតធ្វេសប្រហែសឥតខ្ចោះឡើយហាត់ ។ ដល់មកថ្ងៃអាទិត្យ ២ កើតខែស្រាពណ៍ (១៩ សីហា គ. ស. ១៩៥១) វេលាម៉ោង ១១ នឹង ៤០ នាទី ទទួលអនិច្ចធម្មដោយសុបសុខ្សឹម នៅលើកុដិតូចរបស់លោក ដោយពេតបេះដូងពិការ (ពេតខ្សាច់ចាប់) ក្នុងគំរប់ជន្មាយុ ៥០ ឆ្នាំ ។

កិត្តិគុណាព្រះទេពមុនីយ៉ូរ - ប៉ុណ្ណា
ធំដំសេចក្តីស្តាយនៃក្រុមជំនុំព្រះត្រៃបិដក

ព្រះគុណាគ្រប់អង្គ !

អស់លោក - អ្នកពុទ្ធបរិស័ទទាំងឡាយ !

ព្រះទេពមុនី យ៉ូរ - ប៉ុណ្ណានេះ ជាបព្វជិតដែលមានសណ្តាប់ធ្នាប់ល្អគួរគប់ថាជាអ្នកប្រាជ្ញមួយរូបខាងពុទ្ធសាសនា ក្នុងចំណោមអ្នកប្រាជ្ញទាំងឡាយ ។ ព្រះថេរៈអង្គនេះ មានចំណេះចេះដឹងរបៀបរៀបរយកាលកាសាបាលី ព្រមទាំងធម៌វិន័យដោយហ្មត់ចត់, ជាធម្មកថិកអាចចេះសំដែងធម៌ទេសនាទូន្មានពុទ្ធបរិស័ទបាន, ជាអ្នកមានសមត្ថភាពខាងធម៌អាចនឹងកិច្ចការទាំងពួង, បានទទួលទេសនាផ្សាយតាមវិស្សកម្មជាក្នុងក្រសួងយោសនាការជាញឹកញយ ។ ព្រះទេពមុនី ជាព្រះថេរៈប៉ុន

ប្រសប់, មានឮយ៉ាមក្នុងការតែងធម៌អាថ៌ផ្សេង។ ចុះក្នុងសៀវភៅ
ទស្សនាវដ្តី កម្ពុជសុរិយា ដើម្បីផ្សាយព្រះពុទ្ធសាសនានឹងអក្សរសាស្ត្រ
ជាដើម។ ។ ព្រះថេរៈអគ្គនេះ ឈ្មោះថាជាកម្លាំងដ៏មាំមួនរបស់ពុទ្ធ-
សាសនបណ្ឌិត្យផង រៀបរៀងវត្តខ្ញុំណាលោមនេះផង ។

ព្រះទេពមុនី! ព្រះគុណទទួលអនិច្ចធម្មនិមន្តទៅកាន់បរលោកនាយ
ចោលកិច្ចការពុទ្ធសាសនាអស់ហើយ ។ កិច្ចការទាំងនោះ យើងខ្ញុំ
ទាំងឡាយនឹងទទួលរ៉ាប់រងធ្វើជំនួស, សូមព្រះគុណម្ចាស់កុំព្រួយព្រះ
ទ័យ, សូមនិមន្តទៅកាន់បរលោកនាយដោយសុវត្ថិភាពចុះ, ព្រោះថាព្រះ
គុណម្ចាស់ត្រូវទទួលវេនរបស់មច្ចុសង្រ្គាមហើយ, សូមកុំតូចព្រះទ័យ
ចំពោះដំណើរទៅកាន់បរលោកនាយនេះឲ្យសោះ ព្រោះព្រះគុណម្ចាស់
បានបំពេញការណីយកិច្ចក្នុងព្រះពុទ្ធសាសនា ព្រមទាំងសង្រ្គោះញាតិ
មិត្រសិស្សគណៈដោយសព្វគ្រប់ហើយ ទាំងការបំរើព្រះពុទ្ធសាសនា
ក៏បានប្រគល់កាយថ្វាយទ្វេងជាបព្វជិត ឬជាព្រះពុទ្ធសាសនាផ្ទាល់ខ្លួន
ហើយ ។ ព្រះទេពមុនី! ជីវិតរបស់ព្រះគុណម្ចាស់ ឈ្មោះថាជាជីវិតមាន
ភ័ព្វណាស់, ជាជីវិតមានខ្លឹមសារប្រកបដោយឧត្តមគតិ ដែលគួរឲ្យបព្វជិត
យកតម្រាប់តាមបាន, ជាជីវិតមានសារៈប្រយោជន៍ក្នុងព្រះពុទ្ធសាសនា
ដោយការបំរើព្រះពុទ្ធសាសនាផ្ទាល់ខ្លួនពេញកំឡាំងដរាបមកហើយ ។

អស់លោក-អ្នកគាំង ឡាយ !

រូបដ៏វិតវបស់ព្រះថេរៈអង្គនេះ ទោះបីបាត់បង់ទៅក៏ពិតមែន តែកិត្តិ-គុណគឺកេរ្តិ៍ឈ្មោះល្អរបស់លោក មិនអាចបាត់បង់សាបសូន្យទៅឡើយ ។ ព្រះថេរៈអង្គនេះ មានដីវប្រវត្តិ នឹងកិត្តិគុណ ដែលគួរពុទ្ធបរិស័ទស្តាយអាល័យជាខ្លាំងបំផុត ។ ប្រវត្តិរូបនឹងកិត្តិគុណដែលយើងខ្ញុំបានថ្លែងមកនេះ ពុំតែជាអនុស្សាវរីយ៍មួយរបស់ពុទ្ធសាសនិកជនតទៅ, ព្រោះព្រះទេពមុនី ទទួលអនិច្ចធម្មទៅ តែរូបកាយប៉ុណ្ណោះទេ, ឯគុណនាមនឹងគោត្តគឺកេរ្តិ៍ឈ្មោះល្អរបស់លោក មិនបានទទួលអនិច្ចធម្មទៅផងឡើយ ។

មន្ទីរក្រុមជំនុំព្រះត្រៃបិដក ដែលធ្លាប់តែមានព្រះថេរៈអង្គនេះគង់នៅធ្វើការជាមួយគ្នានឹងយើងខ្ញុំ, ជាទីសប្បាយរីករាយ; ព្រះថេរៈអង្គនេះជាគូប្រឹក្សាជាមួយគ្នា នាំឲ្យក្តីគំនិតថ្កុំថ្កើង ឥឡូវនេះក្រសួងនេះខាតគូប្រឹក្សាមួយរូប, វត្តខ្ពង់ខ្ពស់នេះក៏ឈ្មោះថាខាតមហាថេរមួយអង្គដែរ ដែលនាំឲ្យខ្សោយអំណាចអ្នកវិស្ស ដូចជាពពកមួយផ្ទាំងធ្ងន់ធ្ងរពន្លឺព្រះអាទិត្យព្រះចន្ទ ឲ្យអន់រស្មីគឺថានាំឲ្យយើងខ្ញុំមានអាការរេរាមរាំរជួលក្នុងចិត្តស្ទើរតែគ្រប់ ៗ គ្នា ។

មច្ចុរាជដែលប្រើអំណាចរំលោភ ដណ្តើមយកជីវិតន្ទ្រិយរបស់ព្រះទេពមុនីនេះ មិនមែននាំឲ្យយើងគ្រាន់តែខាតបង់បុគ្គលិកក្នុងក្រសួងប្តូរក្នុងវត្តប៉ុណ្ណោះទេ គឺឈ្មោះថាមច្ចុរាជនេះ ជាអ្នកបំផ្លាញកិច្ចការផ្សេង ។

របស់មុខក្រសួងផង របស់ផ្ទាល់ខ្លួនផង ។ ក្រុមដំនុំព្រះវិតបិដកខាត
សមាជិកមួយរូប ជាដំនួយក្នុងកិច្ចការដែលត្រូវធ្វើតទៅទៀត ។ ការបាត់
បង់សហការីបុគ្គលនេះ នាំឲ្យយើងខ្ញុំក្នុងក្រសួងជាមួយគ្នា មានសេចក្តី
ទុក្ខតានតឹងស្តាយស្រណោះជាខ្លាំងផុត ។

ពេលនេះពុទ្ធបរិស័ទទាំងឡាយ ទាំងបព្វជិតទាំងគ្រហស្ថ បាន
មកប្រជុំគ្នាធ្វើឈាបនកិច្ច (បូជាសព) ព្រះទេពមុនី ។ មុនអំពីការ
បូជានេះ យើងខ្ញុំថ្លែងប្រវត្តិរូបនឹងកិត្តិគុណ ព្រមទាំងសេចក្តីសោក
ស្តាយ ដោយយើងខ្ញុំដែលធ្លាប់ស្គាល់ជាក់លាក់ បានចាំរូបរាងទ្រង់
ច្បាស់ព្រះភ័ក្ត្រនឹងសំដីឥតភ្លេចសោះ នឹកឡើងហាក់ដូចជាឃើញកំពុង
តែអង្គុយលើកៅអីសរសេរធ្វើការជាមួយគ្នា ។ ព្រះសង្ឃវត្តនេះ មាន
សម្តេចជាប្រធាន, កាលបើឥតអំពីព្រះទេពមុនីនេះ, ក៏មានសេចក្តី
ស្តាយស្រណោះរហោងរហាងក្នុងព្រះទ័យ ។ ព្រះថេរៈអង្គនេះមាន
សេចក្តីប្រកាន់តាមច្បាប់បញ្ញត្តិរបស់ក្រសួងដោយខ្ជិងខ្ជាត់ អំពីម៉ោង
ពេលដែលចេញចូលធ្វើការ, ព្រះថេរៈអង្គនេះ មុនអំពីទទួលអនិច្ចធម្ម
បានបំពេញករណីយកិច្ចរបស់សមណភាពផ្ទាល់ខ្លួន ព្រមទាំងរបស់
មនុស្សជាតិដ៏ពេញបរិបូណ៌សមគួរហើយ ។

ក្នុងគ្រាសដំកល់សពនឹងវេលាធ្វើឈាបនកិច្ចនេះ ពុទ្ធបរិស័ទបានធ្វើ
អាមិសទានឧទ្ទិសមគ្គផលដល់ព្រះភិក្ខុ ដើម្បីជាទក្ខិណានុប្បទាន ចំពោះ

ព្រះទេពមុនី ជានតំាងបោះពុម្ពសៀវភៅធម៌ ប្រគេនចែកជាធម្មទាន ចំពោះបព្វជិតនឹងគ្រហស្ថ ដែលបាននិមន្តបានអញ្ជើញមកជួយឧបត្ថម្ភ ទ្រព្យខ្លាយក្នុងបុណ្យនេះ ។ សូមប្រមូលបុញ្ញភាគីតំាងនេះ ទុកជាបណ្ណាការដ៏ប្រសើរ ឧទ្ទិសចំពោះព្រះទេពមុនី ។

ទីបំផុតនេះ សូមពុទ្ធបរិស័ទតំាងឡាយ តាំងចិត្តខមាទោសទន្ទឹង ឧទ្ទិសបុណ្យកុសលចំពោះព្រះទេពមុនីឲ្យគ្រប់ៗ គ្នា !

ព្រះទេពមុនី យូរ-ប៉ុណ្ណា ! យើងខ្ញុំតំាងឡាយសូមខមាទោសចំពោះព្រះគុណម្ចាស់ ដោយហេតុកែងយើងខ្ញុំមានសេចក្តីធ្ងន់ធ្ងន់លើសលោះ ដោយកាយវាចាចិត្ត, ដូច្នេះ សូមព្រះគុណម្ចាស់ឲ្យអភ័យអត់ទោសកំហុសនោះឲ្យទាន ។

យើងខ្ញុំជាពុទ្ធបរិស័ទ សូមប្រគេនបុណ្យកុសល ដោយចេតនាដ៏បរិសុទ្ធ ! សូមព្រះគុណម្ចាស់អនុមោទនាទទួលយកដោយសេចក្តីសោមនស្សឲ្យទាន ! ហើយសូមឲ្យព្រះគុណម្ចាស់ បានប្រកបដោយសុខភាព-វឌ្ឍនភាព មានជ័យមង្គលគ្រប់ប្រការ ក្នុងជីវិតថ្មីរបស់ព្រះគុណម្ចាស់ តាមសេចក្តីប្រាថ្នាតរៀងទៅ ! ។

ភាវនាមគ្គសន្ទិយា

ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៣ ខែធ្នូ លេខ ១២

ព. ស. ២៤៨៤ — គ. ស. ១៩៤១



ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
ពុទ្ធសាសនានឹងគ្រិស្តសាសនា (សន្និសិទ លោកវេដ្ឋបណ្ឌិតមីតូត៍) (ចប់)	លោកវ៉ាយ-ប៊ុក	៨៨៦
ពន្ធអាស៊ីទ្វីប (តមក)	លោកវ៉ាយ-ប៊ុក	៨៩៥
លោកបាលធម៌	ព្រះអរិយកស្សប តុង-ឈួន	៩០២
ភរិធម្មកាសិត	ព្រះមហា ឧម-ស៊ាត្រី	៩០៧
ផ្នែកអក្សរសាស្ត្រ		
សុភាសិតប្រៀនប្រដៅ	ព្រះមហា អ៊ុម-សុខ	៩១១
រឿងអាយោនទាហានចាស់	សាស្ត្រាចារ្យ ផេង-ជ្រឿ	៩១៤
ការបណ្តុះនិស្ស័យ (តមក)	ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម	៩២៥
រឿងសាមកុក (តមក)	ឧកញ៉ា ស៊ូ-កន	៩៣០
ព្រះភដ្ដារិកាវិភារប្រទេសកម្ពុជា (តមក)	ឧកញ៉ា ឈឹម-ក្រសេម	៩៣៨
រឿងអារក្សថ្លែងរឿងម្តែប្រាំ (តមក)	លោកសាង-សារ៉ាត	៩៤២
កំណត់ទីតិប្រវត្តិការណ៍		
ពិធីប្រឡងធម្មវិន័យ វត្តព្រះព្រហ្មរតន៍ ខែត្រសៀមរាប	ព្រះមហា កែ-អឿន	៩៥៣

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃដារ ១៤៥ រ. ០០

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

TABLE DES MATIÈRES

PARTIE RELIGIEUSE		Pages
Bouddhisme et Christianisme (Conférence du Doct. Migot) (suite et fin)	M. RAY-BUC	886
La Lumière de l'Asie (suite)	M. RAY-BUC	895
Lokapâladharma	Vén. Tong Chhuon	902
Kavidhammabhasita	M. Om Nakry	907
PARTIE LITTERAIRE		
Subhasita-prâdit-roeung	Vén. Oum Sok	911
Histoire d'Yon le soldat (conte roumain)	M. Pheng Chrieu	914
Education morale (suite)	Vén. PEUNG-PAM	925
Histoire de SAMKOK (suite)	Oknha NOU-KAN	930
Histoire du Royaume du Cambodge (suite)	Oknha CHHIM-KRASEM	938
Les vingt-cinq récits du mauvais Génie (suite)	M. SANG-SAVATH	942
NOTES ET CHRONIQUES		
Concours de Sortie de l'Ecole Dhamma-Vinaya à Vat Krapoum-Rat (Siamréap)	Vén. Ker Oeun	953

Prix d'abonnement annuel comprenant 12 numéros: 145$00

អំពីទស្សនាវដ្តី កម្ពុជសុរិយា ឆ្នាំ ១៩៥២
ផ្សាយចេញ
អំពីពុទ្ធសាសនបណ្ឌិត្យ

បងប្អូនរួមជាតិទាំងឡាយ ! សៀវភៅទស្សនាវដ្តី កម្ពុជសុរិយា ដ៏ជូចជាព្រះអាទិត្យខ្មែរមួយ សម្រាប់បញ្ចេញផ្លែ គឺអក្សរសាស្ត្រខ្មែរនិងពុទ្ធសាសនា ដែលពុទ្ធសាសនបណ្ឌិត្យធ្លាប់បានចេញផ្សាយរាល់ខែរៀងរាល់ឆ្នាំ ជាយូរឆ្នាំមកហើយនោះ, កន្លងឆ្នាំ ១៩៥២ នេះ នឹងចេញផ្សាយតទៅទៀត ។

សៀវភៅនេះ ជាសៀវភៅអក្សរខ្មែរ ដែលនឹងមានជីវិតចំរើនវែងឆ្ងាយទៅក្នុងអនាគត ដោយសារតែខ្មែរយើងបានមើលបានអានច្រើនគ្នាជាងសព្វថ្ងៃនេះ ។ ហេតុដែលនាំឲ្យខ្មែរបួលចិត្តមើលអានខ្លះសៀវភៅអក្សរខ្មែរ ច្រើនគ្នានោះ. មកពីខ្មែរមានសន្តានជាខ្មែរស្នេហាជាតិ ។ ព្រោះថាធម្មតា ជនណាដែលស្រឡាញ់ជាតិគេពិត ។ គេតែងស្រឡាញ់អក្សរសាស្ត្រនិងភាសារបស់គេ ។ ខ្មែរយើង បើស្រឡាញ់ជាតិយើង គោរលើកតំកើងអក្សរសាស្ត្រនិងភាសាយើងដោយកិច្ចខំរៀន ខំអាន ខំសរសេរ ខំនិយាយ ព្រមទាំងបង្ហាត់ប្រើអក្សរខ្មែរនិង

ភាសាខ្មែរជាផ្លូវការ ដែលទាក់ទងរវាងខ្មែរនឹងខ្មែរ មិនមែន ជើងធ្ងន់ជ្រួលរម្លងធ្ងន់គ្រែប ដូចសព្វថ្ងៃនេះទេ ។

ពុទ្ធសាសនបណ្ឌិត្យសង្ឃឹមទុកចិត្ត ចំពោះខ្មែរស្នេហាជាតិសម័យបច្ចុប្បន្ននេះ ថានឹងមិនបណ្តោយឲ្យអក្សរសាស្ត្រជាតិខ្លួនរលត់រលាយទៅទេ ទើបសូមជូនដំណឹងអំពីរឿងរ៉ាវ ផ្នែកសាសនានឹងផ្នែកអក្សរសាស្ត្រដ៏មានសារប្រយោជន៍សំខាន់ នឹង ពីរោះពីសាជល់អ្នកអាន ដែលបានគ្រោងទុកបម្រុងនឹងចុះផ្សាយ ក្នុងទស្សនាវដ្តី កម្ពុជសុរិយា ឆ្នាំ ១៩៥៦ ដូចមានរាយមាតិកាតទៅនេះ :-

ផ្នែកសាសនា

១ - ដំណឹងផ្សេង ។ ក្នុងព្រះពុទ្ធសាសនា

២ - ធម្មទេសនា ដែលមានអត្ថរសថ្លៃថ្កៅ ។

៣ - សីលធម៌របស់ព្រះពុទ្ធសាសនា

៤ - រឿងព្រះសូត្រនឹងបរមត្ថខ្លះ ដែលជាផ្លូវប្រតិបត្តិ ។

ផ្នែកអក្សរសាស្ត្រ

១ - អក្សរសាស្ត្រខ្មែរ (គោលចារឹកខាងផ្នែកអក្សរសាស្ត្រខ្មែរ ព្រមទាំងពាក្យកាព្យឃ្លោងចាស់ៗ ប្លែកនើប)

២ - ព្រះរាជឥស្សរិយយសកម្ពុជា ត ។ ត្រាតាមលំដាប់

៣ - ឯកសារ (រឿងរ៉ាវសំខាន់ៗ ដូចសិលាចារឹកជាដើម)

៤ - រឿងសាមកុក ត ។ គ្នាតាមលំដាប់ គ្រាតែចប់

៥ - វេស្សន្តរ (ពាក្យចុងក្រោយនៃរឿងជាខ្មែរបស់គណៈកម្មការវេស្សន្តរ)

៦ - សុភាសិតផ្សេងៗ របស់ជាតិយើងនិងនានាជាតិ

៧ - រឿងព្រៃនខ្មែរ ឬរឿងព្រៃនរបស់នានាជាតិ

៨ - រឿងទំនៀមទំលាប់ខ្មែរ របស់គណៈកម្មការទំនៀមទំលាប់ៗលៗ

ហេតុនេះ សូមអស់លោក អ្នកដែលមានបំណងជាវទស្សនាវដ្តីកម្ពុជសុរិយា ប្រចាំឆ្នាំ ១៩៥២ សូមធ្វើឈ្មោះចុះនាមទីលំនៅ និងប្រាក់ចំនួន ១៨៣ រៀលជាដំណែរជាវ ១ ឆ្នាំ ១២ សៀវភៅ ៧ អ្នកគ្រប់គ្រងនៃពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ M. le Secretaire général de l'Institut Bouddhique Pbom-Penh ក្នុងពេលឆាប់ៗ ដើម្បីប្រមូលនាមអ្នកជាវទៅគណនាឲ្យដឹងចំនួន ហើយនឹងចាត់ការចុះពុម្ពតាមចំនួននោះ ។

ថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ១៩៥១

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ពុទ្ធសាសនា និង គ្រិស្តសាសនា

សន្និសីទលោកវេជ្ជបណ្ឌិត មីគូត

លោក ភ័យ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីទស្សនាវដ្តី «ហ្វ្រង្ស-អាស៊ី» ខែមិថុនា ឆ្នាំ ១៩៥០

(តចប់)

ចំណែកខាងប្រទេសទាំងប៊ុន្មាន ដែលកាន់ព្រះពុទ្ធសាសនាសឹង មានសភាពផ្សេងខុសគ្នាពីនានាប្រទេសខាងលើនេះ ។ ព្រោះព្រះពុទ្ធ-សាសនា ជ្រាបជ្រាស្ថិតនៅលើវត្ថុធាតុ លទ្ធិសាសនាបូលទៅស្ថិតនៅក្នុង ជីវភាពតែប៉ុប, ពួកយោគាវចរដែលធ្វើសមាធិកម្មដាន ជាបុគ្គលដ៏ ឧត្តមស្ថិតនៅក្នុងក្រុមដែលមានតម្លៃក្នុងប្រជុំជន ហើយជាទីនិយមរាប់ អាននៃពួកនេះ ដូចខាងបច្ចុប្បន្នបុរេតែងរាប់អានសរសើរនូវពួកធនាគារិក: (Banquier) ទឹងអ្នកស្ងួតជំនាញខាងប្រជាល់ ។ នៅក្នុងពិភព-លោកគ្មានប្រជាពស្តែណាស្ងួតត្រង់ ដូចប្រជាពស្តែដែលកាន់ព្រះពុទ្ធ-សាសនា(១) ឡើយ គឺប្រជាពស្តែដែលមានចិត្តសន្តោសមេត្តាធ្យាយ

---

១ គេអាចតបតមកវិញបានថា មានប្រជារាស្ត្រដែលកាន់ព្រះពុទ្ធសាសនាខ្លះ ច្រើនធ្វើសង្គ្រាមនឹងគ្នាទៅវិញ-មក ដូចជាប្រជារាស្ត្រ ចិន, ជប៉ុន ហើយប្រជារាស្ត្រជប៉ុនត្រឡប់ជាប្រជារាស្ត្រពេញចិត្តខាងការធ្វើសង្គ្រាមទៅវិញ ។ ខ្ញុំអាចឆ្លើយទៅវិញថាប្រទេសទាំងពីរ ពិតមែនតែមានអ្នកកាន់ព្រះពុទ្ធសាសនាដោយភាគច្រើន, បើតាមខ្ញុំយល់ថា មិនមែនជាប្រទេស ដែលនិយមកាន់ព្រះពុទ្ធសាសនាពេញលេញទេ ។

តូង . . .

ផ្តួតផ្តាបជាទម្លាប់ ដែលមានចិត្តច្រណែនសេចក្តីស្អប់ អប់រំមកយូរ
ហើយ ។ ត្រូវតែយើងចាំជាក់ពីអតីតប្រវត្តិ, កាលពួកទីបេត៍តាំងនៅ
ជាអនារ្យជន (Barbares) ឬពួកមជ្ឈិមកូលក្នុងរដ្ឋកាលព្រះបាទសង់សិសខ័ន
ដែលមិនទាន់ចូលសិប្បក្នុងព្រះពុទ្ធសាសនានៅឡើយ, ឥឡូវព្រះពុទ្ធ-
សាសនាបានរចនាអធ្យាស្រ័យជនជាតិទាំងនេះ ទៅជាអ្នកស្មូតត្រង់ក្នុង
បច្ចុប្បន្នសម័យ ។ បើចិត្តសទ្ធាចំពោះពុទ្ធសាសនិកជនមិនទាន់មាន
ខ្នែងជាសង្គម មានសភាពដែលយើងធ្លាប់ស្គាល់ស្រាប់, ពួកនេះបាន
ព្យាយាមអប់រំមេត្តាចិត្តចំពោះសព្វសត្វ, ការពោរពេញវៃសេចក្តីទុក្ខលំបាក
របស់សត្វបានដោយអន្ទើ ។ ល គឺចិត្តមេត្តានោះឯង ដែលជាមូលហេតុ

នៅប្រទេសជប៉ុន, សាសនារបស់រដ្ឋគឺសាសនា "ស៊ិនតូ" ដែលកើតឡើងពីក្បួន
រណោសាស្ត្រខាងពួក "សាមូរៃ" ជាបុគ្គលអ្នកស្នេហាជាតិ, ជាវីរជន ពេញចិត្តខាងការធ្វើ
សង្គ្រាម បានអប់រំជាតិជប៉ុនឲ្យមានកិត្តិសព្ទល្បីល្បាញខាងរណោសាស្ត្រ ព្រមទាំងមានចិត្ត
សប្បុរស តែងជួយដោះទុក្ខអ្នកលំបាក អ្នកមានទោសភ័យ ។ ព្រះពុទ្ធសាសនា ជប៉ុនប្រើន
មានអាឧុភាពផ្សាយទៅកាន់ពួកគណៈសេន (Secte Zen) ។ នៅប្រទេសចិន ព្រះពុទ្ធសាសនា
គឺជាវត្ថុមួយរបស់សាសនា មិនអាចចូលទៅជ្រាបឲ្យជ្រៅដល់ប្រជាការចិនបានទេ; តែប្រជារាស្ត្រ
ចិនជាមនុស្សស្លូត ស្អប់ខ្ពើមសង្គ្រាម ហើយគ្រាន់តែជាអ្នករងគ្រោះសង្គ្រាម ដោយបៀសវាងមិន
ផុតប៉ុណ្ណោះ ។ មនុស្សដែលតាំងឲ្យមានសង្គ្រាម ពងទ័ព សុទ្ធតែមនុស្សថោកទាប អាក្រក់
ពាលទុច្ចរិត ជាសមាសភាពក្នុងចំណោមប្រជាជនទាំងមូល ហើយពួកចិនដែលស្ថិតនៅក្នុង
ត្រកូលខ្ពស់ គេប្រើនប្រមាថមើលងាយពួកទាហាននេះ ។ ត្រូវយើងបន្ថែមសេចក្តីទៀតថា
ប្រទេសទាំងពីរនេះ, ប្រើនឃើញខាងប្រទេសជប៉ុន តែងព្រុយយកវប្បធម៌ជាតិស៊ីវិល្យៃពីពួក
បច្ឆិមជាតិ ដែលផ្ទេរប្រើនតែសភាពណាមក មកឲ្យប្រទេសទាំងពីរ ។

នាំឲ្យកើតទុរ្ភេធមិស្សូតត្រង់ល្អ, មានឥទ្ធិពលដូចជាបុប្ផាផ្សាយគន្ធពិជោរ
ក្រអូបឈ្ងុយឈ្ងប់ ដែលអ្នកវស់ទៅ។ ប្រទេសកាន់ព្រះពុទ្ធសាសនា
ភ្លាមបានជួបប្រទះ ។ គឺជាអាកប្បកិរិយាសំដែងនូវសេចក្តីមេត្តាចំពោះ
សត្វលោកទូទៅ តាំងពីសត្វតូចឡើងទៅ, មេត្តាដែលជ្រួតជ្រាបទៅ
ក្នុងទឹកបេះដូង រមែងទោរទន់ជានិច្ចផ្សាយចេញតាមភ្នែក, តាមមាត់
ញញឹម, តាមការទទួលបដិសណ្ឋារៈដោយមេត្រីដែលជាហេតុឲ្យកើត
សន្តិភាពនេះ មានសភាពផុយនឹងការតស៊ូដើម្បីជីវិត (Struggle for life)
ចំពោះជាតិឯទៀតដែលអប់រំមកយូរហើយ ។ មិនមែនតែប៉ុណ្ណោះទេ,
ចំពោះធម្មិស្សូតត្រង់, មេត្តានោះ ប្រជាពស្ត្រទៅមានការព្យាយាមជា
និរន្តរកាល ដើម្បីតស៊ូនឹងអត្តទត្តភាព (Egoisme) ដោយមិនបានគិត
ថា មានតែខ្លួនអញមួយស្ថិតនៅក្នុងលោក, ថាមិនត្រូវឲ្យលោកធាតុមូល
ប្រព្រឹត្តឬតាមឆន្ទៈរបស់ខ្លួនអញ ឬតាមទំនើងចិត្តខ្លួនដែលត្រូវការ ។
នេះជាគុណធម៌ដ៏ឧត្តមខាងព្រះពុទ្ធសាសនា ។

ខ្ញុំបានពិសោធចំពោះចាប៥ក្បាលនេះ ដោយប្រៀបធៀបសាសនា
ទាំងពីរ, ប្បធម៌ទាំងពីរ, ហើយបល់នៃជីវភាពទាំងពីរថា តើយើងទាំងពីរ
អាចរឭនាវត្តទាំងពីរឲ្យរៀបចំបញ្ចូលមូលគ្នាតែមួយបានឬ? តើយើងអាច
ធ្វើឲ្យវត្តទាំងពីរជួយឧបត្ថម្ភគ្នាទៅវិញ-មក ឬត្រមៀងគ្នាជាឯកច្ឆន្ទ
បានឬ? ។ នេះជាបញ្ហានៃការគមនាគមន៍ ចំពោះបូព៌ាទ្វីបនឹងបច្ឆិមទ្វីប ។

ឡាក់គោលជាបឋមដើម្បីឲ្យប្រជាពុទ្ធបរិស័ទាំងពីរយោកយល់ស្រឡាញ់គ្នាទៅវិញទៅមក គឺត្រូវតែឲ្យអ្នកទាំងពីរស្គាល់គ្នាជាមុនសិន, ហើយត្រូវសិក្សាឲ្យយល់ច្បាស់លាស់នូវវប្បធម៌នៃសាសនាទាំងពីរទៅវិញ ។ តែការពាក់ព័ន្ធនេះចំនួនពីរសតវត្សរ៍មកហើយ, ពួកខាងបូពាក្វីបនឹងពួកខាងបច្ឆិមទ្វីប មិនទាន់ស្គាល់គ្នាគេញ្ញលេញទៅវិញទៅមកនៅឡើយ, ពិតមែនតែពួកបូពាក្វីបស្គាល់នូវស៊ីវិល្ហប្អអារ្យធម៌ខាងយើងច្រើន ជាងយើងស្គាល់អារ្យធម៌ខាងបូពាក្វីប ។ ការដែលល្ងង់មិនស្គាល់នូវរឿងរ៉ាវខាងបូពាក្វីប មកពីការយល់ថា ពួកអ្នកបច្ឆិមទ្វីបគាំងខ្លួនជាជាតិប្រសើរជាងពួកអ្នកបូពាក្វីប ដែលយើងបានសំដែងហេតុឲ្យជ្រាបសព្វគ្រប់មកហើយ ។ ពួកនេះយល់ថា: ស៊ីវិល្ហរបស់ខ្លួនមានតម្លៃជាងគេ, យល់ថាការស្គាល់នូវស៊ីវិល្ហនៃបូពាក្វីបជាការឥតប្រយោជន៍, ហើយយល់ថាស៊ីវិល្ហខាងបូពាក្វីបនេះមុខជានឹងសាបសូន្យ ហើយយកស៊ីវិល្ហខាងបច្ឆិមទ្វីបមកបង្ហាញលោកកពាំងមួលឲ្យបានឡើងទៅកាន់សន្តិភាព ។ រឿងនេះ ដូចកាលអ្នកនិពន្ធយ៉ាងចំណានម្នាក់នាមលោក គីថ (Gœthè) ដែលបានតែងរឿងរ៉ាវពីជាតិភ្លីស្ទាំង (Phlistins) ដែលលោកស្គាល់ចរិយារបស់ជាតិនេះពិតប្រាកដ ។

ចំណែកខាងព្រះពុទ្ធសាសនា, ពួកអ្នកបច្ឆិមទ្វីបគេមិនសូវចេះស្គាល់ ហើយថែមគេយកទៅបង្ហាញឲ្យខុសពីគោលការណ៍ដើមផង ។ ពួក

ទេសកជនខាងគ្រិស្តសាសនាដែលនាំ «សាសនាពិត» មកប្រដិស្ឋានទៅអាស៊ីខ្ញុំបនោះ មិនដែលស្គាល់នូវវប្បធម៌ ព្រមទាំងសាសនានៃប្រជាជាតិស្តីខាងបូពាំខ្ញុំប ។ ពួកនេះមានឆន្ទៈចង់ដឹកនាំពួកអ្នកបូពាំខ្ញុំបឲ្យចូលខាងសាសនារបស់ខ្លួន ហើយមានវិជ្ជាខាងសាសនាតែត្រឹមសញ្ញាណជាបឋមវិជ្ជា ដែលបានរៀនចេះចាំនូវគ្រិស្តសាសនស្ថាន ។ ពួកនេះ ហៅពួកអ្នកដែលកាន់សាសនាក្រៅពីខ្លួនថាជាពាហិរសាសនិក-ជន (Paien) ហើយថាគេជាទិដ្ឋិវិបត្តិ (Superstition) ព្រោះតែចំនេះដឹងនៃសាសនាគេគឺខ្លួនមិនអាចយល់បាន ព្រមទាំងយល់ថាពួកបូពាំជាតិជាពួកអនារ្យជន (Sauvages) ។ ខ្ញុំយល់ថាគួរបំពេញការណ៍យកចិត្តឲ្យប្រសើរជាងនេះទៅទៀត ។ យើងបានឃើញថា ចំពោះសីលធម៌ ឬបរមត្ថវិជ្ជា ឬសាសនវិជ្ជានៃព្រះពុទ្ធសាសនា មិនមែនជាមានសភាពថោកទាបជាងព្រះគ្រិស្តសាសនាទ្រោះទេ ។ ហេតុម្តេចក៏ទៅជាមានឆន្ទៈចង់ធ្វើឲ្យវិនាសនូវពុទ្ធសាសនា ដែលគេទុកជាសាសនាឯកក្នុងលោក ហើយជាបុព្វហេតុនៃវប្បធម៌ខាងបូពាំខ្ញុំប ព្រមទាំងស៊ីវិឡៃសិល្បវិជ្ជា, អក្សរសាស្ត្រ ទឹងធម៌មេត្តា, សូត្រត្រង់, សន្តិភាពទ្រោះទៅវិញ? ហេតុម្តេចក៏ចង់យកសាសនាជំនួសព្រះពុទ្ធសាសនាទៅវិញ? ដែលជាសាសនាតើតចំរើនរយៈវែងនានាការទៅសមុទ្រមេះតែក៏ណា ជាមូលហេតុឲ្យកើតលោកវិជ្ជា, តក្កវិជ្ជា ព្រមទាំងយោបល់ខាងទស្សនវិជ្ជា គឺជា

ខាងទស្សនវិជ្ជា តើជាវត្ថុក្រៅពីចិត្តានៃអ្នកបួសាំទ្វីប ដែលបានទាំមកនូវ
ធម៌ស្លូតត្រង់ ឬសន្តិភាពចំពោះពួកអ្នកបច្ចុមទ្វីប? ។ នេះជាគោលការណ៍
ពិសោធន៍ ដែលគ្រិស្តសាសនាមិនអាចចូលទៅសមាគមគប់យ៉ាងស្និទ្ធ
ចំពោះពួកបណ្ឌិតខាងព្រះពុទ្ធសាសនា, ចំពោះប្រទេសដែលកាន់ពុទ្ធ-
សាសនាដោយមាំមួន ។ ពួកគ្រិស្តសាសនិកជនអាចជឹកនាំបានតែពួក
ជនល្ងង់ខ្លៅ ដោយបង្ហាញនូវព្រះគ្រិស្តសាសនាផ្នែកខាងមនោសញ្ចេត-
នានឹងខាងពិធីក្រៅដែលមិនសូវមានសារៈប្រយោជន៍ ។

ខ្ញុំយល់ថា: មិនត្រូវជឹកនាំពួកអ្នកបួសាំទ្វីបឲ្យប្រតិបត្តិតាមសាសនា
ដែលមានសភាពក្រៅពីគំនិតអធ្យាស្រ័យនៃពួកនេះទេ ត្រូវតែជឹកនាំឲ្យ
ពួកនេះយល់ច្បាស់នូវព្រះពុទ្ធសាសនាទៅវិញ ។ ការដែលយល់ខុស,
ការដែលឃ្លាងគំនិតខាងផ្លូវសាសនា, កិច្ចដែលមិនស្គាល់ច្បាស់លាស់នូវ
សីលធម៌ធំសង្គមនៃពួកអ្នកបួសាំទ្វីប កើតឡើងដោយហេតុមកពីពួកនេះ
មិនសូវយល់នូវសាសនាបស់ខ្លួន ។ ពួកពុទ្ធសាសនិកជន ដែលជាអ្នក
មានសទ្ធាមាំមួនក្នុងសាសនា ចំពោះតែជនណាដែលមិនខាន់ជ្រួតជ្រាប
នូវវិជ្ជាខាងបច្ចុមទ្វីប, ឯពួកខាងគ្រិស្តសាសនាមានច្រើនជាអនេកប្បការ
តែទៅមិនខាន់ចេះដឹងគ្រប់គ្រាន់បរិបូណ៌ល្មមជឹកនាំពួកបួសាំជាតិ ឲ្យបាន
ចំរើនខាងផ្លូវប្រាជ្ញា ។ ក្នុងខ្នេះ, ចំពោះសហការនៃបួសាំទ្វីបទៅកាន់
បច្ចុមទ្វីបដែលនឹងមានផលដ៏ប្រសើរ គឺមកពីពួកបច្ចុមជាតិចេះប៉ិនប្រសប់

អប់រំពួកបូតាំជាតិឲ្យមានចំណេះខាងរបៀបវិជ្ជាសាស្ត្រ, ភ្ជួនភាសា-
សាស្ត្រ ទឹងជីវសាស្ត្រ (Philologie) ត្រមទាំងរចនាជនជាតិនេះ ឲ្យ
យល់ច្បាស់នូវកិច្ចការខាងពួង ដែលពួកជំនាញខាងជាតិអីរុបចានស្រាវ
ជ្រាវ ចំពោះវិជ្ជាអក្សរសាស្ត្រខាងព្រះពុទ្ធសាសនា ។ នេះហើយ
ដែលប្រទេសចាក់ចិត្តមានបំណងចង់ធ្វើឲ្យសម្រេចប្រយោជន៍ក្នុងរឿងនេះ
បានជាស្ថាបនាក្នុង គ. ស. ១៩៣០ នៅពុទ្ធសាសនបណ្ឌិត្យកុំពេញ
ដែលមានផលដ៏ប្រសើរ ចំពោះការរៀបចំជាថ្នូរលទ្ធិពុទ្ធសាសនាខាង
ហីនយាននៅកម្ពុជរដ្ឋ ។ វិជ្ជាស្ថាននេះ, ចានផ្តើមចោះពុម្ពព្រះត្រៃបិដក
ដែលចានចាត់ធ្វើឲ្យមានរបៀបរៀបរយ ត្រមទាំងសៀវភៅនិងអត្ថបទ
ខាងព្រះពុទ្ធសាសនាជាភាសាខ្មែរ ចេញផ្សាយរហូតគ្រប់កូមិ-ស្រុក-
និគមជនបទទាំងដាតផ្សាយ នឹងបើកសេរីភាពឲ្យពួកភិក្ខុ-សាមណេរនៅ
វត្តក្រៅនិមន្តមករៀននៅព្រះពាជធានីកុំពេញចំនួន ៣ ឆ្នាំ (១) រួចត្រឡប់
ទៅវត្តក្រៅសព្វៗ អង្គ ដើម្បីនឹងធ្វើគ្រូចាអាចារ្យផ្សាយនូវធម៌និន័យ
ចំពោះប្រជាពស្ត្រទាំងអស់ ។

នេះជាស្នាដៃដែលគួរធ្វើ ដើម្បីនឹងឲ្យបូតាំខ្ចីបនឹងបច្ចុមខ្ចីបឲ្យមាន
ការគោរពឯកានតែជាតិសន្ធស្នាលដោយមេត្រីភាព, ពួកអ្នកបច្ចុមខ្ចីប
ក៏អាចធ្វើការនេះប្រកបដោយអត្ថជនភាព ហើយមានប្រយោជន៍សំខាន់

---

១ បើតាមមាត្រា ២០ នៃអាណតេលោកគួរើរណើរសណោភ័លលេ។ ៨.៣៥១ ចុះថ្ងៃទី ១ ធ្នូ
១៩៤២, កំណាត់ ៤ ឆ្នាំទើបប្រឡងចេញបាន ។

ចំពោះមនុស្សជាតិទាំងមូល ដើម្បីចែករំលែកចំណេះដឹងចំពោះសហការទឹង
ព្រះសង្ឃខ្មែរឲ្យមានដំណើរទៅកាន់វឌ្ឍនភាព, មិនត្រូវទៅគិតចង់ផ្ទាស់ប្តូរ
សន្ដានចិត្តនៃមនុស្សជាតិដែលកាន់ព្រះពុទ្ធសាសនាឲ្យទៅជាចិត្តនិស្ស័យ
ខាងគ្រិស្តសាសនា ដែលជាសាសនាមិនអាចយកមកធ្វើឲ្យពួកអ្នកបូជា-
ទ្វីបមានចិត្តជ្រះថ្លាទៅបានដោយងាយ ។ រួចការដែលផ្សាយអំពីបច្ចុមទ្វីប
ទូរអនារ្យធម្មិកឯមហាសង្គ្រាមសាកលលោកពីរ ហើយមន្តអាទុភាពទៅ
គ្រប់ប្រទេស នាំឲ្យពួកអ្នកបច្ចុមទ្វីបមានចិត្តអន់ថយគ្រង់កិច្ចស្មើស៊ីរវៃ
ខ្លួនឲ្យយកមកអប់រំពួកអ្នកបូជាទ្វីប ។

បច្ចុមទ្វីបកាន់ខាងគ្រិស្តសាសនា ទឹងបូជាទ្វីបកាន់ខាងពុទ្ធសាសនា
មានផលប្រយោជន៍ដ៏សំខាន់ត្រង់ការជួយឧបត្ថម្ភគ្នាទៅវិញទៅមក, មិន
ត្រូវធ្វើសង្គ្រាមគ្នាទេ ; ពួកខាងបច្ចុមទ្វីបច្រើនមានចំណង់ទៅកាន់វឌ្ឍន-
ភាពខាងជាតុនិយម, ខាងថាមភាព, ខាងការទុកចិត្តចំពោះខ្លួន, ខាង
ការស្អប់ខ្ពើមផ្លូវប្លែកជាដើម, ខាងការចំណង់មាំរបស់ខ្លួន ហើយទឹងការ
រំលោភចង់ឲ្យប្រទេសដទៃនៅក្រោមបង្គាប់បញ្ជាខ្លួន ។ អំពើនេះធ្វើឲ្យ
ពួកបច្ចុមជាតិមិនអាចទទួលខុសត្រូវលំអនៃស៊ីវរវៃ ដែលមានដំណើរទៅកាន់
ផ្លូវប្លែកតែម្យ៉ាងឡើយ ។ កិត្យានុភាពកងការប្រើកំឡាំងមានសភាព
សម្បើមអស្ចារ្យនោះ គឺពួកបច្ចុមជាតិពេញចិត្តខាងសភាពសុខស្រួល
កាយ, សភាពឆើតឆោមកងលោក, ព្រមទាំងការសប្បាយខាងវត្ថុជាតុ

ទឹងការសប្បាយដោយកាមារម្មណ៍ ហើយអាចផ្ទេរទៅអនុភាពខ្លាំងក្លា ពន់ពេកឲ្យមកដល់នានាប្រទេសខាងបូព៌ាទ្វីប ។ មានបុគ្គលជាច្រើននាក់ ច្រើនក្បែចកិច្ចការខាងផ្លូវច្បាប់ ព្រោះធ្វើចិត្តឲ្យជាប់ចុះស្មុគស្មាញក្នុងគ្រឿងច័ក្រ, ពិតមែនតែគ្រឿងនោះ ជាវត្ថុអាចសម្រាប់ខ្លួនបាន, នាំឲ្យកើតសង្គ្រាម, សេចក្តីវិវាទខាងសង្គម ហើយនឹងកយន្តកយឆ្ងៃៗ ដែលមច្ចុមន្ទីបទុកជាការៈមួយ តែងអូសជាប់ស្អិតពីក្រោយពលភាពរបស់ខ្លួនទៅជាមួយផង ។ គេអាចសរសើរ ហើយកម្រឹងធ្វើបានទូទៅប្រទេសខាងអាស៊ីទ្វីបដែលរក្សាទុកនូវវិញ្ញាណក្ខន្ធដ៏បរិសុទ្ធស្អាត, ជាទីដ្រកអ្រស្រ័យនៃសន្តិភាពក្នុងពិភពលោកដែលកំពុងកង្វល់ជាខ្លាំង, ព្រមទាំងឃុំគ្រងស្ថានភាពរបស់ខ្លួនឲ្យនឹងនួនអស់យូរកាល ស្ថិតនៅក្រៅសំណាញ់នៃស៊ីវិលីហ្សេបច្ចុមន្ទីបនឹងកំសួលអាក្រក់ ។ តែបើតាមខ្ញុំស្មានថាមុខជាមិនយូរទេ ដៀមញ៉ីត្រូវបកបរិភោគជាមិនខាន ; តែសូមឲ្យវិនាសដ៏វិត មិនឲ្យវិនាសវិញ្ញាណក្ខន្ធទៀយ ។

ចប់សន្ទិសិទលោកវេជ្ជបណ្ឌិតមីតូត

ពន្លឺអាស៊ីទ្វីប

វគ្គទី ៣

La Lumière de l'Asie

លោក ស៊ីរ - អេតវ៉ាន អាណូលត៍ តែង

លោកវ៉ាយ - ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

ប៉ុមាហានយាម សឹងមានស្តេរដ៍យ៉ាយជាសញ្ញាផ្សាយដំណឹង ក្នុងពេលដែលព្រះសិទ្ធត្ថស្តេចយាងមកដល់ ។ នៅទីនោះ មានពួកព្រះពជ-វង្សានុវង្សជាច្រើនយាងទៅរង់ចាំទទួល នឹង សំដែងការគោរពជាច្រើនវិត ព្រមទាំងមានទាំងនាជកាចាំបាចបម្ចាគ្រប់យ៉ាង នឹង កាត់ព្រៀងថ្វាយជាព្រះកិត្តិយស, ព្រះទីនាំងអស្សតវដែលព្រះសិទ្ធត្តគង់មក នឹងត្រូវដើរលុយគំនរផ្កាកុលាប នឹងបាល់សាមីន (Balsamine) ប្រមាណត្រឹមជង្គង់ ។ ក្នុងពេលនោះ រីឆីទាំងនេះសុទ្ធតែបញ្ចេញនូវលំអគ្រប់យ៉ាង ទូទៅទាំងព្រះពជធានីទាំងមូល, ពុស្បូរសេពួគគ្រឹកគគ្រែងដោយក្លែងត្បូរជន្លឺ នឹងសេចក្តីសប្បាយលាន់ឮកងរំពងពាសពេញសព្វអន្លើ ។ នេះជាព្រះពជទង្ការរំនៃព្រះមហាក្សត្រិយ៍ ដែលទ្រង់ត្រាស់បង្គាប់ឲ្យចាត់ការ, ឯប្រជាកស្តេកំរង់ចាំស្តាប់សព្ទស្តេរដ៍យ ដែលគេទ្លង់ជាដំបូងផ្សាយដំណឹងជាអាណត្តិសញ្ញាថា "ព្រះពជទ្រសស្តេចយាងមកដល់" ។

តែព្រះនាងយសោធរា មានព្រះរាជបំណងចង់ប្រថាប់នៅពីមុខមហាជន ទើបស្តេចឡើងគង់លើព្រះទីនាំងយាងទៅកាន់កំពែងជាន់ក្រៅនៃព្រះរាជធានី ជិតសាលាប្រជុំនោះ ។ នៅជុំវិញមានព្រះរាជឧទ្យានឈ្មោះ "និគ្រោធ" មានរុក្ខជាតិបៃល (Bels) ឧទ្ធដើមល្មើ ដែលខាងលើមានធាងត្រសុំត្រសាយទៀរស្ងាត់ ចោលម្លប់ត្រឈឹងត្រឈៃ ដែលគេជាំជាដួរហូរហែ, នៅក្នុងទីផ្ទៃឧទ្យាននោះ មានផ្លូវបត់កិកកក់ខ្ចាត់ខ្ចែងពាសពាន់មានរុក្ខជាតិផ្សេងៗ គ្រប់បែប សឹងគ្មានផ្កាផ្លែ-រឹត ពុំស្អុះស្អាយ, តពីនោះទៅមានថ្នល់នៅពីខាងត្បូង, តាមចិញ្ចើមថ្នល់ជាំសុទ្ធតែរុក្ខជាតិដែលមានផ្កាក៏រឹតស្អុះស្អាយដែរ ។ នៅចិញ្ចើមថ្នល់ម្ខាងទៀត នៅក្រៅព្រះរាជធានីនេះ មានខ្មួមពួកប្រជារាស្ត្រជាពួកមានវណ្ណៈតាប (សូទ្រៈ) មានសេចក្តីក្រីក្រលំបាកច្រើន ដែលពួកក្សត្រិយ៍ទំងពួកព្រាហ្មណ៍ តែងហាមប្រាមគ្នាមិនឲ្យទៅជាក់ទងប៉ះពាល់កាយឡើយ ដោយក្រែងជាប់មន្ទិលសៅហ្មងជិតដោយមក ។

ពួកវណ្ណៈតាបនោះ ក៏បាននាំគ្នាតាំងបច្ចុសសម័យ រង់ចាំដោយចិត្តព្រួយបារម្ភពន់ពេក ហើយក្រឡេកមើលទៅផ្លូវឆ្ងាយលន្ទឹមលន្ទោចបំណងនឹងឡើងដើមឈើ ក្នុងខណៈដែលបានឮសូរសូរសៃម្រែកជំរំនឹងស្ងាត់ត្រឹមត្រូវ ។ ដល់គ្មានអ្នកណាមក, ពួកនេះបានរៀបចំគេហដ្ឋានដើម្បីជាកិត្តិយសដល់ព្រះអង្គម្ចាស់ មានការចោសច្រាសសំអាតមុខទីលំនៅ,

ត្រជាងទង់ជ័យ, យកស្លឹកពោធិ៍មកដោតជាកម្រង, ដុសខាត់លិង្គម (Lingam) ហើយយកស្លឹកឈើថ្មីៗពុំព័ទ្ធស៊ុំជាថ្មី ហើយក៏សាកសួរអ្នកដំណើរ តើមានឧបស័គ្គអ្វីដែលពាំងពាតាមផ្លូវ ដែលព្រះសិទ្ធត្ថទ្រង់យាងមក? ។ ព្រះនាងយសោធរាទ្រង់បានទតទៅពួកវណ្ណៈតាបដោយព្រះបុណ្យស្អាតល្អ តែព្រះទ័យខ្សោយព្រួយជាខ្លាំងដូចជាពួកនោះដែរ, ព្រះនាងបានត្មៀងព្រះនេត្រទៅកាន់ផ្លូវខាងត្បូង, ផ្ទៀងព្រះស្រោតដើម្បីនឹងសំនៅ តើអ្នកដែលមកវង់ចាំទទួល បានឲ្យដំណឹងពីពុទ្ធដំណើរនោះយ៉ាងណាខ្លះ? កង្វល់ណៈនោះស្រាប់តែព្រះនាងទ្រង់ទតទៅឃើញបុគ្គលម្នាក់ដើរដោយដំហានរង្វើលៗ ក្បាលកោរពុំចំរើរលឿងពាក់លើស្មា, ស្លៀកសង្ឃាំហើយកាន់អម្បែងពងដូចឃ្មោក ដើរសូមទានតាមមាត់ទ្វារគេហដ្ឋាន, ទទួលអាហារគោជនហើយជូនពរសេចក្តីសាធុការហើយដើរតទៅទៀត, បើអ្នកណាមិនឲ្យក៏មិនអាក់អន់ស្រពន់ចិត្តអ្វីឡើយ ។ មានបុគ្គលពីរនាក់ដើរពីក្រោយ, ស្លៀកសង្ឃាំលឿង, តែបុគ្គលដែលកាន់អម្បែងនោះមានលក្ខណៈរូបគួរឲ្យគោតខ្ចាប ហើយបញ្ចេញអានុភាពគួរជាទីជ្រះថ្លាពន់ពេកដោយព្រះបុណ្យតបរិសុទ្ធ; ពួកទាយកទាយិកាដែលបានធ្វើអំណោយអ្វីមួយរួចហើយ ក្រឡេកទៅកាន់បុគ្គលនោះ ដោយសំដែងគារវភាព ហើយមានខ្លះនុនកាយថ្នាយបង្គំ, មានខ្លះទៀតទៅយកទេយ្យវត្ថុមកជូនទៀត, ខ្លះទៀតក្តួញក្តែរថា ខ្លួនក្រគ្មានវត្ថុអ្វីធ្វើទានទេនឹងគេ,

ព្រោះហេតុដូចនេះ ឃានជាមនុស្សប្រុសស្រីដើរពីក្រោយបុគ្គលនោះ ពោលខ្សឹបគ្នាថា: "អ្នកណា នេះ? អ្នកណា? តើជាឥសីឬ?" ប៉ុន្តែ ដល់បុគ្គលនោះទៅដល់សាលាសំណាក់ហើយ ស្រាប់តែទ្វារដែលមានបិទបាំងដោយសំពត់ព្រៃគេបើកឡើង ហើយព្រះនាងយសោធរាទេវីបើកវាស្បៃមុខ តើនឡើងហើយមានព្រះសុរនីយ៍ថា: "ព្រះសិទ្ធត្ថ, ព្រះអង្គអើយ!" ហើយទ្រង់ព្រះឃលនេត្រ ព្រះហស្តទាំងគូរឱ្យប្រណម្យ ហើយទ្រង់ដួលសោយសោកាជិតព្រះបាទព្រះសម្មាសម្ពុទ្ធ ។

ដល់ថ្ងៃក្រោយមក, កាលណាព្រះនាងទ្រង់ព្រួយព្រះពរហ្ឫទ័យជាខ្លាំង ឃានចូលទៅកាន់ផ្ទះវិសុទ្ធិមគ្គហើយ, មានបុគ្គលខ្លះឃានសួរព្រះសម្មាសម្ពុទ្ធថា: ហេតុម្តេចព្រះអង្គទ្រង់លះបង់នូវតណ្ហាជ្រះស្រឡះពីសន្តានទ្រង់ ព្រមទាំងលះបង់ការប៉ះពាល់នូវរាងកាយស្ត្រី ដែលមានសម្ផស្សស្រទន់ដូចជាបុប្ផាទាំងឡាយហើយផុតពីកណ្តាប់ដៃនៃមាតុគ្រាម. ព្រះអង្គទ្រង់បណ្តោយឱ្យព្រះនាងទ្រង់ព្រះអាលិង្គត (ឧប) ព្រះអង្គ? ។ ព្រះសម្មាសម្ពុទ្ធទ្រង់តបទៅនឹងបុគ្គលនោះវិញថា: "បណ្តាបុគ្គលទាំងអស់, អ្នកធំតែងជាប់ជំពាក់នឹងសេចក្តីស្នេហា, ដូចអ្នកតូចតាចដែរ ពិតមែនតែសេចក្តីស្នេហានោះ មានសភាពខ្ពស់ផុតជាលោកុត្តរៈ ។ អ្នកទាំងឡាយ កុំប្រមាថបុគ្គលដែលលះបង់នូវចំណង់លោកបាន ទាំងកុំធ្វើបុគ្គលដែលជាប់ចំណង់ឱ្យគាត់អន់ស្រពន់ចិត្ត ដោយប្រើនិយ្យានិកកាត

ខុសចំនងឡើយ ។ អ្នកអាចជាបុគ្គលសេរីកាចានសម្រែចនូវសេរីភាព (និយ្យានិកភាព) ដោយធម៌ខ្ពង់ ឧត្តមជ្ឈាបាយផ្សេង។ ដែលកើតឡើងដោយទុបាយនៃប្រាជ្ញា ។ ពោធិសត្វ[1] បានបំពេញពុទ្ធការកធម៌ បីថ្នាក់ គឺទីមួយ អធិដ្ឋានធម៌, ទីពីរ ពុទ្ធកិច្ច, ទីបី ការសម្រែចនូវសម្មាសម្ពោធិញ្ញាណ ។ អ្នកឃើញទេ ? តថាគតបានប្រព្រឹត្តនូវអធិដ្ឋានធម៌, បំណងរកសេចក្តីសុខ, ស្វែងរកបញ្ញាលោកុត្តរៈ តែបញ្ញាចក្ខុនៃសត្វលោក បិទជិតរកស្តើគាន ។ អ្នកចូរពាប់គ្រាប់ល្អងខ្សែកងចម្ការនេះ មានចំនួនប៉ុន្មាន ? កងអតីតកាលកន្លងរំលងមកយូរហើយ តថាគតបានទៅចាប់កំណើតជាឈ្មួញទៅតាមមាត់សមុទ្រខាងត្បូង, ចំពីមុខកោះលង្កាដែលសម្បូណ៌ដោយធនជាងគេ ។ កងពេលនោះ, ព្រះនាងយសោធរាបានទៅរួមសុខទុក្ខជាមួយតថាគតទៅកូមិតាមមាត់សមុទ្រនោះ, ព្រះនាងមានរូបឆោមលោមពណ៌ស្អាតដូចសត្វថ្លែ ហើយទ្រង់ព្រះនាមលក្ស្មី (Laksmi) ។ តថាគតបានចាំជាក់ថាតថាគតបានធ្វើដំណើរទៅជួញស្រែកឆ្ងាយ ដើម្បីនឹងស្វែងរកអាហារមកចិញ្ចឹមជីវិត ព្រោះគ្រួសារតថាគតក្រលំបាកណាស់កងពេលនោះ ។ ព្រះនាងបានអង្វរតថាគតថា

---

១ ពោធិសត្វ គឺអ្នកដែលត្រូវត្រាស់សម្មាសម្ពោធិញ្ញាណ តែលះបង់នូវញាណដ៏ប្រសើរនេះ ដើម្បីនឹងយោនយកកំណើតក្នុងវដ្តសង្សារទៅអនាគត បំណងនឹងសង្គ្រោះដល់សត្វលោក ។ បើតាមអ្នកបកប្រែ : ពោធិសត្វ គឺជាបុគ្គលកំពុងបំពេញពុទ្ធការកធម៌ តែមិនទាន់បានត្រាស់ដឹងជាពុទ្ធភូមិនៅឡើយ ។

កុំឲ្យទៅ ហើយកុំឲ្យទៅតស៊ូនឹងការគ្រោះថ្នាក់ ដែលកើតនៅលើផែនដី ឬ តាមសមុទ្រ, ហើយពោលថា: "តើនឹងឲ្យភ្លាច់សេចក្តីស្នេហារបស់ខ្ញុំម្ចាស់ពីស្វាមី ដែលជាទីពេញចិត្តរបស់ខ្ញុំម្ចាស់បានឬ? ។ តថាគតចាកចេញពីគេហដ្ឋានទៅស្រុកឆ្ងាយ ដើម្បីនឹងសែ្វងរកលាភ, តថាគតបានធ្វើដំណើរទៅតាមដែសមុទ្រ ហើយតថាគតបានឆ្លងកុំភ្លេលំបាកដោយខ្យលព្យុះ នឹងការតស៊ូនូវសត្វសមុទ្រ ព្រមទាំងទទួលនូវសេចក្តីភ័យព្រួយគ្រប់យ៉ាង, តថាគតបានគង់ឲ្យមួយភ្លឺចាំងដូចព្រះចន្ទ ដែលមានតម្លៃពន់ប្រមាណ ទាល់តែព្រះមហាក្សត្រិយ៍យកច្បាប់ដែលមាននៅព្រះពាជឃ្លាំងទាំងប៉ុន្មានមកទិញទើបបាន ។ តថាគតក៏ត្រឡប់វិលមកទីលំនៅវិញ, តែក្នុងពេលនោះមានទុព្ភិក្ខភ័យកើតឡើងក្នុងភូមិស្រុក; តថាគតក៏ទៅជាឈឺដោយអត់អាហារ ហើយតថាគតស៊ូធ្វើដំណើរតមកទាល់តែដល់គេហដ្ឋាន ហើយតថាគតបានលាក់គង់ឲ្យដែលជាវត្ថុវិសេសអស្ចារ្យ ។ តែភូមិដែលតថាគតនៅក៏មានទុព្ភិក្ខភ័យដូចគ្នា, ហើយតថាគតចូលទៅក្នុងផ្ទះ ស្រាប់តែឃើញព្រះនាងដែលរងទុក្ខលំបាកជាអនេកជាងទុក្ខលំបាករបស់តថាគតទៅទៀត ដួលដេកនៅទីនោះដាច់អនិច្ចកម្ម, ដោយគ្មានអាហារបរិភោគ ។ ក្នុងពេលនោះតថាគតស្រែកថា: "បើអ្នកណាមានស្រាវ, តថាគតនឹងឲ្យគ្រឿងអលង្ការដ៏វិចិត្រនេះមានជម្ងៃនគរទាំងមូល ដើម្បីនឹងជួយសង្គ្រោះជីវិតដល់ព្រះនាង អ្នកណា

ហ៊ានឲ្យអាហារដល់នាងលក្ខីបរិភោគ តថាគតនឹងឲ្យគង់ក្នុងដូចព្រះចន្ទ្រ" ។ ដល់ពោលដូច្នេះ អ្នកដែលនៅជិតខាងក៏បានយកធញ្ញជាតិចំនួន ៣ សែរ[1] (Sères) ហើយក៏យកគង់ឲ្យនោះទៅ ។ លុះនាងលក្ខីបានរស់ពនមានជីវិតឡើងហើយ ក៏ប្រមកកាន់តថាគតថា: "លោកស្នឹងឲ្យញុំម្ចាស់ពិត" ។ តថាគតបានដូរគង់ឲ្យកងពេលនោះ ដើម្បីនឹងជួយសង្គ្រោះដល់ជីវិតនាង តែគង់ឲ្យនោះ ដែលតថាគតបានព្យាយាមរកយកបានពីកងសមុទ្រមក គឺជាធម៌និធាន: ១២ (បដិច្ចសមុប្បាទ ១២) នឹងផលកុសលមិនអាចធ្វើឲ្យលេតរំលាយ ហើយត្រូវចនាបុណ្យកុសលនោះទៅកាន់សោតណាគាត ព្រោះជាទានធ្វើដោយគ្មានជាប់តណ្ហា ។ ព្រោះថាដំបូកស្រមោច ម្តេចឡើយនឹងទៅប្រៀបផ្ទឹមនឹងកំរុមបាន? ទឹកដែលតើតឡើងដោយទឹកសន្សើម ស្ថិតនៅកងស្នាមដើងច្រើស ម្តេចឡើយនឹងប្រៀបផ្ទឹមនឹងទឹកសមុទ្របាន? អំណោយដែលតថាគតបានធ្វើពីកាលនោះ ម្តេចឡើយមកប្រៀបធៀបនឹងអំណោយដែលធ្វើកងពេលនេះបាន? ព្រោះហេតុនេះ សេចក្តីស្រឡាញ់ដែលច្បាសចាកនូវកាមារម្មណ៍ជាព្រហ្មវិហារដ៏ខ្ពង់ខ្ពស់ អាចមានចិត្តទន់ល្អោនទៅកាន់អ្នកខ្សោយៗពូលភាព ដូចជាព្រះចន្ទនៃនាងយសោធរាមកនូវសន្តិភាពនឹងសេចក្តីសុខកងពេលនេះដូចនោះឯង ។ (មានត)

---

១ សែរ (Sères) គឺរង្វាស់រង្វាល់ មានទំងន់ក្នុងមួយលីត្រ ។

ព្រះបាទ្បាត់អរិយកសប្ប តុង-ឈួន

វត្តបទុមវតី ក្រុងភ្នំពេញ

ទេសនាជាកិវិញ្ញាសនសព្ទ នៃប្រទេសកម្ពុជា កាលពីថ្ងៃ ៨ ធ្នូ ខែមិគសិរ ឆ្នាំកុរនព្ធស័ក ព. ស. ២៤៩០ (៤—១—៤៨)

នមត្ថុ រតនត្តយស្ស ។

ហិរោត្តប្បិយញ្ញេវ លោកំ បាលេតិ សាធុកន្តិ ។

វេលានេះ អាត្មាភាព ត្រូវនេសំដែងវិន្យុធម្មទេសនា ចែកជូនអស់លោកសប្បុរសទាំងឡាយស្តាប់ ។

*អាត្មាភាព នឹងសំដែង អំពីលោកបាលធម៌ គឺធម៌ជាគ្រឿងឃុំគ្រងរក្សាលោកឲ្យបានល្អ ។ ចុះធម៌អ្វីខ្លះ ដែលឈ្មោះថាលោកបាលធម៌? ហិរិ នឹងឧត្តប្ប: ឈ្មោះថាលោកបាលធម៌ ។ ហិរិគឺអ្វី? គឺសេចក្តីខ្មាសអំពើអាក្រក់គ្រប់យ៉ាង ។ ចុះឧត្តប្ប: បានដល់អ្វី? បានដល់សេចក្តីខ្លាចអំពើលាមកគ្រប់បែប ។ ចុះបើគ្រាន់តែខ្មាសនឹងខ្លាចប៉ុណ្ណោះទេ ហេតុអ្វីក៏ឈ្មោះថាឃុំគ្រងរក្សាលោក? ហេតុថា លោកគឺពួកសត្វ ពោះជាគ្រហស្ថក្តី បព្វជិតក្តី បើបានបង្អោនហិរោត្តប្បធម៌នេះ មកដាក់ឲ្យកើតក្នុងសន្តាន ហើយប្រតិបត្តិតាមថែមទៀត, គ្រហស្ថ បព្វជិតនោះ អាចសួយសាង្គកាយទាំងមូល ឲ្យអណ្តែតឡើងផុតអំពីគំនរនៃសេចក្តីអាក្រក់គ្រប់

យ៉ាង ខឹងកំឆ៊ពមិនឲ្យសេចក្តីលាមកកើតឡើងបានទៀត ឬបានជាឈ្មោះថា គ្រប់គ្រងរក្សាលោក ។ តែលោកក្នុងទីនេះ សំដៅយកតែសត្វលោក គឺពួកមនុស្សមួយយ៉ាង ពុំបានពោលដល់សង្ខារលោកនឹងអាកាសលោកឡើយ ។

ឯហិរិឧត្តប្បៈ គឺខ្មាសនឹងខ្លាចចំពោះអំពើទុច្ចរិត សេចក្តីប្រព្រឹត្តិអាក្រក់ផ្សេងៗ ឈ្មោះថា ចិត្តនេះ បើយើងគ្រាន់តែពោលថាខ្មាស ។ ខ្លាច ។ តែមតែបបួរមាត់ក្រៃប៉ុណ្ណោះទេ នោះក៏គ្មានអំពើដែរ ។ សូមលើកតួយ៉ាងដូចពួកពុទ្ធមាមកជនតាំងគ្រហស្ថបព្វជិត មានមុខងារជាអ្នកកាន់កែត្បប្រព្រឹត្តវិន័យ តាមផ្លូវពុទ្ធសាសនា, រង្កោកបាលជន មានមុខងារជាអ្នកប្រព្រឹត្តខ្លួនឲ្យគាំងមៅក្រោមរដ្ឋប្បញ្ញត្តិ គឺច្បាប់ដែលគេតែងតាំងឡើងសម្រាប់ដែន ។

បព្វជិត បើពុំហ៊ានប្រព្រឹត្តកន្ទងវិន័យពុទ្ធប្បញ្ញត្តិ ព្រោះខ្មាសគេ ព្រោះខ្លាចទុបជ្ឈាយាចារ្យផ្តន្ទាទោស ទំនងប្រជានិកវគ្គហានិន្ទាប៉ុណ្ណោះទេ លុះដល់វេលាស្ងាត់កំបាំងក៏តាំងប្រព្រឹត្តលើសកន្ទងវិនយប្បញ្ញត្តិ សិក្ខាបទធំ-តូចតាមតែអំពើចិត្តទៅ ។

គ្រហស្ថជាពុទ្ធសាសនិកជន បើខ្មាស ខ្លាចដូចជាស្ត្រីកែមុំមានរូបល្អ ពុំហ៊ានចេញឆ្ងាយពីបន្ទប់ ដោយខ្លាចគេឯងមើលឃើញ ពុំនោះសោតដូចកូនប្រុស-ស្រីឬកូនសិស្សដែលខ្មាស ខ្លាចមានាបិតាគ្រូបាអាចារ្យ

ផ្តន្ទាទោស ហើយពុំហ៊ានប្រព្រឹត្តអំពើអាក្រក់ លុះតែចង់ចេះតែធ្វើតាមចិត្តទៅ ។

ចំណែកវជ្ជកិច្ចាលជន បើខ្មាសខ្លាចពុំហ៊ានប្រព្រឹត្តល្មើសកន្ទុយវជ្ជប្បញ្ញត្តិដោយគំនិតគោរពព្រោះខ្លាចមហិស្សរាធិបតិជន លុះស្ងាត់កំចាំងកំតាំងរបាន់សង្កត់សង្កិនទៅទាំងអំណាច ។

ការខ្មាស ការខ្លាចបែបនេះ ពុំប្រសើរឡើយ ព្រោះជាអំពើដែលនាំឲ្យក្តៅក្រហាយខាងក្រោយ ។

លុះតែខ្មាស ខ្លាចដុះឡើងអំពីជួងចិត្តរបស់ខ្លួន ចំពោះទោសកំហុសដែលកើតឡើងអំពីការល្មើសវិនយប្បញ្ញត្តិ ឬវជ្ជប្បញ្ញត្តិ ទាំងផ្លូវលោកផ្លូវធម៌ ដោយនឹកដល់ជាតិកំណើត វយៈ សេចក្តីចំរើន, សេចក្តីក្សៀវក្សាអង់អាចនឹងសេចក្តីចេះដឹងរបស់ខ្លួន ព្រមទាំងខ្លាចដល់ការតិះដៀលខ្លួនដោយខ្លួនឯង ខ្លាចអ្នកដទៃគេហានិន្ទា ខ្លាចព្រះរាជអាជ្ញា ខ្លាចគតិដំអាក្រក់ហើយពុំធ្វើអំពើទុច្ចរិត ដើរាប់ថាខ្មាស-ខ្លាច អាចជួយគ្រប់គ្រងអភិបាលគាំទ្រខ្លួនឲ្យបានសេចក្តីសុខ-ចំរើន នឹងសេចក្តីល្អទាំងក្នុងបច្ចុប្បន្ននេះនឹងអនាគត ព្រមទាំងឲ្យឆ្ងងផុតអំពីៈសេចក្តីអាក្រក់ទៅបាន ។ សមតាមលំអានពុទ្ធភាសិតថា ធម្មោ ហវេ រក្ខតិ ធម្មចារិំ "ធម៌ (គឺហិរោត្តប្ប:) រមែងរក្សាអ្នកប្រព្រឹត្តធម៌" ឯ ទុគ្គតិំ គច្ឆតិ ធម្មចារី "បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ" ។ ព្រោះហេតុនេះហិរិនឹងឧត្តប្ប: ដើរបានឈ្មោះថាលោកបាលធម៌ ។

ហិរិនឹងឧត្តប្បធម៌នេះ បើអស់លោក-អ្នក ទាំងគ្រហស្ថ-បព្វជិត ប្រាន្តបង្ហោនមកទុកក្នុងចិត្ត ឬប្រាន្តប្រព្រឹត្តឲ្យល្អហើយ អាចបត់បង្វិលទឹកចិត្តគំនិតនឹងក្បែរបស់លោកអ្នកទាំងឡាយ ឲ្យញញឹមញញែមញែរកាយឈមមុខទៅរកគ្នាប្រាន្តពាល់ពិភពត្រៃ ។

កាលបើអស់លោក-អ្នក ដែលជាអ្នកស្រឡាញ់ ជាតិ សាសនា មហាក្សត្រិយ៍ប្រាន្តជ្រាបថាធម៌នេះ ពិតជាធម៌រក្សាលោកឲ្យប្រាន្តល្អហើយ ក៏សូមខ្ចាត់ចោលនូវកំហុកពោលគឺសេចក្តីអាក្រក់ ផ្លូវកាយវាចាចិត្ត ចេញប្រាកដខ្ជួនឲ្យឆាប់ៗទៅ ហើយសូមខំប្រឹងកសាងបណ្តុះប្តូរបំពេញហិរិភេត្តប្បធម៌ ដែលជាសញ្ញាណៈរបស់យើងទាំងអស់គ្នា ឲ្យគ្រប់គ្រាន់ឡើង ដើម្បីនឹងប្រាន្តជាឧត្តមគតិមួយ ដល់យុវនារី យុវជនដែលជាអ្នកដើរតាមក្រោយ យកជាតម្រាប់ផង ។

ទីបំផុតនេះ អាត្មាភាពសូមជូនពាក្យពីរបទ ផ្ញើទុកចំពោះអស់លោកជារដ្ឋាភិបាល នឹងប្រជានិករ ព្រមទាំងយុវនារី យុវជនរួមជាតិថា: សូមកុំភ្លេចសច្ចៈ (សេចក្តីពិតត្រង់) ហើយកុំលះបង់ វីរិយៈ (សេចក្តីព្យាយាម) ក្នុងកាលដែលលោកអ្នកប្រាន្តបំពេញនូវហិរិភេត្តប្បធម៌គ្រប់គ្រាន់ហើយនោះ ព្រោះសច្ចវីរិយធម៌នេះហើយ ដែលអាចសង្គ្រោះជួយជាតិ សាសនា មហាក្សត្រិយ៍ ព្រមទាំងមាតុភូមិរបស់យើង ឲ្យដំណើរជឿនលឿនទៅកាន់អារ្យធម៌ខាងអនាគត ។

ហេតុនេះ សូមអស់លោកជាមិត្តភាព ភាតរភាពចាំដណ្តើយ ទោះជាគ្រហស្ថក្តី បព្វជិតក្តី ដែលមានសមត្ថភាពយ៉ាងគ្រប់គ្រាន់ សូមកាន់នូវសច្ចៈ សេចក្តីពិតត្រង់ ចំពោះមុខការរបស់ខ្លួន, សូមមានវីរិយៈ សេចក្តីប្រឹងប្រែងខ្នះខ្នែង ចំពោះមុខការរបស់ខ្លួន ឲ្យមុឺងម៉ាត់ឡើង, ព្រោះឧកាសនេះហើយដែលជាឧកាសមួយ គួរអស់លោក-អ្នកខំបំពេញសច្ចវីរិយៈ ទើបនឹងអាចបំបាត់នូវអំពើអយុត្តិធម៌ អំពើលញ្ចុកការរបស់ពុជន, មោហជនបានដោយងាយ ។

អាត្មាភាពសូមថ្វាយព្រះពរ ព្រះពុទ្ធសិរីសួស្តីជយមង្គលព្រះជន្មសុខគ្រប់ប្រការ សូមកើតមានដល់ព្រះបាទសម្តេចព្រះបរមបពិត្រព្រះពុទ្ធសម្ភារដ៏ទ្រទ្រង់នូវព្រះគុណធម៌មហាប្រសើរពាល់ទឹកពាត្រី ព្រមទាំងប្រជានិករក្នុងកម្ពុជរដ្ឋគ្រប់ភូមិ-ជាន់ សូមឲ្យបានប្រកបសុវត្ថិមង្គលសួស្តីតរៀងទៅ ។ ។

សំដែងមកក្នុងលោកធាតុ សូមសន្មតថាចប់ដោយសង្ខេប ប៉ុណ្ណេះ ឯង ។

ចប់

ភារីឆ អ្នកសិក្ខា

មហាវិម-ង៉ាគ្រី

ឃុំស្វាយចេក ស្រុកសង្កែ ខេត្តបាត់ដំបង រៀបរៀង

ឃួន-សុវត្ថិវេទី យួរ-អ៊ុន ពិនិត្យកែ

ឆោសនៃសុក

អ្នកប្រមឹក ផឹកសុក ឥតមេរ៉ៃយ
តែងហិនហោច ខូចហិនវៃ ទ្រព្យសម្បត្តិ
រលត់ប៉ើង រលើងភ្នែយ រលាយខ្លាត់
វិនាសបង់ វិនាសបាត់ ឥតសេសសល់ ។
អ្នកប្រមឹក តែងប្រមូល ចូលចិត្តឈ្លោះ
ពោលគំពេះ ពាក្យគំរក់ លាមកខ្វល់
ជេរបញ្ឆោះ ឈ្លោះបញ្ឆេរ គោលាហល
កើតក្តីក្តាំ នាំប្តឹងផ្តល់ ដល់រដ្ឋបាល(១) ។
អ្នកប្រមឹក ផឹកសុក ក្លាជាប់ជោក
ចណ្តាលភេត បណ្តុះរូប ឲ្យពិការ(១)
ឲ្យក្តៅហួស ឲ្យជ្រួសហល់ រូបសង្ខារ
ឲ្យឆ័ងឆឹត ខូចវិចារ-ណញ្ញាណ ។


---

១ ឬ ល, រ ជាឈ្លល់ស្រួយ, អាចយកប្តូរបង្ហិនគ្នាបាន ។

អ្នកប្រមឹក តែងស្អុយខ្លួច ហោចកេរ្តិ៍ឈ្មោះ
ឮសាយសុះ ថាជាមនុស្ស ខ្ទុស្តឈ្លានពាន
ដើរផ្តេសផ្តាស ពាសទិសទី ដួចតិរច្ឆាន
អួតអាងច្រណែ បែកព្រោកច្រាស តតាំងអ្វី ។
តតអៀនខ្មាស តតបិទបាំង បទគួរបិទ
ជាមនុស្សធិត ជាមនុស្សធុត ជោគពាសី
ធ្វើបញ្ជា ឲ្យអន់ចុះ ឲ្យតុះខ្វី
ធ្វើស្មារតី ឲ្យវង្វិន កំន្តរង្វើង ។
ការប្រមឹក ជាប្រមុខ ឆ្គួតល័លា
ធ្វើឫកពា ឲ្យថោកទាប ភាពអ្នកលេង
ដើរដួលដក មមកជ្រុល រ៉ៃឫកវៃជើង
តែម្នាក់ឯង ដើរផ្លូវមួយ ពោលទ្រគោះ ។
ពោលអំនួត អួតអំណាច រឿងកាចកោង
ឫកក្រអោង កោងក្រអឺត ច្រឡោះចោះ
ដើរធ្លាក់ថ្នក ជង្គុកបឹង តែពាំងជ្រោះ
ពោលឡេះឡោះ ស្រែកឡូឡា ឮឡូឡាង ។
រ៉ៃបញ្ឆោះ ឈ្លោះបញ្ឆេវ កូនប្រពន្ធ
ដេរបង្អន់ ពោលបង្អាប់ សំពុះក្អេងក្អាង

ក៏យថានធ្នាំង ប៉ុង៑ចាំងបែក ក្រឡប្ចាង
មាត់រ៉ូងក៉ង ញ្ចូសក៉ស ពាសពេញស្រែក ។
ក្អួតចង្អោរ ធុំចង្អាប ក្លិនអសោច៑
ដួចជាខ្មោច ហូរគម្រង់ សែនអង្គុត
ជួនដេកដួល ដោយជង្គង់ព្រៃ សុកម៑ម៉ុក
ជួនតត្រុក ដើរទន្ទឹក ញាប់ញ័រកាយ ។
ក់សដៃដើង ឡើង៑ដំនោរ ដោរចំណាប់
អួតចាក់កាប់ អាង៑តែស្ងាប់ ឥតសោកស្តាយ
ឈប់ស្គាល់កូន ចោប្រពន្ធ ខ្ចីពុកម្តាយ
ហ៊ានមើលងាយ ក់យដេរលោក អ្នកមានគុណ ។
ច្រឡំខ្ទ ថាជាពួក ម៉ាកកឿនផឹក
ឃើញមុខមែ៑ បែរជានឹក ថាប្រពន្ធ
តែង៑មិនគួរ ថាជាគួរ ចាបជាបុណ្យ
ទោសជាគុណ បុណ្យជាចាប សាបជាប្រៃ ។
ការប្រមឹក នាំប្រមាទ ខាតកុសល
នាំអំពល់ ដល់អំពើ ប្រសើរកៃ
នាំចានទុក្ខ បុកម្នេញ ពេញដួង៑ចៃ
នាំចង្កៃ នាំបង្រាស ច្រាសព្រាត់គ្នា ។

នាំថោកថាប គ្រកូលញាតិ ជាតិផៅពង្ស
នាំឲ្យស្លៀ ភ្លៀឲ្យស្លង់ ឆ្កួតពាលា
នាំគេខ្ចើម ល្មើមស្អប់ គេនិន្ទា
នាំវេរ ចង់ពៀរគ្នា ជាអង្វែង ។
នាំចាក់កាប់ នាំជាប់គុក នរកគោក
នាំឲ្យសោក វិយោគសៅ យំសង្រែង
នាំអន់អ័ប្ស យ៉ាប់ក្តៅឈ្មោះ យូរអង្វែង
នាំឲ្យក្ងេង លែងកោតក្រែង លែងគោរព ។
ការប្រមឹក ជាប្រមុខ ទុក្ខបច្ចុប្បន្ន
ឃើញរួសរាន់ ខាន់ហាន់ណាស់ គួរតែឈប់
ឯបរលោក ងោកងៀកាន់ ទុគ្គតិភព
គួរកុំផឹក ជាប់សុភ ណាខ្មែរអើយ !!! ។



សុភាសិតប្រៀនប្រដៅ

ព្រះមហា អ៊ុម – សុខ

សិស្សសាលាជាលីជានខ្ពស់ ថ្នាក់ឆ្នាំទី ៤ "១"

រៀបរៀង

គេជឿ សឹមប្រាប់
គេស្តាប់ សឹមចរចា
គេស្រលាំអាត្មា សឹមធ្លើយ ។

សូមសាធុជនត្រងត្រាប់ស្តាប់និទាន "បក្សីនឹងពានរ" ដូចតទៅនេះ:–

នេះនឹងថាថ្ងៃថ្មី ចរចាសំដែងកាលគ្រា
ព្រហ្មទត្តកជា គ្រងបុរីរម្យពារាណសី ។
កាលនោះមែនមាន សកុណាមួយប្រាណប្រិមប្រិយ
ជាតិជាបក្សី គ្រលេងគ្រលោងសោតណា ។
ធ្វើសំបុកនៅ នាជនវៃព្រៃជ្រៅហិមវា
សែនសុខសប្បាយ – ពេញពិតឥតមោះមួន្ទមាំ ។
រង្វេវស្សា ភ្លៀងធ្លាក់ពាសុធាជោកជាំ
រងាទន្ទាំ នាំឲ្យសត្វសត្វព្រួយប្រាណ ។
កាលនោះមានស្វា រងាឯកាឥតស្ថាន

ចរចូលឆ្ពោះភ្លាន ប្រួញប្រាណរកទីអស្រ័យ ។
បក្សីឃើញស្ងាត់ លំបាកអាត្មាភ្នេះនៃ
ទើបពោលនាប់រៃ ថាហៃអឺបង៏ពានរ ។
ដៃដើង៏បង៏ឯង៏ ប្រាកដជាក់ស្តែង៏ស្តាពរ
ដូចមនុស្សនិករ ម្តេចមិនធ្វើផ្ទះគាន់ជក? ។
ស្ងាធ្វើយតបថា ហៃចៅបក្សាពន្ធក
ខ្ញុំនឹង៏ស្មែងរក ធ្វើផ្ទះគាន់ជកម្តេចបាន ។
ដៃដើង៏ក្បាលខ្ញុំ ដូចមនុស្សត្រូចធំគ្រប់ប្រាណ
ប្រាជ្ញាខ្ញុំគ្មាន ធ្វើម្តេចសាង៏ស្ថានថ្កានទៅ ។
គ្រលេង៏គ្រលោង ជាសត្វយិតយោង៏មនុស្សខ្លៅ
ពោលថាលំនៅ មិនមានដល់មនុស្សបៃបង៏ ។
ទើបពោលទៀតថា រ៉ក្តីសុខាមិនស្តែង៏
ដល់មនុស្សបៃបង៏ ជាសត្វមានចិត្តសាភ័ ។
របុលរប៉ូប រហ័សផ្ទេរផ្ទួបច្នេះណា
ទ្រុស្តមិត្តអាត្មា ដូចយ៉ាង៏បង៏ស្ងាឯង៏ហ្នឹង ។
នៃពានរអើយ គួរកុំកន្តើយទ្រមឹង៏
ចូរខំប្រែង៏ប្រឹង៏ ស្មាជ៏ស្មឹង៏នឹង៏គេឡើង៏ទៅ ។
កុំឱ្យិលច្រអូស លះចិត្តស្រមូសហ្នង៏សៅ

កុំឲ្យមាននៅ ចូរទៅធ្វើខ្លួនគ្រាន់ជែក ។
ពាន្យគិតថា អាដែងបក្សាក់មក
ពោលពាក្យចំអក ថាអញជាសត្វខ្ចីស្គមិត្ត ។
ច្នេះមានតែអញ សំដែងផ្ដាំលង្ហាញឲ្យពិត
រឿងក៏ដឹងខ្ចីស្គមិត្ត ឲ្យឃើញច្បាស់ក្បដល់ក ។
គិតហើយស្ទុះផ្លោត ផ្លោះផ្ដាញលោលោតមីមា
ចាប់ចុងព្រឹក្សា ចោចរកេចសម្បុកបក្សី ។
ខ្ចប់ខាតបែកបាក់ ធ្លុះធ្លាយខ្ចាយធ្លាក់ជាសដី
សត្វស្វាបលែងស្ដី ហើរប៉ុពីទីនោះហោង ។
លោកអ្នកចូរស្ដាប់ កាន់តាមសណ្ដាប់កុំហ្មង
កុំមោះកន្ធង ពាក្យពិតភាសិតនេះណា ។
ចូរចាំឲ្យជាក់ បក្សីធ្លាយធ្លាក់គ្រែហា
ព្រោះតែអាត្មា ខ្ចប់ខ្ចាយសត្វស្វាលង់ខ្លៅ ។
ពាល្ស្អប់ខ្ចាក់ បណ្ដិតវៃធ្លាតប្រជៅ,
ឈើកោងមួមៅ តែងស្អប់បង្ខាត់ពេកក្រៃ ។
រុយស្អប់បុប្ផា, កមរៈបក្សាថ្លាថ្លៃ
ស្អប់លាមកក្រៃ; គួរស្ដាប់ឧបមេយ្យនេះហោង ។

រឿងអាយោនជាហានចាស់

លោកធ្លេង-ជ្រៃ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែពីសៀវភៅ «កុងអេឡេហ្សង់ ឧុយប៊ែអឺ រូម៉ាង តាន្ធី ជា អេ អាជាប្តេ ជាប.នរនីន»

(តពីរឿងស្តេចត្រីមក)

កុងអតីតកាល មានជាហានចាស់ម្នាក់ ធ្វើការរាជការអស់ចំនួនម្ភៃបួនឆ្នាំ ហើយត្រូវគេបណ្តេញចេញពីមុខងារ ។ ជាហាននេះមានតែលុយតែចុំមួយសេនទឹងនំបុ័ងមួយដុំ ។ ហេតុដូច្នេះ វាត្រូវធ្វើដំណើរវិលទៅស្រុកកំណើតវិញ ច្រៀងផងដើរផង ដើម្បីកំឡាំងចាត់សេចក្តីព្រួយ ។ វេលៈកំពុងដើរ អាយោនបានជួបតាចាស់កាន់ឈើច្រត់ពីរនាក់ ។ ឯតាចាស់នោះគឺជាទេព្តាចិត្តល្អ ។ ប៉ុន្តែអាយោនមិនស្គាល់ថាជាអ្នកណាឡើយ ។

តាចាស់ទាំងពីរនិយាយថា: ម្ចាលអ្នកក្មាហាន! អាណិតឲ្យយើងសុំអ្វីបន្តិចស៊ីផង, យើងគ្មានអ្វីសោះ សូម្បីតែបន្តិចបន្តួចក៏គ្មាន ។

អាយោនអ្នកចិត្តល្អឆ្លើយថា: បពិត្រលោកតាអើយ! ខ្ញុំបានមានតែលុយចុំមួយសេនទឹងនំបុ័ងមួយដុំទេ ខ្ញុំចែកជូនលោកតាពីរសេនម្នាក់ទឹងនំបុ័ងកន្ទុះដុំម្នាក់ ។

តាចាស់ឆ្លើយថា: សូមអរគុណច្រើន ចៅក្មាហាន! ទេព្តានឹងសងអ្នកវិញ ច្រើនជាងវត្ថុដែលឯងបានឲ្យដល់យើងទៅទៀត ។ រួចតាចាស់ទាំងពីរក៏ធ្វើដំណើរហួសទៅ ។

ចំណែកអាយោនក៏ធ្វើដំណើរតទៅទៀតដែរ ព្រឹងតែម្នាក់ឯងស្ទើរបែកព្រៃជូចជាក់ស្តែចផែនដី ។

កន្លងរំលោះរៀបដើរទ្វេងកាត់ភ្នំ មានតាចាស់ពីរនាក់ទៀត គឺជាខេត្តភ្លាដដែល គ្រាន់តែផ្ទាស់រូបភាព ហើយអាយោនមិនស្គាល់ជាតាចាស់ពីលើកមុនទេ ។

តាចាស់នេះសុំទៀតថា: ម្ចាលចៅក្លាហាន! ចូរឲ្យអីបន្តិចដល់យើងស៊ីផង ។

— មិនអីទេលោកតា! ប៉ុន្តែនំបុ័ងរបស់ខ្ញុំអស់ហើយ ព្រោះខ្ញុំបានចែកជូនចៅលោកតាចាំងពីរអម្បាញ់មិញអស់ទៅ ខ្ញុំនៅសល់តែពីរសេនទេ ហ៎! សូមលោកតាអញ្ជើញយកមួយសេនម្នាក់ចុះ ។

តាចាស់ទទួលយក ហើយតាមួយនិយាយថា: នែតា ចូរស្តាប់! ភាហាននេះគ្មាននៅសល់មួយសេនទឹងខ្ទួនសោះ ដូច្នេះត្រូវយើងឲ្យវត្ថុអ្វីមួយដល់វា ដើម្បីកុំឲ្យស្លាប់ដោយការអត់ឃ្លាន ។

តាចាស់ទីពីរឆ្លើយថា: សូមបំណងរបស់ព្រះគុណសម្រេចចុះ ។

ហើយខេត្តានោះស្រែកហៅអាយោន ដែលដើរទៅឆ្ងាយហើយឲ្យត្រឡប់មកវិញ រួចនិយាយថា: នែចៅ! ចូរឯងយកសព្វាវុធនេះទៅចុះ ចៅអាចបញ្ចូលក្នុងសព្វាវុធនេះតាមចិត្តចង់ នូវវត្ថុអ្វីដែលចៅត្រូវការ; ចៅគ្រាន់តែនិយាយថា: សូមព្រះអគ្គីជួយ ភ្លែងឆាបទេស្អាត សូមឲ្យវត្ថុនេះបូលក្នុងសព្វាវុធខ្ញុំ ។

អាយោនឥយ្យាយថា: "សូមអរព្រះគុណម្ចាស់ច្រែន," រួចទទួលយកស្បៀងហើយបន្តដំណើរទៅទៀតធ្វើព្រងើយមិនចាំបាច់និយាយច្រែន ។

វាបានដល់តៀមលក់អាហារមួយ ។ វាឃ្លានបាយ ស្រមោចខាំពោះ ។ ប៉ុន្តែស៊ីដូចម្តេច បើគ្មានស្បៀង គ្មានសោហ៊ុយ ។ វាក្រឡេកទៅឯពិតានទឹងបង្អួចកោដនផ្ទាន វាឃើញសាច់ក្រកនឹងនំបុ័ងព្យរនៅរណោង វាឃ្លានស្ទើរស្រែកទឹកមាត់... ។ ខណៈនោះ វាក្រឡេកមើលក្នងស្បៀងហើយស្រែកថា: សូមព្រះអង្គជួយ កន្ទែងទេស្អាត, ខ្ញុំបាទត្រូវការនំបុ័ងពីរនឹងសាច់ក្រកមួយគូចូលក្នងស្បៀងខ្ញុំ ។

អាយោនភ្ញាក់ព្រឺត ដោយឃើញនំបុ័ងពីរនឹងសាច់ក្រកមួយគូលោតចូលក្នងស្បៀងរបស់វា ។ វានៅអង្គុយកែវម៉ាស៊ូនទឹក រួចតាំងចាប់បរិភោគអាហារ វាស៊ុបមួយៗយកពេញ។ មាត់ ហាក់ដូចជាខ្លាចនរណាមកនឹងដណ្តើមស៊ី ។ រួចវាដើរទៅទៀត ពេញដោយសេចក្តីក្សាហានជាថ្មី ហើយនិយាយដដែលៗថា: អញឈប់ខ្លាចនរណាទាំងអស់! អញឈប់ខ្លាចនរណាទាំងអស់! ។

អ្នកមានមុខម្ចាក់ក្នងភូមិនោះ ឃានឮអំនួតរបស់វាដូច្នោះ ក៏និយាយថា: បើអ្នកឯងមិនខ្លាចនរណាទាំងអស់ ចូរឈប់សិន គេនឹងនាំអ្នកទៅ ក្នងផ្ទះមួយយ៉ាងស្អាត ហើយឲ្យអ្នកអាស្រ័យនៅក្នងទីនោះ រហូតអស់មួយជីវិត ។

– អើ! ដូចម្តេចក៏ដោយ ខ្ញុំតែខ្លាចទាំងអស់ ។

គេនាំគ្នាទៅក្នុងផ្ទះនោះដោយនឹកស្មានថា: ក្មេងជានឹងស្លាប់មិនខាន ព្រោះគ្រប់មនុស្សគាំងអស់ ដែលត្រូវការទៅដេកល្បងមើលក្នុងផ្ទះនោះតែងតែបែរនឹងសេចក្តីស្លាប់ពុំខាន ។

អាយោនទិយាយថា: សូមលោកឲ្យក្អមមួយ ដាក់មេរ៉ាយគេញមកផង, ខ្ញុំយកទៅដាំផឹក គ្រាន់បានជាគ្នា ។

លុះនៅតែម្នាក់ឯកក្នុងផ្ទះ អាយោនដាំមេរ៉ាយផឹក ច្រៀងរឿរឿ ។ មិនយូរប៉ុន្មាន ក៏ឮសូរដូចជាសំឡេងមួយស្អកៗ ឡាវៗ ដូចសំឡេងគាឈ្មោល ស្រែកពីលើស្មាកមក (សំឡេងនោះបើពុះហើយ ធ្វើឲ្យព្រឺក្បាលប៉ុនកញ្ចើ ស្ទើរនឹងសន្លប់) ពោលពាក្យដដែលៗថា: អាហ៏ អញធ្លាក់! អាហ៏ អញធ្លាក់! ។ អាយោនធ្វើព្រងើយ ។

រួចតមកអាយោនទិយាយឥតងាកក្រោយ ដោយសំដីធម្មតាថា: អញឬដែលត្រូវធ្លាក់? គឺឯងទេតើ ។

បន្ទាប់ពីនោះភ្លាម ក្បាលមនុស្សមួយរមៀលចុះមកតាមបំពង់ផ្សែង ហើយមកតាំងនៅត្រង់មុខក្បែរអាយោន ដែលកំពុងតែកាន់ក្អមមេរ៉ាយទៅដៃ ។

អាយោនស្រែកថា: នែវ៉ុ! ថយឲ្យឆ្ងាយបន្តិចទៅ, អីឯងចង់បំបែកក្អមមេរ៉ាយអញ? ។ ប៉ុន្តែក្បាលនោះទៅស្ងៀម ។ ក្នុងពេលជាមួយ, គេឮសូរមួយថ្នឹកទៀត ស្រែកថា: អាហ៏ អញធ្លាក់! អាហ៏ អញធ្លាក់ឥឡូវ! ។.

អាយោនកាន់តែភ្លឹមមេរ៉ៃ ហើយឆ្លើយថា: យ៉ តាមចិត្ត! ឆ្អាក់មកចុះ! ឯងខ្លះតើ មិនគឺអញឯណា ។ អាយោនថាសឹងមិនផុតពីមាត់ស្រាប់តែវាឃើញតួខ្លួនមនុស្សព្រមទាំងដៃជើង រមៀលឆ្អាក់មកតាមបំពង់ផ្សែង ហើយលោតទៅភ្ជាប់នឹងក្បាល កើតបានជារូបមនុស្សម្នាក់មានដើងដូចសេះ រួចស្ទុះទៅសង្កត់អាយោន។ មុនដំបូងក៏យំដែរ តែលោទឹកភាន់ ក៏ស្រែកថា: ឧ! សូមព្រះអង្គជួយ កន្លែងនេះខ្លះស្អាតសូមចិសាចចូលកន្លះស្បែងអញមក ។

មួយរំពេចនោះ តើអ្នកដឿឬទេ? ខ្មោចចិសាចចូលទាំងបង្គុំទៅក្នុងស្បែង ហើយអាយោនចាប់ចុកវិញ ស្ទើរសំបែតដូចត្រីយូហ៊ី ។

– អាយោន។ អាណិតអញ! អញសូមទោស! អញលែងហ៊ានមកជាន់ទីនេះអស់មួយជីវិតហើយ ។

– យើគ្មានទោសពៃ៍អ្វីទេ ។

– អ្នកហាវហាន! សូមទោស។, ខ្ញុំជូនមាសដល់លោកពីរកញ្ជើ។

– មាសនៅឯណា?

– មាសនៅក្នុងកន្ទេងទាំងគ្រាយផ្ទះ ។

វេលានោះ មាន់រងាវគឹកជារពាក់កណ្តាលអធ្រាត្រ, ចិសាចប្រែតព្រមទាំងចរិកវាំងឡាយ រត់ចាត់អស់ ។ អាយោនបានជាម្ចាស់ចាក់ ទីដ៏ម្ចាស់ផ្ទះ ។ ក៏អាស្រ័យនៅក្នុងគេហស្ថាននោះប្រកបដោយ

សេចក្តីសុខអស់កាលជ័យរ ។ ប៉ុន្តែ គេតែងនិយាយជាហូរហែមអំពីកិច្ច
ជ័អស្ចារ្យរបស់ព ។ រឿងនេះមិនបាត់ស្ងាត់ ឮល្បីឮយ៉ាង ។ តាល់
តែ មានមួយថ្ងៃ មានបទបញ្ជាមួយ បង្គាប់ឲ្យកត្រឡប់ចូលបន្ទាយ
ចាស់ព វិញ យ៉ាងឆាប់ ។ ដ្បិតបន្ទាយនោះ ឥឡូវក្លាយទៅជាកន្លែង
បិសាចនៅ គ្មាននរណា អាចចូលជិតបាន ។

អាយោនទឹកមុំតែងថា: តើនឹងចេញទៅដូចម្តេចកើត? តើអ្នកណា
នៅថែរក្សាផ្ទះឲ្យអញ ? ។ ពួកមេកូមិទាំងឡាយដឹងហើយ ក្រាបថា:
សូមលោកកុំបារម្ភ! យើងធានាមើលរក្សាជូន ។

ព្រឹកឡើងកាន់បន្ទាយនោះ ដែលប្រែតបិសាចបណ្តេញគាហានត់
ចេញគ្មានសល់ម្នាក់ ។

អាយោនស្ថិតនៅក្នុងទីនោះធ្លើព្រងើយ ហើយដេកដូចជាទីកន្លែង
របស់ព ។ ប៉ុន្តែ ព្រដេកលក់ឬទេ? ថាទេ ។ បិសាចច្រើនដូចជា
ស្មៅក្នុងចំការ មកចោមរោមព្រយដំច្រាក់នូវអាយោន ហើយស្រែក
ក្រាបថា: អាឯងកុំមកទៀត អាឯងកុំមកទៀត ។

អាយោនមុនដម្បងភ្ញាក់ឡើងលោតរត់ចេញ លុះទីបំផុតទើបនឹក
ដល់ស្បែងៈ

- សូមព្រះអង្គជួយ កន្លែងទេស្អាត, សូមឲ្យបិសាចទាំងអស់
ចូលក្នុងស្បែងខ្ញុំ ។

ស្រាប់តែបិសាចទាំងនោះ ចូលញ៉ុកក្នុងស្បាន ។ អាយោនគិតតែពីជាន់ជាក់សំពង ទាល់តែអមនុស្ស ស្រែកអង្វរលន់តួស្បថស្បែរថាឈប់មកក្នុងទីនេះទៀតហើយ ។

តុកាសនោះ . គ្រាន់តែអាយោនបង្ហើបមាត់ស្បាង អមនុស្សត្រេចប្រសេចប្រសាចលឿនដូចព្រួញ ទៅសូមជ្រកនឹងស្តេចព្រាយមួយឈ្មោះ បេស៊ីបុត្រ ។ ចំណែកអាយោនកំពុងតែរៀបបន្ទឹងសំពាកខ្លួនម្តងទៀត ស្អួបេស៊ីបុត្រឯងមកដល់ភ្លាមហើយស្រែកសន្ធាប់ថា: នែអាចោរថៃ! អាឯងមកក្នុងទីនេះធ្វើអ្វី? អាឯងមិនដឹងថា បន្ទាយនេះជាទីសំណាក់របស់យើងទេឬ? ។

- អញមិនដឹងជារបស់អាណាទាំងអស់ ។

- មិនដឹង! អើ អាឯងចាំមើលតន់ដឹង ។

បេស៊ីបុត្រចាប់ដំបងមួយយ៉ាងធំ ត្រីវីសំពងបំក្បាលអាយោន។ ដើមឡើងជកដង្ហើមចាន ស្រួលភ្លាមកាលណាក៏តាំងស្រែកថា: សូមព្រះអង្គជួយ! កន្ទុងទេស្អាត សូមឲ្យបេស៊ីបុត្រចូលក្នុងស្បាង ។

ស្រាប់តែបេស៊ីបុត្រវិលខ្លួនចូលឫកក្នុងស្បាង អាយោនចាប់សំពងគ្មានមើលមុខ ក៏ឃុយទាល់តែឈឺដៃ ។ បេស៊ីបុត្រ ស្តេចព្រាយស្រែកអង្វរសូមទោសថា: អាយោន! អញសុំទោស, អញទុកបន្ទាយនេះនឹងរបស់របាំងប៉ុន្មានខាងក្នុង ឲ្យអាឯងទាំងអស់ ។

- អាឯងស្បថថាឈប់មកទៀត ទើបអញត្រឡប់មក, ឮឬទេ ?

- អញឮហើយ អញនឹងឈប់មកទៀតហើយ ។

- អើ បើដូច្នេះ ទៅចុះ ។

រួចបេស៊ីបុត្រ សួរហារត់យ៉ាងល្មើនៗ ជាងពេលដែលវាមកទៅទៀត ។ គ្រានោះ អាយោនអញ្ជើញអស់លោកឧត្តមសេនីយ នឹងពួកគាហានចាំងឡាយឲ្យត្រឡប់ចូលមកវិញ ។ ប៉ុន្តែពួកជនអស់នោះនៅតែមិនចាន់ជើសបំអស់តីពោះ ។ ហើយចាប់ពីពេលនោះមក គេនាំគ្នាដេកជាសុខសប្បាយ មិនដែលមានខ្មោចបិសាចអ្វីមកយាយីទៀតឡើយ សូម្បីតែខ្មោចសង្កត់ក៏គ្មានផង ។ ចំណែកជនជាសប្បុរសចាំងឡាយ តែងនឹកឧបការគុណនៃអាយោនមិនភ្លេច ។

ខាងក្រោយការរៀបចំផ្ទះ ដែលបានពីព្រោយបិសាចនឹងបន្ទាយឲ្យបានស្រួលអស់អំឡុងប៉ុន្មានថ្ងៃហើយ អាយោនលាទៅគាន់ផ្ទះកំណើតរបស់អាគ្នា គឺផ្ទះដែលវាបានបាកចោលដើម្បីទៅធ្វើគាហាន ។ កំពុងដើរ, វាបានជួបតាចាស់ដែលបានឲ្យស្បោងដល់វា ហើយនិយាយថាប់ថា: នែចៅ ! ចូរឯងប្រុងប្រយ័ត្ន ទឹងសំដីដែលតា ទឹងនិយាយប្រាប់ឯងឥឡូវ... ។

- មានការណ៍អ្វីតា ? ។

- កាលណាឯងត្រឡប់ដល់ផ្ទះកំណើតហើយ ចូររៀបចំខ្លួនថ្វាយក្បាលសីលធ្វើបុណ្យឲ្យទាន តាំងចិត្តឲ្យល្អ ហើយធ្វើមួយសុក្រសម្រាប់

ខ្ញុំផង ដ្បិតមិនយូរប៉ុន្មានទេ មច្ចុនឹងមកយកអ្នកឯងហើយ ; ពេល
ឯងដល់ហើយ ខាងក្រោយមរណាកាល ឯងនឹងទៅកើតឯស្ថានសួគ៌ ។

អាយោនសួរតបទៅវិញ ដោយវាចាមិនពីរោះថា : តាឯងជាអ្វី
បានជាហ៊ានមកនិយាយរឿងអប្រិយដូច្នេះដល់ខ្ញុំ ? ។

- នែអាយោន ! អញជាព្រះឥន្ទ្រ ; ចំពោះអញឲ្យ ស្បោងនេះ
ដល់ឯង ព្រោះឯងចិត្តល្អ ។

- អីពិតមែន ? ទេព្រះគុណអើយ ! សូមព្រះគុណអត់ទោសដល់
ខ្ញុំ ។ មិនស្គាល់ព្រះគុណជាអ្វីឡើយ ។

អាយោនលុតជង្គង់ ហើយនិយាយអង្វរតាំងចិត្តកែកន្ត្រកហាមថា :
បពិត្រព្រះគុណម្ចាស់ ! បើអាយុខ្ញុំម្ចាស់អស់ហើយ សូមមេត្តាបញ្ជូន
មច្ចុរាជមកបង្ហាញខ្ញុំឲ្យចេះធ្វើម្ល៉ូសសិន ដ្បិតខ្ញុំម្ចាស់រាល់តែធ្វើទាហាន
នឹងធ្វើការដេញភ្នែចបិសាច ខ្ញុំមិនចេះធ្វើម្ល៉ូសទេ ខ្ញុំមិនដែលតាំងស្គាល់
យ៉ាងដូចម្តេច ម្ល៉ូសនោះផង ។

- អើ មិនអីទេ បាន ។

លុះអាយោនបានទៅដល់ទីលំនៅ មច្ចុរាជក៏មកភ្លាម ។

- នែ ស្តេចមច្ចុ ចូរបង្ហាញខ្ញុំធ្វើម្ល៉ូសបន្តិច ។

- ដូចម្តេច ? អាឰ៎ អីចឹងក៏មិនចេះធ្វើដែរ ? ហ៊ ! ចាំមើល !

មច្ចុតាំងបង្ហាញឲ្យអាយោនរើសយកក្តារស្ទូ ។ ទឹងត្រូវដុំគ្នាបែបយ៉ាង
ណា ។ អាយោនចេះតែធ្វើតាមមច្ចុរាជតទៅត្រង់ណា រួចថ្កាច់ថា :

បពិត្រលោកមច្ចុរាជ ! សូមលោកមេត្តា ចូលក្នុងម្ជុសជាដំបូង ហើយ ពិនិត្យមើល តើជាល្អឬមិនល្អ ។

មច្ចុចូលក្នុងម្ជុសហើយនិយាយថា: ម្ជុសយើងល្អណាស់គាយោន ។

- អីគ្មានន្តូចមួយសោះ? គ្មានពន្លឺថ្លៃចាំងចូលបន្តិចបន្តួចទេឬ?

- គ្មានទេ ជិតស្នុង ។

គាន់តែមច្ចុថា សឹងមិនទាន់ផុតពីមាត់ អាយោនយកគម្របមកជាក់បិទពីលើម្ជុស ចោះភ្លាប់នឹងដែកគោលយ៉ាងមាំ ហើយស្រែកជ្រាបថា: អាឯងអាចចេញពីម្ជុសនេះបាន លុះត្រាតែឪពុកអញរស់ឡើងវិញ ហើយលុះត្រាតែអញព្រមបើកឲ្យចេញផង ។ រួចវាលើកម្ជុសលើយកទៅចោះចោលក្នុងទឹកស្ទឹង ។

អាយោនតាហានចាស់ ចេះតែនៅរស់តទៅ . . . ហើយវាក្លេចចាំងថ្ងៃ ខែ ឆ្នាំ មិនដឹងជាវាកើតពីកាលបរិច្ឆេទណាឡើយ ។ យី វាសម្លាប់មច្ចុបាន ពិតមែន? ។ ម្ល៉ោះហើយអំពើពុំច្បាស់តែចំរើនឡើងពាសពេញក្នុងលោក ដ្បិតឈប់មានមច្ចុរាជមកផ្តាច់ផ្តិលជីវិតសត្វទាំងឡាយ ។ ដោយការក្រែស្ងាប់ មិនដឹងយ៉ាងដូចម្តេចហៅថាស្ងាប់ លោកិយជនតាំងចាប់ហែកគ្នាស៊ីទៅវិញទៅមកដូចតិរច្ឆាន ។

ជាទីបំផុត ទាល់ក្រោយការរស់នៅយូរពេក អាយោនក៏ឡើងទៅ

ស្តានសួគ៌តាមបទបញ្ជានៃព្រះឥន្ទ្រ ។ លុះបានទៅដល់ទ្វារស្តានសួគ៌ រាល់ឃើញទ្វារបិទជិត រាល់ចង់បើកទ្វារ តែពួកទេពារក្សមកឃាត់ ។

អាយោនរកធ្វើអ្វីមិនកើត ក៏ស្រែកថា: ឱ ព្រះគុណ ! សូមព្រះអង្គជួយ កន្ទែងទេស្អាត សូមឲ្យពួកទេពារក្ស ចូលកង់ស្បែងខ្ញុំ ។

ពួកទេវតាទាំងប៉ុន្មានទាំងធំទាំងតូច ចូលសុកប្រញុកកង់ស្បែង, អាយោនលើកស្បែងស្តាយដើរទៅរកព្រះឥន្ទ្រ ហើយនិយាយរឿងរ៉ាវហូរហែទូលព្រះឥន្ទ្រថា: បពិត្រព្រះគុណធម្ម៌ស្តាស់ថ្លៃ ! ឥឡូវនេះខ្ញុំម្ចាស់មកស្តានសួគ៌ តាមសេចក្តីបង្គាប់របស់ព្រះអង្គ តែទេវតាទាំងឡាយ មិនចង់ឲ្យទូលព្រះបង្គំចូលមករកព្រះគុណ ; ខ្ញុំម្ចាស់ទំនាក់ទំនងដោយពាក្យសព្វគ្រប់ តែមិនសម្រេច ហើយខ្ញុំម្ចាស់ប្រមូលដាក់កង់ស្បែងយកមក ។

ចំណែកព្រះឥន្ទ្រ ទ្រង់ដោះលែងទាំងទេពារក្ស ទាំងមច្ចុរាជ ។ តម្រកវត្តទាំងនោះ ត្រឡប់ចាប់ធ្វើការដូចដើម តាមមុខក្រសួងរៀងខ្លួនកង់លោក, មច្ចុ‌រាជចាប់ចំពេញកិច្ច‌របស់អាត្មា តាម‌ការណ៍ដែល‌គួរធ្វើ ។ ព្រះឥន្ទ្រ ឲ្យ‌មាតលី‌ទេវបុត្រ‌នាំយក‌អាយោន‌មក‌កាន់ផែន‌ដីវិញ ។

ចប់

ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៊ុម

អាចារ្យសាលាជាលីវង់ វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ឌាន់រ៉ក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យអ្នកពិនិត្យកែ

(តមក)

រឿងនេះជាគុណធម៌ ដែលជាលក្ខណៈរបស់ចិត្តឧបអាសោយ ។ បើលោក-អ្នកអប់រំបានហើយ លោក-អ្នកវមែងមានចិត្តឧបអាសោយត្រជាក់ត្រជំនឹងខ្លួនឯងយ៉ាង ច្បាស់ថាសេចក្តីសាមគ្គីព្រមព្រៀងគ្នារលាយសាច់មួយ ចេះទទឹង ចេះបណ្តោយ មិនទន់ពេក មិនរឹងពេក មិនក្តៅពេកគាល់តែនេះ មិនត្រជាក់ពេកគាល់តែកក ចេះអើពើជួយសង្គ្រោះគ្នា ជាអ្នកផុតចាកទោស គឺលង់ខ្លៅគួរខ្ពើម ចេះគួរស្អប់, ឧទ្ធ័សមួរទៅដោយគុណ គឺបើលង់ គួរឲ្យអាណិតស្រឡាញ់ ចេះគួរអប់អាន, ជាមនុស្សដែលអ្នកជំងឺគាន់តែឃើញ ឬគាន់តែនឹកឃើញ តើតសេចក្តីស្រឡាញ់គោរពអប់អាន ឧទ្ធ័ចានសេចក្តីសោមនស្សពេញចិត្ត ចង់ជួកកោនការពារភ័យ ។ ពិតមែន របស់ដែលដូចគ្នា រមែងប៉ះគ្នាបាន ៣ មាសរមែងប៉ះនឹងមាស, ដែករមែងប៉ះនឹងដែក, ទុក្ខរមែងប៉ះនឹងទុក្ខ, សុខរមែងប៉ះនឹងសុខ, អ្នកអប់អានគេ រមែងប៉ះនឹងការអប់អានតប, អ្នកបូជាគេ រមែងប៉ះនឹងការបូជាតប ឧទ្ធ័អ្នកគោរពគេ រមែងប៉ះនឹងការគោរពតបវិញ ។

៣ — បិត្តដែលស្គាល់បិត្តថ្មើមគេឯង — អ្នកដែលយល់ចិត្ត
យល់ថ្មើមគេឯងនោះ រមែងចេះប្រៀបធៀបសេចក្តីដឹងរបស់អ្នកដទៃនឹង
សេចក្តីដឹងរបស់ខ្លួន ដូចយ៉ាងចេះស្គាល់ការឧឡើយហត់ ស្គាល់ការសុខ
សម្រាន្ត ស្គាល់ការវិតក្ក ស្គាល់អារម្មណ៍ល្អ ឬអាក្រក់ ស្គាល់ទឹងឬជា
ស្គាល់ការខុសបំណងឬត្រូវបំណងជាដើម គឺឃើញថាបំណងរបស់គេ
មានដំណៀងដូចបំណងរបស់ខ្លួនដែរ ឃើញថាគេទាំងអស់ក៏ជាមនុស្សដូច
គ្នា ការមានបំណងក្នុងផ្លូវត្រូវរបស់គេ រមែងមានសិទ្ធិប៉ុនគ្នានឹងបំណង
ក្នុងផ្លូវត្រូវរបស់ខ្លួនដែរ សូម្បីកាលកើតសេចក្តីគិតឃើញឡើង ក៏កាន់
យកដំណឹងរបស់គេឲ្យដូចជាដំណឹងរបស់ខ្លួនដែរ ប្រតិបត្តិចំពោះអ្នកដទៃ
ដូចជាប្រតិបត្តិចំពោះខ្លួនដែរ យកចិត្តខ្លួនទៅប្រៀបនឹងចិត្តគេ យកចិត្តគេ
មកប្រៀបនឹងចិត្តខ្លួន ជួយត្រៃកអរក្នុងកាលដែលឃើញគេត្រៃកអរ ជួយ
សូតសូប់ក្នុងកាលដែលឃើញគេបានទុក្ខ គឺធ្វើរឿងដែលមកដួបប្រសព្វ
ចំពោះអ្នកដទៃ ឲ្យហាក់ដូចជារឿងនោះមកដួបប្រសព្វចំពោះខ្លួនដែរ ។

អ្នកប្រាជ្ញខាងចិត្តសាស្ត្រនឹងវិទ្យាសាស្ត្រ បានអនុម័តព្រមគ្នាថា
« លលាដ(១) សីស:របស់មនុស្សយើងមានលក្ខណៈដូចគ្រឿងផ្សាយ
នឹងគ្រឿងទទួលរលកជាតុនៃវិទ្យុ ។ បើមនុស្ស ១ បញ្ជូនមិត្តចិត្តទៅឲ្យ,
មនុស្សម្នាក់ទៀតក៏បញ្ជូនមិត្តចិត្តតបមកវិញដែរ » ។ ដូច្នេះ អ្នកដែល

---

១ ត្រូវអានថា លលា ។

ចានយល់ចិត្តយល់ថ្លើមអ្នកដទៃ កាលបើធ្វើនិយាយ ឬគិតអ្វីតែងបញ្ជូនចិត្តទៅត្រួតមើលចិត្តរបស់អ្នកដទៃមុនជានិច្ចថា "គេមានគំនិតនឹងចំណង់យ៉ាងណា?" ។ ការពិនិត្យមើលបែបនេះ លោកប្រៀបដូចវិរុ ព្រោះសុះចេញអំពីចិត្តមួយទៅកាន់ចិត្តមួយ អំពីចិត្តអ្នកធំដែលប្រកបដោយយសសក្តិសម្បត្តិទៅកាន់ចិត្តរបស់អ្នកតូចដែលគ្មានយសសក្តិសម្បត្តិចាន, សប្បាយជាមួយអ្នកដែលសប្បាយ សុតសូបជាមួយអ្នកដែលសុតសូប ។ មនុស្សដែលធ្វើបែបនេះចាន ចាត់ថាជាអ្នកមានប្រក្រតីយល់ចិត្តយល់ថ្លើមគេឯង ។ សូម្បីមនុស្សដែលអន់ជាង មនុស្សដែលតាំងនៅក្នុងការឃុំគ្រង នឹងមនុស្សស្មើគ្នា ដរាបដល់សត្វដែលចិញ្ចឹម ក៏ចានទទួលការយល់ចិត្តយល់ថ្លើម អំពីមនុស្សបែបនេះផងដែរ ។ "ការមានអាយុវែងហើយអាចជាទីរឭកឃើញនៃគ្នានឹងគ្នាចានយូរអង្វែងនោះ គឺការយល់ចិត្តយល់ថ្លើមគ្នាទៅវិញទៅមក" ។ នេះជាឧត្តមគតិ ចូរចាំទុកចុះ ។

៤.—បិត្តិធិងជ្ជ—គឺចិត្តឆាប់ខ្លួន ។ អ្នកមានចិត្តឆាប់ខ្លួននឹងខ្លួនរមែងជាមនុស្សខ្ទើងធឹង រឹងប៉ឹងក្នុងហេតុក្នុងផល មិនមានចិត្តស្រាលជ្រីងាយ។ មិនមានចិត្តប្រែប្រួលរវើរវាយតាយមាយសាវ៉ា ប្រៀនប្រែនប្រែនមណ្តែតអណ្តែង មានសតិជានាយឃុំគ្រងចិត្តរបស់ខ្លួន ចេះបង្ខាប់បញ្ជាចិត្តខ្លួនឲ្យតាំងនៅត្រឹមបង្ខាប់ខ្លួន មិនចោទទន់ទៅតាមគេងាយៗ មិនបណ្តោយខ្លួនឲ្យដូចជាសំឡីប្តូរស្មា អណ្តែតតាមខ្យល់តាមទឹក បង្ខាំងខ្លួនឲ្យជ្រកនៅត្រឹមមូលនៃសេចក្តីល្អ សូម្បីមានក្តែកមានត្រចៀកអាចមើល

រូបគ្រប់យ៉ាងឃើញដោយភ្នែក ស្តាប់សំឡេងគ្រប់បែបបានដោយត្រចៀកក៏ដោយ ក៏ធ្វើជាខ្វាក់ជាថ្លង់ មិនរំគើបញាប់ញ័រក្នុងវត្តុដែលបានឃើញបានឮនោះ មិនប្រាថ្នាវត្តុដែលមិនត្រូវបាន មិនសោកស្តាយវត្តុដែលវិនាសទៅ សូម្បីបានសម្បត្តិដែលគួររីករាយ ក៏មិនស្រើរវង្វេងមានកំឡាំងចិត្តអង់អាចល្មមធ្វើឲ្យដួងបញ្ញាភ្ញឹកថា ឃើញអត្តឃើញធម៌ចាប់ហេតុចាប់ផល នឹង វិនិច្ឆ័យបានត្រឹមត្រូវ ។

លោក - អ្នកទាំងឡាយ ចូរមានចិត្តនឹងនួន ស្មោះត្រង់ចំពោះខ្លួនឯង ។ កុំភូតភរលួងនឹងមើលងាយចំពោះខ្លួន ។ ត្រូវប្រតិបត្តិតាមសេចក្តីខុសនឹងត្រូវដែលខ្លួនបានដឹង គឺបើដឹងថាអ្វីខុស កុំប្រកាន់យកចូរផ្តាច់ចោលខ្លួនឯងឲ្យឃើញត្រូវ បើដឹងថាអ្វីអាក្រក់ កុំកន្ធរលើសធ្វើទៅទាំងបំពាន ។ បើមិនទាន់បានពិចារណាឲ្យឃើញហេតុផលចំពោះខ្លួនទេ កុំអាលធ្វើគេងាយៗ ។ ចូររឹងប៉ឹងក្នុងហេតុផល កាលដួបប្រទះនឹងហេតុការណ៍ដែលគួរវន្ទត់ គួរខ្ជាប គួរតក់ស្លុត ក៏កុំវន្ទត់ កុំខ្ជាប កុំភ្ញាប់ញ័រ ។ ចូរមានចិត្តសប្បាយរីករាយក្នុងកាលដែលប្រទះនឹងទុក្ខ ។ ចូរមានចិត្តខ្ជាប់ខ្ជួនក្នុងអារម្មណ៍ដែលខ្លួនប្រាថ្នា ។ កុំរើរែកយកយមាយអណ្តែតអណ្តូងទៅក្នុងអារម្មណ៍ដទៃ ។ ចូរធ្វើកិច្ចដែលខ្លួនចាប់ធ្វើហើយឲ្យសម្រេចទៅកុំបង្អង់ ។ ព្រោះថាសត្វវត្តុក្នុងលោកនេះ បើលោកអ្នកជាមនុស្សចិត្តស្រាលរើរែកយកយមាយសាកាំហើយ សូម្បីវត្តុនោះ

ត្រឹមតែ ១ ចំណែក ក៏នឹងក្លាយជាយល់សប្តិដល់ទៅ ១០ ចំណែក ឬ បើយ៉ាងពិតណាស់ ក៏ត្រឹមតែ ១ ចំណែកប៉ុណ្ណោះ ៩ ចំណែកទៀត ទៅជាយល់សប្តិ ។ លុះតែលោកអ្នកមានចិត្តនឹងធឹង ទើបបានទៅជាសេចក្តីពិតទាំង ១០ ចំណែក ឬបើយ៉ាងអន់ណាស់ ក៏ជាយល់សប្តិត្រឹមតែ ១ ចំណែកប៉ុណ្ណោះ ឯ ៩ ចំណែកទៀត ជារបស់ធ្លាក់ដប្រជា ។

ចិត្តនឹងធឹងនោះ គឺចិត្តនឹងធឹងក្នុងវត្ថុដែលគាប់ចិត្ត ឬក្នុងវត្ថុដែលមិនគាប់ចិត្ត ។ ឯវិធីដែលនឹងប្រតិបត្តិចំពោះវត្ថុគាប់ចិត្តមាន ៣ ប្រការ គឺ:

ក) កាលបើលោក-អ្នកស្វែងរក ក៏កុំស្វែងរកឲ្យខុសធម៌ ចូរស្វែងរកតែដោយត្រូវធម៌ ។

ខ) កាលបើនឹងប្រើការសង្គ្រោះ ក៏កុំសង្គ្រោះដោយសេចក្តីវង្វេងភ្លើតភ្លើន ។

គ) កាលបើនឹងចាកចេញ ក៏កុំចាកចេញដោយខ្មោមនស្ស ។

សូម្បីវិធីដែលគប្បីប្រតិបត្តិចំពោះវត្ថុដែលមិនគាប់ចិត្តនោះ ក៏មាន ៣ ដែរ គឺ:

ក) កាលបើអន្តរាយមិនទាន់មកដល់ ចូរការពារខ្លួនដោយសេចក្តីមិនប្រមាទកុំឲ្យហើយជាមុន ។

ខ) បើមកដល់ហើយ ចូរកុំសៅសោក ។

គ) បើអន្តរាយនោះ វិនាសបាត់ទៅវិញហើយ ក៏កុំរំលើបចិត្តរកអន្តរាយឡើងវិញ ។

(មានត)

រឿងសាមកុក

កណ្ឌទី ១១

ឧកញ៉ាវិបុលរាជសេនា ន្ង-កន ប្រែរៀបរៀង

(តមក)

ឮរឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
ទឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ខណៈនោះ មានបំរើសេះមកជ្រាបលីឈុយថា តៀវចេលើកទាហានមក ១ កងពីខាងទិសឯលិច ហើយស្រែកប្រកាសថា នឹងមកឃាត់ហាមលោកមិនឲ្យបង្ក៉ាំងគ្នានឹងគុយតី បើខាងណាមិនស្តាប់ តៀវចេនឹងធ្វើសង្គ្រាមតនឹងអ្នកនោះ ។ លីឈុយគិតថា ទាហានយើងក៏នៅស្រាលស្តើងណាស់ហើយ, ដែលនឹងធ្វើសឹកគេទៅនឹងគុយតីនោះឃើញទុញទាល់ណាស់ តៀវចេមកឃាត់ហាមនោះក៏សមប្រកបនឹងគំនិតយើងដែរ គួរតែយើងធ្វើមេត្រីទុកឲ្យតៀវចេឃើញថា យើងស្តាប់ពាក្យសំដី" គិតហើយក៏ចាត់ទាហានឲ្យទៅទទួលហើយផ្តាំឲ្យជ្រាបតៀវចេថា យើង

ចានឮដំណឹងថាតៀវចេនឹងមកឃាត់មិនឲ្យច្បាំងគ្នានឹងគុយតីនោះ យើងយល់មុខតៀវចេណាស់ ចានជាព្រមស្តាប់តាមពាក្យ ។

គុយតីចានដឹងដំណឹង កំច្រើតាហានចេញទៅនិយាយនឹងតៀវចេថា ដែលលោកលើកតាហានមកឃាត់ហាម មិនឲ្យច្បាំងគ្នានឹងលីឈុយនោះ គុយតីព្រមស្តាប់តាមពាក្យឃាត់ហើយ ។ តៀវចេមានចិត្តត្រេកអរណាស់ តាំងឲ្យចោះទំពាំងបាយទៅពីនោះ ហើយធ្វើសំបុត្រចូលទៅគ្រាបបង្គំទូលព្រះចៅហៀនតេថា ទូលព្រះបង្គំជាខ្ញុំតៀវចេចានមកឃាត់ហាមលីឈុយគុយតីតាំងសង្វាង ចានព្រមសះសាជានឹងគ្នាលែងច្បាំងគ្នាហើយ ទូលព្រះបង្គំជាខ្ញុំ សូមអញ្ជើញព្រះអង្គយាងទៅគង់នៅស្រុកហាងឡុង ដែលជាមុខគយស្រុកតៀវហាន់ ។

ព្រះចៅហៀនតេមានព្រះទ័យសោមនស្សត្រាស់ថា សម័យតាំងតុ: យើងក៏ចេញចាកស្រុកឡុកអៀងមកនៅស្រុកតៀវហាន់, គ្រានេះរើមកនៅស្រុកដែលតាំងតុ:សាងថ្មីទៀត ក៏មានតែទុក្ខចង្អៀតរកសេចក្តីសុខគ្មាន ឥឡូវនេះតៀវចេចង់ឲ្យទៅនៅស្រុកហាងឡុងវិញ ប្រហែលនឹងចាត់ទុក្ខ មានសេចក្តីសុខ ព្រោះបុណ្យរបស់យើងខ្ញុំដឹង" ទ្រង់ព្រះចិន្តាហើយ កំតាំងឲ្យតៀវចេធ្វើជា "តៀវគីបុងគុន" ប្រែថា "នាយតាហានធំ" ។ តៀវចេចានឡើងទីក៏មានសេចក្តីត្រេកអរណាស់ ទើបចាត់ចែងចំណីតែសាច់ន័ងរបស់ត្រកាលនាំចូលទៅថ្វាយ ។ ព្រះចៅហៀនតេក៏ទ្រង់ព្រះពរជាឲ្យចាវព្រាវតាំងពួនដែលអត់ឃ្លាន ។

គុយតីដឹងដូច្នោះ ក៏បើកលែងនាហ្នឹងដែលត្រូវឃុំក្នុងគុកនោះ នាំយកទៅថ្វាយព្រះចៅហៀនតេ ។ បណ្តានាហ្នឹងមុខមន្ត្រីខ្ញុំពាដីការតូចធំក៏ប្រជុំគ្នា ចាត់ចែងតាហានទឹងគ្រឿងហែហមត្រមះបរិបូណ៌ហើយ ក៏អញ្ជើញព្រះចៅហៀនតេនឹងព្រះអគ្គមហេសីស្រីព្រះសុំ ឡើងគង់ព្រះពាជរថ លើកព្យូហៈយោធាកាត់ស្រុកសុំនឡង ឆ្ពងទៅដល់ស្ពានទន្លេប៉ាឡេង ទទួលឮសំឡេងស្រែកហ៊ោកញ្ជ្រៀវ ហើយលើកតាហានមកស្កាត់នៅលើស្ពាន នាយតាហានក៏ស្រែកសួរថា ដែលលើកមកនេះនឹងទៅណា ? ។ អៀវគីបរសេះឡើងលើស្ពាន ហើយស្រែកតបថា ព្រះចៅហៀនតេស្តេចយាងមក, ដែលលើកតាហានមកស្កាត់លើស្ពាននេះ ឈ្មោះអ្វី ? ម្តេចមិនគ្រាបថ្វាយបង្គំ ? ។ តាហានឯក ២ នាក់ឆ្លើយតបថា គុយតីឲ្យយើងមករក្សាផ្លូវនេះ មិនឲ្យនរណាទៅជួយលីឈុយ, ដែលអ្នកថាព្រះចៅហៀនតេស្តេចមក នោះចូរឲ្យយើងឃើញច្បាស់សិនយើងនឹងថ្វាយបង្គំហើយបើកផ្លូវឲ្យស្តេចយាងទៅ ។ អៀវគីក៏ឲ្យតាហានស្រែតបង្គំបរព្រះពាជរថនោះឡើងមកលើស្ពាន ព្រះចៅហៀនតេក៏ទ្រង់បើកព្រះមាលីចេញ ហើយត្រាស់ថាបរះបង្គាប់ឡើងទឹងអាលផុតស្ពាន ។ តាហានទាំងពួងឃើញជាក់ច្បាស់ក៏លុតជង្គង់ថ្វាយបង្គំទាំងអស់គ្នា រាំថយពីលើស្ពានចេញទៅ ព្រះពាជរថក៏លឿនផុតស្ពាន ។

ខណៈនោះនាយតាហានទាំង ២ នាក់ ត្រឡប់ទៅជ្រាបគុយតីថា ព្រះចៅហៀនតេ- យាងទៅដល់ស្ពានទន្លេប៉ាឡេងហើយឆ្ពងហួសទៅ

ហើយ ។ គុយគីពួដូច្នោះឮដឹងណាស់ថា "យើងស្តាប់តែវេតែមាត់យើងនឹងឲ្យលើកទាហានទៅស្កាត់ចាប់ព្រះចៅហ្នែនតែ ឯទីក្រុងដែលតាំងតុះសាងថ្មី, ហេតុអ្វីមិនធ្វើតាមបង្គាប់ ក៏ត្រឡប់ឲ្យស្តេចយាងហួសទៅបាន" ថាហើយក៏ឲ្យយកនាយទាហានតាំង ២ នោះទៅសម្លាប់ចោលរួចលើកទ័ពតាមទៅ ។ ព្រះចៅហ្នែនតេយាងទៅដល់ស្រុកហួហុំមក៏ឮនូវសំឡេងទាហានហោកញ្ជែវពីក្រោយថា នាហ្នឹងតាំងអស់គ្នាកុំអាលនាំយកស្តេចទៅណា ឲ្យបង្អង់ឈប់សិន ។

ព្រះចៅហ្នែនតេឮដូច្នោះ ទ្រង់ព្រះកន្ទែងសោកា ហើយត្រាស់ថា ផុតពីលើឈុយមកហើយគិតថានឹងធូរទូលាយសប្បាយចិត្តខ្លះ ថែមមកប្រទះនឹងទាហានតាំងផ្លូវស្ទានទៀត ឥឡូវនេះមានគេតាមមកជិតជិតដល់ទីនេះនឹងវាសទៅខាងណា ចេញពីមាត់ខ្វាទៅចូលមាត់ក្រពើដូច្នេះ គ្រានេះនឹងគិតដូចម្តេចទើបនឹងបានរួចក័យ ។ មន្ត្រីតាំងអស់មិនបានធ្វើយថាដូចម្តេច ។ ឯទ័ពគុយគីក៏លើកមួយរំពេចចូលមកទៀត, ព្រះចៅហ្នែនតេតែតែទ្រង់ព្រះកន្ទែងសោកានៅលើព្រះពាជវេថនោះ ។

ឯអ្នកវេហង ដែលរត់ពីលើឈុយទៅ។ នៅសំណាក់កងកុំសាំសាន់ខាងទិសបស្ចិមនោះ លុះដឹងដំណឹងថា ព្រះចៅហ្នែនតេស្តេចយាងទៅដល់ស្រុកហង់ឡង់ ក៏តាំងតែក្លុំសេនាទាហានលើកតាមស្តេចទៅ ដើម្បីនឹងជួយការពារសេចក្តីអន្តរាយ, លុះលើកទៅដល់ខ្លង់ទុំងក្បួនហែដែល

ស្តេចព្រះរាជដំណើរ ក៏ពើបពះច្រទះនឹងកងទ័ពគុយគីលើកដេញតាម
ពីក្រោយ អៀវហង៍ក៏លើកទាហានបណ្តាយចូលទៅស្ទាក់កងទ័ពគុយ-
គីជាប់ ។ ស៊ុយយ៉ុង៍សេនាគុយគីក្រឡេកឃើញកងទ័ពអៀវហង៍លើក
មកស្ទុក់ ក៏ញាក់សេះពារទាហានពានទៅពីមុខ ហើយស្រែកដេរ
អៀវហង៍ជាពាក្យអាស្រូវកាសផ្សេង។ ។ អៀវហង៍ទឹងណាស់ប្រើស៊ុ-
ឡុងសេនាឯកឲ្យកាន់ពូថៅធំដែកចេញទៅតយុទ្ធនឹងស៊ុឡុង ឃានតែមួយ
ស្រចក់ ស៊ុឡុងក៏កាប់ស៊ុយយ៉ុង៍ធ្លាក់ពីលើសេះស្លាប់ ។ អៀវហង
ក៏លើកកងទាហានបំពានចូលទៅ ប្រកាប់កងទ័ពគុយគីស្លាប់ដេរដាស
ពលទាហានរត់ទោសចូលព្រៃ ហើយដេញតាមទៅចម្ងាយផ្លូវប្រហែល
២០០ សិន (៨គ-ម៉) រួចអៀវហង៍លើកត្រឡប់នាំកងទ័ពចូលទៅ
ថ្វាយព្រះចៅហៀនតេ ។ ទ្រង់មានព្រះតម្រាស់សាកសួរដោយពេរពាយ
ហើយថា អៀវហង៍លើកទាហានមកជួយយើងគ្រានេះ ជាគុណូបការៈ
ដ៏ធំមន្ទំណាស់ យើងមិនភ្លេចគុណអ្នកតទៅទៀត ឯសេនារបស់អ្នក
ដែលឃានសម្លាប់ស៊ុយយ៉ុង៍នោះ ឥឡូវនៅឯណា ? សុំឲ្យនាំខ្លួនមកបង្ហាញ
ឲ្យយើងស្គាល់មុខ ។ អៀវហង៍ឲ្យហៅស៊ុឡុងចូលមកគាល់ ហើយ
អៀវហង៍ក្រាបបង្គំទូលថា ស៊ុឡុងនេះជាពួកអ្នកស្រុកហោតាំង ។

ព្រះចៅហៀនតេទ្រង់មានព្រះតម្រាស់ថា អ្នកតាំង ២ នេះឃាន
ធ្វើសេចក្តីគាប់ប្រសើរលើខ្លួនយើង។ សុំឲ្យអ្នកតាំងអស់គ្នានៅជាមួយនឹង

យើងតទៅចុះ ។ លុះលោយចប់អៀវហង៍ឲ្យរៀបតាំងបន្ទាយពាយដុំវិញ ដើម្បីការពារក្សាព្រះអង្គព្រះចៅហៀនតេ ។

ឯគុយគីដែលបែកទ័ពត្រឡប់ទៅនោះ ឃានបញ្ជុះបញ្ចូលប្រមូលសេនាឥឃានច្រើនឡើងវិញ លុះត្រឹកឡើងកំលើកជាកងទ័ពត្រឡប់តាមទៅច្បាំងនឹងអៀវហង៍ទៀត ។ ស៊ីឡុងក៏ប្រុងប្រៀបរៀបឥឃានជាកងទ័ពស្រេច ដល់ឃើញឥឃានគុយគីលើកទៅឡោមព័ទ្ធដុំវិញ ក៏បរសេះនឹងចេញទៅតទល់គ្នា ស្រាប់តែឃើញតាំងសុនលើកយោធាការពារលាយកងទ័ពគុយគី ពីទិសខាងកើតចូលមក កងទ័ពគុយគីបែកបាក់ខ្ចាត់ខ្ចាយរត់ប្រែតជ្រកជាចលាចល ។ ស៊ីឡុងក៏បរពលចូលទួចប់ពីខាងលិចគេចចាក់កាប់សម្លាប់ ឥឃានគុយគីវិនាសស្លាប់ជាច្រើន ។ គុយគីបែកទ័ពលើកត្រឡប់ទៅវិញ មិនមានសេសសល់ឡើយ ។

តាំងសុននោះមិញចូលទៅក្រាបបង្គំគាល់ព្រះចៅហៀនតេ។ ទតយល់តាំងសុន ទ្រង់ព្រះកន្ទែងថ្ងៃងសោក ត្រាស់បរិហារឿងការដែលព្រួយលំបាកឲ្យតាំងសុនស្តាប់គ្រប់ប្រការ ។ តាំងសុនក្រាបទូលថា កុំឲ្យព្រះអង្គទ្រង់ព្រះវិតក្កតទៅទៀត ការក្រអាយទូលាយចង្អៀត សឹមទូលព្រះបង្គំជាខ្ញុំនឹងអៀវហង៍ រងទូលរក្សាការពារព្រះអង្គតទៅ ឯខ្លួនអាសត្រូវតាំង ២ នាក់ ទូលព្រះបង្គំជាខ្ញុំនឹងសុំជាធុរៈកាប់សម្លាប់ចេញឲ្យបាន ដើម្បីនឹងឲ្យផែនដីជាសុខក្សេមក្សាន្តតទៅ ។ ព្រះចៅហៀន

តែទ្រង់ត្រែកអរសោទរក្នុងព្រះទ័យណាស់ ត្រាស់ឲ្យលើកព្យុហៈទ័ពទៅ
តាំងយប់តាំងថ្ងៃ ក៏បានទៅដល់ស្រុកហង់ឡុង ។

ឯគុយគីមានតែទីពេមនស្ស ព្រោះចាញ់ទ័ពពីរគ្រា ទំរែមូល
ពលយោធាដែលបាក់បែកនោះបានមកវិញខ្លះ ។ ខាងលីឈុយនោះ
លើកកងទ័ពតាមទៅទៀត ប្រាថ្នាទង់ធ្វើអន្តរាយព្រះចៅហៀនតេឲ្យបាន,
លុះទៅចួបទង់គុយគី អ្នកទាំង ២ ក៏សះជានឹងគ្នាហើយប្រកាន់ថា តាំង
សុំនទឹងអៀវហង់ នាំយកព្រះចៅហៀនតេស្តេចទៅឯស្រុកហង់ឡុង
ដែលមានផ្លូវទៅលើក្រុងតៀវហាន់, បើស្តេចរហូតទៅទៅតាំងទ័ពខ្ជាប់
ខ្ជួនក្នុងស្រុកតៀវហាន់ហើយ គង់ទង់មានសំបុត្រព្រះតម្រាស់ទៅដល់
អាណាខែត្រក្រៅតាំងប៉ុន្មាន ឲ្យលើកពលទាហានមកធ្វើទុក្ខបុកម្នេញ
យើងតាំង ២ ជាប្រាកដ ។ លីឈុយតបថា ឥឡូវនេះតៀវចេតាំងទី
រក្សាស្រុកតៀវហាន់ មានសេនាទាហានខ្លាំងពូកែច្រើនណាស់ យើង
ទង់លើកទៅប៉ះក៏មិនបាន ត្រូវតែយើងតាំង ២ លើកតាមទៅឯស្រុក
ហង់ឡុងវិញ ដើម្បីទង់ចាប់យកព្រះចៅហៀនតេសម្លាប់ចេញ បើសម្លាប់
បានហើយ ទ្រព្យសម្បត្តិតាំងប៉ុន្មានយើងត្រូវបែងចែកគ្នាពាក់កណ្តាល
ម្នាក់ ។ គុយគីបានស្តាប់ក៏ចាប់ចិត្តគិតអរណាស់ ព្រោះជាមនុស្សមាន
សេចក្តីលោភលន់ នាំលីឈុយលើកទ័ពទៅដល់ទីតំបន់ណា ឲ្យសេនា
ទាហានទន្ទ្រានបែកឥតត្បាតយកទ្រព្យរបស់ អស់អាណាប្រជានុរាស្ត្រ
ក្នុងទីនោះ ។

ចំណែកតាំងសុំនអៀវហាងនាំស្តេចទៅដល់តំបន់តាន់កាន់ ដឹងថា "លីឈុយ នឹងគុយគី រួមគំនិតគិតលើកទ័ពតាមចាប់ព្រះចៅហ្វានតេ" ក៏បញ្ជូនពួកកងទ័ពទៅទីនោះ ហើយប្រុងប្រៀបរៀបសេនាគាហានការពារក្សាព្រះអង្គ ។

ឯលីឈុយនឹងគុយគីប្រឹក្សាគ្នាថា "គាហានយើងលើកមកច្រើនជាងគាហានតាំងសុំននឹងអៀវហាង យើងនឹងលើកធ្វើងចូលទៅតតាំងច្បាំងដណ្តើមយកព្រះចៅហ្វានតេប្រហែលជាបាន" លុះគិតព្រមគ្នាហើយក៏បែងកងទ័ពម្ខាត់ពាក់កណ្តាលលើកចូលទៅដាប៉ែកធ្វើង - ស្តាំ ។ តាំង-សុំននឹងអៀវហាងក៏វេចទ្វួលតតាំងច្បាំងគ្នា លុះយើញថាកំឡាំងនឹងតទល់ពុំឈ្នះ តាំងសុំននឹងអៀវហាងក៏លើកច្បាសតែយកតែខ្លួន ចោលអស់របស់ទ្រព្យនឹងគ្រឿងប្រដាប់ផ្សេង ។ ហើយនាំយកព្រះចៅហ្វានតេនឹងព្រះអគ្គមហេសីស្រីព្រះស្នំទៅអស់នាហ្នឹនមុខមន្ត្រី ពារំលាយកងទ័ពលីឈុយគុយគីចេញទៅទិសខាងជើង ។ លីឈុយគុយគីក៏លើកគាហានដេញចេញទៅ, ឯទ្រព្យរបស់ដែលសល់នៅ ពួកគាហានលីឈុយគុយគីរើដញ្ជួនយកទៅតាំងអស់ យកតាំងទ្រព្យរបស់អាណាប្រជានុរាស្ត្រក្នុងស្រុកហាងឡុងថែមទៀត ។

(មានត)

ភាគទី ២

សម័យនគរធំ

ឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(តទៅ)

ការបេញក្រៅព្រះបរមរាជវាំង – តាមសេចក្តីកត់ហេតុរបស់ជាវគាក្លួន និយាយត្រួសថា: វេលាស្តេចចេញក្រៅព្រះបរមរាជវាំង រមែងមានក្បួនហែជាដរាប, ក្បួនហែជាធម្មតា (មិនមែនក្បួនសឹក) មានរបៀបយ៉ាងនេះ :

ទី ១ – កងឥស្សានសេះ មានចំនួនច្រើន ហែនាំមុខបង្អស់ ។

ទី ២ – បន្ទាប់មក ក្រុមទន់ជ័យធំ នឹងក្រុមទន់ជ័យតូច ។

ទី ៣ – ក្រុមក្មេងផ្សេងៗ ។

ទី ៤ – ក្រុមកុមារីក្នុងព្រះបរមរាជវាំង មានចំនួនពី ៣០០ ដល់ ៥០០ នាក់ កាន់ក្តីងខ្សែនធំៗ ហែ(១) ។

ទី ៥ – ពួកកុមារីក្នុងព្រះបរមរាជវាំង ដែលជាមហាតឡិក កាន់គ្រឿងរាជូបភោគ សុទ្ធសឹងជាមាស-ប្រាក់ទាំងអស់ នឹងគ្រឿងប្រដាប់ផ្សេងៗ យ៉ាងដទៃទៀត ជាច្រើន ។

---

១ ពោះស្តេចចេញវេលាថ្ងៃ ក៏មានហែភ្លើងដែរ ។

ទី ៦ - ពួកស្ត្រីក្នុងព្រះបរមរាជវាំង ជាក្រុមតម្រួតកាន់លំពែងនឹងខែលដើរហែជាដួរ។ ។

ទី ៧ - ក្បួនរថសេះ សឹងរថនាដោយមាសច្រាលឆ្លៀត ។

ទី ៨ - គណៈសេនាបតី នឹងព្រះរាជវង្សានុវង្ស ជាយ៉ាងច្រើនជិះដំរី ដ៏ដេរជាសទៅដោយកូស់ក្រហមច្រាល ។

ទី ៩ - ព្រះអគ្គមហេសី នឹងពួកព្រះស្រីគ្នារ ខ្លះជិះអង្រឹងស្នែង ខ្លះជិះរថ ខ្លះជិះដំរី ច្រើនខ្នាន់ខ្នាប់ មានកូស់មាសបើកបាំង ច្រើនជាងរយ ។

ទី ១០ - ព្រះមហាក្សត្រិយ៍ ស្តេចស្ថិតឈរលើដំរីព្រះទីនាំង ១ ព្រះហស្តខ្ចែងកាន់ព្រះខាន់ យ៉ាងសង្ហា, ក្នុកដំរីព្រះទីនាំងសឹងស្រោបមាសគាំងសង្ខាង មានព្រះកូស់មាសជាង ២០ បើកបាំង នឹងមានមាហានកងដំរី កងសេះ ចោមរោមជាយសបរិវារ ។

ការព្រះសាសនា - សាសនានៅប្រទេសកម្ពុជាក្នុងសម័យនោះ មានតែសាសនាព្រាហ្មណ៍ នឹងព្រះពុទ្ធសាសនាប៉ុណ្ណោះ ។ តែសាសនាព្រាហ្មណ៍កំពុងរៀវរោយចុះ ព្រះពុទ្ធសាសនាបានឡើងជាសាសនាសម្រាប់រដ្ឋ តាំងអំពីរជ្ជកាលព្រះបាទជយវរ្ម័នទី ៧ មកហើយ ។ ជាវិសាកសួនថា អ្នកកាន់សាសនាក្នុងគ្រានោះមាន ៣ ពួក គឺ :

១ - ពួកបណ្ឌិត, ពួកនេះគេចាត់ជាបុគ្គលជាន់ខ្ពស់ ដោយមានសេចក្តីចេះដឹងគាំងកងផ្លូវសាសនាព្រាហ្មណ៍ គាំងកងផ្លូវព្រះពុទ្ធសាសនា

ទឹងក្នុងបច្ចាប់ទម្លាប់ ទឹងគតិលោកគ្រប់យ៉ាង ។ ពួកនេះ ស្លៀកពាក់ដូចអ្នកស្រុកធម្មតា ប្លែកតែមានខ្សែអំបោះសចង់នៅកជាគ្រឿងសំគាល់ ។

២- ពួកបស្សី, ពាក្យថា បស្សី ស្លៀងចេញពីពាក្យសំស្ក្រឹតថា តបស្សី (ប៉ាលីថា តបសី) ដែលយើងច្រើនហៅថាតាបស ។ ពួកនេះគឺជាអ្នកកាន់លទ្ធិសៃ មានប្រក្រតីគោរពរូបសិវលិង្គ ដែលគេច្រើនធ្វើអំពីថ្ម ទំនងប្រហែលអ្នកកាន់សាសនាសៅអ៊ិស្ម ដែលគោរពដុំថ្មបែបនេះដែរ ។ ពួកនេះគេថា ស្លៀកពាក់សំពត់ពណ៌ក្រហមឬស ហើយមានសំពត់សសម្រាប់ជូតក្បាល មានអាសមតូច។ ជាទីប្រតិស្ឋានសិវលិង្គ ហើយទឹងជាទីគោរពបូជា តែក្នុងគ្រានោះ ។ ពួកនេះមានចំនួនតិចណាស់ទៅហើយ ទាំងគ្មានសេចក្តីរុងរឿងទេ ។

៣- ពួកចៅកូវ, នេះជាពាក្យខ្មែរបូរាណ សម្រាប់ហៅបព្វជិតក្នុងព្រះពុទ្ធសាសនា ត្រង់ទឹងពាក្យក្នុងបច្ចុប្បន្នថា លោកសង្ឃ, សម័យនេះនៅមានន័យយូរដែរឆ្ងើល។ ដូចយ៉ាងលោកសង្ឃ លោកចៅកូវ ។ ព្រះពុទ្ធសាសនាក្នុងជំនាន់នេះ មានតែលទ្ធិស្ថវីរៈ ១ យ៉ាង, លទ្ធិមហាយានរៀវភេយអស់ហើយ មកពីមិនសូវមានខ្លឹមសារ ។

ព្រះសង្ឃក្នុងសម័យនោះ ឃើញដូចជាមានការតែងតាំងឲ្យមានសមណសក្តិធំ-តូចដូចក្នុងសម័យនេះដែរ ។ ប្លែកដក្នុងសេចក្តីកត់ហេតុថា ព្រះសង្ឃអ្នកមានសមណសក្តិខ្ពស់ ទ្រង់ព្រះរាជានុញ្ញាតឲ្យប្រើរទឹង

ក្ងស់ដងមាស, អ្នកមានសមណសក្តិបន្ទាប់មកឲ្យប្រើ ៤ នឹងក្ងស់ដងប្រាក់, ពាបជាង៤នេះមកទៀត ឲ្យប្រើអ្វី មិនឃើញមានពោលដល់ ។

ព្រះបាទស្រីន្ទ្រវរ្ម័នទី ២ ទ្រង់ព្រះបន្ទូលថា ម្នាលក្តីស្តាវ: ។ កន្លះសេចក្តីកត់ហេតុថា តែង៤ស្តេចទៅនមស្សការព្រះចេតិយមាស ១ ជាញឹកញយ ។ ព្រះចេតិយមាសនោះប្រហែលជាទ្រង់សាង៤ឡើងដោយព្រះអគ្គឯង៤ នៅកន្លងទីវត្តណាមួយដ៏មានកន្លះកំពែងក្រុង ។ ចំណែកឯប្រជាជនខ្មែរភាគច្រើនជាបំផុត ជាអ្នកកាន់ព្រះពុទ្ធសាសនា មានវត្តអារាមដេរដាសនៅក្នុង៤ព្រះរាជអាណាចក្រ ។

ព្រះបាទស្រីន្ទ្រវរ្ម័នទី ២ ស្តេចស្ថិតនៅក្នុង៤រាជសម្បត្តិមកដល់ឆ្នាំ ព. ស. ១៨៥០ ទើបសោយទិវង្គត, គេថ្វាយព្រះនាមព្រះបរមសពដូចម្តេចមិនប្រាកដ ។ (មានត)

សូមកុំក្រេង

អ្នកដែលទទួលវង៤ណ្ឌកម្ម ព្រោះជាតិមាតុភូមិ ជាមនុស្សប្រសើរ ។ សេចក្តីស្ងប់ ព្រោះយកអាសាមាតុភូមិ ទុកជាជោគដែលគួរប្រាថ្នា ។ សេចក្តីស្នេហាចំពោះមាតុភូមិ ប្រសើរខ្ពង់ខ្ពស់ជាង៤អ្វីទាំង៤អស់ ។

រឿងអាវ័ក្យថ្លែងរឿងថ្លៃថ្លា

លោកសាង · សារ៉ាត លេខាធិការ ក្រសួងបរិរញ្ញវត្ថុ

ប្រែពីភាសាចាំងមកជាខ្មែរ

(តមក)

រឿងទី ៣

អាវ័ក្យមានវាចាថា "ឧ មហារាជ! មានទីក្រុងមួយ ហៅថា ក្រុងចាធ្វិន (Bardhvan) ។ ថ្ងៃមួយនោះព្រះចាឫបសេន (Rûpsên) ជាព្រះចៅនៃទីក្រុងនេះ ស្តេចទ្រង់ប្រថាប់ក្នុងបន្ទប់មួយ នៅក្បែរទ្វារព្រះរាជវាំង មានសូរស័ព្ទសន្ធឹកមួយ ចូលពីក្រៅមកដល់ព្រះអង្គ ។ ព្រះអង្គក៏ទ្រង់ត្រាស់សួរថា: "អ្នកណានៅមាត់ទ្វារ? រួចតើសូរស័ព្ទអ្វី?" ។

អ្នកយាមទ្វារទូលព្រះរាជាវិញថា "សំនួរដែលព្រះករុណាថ្លៃវិសេសត្រាស់សួរនេះប្រពៃណាស់! សូមព្រះករុណា ទ្រង់ជ្រាបថា ធម្មតាមាត់ទ្វាររបស់ជនអ្នកមានសម្បត្តិ ហើយដែលអ្នកផងគេស្គាល់ច្រើននាក់នោះ តែងសម្បូរណ៌ដោយជនពាលឡាយដែលតណ្ហាក្នុងធនធានប្រយឹតប្រាថ្នាពុំខាន; ឯជនពាលឡាយនេះ អង្គុយហើយជជែកគ្នាអំពីរឿងផ្សេងៗ នេះហើយជាដើមហេតុនៃសូរស័ព្ទនេះ" ។ ព្រះរាជាលុះទ្រង់ព្រះសណ្តាប់ដូច្នោះ ទ្រង់គង់នៅស្ងាត់ស្ងៀម ។

ក្នុងពេលនោះ មានអ្នកដំណើរម្នាក់មកពីទិសខាងត្បូង ជានាយសេនាកងទ័ព ឈ្មោះបីរបារ «Birbar» បានមកបង្ហាញខ្លួន ទៅមាត់ទ្វារព្រះបរមរាជវាំង ដោយប្រាថ្នាចង់ចូលបំរើព្រះរាជា ។ ឯនាយយាមទ្វារលុះបានដឹងបំណងនេះ ក៏ទៅបង្គំទូលព្រះចេស្តាថា "សូមទ្រង់ព្រះមេត្តាប្រោស ! មានមនុស្សម្នាក់ ជាអ្នកចំបាំងបានមកដល់ ហើយមានបំណងចង់ថ្វាយខ្លួនបំរើព្រះអង្គ ឥឡូវឈរនៅមាត់ទ្វារ រង់ចាំព្រះរាជានុញ្ញាត ដើម្បីចូលបង្ហាញខ្លួនចំពោះព្រះអង្គ" ។ លុះកាលណាបានព្រះរាជានុញ្ញាតឲ្យនាំបុរសនោះមកហើយ នាយយាមទ្វារក៏ទៅនាំបុរសនោះមក ។ ព្រះមហាក្សត្រិយ៍មានព្រះរាជឱង្ការសួរថា: "អ្នកត្រូវការសុំអ្វីដើម្បីចាយវាយពាល់ថ្ងៃ?" ។

បីរបារ ទូលថា: "សូមព្រះអង្គប្រោសព្រះប្រាននូវមាស ១ ពាន់ហ៊ុន ពាល់ថ្ងៃឲ្យទូលព្រះបង្គំ ព្រោះមាសចំនួនប៉ុណ្ណោះ ទូលព្រះបង្គំអាចចិញ្ចឹមជីវិតរស់បានហើយ" ។ ព្រះរាជាមានព្រះបន្ទូលសួរទៀតថា: "ចុះគីគាអ្នកឯង មានប៉ុន្មានអ្នកដែលនៅជាមួយ?" ។ បីរបារ ក្រាបបង្គំទូលទៀតថា: "ដំបូងបង្អស់ ទូលព្រះបង្គំមានប្រពន្ធមួយ, បន្ទាប់ទី ២ កូនប្រុសមួយ, ទី ៣ កូនស្រីមួយ, ទី ៤ មានខ្លួនទូលព្រះបង្គំនេះ" ។

"ហេតុអ្វីបានជា មនុស្សនេះ សុំប្រាក់ច្រើនដល់ម្ល៉េះ?" ។ ប៉ុន្តែលុះទ្រង់គិតថា ប្រាក់អស់នេះ អាចបង្កើនប្រយោជន៍ ដល់បុរសនេះ ។

ក្នុងថ្ងៃមួយ ព្រះអង្គក៏ទ្រង់ត្រាស់ហៅអ្នកអមព្រះអង្គមក ទ្រង់បង្គាប់ឲ្យយកលុយឃ្វាំងរាល់ថ្ងៃ ចំនួន ១ ពាន់ហ៊ុន ដើម្បីឲ្យទៅបីវចារ។ ដែលបានមាស ១ ពាន់ហ៊ុននោះ ក្នុងថ្ងៃនោះភ្លាម ក៏យកមាសនោះទៅដល់ផ្ទះ ។ បីវចារតាំងចែកជាពីរចំណែក មួយចំណែកឲ្យទៅព្រាហ្មណ៍, មួយចំណែកទៀត បែងចេញជាពីរភាគទៅទៀតហើយយកមួយភាគឲ្យទៅពួកបូជនីយេសក៍ (Pèlerins) ឲ្យទៅព្រះសង្ឃ ឲ្យទៅអ្នកដែលគោរពវិស្ណុ ឲ្យទៅសូមយាចក, ឯមួយភាគទៀតនោះឲ្យធ្វើម្ហូបអាហារឲ្យអ្នកក្រីក្របរិភោគ រួចអ្នកបរិភោគតែម្ហូបណាដែលសល់ ។

បីវចារធ្វើតែយ៉ាងដូច្នេះ ជាមួយប្រពន្ធ និងកូនរបស់ខ្លួន ។ រួចដល់ពេលយប់ បីវចារយកខែលនិងដាវរបស់ខ្លួនមកកាន់ ហើយឈរយាមល្បាតនៅក្បែរគ្រែព្រះរាជា ។ ដល់ព្រះអង្គតើនឡើងទ្រង់សួរថា: "អ្នកណានោះ?" ។ បីវចារទូលវិញថា: ទូលព្រះបង្គំឈ្មោះបីវចារ ទូលបង្គំចាំទទួលព្រះរាជឥណ្ណាស់" ។

គ្រប់តែពេលដែលព្រះរាជាទ្រង់ហៅ, បីវចារបង្គំទូលតែពាក្យដដែលនេះ រួចតែងធ្វើតាមបង្គាប់ព្រះរាជាគ្រប់អស់ ទោះយ៉ាងណាក៏ដោយ ។ ដើម្បីឲ្យបានច្បាស់នោះ បីវចារមើលថែព្រះមហាក្សត្រិយ៍តែយ៉ាងដូច្នោះ រៀងរាល់ទិវាតិ ។ បីវចារបរិភោគអាហារក្តី ដឹក

ទឹកក្តី ដេកក្តី សំពកក្តី ដើរក្តី ឬដើរលេងក្តី តែងគិតដល់កិច្ចការរបស់
ចៅហ្វាយនាយខ្លួនណាស់ ។

នេះជាការណ៍ពួកគេ "ដូនណាលក់អ្នកដឹតខាងរបស់ខ្លួន ដូនោះ
ត្រូវគេលក់ខ្លួនវិញ" ។ ប៉ុន្តែអ្នកបំរើល្អដែលចូលធ្វើការ លក់ខ្លួនឯង ។
ដល់លក់ខ្លួនឯងដូច្នេះ ត្រូវតែនៅកន្ទុយរបស់ចៅហ្វាយនាយរបស់ខ្លួន ។
ចុះតើអ្នកដែលនៅក្រោមទុយ៉ាងណាទៅ? គឺ
ជាការណ៍មួយពិតប្រាកដណាស់ ធម្មតាអ្នកដែលបំរើគេ តែងមានដំរេះ
តែងប៉ុនប្រសប់ តែងមានប្រាជ្ញា យ៉ាងណាក៏ដោយ ទៅជាគេវិញមិន
មានដោយសេចក្តីខ្វាច ការណ៍នៅពីមុខចៅហ្វាយនាយរបស់ខ្លួន ។
អ្នកបំរើនេះ តែងនៅស្ងៀមដកបរ ហើយបានឆ្ងរស្បែយនោះ លុះត្រាតែ
បាននៅឆ្ងាយអំពីចៅហ្វាយនាយ ។ ដោយអាស្រ័យហេតុទាំងនេះហើយ
បានជាអ្នកប្រាជ្ញនិយាយថា: "ការដែលធ្វើដោយសម្បជញ្ញៈ ពិបាក
ជាងការបួសទៅទៀត" ។

គេនិទានថា ម្តងនោះ នៅពេលយប់គេឮសូរសេម្ងសីម្នាក់យំ
នៅចាំធា ។ ព្រះមហាក្សត្រិយ៍ដែលទ្រង់បានឮសូរសេម្ងនេះ ស្តេច
ទ្រង់មានព្រះរាជឱង្ការថា: "អ្នកណានោះ?" ។ ឯបំរើបាវ ដល់ឮព្រះ
រាជាទ្រង់សួរ ក៏ធ្វើយទូលទៅព្រះអង្គវិញថា: "ទូលព្រះបង្គំនៅនេះ
តើព្រះអង្គឆ្ងាប់យ៉ាងណា?"

ព្រះអង្គក៏ទ្រង់បង្គាប់ថា: "ចូរឯងទៅត្រង់កន្លែងដែលគេឮមាត់ស្រីយំនោះ សាកសួរមើល តើវាយំអី? ហេតុយ៉ាងណា បានជាវាយំនេះ រួចត្រឡប់មកវិញឲ្យឆាប់" លុះទ្រង់បង្គាប់ដូច្នោះហើយ ព្រះរាជាទ្រង់គិតថា: "ដើម្បីពិសោធមើលចិត្តអ្នកបំរើរបស់ព្រះអង្គ គ្មានអ្វីក្រៅអំពីប្រើវា ពេលណាក៏ដោយដូច្នេះទេ ។ បើសិនណាជាវាធ្វើតាមបង្គាប់នេះ អញនឹងដឹងថាវាមានប្រយោជន៍ ។ បើវាប្រែតែវិញវាគ្មានបានការអ្វីទេ ។ គឺក្នុងពេលលំបាកហើយ ដែលគេត្រូវពិសោធចិត្តបងប្អូន មិត្តភក្តិរបស់ខ្លួន ។ ១ ទៀត គឺនៅក្នុងគ្រាគ្រឹះហើយដែលគេស្គាល់ស្រី" ។

លុះទទួលបង្គាប់ហើយ បីវ៉ាវ ក៏ដើរឆ្ពោះតម្រង់ទៅកាន់ទីដែលសូរយំមកនោះ ឯព្រះរាជាដើម្បីជ្រាបចិត្តក្លាហានដល់ណា របស់បីវ៉ាវ ស្តេចទ្រង់ស្ងៀកពាក់ខ្មៅ ហើយយាងតាម ដោយមិនឲ្យដឹងឡើយ ។ កាលណាបុរសទៅដល់ប៉ាន ដែលសម្ងួនយំចេញមកនោះ អ្នកស្រឡាំងកាំងដោយបានឃើញស្ត្រីម្នាក់ល្អឯក ពាក់គ្រឿងអលង្ការពីក្បាលដល់ចុងជើង ។ នាងថ្ងូរ ហើយទាំងធ្វេញ ដោយសេចក្តីអស់សង្ឃឹម ។ ដួងកាលនាងរាំ ដួងកាលនាងលោត ដួងកាលនាងវត់ទៅម្ខាង រួចទៅម្ខាងទៀត ប៉ុន្តែក្នុងភ្នែកនាងគ្មានទឹកភ្នែកសោះ ។ នាងញីញក់ក្បាលរបស់នាង នាងស្រែកច្រៀងហាមិនឈប់ នាងនៀលលើដី ។ លុះ

យើញដូច្នោះ បីវជ្ជោ សាកសួរនាងអំពីហេតុដែលបណ្តាលឲ្យនាងយំ នាងទុក្ខសោកយ៉ាងណាខ្លះហើយ តើមានទុក្ខអ្វី? ។ នាងឆ្លើយថា: "ខ្ញុំជាទេវតារក្សាស្តេច" ។ បីវជ្ជោ សួរទៀតថា: "ហេតុអ្វីបានជានាងយំ?" ។

នាងក៏និយាយថា ក្នុងព្រះបរមរាជវាំងនឹងមានកើតអំពើអកុសលដែលជាដើមហេតុនៃទុក្ខយ៉ាងធំ ។ នាងនិយាយបន្តទៀតថា: "ខ្ញុំនឹងចាកចេញអំពីវាំងនេះហើយ ដល់មួយវេរៈក្រោយទៀត ព្រះមហាក្សត្រិយ៍មុខជាទ្រង់ទិវង្គត ដល់ស្តេចទ្រង់ច្រឈួនយ៉ាងធ្ងន់ដូច ។ ខ្ញុំអាស្រូវដល់ហេតុអាក្រក់នេះណាស់ ដែលធ្វើឲ្យខ្ញុំមានទុក្ខព្រួយជាពន់ពេក ព្រោះខ្ញុំតែងរក្សាសេចក្តីសុខក្នុងវាំងនេះ ។ ឯទុក្ខនេះដៀសមិនផុតទេ" ។

បីវជ្ជោសួរថា: "តើគ្មានថ្នាំណាមួយ អាចទប់ទល់បានឬអ្វី? តើគ្មានអ្វីមួយអាចជួយសង្គ្រោះជីវិតព្រះរាជា ហើយធ្វើឲ្យព្រះអង្គគង់ធម្មបាន ១០០ ព្រះវស្សាទេឬអ្វី?" ។ នាងឆ្លើយទៀតថា: "ចំនួន ៤ យោជន៍ពីនេះ មានព្រះវិហារមួយរបស់ទេវតាមួយ ។ បើសិនណា អ្នកកាត់សិរសាកូនប្រុសរបស់អ្នក ដោយដៃអ្នក យកទៅថ្វាយដល់ទេវតានោះ ព្រះមហាក្សត្រិយ៍ នឹងបានសោយរាជ្យចំនួន ១០០ ឆ្នាំទៀតមុខទៀត ហើយគ្មានទុក្ខសោកអ្វីអាចមានដល់ព្រះអង្គឡើយ" ។

លុះកាលណាបានឮពាក្យអស់នេះហើយ ប៊ីរប៉ាត្រឡប់ទៅលំនៅអាត្មាវិញ ដោយមានព្រះមហាក្សត្រិយ៍លបតាមពីក្រោយផង ។ លុះបានទៅដល់ផ្ទះរបស់អ្នកកាលណា អ្នកជាស់ករិយា ហើយនិទានរឿងសព្វគ្រប់ប្រាប់នាង ។ ឯនាង លុះបានឮដូច្នោះ ក៏ជាស់កូនប្រុសនឹងកូនស្រីរបស់នាង ។ នាងមានវាចាទៅកាន់កុមារថាដូច្នេះ "កូនប្រុសមាសម្លាយ កាលណាឯងថ្វាយសិរសាឯង ព្រះមហាក្សត្រិយ៍នឹងរួចជន្មជិវិត ហើយព្រះអង្គបានសោយសម្បត្តិតទៅមុខទៀត" ។

លុះបានឮពាក្យនេះ កុមារឆ្លើយតបប្រាប់មាតាថា: "ឧអ្នកម្លាយ! តែដ៏ថ្លៃថ្លាបំផុតរបស់កូននេះ គឺបង្គាប់របស់អ្នកម្លាយ រួចគឺប្រយោជន៍របស់នាយចៅហ្វាយកូន ។ ម្យ៉ាងទៀត កូនលោកិយនេះ តើមានវត្ថុណាមួយដែលគាប់ប្រសើរជាងធ្វើពលិកម្មរួបខ្លួន ថ្វាយដល់ទេវតានោះ? បើសិនណាពលិកម្មនេះ ខានមិនបានទេ មិនត្រូវវាវែកឡើយ ។ មានភាសិតមួយនិយាយថា: "ជនណាមានវត្ថុតាំងប្រាំដូចតទៅនេះ គឺកូនមួយដែលចំណុះ, រូបកាយមួយដែលគ្មានភេគា, វិទ្យាសាស្ត្រ, មិត្តមួយមានប្រាជ្ញា នឹងប្រពន្ធមួយដែលស្អាប់បង្គាប់ ជននោះអាចបានសប្បាយជាពន់ពេក ហើយគ្មានទុក្ខអ្វីឡើយ ។ ចំណែកអ្នកបំរើម្នាក់ចិត្តក្បត់, ស្ពៃចមួយអង្គកំណាញ់, មិត្តមួយអាក្រក់, ប្រពន្ធមួយឯកច្ឆន្ទ វត្ថុ

ចាំងបួននេះដែលនាំឲ្យមានទុក្ខ ហើយនាំឲ្យវិលឲ្យល់ជាពន់ពេក" ។
ឯបីរបាវ និយាយទៅកាន់ការិយារបស់អ្នកថា "បើសិនណាអូនសុខចិត្ត
ឲ្យកូនមកបងដោយរីករាយ បងនឹងយកកូននេះទៅ រួចបងនឹងសម្លាប់
ចោយទៅតាដោយស្នេហាស្តេចក្រែណាស់នេះ" ។

នាងក៏និយាយថាដូច្នេះ "កូនប្រុស កូនស្រី មិត្តភ័ក្តិ បងប្អូន
របស់ខ្ញុំគ្មានថាអ្វីចាំងអស់ ។ សេចក្តីរីករាយសប្បាយរបស់ប្អូន គឺស្ថិត
នៅនឹងរូបបង ។ គេមានសរសេរក្នុងសៀវភៅទេសការិយាថា "ស្រីមួយ
មិនអាចល្អទៅកើត ដោយនាងនោះធ្លាប់បុណ្យ ឬបួសនោះទេ គឺដោយ
នាងនោះបំរើប្តីយ៉ាងស្មោះត្រង់ ទោះប្តីនោះ ក ថ្ងង់ ខ្វាក់ ខ្វាក់ខ្លាង ឃ្លង់
ឬគមន្តយ៉ាងណាក៏ដោយ ។ បើស្រីនោះមិនស្តាប់បង្គាប់ប្តីទេ មុខជា
ធ្លាក់កងអវិចី ទោះបីនាងនោះបានធ្វើគុណធម៌យ៉ាងណាក្នុងលោកនេះ
ក៏ដោយ" ។

កុមារនិយាយម្តងទៀតថា: "លោកឪពុក! មនុស្សដែលមាន
ប្រយោជន៍ដល់ទៅហ្វាយនាយរបស់ខ្ញុំ តែងមានជីវិតមួយបរិបូណ៌
ដោយទ្រព្យនៅស្ថានតណ្ហាលនេះ រួចដោយសារជម្ងៃរបស់សង្ខារនេះ
មនុស្សនោះអាចបានសុខកងលោកចាំងពីរមិនខាន" ។

នាងបុត្រនិយាយថា: "បើសិនមានតាំពូលបុត្រ, រួចបិតាលក់បុត្រ ឯស្តេចវិបជានសម្លាត្តិ តើអ្នកណាមួយការពារយើង?" ។

លុះដដែកដូច្នេះហើយ ជនពាំងបួននាក់ នាំគ្នាត្រសង៍ទៅព្រះវិហារ ឯព្រះមហាក្សត្រិយ៍ក៏ទ្រង់យាងលបតាមពីក្រោយដរាប ។

កាលណាបីវច្ចារទៅដល់ហើយ អ្នកចូលទៅក្នុងព្រះវិហារទៅតាសំពះរួចបន់ថា: "ឧទេវី! ខ្ញុំធ្វើពលិកម្ម កូនប្រុសខ្ញុំថ្វាយលោក សូមឲ្យលោកធ្វើតបវិញ ដោយធ្វើឲ្យសង្ខារស្តេច តើនឡើងឲ្យបានចំនួន ១០០ ឆ្នាំទៀត" លុះបន់ដូច្នោះរួចអ្នកហូតដាវ ។ ឯសិរសាបុត្រាបស់អ្នក ក៏ជាប់ធ្លាក់ដល់ធរណី ។ លុះឃើញបង់ប្រុសនាងស្ងាប់ដូច្នោះ នាវីកូនស្រីក៏យកដាវកាត់កខ្វងឯង ហើយក្បាលនាងក៏ធ្លាក់ជាប់អំពីខ្នងនាងទៅ ។ ឯកវិយារបស់បីវច្ចារ លុះឃើញកូនប្រុស កូនស្រីស្ងាប់អស់ដូច្នោះ នាងចាក់បំពង់កនាងមួយកាំបិត រួចក្បាលនាងក៏ធ្លាក់ដែរ ។ លុះឃើញស្ងាប់ពាំងបីដូច្នោះហើយ ចំវច្ចារគិតថា: "ឥឡូវនេះ កូនរបស់អញស្ងាប់អស់ហើយ តើនៅបំរើអ្វី? តើអញឲ្យមាសដែលអញបានអំពីស្តេច ទៅអ្នកណា?" ថាហើយអ្នកយកកាំបិតស្នៀតចាក់ខ្លួនឯង រួចសិរសារបស់អ្នកក៏ជាប់ធ្លាក់ដល់ដី ។

លុះឃើញជនពាំងបួនស្ងាប់ ព្រះពជ្ឈទ្រង់នឹកថា: "ក្រុមញាតិរបស់បីវច្ចារពាំងមូលស្ងាប់ពីព្រោះអញ ។ សុំឲ្យអន្តរធានដល់រដ្ឋកិច្ចល

ដែលបានបំផ្លាញគ្រួសារមួយទាំងមូល រួចដែលបុគ្គលម្នាក់ខាន់វង្វាតិបាល
នេះ មិនត្រូវសោយរាជ្យដូច្នេះទេ" ។ លុះទ្រង់គិតដូច្នេះ ស្តេចទ្រង់
ទាញជាវរបស់ព្រះអង្គ ដើម្បីពិឃាដជីវិតព្រះអង្គ ស្រាប់តែទេវតាមក
ដល់ចាប់ព្រះហស្ត ហើយនិយាយទូលទៅព្រះអង្គថា: "នុកូន!
យើងឥតញ៉ែចិត្តនឹងបំណងរបស់អ្នកហើយ រួចយើងឲ្យអ្នកសុំអ្វី យើងសុំ
ឲ្យបានតាមចិត្ត" ។

ព្រះមហាក្សត្រិយ៍ទ្រង់ឆ្លើយវិញថា: "មាសម្លាយ! បើអ្នក
សប្បាយនឹងកូនហើយ កូនសុំឲ្យអ្នកធ្វើឲ្យសត្វទាំងបួននេះរស់មានជីវិត
ឡើងវិញ" ។ ទេវតានិយាយថា "មិនអីទេ យើងធ្វើឲ្យ" ។

អាក្សលុះនិទានរឿងមកដល់នេះទើបបន្តែមថា: "សាធុ អ្នកចំរើ
ណាដែលមានចិត្តស្នេហានាយចៅហ្វាយរបស់ខ្លួន មិនគិតរួញរាបូជាជីវិត
នឹងជីវិតគ្រួសាររបស់ខ្លួន, ម្យ៉ាងទៀត សាធុ ស្តេចអង្គណា ដែល
មិនសូវចង់ជាប់នឹងព្រះពជ្ឈានី ហើយនឹងសង្ឃារបស់ព្រះអង្គ" ។


"នុមហាពជ ខ្ញុំសូមសួរទ្រង់ ក្នុងបណ្តាជនទាំងពីរនេះ តើជន
ណាមួយមានគុណធម៌លើសគេបំផុត?" ។

ព្រះបាទពិកវ័ន ទ្រង់ឆ្លើយថា: "គឺស្តេច" ។

អាក្សសួរទៀតថា "តើហេតុដូចម្តេច?" ។

ព្រះជាទេពិកវ័ន មានព្រះពាដនុង្ការថា: "ការដែលអ្នកបំរើ ឬជាដំរីតដល់នាយចៅហ្វាយ ជាការធម្មតាទេ ព្រោះជាកាណីកិច្ចរបស់ខ្លួន; ប៉ុន្តែស្តេចចាកចោលពាដធានីដោយស្រឡាញ់នាយអាមាត្យរបស់ព្រះអង្គ ស្តេចអង្គនេះ គ្មានទ្រង់គិតដល់ជីវិតរបស់ព្រះអង្គ ដែលព្រះអង្គទុកដូចចំបើងមួយចំរៀក គុណធម៌របស់ព្រះអង្គ មានលើសគុណធម៌របស់បីរបារ" ។

អាវ័ក្សលុះឮព្រះពាដនុង្ការដូច្នោះ ត្រឡប់ទៅប៉ាន់ាវិញ ហើយឮរួនលើកាដូចមុន ។ ឯព្រះមហាក្សត្រិយ៍ ដល់ត្រឡប់ទៅកន្លែងនោះ ស្តេចចាប់អាវ័ក្សដាក់លើស្មាហើយលីយាងទៅ ។



(មានត)

តំណែប្រឡងធម្មវិន័យ

នៅវត្តព្រះព្រហ្មវត្តន៍ ខេត្តសៀមរាប

ព្រះមហាឧត្តមរដ្ឋា កែ-អឿន (រ៉ែយប្បញ្ញោ)

រៀបរៀង

កាលពីថ្ងៃសៅរ៍ ២ កើតខែមិគសិរ ឆ្នាំថោះត្រីស័ក ព.ស. ២៤៨៤ (១៥-១២-៥១) នៅវត្តព្រះព្រហ្មវត្តន៍ សៀមរាប មានពិធីបុណ្យមួយដ៏ធំធ្ងាក គឺបុណ្យប្រឡងធម្មវិន័យចំពោះសិស្ស ១៥៤ ដែលបានសិក្សាក្នុងសាលាធម្មវិន័យ វត្តព្រះព្រហ្មវត្តន៍ ឆ្នាំ ១៩៥១ នេះ ដោយកាលបរិច្ឆេទប្រឡងនេះមកដល់ស្រាប់ ។ ក្នុងពេលនោះ លោកវរសេនីយត្រី ឈួនម្ទុលពេជ្រ នឹងពុទ្ធបរិស័ទចំណុះវត្ត បានប្រារព្ធធ្វើបុណ្យទ្វង់សាលាធម្មវិន័យ ដែលបានជួសជុលជាថ្មី ឲ្យសមរម្យជាសាលាសម្រាប់សិក្សាក្នុងព្រះពុទ្ធសាសនា ដើម្បីឧបត្ថម្ភដល់សិស្សក្នុងពេលប្រឡងនោះផង ។

ថ្ងៃទី ១ — ពិធីបុណ្យនេះបានប្រារព្ធធ្វើតាំងពីល្ងាចថ្ងៃ ១៤ រោច ដោយរៀបចំរោងព្រះបរិត្ត មានព្រះសង្ឃនឹងឥស្សរជន ព្រមទាំងពុទ្ធបរិស័ទនិមន្ត នឹង អញ្ជើញទៅកាន់ពិធីបុណ្យនោះជាច្រើនរយនាក់ ។ កាលព្រះសង្ឃនឹងឥស្សរជនពួកពុទ្ធបរិស័ទនិមន្ត នឹង អញ្ជើញទៅដួបជុំហើយ, ម៉ោង ៨ យប់ និមន្តព្រះសង្ឃចំរោងព្រះបរិត្ត។ ចប់ និមន្តព្រះសម្ពហ៌គណ សូ-ជិត វត្តគ បាត់ដំបង សំដែងធម្មទេសនា ។

ថ្ងៃទី ២ — ព្រឹកឡើងថ្ងៃ ២ រោចខែមិគសិរ (១៤-១២-៥១) មោង ៨, ការដួបជុំសិស្សចាំង ២ ថ្នាក់ គឺថ្នាក់ត្រី ១២៤ រូប ថ្នាក់គោ ២៨ រូប, ការហៅឈ្មោះឲ្យចូលទៅអង្គុយតាមកន្លែងតុនឹងបែកក្រដាសសម្រាប់ប្រឡង, សិស្សអង្គុយរៀបរយតាមកន្លែងរួចហើយ, ពេលនោះពួកក្រុមមេប្រយោគ មានព្រះសុមង្គលសីលាចារ្យមេគណជាអធិបតី ព្រះគ្រូបញ្ញាវិជ្ជាអនុគណជាអធិបតីវង ទឹងលោកចៅហ្វាយស្រុកៗសៀមរាបលោកកូឈួយខែត្រអញ្ជើញទៅជាកិត្តិយសមេប្រយោគផង ។ បើកវិញ្ញាសាទី ១ គឺ សាសនសុភាសិតចាំងថ្នាក់ត្រី ថ្នាអ់ោ ដែលនៅក្នុងស្រោមចំនួនកាលខ្ចី ហើយសរសេរនៅក្តារធំ ឲ្យសិស្សតែងជារបៀបទេសនា ។ មោង ១២ ពុទ្ធបរិស័ទប្រគេនចង្ហាន់ដល់សិស្សប្រឡង ។ មោង ៣ រសៀល គោះគាំងប្រជុំសិស្សដួចមុន អធិបតីបើកវិញ្ញាសាទី ២ គឺ: ប្រស្នាធម្មវិភាគចំនួន ៧ ១ ចាំងថ្នាក់ត្រី ថ្នាក់គោ ឲ្យសិស្សស្រេរសេរឆ្លើយ ។ លុះដល់មោង ៨ យប់ និមន្តព្រះអាចារ្យ ខៀវ-ដុំ វត្តលង្កាកុំពេញសំដែងធម៌ទេសនា។ ចប់ ចាប់លេងល្ខោនជាតិតទៅ ដរាបដល់មោង ១២ កន្លះយប់ ។

ថ្ងៃទី ៣ — ថ្ងៃ ៣ រោចខែមិគសិរ (១៦-១២-៥១) មោង ៣ រសៀល ដួបជុំសិស្សដួចមុន អធិបតីបើកវិញ្ញាសាទី ៣ គឺ ប្រស្នាពុទ្ធប្បវត្តិ ទឹងប្រស្នាអនុពុទ្ធប្បវត្តិចាំងថ្នាក់ត្រីថ្នាក់គោចំនួន ៧ ១ ឲ្យ

សិស្សសរសេរឆ្លើយ, មើ៉ង ៨ យប់ និមន្តព្រះសង្ឃចំរើនព្រះបរិត្តៗ រួចហើយ ព្រះមហាឧត្តមវិជ្ជា កែ-អឿន ថ្លែង សុជ្ឈកថា ដូចមានសេចក្តីតទៅនេះ :-

សូមថ្វាយបង្គំព្រះតេជព្រះគុណ ព្រះសុមង្គលសីលាចារ្យមេគណ !

សូមថ្វាយបង្គំព្រះតេជព្រះគុណ ព្រះគ្រូបញ្ញាវិជ្ជាអនុគណ !

សូមពិតថេរវាចា ព្រះថេរានុត្ថេរាទាំងឡាយ !

សូមចំរើនពរព្រះតេជព្រះគុណវរសេនីយត្រី !

សូមចំរើនពរលោកនាយកក្រុមព្រះនគរបាល - នឹងឥស្សរជនទាំង-ឡាយ ព្រមទាំងលោកអ្នកជាពុទ្ធបរិស័ទទាំងឡាយ ! ខ្ញុំព្រះករុណាអាត្មាភាពជាតំណាងនាមព្រះសង្ឃជាសិស្សានុសិស្សជាដើម សូមអភ័យទោស - ប្រកាសជាឧឡារិកចំពោះព្រះតេជព្រះគុណ, លោក-អ្នកជាពុទ្ធបរិស័ទទាំងឡាយថា ថ្ងៃនេះជាថ្ងៃនក្ខត្តឫក្ស ព្រោះមានពិធីបុណ្យប្រឡងធម្មវិន័យនៃសិស្សដែលបានសិក្សា ក្នុងឆ្នាំ ១៩៥១ នេះ នឹងពិធីបុណ្យក្នុងសាលាធម្មវិន័យនេះ ។ ក្នុងឧកាសបុណ្យនេះ ព្រះតេជព្រះគុណ, លោក-អ្នកជាពុទ្ធបរិស័ទទាំងឡាយបានអញ្ជើញមកជាអធិបតីនឹងអនុមោទនាការកុសល ទុកជាកិត្តិយសដ៏ប្រសើរបំផុត ចំពោះការសិក្សាដែលខំព្យាយាមបំពេញការណីយកិច្ចតាមវត្តុបំណង ដែលប៉ងរួចមកហើយ; វត្តុបំណងនេះ បើពិចារណាតាមអត្តព្យញ្ជនៈ ជានសេចក្តី

វែងឆ្ងាយទូលាយ ពោលគឺទំនុកបំរុងព្រះពុទ្ធសាសនា ឲ្យបានចំរើនរុងរឿង, ការសិក្សាព្រះពុទ្ធសាសនាដែលបានរុងរឿងតាំងនេះក៏ដោយសារតែព្រះតេជព្រះគុណជាឥស្សរជន ទីឯពុទ្ធបរិស័ទតាំងឡាយមានសាមគ្គីធម៌ ព្រមព្រៀងមូលមិត្តគ្នាជាឯកច្ឆន្ទ ជួយឧបត្ថម្ភការគាំទ្រទាំងទ្រព្យទាំងសតិប្បញ្ញាគ្រប់ៗ គ្នា ។ ការជួយឧបត្ថម្ភសាលាធម្មវិន័យនេះ ឈ្មោះថាជួយឧបត្ថម្ភដល់ព្រះពុទ្ធសាសនាឲ្យបានចំរើនរុងរឿងផង ឈ្មោះថាអប់រំព្រះសង្ឃដែលនៅក្នុងមុខ្យភាព ឲ្យឡើងទៅកាន់បណ្ឌិតភាពផង ឈ្មោះថារចនាទាំងខ្លួនឲ្យមានវិជ្ជា ឲ្យមានពន្លឺភ្លឺស្វាង ដើម្បីឲ្យការសានឹងអក្សរជាតិវិវត្តន៍ទៅកាន់វឌ្ឍនធម៌បានផង ។

ម្យ៉ាងទៀតអាចនឹងពោលបានថា លោកជាឥស្សរជនដែលជួយឧបត្ថម្ភការសិក្សាទុកដូចជាវត្តធាតុដែលមានដីជាតិល្អ, សាលាធម្មវិន័យទុកជាដើមរុក្ខា, ព្រះសង្ឃដែលបានសិក្សាទុកដូចជាបុប្ផា ដែលមានក្លិនក្រអូប, ឧបាសក ឧបាសិកា ទុកដូចជាឃ្មុំឬកន្ធន៍ តែងដញ្ជក់នូវលំអងបុប្ផាតាំងនោះ មកធ្វើជាសំបុក គឺចំណេះវិជ្ជាគ្រប់ៗ គ្នា ។ សាលាធម្មវិន័យជាឱរសិរសីនៃព្រះពុទ្ធសាសនា, ហើយជាវិជ្ជាស្ថានមួយដ៏ប្រសើរអាចបណ្តុះពូជព្រះសង្ឃដែលបានសិក្សា ឲ្យចេះដឹងទៅជាបណ្ឌិត អ្នកប្រាជ្ញអាចប្រតិបត្តិធម៌វិន័យ ឲ្យដើរទៅតាមផ្លូវត្រង់ ។

ថ្ងៃនេះទុកជាថ្ងៃជយមង្គល នាំឲ្យសិស្សដែលបានមកប្រឡងនឹក
រលឹកទុកជាអនុស្សាវរីយ៍ក្នុងមនោវិញ្ញាណ ដែលបញ្ជូញនូវសុភនិមិត្ត
អាចទស្សនាទៅហើយនាំឲ្យកើតបីតិប្រាមោជ្ជៈ ប្រកបដោយអច្ឆរិយភាព,
ក្លេចនឹកដល់ការព្រួយលំបាកខ្សឹយហត់អំពីអតីតកាល ថែមទាំងឲ្យសិស្ស
ដែលប្រឡងចូល ធ្វើមនសិការទុកក្នុងចិត្តដោយខ្ចាយដ៏ប្រពៃថានឹង
ព្យាយាមឲ្យពេញកម្ទាំងដើម្បីនឹងសម្រេចឥដ្ឋផលនេះ ។

អាត្មាភាព សូមថ្លែងកតញ្ញូកតវេទីចំពោះព្រះតេជព្រះគុណ, លោក-
អ្នកទាំងឡាយ, ដែលបានអញ្ជើញមកជួយឧបត្ថម្ភដោយសោមនស្សដ៏
ឧត្តម កិច្ចដែលព្រះតេជព្រះគុណលោកអ្នកទាំងឡាយបានធ្វើហើយនេះ
ជាកិច្ចមានសារៈប្រយោជន៍ចំពោះសិស្សដែលបានសិក្សាមកហើយ បុំបុង
នឹងសិក្សាតទៅទៀត ។ ព្រះតេជព្រះគុណលោកអ្នកទាំងឡាយដែល
មានសាមគ្គីធម៌មកជួយឧបត្ថម្ភការកុសលនេះ ឲ្យបានសម្រេចដោយយល់
ថា សាលាធម្មវិន័យជាឃ្លាំងធម៌មួយធំ សម្រាប់ដំកល់ទុកនូវវិជ្ជាខាង
ពុទ្ធសាសនានឹងអក្សរសាស្ត្រខ្មែរ ។

ក្នុងអវសាននេះ សូមឧទ្ទិសជូនកុសលដែលកើតដោយបុណ្យនេះ
ចំពោះព្រះតេជព្រះគុណ, លោកអ្នកជាពុទ្ធមាមកជនទាំងឡាយ ហើយ
សូមគុណានុភាពព្រិះរៃតន៍ ព្រមទាំងវត្ថុសក្តិសិទ្ធិក្នុងសកលលោក
នឹងផលានិសង្សនៃបុណ្យនេះ ប្រសិទ្ធិពរជូនព្រះតេជព្រះគុណ លោក

អ្នកជាពុទ្ធមាមកជនតាំងឡាយ ឲ្យបានប្រកបដោយសេចក្តីសុខសេចក្តីចំរើន សិរីសួស្តីជយមង្គលគ្រប់ដំពូក ទទឹងបានសម្រេចនៃតិពិធសម្បត្តិជាឥដ្ឋមនុញ្ញផលគឺ សម្បត្តិមនុស្ស ១ សម្បត្តិសួគ៌ ១ សម្បត្តិព្រះនិព្វាន ១ កុំបីឃ្លៀងឃ្លាតឡើយ ! ។

លុះចប់សុន្ទរកថា គេនិមន្តព្រះមហាឧត្តមវិជ្ជាកែ-អឿន ទទឹងព្រះអាចារ្យសុខ-សាន វត្តព្រះពេហ្វាតន៍ សំដែងធម៌ទេសនាបុច្ឆា-វិសជ្ជនាទេសនាចប់ លេងល្ខោនជាតិតៅដូចយប់មុន ។

ថ្ងៃទី៤— ថ្ងៃ ៤ រោច ខែដដែល (១៧ ១២-៥១) ម៉ោង ១១ ព្រឹក ពុទ្ធបរិស័ទពាប់ចាត្រតួងសាលាធម្មវិន័យ;

ម៉ោង ៣ រសៀល អធិបតីបើកវិញ្ញាសាទី ៤ គឺ: ប្រស្នាវិន័យតាំងថ្នាក់ត្រីថ្នាក់ទោចំនួន ៧ ១ ឲ្យសិស្សសរសេរធ្វើយ;

ម៉ោង ៨ យប់ និមន្តវិន័យធរអនុគណ ឯក-ញឹម វត្តធម្មិស្សរាម (រលួស) សំដែងធម៌ទេសនា។ ចប់ ចាប់លេងល្ខោនជាតិតៅ ដរាបដល់ម៉ោង ១ ទើបឈប់ ។

ប្រឡងធម្មវិន័យក្នុងពេលនេះ ក្រសួងធម្មការបានចាត់តាំងព្រះសុមង្គលសីលាចារ្យមេគណខិត-ទិម វត្តដំណាក់ សៀមរាប ជាអធិបតី, ព្រះសុមង្គលសីលាចារ្យបានតាំងគណៈកម្មការសមាជិក ៨ រូបទៀត តាំងថ្នាក់ត្រីថ្នាក់ទោ ដើម្បីត្រួតត្រាការប្រឡងតាមបន្ទប់ប្រឡង ។

ថ្នាក់ត្រីមានសមាជិក ៤ រូប គឺ :

ជាសមាជិក
- ១ - ព្រះវិន័យធរអនុគណ ឯក ញឹម
- ២ - ព្រះសមុហ៍គណ សូ - ឯត
- ៣ - ព្រះមហាទត្តមវិជ្ជា កែ - អឿន
- ៤ - ព្រះអាចារ្យ ស៊ុន - សាន


ចំណែកថ្នាក់ទោ មានសមាជិក ៤ រូប គឺ :

- ១ - ព្រះគ្រូបញ្ញាវិជ្ជាអនុគណ អ៊ុក - មោ៉ញ ជាអធិបតីវត
ជាសមាជិក
- ២ - ព្រះមហាបរិយត្តិ មាស - លន
- ៣ - ព្រះអាចារ្យ សុ១ - សាន
- ៤ - ព្រះមហាបរិយត្តិ ព្រំ - យឹម

ព្រះមហាបរិយត្តិ មា៉ន់ - ឡាយ ជាលេខាធិការ ។

កាលបើសិស្សធ្វើវិញ្ញាសានីមួយៗ ចប់ហើយ ក្រុមសមាជិកបានយកវិញ្ញាសានោះ ចែកទៅកុងត្រៃសាមលំបុត្រធំមួយហើយបិទភាកល៏ះប្រថាប់ត្រាពីខាងក្រៅដូនទៅអធិបតី។ ទីឆាត់បញ្ជូនទៅព្រះតេជព្រះគុណព្រះមុនីគោសលមេគណវត្តពោធិ៍វាលខែត្របាត់ដំបង តាមសេចក្តីបង្គាប់អំពីក្រសួងធម្មការ, ព្រះតេជព្រះគុណព្រះមុនីគោសល ទីឆាត់ឲ្យទៅគណកម្មការត្រួតសំណុំរឿងប្រឡងនោះ ។

ក្នុងវេលាបុណ្យប្រឡងធម្មវិន័យប៉ុន្មានថ្ងៃនេះ លោកវរសេនីយ៍ត្រី ឈួនម្ទុលពេជ្រ បានចំណាយហិរញ្ញវត្ថុជាបៀវត្សចំនួន ២០០០រ, ០០ ជួយឧបត្ថម្ភកងពិធីបុណ្យប្រឡង ព្រមទាំងលោកអ្នកពាជការក្នុងខេត្ត ក្រសួងខ្លះបានជួយឧបត្ថម្ភជាមួយផង ព្រមទាំងពុទ្ធបរិស័ទជិតឆ្ងាយបាន ជួយឧបត្ថម្ភកងបុណ្យប្រឡងនេះ ដរាបដល់រួចកិច្ចប្រឡង ។



ជនៈ ខេមរាតិ

សេចក្តីល្អអាក្រក់ឬកិច្ចការអ្វីគ្រប់យ៉ាង មិនមែនទេវបុត្រ ទេវតាព្រះឥន្ទ្រព្រះព្រហ្មណាធ្វើឲ្យយើងទេ មានតែខ្លួនយើង ហ្នឹងហើយ ធ្វើឲ្យខ្លួនយើង ។

វរសេនីយ៍ត្រី ឈួនម្ទុលពេជ្រ